ក្រសួងអប់រំ យុវជន និង កីឡា
សាកលវិទ្យាល័យខេមរៈ
KHEMARAK UNIVERSITY

មហាវិទ្យាល័យ វិទ្យាសាស្ត្រនយោបាយ
Faculty of Political Science

ឯកទេស វិទ្យាសាស្ត្រនយោបាយ
Specialization: Political Science

## និក្ខេបបទថ្នាក់បណ្ឌិត
## DISSERTATION

# សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា
# People's rights and Freedom in the context of democracy in Cambodia

បេក្ខជនបណ្ឌិត : ស៊ុយ សែនសីហៈ

សាស្ត្រាចារ្យណែនាំ : បណ្ឌិត ឈុន ណារ៉េត
បណ្ឌិត សយ រាសី

ភ្នំពេញ ២០១១

និក្ខេបបទបណ្ឌិត
ស៊ុយ សែនសីហៈ
សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា
People's rights and Freedom in the context of democracy in Cambodia
ឆ្នាំ ២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិសាសនាព្រះមហាក្សត្រ

សាកលវិទ្យាល័យខេមរៈ
KHAMARAK UNIVERSITY

## តារាងវាយតម្លៃនិក្ខេបបទបញ្ចប់

### ថ្នាក់បណ្ឌិត ជំនាន់ទី២ ឯកទេស : វិទ្យាសាស្ត្រនយោបាយ

និក្ខេបបទរបស់បេក្ខជនបណ្ឌិត : ស៊ុយ សែនសីហៈ ភេទ ប្រុស

ប្រធានបទ : សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា

សាស្ត្រាចារ្យណែនាំទី១ : បណ្ឌិត ឈុន ណារ៉េត

សាស្ត្រាចារ្យណែនាំទី២ : បណ្ឌិត សយ រាសី

| ល.រ | ឈ្មោះគណៈកម្មការ | តួនាទី | យោបល់សម្រេច | ហត្ថលេខា |
|---|---|---|---|---|
| ១ | បណ្ឌិត សុខ ទូច | ប្រធាន | | |
| ២ | បណ្ឌិត ទេព ឈុនណារិទ្ធ | សាស្ត្រាចារ្យវាយតម្លៃទី១ | | |
| ៣ | បណ្ឌិត ធីង សុខុល | សាស្ត្រាចារ្យវាយតម្លៃទី២ | | |
| ៤ | បណ្ឌិត ប្រាង់ស័រ អ៊ីម | សាស្ត្រាចារ្យវាយតម្លៃទី៣ | | |
| ៥ | បណ្ឌិត ឈុន ណារ៉េត | សមាជិក | | |
| ៦ | បណ្ឌិត សយ រាសី | សមាជិក | | |

បានឃើញ និង ឯកភាព
**ប្រធានគណៈកម្មការវាយតម្លៃ**

**បណ្ឌិត.សុខ ទូច**

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១១
**លេខាកត់ត្រា**

# អំណះអំណាង

ខ្ញុំបាទ **ស៊ុយ សែនសីហៈ** សូមធានាអះអាងនិងទទួលខុសត្រូវថា ប្រធានបទស្តីពី **សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា** និងខ្លឹមសារនៃនិក្ខេបបទនេះ គឺជាស្នាដៃស្រាវជ្រាវ ផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ដោយគ្មានពាក់ព័ន្ធជាមួយនឹងនិក្ខេបបទអ្នកផ្សេងឡើយ។ ឯរបកគំហើញនៃការស្រាវជ្រាវដែលបានលើកឡើងនៅក្នុងនិក្ខេបបទនេះ គឺថ្មីហើយពុំទាន់មានអ្នកណាម្នាក់យកទៅប្រើប្រាស់នៅក្នុងនិក្ខេបបទរបស់គេឡើយ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១១

ហត្ថលេខា

**ស៊ុយ សែនសីហៈ**

# អារម្ភកថា

កិច្ចដំណើរការសន្តិភាពនិងការបង្រួបបង្រួមជាតិខ្មែរ ដែលបានរៀបចំនិងប្រព្រឹត្តទៅតាមកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានផ្លាស់ប្តូរមូលដ្ឋានស្ថានភាពទូទៅនៃប្រទេសកម្ពុជា។ ដោយសារមានការយកចិត្តទុកដាក់ និងជ្រោមជ្រែងពីសហគមន៍អន្តរជាតិផងនោះ ការបោះឆ្នោតដោយសេរី និងតាមលក្ខណៈប្រជាធិបតេយ្យ ដែលបានប្រព្រឹត្តទៅនាខែឧសភា ឆ្នាំ១៩៩៣ បាននាំមកនូវការបង្កើតរដ្ឋធម្មនុញ្ញ រដ្ឋសភា និងព្រះរាជាណាចក្រកម្ពុជា។

សង្គមកម្ពុជាបច្ចុប្បន្ន ជាសង្គមមួយកំពុងអភិវឌ្ឍក្នុងបរិយាកាសប្រជាធិបតេយ្យនីយកម្ម ទើបមានការស្រាវជ្រាវប្រធានបទ "សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា"ត្រូវបានសិក្សា ដើម្បីចូលរួមធ្វើឲ្យកាន់តែប្រសើរឡើង នូវសកលភាពនៃតម្លៃរួមស្តីអំពីសិទ្ធិមនុស្ស ជាពិសេសបាន ធ្វើឲ្យប្រជា-ពលរដ្ឋកាន់តែមានតម្លៃដ៏ឧត្តុង្គឧត្តម គឺសិទ្ធិសេរីភាពខាងនយោបាយ និងអំណាចប្រជាពលរដ្ឋតាមគោល-ការណ៍ប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។

ម្យ៉ាងទៀតបណ្តាប្រទេសដែលប្រកាន់យករបបនយោបាយដឹកនាំបែបប្រជាធិបតេយ្យ គឺជាសង្គមមួយដែលមានលក្ខណៈពិសេសត្រង់ចំណុចមួយ គឺប្រជាធិបតេយ្យបានផ្តល់ឱកាសឲ្យប្រជារាស្ត្រសម្តែងមតិទិទៀនរិះគន់ស្ថាបនា ចំពោះបញ្ហាសំខាន់ៗនានា ដែលបានកើតឡើងដោយផ្តល់ផលមិន ល្អទៅក្នុងសង្គម។ ការសម្តែងមតិក្នុងសង្គមប្រជាធិបតេយ្យមានន័យថា មនុស្សមានសេរីភាពនិយាយស្តី ជជែក ដេញដោល រកហេតុផលដើមចម ការប្រមូលផ្តុំជួបជុំ ធ្វើការបោះឆ្នោតគាំទ្រ ឬជំទាស់ ដើម្បីធានាបាននូវ យុត្តិធម៌សម្រាប់ជនគ្រប់ៗរូប តម្លាភាព ការអភិវឌ្ឍន៍ និងជាពិសេសរកឃើញបុគ្គលមានគំនិតជឿនលឿន មានទេពកោសល្យ មានភាពប៉ិនប្រសប់ មានបញ្ញាញាណ...ក្នុងការដឹកនាំប្រទេសជាតិ។ ហេតុដូច្នេះហើយ ទើបការសម្តែងមតិក្នុងរបបប្រជាធិបតេយ្យត្រូវបានគេចាត់ទុកថា ជាសរសៃឈាមនៃលទ្ធិប្រជាធិបតេយ្យ។

ចំណែករដ្ឋាភិបាលប្រជាធិបតេយ្យ ដែលឈរលើការព្រមព្រៀង ពេញចិត្ត ឯកភាពពីជនដែលខ្លួនគ្រប់គ្រង អាចនិយាយ និងធ្វើសកម្មភាពពោរពេញដោយសេចក្តីទុកចិត្តលើខ្លួនឯង។

ដោយយល់ឃើញថា ព្រះរាជាណាចក្រកម្ពុជា បានឯកភាពយករបបប្រជាធិបតេយ្យសេរីពហុបក្ស សម្រាប់គ្រប់គ្រងនិងដឹកនាំប្រទេស ដែលទើបនឹងធ្វើដំណើរពីឆ្នាំ១៩៩៣ដល់បច្ចុប្បន្ន(២០១១) ប្រាកដជាពុំទាន់មានសមត្ថភាពពង្រឹងពង្រីកឲ្យបាននូវតម្លៃរួមទៅតាមលក្ខខណ្ឌប្រជាធិបតេយ្យ ដូចប្រទេសប្រជា-ធិបតេយ្យជឿនលឿនយូរយានានាលើសកលលោកជាក់ជាមិនខាន ទើបលើកទឹកចិត្តឲ្យអ្នកស្រាវជ្រាវលើកប្រធានបទ **"សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា"** ជាកម្មវត្ថុស្រាវជ្រាវសំដៅ រកឲ្យឃើញ នូវចំណុចគន្លឹះជាសក្តានុពល ដើម្បីពន្លឿនក្នុងការពង្រីកការអនុវត្តន៍សិទ្ធិមនុស្ស សិទ្ធិសេរីភាពខាងនយោបាយក្នុងទិសដៅសុខសន្តិភាព ស្ថេរភាពនយោបាយនិងការអភិវឌ្ឍន៍។ ជាពិសេសជំរុញភាពខ្លាំង

នៃភាពជាម្ចាស់អំណាចរបស់ប្រជាពលរដ្ឋក្នុងបរិយាកាសប្រជាធិបតេយ្យ។ ព្រោះថា ប្រទេសប្រជាធិបតេយ្យជឿនលឿន បានពឹងផ្អែកជាអាទិភាពលើវត្តមានមិនអាចខ្វះបានពីការចូលរួមរបស់ប្រជាពលរដ្ឋ ជាអ្នកកំណត់ជោគវាសនាប្រទេសជាតិ ប្រកបដោយការយល់ដឹង។ ប្រជាពលរដ្ឋបែប
ណាជ្រើសរើសបានមេដឹកនាំបែបនោះ។

ដំណោះស្រាយចំពោះបញ្ហាសិទ្ធិសេរីភាពប្រជាពលរដ្ឋ ជាពិសេសសិទ្ធិសេរីភាពខាងនយោបាយ ពិតជាមានទំនាក់ទំនងមិនអាចខ្វះបានឡើយ នូវការពាក់ព័ន្ធគ្នានៃប្រជាពលរដ្ឋខ្លួនឯង ស្ថាប័នរដ្ឋសភា ស្ថាប័នរដ្ឋាភិបាល ស្ថាប័នតុលាការ សេរីភាពរបបសារព័ត៌មាន។ ដើម្បីឲ្យកម្ពុជាក្លាយជាជើងឯកខាងការដាំបណ្តុះប្រជាធិបតេយ្យ ចាំបាច់ណាស់ត្រូវមានគោលការណ៍តុល្យភាពអំណាចដឹកនាំ នៃស្ថាប័នកំពូលទាំងបីរបស់ជាតិ។ រដ្ឋាភិបាល គួរដកចេញនូវរបាំងនៃការបង្ក្រាប ការរើសអើងនិន្នាការនយោបាយ ការលាបពណ៌នយោបាយនិងការរារាំងគ្រប់រូបភាពចំពោះប្រជាពលរដ្ឋ ហើយប្រមូលកម្លាំងជាតិគ្រប់ភាគីចូលរួមកសាងប្រទេស។

ចំណោទចម្បងនៅត្រង់ថា តើអ្នកដឹកនាំមានឆន្ទៈនយោបាយបើកទូលាយពិតប្រាកដឬដូចម្តេច? ហើយ ប្រជាពលរដ្ឋព្រមព្រៀងបន្តបេសកកម្មពង្រឹងពង្រីកសិទ្ធិសេរីភាព សិទ្ធិមនុស្ស យុត្តិធម៌សង្គម ដើម្បីបំបែងខ្លួនឲ្យទៅជា ឯកទេសកម្មអំណាចដោយខ្លួនឯងនៅក្នុងបរិបទប្រជាធិបតេយ្យដែរឬទេ។ សក្តានុពលទាំងនេះអាស្រ័យទៅលើ កម្រិត នៃការយកចិត្តទុកដាក់ចាប់អារម្មណ៍និងទំហំពលិកម្មរបស់ប្រជាពលរដ្ឋខ្លួនឯង។ នៅក្នុងរបបប្រជាធិបតេយ្យ ស្ថាប័នទទួលដឹកនាំអំណាចនានា មិនមែនសម្រេចចិត្តធ្វើអ្វីៗតាមទំនើងចិត្តរបស់បក្សពួកខ្លួននោះទេ ឯប្រជាពលរដ្ឋក៏មិនមែនចេះតែប្រើសិទ្ធិសេរីភាពតាមទំនើងចិត្តរបស់ខ្លួននោះដែរ។ យើងយល់ឃើញថា គ្រប់កោសិកាទាំងអស់របស់សង្គម គប្បី គៀកករគ្នារកឲ្យឃើញនូវចំណុចប្រសព្វដើម្បីឧត្តមភាពខាច់ខាតរបស់ប្រទេសជាតិ៕

# ឧទ្ទិសកថា

( Dedication )

*ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះ :*

- លោកអ្នកដ៏មានគុណក្នុងប្រទេស និងនៅបរទេស ដែលបានចិញ្ចឹមបីបាច់ថែរក្សា អប់រំ ផ្តល់តំបូន្មានឲ្យកូនដើរតាមគន្លងដ៏ល្អ គោរពប្រតិបត្តិតាមមេរៀនរបស់ព្រះសម្មាសម្ពុទ្ធ និងគោរពច្បាប់នានារបស់អាណាចក្រ ជាពិសេសបណ្តុះស្មារតីឲ្យកូនមានជំនឿលើខ្លួន មានការប្តេជ្ញាចិត្តខ្ពស់ ក្លាហាន តស៊ូ ព្យាយាម ខន្តី និងចេះទទួលខុសត្រូវរាល់ការងាររបស់ខ្លួន ព្រមទាំងយកចំណេះដឹងទាំងប៉ុន្មាន ដើម្បីផលប្រយោជន៍ ជាតិ សាសនា ព្រះមហាក្សត្រ និងក្រុមគ្រួសារ។

- ព្រះវិញ្ញាណក្ខ័ន្ធបញ្ញាវ័ន្ត បុព្វព្រះមហាក្សត្រ សម្តេចព្រះសង្ឃរាជខ្មែរគ្រប់ជំនាន់ និងវីរៈជន អ្នកស្នេហាជាតិទាំងអស់ ព្រមទាំងប្រជាពលរដ្ឋខ្មែរ ដែលបានបូជាជីវិតរបស់ខ្លួនក្នុងបុព្វហេតុ ការពារប្រពៃណី វប្បធម៌ អរិយធម៌ ព្រលឹងជាតិខ្មែរ និងមាតុភូមិអង្គរដ៏បវរនៃយើង ឲ្យបានគង់វង្សចាប់តាំងពីកកើតទឹកដីរហូតមកទល់សព្វថ្ងៃ។

- ប្រជាជនខ្មែរគ្រប់រូបនៅគ្រប់ទីកន្លែងនៃពិភពលោក ជាពិសេសប្រជាជនខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ ដែលជាម្ចាស់ប្រទេស សូមទទួលបាននូវស្មារតីរឹងមាំ ក្លាហានមុះមុត ដើម្បីការពារសុខសន្តិភាព ស្ថេរភាព និងការពារប្រទេសជាតិយើងឲ្យគង់វង្ស ដោយនៅតែរក្សាបាន ជាប្រទេសឯករាជ្យ មានអធិបតេយ្យ បូរណភាពទឹកដី ដូចដែលយើងបានដឹងតទៅអនាគតជាអមតៈ។

- ចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បណ្ឌិត គ្រប់កម្រិតសិក្សាកន្លងមក ដែលបានបង្ហាត់បង្រៀន អប់រំ ណែនាំដល់ខ្ញុំបាទ សូមទទួលបានសេចក្តីសុខក្សេមក្សាន្ត និងជោគជ័យគ្រប់ភារកិច្ច និងសូម ឧទ្ទិសផលនៃស្នាដៃនេះផ្សាយដល់ជីដូនជីតា និងញាតិការទាំងប្រាំពីរសន្តាន រួមទាំងបុព្វការីជនជាតិខ្មែរទាំងអស់ដែលបានចែកឋានទៅ សូមទៅដល់សុគតិភពគ្រប់ៗគ្នា។

# សេចក្តីថ្លែងអំណរគុណ

## ( Acknowledgements )

ខ្ញុំបាទ **ស៊ុយ សែនសីហៈ** ជានិស្សិតថ្នាក់បណ្ឌិត ជំនាន់ទី២ វគ្គ២ ជំនាញ វិទ្យាសាស្ត្រនយោបាយ នៃសាកលវិទ្យាល័យខេមរៈ

ខ្ញុំសូមលើកអញ្ជលី លំឱនកាយគោរពដល់លោកអ្នកដ៏មានគុណគឺ លោកឪពុក **ស៊ុយ ហួត** និង អ្នកម្តាយ **ឡៀប យ៉េខ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាថ្នាក់ថ្នម ផ្តល់នូវសេចក្តីស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ អប់រំ ទូន្មាន និងទំនុកបំរុងគ្រប់បែបយ៉ាងឲ្យកូនបាន សិក្សាចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បណ្ឌិតប្រកបដោយជោគជ័យ។

ខ្ញុំសូមលើកអញ្ជលី លំឱនកាយគោរពដល់លោកអ្នកដ៏មានគុណគឺ អ្នកម្តាយ **ឈិតដាវ គុណាទ្រី** អ្នកម្តាយ **ឈិតដាវ សុខានី** អ្នកម្តាយ **ឈិតដាវ ចិន្ត្រា** ព្រមទាំងអ្នកម្តាយមីង **ឈិតដាវ សារីណា ឈិតដាវ ចាន់សិដា ឈិតដាវ សុជាតា** និង **ឈិតដាវ សៅវ៉ាណ្ណី** ដែលបានទំនុកបំរុងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាតាំងពីថ្នាក់បរិញ្ញាបត្រ រហូតដលថ្នាក់បណ្ឌិត ដោយទទួលបានជោគជ័យ។

និងសូមសម្តែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ :

**ឯកឧត្តមបណ្ឌិត សុខ ទូច** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យខេមរៈ ដែលបានអនុញ្ញាតឲ្យខ្ញុំបានចូលសិក្សានៅសាកលវិទ្យាល័យនេះ ព្រមទាំងបានផ្តល់មតិណែនាំនិងអនុសាសន៍ល្អៗ នៅក្នុងការសរសេរនិក្ខេបបទរបស់ខ្ញុំបាទ។

លោកបណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យណែនាំទី១ និងលោកបណ្ឌិត **សយ រាសី** ជាសាស្ត្រាចារ្យណែនាំទី២ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងដ៏មមាញឹកក្នុងការបង្រៀន ផ្តល់ការណែនាំ និងផ្តល់ឯកសារ ដើម្បីរៀបចំសរសេរនិក្ខេបបទនេះឡើង។

**លោកសាស្ត្រាចារ្យ បណ្ឌិត** ដែលជាសមាសភាពក្នុងគណៈកម្មការវាយតម្លៃលើការការពារនិក្ខេបទបញ្ចប់ថ្នាក់បណ្ឌិត សម្រាប់បេក្ខជនបណ្ឌិត **ស៊ុយ សែនសីហៈ** ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ដោយបានផ្តល់អនុសាសន៍ដ៏ល្អៗក្នុងការកែលំអរនិក្ខេបបទរបស់ខ្ញុំបាទ។

ថ្នាក់ដឹកនាំ បុគ្គលិកសិក្សា នៅសាកលវិទ្យាល័យខេមរៈទាំងអស់ ដែលបានបង្ករលក្ខណៈងាយស្រួលដល់ការសិក្សារបស់ខ្ញុំបាទ។

ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញ ព្រមទាំងទស្សនវិទូធំៗក្នុងលោក ដែលខ្ញុំបានសិក្សាពីស្នាដៃរបស់លោកក្នុងការបំពេញនិក្ខេបបទនេះប្រកបដោយ លក្ខណៈវិទ្យាសាស្ត្រពិតៗ។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបានអំពីខ្ញុំបាទ ចំពោះឧបការគុណដ៏ធំធេងចំពោះខ្ញុំបាទ។ សូមអ្នកទាំងអស់គ្នា ទទួលបាននូវបរមសុខោទ័យ សេរីសោភ័កសម្បត្តិគ្រប់កាល។ សូមឲ្យលទ្ធផលនៃការសិក្សានេះបានជាគុណប្រយោជន៍ដ៏ឧត្តុងឧត្តម ដល់បរិបទប្រជាធិបតេយ្យនៅកម្ពុជា សំដៅរួមចំណែកលើកកម្ពស់សិទ្ធិសេរីភាពប្រជាពលរដ្ឋ សន្តិភាពស្ថេរភាពនយោបាយ និងវឌ្ឍនភាពកុំបីឃ្លៀងឃ្លាតឡើយ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១១

ហត្ថលេខា

**ស៊ុយ សែនសីហៈ**

# បញ្ជីកាត់

( Acronyms )

គ.ជ.ប : គណៈកម្មការជាតិរៀបចំការបោះឆ្នោត

គខ/កប : គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត

គឃ/សប : គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត

ម.ស.ម.ក : មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

CCHR : Cambodia Center for Human Rights.

CDR : Cambodia′s Leading Independence Development Policy Research Intitute.

CDP : Cambodia Defenders Project.

CPP : Cambodia People party.

CSD : Center of Social Development.

ICCPR : International Convent on Civil and Political Rights.

NICFEC : Neutral and Impartial Committee for Free and Far Elections.

NGO : Non-Government Organization.

PEFOJ : People Forum Cambodia and Japan.

UNDP : United Nations Development Program.

UNFPA : United Nations Population Fund.

UNTAC : United Nations Transition Authority in Cambodia.

VOA : Voice of America.

# ខ្លឹមសារសង្ខេប
# សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា

ការស្រាវជ្រាវនេះ មានគោលបំណងរកឲ្យឃើញបណ្តាកត្តាដែលនាំទៅដល់ធានាការគោរពសិទ្ធិ សេរីភាព ប្រជាពលរដ្ឋ សេចក្តីថ្លៃថ្នូរ ជាពិសេសសិទ្ធិសេរីភាពខាងនយោបាយនៅកម្ពុជា ឲ្យធ្វើដំណើរទៅកាន់តម្លៃសកលភាពនៃប្រជាធិបតេយ្យភាវូនីយកម្ម ដោយយកជាទិសដៅអនុវត្តកែលំអ និងជាលក្ខខណ្ឌត្រូវជៀងវាង នូវប្រព័ន្ធដឹកនាំរដ្ឋាភិបាល ប្រមូលផ្តុំអំណាចក្នុងប្រព័ន្ធនយោបាយប្រជាធិបតេយ្យ ដែលអាចក្លាយទៅជាពុម្ពគំរូដល់រដ្ឋាភិបាលអាណត្តិក្រោយៗទៀត។ ម្យ៉ាងទៀត វប្បធម៌អំណាចផ្តាច់ការ ចក្រពត្តិបែបនេះ វាផ្ទុយទាំងស្រុងទៅនឹងទ្រឹស្តីអ្នកប្រាជ្ញល្បីៗ ដែលបាន លើកឡើងក្នុងនិក្ខេបបទនេះ ហើយលទ្ធិប្រជាធិបតេយ្យក្នុងយុគសម័យដ៏ទំនើបនេះ មិនអនុញ្ញាតឲ្យមានការប្រមូល ផ្តុំអំណាចក្នុងស្ថាប័នដឹកនាំណាមួយ ឬមិនអនុញ្ញាតឲ្យប្រមូលផ្តុំអំណាចដាក់ក្នុងបាតដៃបុគ្គលណាមួយដែរ។ ក្នុងស្នាដៃនេះបានសិក្សាស៊ីជម្រៅលើ ឯកសារពាក់ព័ន្ធនានា និងអង្កេតលើតថភាពបច្ចុប្បន្ន ដើម្បីជាមូលដ្ឋានក្នុងការធ្វើសេចក្តីសន្និដ្ឋាន និង អនុសាសន៍។ លទ្ធផលបានរកឃើញថា ដើម្បីលើកស្ទួយសិទ្ធិ សេរីភាព សិទ្ធិមនុស្ស សិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រជាធិបតេយ្យនៅកម្ពុជា ចាំបាច់ជាទីបំផុតនោះ ត្រូវគោរពគោលការណ៍តុល្យភាពអំណាច និង អំណាចឯករាជ្យ ពិតជាក់ស្តែងរបស់ស្ថាប័នកំពូលទាំងបីរបស់ជាតិ(ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការ) ដែលចាំបាច់ត្រូវប្រើយន្តការអនុម័តច្បាប់អព្យាក្រិត្យ ចំពោះមន្ត្រី រាជការស៊ីវិល ចំពោះមេបញ្ជាការកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងអនុម័តច្បាប់អព្យាក្រិត្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមព្រះរាជអាជ្ញានិងចៅក្រម ដែលតំណែងទាំងនេះមិនត្រូវជ្រើសរើសចេញពីគណបក្សនយោបាយឡើយ។ ហើយត្រូវបញ្ញត្តិជាច្បាប់ហាមឃាត់មិនឲ្យមន្ត្រីទាំងនេះជាប់ពាក់ព័ន្ធនឹងគណ- បក្សនយោបាយជាដាច់ខាត ទើបអាចរក្សានូវលំនឹង នយោបាយរបស់ស្ថាប័នកំពូលរបស់ជាតិបាន។ លក្ខខណ្ឌ បែបនេះ អាចបើកច្រកឲ្យប្រជាពលរដ្ឋប្រើឧត្តមភាពរស់រវើក នៃសិទ្ធិសេរីភាពរបស់ខ្លួនបានទូលំទូលាយក្នុង បេសកកម្មអភិវឌ្ឍន៍ជាតិមាតុភូមិ ជួយផ្តត់ផ្គង់សុខសន្តិភាព ស្ថេរភាព សុភមង្គល ចូលរួមទទួលខុសត្រូវក្នុងការ ធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗនានាដែលជាអាយុជីវិតរបស់ជាតិ។

វប្បធម៌នយោបាយប្រជាធិបតេយ្យនៅប្រទេសជឿនលឿន គឺមានទម្លាប់ប្រកាន់យកយន្តការ ពិភាក្សា (Debate) ការចរចារ និយមអហិង្សា ប្រកួតប្រជែងផ្នែកចក្ខុវិស័យ ទទួលការរិះគន់ដោយអត់ធ្មត់ដែលជាកត្តាជោគជ័យនៃយន្តការដឹកនាំរដ្ឋដូចបានបង្ហាញនៅក្នុងនិក្ខេបបទនេះ។

# Abstract

**People's rights and Freedom in the context of democracy in Cambodia**

The purpose of this research is to find out the factors that lead to securing respect for people's rights, freedom, dignity, especially political freedom in Cambodia, to move towards the global value of democratization as the goal for making improvement and providing conditions for avoiding a centralized government leadership system in the democratic political system, which can become a bad mould or model for subsequent elected governments. Moreover, the culture of imperialist dictatorships is completely contrary to the theories of well-known scholars mentioned in this thesis. Democracy in this modern era neither authorizes centralization of power in any leading institution nor centralization of power in the hands of any individual.

This work has engaged in a comprehensive study of various relevant documents and observation of the present facts as a foundation for its conclusion and recommendations. The findings reveal that to promote rights, freedom, human rights and the political rights of people in democratic localities in Cambodia, it is imperative to respect the principle of true and genuine balance of power and the independent power of the three national supreme bodies (Legislative Body, Executive Body and Judicial Body), which must apply the mechanisms for passing neutral laws for civil servants, commanders of armed forces of all types and for enacting neutral laws for the Supreme Council of Magistracy, prosecutors and judges. These positions shall not be selected from any political party.

Furthermore, there shall be various legal regulations to strictly prohibit these officials from being involved with any political party so the balance of power of the national supreme bodies can be maintained. Upholding this principle can open a gate for people to widely exercise the lively superiority of their rights and freedom with the aim of developing the nation, helping deliver peace, stability, happiness and contributing in taking responsibility for making major decisions, which is a matter of life and death for the country.

The culture of democratic politics in advanced countries is the practice of adhering to mechanisms for debate, negotiation and nonviolence, challenging of views, patient acceptance of criticism, which are the factors leading to successful mechanisms for leading a state, as presented in this thesis.

# មាតិកា

**ចំណងជើង** **ទំព័រ**

**អំណះអំណាង** ........ i
**អារម្ភកថា** ........ ii
**ឧទ្ទិសកថា** ........ iii
**សេចក្ដីថ្លែងអំណរគុណ** ........ iv
**មាតិកា** ........ v
**បញ្ជីតារាង** ........ vi
**ខ្លឹមសារសង្ខេប** ........ viii
Abstract ........ ix

## ជំពូកទី ១
## សេចក្ដីផ្ដើម

១.១ បុព្វហេតុនៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៧
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ៧
១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៨
១.៥ វិធីសាស្ត្រស្រាវជ្រាវ ........ ៨
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៩
១.៧ របកគំហើញនៃការស្រាវជ្រាវ ........ ១០
១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ១៣

## ជំពូកទី២
## ទស្សនៈទូទៅស្ដីអំពីសិទ្ធិពលរដ្ឋ

២.១ និយមន័យ នៃសិទ្ធិពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ ........ ១៤
២.២ ទ្រឹស្ដីអំពីសិទ្ធិពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ ........ ២០
២.៣ ទស្សនវិទ្យានៃសិទ្ធិពលរដ្ឋ ........ ៥០

២.៣.១ លក្ខណៈទូទៅស្ដីអំពីសិទ្ធិសេរីភាពពលរដ្ឋ ......៥១
២.៣.២ សិទ្ធិសេរីភាពប្រជាពលរដ្ឋ ......៥៤
២.៣.៣ កាតព្វកិច្ចរដ្ឋចំពោះសិទ្ធិសេរីភាពប្រជាពលរដ្ឋ ......៥៥
២.៤ ដើមកំណើតសិទ្ធិពលរដ្ឋ និងការបែងចែកសិទ្ធិពលរដ្ឋក្នុងសង្គមខ្មែរ ......៥៥
២.៤.១ ដើមកំណើតសិទ្ធិពលរដ្ឋ ......៥៥
២.៤.២ ការបែងចែកសិទ្ធិពលរដ្ឋក្នុងសង្គមខ្មែ ......៥៦
២.៤.២.១ សិទ្ធិសង្គម ......៥៦
២.៤.២.១.១ សិទ្ធិសេរីភាពក្នុងពិធីបុណ្យទាន ......៥៦
២.៤.២.១.២ សិទ្ធិសេរីភាពក្នុងជំនឿសាសនា ......៥៧
២.៤.២.២ សិទ្ធិនយោបាយ ......៥៨
២.៤.២.២.១ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ......៥៨
២.៤.២.២.២ សិទ្ធិសេរីភាពក្នុងរបបគ្រប់គ្រងសង្គម ......៥៩
២.៤.២.២.៣ សិទ្ធិសេរីភាពក្នុងការប្រជុំ និងបង្កើតសមាគម ......៦១
២.៤.២.២.៤ សិទ្ធិសេរីភាពទទួលបានយុត្តិធម៌ ......៦៣
២.៤.២.២.៥ សិទ្ធិសេរីភាពខាងប្រជាធិបតេយ្យ ......៦៤

## ជំពូកទី៣
## ស្ថានភាពទូទៅនៃសិទ្ធិពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា

៣.១ សិទ្ធិសេរីភាពខាងសង្គម ......៧០
៣.១.១ សិទ្ធិដើម្បីរស់រានមានជីវិត ......៧០
៣.១.២ សិទ្ធិមានសេរីភាពស្មើគ្នាចំពោះមុខច្បាប់ ......៧៨
៣.១.៣ សិទ្ធិសេរីភាពរួចផុតពីការរើសអើង ......៨៧
៣.២ សិទ្ធិសេរីភាពខាងនយោបាយ ......៩១
៣.២.១ សេរីភាពនៃការបញ្ចេញមតិ ......៩១
៣.២.២ សេរីភាពក្នុងការចូលរួមប្រជុំមហាជន ......១០០
៣.២.៣ សិទ្ធិសេរីភាពស្ដីពីសារព័ត៌មាន ......១០៥
៣.២.៤ សិទ្ធិសេរីភាពទទួលព័ត៌មានរបស់សាធារណៈជន ......១១៤
៣.២.៥ សិទ្ធិបោះឆ្នោតជាសកលដោយ សេរី យុត្តិធម៌ និងទៀងទាត់ ......១២០
៣.៣ ការប្រឈមចំពោះសិទ្ធិសេរីភាពក្នុងការបោះឆ្នោតនៅកម្ពុជា ......១៣១

៣.៣.១ ការប្រឈមក្នុងឆ្នាំ២០០២ ..................................................................................................................១៣១
៣.៣.២ ការប្រឈមក្រោយការបោះឆ្នោតសកលក្នុងឆ្នាំ២០០៣ ..........................................................................១៣៣
៣.៣.៣ ការប្រឈមនៅក្នុងឆ្នាំ២០០៨ .........................................................................................................១៣៨
៤.១ ផលវិបាកនៃការអនុវត្តន៍សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ..................................................................................១៥១
៤.១.១ ការលំអៀងរបស់អាជ្ញាធរ ..............................................................................................................១៥១
៤.១.២ ចំណេះដឹងរបស់ម្ចាស់អំណាចនៅមានកម្រិត .......................................................................................១៥៣
៤.១.៣ ភាពក្រីក្រ ..................................................................................................................................១៥៧
៤.១.៤ ការភ័យខ្លាច និងការបំភិតបំភ័យ ......................................................................................................១៥៨
៤.១.៥ អំណាចមជ្ឈការ ឬប្រមូលផ្តុំ .........................................................................................................១៦១
៤.២ វិភាគលើការប្រើសិទ្ធិពលរដ្ឋតាមរយៈស្ថាប័នដឹកនាំ ........................................................................................១៦៦
៤.២.១ ករណីស្ថាប័នរដ្ឋសភា .....................................................................................................................១៦៧
៤.២.២ ករណីស្ថាប័នប្រព័ន្ធតុលាការ និងច្បាប់ ...........................................................................................១៨០
៤.២.៣ ករណីស្ថាប័នរាជរដ្ឋាភិបាល ..........................................................................................................១៩៣
៤.២.៤ ឥរិយាបទប្រជាពលរដ្ឋ អំពីសិទ្ធិសេរីភាពក្នុងនយោបាយ ....................................................................១៩៧
៤.៣ យន្តការពង្រឹងសិទ្ធិសេរីភាពប្រជាពលរដ្ឋ ......................................................................................................២០១
៤.៣.១ ការអប់រំ និងជម្រុញអង្គការសង្គមស៊ីវិលចូលរួមពង្រឹងសិទ្ធិសេរីភាព ...................................................២០១
៤.៣.២ តួនាទីរបស់គណបក្សនយោបាយក្នុងបរិបទប្រជាធិបតេយ្យ ...................................................................២០៦
៤.៣.៣ ការរួបរួមគ្នាជាក្រុម សមាគម ឬសហគមន៍ ......................................................................................២០៨
៤.៣.៤ បង្កើតកម្មវិធីវគ្គបណ្តុះបណ្តាលអប់រំស្តីពី ពលរដ្ឋវិទ្យា លទ្ធិប្រជាធិបតេយ្យ ច្បាប់
និងសិទ្ធិមនុស្ស ...................................................................................................................................២០៩

## ជំពូកទី៥
## សន្និដ្ឋាន និងអនុសាសន៍

៥.១ សន្និដ្ឋាន ...........................................................................................................................................២១២
៥.២ អនុសាសន៍ ........................................................................................................................................២១៦

**គន្ថនិទ្ទេស**

# ជំពូកទី១

# សេចក្ដីផ្ដើម

# ជំពូកទី ១
# សេចក្តីផ្តើម

## ១.១. បុព្វហេតុនៃការស្រាវជ្រាវ

អ្នកប្រាជ្ញផ្នែកទស្សនវិទូជាច្រើនបានលើកឡើងថា មនុស្សគ្រប់រូបកើតមកលើលោកតែងតែមានសិទ្ធិស្មើៗគ្នា។ ធម្មជាតិបានផ្តល់ឲ្យគេនូវសិទ្ធិទាំងឡាយ ដែលគ្មាននរណានឹងអាចរំលោភបំពានបាន។ សិទ្ធិទាំងនោះរួមមាន សិទ្ធិរស់នៅ សិទ្ធិសេរីភាព សិទ្ធិស្វែងរកសុភមង្គល និងសិទ្ធិផ្សេងៗទៀត។

តាមប្រវត្តិសាស្ត្រជាយូរលង់មកហើយជាពិសេស គឺក្នុងសម័យផ្តាច់ការនិយម និងសម័យអាណានិគម-និយមបានធ្វើឲ្យប្រជាពលរដ្ឋភាគច្រើនលើសកលលោករងនូវការឈឺចាប់ខ្លោចផ្សា។ ដោយសារមានការរំលោភបំពានទៅលើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពួកគេពីសំណាក់អ្នកកាន់អំណាច ដែលជាពួកផ្តាច់ការនិយម។

ប្រជាពលរដ្ឋភាគច្រើនបានរងនូវការឈឺចាប់ ទទួលរងនូវការធ្វើទុក្ខបុកម្នេញ ការគំរាមកំហែង ការគាបសង្កត់ ការធ្វើអាជីវកម្មលើមនុស្ស ការប្រើអំពើហិង្សា ការបែងចែកស្រទាប់វណ្ណៈ ដែលបណ្តាលឲ្យសង្គមមនុស្សពី មួយថ្ងៃទៅមួយថ្ងៃកាន់តែដុនដាប បង្កើតឲ្យមានបរិយាកាសអនាធិបតេយ្យ ច្របូកច្របល់ គ្មានការទទួលខុសត្រូវ គួរឲ្យស្អប់ខ្ពើម។ បទពិសោធន៍នៃអំពើហិង្សា ឃោរឃៅ អមនុស្សធម៌គ្រប់បែបយ៉ាង បានបង្រៀនពួកគេឲ្យមានសមត្ថភាពយល់ដឹងកាន់តែច្បាស់អំពី សិទ្ធិសេរី និងអំណាចរបស់ខ្លួន ហើយស្វែងយល់ថា បុព្វហេតុ ដែលនាំឲ្យមានសន្តិភាព និងភាពថ្លៃថ្នូរអាចដំណើរការទៅបាន លុះត្រាណាសិទ្ធិសេរីជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ត្រូវបានគេគោរពការពារ និងលើកតម្កើង ត្រូវមានសមភាពនៃជីវភាពរស់នៅក្នុងសង្គម ពីសំណាក់អ្នកកាន់អំណាចតាមស្ថាប័នកំពូលៗរបស់ជាតិ។ម្យ៉ាងទៀត រឿងសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ត្រូវបានពួកបុរាណវិទូចាប់អារម្មណ៍ ហើយបានដាក់បញ្ចូលរឿងនេះទៅក្នុងកម្រងអត្ថបទទស្សនវិជ្ជាទំនើប ក្រោយមកទ្រឹស្តីនេះបានចាក់ឫសយ៉ាងជ្រៅទៅក្នុងប្រព័ន្ធទ្រឹស្តីនៃទស្សនវិជ្ជាខាងនយោបាយ ក្នុងគោលបំណងលើកស្ទួយនូវសិទ្ធិសេរីភាពនិងសមភាពនៅក្នុងសង្គមដែលគេរស់នៅ និងនៅក្នុងពិភពលោកទាំងមូល។ នៅទីបំផុតតម្លៃនៃសិទ្ធិសេរីភាពរបស់មនុស្សត្រូវបានទទួលស្គាល់ និងបានគាំពារយ៉ាងពេញទំហឹងពីពួកទស្សនវិទូនៃក្រុងអាថែននិងក្រុងរ៉ូម ហូតដល់មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងវវាង អាមេរិក បារាំង និងអង់គ្លេស ស្តីពីបញ្ហាសិទ្ធិមនុស្ស និងលទ្ធិប្រជា-ធិបតេយ្យនៅចុងសតវត្សទី១៨។ នៅមុនសង្គ្រាមលោកលើកទី១ គេឃើញមានចុះហត្ថលេខាត្រីភាគី និងទ្វេភាគី លើកិច្ចព្រមព្រៀងស្តីអំពីសិទ្ធិសេរីភាពរបស់មនុស្ស។ ឧទាហរណ៍ ដូចជា សន្ធិសញ្ញាក្រុងប៉ារីស និងក្រុងបែរឡាំង ស្តីពីកិច្ចការជនជាតិភាគច្រើន ដែលកាន់សាសនាគ្រិស្តនៅក្នុងអាណាចក្រទួរគី។

នៅក្រោយសង្គ្រាមលោកលើកទី២ ដោយមានការបារម្ភ និងភ័យខ្លាចចំពោះអំពើរំលោភសិទ្ធិយ៉ាងសាហាវព្រៃផ្សៃ គឺពួកអ៊ីត្លែ និងជប៉ុន លោក Franklin Roosevel អតីតប្រធានាធិបតីសហរដ្ឋអាមេរិក

បានធ្វើសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិ និងសេរីភាពរបស់មនុស្ស។ សេចក្តីថ្លែងការណ៍នោះរួមមាន ៤ ចំណុចៈ សេរីភាពក្នុងការបញ្ចេញមតិ(Freedom of Speech) សេរីភាពក្នុងជំនឿសាសនា(Freedom of Religion) សេរីភាពរួចផុតពីភាពក្រីក្រ(Freedom from want) សេរីភាពរួចផុតពីការភ័យខ្លាច(Freedom from fear)។ សហគមន៍អន្តរជាតិ បានបង្កើតនូវតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិនៅញូរឹបប៊ឺរ(Neuremberg) និងតូក្យូ(Tokyo) ដើម្បីវិនិច្ឆ័យទោសចំពោះពួកឧក្រិដ្ឋជន Nazi ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ នៅឆ្នាំ១៩៤៥សហគមន៍អន្តរជាតិ បានបង្កើតនូវធម្មនុញ្ញនៃអង្គការសហប្រជាជាតិ មាត្រា៥៥នៃធម្មនុញ្ញនេះបានចែងថា"អង្គការសហប្រជាជាតិ សន្យាលើកកម្ពស់ការគោរពសិទ្ធិមនុស្សជាសកលសម្រាប់ជនគ្រប់រូបដោយគ្មានការប្រកាន់ពូជសាសន៍ ភេទ ភាសា និងជំនឿសាសនាឡើយ"។ មាត្រា៥៦ នៃធម្មនុញ្ញចែងថា "សមាជិកទាំងអស់សន្យាដោយខ្លួនឯងថា នឹងធ្វើសកម្មភាពរួម និងដោយឡែកក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការសហប្រជាជាតិ ដើម្បីសម្រេចគោលបំណង ដែលមានចែងក្នុងមាត្រា៥៥នេះ"។ សហគមន៍អន្តរជាតិ ក៏បានអនុម័តសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស ដែលប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៤៨។ សេចក្តីថ្លែងការណ៍នេះបាននិយាយអំពីសិទ្ធិមនុស្សជាមូលដ្ឋានគ្រឹះសម្រាប់មនុស្សទូទៅក្នុងពិភពលោកទាំងមូល។ ដោយសារការយកចិត្តទុកដាក់ពីសហគមន៍អន្តរជាតិស្តីពីសិទ្ធិនិងសេរីភាព គេបាន បង្កើតនូវកម្រងបទដ្ឋានគតិយុត្តពីរផ្សេងទៀតគឺ កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (International Conventions on Economic Social and Cultural Rights) កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(Internationnal Conventions on Civil and Political Rights)។ ផ្តើមចេញពីវិធានការជាអន្តរជាតិដ៏មានតម្លៃនេះ បានធ្វើឲ្យសង្គមមនុស្សមានការវិវត្តន៍ពីមួយថ្ងៃទៅមួយថ្ងៃ ដោយសន្ទុះល្បឿនលឿនឥតឧបមា ដើម្បីឈោងចាប់យករាល់ព្រឹត្តិការណ៍ថ្មីៗមកបំពេញនូវអ្វីដែលខ្វះខាត ដើម្បីឆ្ពោះទៅមុខលើផងវិថីអភិវឌ្ឍតាមកាលសម័យឥតព្រំដែនកំណត់ឡើយ។ ទន្ទឹមនឹងការបង្កើតថ្មីៗ អ្វីៗដែលចាស់គំរិលហួសសម័យក៏ត្រូវបានជម្រុះចោលជាបណ្តើផងដែរ រីឯជីវភាពនយោបាយនៃប្រទេសជាតិនីមួយៗក៏ប្រែប្រួលតាមនិន្នាការនោះដែរ ដោយគ្រាន់តែមានសភាពខុសគ្នាតាមទីតាំងភូមិសាស្រ្ត ប្រវត្តិសាស្រ្ត លក្ខណៈចរិត ចិត្តសាស្រ្តសង្គម កម្រិតអប់រំបណ្តុះបណ្តាល អត្តសញ្ញាណជាតិ ប្រពៃណី ទំនៀមទម្លាប់ វប្បធម៌... នៃប្រជាជាតិនីមួយៗប៉ុណ្ណោះ។

ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងក្រោយឆ្លងកាត់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃជាងពីរទសវត្ស ដោយធ្វើឲ្យប្រជាពលរដ្ឋខ្មែររងនូវការឈឺចាប់ខ្លោចផ្សា វិនាសហិនហោច និងការប្រែប្រួលឥតស្រាកស្រាន្តពីមួយជំនាន់ទៅមួយជំនាន់ ជាពិសេសមានការផ្លាស់ប្តូរប្រព័ន្ធនយោបាយឥតឈប់ឈរ។ ភាពឆ្អែតទាំងនេះបានញ៉ាំងឲ្យប្រជាពលរដ្ឋខ្មែរ ងាកមកអបអរសាទរទទួលយករបបនយោបាយដ៏មានប្រជាប្រិយពេញនិយមលើសកលលោក គឺរបបប្រជាធិបតេយ្យសេរីពហុបក្ស ដែលកើតមានឡើងតាមរយៈកិច្ចព្រមព្រៀងសន្តិភាពស្តីពី ដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា

ឆ្នាំ១៩៩១ ធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាយើងបានផ្លាស់ប្តូរមុខមាត់ថ្មី ក្រោមការរៀបចំបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រជាសកល ដោយសេរី និងយុត្តិធម៌ និងសម្ងាត់ គោរពតាមគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ដែលរៀបចំដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ(UNTAC)។ លទ្ធផលនៃការបោះឆ្នោតជាសកល និងសម្ងាត់បាននាំមកនូវសភាធម្មនុញ្ញមួយដែលមានតួនាទីបំពេញភារកិច្ចរបស់ខ្លួនក្នុងការ ពិភាក្សាតាក់តែង និងអនុម័តលើច្បាប់រដ្ឋធម្មនុញ្ញថ្មីមួយ ដែលជាច្បាប់កំពូលរបស់ប្រទេសនាឆ្នាំ១៩៩៣។ តាមរយៈកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នេះព្រះរាជាណាចក្រកម្ពុជាបានទទួលលទ្ធផលដ៏មានតម្លៃជាប្រវត្តិសាស្ត្រសម្រាប់ជាតិដោយឥតកាត់ថ្លៃបាន គឺសិទ្ធិនិងអធិបតេយ្យភាពពេញលេញរបស់ខ្លួនក្នុងនាមជារដ្ឋឯករាជ្យ តាមលក្ខណៈជារដ្ឋប្រជាធិបតេយ្យសេរីពហុបក្ស។ នៅក្នុងកិច្ចព្រមព្រៀងសន្តិភាពនេះ កម្ពុជាបានសន្យាជាមូលដ្ឋានចំពោះសិទ្ធិមនុស្សថា មនុស្សគ្រប់រូបនៅកម្ពុជា ដូចជាជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងទាំងអស់ ត្រូវមានសិទ្ធិ និងសេរីភាព ដូចមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធសិទ្ធិមនុស្ស។ កិច្ចព្រមព្រៀងនេះចែងថាប្រទេសកម្ពុជាបានសន្យាថា នឹងចូលរួមយ៉ាងខ្ជាប់ខ្ជួនក្នុងកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយណាដែលជាប់ទាក់ទងនឹងសិទ្ធិមនុស្ស។ ជាពិសេសដោយប្រតិបត្តិតាមបទបញ្ញត្តិនេះ ប្រទេសកម្ពុជារបស់យើង គឺជាប្រទេសមួយក្នុងចំណោមប្រទេសប្រជាធិបតេយ្យដ៏កម្រដែលបានទទួលស្គាល់ និងជ្រើសរើសសិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិផ្សេងៗទៀតជាច្រើន បញ្ចូលទៅក្នុងអត្ថបទរដ្ឋធម្មនុញ្ញរបស់ជាតិដោយឲ្យតម្លៃគតិយុត្តខ្ពស់បំផុត ដែលច្បាប់អាចអនុញ្ញាត។ ដូចជាមាត្រា៣១នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ជាដើម។ នៅក្នុងសង្គមប្រជាធិបតេយ្យ សិទ្ធិជាមូលដ្ឋាន ដែលមានសារៈសំខាន់ និងចាំបាច់ជាងគេ គឺសិទ្ធិពលរដ្ឋ សិទ្ធិមនុស្ស សិទ្ធិសេដ្ឋកិច្ច និងសង្គម ជាពិសេសគឺ សិទ្ធិសេរីភាពខាងនយោបាយ។ មាគ៌ានៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជាបច្ចុប្បន្ន បាននឹងកំពុងតែធ្វើដំណើរទៅកាន់វឌ្ឍនភាព និងតម្លៃរួមមួយនៃចរន្តប្រជាធិបតេយ្យពិភពលោក ដើម្បីចូលរួមរក្សានូវពហុឯកសណ្ឋាននៃអត្តិភាពរបស់ខ្លួន ដោយបានធ្វើការបង្រួបបង្រួមបុគ្គលស្រទាប់វណ្ណៈក្នុងសង្គមឲ្យក្លាយជាឯកសណ្ឋានមួយស្របតាមសកលភាពនៃតម្លៃរួម នៃប្រជាធិបតេយ្យ ដូចបានអនុវត្តនៅបណ្តាប្រទេសប្រជាធិបតេយ្យជឿនលឿននានាលើពិភពលោក។ បច្ចុប្បន្នសិទ្ធិទាំងនេះត្រូវបានប្រគល់ជូនប្រជាពលរដ្ឋជាម្ចាស់អំណាច ដែលញ៉ាំងឲ្យប្រជាពលរដ្ឋកម្ពុជា មានសិទ្ធិសេរីភាពជាងពេលណាៗទាំងអស់ នៅក្នុងប្រវត្តិសាស្ត្រនៃដំណើរគ្រប់គ្រងដឹកនាំនិងការរីកចម្រើនរបស់ខ្លួន។ សមិទ្ធិផលដ៏មានតម្លៃនេះ គឺជាលទ្ធផលនៃការប្រឹងប្រែងរបស់អ្នកដឹកនាំ បានសម្រេចជ្រើសរើសយករបបគ្រប់គ្រងដឹកនាំដ៏ត្រឹមត្រូវមួយ គឺរបបប្រជាធិបតេយ្យសេរីពហុបក្សសម្រាប់ប្រជាជន និងមាតុភូមិខ្មែរ និងជាពិសេសសម្រាប់វឌ្ឍនភាពវប្បធម៌ខ្មែរយើង ដែលជារដ្ឋមានវ័យចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៍និងធ្លាប់ទទួលនូវកិត្យានុភាពអារ្យធម៌ដ៏ខ្ពង់ខ្ពស់ដល់កំពូលចាប់ពីសតវត្សទី១១ ដល់សតវត្សទី១៣ ក្នុងសម័យអង្គរដ៏រុងរឿង ដែលពេលនោះទាំងថ្នាក់ដឹកនាំដ៏ខ្លាំងពូកែនិងប្រជាពលរដ្ឋមានសេចក្តីក្លាហាន ខ្លាំងក្លា សាមគ្គីជាធ្លុងមួយដ៏រឹងមាំគឺ ឯកភាព

ជាតិ ឯកភាពទឹកដីក្នុងទឹកចិត្តយោគយល់គ្នា គោរពស្រឡាញ់រាប់អានគ្នា មនសិកាជាតិខ្ពស់ ដើម្បីកសាងការពារមាតុភូមិអង្គរដ៏បវរ។

ក្រោយពីការកើតឡើងនូវព្រះរាជាណាចក្រកម្ពុជាទី២ តាមរយៈការបោះឆ្នោតជាសកល ដែលរៀបចំដោយអាជ្ញាធរបណ្តោះអាសន្ន(UNTAC)នាឆ្នាំ១៩៩៣មក ក្នុងបេសកកម្មដើម្បីសន្តិភាព រដ្ឋាភិបាលកម្ពុជាបានពង្រឹងពង្រីកស្ថេរភាពនយោបាយ និងសុខសន្តិភាពពេញលេញតាមបន្ទាត់នយោបាយឈ្នះ-ឈ្នះ ហើយឈានទៅដល់ការបង្រួបបង្រួមជាតិ ដោយធ្វើសមាហរណកម្មកងកម្លាំងយោធា និងអង្គការចាត់ខាងនយោបាយរបស់ខ្មែរក្រហម ឲ្យមករួមរស់យ៉ាងសុខសាន្តជាមួយរាជរដ្ឋាភិបាល ដោយទទួលបាននូវឯកភាពជាតិ ឯកភាពទឹកដី ក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ព្រះមហាក្សត្រតែមួយព្រះអង្គ ទង់ជាតិតែមួយ និងរដ្ឋាភិបាលតែមួយនៅលើទឹកដីអង្គរ ដែលធ្លាប់តែរុងរឿងមួយនេះ។ ផ្តើមចេញពីសុខសន្តិភាព ស្ថេរភាពនយោបាយពេញលេញ និងរឹងមាំទូទាំងប្រទេស ព្រមទាំងមានការជ្រោមជ្រែងគាំទ្រពេញទំហឹងពីសហគមន៍អន្តរជាតិផងនោះ ប្រមុខដឹកនាំរាជរដ្ឋាភិបាលប្រកបដោយបញ្ញាញាណចាក់ធ្លុះ ពេញសមត្ថភាព នៃ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី រួមសាមគ្គី ស្វាមីភក្តិស្មោះស្ម័គ្រជាមួយប្រជាពលរដ្ឋជាម្ចាស់អំណាចជាម្ចាស់ជោគវាសនាប្រទេសជាតិ បានបង្កើតកម្មវិធីនយោបាយក្នុងកម្រិតកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅលើគ្រប់វិស័យសំខាន់ៗជាអាទិភាព ដើម្បីដឹកនាំប្រទេសទៅកាន់នីតិរដ្ឋ ប្រជាធិបតេយ្យសេរីពហុបក្ស អភិបាល-កិច្ចល្អ យុត្តិធម៌សង្គម គោរពសិទ្ធិមនុស្ស សិទ្ធិសេរីភាពប្រជាពលរដ្ឋ សិទ្ធិនយោបាយ និងកាត់បន្ថយភាពក្រីក្រ សំដៅលើកស្ទួយជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងអភិវឌ្ឍសេដ្ឋកិច្ចក្នុងគន្លងនិរន្តរភាព។

បរិយាកាស និងថេរវេលានេះអាចសមរម្យណាស់ចំពោះស្ថាប័នកំពូលជាតិ រួមគ្នាលើកកម្ពស់ការអនុវត្តន៍សិទ្ធិមនុស្ស យុត្តិធម៌សង្គម ជាពិសេសរួមគ្នាលុបបំបាត់នូវរាល់ទម្រង់រើសអើងនយោបាយ បក្សពួកនិយម ការប្រមូលផ្តុំអំណាច ចរិតផ្តាច់ការក្រោមស្លាកប្រជាធិបតេយ្យ បំបាត់អំពើពុករលួយ... និងបើកចំហឆន្ទៈនយោបាយឲ្យប្រជាពលរដ្ឋ ម្ចាស់ឆ្នោត ម្ចាស់ប្រទេស និងជាម្ចាស់អំណាច ហ៊ានប្រើសិទ្ធិសេរីភាពសំខាន់ៗរបស់ខ្លួនតាមគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចបានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឲ្យទូលំទូលាយដូចទៅនឹងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យរបស់ប្រជាពលរដ្ឋ នៅបណ្តាប្រទេសជឿនលឿននានាលើសកលលោក ដើម្បីឈានទៅដល់ចំណុចបទដ្ឋានអន្តរជាតិ ដែលជាតម្លៃសកលនៃគោលការណ៍ប្រជាធិបតេយ្យសកលលោក ក្នុងនាមជាប្រទេសមួយធ្លាប់មានអារ្យធម៌រុងរឿង និងមានកិត្តិសព្ទថ្លៃថ្នូល្បីរន្ទឺលើសកលលោកដែរនោះ។

បច្ចុប្បន្នពាក្យថា សិទ្ធិ សេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋម្ចាស់ប្រទេស ម្ចាស់ឆ្នោត នៅក្នុងបរិបទប្រជាធិបតេយ្យ គឺទាំងប្រជាពលរដ្ឋខ្លួនឯង មន្ត្រី និងអ្នកនយោបាយបានប្រើប្រាស់រត់មាត់ថា ប្រជាធិបតេយ្យគឺជារបបដែលដឹកនាំឲ្យប្រជាពលរដ្ឋ ជារបបយករាស្ត្រជាធំ ដើម្បីអនុវត្ត ឬសម្រេចចិត្តអ្វីមួយដោយយកមតិ

ភាគច្រើនធ្វើជាគោលការណ៍ និងជារបបមួយដែលបានកំណត់អំណាចរបស់ស្ថាប័នកំពូលៗរបស់ជាតិនៅដាច់ពីគ្នា។ ជាការប្រពៃណាស់ ដែលខ្មែរយើងទូទាំងប្រទេសយល់បានច្បាស់លាស់ពីនិយមន័យនៃពាក្យនេះ ក៏ប៉ុន្តែពួកគេពុំទាន់យល់ឲ្យបានច្បាស់លាស់អំពីសក្តានុពល នៃតម្លៃដាច់ខាតរបស់សិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋនៅក្នុងគោលការណ៍គ្រឹះនៃលទ្ធិប្រជាធិបតេយ្យ និងពុំទាន់អនុវត្តបានត្រឹមត្រូវនៅឡើយទេ។ តាមការពិត សិទ្ធិ សេរីភាព និងអំណាចរបស់ម្ចាស់ឆ្នោត(ប្រជាពលរដ្ឋ) ក្នុងបរិបទប្រជាធិបតេយ្យ គឺជាកម្មវត្ថុនៃការតស៊ូមតិបែបអហិង្សាក្នុងសមានចិត្តស្ថាបនា ប្រកបដោយសទ្ធាសម្បយុត្តដ៏លាតសន្ធឹងរបស់ប្រជាពលរដ្ឋម្ចាស់ប្រទេស ម្ចាស់អំណាច គ្រប់ជំនាន់ជាដរាបគ្មានទីបញ្ចប់ ដើម្បីសេចក្តីសុខសាន្ត ស្ថេរភាពនយោបាយ ការរីកចម្រើន យុត្តិធម៌សង្គម។ ជាពិសេសតម្លៃ នៃអធិបតេយ្យរបស់ប្រជាពលរដ្ឋក្នុងនាមជាម្ចាស់អំណាចម្ចាស់ប្រទេស និងជាអ្នកនាំមុខក្នុងការបង្កើតឲ្យមានឡើងយ៉ាងពិតប្រាកដ នៃគោលការណ៍តុល្យភាពអំណាចរបស់ស្ថាប័នកំពូលៗរបស់ជាតិ។ ផ្អែកតាមទិដ្ឋភាពជាក់ស្តែងទូទៅស្តីពីសមត្ថភាព និងលទ្ធភាពនៅកម្ពុជា ការចាក់សោរប្រព័ន្ធអំណាចដ៏តឹងរឹងបើកចំហឲ្យប្រជាពលរដ្ឋប្រើសិទ្ធិសេរីភាពរបស់ខ្លួនក្នុងចរន្តប្រជាធិបតេយ្យភាវូបនីយកម្មនៅកម្ពុជាបច្ចុប្បន្នមិនអាចនិយាយថា ជារឿងតក់ក្រហល់ ឬជាដំណាក់កាលដំបូងៗនោះទេ។ ព្រោះថា រដ្ឋាភិបាលប្រជាធិបតេយ្យមួយ គឺជារដ្ឋាភិបាលដែលបានគ្រប់គ្រងតាមឆន្ទៈរបស់ប្រជារាស្ត្រជាធំ ដើម្បីប្រជារាស្ត្រ និងជារបស់ប្រជារាស្ត្រ អ្វីៗទាំងអស់ប្រមូលផ្តុំលើប្រជារាស្ត្រ។ ដំណើរការប្រជាធិបតេយ្យនីយកម្ម អាចប្រព្រឹត្តទៅប្រកបដោយជោគជ័យ លុះត្រាតែមានការចូលរួមពីប្រជាពលរដ្ឋម្ចាស់ឆ្នោត ម្ចាស់អំណាច ប្រកបដោយការយល់ដឹង ព័ត៌មានពិតប្រាកដ ក្រមសីលធម៌ល្អ គ្មានការបំភិតបំភ័យ បោកបញ្ឆោត និងមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ ព្រមទាំងមានការចូលរួមវិភាគទានជាចាំបាច់ក្នុងការជួយតម្រែតម្រង់ និងការឧបត្ថមគាំទ្រយ៉ាងពេញទំហឹង ពីសំណាក់សហគមន៍អន្តរជាតិមិនអាចខ្វះបានឡើយ។ ជាពិសេសស្ថាប័នកំពូលៗរបស់ប្រទេសជាតិ ចាំបាច់ត្រូវរក្សាឲ្យបាននូវគោលការណ៍តុល្យភាពអំណាច(Checks and Balances)។ កាលណាបាត់មូលដ្ឋាននេះ ធ្វើឲ្យស្ថានភាពនៃការប្រព្រឹត្តទៅរបស់ជាតិ ស្ថិតនៅចំណុចរបត់ផ្តាច់ការ បុគ្គលនិយម បក្សពួក ខ្សែស្រឡាយនិយម អយុត្តិធម៌ ការិយាធិបតេយ្យ អំពើពុករលួយគ្រប់ច្រកល្ហកនៃរចនាសម្ព័ន្ធដឹកនាំរដ្ឋ ដែលមុខសញ្ញានៃនិន្នាការនេះ គឺធ្វើឲ្យប្រជាពលរដ្ឋក្លាយជាកម្មវត្ថុនៃការគាបសង្កត់តាមរយៈប្រជាធិបតេយ្យប្រជាភិថុត ឬប្រជាធិបតេយ្យក្រោមរូបភាពក្បត់ខ្លឹមសារ។

ថ្វីត្បិតតែយើងទាំងអស់គ្នាកំពុងរួមរស់ក្នុងសន្តិភាព ស្ថេរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចរៀងរាល់ឆ្នាំក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដោយប្រកាន់ខ្ជាប់នូវរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ឬក៏អាចនិយាយម្យ៉ាងទៀតថា របបនយោបាយចំហជើងមេឃ សម្រាប់កិច្ចទំនាក់ទំនងទូលំទូលាយក្នុងប្រទេស និងប្រទេសនានាលើសកលលោកប្រកបដោយមោទនភាពក្តី ក៏ប៉ុន្តែដោយសារជ័យជម្នះប្រជាធិបតេយ្យនៅមានភាពផុយស្រួយ ប្រព័ន្ធដឹកនាំប្រទេសមានលក្ខណៈអាជ្ញានិយម ប្រមូលផ្តុំអំណាច បក្សពួកនិងបុគ្គលនិយម

ជុំវិញតំណែងនាយករដ្ឋមន្ត្រី ធ្វើឲ្យដំណើរការអនុវត្តសិទ្ធិប្រជាពលរដ្ឋ សិទ្ធិមនុស្ស ជាពិសេសសិទ្ធិនយោបាយរបស់ពលរដ្ឋស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅពុំទាន់បានយកចិត្តទុកដាក់ជាដុំកំភួន និងបើកចំហឲ្យបានទូលំទូលាយ ទៅតាមគោលការណ៍រួមនៃលទ្ធិប្រជាធិបតេយ្យនៅឡើយទេ។ សិទ្ធិនយោបាយរបស់ពលរដ្ឋនៅតែស្លួចស្លើងបំផុត និងរុញឲ្យស្ថិតនៅកម្រិតអន្តរកាល ក្រោមឆន្ទៈអ្នកនយោបាយដោយពុំទាន់ជ្រាបច្បាស់អំពីចក្ខុវិស័យដឹកនាំប្រទេសជាតិ។ ប្រជាពលរដ្ឋមានតែសិទ្ធិ ដូចបានចែងក្នុងរដ្ឋធម្មនុញ្ញ តែលំបាក ឬមិនហ៊ានយកសិទ្ធិទាំងអស់នោះមកអនុវត្តឲ្យបានទូលំទូលាយតាមវប្បធម៌ប្រជាធិបតេយ្យ ដូចបានអនុវត្តតាមបណ្ដាប្រទេសមហាអំណាចប្រជាធិបតេយ្យឡើយ។ តាមការសិក្សាស្រាវជ្រាវរកឃើញថា មានឧបសគ្គពីរដែលបង្កឲ្យរាំងស្ទះដល់ដំណើរការនៃសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋគឺ ទី១.ការមិនទទួលស្គាល់សិទ្ធិមនុស្សក្នុងអង្គហេតុជាលក្ខណៈសកល និងទី២.មានលក្ខណៈពុតត្បុតច្រើនជាង ឧបសគ្គទី១នោះ គឺជម្ងឺផ្ទៃក្នុង ដែលអាចជាជម្ងឺមហារីកដោយសារមិនទាន់យល់ដឹងឲ្យបានស្គាល់ច្បាស់នូវអ្វីដែលហៅថា សិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ។ ទាំងម្ចាស់សិទ្ធិសេរីភាព ទាំងម្ចាស់សង្គមទាំងមូលបានប្រើប្រាស់ត្រឹមត្រូវ នៃសិទ្ធិ និងការប្រើប្រាស់មិនត្រឹមត្រូវនៃសិទ្ធិ។ សំខាន់ជាងនេះការសិក្សាបញ្ជាក់ថា ប្រព័ន្ធដឹកនាំ និងគ្រប់គ្រងរដ្ឋដែលបានផ្ដល់លទ្ធភាពឲ្យស្ថាប័ននីតិប្រតិបត្តិមានអំណាចច្រើនជាងស្ថាប័នអង្គការនីតិបញ្ញត្តិ និងស្ថាប័នតុលាការ ជាពិសេសស្ថាប័នទាំងបីនេះហាក់បីដូចជា ពុំមែនជាស្ថាប័នរបស់រដ្ឋតែ គឺជាស្ថាប័នរបស់គណបក្សទៅវិញ ដែលសមាសភាពថៅក្រមនិងព្រះរាជអាជ្ញាភាគច្រើនគឺ មន្ត្រីជាន់ខ្ពស់របស់គណបក្សនយោបាយកាន់អំណាច។ លើសពីនេះទៅទៀតនោះគឺអគ្គមេបញ្ជាការ មេបញ្ជាការនៅគ្រប់ស្ថាប័នឋានានុក្រម នៃអគ្គបញ្ជាការដ្ឋានកងកម្លាំងប្រដាប់អាវុធទាំងអស់ គឺដឹកនាំដោយបុគ្គលមានតំណែងខ្ពស់នៅក្នុងគណបក្សនយោបាយក្រោមការរៀបចំដោយអំណាចរដ្ឋាភិបាល។ ដូច្នេះបើកាលណាអង្គការនីតិ-បញ្ញត្តិ ជាស្ថាប័នកំពូលមួយរបស់រដ្ឋ តំណាងឲ្យអំណាច ប្រជាពលរដ្ឋគ្មានអំណាចរឹងមាំ និងឯករាជ្យពិតប្រាកដទេ នោះប្រជាពលរដ្ឋទាំងអស់ក៏បាត់បង់អំណាចរបស់ខ្លួននៅក្នុងដំណើរការប្រជាធិបតេយ្យនីយកម្មជាស្វ័យប្រវត្តិផងដែរ។ បើតាមទិដ្ឋភាពរួមនៃពុម្ពគំរូចរន្តប្រជាធិបតេយ្យ ប្រជាពលរដ្ឋមិនគួរគ្មានអំណាចដើម្បីអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនឲ្យបានទូលំទូលាយឡើយ។ ហេតុផលនេះបានញ៉ាំងឲ្យខ្ញុំបាទជាអ្នកស្រាវជ្រាវមានការងឿងឆ្ងល់យ៉ាងខ្លាំង និងបានលើកយកបញ្ហាទាំងនេះ ជារបៀបវារៈទីមួយ ដើម្បីសិក្សាវិភាគក្នុងប្រធានបទស្ដីអំពី " **សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា** " មកធ្វើការសិក្សា។ វប្បធម៌រើសអើងនយោបាយ ដែលចាប់ផ្ដើមក្នុងយុគសម័យសង្គ្រាមត្រជាក់ និងបានសាយភាយចូលក្នុងសង្គមខ្មែរនៅពេលនោះ ក៏នៅតែកើតមានក្នុងពេលបច្ចុប្បន្នក្នុងនយោបាយនៅកម្ពុជាដដែល។ ចរិតវប្បធម៌ទំនៀមទម្លាប់ និងប្រពៃណីរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ បែបខន្តី ស្មោះត្រង់ ទន់ភ្លន់ ជឿបុណ្យជឿបាប បែបឥទ្ធិពលព្រះពុទ្ធសាសនាថេរវាទ និង ភាគច្រើនពុំធ្លាប់អប់រំខ្លួនជាប្រជាពលរដ្ឋសកម្មប្រយុទ្ធក្នុងនយោបាយប្រជាធិបតេយ្យនោះទេ។ ប្រជាពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ គឺជាប្រជាពលរដ្ឋមានអំណាចប្រើសិទ្ធិ

សេរីភាព របស់ខ្លួនយ៉ាងពេញលេញប្រកបដោយការយល់ដឹង ដើម្បីចូលរួមកំណត់ជោគវាសនាប្រទេសជាតិ និងជាអ្នកកំណត់ថា តើវរជននយោបាយរូបណា ជាអ្នកមានសមត្ថភាពមកដឹកនាំរដ្ឋាភិបាល។ ប្រជាពលរដ្ឋខ្មែរមានផ្នត់គំនិត មានភក្តីភាព ជឿជាក់ និងផ្ញើជោគវាសនារបស់ខ្លួនទាំងស្រុងទៅលើមេដឹកនាំ។ មានកត្តាជាច្រើនទៀតដែលបានរកឃើញដោយព្យាយាមទាញហេតុផល ដើម្បីកែទម្រង់ប្រព័ន្ធដឹកនាំដូចបានស្រាយបញ្ជាក់នៅក្នុងនិក្ខេបបទ។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទខាងលើ គឺជាភាពចាំបាច់មួយសម្រាប់សង្គមខ្មែរយើងនាពេលបច្ចុប្បន្ននេះ ដើម្បីជាការពង្រឹងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងនាមពលរដ្ឋជាម្ចាស់អំណាចទាំងអស់ ជាម្ចាស់ប្រទេស ជាម្ចាស់ជោគវាសនានៃប្រទេសជាតិទាំងមូល ព្រោះវាជាមូលដ្ឋានដ៏រឹងមាំធ្វើឲ្យយើងជាប្រជាពលរដ្ឋអាចស្គាល់ច្បាស់អំពីសិទ្ធិអំណាចរបស់ខ្លួន តាមរយៈរដ្ឋធម្មនុញ្ញនៃប្រទេសប្រកាន់របបដឹកនាំតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស។ ប៉ុន្តែដោយសារអ្នកនយោបាយបច្ចុប្បន្នពុំសូវមានបទពិសោធន៍ និងភាពចាស់ទុំក្នុងមជ្ឈដ្ឋានប្រជាធិបតេយ្យសេរីពហុបក្សរីឯប្រជាពលរដ្ឋខ្មែរទូទៅក៏នៅមានចំណេះដឹងទាបកម្រិតសេដ្ឋកិច្ចពុំទាន់រីកចម្រើន ជាពិសេសកម្រិតសីលធម៌នៅទាបផងនោះ ធ្វើឲ្យមានបញ្ហាចម្រូងចម្រាសជាច្រើនក្នុងការប្រើប្រាស់សិទ្ធិអំណាច និងសិទ្ធិសេរីភាពដែលមានចែងក្នុងគោលការណ៍ជាមូលដ្ឋានក្នុងរបបប្រជាធិបតេយ្យ។

ដើម្បីងាយយល់ឲ្យកាន់តែច្បាស់ទៅលើប្រធានបទខាងលើ គប្បីចោទសំណួរមួយចំនួនដូចខាងក្រោមៈ

-តើប្រជាពលរដ្ឋខ្មែរ មានអំណាចប្រើសិទ្ធិសេរីភាពខាងនយោបាយរបស់ខ្លួនបានទូលំទូលាយតាមគោលការណ៍ប្រជាធិបតេយ្យដូចរដ្ឋធម្មនុញ្ញបានចែងដែរ ឬទេ?

-តើមានមូលហេតុអ្វីខ្លះ ដែលរារាំងប្រជាពលរដ្ឋក្នុងការអនុវត្តន៍សិទ្ធិសេរីភាព និងអំណាចរបស់ខ្លួន?

-តើស្ថាប័នរដ្ឋសភា ដែលជាស្ថាប័នតំណាងឲ្យអំណាចប្រជាពលរដ្ឋបានការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋតាមតួនាទីរបស់ខ្លួនដែរ ឬទេ?

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការតាក់តែងនិក្ខេបបទនេះ គឺធ្វើឡើងក្នុងគោលបំណងដូចខាងក្រោមៈ

-សិក្សាពីឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបើកចំហឲ្យប្រជាពលរដ្ឋដែលជាម្ចាស់អំណាចបានប្រើសិទ្ធិសេរីភាព ប្រើអំណាចតាមគោលការណ៍ប្រជាធិបតេយ្យ និងការការពាររបស់រដ្ឋាភិបាលចំពោះប្រជារាស្ត្រម្ចាស់ឆ្នោត។

-ចូលរួមបង្ហាញពីស្ថាប័ននីតិបញ្ញត្តិថា តើមានសិទ្ធិអំណាចដូចម្តេចក្នុងការការពារសិទ្ធិពលរដ្ឋ។

-ចូលរួមបំភ្លឺប្រជាពលរដ្ឋឲ្យស្គាល់កាន់តែច្បាស់អំពីឥទ្ធិពលនៃសិទ្ធិ និងអំណាចរបស់ប្រជារាស្ត្រក្នុងរបបប្រជាធិបតេយ្យ និងចេះទាមទារដោយខ្លួនឯង។

-កំណត់អត្តសញ្ញាណកម្មលើចំណុចខ្វះខាតស្តីអំពី ការប្រើសិទ្ធិសេរីភាពក្នុងរបបប្រជាធិបតេយ្យ ដែលនឹងត្រូវកែលំអ ដើម្បីធ្វើឲ្យប្រសើរឡើងជាលំដាប់ចំពោះសិទ្ធិ និងអំណាចរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត ម្ចាស់អំណាចតទៅអនាគត។

## ១.៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីឲ្យការស្រាវជ្រាវប្រព្រឹត្តទៅបានល្អ និងអាចធ្វើការវិភាគគ្រប់ជ្រុងជ្រោយ តាមលក្ខណៈវិទ្យាសាស្ត្រផងដែរនោះ វិសាលភាពនៃការស្រាវជ្រាវត្រូវបានផ្តោតការយកចិត្តទុកដាក់លើសិទ្ធិសង្គម និងជាពិសេស ទៅលើសិទ្ធិសេរីភាពខាងនយោបាយក្នុងបរិបទប្រជាធិបតេយ្យ ដោយចាប់ផ្តើមសិក្សាស្រាវជ្រាវនៅចន្លោះឆ្នាំ២០០២ ដល់ឆ្នាំ២០១០។

## ១.៥. វិធីសាស្ត្រស្រាវជ្រាវ

### ក. ត្រីវិស័យនៃការស្រាវជ្រាវផ្អែកលើមូលដ្ឋានប្រាំគឺ:

១. ផ្អែកទៅលើមូលដ្ឋាននៃទស្សនវិជ្ជា និងទ្រឹស្តីផ្នែកវិទ្យាស្ត្រសង្គម។

២. ផ្អែកទៅលើមូលដ្ឋាននៃតក្កវិជ្ជា។

៣. ផ្អែកទៅលើព្រឹត្តិការណ៍វិវត្តន៍នៃស្ថានភាពសង្គម និងនយោបាយខ្មែរ។

៤. ផ្អែកទៅលើមូលដ្ឋាននៃទស្សននយោបាយនិងចិត្តសាស្ត្រសង្គម និងលក្ខខណ្ឌវិទ្យាសាស្ត្រសង្គមវិជ្ជា ដែលពាក់ព័ន្ធនឹងសិទ្ធិសេរីភាពក្នុងរបបដឹកនាំបែបប្រជាធិបតេយ្យ។

៥. ឯកសារ បទដ្ឋានគតិយុត្ត និងច្បាប់ផ្សេងៗរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានបោះពុម្ពផ្សាយ និងមានតំកល់ទុកនៅក្នុងក្រុងភ្នំពេញ នៅតាមបណ្ណាល័យនានា ព្រមទាំងសៀវភៅ និងកម្រងអត្ថបទពិសេសផ្សេងៗទៀត។ ម្យ៉ាងទៀតជម្រើសដ៏សមរម្យបំផុតយកមកប្រើប្រាស់ក្នុងគម្រោងស្រាវជ្រាវគឺ យើងខ្ញុំបានគោរពតាមការណែនាំ និងតាមគម្រោងសកម្មភាពរបស់ខ្លួនឯងផ្ទាល់ ដែលជាជំនួយក្នុងការពិពណ៌នាបែបគុណភាព ដោយរួមបញ្ចូលគ្នារវាងទិន្នន័យទាំងពីរ និងវិភាគទៅលើដើមចមនៃប្រភពរាំងម្ចាស់អំណាច មិនអាចប្រើសិទ្ធិសេរីភាពខាងនយោបាយបានទូលំទូលាយតាមរដ្ឋធម្មនុញ្ញបាន។ ដូច្នេះ វិធីសាស្ត្រសមស្រប ដែលបានប្រើខាងលើត្រូវបានបង្កើតឡើងដើម្បីវិភាគឲ្យបានស៊ីជម្រៅចំពោះ **"សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជា ឆ្នាំ២០០២-២០១០"** និងឈានឆ្ពោះទៅធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍ ដើម្បីកែលំអឲ្យបានកាន់តែល្អប្រសើរជាលំដាប់ក្នុងដំណើរការអនុវត្តន៍ប្រជាធិបតេយ្យនៅកម្ពុជា។

### ខ. វិធីសាស្ត្រប្រមូលទិន្នន័យ:

**-ទិន្នន័យទីមួយ** ជាប្រភេទទិន្នន័យផ្ទាល់(Primary Data) បានសាកសួរសំណួរមួយចំនួនចំពោះឥស្សរជននយោបាយ និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ។ ហើយបានចូលរួមក្នុងសិក្ខាសាលា និងសន្និសិទនានា ដោយផ្ទាល់តែម្តង។

**-ទិន្នន័យទីពីរ**(Secondary Data) បានមកពីការដកស្រង់ចំពោះខ្លឹមសារសំខាន់ៗ និងចាំបាច់នានា ដែលប្រមូលបានពីគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល គណៈកម្មការសិទ្ធិមនុស្សរបស់រដ្ឋសភា ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ណាល័យ និងព្រឹត្តបត្រ របាយ-ការណ៍ ទស្សនាវដ្តី និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់នានាដែលពាក់ព័ន្ធ និងដំណើរការរបស់ស្ថាប័ននយោបាយ ព្រមទាំងឯកសារពីសារព័ត៌មានជាតិ និងអន្តរជាតិ។ល។ ដែលបានដាក់នៅក្នុងឯកសារយោង។

### គ. វិធីសាស្ត្រវិភាគទិន្នន័យ:

ការលើកយកប្រធានបទខាងលើនេះមកសិក្សាវិភាគ គឺចង់បង្ហាញថា យើងបានប្រើវិធីសាស្ត្រប្រៀបធៀបរវាងទ្រឹស្តីសិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋ នៅក្នុងគោលការណ៍ប្រជាធិបតេយ្យទៅនឹងការអនុវត្តន៍នយោបាយជាក់ស្តែងរបស់រាជរដ្ឋាភិបាលផងដែរ ខ្ញុំបាទក៏បានប្រើវិធីសាស្ត្រអធិប្បាយទៅតាមហេតុការណ៍ ដែលបានកើតឡើងពិតៗតែម្តង នៅក្នុងការអនុវត្តន៍ប្រជាធិបតេយ្យនៅកម្ពុជា។ ហើយរាល់ការវិភាគរបស់យើងផ្អែកទៅលើភាពតក្កវិជ្ជា និងផ្អែកទៅលើកត្តាឯកសារច្បាប់ សំណុំអត្ថបទឯកសារ ព្រះរាជក្រមសេចក្តីសម្រេច លិខិតបទដ្ឋានក្រោមច្បាប់ របាយការណ៍បូកសរុប សេចក្តីថ្លែងការណ៍នានា ព្រមទាំងវិភាគលើទិដ្ឋភាពមាត្រាច្បាប់ និងបទបញ្ញាផ្ទៃក្នុងរបស់រដ្ឋសភាខ្លះៗផងដែរ។

ទិន្នន័យដែលប្រមូលបានគឺ យកមកវិភាគតាមរយៈពិពណ៌នាបែបគុណភាព ដោយប្រើទិន្នន័យទីពីរ(Secondary Data) ច្រើនលើសលប់ជាងទិន្នន័យទីមួយ ព្រោះថា ទិន្នន័យទីមួយមានការលំបាកដោយសារឥស្សរជននយោបាយមិនអាចជួបសុំការបំភ្លឺបាន។

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវលើប្រធានបទនេះ នឹងចូលរួមជាវិភាគទានដ៏សំខាន់ ខាងផ្នែកសតិស្មារតីចំណេះដឹងលើវិស័យនយោបាយនៅកម្ពុជា ហើយក៏ជាឯកសារស្រាវជ្រាវបែបវិទ្យាសាស្ត្រមួយថ្មីថែមទៀត ដែលបំពេញឲ្យសេចក្តីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ ដែលបាននឹងកំពុងជួបប្រទះកង្វះខាតឯកសារ ព្រមទាំងចូលរួមជាទស្សនាទានដ៏សំខាន់ក្នុងកិច្ចការអភិវឌ្ឍន៍សង្គមជាតិដោយនិរន្តរភាព និងអាចបញ្ចៀសបាននូវភាពខុសឆ្គង ដែលលេចឡើងនៅក្នុងដំណើរការនយោបាយប្រជាធិបតេយ្យនៅកម្ពុជាកន្លងមក ហើយវាក៏វាត្រីវិស័យសម្រាប់អ្នកនយោបាយគ្រប់លំដាប់ថ្នាក់។ ជាពិសេសមានភាពងាយស្រួលសម្រាប់អ្នកស្រាវជ្រាវបន្តទៀត ក្នុងផ្នែកវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រផងដែរ និងទុកជាសម្បត្តិវប្បធម៌ដ៏មានតម្លៃរបស់ជាតិ និងបន្សល់ទុកជាស្នាដៃសម្រាប់អ្នកសិក្សា និងកូនចៅជំនាន់ក្រោយឲ្យបានយល់ជ្រាប និងជាលំអានសម្រាប់ជាមូលដ្ឋានដំណើរជីវិត និងសង្គមរបស់យើងទាំងអស់គ្នា។

ការសិក្សាស្រាវជ្រាវនេះ បានផ្តោតជាសំខាន់លើសិទ្ធិសេរីភាពខាងនយោបាយប៉ុណ្ណោះ។ ក្នុងបរិបទ

ប្រជាធិបតេយ្យភាវូបនីយកម្ម មានសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋជាច្រើនទៀត ដែលអ្នកសិក្សាស្រាវជ្រាវឯទៀត អាចលើកយកមកសិក្សាស្រាវជ្រាវបន្ត ដើម្បីបំពេញសេចក្ដីខ្វះខាតលើការសិក្សារបស់ខ្ញុំបាទ។

## ១.៧. របកគំហើញនៃការស្រាវជ្រាវ

រាជរដ្ឋាភិបាលកំពុងតែតម្រង់ទិសឆ្ពោះទៅតាមផ្លូវនីតិរដ្ឋ នៅលើវិថីប្រជាធិបតេយ្យនីយកម្ម ដើម្បីលើកស្ទួយសិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋទៅតាមគោលការណ៍សកលស្ដីអំពីប្រជាធិបតេយ្យ។ ជាមួយគ្នានេះដែរ យើងសង្កេតឃើញថា តាមលទ្ធផលនៃការសិក្សាបានបង្ហាញថា សិទ្ធិសេរីភាពប្រជាពលរដ្ឋផ្នែកនយោបាយនៅមានកម្រិតស្ថិតនៅឆ្ងាយពីបទដ្ឋានប្រជាធិបតេយ្យជឿនលឿនគឺ បណ្ដាលមកពីហេតុផលៈ ទី១- ចំណេះដឹងរបស់ម្ចាស់អំណាចស្ដីអំពីសក្ដានុពលនៃសិទ្ធិ និងអំណាចនៅក្នុងរបបប្រជាធិបតេយ្យនៅមានកម្រិត និងពីភាពក្រីក្រ។ ប្រជាពលរដ្ឋខ្មែរភាគច្រើនពុំសូវតាមដានព័ត៌មាន ក៏ដូចជាពុំសូវមានចំណេះដឹងផ្នែកពលរដ្ឋវិទ្យាឡើយ ជាហេតុធ្វើឲ្យគាត់ពុំមានមូលដ្ឋាន ដើម្បីសម្គាល់រកមេដឹកនាំណាដែលមានកម្រិតសីលធម៌ខ្ពង់ខ្ពស់ ភាពប៉ិនប្រសព្វ ភាពឈ្លាសវៃ ការទទួលខុសត្រូវ មានចក្ខុវិស័យចាក់ឆ្លុះក្នុងការដឹកនាំប្រទេសជាតិឡើយ ពេលការជ្រើសរើសរបស់ប្រជាពលរដ្ឋសំដៅទៅលើការស្រឡាញ់ពេញចិត្ត អាចនិយាយលេងសើចបានបែបមនោសញ្ចេតនា និងផ្អែកតាមគុណស្រ័យទៅវិញ។ ឯភាពក្រីក្រក៏ជាឧបសគ្គក្នុងការអនុវត្តន៍សិទ្ធិសេរីភាព និងអំណាចរបស់ខ្លួនផងដែរ។ ប្រជាពលរដ្ឋម្ចាស់ឆ្នោតយកពេលវេលាស្ទើរតែទាំងស្រុងប្រកបដោយការងារចិញ្ចឹមជីវិតរបស់ខ្លួន ពុំចាប់អារម្មណ៍អំពីតម្លៃនៃសិទ្ធិសេរីភាពអំណាចរបស់ខ្លួន និងតួនាទីរបស់រដ្ឋាភិបាលឡើយ។ ប្រជាពលរដ្ឋមួយចំនួន បានដោះដូរសន្លឹកឆ្នោតរបស់ខ្លួនទៅនឹងរបស់របរបន្តិចបន្តួចដើម្បីបំពេញសេចក្ដីខ្វះខាត និងខ្លះទៀតមិនបានចូលរួមបោះឆ្នោតទេ ដោយសាររវល់នឹងបំពេញការងារ ។ល។ និង ។ល។ ទី២- បណ្ដាលមកពីប្រពៃណីគ្រប់គ្រង និងភាពភ័យខ្លាចនៃប្រជាជនខ្មែរ។ ភាគច្រើនប្រវត្តិនៃការរស់នៅរបស់ប្រជាជនខ្មែរធ្លាប់រស់នៅក្នុងរបបដឹកនាំផ្ដាច់ការសក្ដិភូមិច្រើនជាងធ្លាប់រស់នៅក្នុងស្ថេរភាព សុខសន្តិភាព ជាពិសេសរបបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ១៩៧៥-១៩៧៩ ជារបបមហាវិនាសកម្ម ដែលបានបន្សល់ទុកនូវមរតកឈឺចាប់ខ្លោចផ្សាពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រខ្មែរ ធ្វើឲ្យប្រជាពលរដ្ឋ បាក់ស្បាត រៀងចាល ភ័យខ្លាចរហូតមកដល់សព្វថ្ងៃនេះ។ ទី៣- ទោះបីជារដ្ឋធម្មនុញ្ញ បានចែងអំពីការបែងចែកអំណាចពីអង្គការធំទាំងបីរបស់រដ្ឋក៏ដោយ ក៏នៅក្នុងការអនុវត្តន៍ជាក់ស្ដែងគឺ ពិបាកនឹងញែកឯករាជ្យភាពនៃអង្គការរដ្ឋទាំងបីឲ្យដាច់ស្រឡះពីគ្នាណាស់ ដោយសារអង្គនីតិប្រតិបត្តិតែងមានឧត្តមភាពលើអង្គតុលាការទាំងរូបភាពនៃការផ្ដល់ធនធាននានាដល់តុលាការ ឬក្នុងការតែងតាំងតំណែងផ្សេងៗ លើវិស័យតុលាការ។ ទី៤- តំណែងថ្នាក់ដឹកនាំស្ថាប័នស្នងការនគរបាលជាតិ អគ្គមេបញ្ជាការកងយុទ្ធពលខេមរភូមិន្ទ និងអគ្គមេបញ្ជាការកងរាជអាវុធហត្ថ មិនមែនជាមនុស្សឯករាជ្យ និងអព្យាក្រឹតទេ ពោលគឺថាសមាសភាពដឹកនាំចេញមកពីមន្ត្រីជាន់ខ្ពស់របស់គណបក្សនយោបាយ ហើយត្រូវតែងតាំងឲ្យដឹកនាំស្ថាប័នរដ្ឋទាំងនេះដោយនាយករដ្ឋមន្ត្រីនិងទី៥-តំណែងគណៈ-

អភិបាលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ទូទាំងប្រទេសត្រូវបានរៀបចំចាត់តាំងដោយអំណាចរដ្ឋាភិបាលដែរ។ ទម្រង់ដែលលើកមកនេះ គឺជាហេតុផលចម្បងដែលធ្វើឲ្យអំណាចរបស់រដ្ឋាភិបាលមានលក្ខណៈប្រមូលផ្តុំ ឯប្រជាពលរដ្ឋគឺមានតែសិទ្ធិ តែអំណាចប្រើសិទ្ធិសេរីភាពទាំងនេះ គឺនៅមានកម្រិតទាបបំផុត ពិសេស អំណាចក្នុងការប្រើសិទ្ធិខាងនយោបាយ ដែលជាកម្មវត្ថុដ៏រឹងមាំនៃអំណាចនយោបាយក្នុងចលនាប្រជាធិបតេយ្យ។

ក្រោយពីបានសិក្សាលើប្រធានបទខាងលើរួចមក ខ្ញុំបាទសូមផ្តល់ជាទស្សនាទានមួយចំនួន ដែលជាដំណោះស្រាយដ៏ល្អសម្រាប់វប្បធម៌សិទ្ធិសេរីភាពខាងនយោបាយក្នុងបរិបទប្រជាធិបតេយ្យ ដូចខាងក្រោមនេះ :

-ត្រូវបង្កើនការអប់រំទាំងផ្នែកចំណេះដឹងបច្ចេកទេស ទាំងផ្នែកពលរដ្ឋវិជ្ជា ដាំបណ្តុះចំណេះដឹងស្តីអំពីភាពចាំបាច់ និងសារៈសំខាន់នៃសិទ្ធិសេរីភាព អំណាច ប្រជាធិបតេយ្យ ភាពជាម្ចាស់ ក្រមសីលធម៌ សេចក្តីក្លាហាន ការតស៊ូអត់ធ្មត់ និងដាំបណ្តុះស្មារតីសាមគ្គីសហប្រតិបត្តិការក្នុងការរស់នៅ។

-ត្រូវកម្រិតអំណាចឲ្យកាន់តែជាក់លាក់តាមស្ថាប័នជាតិកំពូលទាំងបី ដើម្បីឲ្យមានការគោរពគោល-ការណ៍តុល្យភាពអំណាចពិតប្រាកដ ដោយត្រូវហាមឃាត់អនុម័តបញ្ញត្តិជាច្បាប់ មិនអនុញ្ញាតឲ្យមន្ត្រីរបស់គណបក្សនយោបាយមកដឹកនាំស្ថាប័នឯករាជ្យ អព្យាក្រឹត ដូចជាតំណែងអគ្គមេបញ្ជាការកងយោធពលខេមរ-ភូមិន្ទ អគ្គស្នងការនគរបាលជាតិ និងមេបញ្ជាការកងរាជអាវុធហត្ថឡើយ ពោលត្រូវជ្រើសរើសបុគ្គលឯករាជ្យ អព្យាក្រឹត ដាច់ចេញពីនយោបាយ ទើបរក្សាបាននូវជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងជាពិសេសគឺជាសមាស-ធាតុមួយក្នុងចំណោមសមាសធាតុដទៃទៀត ដែលជានារបៀបរបបដឹកនាំរដ្ឋមួយ ដែលចាក់គ្រឹះរឹងមាំ មិនអាចដួលរលំដោយសារមានបញ្ហាប្រឈមផ្នែកនយោបាយកើតឡើង និងម្យ៉ាងទៀត គឺសមស្របតាមគោលការណ៍សកលស្តីអំពីលទ្ធិប្រជាធិបតេយ្យដែលបានតម្រូវឲ្យមានគោលការណ៍តុល្យភាពអំណាចរបស់ស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងស្ថាប័នតុលាការ ដែលជាស្ថាប័នកំពូលរបស់ជាតិមានអំណាចដាច់ដោយឡែក ឯករាជ្យ និងត្រួតពិនិត្យគ្នាទៅវិញទៅមក និងមិនអនុញ្ញាតឲ្យរំលោភលើគ្នាឡើយ។

-ស្ថាប័ននីតិបញ្ញត្តិ ដែលជាតំណាងផ្ទាល់របស់ប្រជាពលរដ្ឋមានបេសកកម្មរបស់ខ្លួនគឺ ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងត្រួតពិនិត្យរាល់ការអនុវត្តន៍របស់នីតិប្រតិបត្តិ ចាំបាច់ត្រូវប្តេជ្ញាចិត្តម៉ឺងម៉ាត់ មានសេចក្តីក្លាហានហ៊ានអនុវត្តអំណាចរបស់ខ្លួនដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីពង្រឹងអំណាចរបស់ស្ថាប័នកំពូលរបស់ជាតិមួយនេះ ឲ្យក្លាយទៅជាស្ថាប័នជាតិមានអំណាចឯករាជ្យ និងជាស្ថាប័នតំណាងឲ្យអំណាចប្រជាពលរដ្ឋម្ចាស់ប្រទេស ម្ចាស់អំណាច ពិតប្រាកដ និងមានសក្តានុពលរឹងមាំដូចបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ពោលគឺ ត្រូវប្រែក្លាយស្ថាប័នដ៏ទន់ខ្សោយនេះទៅជាស្ថាប័នតំណាងឲ្យអំណាចប្រជាពលរដ្ឋដ៏មានឥទ្ធិពលខ្លាំងក្លា សម្រាប់ជាមរតករបស់ប្រជាជាតិ មិនអាចស្ថាប័នដទៃរំលោភអំណាចបាន និងត្រូវធ្វើយ៉ាងណាជានាថា ស្ថាប័នជាតិទាំងនេះមិនមែនជាស្ថាប័នតំណាងគណបក្សនយោបាយ។

-ត្រូវរៀបចំអនុម័តច្បាប់ ស្តីពីការបោះឆ្នោតជាសកលផ្ទាល់ពីប្រជាពលរដ្ឋ សម្រាប់ជ្រើសរើសក្រុមប្រឹក្សា

និងគណៈអភិបាលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ទូទាំងប្រទេស ដោយយកតាមទម្រង់ការបោះឆ្នោតជាសកល ស្ដីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

-ត្រូវរៀបចំអនុម័តច្បាប់ស្ដីពីឧត្ដមក្រុមប្រឹក្សាការពារជាតិ ដើម្បីឧត្ដមក្រុមប្រឹក្សាការពារជាតិមានអំណាច រៀបចំតែងតាំងតំណែងអគ្គមេបញ្ជាការគ្រប់កងកម្លាំងប្រដាប់អាវុធ ចាំបាច់ឲ្យផ្ដល់សេចក្ដីទុកចិត្តលើការតែង តាំងតំណែងនេះពីរដ្ឋសភាជាតិ និងបញ្ញត្តិហាមឃាត់មិនឲ្យមន្ត្រីបំពេញនាទីជាកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាប់ពាក់ព័ន្ធនឹងគណបក្សនយោបាយ ព្រមទាំងបញ្ញត្តិបញ្ជាក់ពីទោស ទណ្ឌកម្មផងដែរ ករណីអនុវត្តផ្ទុយ នឹងច្បាប់។

-ធ្វើច្បាប់អព្យាក្រឹតចំពោះមន្ត្រីរាជការទូទាំងប្រទេស។

-ធ្វើច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញាដាច់ដោយឡែកពីច្បាប់ស្ដីពីមន្ត្រីរាជការស៊ីវិល និង ត្រូវរៀបចំអនុម័តច្បាប់ស្ដីពីការបង្កើតតុលាការជូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដោយត្រូវរៀបចំរចនាសម្ព័ន្ធរូបវន្តនិង សមាជិកឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម សមាសភាពចៅក្រម ព្រះរាជអាជ្ញា នៅគ្រប់សាលាជនុំជម្រះក្ដី ទាំង២៤រាជធានី/ខេត្ត ដោយជ្រើសរើស(បោះឆ្នោត)ចេញពីបុគ្គលអព្យាក្រឹតភាព ឯករាជ្យ និងបញ្ញត្តិពីកម្រិត វិជ្ជាជីវៈ និងដាច់ខាតមិនត្រូវជ្រើសរើសចេញពីមន្ត្រីរបស់គណបក្សណាមួយនោះទេ។ ពោល គឺត្រូវធ្វើឲ្យទៅជា ស្ថាប័នជាតិ ដែលអាចធានាយុត្តិធម៌ដ៏មានអនុភាព សម្រាប់ប្រជាជាតិទាំងមូល និងមិនមែនជារបស់ គណបក្សនយោបាយ មិនមែនជារបស់អ្នកមានអំណាច និងមិនមែនជារបស់អ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភនោះ ទេ។ ដើម្បីធានាស្ថេរភាពនយោបាយ សន្តិសុខ និងទទួលបានភាពជឿទុកចិត្តពីប្រជាពលរដ្ឋ និងអ្នក វិនិយោគទុនផ្ទាល់បរទេស តាមរយៈធ្វើឲ្យយុត្តិធម៌មានឧត្ដមភាពទៅលើនយោបាយផ្ដាច់ការ។

-រៀបចំតាក់តែងច្បាប់ ដើម្បីធ្វើឲ្យស្ថាប័នព្រះរាជអាជ្ញាមានឯករាជ្យភាពជាក់ស្ដែង។

**ផលប្រយោជន៍នៃការសិក្សា:**

តាមរយៈស្នាដៃសិក្សាស្រាវជ្រាវនេះ នឹងនាំទៅដល់ការចូលរួមកែលំអរបៀប និងប្រព័ន្ធដឹកនាំប្រទេស ដែលកំពុងតែប្រមូលផ្ដុំអំណាចស្ទើតែទាំងស្រុងលើកណ្ដាប់ដៃតំណែងនាយករដ្ឋមន្ត្រី ឲ្យបែរមករៀបចំប្រព័ន្ធ ដឹកនាំប្រទេសតាមគោលការណ៍ប្រជាធិបតេយ្យពិតប្រាកដ។ ដោយលើកបង្ហាញភ្ជាប់ពីកាតព្វកិច្ចនិងភារកិច្ច របស់ប្រជាពលរដ្ឋ ព្រមទាំងជំរុញលើកទឹកចិត្តម្ចាស់ឆ្នោត ម្ចាស់អំណាច ម្ចាស់ប្រទេស ឲ្យចូលរួមបានយ៉ាង សកម្ម ក្នុងចរន្តប្រជាធិបតេយ្យប្រកដដោយស្មារតីទទួលខុសត្រូវគ្រប់គ្នា។

ជាចំណុចចាប់ផ្ដើមដំបូងៗ នៃការលើកយកចំណុចរសើបនៃសំណុំព័តមានស្ដីពិផ្នត់គំនិត ឥរិយាបទ នៃ អ្នកដឹកនាំប្រទេសក្នុងបរិបទអំណាចនយោបាយនៅកម្ពុជា ដែលមិនធ្លាប់លេចឡើងនៅក្នុងរបបដឹកនាំប្រទេស ប្រជាធិបតេយ្យជឿនលឿននានាលើសកលលោក ដែលអាចធ្វើជាមូលដ្ឋានសម្រាប់អ្នកសិក្សាស្រាវជ្រាវក្រោយ លើកយកមកសិក្សាបន្តទៀត ក្នុងទិសដៅទ្រទ្រង់ស្ថេរភាពនយោបាយឲ្យស្ថិតក្នុងសុខសន្តិភាព និងអភិវឌ្ឍ។

## ១.៨. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សានិក្ខេបបទនេះ មានចំនួន២១៨ទំព័រ ហើយត្រូវបានបែងចែកជា៥ជំពូក ដូចខាងក្រោមនេះ :

**ជំពូកទី១: សេចក្តីផ្តើម** : ជំពូកនេះបានបង្ហាញពីលំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការសិក្សាស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ របកគំហើញនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ(មានចំនួន១៣ទំព័រ ចាប់ពីទំព័រទី១ ដល់ទំព័រទី១៣)។

**ជំពូកទី២ : ទស្សនៈទូទៅស្តីពីសិទ្ធិពលរដ្ឋ** (មានចំនួន៥៩ទំព័រ ចាប់ពីទំព័រទី១៤ ដល់ទំព័រទី៧២)។

**ជំពូកទី៣ : ស្ថានភាពអនុវត្តសិទ្ធិពលរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា** : ជំពូកនេះបង្ហាញពីការអនុវត្តន៍កតិកាសញ្ញាស្តីពីសិទ្ធិនយោបាយ និងសិទ្ធិសង្គម។ (មានចំនួន៨៣ទំព័រ ចាប់ពីទំព័រទី៧៣ ដល់ទំព័រទី១៥៥)។

**ជំពូកទី៤ : វិភាគលើការប្រើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ** : (មានចំនួន៦៤ទំព័រ ចាប់ពីទំព័រទី១៥៦ ដល់ទំព័រទី២១៩)។

**ជំពូកទី៥ : សន្និដ្ឋាន និងអនុសាសន៍** : ជំពូកនេះធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបទៅលើគ្រប់ចំណុចដែលបានវិភាគ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលំអ។ (មានចំនួន ៧ទំព័រ ចាប់ពីទំព័រទី២២០ ដល់ទំព័រទី២២៦)។

# ជំពូកទី២

# ទស្សនៈទូទៅស្ដីអំពីសិទ្ធិពលរដ្ឋ

# ជំពូកទី២
# ទស្សនៈទូទៅស្ដីអំពីសិទ្ធិពលរដ្ឋ

## ២.១. និយមន័យ នៃសិទ្ធិពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ

មានការពិភាក្សារបស់អ្នកសិក្សាជាច្រើនស្ដីពីនិយមន័យ និងខ្លឹមសារទូទៅស្ដីពី សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងប្រជាធិបតេយ្យ។ ដោយឡែកការសិក្សាស្រាវជ្រាវនេះ គ្មានបំណងលើកយកមកបកស្រាយសារឡើងវិញ ចំពោះការអត្ថាធិប្បាយរបស់អ្នកសិក្សាទាំងនោះឲ្យបានវែងឆ្ងាយនោះទេ ពោលគឺគ្រាន់តែបំភ្លឺបន្ថែម អំពីខ្លឹមសារជាសារវន្តនៃគោលការណ៍គំនិតដែលនឹងយកមកប្រើប្រាស់ដើម្បីធ្វើការសិក្សាតែប៉ុណ្ណោះ។

ចំពោះឃ្លាស្ដីអំពីសិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជានេះ ដើម្បីយល់បានកាន់តែច្បាស់ សូមលើកយកពាក្យចំនួន **បួន** ដែលចាំបាច់ធ្វើការពន្យល់គឺ:

**សិទ្ធិ** : ប្រភេទជានាម : មានន័យថា សេចក្ដីសម្រេច, សេចក្ដីសម្រេចផល ឬផលសម្រេច, ការសម្រេចប្រយោជន៍ខ្លាំងពូកែ សេចក្ដីសម្បូណ៌, សេចក្ដីសម្រេចតាមអំណាចច្បាប់, អំណាច, សេចក្ដីអង់អាចមុខការដែលត្រូវសម្រេចលើខ្លួន[១]។

**សិទ្ធិ** បើនិយាយក្នុងលក្ខណៈច្បាប់ គឺសំដៅទៅលើការមិនបើកចំហ ការអនុញ្ញាតដោយច្បាប់។

**សេរីភាព** : Freedom:(noun) ១- it means the right to do or to say what you want without anyone stopping you: freedom of speak /thought/exression/ worship[២]. –a threath to press/ academic freedom –rights and freedoms guaranteed by the constitution- freedom of information(= the right to see secret information that government has about people and organizations). ២- the state of being able to do what you want, without anything stopping you: freedom of actions/ choice- complete freedom to do as you wish. ១: មានន័យថា សិទ្ធិក្នុងការធ្វើអ្វី ឬនិយាយអ្វីដោយគ្មានអ្នកណាអាចមកបញ្ឈប់ ឬរាំងបានឡើយដូចជា: សេរីភាពក្នុងការនិយាយ, ការគិត, ការសម្ដែងមនោសញ្ចេតនា, ការស្រឡាញ់ សេរីភាពនៃការសិក្សា ។ល។ សិទ្ធិ និងសេរីភាពទាំងនេះ ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ដូចជា សិទ្ធិសេរីភាពខាងសារព័ត៌មាន(សិទ្ធិក្នុងការមើលការសម្ងាត់របស់រដ្ឋាភិបាល ដែលទាក់ទងចំពោះប្រជាពលរដ្ឋ និងសង្គមស៊ីវិល)។ ២: រដ្ឋាភិបាលមានកាតព្វកិច្ច សម្រួលឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោតធ្វើនូវអ្វីដែលគេចង់ដោយសន្តិវិធី ដោយគ្មានអ្វីមករារាំង ជ្រៀតជ្រែក ឬបញ្ឈប់ឡើយ

---

[១] ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត: វចនានុក្រមខ្មែរ ភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រ ១៣៧៩

[២] UgeHornby. A S: Oxford Advanced Learner's Dictionary of Current English by Sally Wehmeir Phonetics Editor Michael ashby, China ,p.596.

ដូចជា សេរីភាពក្នុងការធ្វើសកម្មភាព សេរីភាពក្នុងការជ្រើសរើស។ ឬរដ្ឋបាល ដែលមានប្រជាជនជាធំក្នុងការជ្រើសរើសតំណាងរបស់ខ្លួន ដើម្បីឲ្យធ្វើជាអ្នកសម្រេចកិច្ចការក្នុងប្រទេសជំនួសប្រជាពលរដ្ឋ[៣]។

**សេរីភាព** ចែកជាពីរយ៉ាងៈ ១-សេរីភាព(Freedom also) មានន័យថា សេរីភាពបានពីណា ឬទាក់ទងទៅនឹងនរណា។ ២-សេរីភាព-ដើម្បី(Freedom for) មានន័យថា ជាសមត្ថភាពនៃការបង្កបង្កើត ការអភិវឌ្ឍន៍ ការបង្ហាញទង្វើទៅលើការពន្យល់បកស្រាយបំភ្លឺនូវអ្វីមួយ ដូចជាស្នាដៃវិស្វករ វិចិត្រករជាដើម។ ឧទាហរណ៍ ដើម្បីមានពេលទំនេរសម្រាកពីការងារ គប្បីត្រូវបំពេញភារកិច្ចរបស់ខ្លួនបានចប់បរិបូរណ៍ជាមុនសិន។ សេរីភាពជាធាតុផ្សំដ៏មានសារៈសំខាន់មួយក្នុងការកសាងសង្គមប្រជាធិបតេយ្យ ដែលមានលក្ខណៈមួយពេញលេញ។ សេរីភាពត្រូវបានបែងចែកទៅតាមតំបន់ ទៅតាមលំអានទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជាតិនីមួយៗក្នុងពិភពលោក ដូចជាៈ នៅបណ្តាប្រទេសអឺរ៉ុបប៉ែកខាងលិច សេរីភាព គឺត្រូវបានកំណត់តាមច្បាប់នីតិក្រម (ច្បាប់រដ្ឋធម្មនុញ្ញ)។ បើនៅប្រទេសអឺរ៉ុបប៉ែកខាងកើត សេរីភាព គឺស្ថិតនៅលើការដើរដង្ហែរក្បួននានា ដូចជាៈ ការធ្វើបាតុកម្ម កុប្បកម្ម បុណ្យជ័យជម្នះ ការកៀរគរជាក្រុមប្រឆាំងចំពោះការមិនពេញចិត្តនឹងអ្វីមួយជាដើម។ ដោយឡែកសេរីភាពបែបឥណ្ឌា គឺឲ្យតម្លៃទៅលើការជ្រើសរើសប្រើប្រាស់គ្រឿងអលង្ការ មានន័យថា សេរីភាពកាន់តែច្រើនឡើងនៅពេលណាដែលគេអាចពាក់អលង្ការបានច្រើន។ ចំណែកឯសេរីភាពបែបអាមេរិកកាំង គឺស្ថិតនៅលើភាពសេរីនិយម(Beralism) គឺគេនិយមអ្វីៗដែលថ្មីប្លែក។

ផ្តើមចេញពីសេរីភាពរបស់បណ្តាប្រទេសខាងលើ និងដើម្បីជ្រាបច្បាស់ ពីភាវរស់នៃសេរីភាពរបស់ខ្មែរ សូមធ្វើការវិភាគដូចខាងក្រោមៈ

សេរីភាពបែបព្រះពុទ្ធសាសនាខ្មែរ(សេរីភាពខាងស្មារតីក្រមសីលធម៌) នៅក្នុងមេរៀនព្រះពុទ្ធ គឺបទដ្ឋានសម្រាប់មនុស្សទូទៅក្នុងលោកទាំងអស់គ្នា។ សេរីភាពនៃការសំអាតចិត្តដ៏បរិសុទ្ធ(ធម្មជាតិនៃចិត្ត) ដោយកំចាត់ ឬរំលត់ ឫសគល់អាសវៈ(គ្រឿងសៅហ្មង)ទាំងឡាយ ភាពគ្រោតគ្រៀត សេចក្តីស្អប់ខ្ពើម ភាពកំណាញ់ស្វិតអំពើអាក្រក់ ភាពយង់ឃ្នង ព្រៃផ្សៃឲ្យអស់ ដើម្បីជានានូវភាពបរិសុទ្ធរបស់ខ្លួន បទដ្ឋាននេះ គឺជាបន្ទាត់សម្រាប់មនុស្សលោកទាំងអស់គ្នា ប៉ុន្តែកម្រិតអប់រំបណ្តុះបណ្តាលបញ្ញាញាណរបស់មនុស្សម្នាក់ គឺខុសៗគ្នាដែលធ្វើឲ្យការកំណត់សិទ្ធិសេរីភាពក៏ខុសគ្នាដែរ។ សេរីភាពរបស់ប្រជាពលរដ្ឋខ្មែរ គេឃើញតាមរយៈការនិយមលែងសត្វឲ្យចេញពីទ្រុង ដូចជាលែងសត្វចាប លែងសត្វអណ្តើកជាដើម មានន័យថា មានសេរីភាពទាំងកាយទាំងចិត្ត នេះជាសេរីភាពឥតព្រំដែនកំណត់ច្បាស់លាស់។ នេះជាទម្លាប់មួយដែលលំបាកខ្លាំង ដើម្បីកែផ្នត់គំនិតពត់ឥរិយាបថ តាមរបៀបរបបអនុវត្តប្រជាធិបតេយ្យបច្ចុប្បន្ននៅកម្ពុជា។ តាមការសិក្សាឃើញថា មេរៀនព្រះពុទ្ធសាសនា ដែលខ្មែរគោរពប្រតិបត្តិបានផ្តល់ផលវិជ្ជមានដ៏សំខាន់ទាក់ទងទៅនឹងប្រព័ន្ធដឹកនាំ ដោយបានជួយពង្រឹងដាំបណ្តុះបញ្ញាញាណ និងស្មារតីឲ្យមនុស្សខ្មែរជឿ ដោយសេចក្តីអង់អាចក្លាហាន មានទំនោរ

[៣] ខៀវ ជុំ : ប្រជាធិបតេយ្យចាស់ទុំ ភ្នំពេញ ឆ្នាំ១៩៧២ ទំព័រ ៩, ១០

ទន់ភ្លន់តែរឹងមាំដោយសទ្ធាជ្រះថ្លា(ការយល់សព្វគ្រប់ចំពោះបញ្ហាណាមួយ) ដោយសទ្ធាសម្បយុត្តការណ៍នេះពុំមែនជាការដាក់ទណ្ឌកម្មខ្លួនឯង ដើម្បីទទួលយកសច្ចភាពនោះទេ គឺកើតឡើងដោយសេរីភាពអមដោយយល់ជឿជាក់របស់ខ្លួន ព្រមទាំងបង្រៀនឲ្យខ្មែរ និងមនុស្សទាំងឡាយក្នុងលោក ចាំបាច់ត្រូវគិតពីបច្ចុប្បន្នជាតិ ព្រោះបើបច្ចុប្បន្នជាតិនេះមានស្ថានភាពល្អ នោះអ្វីៗក៏ល្អនៅក្នុងជាតិក្រោយដែរ តែបើស្ថានភាពបច្ចុប្បន្នមិនបានល្អនោះអ្វីៗនៅពេលអនាគតក៏ពុំបានល្អដែរ។ ព្រះពុទ្ធមិនបានបង្រៀន និងបង្គាប់បញ្ជាឲ្យមនុស្សខ្មែរនិងមនុស្សលោកឲ្យជឿលើព្រេងវាសនា ដែលព្រះប្រទានឲ្យនោះទេ។ មេរៀនព្រះសម្ពុទ្ធ ពុំបានសរសេរទុកថា អ្នកនេះត្រូវធ្វើលោកធំ អ្នកនេះមិនអាចដឹកនាំ ឬខ្ញុំគេនោះទេ ព្រះសម្ពុទ្ធបង្រៀនមនុស្សលោកត្រូវប្រយុទ្ធយកឈ្នះ មាសត្រូវគ្រប់ទិសទី ជាពិសេសមាសត្រូវនៅក្នុងខ្លួនរបស់សត្វលោក(អំពើអាក្រក់ទាំងឡាយ) ដែលពិបាកកំចាត់ជាងគេ ហើយបានយកឈ្នះមាសត្រូវជាមនុស្ស ដូចជា អង្គុលីមា ទេវទត្ត ជាដើម គឺផ្ចាញ់ដោយសេចក្តីសង្គ្រោះ សេចក្តីស្រឡាញ់ ដែលទីបំផុតបាននាំឲ្យអង្គុលីមា បានសម្រេចជាព្រះអរហន្ត(លែងវង្វេង ក្នុងវដ្តតទៅទៀត) មានន័យថា ព្រេងវាសនារបស់មនុស្សម្នាក់ៗ គឺស្ថិតនៅក្នុងដៃខ្លួនឯង ខ្លួនទីពឹងខ្លួន (អត្តនោ-នាថោ)។ ឯការដាក់ខ្លួនឲ្យចូលក្នុងកម្មវត្ថុនៃការគាបសង្កត់ ទណ្ឌកម្មដូចបានឃើញនៅសង្គមកាលពីអតីតកាល ឧទាហរណ៍ ការកាប់សម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ដោយយកប្រជាជនខ្មែរទាំងខ្សែៗទៅសម្លាប់... ការសុខចិត្ត ឬមិនហ៊ានតវ៉ា... គឺបណ្តាលមកពីមិនទាន់យល់ ឬយល់ខុស អំពីគោលបំណង និងទិសដៅពិតប្រាកដពីមេរៀនព្រះសម្ពុទ្ធ។ ករណីនៅក្នុងកាលៈទេសៈសង្គ្រាម ប្រជាពលរដ្ឋខ្មែរក៏ដូចជាអ្នកនយោបាយដឹកនាំកំពូលៗ បាននាំគ្នាបួងសួង សុំកម្លាំងជំនួយពីព្រះឥន្ទ្រ ព្រះព្រហ្ម ទេវតា អារក្ស អ្នកតាឲ្យតាមជួយថែរក្សាទ្រទ្រង់ការពារការងាររបស់ខ្លួន ដែលអំណាចនេះទោះបីពិតឬមិនពិតគឺវាស្ថិតនៅអាថ៌កំបាំងរបស់សិល្បៈធម្មជាតិដែលត្រូវទុកឲ្យអ្នកវិទ្យាសាស្ត្រជាអ្នកបកស្រាយផ្តល់ចម្លើយ។លើសពីនេះការគោរព ប្រតិ-បត្តិមេរៀនរបស់ព្រះពុទ្ធក៏បានផ្តល់ផ្នែកចរិយាធម៌ សីលធម៌ ផងដែរដូចជាៈ ទឹកចិត្តជ្រះថ្លា ចិត្តសប្បុរស ស្មារតីសន្តិភាព ជឿបាប ជឿបុណ្យ ការលើកលែងអធ្យាស្រ័យទោសកំហុស ការសម្បទានឲ្យគ្នាទៅវិញទៅមក ការយោគយល់គ្នា ភក្តីភាពពិតប្រាកដ បោះបង់គំនុំ ផ្សាយមេត្តាចិត្ត មានន័យថា សេចក្តីស្អប់មិនអាចបញ្ចប់បានសេចក្តីស្អប់ទេ ប៉ុន្តែសេចក្តីស្អប់ពិតជាអាចបញ្ចប់សេចក្តីស្រឡាញ់ចេញពីបេះដូងពិតៗ ទើបមានសន្តិភាព សេចក្តីរីកចម្រើន។ បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា មានច្បាប់ទម្លាប់គ្រប់គ្រាន់ល្មម ដើម្បីអនុវត្តក្នុងជីវិតធម្មតា និងក្នុងស្ថាប័នរដ្ឋផងដែរ ប៉ុន្តែខ្មែរទាំងអស់ចូលចិត្តរស់នៅតាមប្រពៃណីទំនៀមទម្លាប់ ដែលមាននៅក្នុងដួងព្រលឹងរាប់ពាន់ឆ្នាំដដែល។ តាមលំអាននៃផ្នត់គំនិត និងអត្តចរិតខ្មែរ ពុំទាន់បានបែងចែកដាច់ស្រឡះនូវធាតុផ្សំរវាងជីវិតរស់នៅធម្មតា និងជីវភាពក្នុងនយោបាយរបស់ខ្លួនពីជំនឿលើមន្តអាគមអូមអាម ព្រេងវាសនា ជោគជាតារាសីជាដើមនៅឡើយ។ ការសិក្សាផ្នែកសង្គមវិជ្ជាបានចេញស្ថិតិបញ្ជាក់ថាប្រជាពលរដ្ឋខ្មែរប្រហែល៨០% បានជឿស៊ុបទៅលើបាតុភូតនេះ។ ចិត្តវិទូស្ត្រីបារាំងម្នាក់ ដែលបានរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងយូរកន្លងមកហើយបានសរសេរទុកថាៈ សង្គមខ្មែរមិនមែនជាសង្គមសនិទានទេ

ពួកគេរស់នៅពោរពេញ ជំនឿទៅលើភាពអច្ឆរិយ និងមន្តអាគមគាថា ហើយងាយស្រួលភាន់ច្រឡំទៅរកផ្លូវអាក្រក់ ដូចជា សេចក្តីស្អប់អំពើហិង្សា មើលមិនឃើញនូវអ្វីដែលល្អ អ្វីដែលត្រឹមត្រូវ ជាសច្ចធម៌។ ចិត្តវិទូរូបនេះ បានបន្តថាៈ ចរិតខ្មែរករណីមានការប្រមាថមើលងាយ ដេរស្តីដោយគ្មានកំហុស គេអាចប្រើអំពើហិង្សាធ្វើទុក្ខបុកម្នេញភ្លាមៗដោយគ្មានពិចារណា[៤]។ បញ្ហាមួយទៀតនៃអត្តចរិតប្រជាពលរដ្ឋខ្មែរ គឺស្ទើរជា និច្ចកាលខ្មែរនិយមចូលចិត្តភាពមិនប្រក្រតីមិនតាមច្បាប់ទម្លាប់។ មនុស្សខ្មែរហាក់ដូចជាមនុស្ស(Tem-perament) ដែលជាបាតុភូតចំឡែកមួយក្នុងសង្គមខ្មែរ តើនេះមកពីខ្មែររស់នៅបានសុខស្រួលតាមវិធីខាងលើ ឬក៏ជាអំណោយផលធម្មជាតិនៃទីតាំងភូមិសាស្ត្រ ឬក៏ជាទំនៀមទម្លាប់?។ ការមិនជឿជាក់លើបញ្ញាញាណបែរជាទៅពឹងផ្អែកឥទ្ធិពលក្រៅខ្លួន(ពឹងបារមី ទេវតា អ្នកតា មន្តអាគមគាថា...។ល។) គឺមិនមែនជាការប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនានោះទេ។ ទង្វើនេះគឺផ្ទុយពីខ្លឹមសារមេរៀនរបស់ព្រះសម្ពុទ្ធទាំងស្រុង។ ការទោរទន់ទៅរកពឹងបារមី ទេវតា អ្នកតា មន្តអាគមគាថា គ្រូទាយ... របស់សង្គមខ្មែរ គឺជាការខ្វះវិចារណញ្ញាណបណ្តាលឲ្យបាត់លំនឹង បាត់ភាពជឿជាក់ បាត់ព្រលឹង បាត់សេចក្តីក្លាហាន។ ការណ៍នេះ ដូចគ្នាទៅនឹងការលើកឡើងរបស់ Hume D.(១៧១១-១៧៧៦) និងលោក Freud Z. (១៨៥៦-១៩៧៣) បានលើកឡើងថាៈ ការផ្តេកទៅដោយសេចក្តីទុក្ខកង្វល់វេទនាច្រើនហួសហេតុពេក ធ្វើឲ្យប្រព័ន្ធស្មារតីរបស់មនុស្សមានសភាពទ្រុឌទ្រោមដែល មូល-ហេតុចម្បងធ្វើឲ្យមនុស្សគ្មានស្មារតី និងគោលជំហររឹងមាំប្រាកដប្រជាក្នុងជីវិតរស់នៅរបស់ខ្លួនទេ[៥]។ ដូច្នេះអាចសន្និដ្ឋានបានថាៈ ជាក់ស្តែងប្រជាពលរដ្ឋខ្មែរបច្ចុប្បន្នមានជម្ងឺម្យ៉ាងឈ្មោះថា "របួសឬពិការហ្សៀន Defective Genius" ដែលពិការភាពទាំងនេះ ពិតជាអាចរីករាលដាលដល់អនាគត ដែលចាំបាច់ត្រូវថ្នាក់ដឹកនាំប្រទេសគ្រប់ស្ថាប័នកំពូលៗ យកចិត្តទុកដាក់លើបញ្ហាសុខភាពផ្លូវចិត្ត(Sanitary mentally nation)។ ជាពិសេសត្រូវយកចិត្តទុកដាក់បំផុតអំពីការលើយកទ្រឹស្តីរបស់ព្រះពុទ្ធមកពន្យល់បកស្រាយ អប់រំ ធ្វើយ៉ាងណាឲ្យចំចំណុចចង់បានរបស់ព្រះសម្ពុទ្ធ ដោយធៀបទៅនឹងវប្បធម៌ខ្មែរ។ ពុទ្ធិរបស់ព្រះពុទ្ធសាសនា ពិតជាបានបង្រៀនបណ្តុះខ្មែរទូទៅឲ្យមានសេចក្តីក្លាហាន ស្មារតីរឹងមាំ ចិត្តសម្បទាន ទាំងនៅក្នុងជីវភាពរស់នៅធម្មតា និងជាពិសេសសម្បទាននៅក្នុងស្ថាប័នដឹកនាំរដ្ឋទៀតផងដែរ ដូចជាការចរចារសម្បទានអំណាចដឹកនាំរដ្ឋរវាងគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា ដើម្បីបង្កើតរដ្ឋាភិបាលអាណត្តិទី១ អាណត្តិទី២ និងអាណត្តិទី៣ ជាដើម។

**ប្រជាធិបតេយ្យ** ត្រូវបានចែកជាពីរបទគឺៈ ប្រជា និងអធិបតេយ្យ។ ប្រជា គឺសំដៅដល់ប្រជាជន, អធិបតេយ្យ គឺភាពជាធំ។ រួមមកប្រជាធិបតេយ្យ គឺប្រជាជនមានភាពជាធំ, ពាក្យនេះមានន័យប៉ុនគ្នា ឬជិតតែនឹងស្មើគ្នា និងពាក្យរបស់អង់គ្លេសថា Democracy មកពីពាក្យ Demokratos។ ពាក្យនេះញែកបានជាពីរៈ Demos មានន័យថា មនុស្ស "ប្រជាជន", Kratos មានន័យថា អំណាច, កាលបើប្រែរួមគ្នាមានសេចក្តីថា ត្រូវ

[៤] LacoutureJ.,MartinM.ALe Mal Cambodien.Paris1989,page 135

[៥] Spent of philosophy dictionary. Misk 1999 pege 778

នឹងពាក្យអង់គ្លេសថា People's power(អំណាចប្រជាជន)។

ពាក្យនិយមរបស់ប្រជាធិបតេយ្យយ៉ាងខ្លីថាៈ ប្រជាធិបតេយ្យ គឺជារូបនៃការគ្រប់គ្រង ឬរបបគ្រប់គ្រង ដែលប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់មានអំណាចខ្ពង់ខ្ពស់បំផុត ព្រមទាំងប្រើអំណាចនេះចំពោះអ្នកតំណាងរបស់ខ្លួន (តំណាងរាស្ត្រ)។

ប្រជាធិបតេយ្យ ជាទម្រង់នៃរបបនយោបាយមួយសម្រាប់គ្រប់គ្រងរដ្ឋ ឬប្រទេសដែលលើកយកប្រជាពលរដ្ឋជាធំ ជាម្ចាស់អំណាច និងជាម្ចាស់ជោគវាសនាប្រទេសជាតិ[៦]។

ប្រជាធិបតេយ្យ សំដៅទៅលើភាពជាធំ ជាកំពូល ជាម្ចាស់អំណាច។ ជាអំណាច ដែលមិនអាចផ្ទេរបាន។ អធិបតេយ្យប្រជាពលរដ្ឋ គឺជាសិទ្ធិអំណាចរបស់ប្រជាជន ឬប្រជាពលរដ្ឋជាធំលើសគេទាំងអស់។ ប្រជាធិប-តេយ្យ ជាភារៈនៃប្រទេសមួយដែលមានប្រជាពលរដ្ឋធ្វើជាអធិបតី ជាប្រទេស ឬ រដ្ឋមួយដែលមានប្រជាជនធ្វើជាធំក្នុងការជ្រើសរើសតំណាងរបស់ខ្លួនឲ្យសម្រេចរាល់កិច្ចការសព្វសារពើ ដែលបម្រើឲ្យផលប្រយោជន៍ទាំងខាងសម្ភារៈ ស្មារតីនិងអាយុជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ជាទម្រង់គ្រប់គ្រងរដ្ឋមួយដោយរដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ... ជាស្ថាប័ននីយកម្មនៃសេរីភាព ជាគំនិត និងគោលការណ៍ស្តីអំពីសេរីភាពទាំងអស់ជាប្រព័ន្ធគ្រប់គ្រងមួយដែលក្នុងនោះប្រជាពលរដ្ឋទាំងអស់របស់ប្រទេសមួយ ត្រូវចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ជារដ្ឋាភិបាលដែលប្រជាពលរដ្ឋទាំងអស់បានអនុវត្តនូវសិទ្ធិសេរីភាព និងអំណាចរបស់ខ្លួន[៧]។

ប្រជាធិបតេយ្យមានន័យថា សមាជិកនៃអង្គការចាត់តាំងមួយមានសិទ្ធិសេរីភាពចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយយុត្តិធម៌ជាមួយនឹងប្រព្រឹត្តិកម្មស្មើៗគ្នា... នៅក្នុងប្រទេសមួយដែលមានប្រព័ន្ធគ្រប់គ្រងតាមលទ្ធិប្រជាធិបតេយ្យ[៨]។

សិទ្ធិសេរីភាពក្នុងរបបប្រជាធិបតេយ្យ សំដៅលើគ្រប់របបគ្រប់គ្រង ដែលក្នុងនោះប្រជាពលរដ្ឋទាំងអស់បានទទួលកិច្ចធានាការពារសិទ្ធិសេរីភាព និងផលប្រយោជន៍ស្មើៗគ្នា ប៉ុន្តែប្រជាពលរដ្ឋអាចស្វ័យគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាង ឬដោយផ្ទាល់តាមប្រជាសិទ្ធិ[៩]។

ប្រជាធិបតេយ្យ ជាវិទ្យានយោបាយ ដែលសិក្សាអំពីរបបស្វ័យគ្រប់គ្រងសង្គមដោយខ្លួនឯងរបស់ប្រជាជនសិក្សាថា ប្រជាពលរដ្ឋកាន់កាប់អំណាចដែលពោរពេញដោយអធិបតេយ្យភាព និងកំណត់ថាអធិបតេយ្យភាពស្ថិតនៅក្នុងដៃរបស់ប្រជាពលរដ្ឋទាំងអស់[១០]។

---

៦ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ ៧

៧ Auge Guillon, Hollier- larousse, Moreanetc, petit Larousse dictionnaririe imprimeries Larouse en France ,Paris 6, 1967,p.310.

៨ Hornby.A S: Oxford Advnaces Learn's Dictionary of Current English by Sally Wehmeire , Phonetics Editor Michael Ashby , Paris, 2001,p.334.

៩ Henri Benac: Hachette Dictionnnaire Des Synonymes 1956-1982, Paris, p.234.

បើតាមវចនានុក្រម Oxford Advanced Leaner's Dictionary ប្រជាធិបតេយ្យមាននិយមន័យ ៣ យ៉ាង[១១]។

- ប្រជាធិបតេយ្យ ជាប្រព័ន្ធនៃការដឹកនាំរដ្ឋដោយប្រជាពលរដ្ឋតាមរយៈអ្នកតំណាងរបស់ខ្លួនដែលពួកគេបោះឆ្នោតឲ្យ។ ចំពោះអ្នកដែលត្រូវគេបោះឆ្នោតឲ្យនោះ ត្រូវតែគិតគូរដល់បញ្ហាទាំងឡាយដូចជាៈ បញ្ហាសេរីភាព សាសនា និងទស្សននយោបាយ។
- ប្រជាធិបតេយ្យ គឺជាការគ្រប់គ្រងរបស់អង្គការមួយ ហើយដែលសមាជិកនៃអង្គការរបស់ពួកគេនោះត្រូវបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗ។
- ប្រជាធិបតេយ្យ គឺជាការគ្រប់គ្រងដោយសមភាព និងយុត្តិធម៌ គ្មានការបែងចែកវណ្ណៈឋានៈសង្គមឡើយ។

លោក ឡេវីស លីបសីតហ្ស(Lewis Lipstz) នៅក្នុងសៀវភៅមួយរបស់លោក ដែលមានចំណងជើងថា "American Democracy" បានកំណត់និយមន័យ លទ្ធិប្រជាធិបតេយ្យចំនួន ៣ ដូចខាងក្រោម[១២]:

- ប្រជាធិបតេយ្យ គឺជាការសម្រេចចិត្តរបស់មតិភាគច្រើន មានន័យថាមតិភាគច្រើនរបស់ប្រជាពលរដ្ឋបានផ្តល់នូវការយល់ព្រមដោយពេញចិត្តរបស់ពួកគេទៅឲ្យអ្នកដឹកនាំ ឬគោលនយោបាយណាមួយ។
- ប្រជាធិបតេយ្យ សង្កត់ធ្ងន់លើសេរីភាពនិយម។ និយមន័យនេះរួមបញ្ចូលនូវច្បាប់នានា ដែលគោរពសេរីភាពជនស៊ីវិល និងការការពារសិទ្ធិបុគ្គល។
- ប្រជាធិបតេយ្យ សំដៅលើសមភាពនិយម។ ទស្សនៈនេះមិនត្រឹមតែមានន័យថា ការការពារសេរីភាព និងសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវសមភាពផ្នែកសេដ្ឋកិច្ច និងសង្គមទៀតផង។ ត្រង់នេះ ប្រជាធិបតេយ្យ អាចរកឃើញនូវជាតុនានារបស់ខ្លួន ដែលត្រូវបានគេរំលោភជាន់ឈ្លីនៅក្នុងសង្គម ពិសេសលើជនក្រីក្រ។

**អំណាចៈ** ប្រភេទជានាមៈ មានន័យថា អានុភាព, គឺសេចក្តីអាច, ដំណើរអង់អាច, សេចក្តីក្លាហាន, ដំណើរអាចធ្វើអ្វីៗបានតាមចិត្ត ឬតាមលំអានច្បាប់ៈ មានអំណាច, អំណាចរាជការ, អំណាចច្បាប់។ ដោយអំណាចដោយសារ, ដោយកម្លាំងៈ ដោយអំណាចគុណបុណ្យ...។ តាមអំណាចចិត្ត តាមអំពើចិត្ត ធ្វើតាមអំណាចចិត្តឥតក្រែងច្បាប់។ ឡើងអំណាច, ឡើងចាង, ឡើងដៃ។ អស់អំណាច, អស់សេចក្តីអាច, អស់អានុភាព។ល។[១៣]

---

[១០] ដៃយ៉ាន-រ៉ាវិចៈ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ក្រសួងឃោសនាការអាមេរិក បោះពុម្ព. ខែតុលាឆ្នាំ២០០១ ទំព័រ ៣

[១១] Jonathan Crowther "***Oxford Advanced Leaner's Dictionary***" Oxford University Press, CD. Dictionary

[១២] Lewis Lipstz "***American Democracy***" St. Martin's Press, Inc., The United States of American, 1986, p.4-5

[១៣] ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិតៈ វចនានុក្រមខ្មែរ ភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រ ១៨៤៨

ដូច្នេះ សិទ្ធិសេរីភាពពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យ គឺសំដៅទៅលើសង្គមមួយដែលប្រជាពលរដ្ឋមានសិទ្ធិ មានសេរីភាពពេញលេញ ហើយមានអំណាចក្នុងការប្រើប្រាស់សិទ្ធិដោយសេរីក្រោមក្រិត្យក្រមច្បាប់ ដោយពុំខ្លាច ពុំញញើតក្នុងការចូលរួមក្នុងកិច្ចការសង្គមរបស់ខ្លួន ដើម្បីធ្វើការសម្រេចចិត្តក្នុងការកំណត់ជោគវាសនាប្រទេសជាតិរបស់ខ្លួនគ្រប់ៗរូប។ ជាពិសេសប្រជាពលរដ្ឋប្រើអធិបតេយ្យរបស់ខ្លួន ដើម្បីទាមទារឲ្យរដ្ឋាភិបាលការពារសិទ្ធិសេរីភាព ការពារសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្សជាតិ ដែលសិទ្ធិសេរីភាពទាំងនេះមានជាប់តាំងពីកំណើតដែលតម្រូវឲ្យអាជ្ញាធរ រដ្ឋាភិបាលការពារឲ្យបានដូចមានចែងក្នុងច្បាប់ជាតិ កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិ។ ប្រជាពលរដ្ឋ អាចប្រើអធិបតេយ្យរបស់ខ្លួនតាមរយៈអ្នកតំណាងរាស្ត្រ ដែលជាអ្នកត្រួតពិនិត្យជានាឲ្យរដ្ឋាភិបាល គោរព និងប្រតិបត្តិតាមគម្រោងផែនការត្រឹមត្រូវរបស់ខ្លួន។

## ២.២.ទ្រឹស្តីអំពីសិទ្ធិពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ

ព្រះសម្ពុទ្ធ ជាព្រះអរហន្ត ដែលសម្រេចនូវសម្មាសម្ពោធិញ្ញាណ ដោយបានបង្កើតឲ្យមាននិកាយទស្សនវិជ្ជាសាសនានៅលើដែនដីឥណ្ឌាក្នុងសតវត្សទី៦មុនគ.ស. ដែលព្រះធម៌ជាពាក្យប្រៀនប្រដៅទាំងឡាយ និងឥទ្ធិពលរបស់ព្រះអង្គបានផ្សព្វផ្សាយទៅទូទាំងទ្វីបអាស៊ីភាគកណ្តាល ខាងត្បូង និងខាងជើង នៅទីនោះឥទ្ធិពលនោះបានបន្តផ្តល់ឲ្យមានចំណងវប្បធម៌រួមគ្នា។ ពាក្យប្រៀនប្រដៅទាំងឡាយក៏ត្រូវបានគេទទួលស្គាល់ផងដែរ នាពេលសព្វថ្ងៃនេះនៅក្នុងអឌ្ឍគោលខាងលិច។ មេរៀនរបស់ព្រះសម្ពុទ្ធបានផ្តោតជាសំខាន់ គឺនាំទៅកាន់អត្តាធីនភាពរបស់មនុស្ស(ភាពចេញផុតពីទុក្ខ)ក្នុងលោកិយ។ ចំពោះទស្សនៈរបស់ព្រះអង្គស្តីអំពីសិទ្ធិមនុស្ស គឺលេចចេញមកពីសម្មតិកម្មគ្រឹះ ពីរ យ៉ាង មួយគឺទស្សនវិជ្ជា និងមួយទៀតគឺ អភិសមាចារ។ សម្មតិកម្មទស្សនវិជ្ជា គឺថាមនុស្សកើតមកមានសេរីភាព និងមានការទទួលខុសត្រូវពេញលេញ។ ដោយមនុស្សពុំមែនជាការបង្កើតរបស់ព្រះបង្កើតលោកណាមួយទេ មនុស្សរមែងចំណុះតែក្រោមក្រឹត្យក្រមហេតុភាពអនិយតិវាទ (Non-deterministic causal laws)ប៉ុណ្ណោះ ដោយហេតុនេះ ជោគវាសនារបស់គេតែងស្ថិតនៅក្នុងដៃរបស់គេផ្ទាល់។

សេរីភាពរបស់មនុស្សបានចាប់ផ្តើមមានតាំងតែពីមានកំណើតផ្ទាល់របស់គេ ហើយគេទទួលស្គាល់សមភាពរបស់គេនៅក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិទាំងឡាយពិតជាមានបញ្ជាក់យ៉ាងច្បាស់ តាមរយៈការឲ្យតម្លៃ និងកោតសរសើររបស់ព្រះអង្គលើអត្តការៈ (ការខិតខំផ្ទាល់ខ្លួន) បុរិសការៈ(ការខ្នះខ្នែងរបស់មនុស្ស) បុរិសថាមៈ(កម្លាំងរបស់មនុស្ស) បុរិសវិរិយៈ(សេចក្តីព្យាយាមរបស់មនុស្ស) បុរិសបរក្កមៈ(តម្លៃរបស់មនុស្ស) និងបុរិសធោរយៈ(ការទទួលខុសត្រូវរបស់មនុស្ស)[១៤]។ សិទ្ធិមនុស្សក្នុងមេរៀនព្រះពុទ្ធ គឺជាអត្ថប្រយោជន៍នាំទៅកាន់សុខុមាលភាពរបស់មនុស្សជាតិ ជាប្រយោជន៍កើតចេញពីសេចក្តីត្រូវការផ្ទាល់របស់បុគ្គលម្នាក់ៗ(អត្តហិតៈ) និងកើតចេញពីន័យនៃករណីកិច្ច និងកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗចំពោះមនុស្សលោកទាំងអស់(បរហិតៈ)។

---

[១៤] សិទ្ធិមនុស្សតាមរយៈព្រះពុទ្ធសាសនា ភ្នំពេញ ឆ្នាំ១៩៩៩ ទំព័រ ១៧-១៨

ទ្រឹស្តីទាំងនេះ គឺសមស្របទៅនឹងមាត្រា១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ **មាត្រា១នេះចែងថា: មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិទាំងឡាយ**។ ក្នុងផ្លូវនយោបាយ និងច្បាប់វិញសង្កេតឃើញថា ព្រះសម្មុទ្ធទ្រង់ឈរលើទស្សនៈមុតមាំរិះគន់ចំពោះការបែងចែកវណ្ណៈ និងបញ្ហាវិសមភាពសង្គម ដូចដែលមានកំណត់ទុកនៅក្នុងលទ្ធិព្រាហ្មណ៍ និងច្បាប់ម៉ានូ។ អ្វីដែលព្រះសម្មុទ្ធបានរិះគន់ចំពោះការបែងចែកអំណាចនោះ គឺព្រះអង្គមិនពេញចិត្តចំពោះការលើកតម្កើងតួនាទី និងសិទ្ធិហួសហេតុពេករបស់ពួកព្រាហ្មណ៍ក្នុងសង្គម។ ដូចជា ក្នុងច្បាប់ម៉ានូជំពូកទី១ មាត្រា១០០ បានចែងថា "អ្វីៗទាំងអស់នៅលើលោកនេះ ជាកម្មសិទ្ធិរបស់ពួកព្រាហ្មណ៍។ អ្នកណាមានកំណើតក្នុងនាមព្រះព្រហ្ម ជាមនុស្សដែលមានសិទ្ធិលើអ្វីៗទាំងអស់"[១៥]។ បុគ្គលទាំងអស់នោះមានវណ្ណៈ ឬឋានៈក្នុងសង្គមជាអ្វីក៏ដោយត្រូវទទួលទោសដោយមានប្រភេទ និងមានកម្រិតទណ្ឌកម្មដូចគ្នា ប្រសិនរកឃើញថា បានប្រព្រឹត្តល្មើសមកលើច្បាប់។ នៅក្នុងព្រះរាជប្រកាសសសរស្តម្ភទី៤ ព្រះអង្គមានបន្ទូលថា ព្រះអង្គមានព្រះរាជបំណងខ្លាំងក្លាបំផុត ចង់ឲ្យមានសមភាពចំពោះមុខច្បាប់ និងការផ្តន្ទាទោស។ ទ្រឹស្តីរបស់ព្រះសម្មុទ្ធបានបង្ហាញឲ្យឃើញច្បាស់អំពីការទទួលស្គាល់សារៈសំខាន់នៃសមភាពនៅចំពោះមុខច្បាប់ ដែលបម្រើអត្ថប្រយោជន៍ដ៏ប្រសើរបំផុតរបស់សង្គមទាំងមូលដោយគ្មានបុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិពិសេសណាមួយផ្តល់ឲ្យចំពោះផ្នែកណាមួយ ដែលបានទទួលសេចក្តីអនុគ្រោះពិសេសណាមួយពីសង្គមនោះទេ វិសមភាពទាំងឡាយដូចជា ការដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរលើអ្នកក្រីក្រមិនត្រូវបានយល់ព្រមឲ្យធ្វើសោះឡើយ[១៦]។ ក្នុងវោហាស័ព្ទរបស់ព្រះពុទ្ធបានលើកឡើងថា **ធម្មិកំរក្ខាវរណគុត្តំ** បានសេចក្តីថា ការថែរក្សា និងកិច្ចការពារត្រឹមត្រូវដោយឥតលំអៀង នេះបង្ហាញឲ្យឃើញថា ទ្រង់គ្មានទ្រទ្រង់រើសអើងបែបណាមួយឡើយ គឺកិច្ចការពារស្មើភាពគ្នាដោយច្បាប់។ ទស្សនៈនេះដូចគ្នាទៅនឹងមាត្រា៧ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ដែលចែងថា **ទាំងអស់គ្នាមានភាពស្មើគ្នានៅចំពោះមុខច្បាប់ ហើយមានសិទ្ធទទួលកិច្ចការពារស្មើគ្នាអំពីច្បាប់ ដោយគ្មានការរើសអើងណាមួយឡើយ។**

ទ្រឹស្តីព្រះសម្មុទ្ធឲ្យតម្លៃ និងទទួលស្គាល់ចំពោះសិទ្ធិមានសេរីភាពខាងការគិត ខាងមនសិការ និងខាងសាសនាពោល គឺពុំមានការបង្ខិតបង្ខំឲ្យជឿតាម ដោយគ្រាន់តែមានសទ្ធាឡើយ គឺត្រូវស្វែងរកសច្ចៈធម៌ដោយខ្លួនឯងដោយសេរី។ មេរៀនព្រះសម្មុទ្ធទុកដូចជា ផ្ទះបើកទ្វារចំហសម្រាប់ជំនឿគ្រប់សាសនាទាំងអស់ ត្រង់ចំណុចនេះស្របទៅនឹងមាត្រា១៨ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស **ដែលមាត្រានេះចែងថា មនុស្សគ្រប់រូបមានសិទ្ធិ មានសេរីភាពខាងការគិត ខាងមនសិការ និងសាសនា...**។ មនុស្សម្នាក់ៗមានសេរីភាពផ្តល់ការបកស្រាយផ្ទាល់របស់ខ្លួនលើបញ្ហាអ្វីមួយ (មានគណៈឬនិកាយទ្រឹស្តីនៃពុទ្ធសាសនាផ្សេងៗ) ដោយគ្មានការជ្រៀតជ្រែក ដោយមិនគិតពីមធ្យោបាយដែលប្រើសម្រាប់និយាយ និងដោយឥតមានរបាំង

[១៥] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ៨-៩

[១៦] សិទ្ធិមនុស្សតាមរយៈព្រះពុទ្ធសាសនា ភ្នំពេញ ឆ្នាំ១៩៩៩ ទំព័រ ៥២-៥៣

ហាមឃាត់។ ដោយគ្រាន់តែសេរីភាពនៃការសម្ដែងមតិ ឬយោបល់ត្រូវនាំយកមកជាមួយខ្លួននូវកាតព្វកិច្ចធានារ៉ាប់រងថា យោបល់របស់ខ្លួនត្រូវបានបង្កបង្កើតឡើងដោយប្រុងប្រយ័ត្ន ពីព្រោះយោបល់របស់ខ្លួនអាចប៉ះពាល់ដល់ខ្លួនឯង និងជះឥទ្ធិពលមិនល្អដល់មនុស្សទាំងឡាយឯទៀតផងដែរ។ ដូចគ្នានេះដែរ សិទ្ធិខាងនិយាយស្ដីត្រូវតែបានអនុវត្តដោយមានការទទួលខុសត្រូវ ដើម្បីកុំឲ្យបង្កសេចក្ដីអន្តរាយដល់អ្នកដទៃ ឬដល់ខ្លួនឯងក៏ដូចជាសង្គមផងដែរ។

ទស្សនៈរបស់ព្រះសម្មុទ្ធ ទ្រង់ចង់ឲ្យមានសមភាពសង្គម និងចង់ជាស់តឿនមនុស្សដែលស្ថិតក្នុងស្រទាប់ក្រោម និងត្រូវបានពួកវណ្ណៈខ្ពង់ខ្ពស់មើលងាយទាំងនេះឲ្យយល់ដឹងពីខ្លួនផ្ទាល់ ហើយនិងជំរុញឲ្យពួកគេចេះធ្វើការដើម្បីសង្គ្រោះខ្លួនឯងដោយខ្លួនឯង។ តែដោយសង្គមមនុស្ស មិនអាចមិនមានវណ្ណៈព្រាហ្មណ៍នោះឡើយ នោះពួកព្រាហ្មណ៍ត្រូវបែរទៅជាទីប្រឹក្សារបស់វណ្ណៈក្សត្រទៅវិញ។ ឯចំណែកវណ្ណៈពីរផ្សេងទៀតត្រូវឋិតនៅក្នុងលំដាប់ថ្នាក់ទាបក្នុងនាមជាប្រជាពលរដ្ឋមានសេរីភាព។ ការណ៍ដែលព្រះពុទ្ធអង្គហ៊ានរិះគន់បែបនេះគឺមកពីព្រះអង្គមិនទទួលស្គាល់ចំពោះអត្ថិភាពរបស់ព្រះអាទិទេពឡើយ។ អាទិទេពរបស់ព្រះអង្គ គឺជាបុគ្គលជាន់ខ្ពស់ដែលដឹកនាំពិភពដោយសីលធម៌ និងជាអ្នកបង្កើតច្បាប់ដំបូងគេបង្អស់។ ព្រះអង្គមិនជឿលើកម្លាំងខាងក្រៅដែលឃ្លាតឆ្ងាយពីសមត្ថភាពរបស់មនុស្សឡើយ ដោយព្រះអង្គបានមានព្រះបន្ទូលថា រាល់កិច្ចការទាំងឡាយរបស់មនុស្ស គឺមានភាពអាស្រ័យទៅនឹងការខិតខំប្រឹងប្រែងរបស់មនុស្សដោយផ្ទាល់មិនមែនជាការដែលពឹងផ្អែកទៅលើកម្លាំងខាងក្រៅ ឬឆន្ទៈរបស់អាទិទេពនោះឡើយ។

ទាំងច្បាប់ទូន្មានអប់រំបែបសីលធម៌ សម្រាប់រៀបចំដំណើរការជីវិតរបស់មនុស្សនៅលើផែនដី ដែលព្រះសម្មុទ្ធទ្រង់បានត្រាស់ឃើញនោះ ក៏មិនមែនជាស្នាដៃដែលព្រះអាទិទេពប្រទានឲ្យ ឬជាច្បាប់ដែលត្រូវបានបង្កើតឡើងក្រោមឥទ្ធិពលនៃឆន្ទៈអាទិទេពនោះឡើយ។ ព្រះអង្គបានមានព្រះបន្ទូលថា ក្បួនច្បាប់សីលធម៌ជាឥទ្ធិពលនៃការឯកភាពសង្គម តែមិនមែនជាបទបញ្ជានៃព្រះអាទិទេពណាមួយឡើយ។

ទស្សនៈបញ្ញត្តិទី២របស់ព្រះពុទ្ធស្ដីពីសមភាព គឺទាមទារសិទ្ធិសេរីភាពទាំងឡាយគប្បីឋិតនៅឥតមានឧបសគ្គដោយគំនិតចង្អៀតចង្អល់ដោយកត្តាទាំងឡាយដូចជា ពូជជាតិ ពណ៌សម្បុរ ភេទ ប្រភព ឬសង្គមធនធាន កំណើត ឬស្ថានភាពដទៃទៀតនោះទេ។

ដូច្នេះអាចសន្និដ្ឋានបានថាៈ គឺព្រះសម្មុទ្ធចង់លើកឡើង អំពីរង្វង់នៃការរស់នៅរបស់មនុស្សនៅក្នុងរដ្ឋ និងសកលលោកទាំងមូល គឺសិទ្ធិសេរីភាពដូចៗគ្នាតាំងពីកំណើត ហើយទាមទារឲ្យគោរពគ្នាទៅវិញទៅមកសាមគ្គីដោយសេចក្ដីស្មោះត្រង់នឹងគ្នាទើបមានសន្តិភាព និងការរីកចម្រើនក្នុងលំនឹងនិរន្តរភាព។ ជាពិសេសដាស់តឿនមនុស្សគ្រប់ៗគ្នាក្នុងប្រទេស និងពិភពលោកទាំងមូលយល់ថា សេចក្ដីសុខទុក្ខ និងការរីកចម្រើនភាពអន្តរាយ ការបាត់បង់សិទ្ធិសេរីភាព គឺកើតឡើងដោយសារខ្លួនឯងមិនមែនកើតឡើងដោយសារព្រះអាទិទេពឯណានោះទេ ដូច្នេះប្រជាពលរដ្ឋខ្លួនឯង តោងត្រូវសាមគ្គីតស៊ូរើបម្រាស់ដោយអហិង្សា ដើម្បីចេញឲ្យផុតនូវរាល់ការជិះជាន់ អំពើផ្ដាច់ការចក្រពត្តិ សក្តិភូមិ គាបសង្កត់ អយុត្តិធម៌នានា ដែលបានកើតឡើងនៅក្នុងសង្គមរស់

នៅរបស់ខ្លួន។

សូក្រាត(SOCRATES)(៤៦៩-៣៩៩ មុនគ្រិស្តសករាជ) ជាទស្សនវិទូក្រិចម្នាក់ ដោយបានលើកឡើងនូវទស្សនៈទាក់ទងទៅនឹងការដឹកនាំសង្គមថា នយោបាយ គឺជាសិល្បៈដែលទាមទារឲ្យមាននូវចំណេះដឹងជាមូល-ដ្ឋានដ៏ល្អ។ រដ្ឋដែលរីកចម្រើន គឺដោយសារមានច្បាប់ល្អដឹកនាំ ហើយអ្នកដឹកនាំត្រូវតែមានចំណេះដឹងច្រើន។ ទស្សនៈនេះបានប្រឆាំងទៅនឹងគំនិតប្រជាធិបតេយ្យរបស់អាថែន ដែលត្រូវការចាំបាច់នូវសំឡេងមនុស្សគ្រប់រូបគ្រាប់តាមមាត់របស់ពួកគេដូចៗគ្នា[១៧]។ លោកបានដាក់ចេញនូវសេចក្តីសន្និដ្ឋានថា យុត្តិធម៌ និងច្បាប់ ជាសទិ-សន័យនឹងគ្នា។ ច្បាប់ ជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូបដែលត្រូវតែទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន។ ម្យ៉ាងទៀត ការបង្ហាញឲ្យឃើញនូវភាពត្រឹមត្រូវមួយទៀតអំពីច្បាប់និងយុត្តិធម៌ គុណធម៌និងអំពើល្អ ដែលផ្តល់ផលប្រយោជន៍ទាំងអស់នេះ អាចចាត់ទុកក្នុងចង្កោមដែលមានមូលដ្ឋានពីចំណេះដឹង និងការអប់រំបានល្អ។ គំនិតជាចម្បងរបស់លោក SOCRATES គឺសុភវិនិច្ឆ័យរបស់រដ្ឋាភិបាល ហើយសិទ្ធិជាកត្តាចាំបាច់ដំបូងដែលជាប់ពាក់ព័ន្ធទៅនឹងគ្រប់ទម្រង់គ្រប់គ្រងនយោបាយទាំងអស់។ ស្តេចទាំងឡាយ និងអ្នកដឹកនាំទាំងឡាយត្រូវមានលក្ខណៈចាំបាច់ជាច្រើនដូចខាងលើ មិនមែនសំដៅទៅលើតែមនុស្សពាក់មកុដ និងគ្រឿងអលង្ការពេញខ្លួន ឬមិនមែនសំដៅទៅលើតែមនុស្ស ដែលគេជ្រើសរើសដោយសារមនុស្សមានទ្រព្យច្រើន ឬមានបូកពាខ្ពស់សមរម្យ ឬមិនមែនសំដៅទៅលើមនុស្សដែលបានអំណាចដោយសារកម្លាំងអាវុធ និងអំពើហិង្សា ពូកែភូតភរនោះទេ ក៏ប៉ុន្តែត្រូវការជាចាំបាច់ចំពោះអ្នកមានសមត្ថភាពដឹកនាំ និងគ្រប់គ្រង។ លោក SOCRATES រិះគន់របបផ្តាច់ការខ្លាំងជាងគេបំផុតដោយលោកបានលើកឡើងថាៈ[១៨]

១-កិច្ចការទំនាក់ទំនងរវាងរដ្ឋ និងពលរដ្ឋមិនដូចគ្នាទៅនឹងទំនាក់ទំនងរវាងឪពុកម្តាយ និងកូនទេ គឺរដ្ឋជំពាក់គុណពលរដ្ឋ ព្រោះពលរដ្ឋជាឪពុកម្តាយរបស់រដ្ឋ។

២-បើអ្នកគ្រប់គ្រងមិនគោរពច្បាប់ គឺថាមានលទ្ធផលប្រកបដោយគ្រោះថ្នាក់ក្នុងការវិនិច្ឆ័យករណីរឿងក្តី។

តាមទស្សនៈសូក្រាត(SOCRATES)គឺចង់បង្ហាញថា អ្នកដឹកនាំប្រទេសដាច់ខាតត្រូវតែជាមនុស្សដែលមានភាពឈ្លាសវៃប៉ិនប្រសព្វ មានបញ្ញាញាណភ្លឺថ្លា ចក្ខុវិស័យចាក់ធ្លុះ ក្នុងការដោះស្រាយបញ្ហាមនុស្សក្នុងសង្គម។ តំណែងជាអ្នកដឹកនាំប្រទេស ចាំបាច់ត្រូវមានសីលធម៌ខ្ពស់ណាស់ គឺសំដៅដល់ការបំពេញកាតព្វកិច្ចឈរលើសតិសម្បជញ្ញៈដោយមិនគិតពីគុណស្រ័យនោះទេ ការដឹកនាំប្រទេស គឺប្រៀបដូចទៅផ្លែខ្នុរដែលទុំដោយបញ្ចេញក្លិនក្រអូប មានន័យថា មិនមែនផ្លែខ្នុរចង់ទុំទេ ធម្មជាតិផ្លែខ្នុរនៅពេលទុំតែងចោលក្លិនក្រអូបឯមេដឹកនាំតែងធ្វើការងារបម្រើប្រជាជន និងប្រទេសជាតិ មិនចាំមានកាតព្វកិច្ច ចាំគេបញ្ជោរ លើកសសើរចង់បានប័ណ្ណសរសើរ ឬមេដាយ...នោះទេ គឺមានស្មារតីភ្ញាក់រលឹកជាប់ជានិច្ច ហើយគុណធម៌និងមនសិការ

---

[១៧] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ៥២

[១៨] ដ.ឯ.ម ទំព័រ ៥៥-៥៦

បានបញ្ជាឲ្យមេដឹកនាំខិតខំបំពេញការងារក្នុងស្មារតីទទួលខុសត្រូវ ដោយមិនខ្លាចនឿយហត់ មិនចង់បានគុណសម្បត្តិ មិនទាំងបានគិតពីការសរសើរអ្វីឡើយ គឺធ្វើឡើងក្នុងសមានចិត្តត្រិះរិះយ៉ាងណាឲ្យប្រជាពលរដ្ឋទទួលបានសេចក្តីសម្បូណ៌សប្បាយ សុភមង្គល ប្រទេសជាតិទទួលបានសុខសន្តិភាព ស្ថេរភាព រីកចម្រើនរុងរឿង ជឿនលឿន ចំណែកឯកិត្តិយស និងគោរម្យងារ គឺប្រជាពលរដ្ឋជាអ្នកដាក់ពិន្ទុឲ្យ ឬអត់ គឺមិនមែន ជាករណីចាំបាច់នោះទេ។

ប្លាតុង(PLATO)(៤២៧-៣៤៧ មុនគ្រិស្តសករាជ) លោកជាទស្សនវិទូសម័យក្រិចបុរាណ និងជាអ្នកនយោបាយម្នាក់។ ទស្សននយោបាយរបស់លោក PLATO ផ្តោតទៅលើរដ្ឋ និងច្បាប់។ ជាតុទាំងនេះជាកត្តាជំរុញឲ្យមានភាពអាស្រ័យយ៉ាងខ្លាំងលើបញ្ហាធ្វើឲ្យមានភាពប្រសើរ សម្បូណ៌សប្បាយ និងមានសុភមង្គលជូនប្រជាពលរដ្ឋ និងកាត់បន្ថយនូវវិបត្តិ ដែលតែងតែកើតឡើងជាប្រចាំក្នុងជិវិតរស់នៅ។ និយាយឲ្យខ្លីជួយសម្រាលបន្ទុក និងធ្វើឲ្យសង្គមទាំងមូលស្ថិតក្នុងស្ថេរភាពទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកនយោបាយ។ល។ លោក PLATO ព្យាយាមដោះស្រាយរាល់បញ្ហាទាំងឡាយដែលគេតែងតែជួបប្រទះក្នុងសង្គមក៏ដូចជា នៅក្នុងជីវភាព រស់នៅផងដែរ ដោយប្រើវិធីមួយ គឺបង្កើតរដ្ឋគំរូមួយ ដែលមានមេដឹកនាំប្រកបដោយកម្រិតស្នេហាជាតិមានសុភវិនិច្ឆ័យ។ អត្ថន័យរដ្ឋគំរូរបស់លោក PLATO បានបង្ហាញឲ្យឃើញនូវភាពយុត្តិធម៌ក្នុងការដឹកនាំដោយជ្រើសរើសយកអ្នកទស្សនវិទូឆ្លាតវៃ ពីព្រោះចំណេះដឹងពិតប្រាកដ និងចិត្តកសាងកុសលចំពោះអ្នកដទៃទៀត នោះមនុស្សប្រភេទនេះហើយដែលបានធ្វើសម្បទាន។ តួអង្គដែលតំណាងឲ្យរដ្ឋគំរូរបស់លោក PLATO គឺជាអ្នកធ្វើការក្នុងបូរី។ តើរដ្ឋគំរូរបស់លោក PLATO មានសញ្ញាយ៉ាងដូចម្តេច?

បើតាមទស្សនៈរបស់លោក PLATO ដែលបាននិយាយនៅក្នុងស្នាដៃ សញ្ញាដ៏សំខាន់របស់រដ្ឋគំរូ គឺត្រូវមានភាពយុត្តិធម៌។ យុត្តិធម៌ បើតាមទស្សនៈលោក PLATO គឺស្ថិតនៅត្រង់ថា ពលរដ្ឋម្នាក់ៗត្រូវតែមានការងារធ្វើ ហើយអាស្រ័យទៅតាមឧបនិស្ស័យរបស់គេ ដូច្នេះ ភាពយុត្តិធម៌របស់រដ្ឋ គឺធ្វើយ៉ាងណាឲ្យពលរដ្ឋមានការងារធ្វើ ហើយពួកគេមានសកម្មភាពស្របទៅតាមសមត្ថភាព និងអត្តិភាពរបស់ខ្លួនផ្ទាល់។ លោក PLATO បានធ្វើការបែងចែកយ៉ាងច្បាស់នូវឋានានុក្រមស្រទាប់មនុស្សក្នុងសង្គមថា ពួកទស្សនវិទូដែលដឹកនាំប្រទេស(វណ្ណៈកម្រិតខ្ពង់ខ្ពស់) អ្នកយាម ទាហាន មន្ត្រីរាជការ(វណ្ណៈក្នុងកម្រិតមធ្យម) និងសិប្បករ កម្មករ និងកសិករ(វណ្ណៈក្នុងកម្រិតទាប)។ មិនតែប៉ុណ្ណោះ លោក PLATO បានពិនិត្យយ៉ាងហ្មត់ចត់លើបញ្ហាការសិក្សា និងអប់រំ។ លោក PLATO ធ្វើការបែងចែកដូច្នេះ អាស្រ័យទៅលើឧបនិស្ស័យរបស់មនុស្ស ភាពវៃឆ្លាត ភាពម៉ឺងម៉ាត់ និងទទួលខុសត្រូវក្នុងភាពជាអ្នកដឹកនាំ។ សម្រាប់លោក PLATO រចនាសម្ព័ន្ធរដ្ឋល្អ គឺនៅកន្លែងណាដែលពលរដ្ឋម្នាក់ៗធ្វើការដើម្បីផលប្រយោជន៍របស់ខ្លួននៅក្នុងទិសដៅសង្គម។ រដ្ឋ និងសង្គមពលរដ្ឋរបស់លោក គឺមានលក្ខណៈតែមួយ។ បើតាមទស្សនៈរបស់លោក រដ្ឋគំរូនោះ គឺត្រូវជួយផ្គត់ផ្គង់ជាអតិបរមាដល់កង្វះខាតក្នុងជីវិតប្រជាពលរដ្ឋ ទាំងសម្ភារៈ ទាំងស្មារតី។ ដូច្នេះ រដ្ឋគំរូរបស់ PLATO គឺត្រូវតែអាស្រ័យនឹងការបែងចែកជាក្រុម ប្រកបដោយគុណធម៌ទាំង ៤យ៉ាងគឺ ចំណេះដឹងជ្រៅជ្រះ សេចក្តីក្លាហាន វិចារណញ្ញាណ និង

យុត្តិធម៌។

- ចំណេះដឹងជ្រៅជ្រះ ដែលក្នុងនាមជាអ្នកបំពេញនូវតួនាទីជាអ្នកដឹកនាំរដ្ឋ។

- សេចក្តីក្លាហាន ដែលជាគុណសម្បត្តិរបស់ទាហាន តួនាទីជាអ្នកការពារ។

- វិចារណញ្ញាណ និងយុត្តិធម៌ ជាគុណធម៌ដែលមានគ្រប់ពលរដ្ឋទាំងអស់នៅរដ្ឋគំរូ។

ចំពោះទស្សននយោបាយដឹកនាំរដ្ឋរបស់លោក PLATO របបប្រជាធិបតេយ្យជារបបផ្សេងមួយ ដែលសង្គមមនុស្សរស់នៅក្នុងគោលការណ៍សមភាពក្នុងឋានៈជាពលរដ្ឋ។ នៅក្នុងរដ្ឋការកើតឡើងនូវសិទ្ធិសេរីភាពពេញលេញ និងឥតលាក់លៀម និងមានលទ្ធភាពធ្វើអ្វីដែលខ្លួនចង់ធ្វើ មិនចាំបាច់ត្រូវឱនលំទោនចំពោះនរណាទេ បើខ្លួនមិនចង់ធ្វើ។ ដូច្នេះ មើលទៅហាក់ដូចជារបបនយោបាយមួយដែលល្អប្រសើរបំផុត។ ប៉ុន្តែក្នុងរបបនេះពុំមានអ្នកណាមួយមានតួនាទីត្រូវតែដឹកនាំនោះទេ។ នៅក្នុងរដ្ឋប្រជាធិបតេយ្យមនុស្សមានយសសក្តិ អាស្រ័យដោយសារតែគេមានលក្ខណៈពិសេសប្លែកពីគេបានត្រូវរកឃើញក្នុងជួរមហាជន។ ហើយក្នុងរបបប្រជាធិប-តេយ្យ ក៏មិនមែនអាស្រ័យលើបុគ្គលណាដែលចូលរួមសកម្មភាពដឹកនាំរដ្ឋទេ។

លោក PLATO បានផ្តាំជាអក្សរចារឹកគ្រប់ទំព័រគម្ពីររបស់គាត់ឲ្យយើងគ្រប់គ្នា និងសង្គមលោកទាំងមូលខិតខំប្រឹងប្រែងព្យាយាមហាត់ពត់ចិត្តគំនិតប្រកាន់ខ្ជាប់ផ្អែកទាំងស្រុង ដើម្បីធ្វើដំណើរស្របគ្នាឆ្ពោះទៅរកមាគ៌ាយុត្តិធម៌ សេរីភាព មនុស្សធម៌ និងសមភាព[១៩]។ មានន័យថាៈ ការបើសិទ្ធិសេរីភាពទៅតាមក្រិត្យក្រមច្បាប់ ដែលចាំបាច់អមដោយការដាំបណ្តុះសមភាព មនុស្សធម៌ សីលធម៌ គុណធម៌ គតិបណ្ឌិត ឲ្យក្លាយទៅជាវប្បធម៌ ជាពុម្ពគំរូស្នូលរឹងមាំរបស់ជាតិ ទើបសង្គមទាំងមូលទទួលបានសន្តិភាព យុត្តិធម៌ និងការអភិវឌ្ឍន៍។ សង្គមខ្មែរយើងមានប្រវត្តិសាស្ត្រមិនច្បាស់លាស់ ស្តីអំពីបទដ្ឋាននៃការបណ្តុះបណ្តាលសិទ្ធិ សេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យជូនប្រជាពលរដ្ឋទេ ដែលចាំបាច់ត្រូវប្រជាពលរដ្ឋខ្លួនឯង តោងខ្នះខ្នែងសិក្សា ជាពិសេសត្រូវរដ្ឋាភិបាលគួរយកចិត្តទុកដាក់ពីបញ្ហានេះ ដៀសវាងបញ្ហានៅតែកើតមានជាដដែល ជុំវិញប្រព័ន្ធដឹកនាំបែបប្រជាធិបតេយ្យក្លែងក្លាយ ព្រោះថាបណ្តុំគតិបណ្ឌិត គឺនៅក្នុងចំណោមមហាជនដែលត្រូវតែស្វែងរក។ ការវិភាគនេះ ស្រដៀងគ្នាទៅនឹងទស្សនៈរបស់លោកPLATOដែរ ដែលលោកវិភាគឲ្យឃើញថា មេដឹកនាំក្នុងរបបប្រជាធិបតេយ្យសេរីគឺកើតចេញពីជួរមហាជនដែលមានបញ្ញាញាណលើសមនុស្សធម្មតា ដែលប្រជាពលរដ្ឋបានសម្រេចផ្តល់សេចក្តីទុកចិត្តនិងជ្រើសរើស មិនមែនចាំតែពូជអញ ឬក្រុមបក្សពួកអញ ទើបធ្វើជាអ្នកដឹកនាំប្រទេសនោះទេ។

នៅក្នុងរដ្ឋប្រជាធិបតេយ្យ អ្នកឮតែពាក្យសរសើរដោយឥតព្រំដែន អំពីសេរីភាពដ៏ល្អប្រសើរនៅពេលដែលអ្នកមិនចង់ស្តាប់បង្គាប់បះបោរឡើង[២០]។

---

[១៩] សុខ សុត្តាល មហាទស្សនវិទូ និងទស្សនវិជ្ជាក្នុងលោក ភ្នំពេញ ឆ្នាំ១៩៧១ ទំព័រ ១៨៧

[២០] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ៨២

អារីស្តូត(ARISTOTLE)(៣៨៤-៣២២ មុនគ្រិស្តសករាជ) ជាទស្សនវិទូក្រិច។ នៅក្នុងរង្វង់ទស្សនវិជ្ជា លោក ARISTOTLE យល់ថា នយោបាយត្រូវក្តោបយកទាំងបញ្ហាសីលវិជ្ជា ទាំងបញ្ហាសេដ្ឋកិច្ច។ លោកចាត់ទុកថា នយោបាយជាវិទ្យាសាស្ត្រអំពីភាពថ្កុំថ្កើង សម្បូណ៌សប្បាយរបស់មនុស្ស និងរដ្ឋ។ គោលបំណងរបស់នយោបាយ និងសីលធម៌មានតែមួយដូចគ្នា គឺដើម្បីសុភមង្គល និងភាពសម្បូណ៌ សប្បាយរបស់មនុស្ស និងរដ្ឋ[២១]។ លោកចាត់ទុកថា មនុស្សជាផ្នែកមួយរបស់រដ្ឋ ឯកម្មសិទ្ធិឯកជនទាំងឡាយ ត្រូវស្ថិតនៅលំដាប់ទីពីរបន្ទាប់ពីប្រយោជន៍រួម។ លោក ARISTOTLE បានដាក់ងារឲ្យពលរដ្ឋថា មនុស្សមានសេរីភាព។ ពលរដ្ឋជាអ្នកដែលបម្រើការងារចម្បាំង បង្កើតច្បាប់ កាន់ការងារតុលាការ។ សេរីភាព និងវិសមភាពត្រូវបានគេពិចារណានៅក្នុងស្រទាប់មហាជន។

តាមទស្សនៈរបស់លោកអារីស្តូត(ARISTOTLE) រដ្ឋកើតឡើងដោយសារតែហេតុផលចាំបាច់មួយ គឺធ្វើឲ្យជីវភាពរស់នៅរបស់ពលរដ្ឋឲ្យមានភាពប្រសើរជាងមុន។ មានតែនៅក្នុងមជ្ឈមណ្ឌលខាងក្នុងទេ ដែលអាចបង្កលក្ខខណ្ឌល្អៗឲ្យមនុស្សរស់នៅក្នុងភាពសុខដុមរមនានិងសុមភង្គល ពីព្រោះភាពយុត្តិធម៌និងសិទ្ធិដែលបានបម្រើផលប្រយោជន៍ឲ្យប្រជាពលរដ្ឋគ្រប់រូបមានតែនៅក្នុងរដ្ឋប៉ុណ្ណោះ។ ម្យ៉ាងទៀត លោក ARISTOTLE បានកំណត់នូវរបបនយោបាយ និងទម្រង់គ្រប់គ្រងរដ្ឋ គឺស្ថិតនៅលើអត្ថន័យពិតរបស់អំណាច។ លោកបានគូសបញ្ជាក់ថា បើសិនរបបរាជានិយម អំណាចជាកម្មសិទ្ធិរបស់មនុស្សម្នាក់នៅក្នុងរដ្ឋនោះទម្រង់Polity គឺជាអំណាចរបស់ប្រជាជន ដែលមានសេរីភាពទាំងអស់ ថ្វីត្បិតតែអំណាចដែលប្រជាជនម្នាក់ៗមានអាស្រ័យកម្រិតស្ថានភាពរបស់ខ្លួនផ្ទាល់ក៏ដោយ។

របបនយោបាយជាគំរូ លោក ARISTOTLE បានគិតថា Polity ពីព្រោះនៅក្នុងរបបនេះអំណាចស្ថិតនៅក្នុងការគ្រប់គ្រងដោយវណ្ណៈមធ្យម។ តាមទស្សនៈរបស់ ARISTOTLE "Polity" គឺចំពោះរដ្ឋណាដែលដឹកនាំប្រកបទៅដោយគតិវិញ្ញូនៅក្នុងសកម្មភាពរបស់ខ្លួន ហើយអំណាចស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្សភាគច្រើន។

លោក ARISTOTLE បានចាប់អារម្មណ៍ជាខ្លាំងចំពោះស្ថានភាពខាងក្រៅនៃអត្ថិភាពរបស់រដ្ឋ ជាបឋម គឺចំនួនប្រជាពលរដ្ឋ ស្ថានភាពរស់នៅដោយមានការឧបត្ថម្ភគ្រប់បែបយ៉ាង និងស្ថានភាពទឹកដី ដើម្បីការពារទប់ទល់នឹងសត្រូវឈ្លានពាន។ ចំពោះរចនាសម្ព័ន្ធសង្គមរដ្ឋគំរូរបស់លោក ARISTOTLE គឺប្រហាក់ប្រហែលនឹងសង្គមអភិជនាធិបតេយ្យ។ ម៉្យាងទៀត រដ្ឋដែលគិតគូរដល់ប្រយោជន៍រួមនៃវណ្ណៈមធ្យមជាអតិបរិមា។ រចនាសម្ព័ន្ធសំដៅទៅលើគោលការណ៍នៃបុគ្គលភាពដែលជាមនុស្សប្រកាន់ភ្ជាប់នូវគុណធម៌ ចាត់ទុកដូចជាទិសដៅនយោបាយសង្គមដ៏សំខាន់បំផុត ពិសេសគឺនយោបាយទំនាក់ទំនងគ្នារបស់ប្រជាជនដែលរស់នៅក្នុងរដ្ឋ។ កត្តាចាំបាច់ដើម្បីឲ្យរដ្ឋនាំមុខបុគ្គល(តាមទស្សនៈលោក ARISTOTLE) រដ្ឋត្រូវបង្កលក្ខណៈល្អប្រសើរសម្រាប់ជីវិតពលរដ្ឋ។ មានតែនៅក្នុងរដ្ឋទេ ទើបមនុស្សអាចមានការជឿនលឿន ពីព្រោះរដ្ឋនាំមកនូវយុត្តិធម៌

[២១] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ៨៩

និងសមធម៌ ដែលបម្រើផលប្រយោជន៍ប្រជាជន។ លោក ARISTOTLE បាននិយាយអំពីរដ្ឋ គឺដូចជាចុះកិច្ចព្រមព្រៀងសង្គមពលរដ្ឋដែលថា ប្រភពទស្សនាទាននៃការកកើតសង្គមពលរដ្ឋ ទោះយ៉ាងណាក៏ដោយលោកបាននិយាយថា រដ្ឋត្រូវតែឆ្លុះបញ្ចាំងនូវផលប្រយោជន៍ប្រជាពលរដ្ឋដែលមានសេរីភាព[២២]។ ទម្រង់រដ្ឋដែលលោក ARISTOTLE ស្រមើស្រមៃចង់បាននោះជាទម្រង់រដ្ឋដែលក្នុងនោះ ពោរពេញទៅដោយគុណធម៌ ទ្រព្យសម្បត្តិ និងសេរីភាព។ លោក ARISTOTLE បានបន្តថា មានតែនៅក្នុងប្រជាសហគមន៍រួមទេ ដែលប្រជាពលរដ្ឋខ្លួនឯងអាចផ្សំ ពូក ករ ឬការសង់ខ្លួនឡើងជាទម្រង់មនុស្សមានសីលធម៌ល្អឥតខ្ចោះដោយខ្លួនឯងបាន។ លោកបានចាត់ទុកថាៈ លក្ខខណ្ឌរបស់មេដឹកនាំ គឺជាការរកសុខដុមនីយកម្ម សុខុមាលភាព និងសុភមង្គល ជូនប្រជាពលរដ្ឋ។ លោកបានបញ្ជាក់យ៉ាងច្បាស់ថាៈ ក្បាលម៉ាស៊ីនដឹកនាំរដ្ឋត្រូវតែតំណាងឲ្យពូជពង្ស ជាតិសាសន៍របស់ខ្លួន និងសម្រេចធ្វើអ្វីៗទាំងអស់ ដើម្បីការរីកចម្រើនជូនសង្គមរបស់ខ្លួន។ ឯជីវិតខ្ពង់ខ្ពស់របស់មនុស្ស តាមទស្សនៈរបស់លោក គឺមិនមែនស្ថិតនៅលើទ្រព្យសម្បត្តិស្តុកស្តម្ភជាសំខាន់ប៉ុណ្ណោះទេ ប៉ុន្តែចំណុចសំខាន់ទី១ នៃសុភមង្គល គឺការគោរពគ្រងគ្រាប់នូវអ្វី ដែលប្រជាពលរដ្ឋទាំងអស់គ្នាចាត់ទុកថា ជាច្បាប់រួម ច្បាប់កំពូល សច្ចធម៌ និងយុត្តិធម៌ក្នុងសង្គមទាំងមូល។ បញ្ញាយុត្តិធម៌លោក ARISTOTLE យល់ថាៈ គឺជាបញ្ញាអាទិភាពចាំបាច់បំផុត ដោយហេតុថា វាបានរៀបចំតាក់តែងឲ្យមនុស្សរស់នៅក្នុងមូលដ្ឋានគ្រឹះទសពិតរាជធម៌ គុណធម៌ សប្បុរសធម៌ និងមានវិចារណញ្ញាណ សតិសម្បជញ្ញៈ ទេពកោសល្យ សេចក្តីក្លាហាន សេចក្តីសុខកាយសប្បាយចិត្ត ភាពស្មោះត្រង់ ការសម្បទាន និងជាសេចក្តីសង្ឃឹមជាដើម។ ដូច្នេះ ទ្រឹស្តីរបស់លោកARISTOTLE ពិតជា ទស្សនៈមួយដែលចង្អុលបង្ហាញពីអំណាចតុលាការ ដែលជាស្ពានដើម្បីដោះស្រាយបញ្ហារវាងអន្តរទំនាក់ទំនងរបស់មនុស្សក្នុងសង្គម។

សាំង អូហ្គូស្តាំង(SANG AUGGOSTANG) (៤៣០-៣៥៤ មុនគ្រិស្តសករាជ) ជាទស្សនវិទូគ្រិស្តសាសនាក្នុងទីក្រុងមួយឈ្មោះ តាហ្គាសនុយមីដ្យា សព្វថ្ងៃទីនោះឈ្មោះថា ស៊ុកអារ៉ាស នៃប្រទេសអាល់ហ្សេរី។ សន្តិភាពគឺជាលក្ខខណ្ឌទីមួយ នៃគោលបំណងរបស់ព្រះមហាក្សត្រ ឬអ្នកដែលមានឋានៈខ្ពង់ខ្ពស់បំផុត។ បើមានសន្តិភាព គេអាចឆ្ពោះទៅរកភាពស្រុះស្រួលគ្នា ភាពស៊ីសង្វាក់គ្នារវាងអ្នកដឹកនាំ និងអ្នកត្រូវគេដឹកនាំ ហើយសំខាន់បំផុត គឺការយល់ព្រមពីសំណាក់អ្នកនៅក្រោមបង្គាប់។ សន្តិភាពរបស់បូរី គឺថាភាពស្រុះស្រួលប្រកបដោយសណ្តាប់ធ្នាប់នៃបញ្ជា និងអ្នកដែលគោរពតាមបទបញ្ជា[២៣]។ តាមទស្សនៈ SANG AUGGOSTANG មានន័យថា សមាជិកសង្គមទាំងមូលអាចស្រុះស្រួលទៅកើត លុះត្រាតែមានយុត្តិធម៌សម្រាប់ទាំងអស់គ្នាឯកភាពគ្នា ពោលគឺពុំមែនយុត្តិធម៌សម្រាប់តែអ្នកបញ្ញា ឬក្រុម(Elite)នោះទេ។ ដើម្បីឲ្យមានភាពរលូននៃការដឹកនាំរបស់ប្រទេសជាតិមួយ ចាំបាច់ត្រូវកើតឡើងក្រោមក្រិត្យក្រមច្បាប់ទម្លាប់របស់ប្រទេស និងមានការ

---

[២២] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ៩៧-១០០

[២៣] អ៊ំ ប៉ុម ប្រវត្តិគំនិតនយោបាយបច្ចឹមប្រទេស ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ៧០-៧១

ឯកភាពជាទូទៅ ឬយ៉ាងហោចណាស់ដោយមតិភាគច្រើន(ជាមតិដែលសម្រេចចិត្តដោយពុំមានការភ័យខ្លាចគ្មានការគាបសង្កត់) ដែលស្រដៀងគ្នាទៅនឹងទស្សនវិទូមុនៗដែរ។ ដូច្នេះ អាចសន្និដ្ឋានថា លោកឲ្យតម្លៃទៅលើការព្រមព្រៀងរបស់ប្រជាពលរដ្ឋជាធំ។

ខុងជឺ(CONFUCIUS) (៥៥១-៤៧៩ មុនគ្រិស្តសករាជ) ជាទស្សនវិទូចិនមួយរូបល្បីល្បាញមានកិត្តិនាមស្មើនឹង SOCRATE នៅប្រទេសក្រិច។ CONFUCIUS បានហាមមិនឲ្យធ្វើសង្គ្រាមជាដាច់ខាតទោះបីឋិតក្នុងស្ថានភាពបែបណាក៏ដោយ។ CONFUCIUS មើលឃើញសង្គ្រាមជាប្រភពអមនុស្សធម៌។ លោកមិនពេញចិត្តចំពោះអំពើឃោរឃៅអមនុស្សធម៌ ដែលពួកមនុស្សធ្វើទៅលើសត្វ និងធ្វើទៅលើ មនុស្សគ្នាឯងដូចជា ករណីកងទ័ពចាប់ឈ្លើយសឹកមកកាត់ដៃ កាត់ជើង បោះទៅលើចុងលំពែង និងចាប់មនុស្សយកទៅស្រុះទឹកក្តៅដូចមាន់នោះទេ។

CONFUCIUS មើលឃើញយុត្តិធម៌ក្នុងរូបភាពពីរយ៉ាង គឺយុត្តិធម៌នៅក្នុងសង្គម និងយុត្តិធម៌នៅក្នុងគ្រួសារ។ ពីដំបូង យុត្តិធម៌កើតមាននៅក្នុងគ្រួសារជាមុនសិន ក្រោយមកទើបរាលដាលដល់សង្គម។ CONFUCIUS មើលឃើញយុត្តិធម៌ពួនសម្ងំនៅក្នុងចិត្ត និងកាយវិការរបស់មនុស្ស។ ហេតុនេះ ដើម្បីឲ្យយុត្តិធម៌សង្គមកើតមានឡើងជាជំហានទីមួយ ត្រូវធ្វើឲ្យមានយុត្តិធម៌នៅក្នុងគ្រួសារជាមុនសិន។ ម្យ៉ាងវិញ ទៀតCONFU-CIUS ចាត់ទុកថា ការគ្រប់គ្រងគ្រួសារដ៏ធំដែលហៅថា រដ្ឋនោះដោយគុណធម៌មានលក្ខណៈល្អប្រសើរជាងការគ្រប់គ្រងដោយច្បាប់។ លោករំពឹងថា ការគ្រប់គ្រងបែបនេះអាចមានដំណើរការទៅរួច និងឈានដល់សម្រេចបានផ្លែផ្កាទៀតផង។ ការគ្រប់គ្រងល្អ គឺមានន័យថា ធ្វើសង្គមឲ្យមានសណ្តាប់ធ្នាប់ និងជីវភាពជាតិរុងរឿង។ ចង់ឲ្យជីវភាពរុងរឿង ត្រូវចេះគ្រប់គ្រងជីវភាពគ្រួសារឲ្យបានល្អជាមុនសិន។ ចង់គ្រប់គ្រងជីវភាពគ្រួសារឲ្យបានល្អ លុះត្រាតែមានឆន្ទៈស្មោះត្រង់ និងមានការអប់រំល្អ។ ផ្ទុយទៅវិញ នៅពេលដែលមនុស្សមានការអប់រំនាំឲ្យជីវភាពគ្រួសាររបស់គេត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព។ បើជីវភាពគ្រួសារត្រូវបានគ្រប់គ្រងនាំឲ្យជីវភាពសង្គមជាតិមានសណ្តាប់ធ្នាប់ ពេលនោះពិភពលោកនឹងមានសន្តិភាព។ CONFUCIUS យល់ព្រមថា គ្រប់មនុស្សទាំងអស់គួរតែទទួលបាននូវអ្វីដែលគេចង់បាន ហើយអ្វីដែលមនុស្សចង់បានជាងគេ គឺសុភមង្គល។ ដើម្បីទទួលបានសុភមង្គលមនុស្សហ៊ានពលិកម្មគ្រប់បែបយ៉ាង។ ផុសចេញពីទស្សនៈបែបនេះ CONFUCIUS បានធ្វើការអះអាងទៅលើមុខងាររបស់រដ្ឋាភិបាល"រដ្ឋាភិបាលដែលល្អ គឺរដ្ឋាភិបាលដែលធ្វើយ៉ាងណាឲ្យប្រជាជន របស់ខ្លួនមានសុភមង្គល"។ ដើម្បីឲ្យសង្គមមានសុភមង្គល CONFUCIUS បានមើលឃើញទម្រង់គ្រប់គ្រងរដ្ឋក្នុងរូបភាពជាគ្រួសារដ៏សែនធំមួយដែលមានស្តេចជាឪពុក។ រដ្ឋប្រភេទនេះមានអត្ថិភាពឡើងគឺដើម្បីធ្វើយ៉ាងណាឲ្យជីវភាពនៅក្នុងសង្គមទាំងមូលមានលក្ខណៈល្អប្រសើរជាង គឺដើម្បីបម្រើផលប្រយោជន៍គ្រួសារដ៏សែនធំនេះ។ តាមទស្សនៈ CONFUCIUS ស្តេចត្រូវតែផ្គត់ផ្គង់ចិញ្ចឹមថែរក្សា និង បង្ហាត់បង្រៀនដល់ប្រជារាស្ត្រ ដែលត្រូវជាកូនចៅរបស់ព្រះអង្គ។ អំណាចនៃរដ្ឋប្រភេទនេះត្រូវតែជាអំណាចបិតុនិយម ដែលតំណាងរបស់ព្រះមហាក្សត្រ។ CONFUCIUS ចាត់ទុកថា នៅក្នុងសង្គមដាច់ខាតត្រូវមានពួកប្រភេទអភិជនពួកមនុស្សសាមញ្ញ និងពួកមនុស្ស

ល្ងង់ខ្លៅ។ អ្វីដែលចាប់អារម្មណ៍នោះគឺ CONFUCIUS មិនបានប្រើប្រាស់កម្លាំងខាងក្រៅមកជួយរៀបចំ និងដោះស្រាយបញ្ហាសង្គមមនុស្សឡើយ។ តែលោកបានប្រើក្បួនច្បាប់សីលធម៌ធ្វើជាមូលដ្ឋានសម្រាប់ដោះស្រាយបញ្ហាសង្គមទៅវិញ។ និយាយឲ្យខ្លីទៅវិធីសាស្ត្ររបស់លោកទាំងអស់អប់រំមនុស្សឲ្យមានជំនឿលើខ្លួនឯង អប់រំខ្លួនឯងប្រកាន់នូវក្រមសីលធម៌។ល។ ធម៌ទាំងនេះជាប្រទីបបំភ្លឺផ្លូវឆ្ពោះទៅដល់សេចក្តីសុខ សុខភាព ស្ងប់ស្ងៀម ឬក៏ទទួលបានជាគុមួយ ដែលជាវត្ថុបំណងរបស់មនុស្ស គឺសុភមង្គល[២៤]។

លោកម៉ាគីអាវែលី(NiccoloMachiavelli)(១៤៦៩-១៥២៧) ជាទស្សនវិទូនយោបាយ ប្រវត្តិវិទូ អ្នកទ្រឹស្តីសង្គ្រាម និងជាអ្នកបម្រើការងារសង្គមដ៏ចំណាននៃជនជាតិអ៊ីតាលីម្នាក់។ លោកចាត់ទុកប្រជាធិបតេយ្យថាជាទម្រង់គ្រប់គ្រងត្រឹមត្រូវរបស់មហាជន។ លោកបានពន្យល់ថា ប្រជាជនទូទៅអាចដោះស្រាយបញ្ហាបានល្អប្រសើរជាងស្តេច។ លោកបានបញ្ជាក់ថា "សាធារណៈរដ្ឋអាចផ្តល់ផ្តង់ស្ថេរភាព សេរីភាព និងសមភាពសង្គម"។ ជាធម្មតានៅក្នុងសាធារណៈរដ្ឋត្រូវតែមានទិសដៅពីរប្រឈមមុខគ្នា ទីមួយខាងប្រជាជន និងទីពីរខាងវណ្ណៈខ្ពស់។ នៅរ៉ូមបុរាណ សាធារណៈរដ្ឋចម្រុះកើតចេញមកពីលទ្ធផលនៃការតស៊ូ និងការសម្រុះសម្រួលគ្នារវាងប្រជាជន និងអភិជន។ លោកបានបញ្ជាក់បន្ថែមថា ប្រជាជនស្មោះត្រង់ និងមានប្រាជ្ញាជាងអ្នកដឹកនាំរដ្ឋម្នាក់ គឺស្តេច។ លោកយល់ថា ប្រសិនបើស្តេចមួយអង្គដឹកនាំបានល្អ បង្កើតច្បាប់បានល្អ នោះប្រជាជនក៏ជាអ្នកការពារស្ថាប័នរដ្ឋនោះបានល្អជាងដែរ។ ប្រជាជនមិនសូវមានកំហុសក្នុងកិច្ចការដឹកនាំរដ្ឋទេ[២៥]។

លោកថូម៉ាស ហូប(THOMAS HOBBES)(១៥៨៨-១៦៧៩) ជាទស្សនវិទូ និងអ្នកទ្រឹស្តីនយោបាយជនជាតិអង់គ្លេស។ លោកចង់ផ្តល់ឲ្យមនុស្សនូវសន្តិភាព ដែលជាសេចក្តីប្រាថ្នាតែមួយគត់របស់គាត់ និងចង់ឲ្យមានការធានាឲ្យមានភាពសុខសាន្ត និងការរួបរួមគ្នាតែប៉ុណ្ណោះ។

សេរីភាពត្រូវបានលោក THOMAS HOBBES យល់ថា ជាសិទ្ធិធ្វើអ្វីៗគ្រប់បែបយ៉ាងដែលច្បាប់មិន ហាមឃាត់។ លោកអះអាងថា ទីណាដែលព្រះមហាក្សត្រមិនបានសរសេរហាមពីអ្វីមួយនោះ ទីនោះពលរដ្ឋមានសេរីភាពគ្រប់គ្រាន់អាចធ្វើអ្វីមួយ ឬមិនធ្វើអ្វីមួយបានអាស្រ័យដោយការប្រុងប្រយ័ត្នរៀងៗខ្លួន តែសេរីភាពអាចលក់ និងទិញបានដោយគ្រាន់តែចុះកិច្ចសន្យារវាងគ្នានិងគ្នា[២៦]។ ថ្វីត្បិតតែទស្សនៈរបស់លោក HOBBES មានទំនោរទៅរករាជានិយមផ្តាច់ការ(Absolut Monarchete) ច្រើនក៏ដោយ ប៉ុន្តែលោកបានលើកឡើងថា ការបង្កើតជាក្រឹត្យក្រមក្នុងការបែងចែកអំណាច គឺសំដៅទៅលើការការពារសន្តិសុខ សន្តិភាព តម្លាភាព សមភាព ស្ថេរភាព និងរក្សាផលប្រយោជន៍រួមដល់សមាជិកសង្គម និងបានបើកឲ្យមានពន្លឺខ្លះៗ ឆ្ពោះទៅរកគោលការណ៍ដឹកនាំបែបប្រជាធិបតេយ្យផងដែរ។

---

[២៤] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ១១៤

[២៥] ដ.ឯ.ម. ទំព័រ ១៨១

[២៦] www: tep.utm.edu/h/hobmarn; htmdattd

លោក ចន ឡុក (JOHN LOCKE)(១៦៣២-១៧០៤) ជាទស្សនវិទូ និងជាអ្នកទ្រឹស្តីនយោបាយជនជាតិអង់គ្លេស ជាស្ថាបនិកទ្រឹស្តីសេរីនិយម។ លោក JOHN LOCKE បានបកស្រាយស្ថានភាពធម្មជាតិរបស់មនុស្សជាស្ថានភាពដែលមនុស្សមានសេរីភាពគ្រប់គ្រាន់ក្នុងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល។ ស្ថានភាពធម្មជាតិ ជាស្ថានភាពដែលពោរពេញទៅដោយសមភាព ទាំងអំណាច ទាំងសិទ្ធិ សុទ្ធតែស្មើៗគ្នាសម្រាប់គ្រប់បុគ្គលទាំងអស់ដោយមិនមានបុគ្គលណាម្នាក់មានសិទ្ធិអំណាចច្រើនជាងបុគ្គលដទៃ ហើយសិទ្ធិសេរីភាពមិនអាចកាត់ផ្តាច់ពីបុគ្គលឡើយក្នុងស្ថានភាពធម្មជាតិនោះទេ។ សភាពធម្មជាតិ ជាកន្លែងដំបូងដែលបានផ្តល់សិទ្ធិឲ្យមនុស្ស។ ស្ថានភាពធម្មជាតិ ជាសភាពសន្តិភាព និងជាសភាពដែលមនុស្សមានសុឆន្ទៈចង់ជួយគ្នាទៅវិញទៅមក ជាសភាពដែលមនុស្សមានវិចារណញ្ញាណអាចយល់ដឹងច្បាប់ធម្មជាតិ និងជាសភាពដែលមនុស្សចេះសម្របសម្រួលអាកប្បកិរិយារបស់ខ្លួនទៅនឹងច្បាប់ធម្មជាតិ។ យោងតាមទស្សនៈរបស់លោក JOHN LOCKE ជាមនុស្សមានសិទ្ធិរស់នៅសេរីភាពនេះជាលក្ខណៈពិសេសតាមសភាពធម្មជាតិតាំងពីកំណើតមក។ តែជាសភាពធម្មជាតិក៏ជាសភាពខ្វះខាតមិនមានការកំណត់ច្បាប់ និងប្រកាសឲ្យប្រើច្បាប់សម្រាប់ទាំងអស់គ្នាឡើយ។ ក្នុងសភាពធម្មជាតិ ខ្វះខាតនូវអំណាចតុលាការសម្រាប់ទប់ស្កាត់មិនឲ្យមានការសងសឹកគ្នា ការដណ្តើកគ្នាយកឈ្នះយកចាញ់តាមលក្ខណៈបុគ្គល ដែលស្តែងឡើងក្នុងរូបភាព ជាកូនក្តីផង ជាមេធាវីផង ជាចៅក្រមផងដែរ។ ប្រព័ន្ធរស់នៅក្នុងសភាពធម្មជាតិ មិនអាចឋិតនៅបានទេ ដូច្នេះ បើកម្មសិទ្ធិរបស់មនុស្សមិនអាចរក្សាបានល្អទេ បើគ្មានសង្គមក៏គ្មានរដ្ឋដែរ។ ដូច្នេះ សង្គមជាអ្នកថែរក្សា ជាអ្នកជួយសម្រួលស្ថានភាពដល់កម្មសិទ្ធិទាំងនោះ។

បញ្ញត្តិស្តីអំពី សភាពធម្មជាតិនេះមានសារៈសំខាន់ណាស់ចំពោះលោក JOHN LOCKE ពីព្រោះថា សេរីភាព ដែលជាទ្រព្យដ៏ពិសិដ្ឋរបស់មនុស្សក៏កើតពីធម្មជាតិដែរ។ ដោយសារសេរីភាពនេះហើយដែលធ្វើឲ្យមនុស្សមានសិទ្ធិជាប់មកជាមួយនឹងខ្លួនគេតែម្តង។ លោក JOHN LOCKE គឺជាអ្នកបង្កើតទ្រឹស្តីបែងចែកអំណាចដែលជាមូលដ្ឋាននៃនីតិរដ្ឋតាមគោលការណ៍បែងចែកអំណាចរបស់លោក JOHN LOCKE ចែកជាបីគឺៈ

១-អំណាចនីតិបញ្ញត្តិ ស្ថិតក្នុងដៃរដ្ឋសភា(Parlement)

២-អំណាចនីតិប្រតិបត្តិ ស្ថិតក្នុងដៃរដ្ឋាភិបាល តុលាការ និងយោធា

៣-អំណាចសហព័ន្ធ(Ferdaration or union)ស្ថិតក្នុងដៃស្តេចនិងមន្ត្រីនានាដែលជាអំណាចសម្រាប់ចុះសន្ធិសញ្ញានានា និងប្រកាសសង្គ្រាម។

ស្តេច ជាប្រមុខរដ្ឋនៃអំណាចនីតិប្រតិបត្តិ និងអំណាចសហព័ន្ធ។ អភ័យឯកសិទ្ធិរបស់រដ្ឋាភិបាលត្រូវបានកំណត់ក្នុងច្បាប់។ អំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ មិនត្រូវស្ថិតក្នុងដៃរបស់បុគ្គលណាមួយឡើយ ព្រោះបើបុគ្គលនោះយកអំណាចទៅប្រើក្នុងដៃបុគ្គលដោយពុំបានបម្រើផលប្រយោជន៍រួម ធ្វើឲ្យកើតមាននូវរបបផ្តាច់ការ។ ដូច្នេះ ការបែងចែកអំណាច ជាវិធីសាស្ត្រជៀសវាងមិនឲ្យកើតមានឡើងនូវការប្រើអំណាចតាមទំនើងចិត្តបែបអាជ្ញាព្រឹត្ត ដែលជាកត្តាមិនធានាដល់សិទ្ធិសេរីភាព និងកម្មសិទ្ធិរបស់ពលរដ្ឋឡើយ។ រដ្ឋាភិបាល ត្រូវតែគោរពច្បាប់រដ្ឋទាំងមូល។ មានន័យថា អំណាចនីតិប្រតិបត្តិ ពុំមែនជាអ្នកបង្កើតច្បាប់

ហើយក៏មិនមែនជាអំណាចទីមួយនោះឡើយ។ ប្រជាពលរដ្ឋត្រូវស្ថិតនៅលើអធិបតេយ្យភាព មានសិទ្ធិក្នុងនយោបាយ មានសិទ្ធិរិះគន់ ប្រឆាំង(ដែលសកម្មភាពតវ៉ាទាំងនេះ ស្ថិតក្នុងឥរិយាបថ ស្ថាបនា នីតិវិធីស្របច្បាប់ត្រឹមត្រូវ) ទៅនឹងរដ្ឋាភិបាលណាដែលមានឆន្ទៈនយោបាយផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ សកម្មភាពនៃការអនុវត្តន៍សិទ្ធិសេរីភាពនេះ គឺវាបានបង្កើតឲ្យមានតុល្យភាពផ្នែកនយោបាយក្នុងសង្គម។

លោក ហ្សង់ហ្សាក់រូសូ(JEAN JACQUES ROUSSEAU)(១៧១២-១៧៧៨) ជាទស្សនវិទូបារាំង ជាអ្នកទ្រឹស្តីនយោបាយ និងជាអ្នកក្រមសីលធម៌[២៧]។

ដើម្បីឲ្យមានការកើតឡើងនូវឆន្ទៈរួមលោក JEAN JACQUES ROUSSEAU បានគិតថា ជាការចាំបាច់ត្រូវការនូវលក្ខន្តិកៈមួយចំនួន ហើយជាបឋម គឺសមភាពនៅក្នុងសង្គម។ លោកទទូចឲ្យមូលដ្ឋាននយោបាយមានការបង្រួបបង្រួមតែមួយ គឺចង់ឲ្យស្មារតីនយោបាយនៅក្នុងសង្គមស្តែងឡើងក្នុងរូបភាពការបញ្ចេញមតិរបស់ខ្លួនឯងផ្ទាល់។ ជាពិសេស គឺមិនចង់ឲ្យក្រុមវណ្ណៈណាមួយកាន់កាប់អំណាចរដ្ឋ ផ្តាច់មុខតែឯងឡើយ។ លោកបញ្ជាក់ថា ដោយសារឆន្ទៈមិនអាចប្តូរបាន និងមិនអាចលក់បានទេ។ ហេតុដូច្នេះ ឆន្ទៈក៏មិនអាចតំណាងបានដែរ។ អំណាចបែបតំណាង គឺជាអំណាចបែបទាសភាព។ ចំពោះបញ្ហាទម្រង់រដ្ឋវិញ លោកមិនអនុញ្ញាតឲ្យមានរបបគ្រប់គ្រងបែបតំណាងឡើយ ប៉ុន្តែលោកគាំទ្ររបបគ្រប់គ្រងបែបប្រជាធិបតេយ្យផ្ទាល់។

ស្តីអំពីប្រជាធិបតេយ្យ លោក ROUSSEAU ចង្អុលបង្ហាញថា អធិបតេយ្យរបស់ប្រជាជនស្ថិតនៅជារបស់ប្រជាជន។ អធិបតេយ្យនេះពុំអាចផ្ទេរទៅឲ្យនរណាម្នាក់បានឡើយ។ សង្គម គឺជាសំណុំនៃមនុស្សទាំងអស់ ហើយគ្មានអ្នកណាម្នាក់បាត់បង់សេរីភាពរបស់គេទេ។ សេរីភាព និងសមភាពរបស់គេម្នាក់ៗត្រូវបានធានា។ សង្គមនយោបាយជាអ្នកសង្គ្រោះអ្វីដែលមនុស្សមានកាលនៅក្នុងសភាពធម្មជាតិ គឺមានសេរីភាពនិងសមភាព ដោយធានាសន្តិសុខរបស់បុគ្គលផងដែរ។ នៅក្នុងកិច្ចសន្យា គេមិនអាចប្រគល់អំណាចទៅឲ្យស្តេចមួយអង្គបានទេ ពីព្រោះថា ការរស់នៅចំណុះស្តេចមិនប្រសើរជាងការរស់នៅក្នុងសភាពធម្មជាតិទេ។

លោក JEAN JACQUES ROUSSEAU បានរិះគន់ដល់អ្នកតំណាង ពីព្រោះប្រជាធិបតេយ្យមានដើមកំណើតពីប្រជារាស្ត្រ ដែលជាអ្នកកាន់កាប់អធិបតេយ្យ។ ប្រជារាស្ត្រ ត្រូវសម្រេចអ្វីៗដោយខ្លួនឯង។ គេអាចប្រតិបត្តិតាមឆន្ទៈរបស់អ្នកណាម្នាក់ តែគេមិនអាចតំណាងឆន្ទៈរបស់អ្នកនោះបានទេ។ ដូច្នេះ អ្នកតំណាងអាចធ្វើឲ្យប្រជាធិបតេយ្យក្លាយពីល្អទៅអាក្រក់បាន ពីព្រោះអ្នកតំណាងប្រាកដជាជ្រើសរើសអ្វីទៅតាមបំណងរបស់គេ មិនមែនទៅតាមបំណងរបស់ប្រជារាស្ត្រ។ លោក ROUSSEAU មិនយល់ព្រមឲ្យមានអ្វីដែលជារបបតំណាងឡើយ។ គាត់បាននិយាយយ៉ាងច្បាស់ថា កាលណាមានការបោះឆ្នោត ហើយបើគ្មានការធានាចំពោះអ្នកតំណាងទេ នោះប្រជារាស្ត្របានលក់សេរីភាពរបស់គេហើយ។

ស្តីពីប្រជាធិបតេយ្យ លោក ROUSSEAU បានលើកឡើងនូវមធ្យោបាយមួយចំនួន ដើម្បីរៀបចំរបប

[២៧] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ១៤១

នយោបាយដែលត្រូវបានធានាសេរីភាពរបស់ប្រជារាស្ត្រ។ គោលការណ៍របស់ប្រជាធិបតេយ្យ គឺថាប្រជាជនទាំងមូល ជាម្ចាស់នៃអធិបតេយ្យ ហើយប្រជារាស្ត្រខ្លួន ជាអ្នកប្រើប្រាស់អធិបតេយ្យនេះ។ នេះជាប្រជាធិតេយ្យរបស់លោក ROUSSEAU ។ តើប្រជាធិបតេយ្យ រាស្ត្រប្រើប្រាស់អធិបតេយ្យដោយខ្លួនគេផ្ទាល់យ៉ាងដូចម្តេច? គេប្រើប្រាស់អធិបតេយ្យតាមរយៈការបង្កើតច្បាប់។ ច្បាប់ជាសេចក្តីប្រកាសជាសាធារណៈ និងជាឱឡារិកនូវឆន្ទៈទូទៅលើកម្មវត្ថុរួមមួយ នេះគឺជាជំនឿនៅក្នុងច្បាប់ជាប្រភពនៃសេរីភាព។ ប្រភពនៃច្បាប់ គឺឆន្ទៈទូទៅ។ ឆន្ទៈទូទៅ គឺជាចំនួនបូករួមនៃឆន្ទៈរបស់ប្រជាពលរដ្ឋទាំងមូល។ លោក ROUSSEAU បានផ្តល់ឧទាហរណ៍ថា បើរដ្ឋមានពលរដ្ឋចំនួន១០០០០នាក់ នោះសមាជិកម្នាក់ៗ រដ្ឋមានចំណែករបស់គេនូវចំនួន ១/១០០០០នៃអំណាចកំពូល។ ស្តេចមួយអង្គ សភាមួយរូប គណបក្សមួយ សមាគមមួយមានឆន្ទៈរួមរបស់គេមួយ ប៉ុន្តែមិនមែនឆន្ទៈទូទៅទេ។ សេចក្តីសម្រេចដែលអាចយកជាបានការ ទាល់តែមានប្រជារាស្ត្រទាំងមូលជាអ្នកសម្រេច គឺជាឆន្ទៈរបស់ប្រជារាស្ត្រទាំងមូល។ ច្បាប់ ជាឆន្ទៈទូទៅ ច្បាប់ត្រូវធ្វើក្នុងគោលដៅទូទៅសម្រាប់គោលការណ៍ធំៗ មិនមែនសម្រាប់បញ្ហាលំអិត ដែលជាកិច្ចការរបស់រដ្ឋាភិបាលទេ។ ក្នុងការអនុវត្តន៍ទូទៅក៏ដូច្នេះដែរ គឺជាច្បាប់សម្រាប់ពលរដ្ឋទាំងអស់គ្នាអនុវត្ត។ នេះជាទស្សនាទានរបស់លោក ROUSSEAU ហើយក៏ជាទស្សនាទានរបស់ច្បាប់សម័យទំនើបដែរ។

និយាយពីអធិបតេយ្យ លោក ROUSSEAU ថា តំណាងរាស្ត្រមិនមែនជាតំណាងរាស្ត្រទេ តំណាងរាស្ត្រគ្រាន់តែជាស្នងការរបស់រាស្ត្រតែប៉ុណ្ណោះ (Commissaire) តំណាងរាស្ត្រមិនអាចធ្វើសេចក្តីសម្រេចជាស្ថាពរណាមួយបានទេ។ លោក ROUSSEAU បានបញ្ជាក់បន្ថែមថា អ្វីដែលប្រជាពលរដ្ឋខ្លួនឯងបានអនុម័តគឺជាច្បាប់។ ច្បាប់ដែលរាស្ត្រខ្លួនឯងមិនបានអនុម័តមិនមែនជាច្បាប់ទេ បើរាស្ត្រខ្លួនឯងមិនបានធ្វើអន្តរាគមន៍ដោយផ្ទាល់យ៉ាងហោចណាស់ក៏មានប្រជាមតិ ទទួលយល់ព្រមពីរាស្ត្រដែរ។ ច្បាប់សំខាន់ៗរបស់រដ្ឋត្រូវតែឲ្យប្រជារាស្ត្រជាអ្នកអនុម័ត។ ចំពោះបញ្ហាដែលពុំសូវសំខាន់ក៏ត្រូវទុកឲ្យតំណាងរាស្ត្រជាអ្នកអនុម័ត។ លោក ROUSSEAU បានទាញយកការពន្យល់ទៅតាមប្រវត្តិសាស្ត្រ គំនិតឲ្យមានអ្នកតំណាង ជាគំនិតដែលកើតឡើងពីរដ្ឋាភិបាលសហព័ន្ធ ដែលធ្វើឲ្យមនុស្សបាត់បង់កិត្តិយសជាមនុស្ស។ លោក ROUSSEAU បានរិះគន់ទៅលើប្រជារាស្ត្រអង់គ្លេសយ៉ាងដូច្នេះថា ប្រជារាស្ត្រគិតថា ខ្លួនមានសេរីភាពនោះ គឺជាការភាន់ច្រឡំណាស់។ ប្រជារាស្ត្រមានសេរីភាព តែនៅពេលមុនការបោះឆ្នោតជ្រើសរើសសមាជិកសភាតែប៉ុណ្ណោះ។ នៅពេលដែលគេជ្រើសរើសតំណាងរាស្ត្រគេ ហើយប្រជារាស្ត្រនឹងក្លាយទៅជាទាសកររបស់សមាជិកសភាទៅវិញ។ អ្នកតំណាងរាស្ត្រត្រូវកម្រិតឲ្យមានការជ្រើសរើសជាថ្មីត្រឹមតែម្តង ឬពីរដង បន្ទាប់មកត្រូវរងចាំពីរ ឬបីឆ្នាំទៀត ទើបអាចឈរឈ្មោះឲ្យគេជ្រើសរើសជាថ្មីម្តងទៀត។ ត្រូវមានច្បាប់ដាក់ទោសចំពោះអ្នកតំណាង ដែលមិនអនុវត្តឆន្ទៈរបស់ប្រជារាស្ត្រ ឬកម្មវិធីរបស់ខ្លួន។ លោក ROUSSEAU បានធ្វើការវែកញែករវាងអត្ថិភាពរបស់រដ្ឋ និងអត្ថិភាពរបស់រដ្ឋាភិបាល។ នេះជាចំណុចមួយដែលខុសពីទស្សនៈរបស់អ្នកនិពន្ធមុនៗ។ អត្ថិភាពរបស់រដ្ឋ គឺធ្វើឲ្យមានអធិបតេយ្យរបស់ប្រជារាស្ត្រ អធិបតេយ្យរបស់រាស្ត្រស្ថិតនៅក្នុងអំណាចនីតិបញ្ញត្តិ ដែលជាអំណាចធ្វើច្បាប់ និងលុបច្បាប់។ អធិបតេយ្យរបស់ប្រជារាស្ត្រ គឺប្រជារាស្ត្រជាអ្នកចាត់ចែងដោយផ្ទាល់។ អធិបតេយ្យរបស់រដ្ឋាភិបាល

ទាក់ទងនឹងការអនុវត្តន៍ច្បាប់។ រដ្ឋាភិបាលគ្រាន់តែជាអ្នកតំណាងរបស់រាស្ត្រនិងរបស់ច្បាប់ រដ្ឋមន្ត្រីជាខ្ញុំបម្រើរាស្ត្រ ប៉ុន្តែរដ្ឋមន្ត្រីក៏អាចត្រូវបានដកហូតងារផងដែរ។ រដ្ឋមន្ត្រី មិនមែនជាម្ចាស់កម្មសិទ្ធិនៃអំណាចនីតិប្រតិបត្តិទេ គេជាអ្នកទទួលខុសត្រូវរក្សាអំណាចទាំងនេះ។

លោក ROUSSEAU បានបញ្ជាក់ពីរបបប្រជាធិតេយ្យថា ជារបបដែលល្អឥតខ្ចោះ ប្រសិនបើរបបនយោបាយអាចឲ្យអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិមានការត្រួតពិនិត្យថ្លឹងថ្លែងឲ្យមានតុល្យភាពជាមួយគ្នា។ ការត្រួតពិនិត្យ និងថ្លឹងថ្លែងឲ្យមានតុល្យភាព គឺជាទ្រឹស្តីរបស់ប្រជាធិបតេយ្យ។ របបប្រជាធិបតេយ្យអាចដំណើរការទៅបានល្អ ប្រសិនបើប្រជារាស្ត្រមានកម្រិតយល់ដឹងខ្ពស់ និងមានសីលធម៌ល្អ។

ដើម្បីធានានូវសេរីភាពរបស់ប្រជាពលរដ្ឋ លោក ROUSSEAU បានលើកនូវគោលការណ៍ប្រជាធិបតេយ្យដែលមានន័យថា ប្រជាជនទាំងមូលជាម្ចាស់អធិបតេយ្យ ហើយប្រជាជនខ្លួនឯងជាអ្នកប្រើប្រាស់អធិបតេយ្យនេះ គឺត្រូវតាមរយៈការបង្កើតច្បាប់។ ច្បាប់ដែលបង្កើតហើយត្រូវបានអនុវត្តចំពោះមនុស្សទូទៅ។ ផ្ទុយទៅវិញ បើច្បាប់មិនត្រូវបានអនុវត្តចំពោះមនុស្សទូទៅទេ គឺមិនមែនជាប្រជាធិបតេយ្យទេ។ ក្នុងរបបប្រជាធិប-តេយ្យ រដ្ឋាភិបាលត្រូវតែខ្លាំង ប៉ុន្តែត្រូវចំណុះដោយច្បាប់។

ក្នុងស្នាដៃឈ្មោះកិច្ចសន្យាសង្គម លោក ROUSSEAU បានប្រៀបធៀបសង្គមស៊ីវិលទៅនឹងសភាពធម្មជាតិ។ លោកបានបញ្ជាក់ថា ក្នុងសភាពធម្មជាតិត្រូវបានដឹកនាំដោយសភាវគតិប៉ុណ្ណោះ ចំណែកក្នុងសង្គមវិញមនុស្សត្រូវបានស្រូបទាញយកអំពើយុត្តិធម៌ និងសីលធម៌។ តាមរយៈកិច្ចសន្យាសង្គម មនុស្សបាត់បង់នូវសេរីភាពជាលក្ខណៈធម្មជាតិរបស់ខ្លួន ប៉ុន្តែមនុស្សបានទទួលមកវិញនូវសេរីភាពជាពលរដ្ឋ និងសិទ្ធិជាកម្មសិទ្ធិលើអ្វីៗដែលគេមាន។ សេរីភាព ជាលក្ខណៈធម្មជាតិ មិនមែនជាសេរីភាពពិតប្រាកដទេ ពីព្រោះជាសេរីភាពដែលមិនទទួលការត្រួតពិនិត្យឡើយ ជាពិសេសទៅលើចំណង់គ្រប់ប្រភេទរបស់មនុស្ស។ ផ្ទុយទៅវិញ សេរីភាពតាមបែបសីលធម៌ ឬសេរីភាពផ្លូវចិត្ត ដែលមនុស្សទាំងអស់តែងតែប្រាថ្នាក្នុងសភាពជាពលរដ្ឋបានញ៉ាំងឲ្យមនុស្សក្លាយទៅជាម្ចាស់លើខ្លួនឯង ពីព្រោះគេបានគោរពចំពោះច្បាប់ ដែលគេបានតាក់តែងឡើងសម្រាប់ខ្លួនគេផ្ទាល់។ បើមានលក្ខណៈបែបនេះ ទើបគេចាត់ទុកថា មនុស្សអាចមានសេរីភាពទៅបាន។

លោក ROUSSEAU បានចែកសេរីភាពជាបីសណ្ឋាន ហើយសេរីភាពទាំងនេះមានការវិវត្តន៍រីកចម្រើនពីទាបទៅខ្ពស់[២៨]

១-សេរីភាពតាមបែបធម្មជាតិ និយាយដោយសាមញ្ញ សេរីភាពបែបធម្មជាតិរបស់មនុស្ស គឺជាសេរីភាពផ្អែកលើកម្លាំងបុគ្គល ដើម្បីធានាអះអាងចំពោះខ្លួនឯងផ្ទាល់។

២-សេរីភាពតាមបែបពលរដ្ឋសេរីភាព គឺជាសេរីភាពរឹងមាំ និងមានគ្រឹះត្រឹមត្រូវដោយសារសេរីភាពនេះទាក់ទងជាមួយច្បាប់ និងវិធានការរបស់សហគមន៍នយោបាយណាមួយ ដែលបានកំណត់ចំពោះ សមាជិក

---

[២៨] អ៊ុំ ប៉ុម ប្រវត្តិគំនិតនយោបាយបច្ចឹមប្រទេស ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ១២៥

របស់គេនូវអ្វីដែលគួរធ្វើ និងអ្វីដែលមិនគួរធ្វើ ក្នុងទំនាក់ទំនងជាមួយសមាជិកទាំងអស់របស់សហគមន៍។

៣-សេរីភាពផ្លូវចិត្ត សេរីភាពជាលក្ខណៈពលរដ្ឋនឹងនាំទៅដល់សេរីភាពមួយបែបទៀត គឺជាសេរីភាពផ្នែកសីលធម៌ ឬ សេរីភាពផ្លូវចិត្ត។ ដូច្នេះ សេរីភាពផ្លូវចិត្ត ជាសេរីភាពមួយបែបដែលបុគ្គលម្នាក់ៗឋិតក្នុងលក្ខណៈសេរី ចំពោះទំនាក់ទំនងជាមួយខ្លួនឯង។

ម៉ុងតេសគីយើ(BARON MONTESQUIEU CHARLES LOUIS) (១៦៨៩-១៧៥៥) ជាទស្សនវិទូនយោបាយ អ្នកប្រវត្តិសាស្ត្រ អ្នកនិពន្ធប្រលោមលោក និងអ្នកសង្គមវិទ្យាបារាំង។ គាត់ប្រឆាំងនឹងទ្រឹស្តីផ្តាច់ការ។ លោកព្យាយាមបកស្រាយឲ្យឃើញនូវលក្ខណៈខ្វះខាតនៃទម្រង់គ្រប់គ្រងរដ្ឋតាមបែបផ្សេងគ្នា។ គោលការណ៍សំខាន់លោក គឺផ្តត់ផ្តង់ច្បាប់ និងការបែងចែកអំណាចក្នុងរដ្ឋ[២៩]។

ចំពោះសេរីភាព លោកបានពោលថា ក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាជនធ្វើសកម្មភាពទៅតាមអ្វីដែលខ្លួនពេញចិត្ត។ ប៉ុន្តែសេរីភាពនយោបាយមិនអាចនឹងកើតមានក្នុងសេរីភាពឥតព្រំដែននោះទេ។ នៅក្នុងរដ្ឋាភិបាលក៏ដូចជានៅក្នុងសង្គមដែលដឹកនាំដោយច្បាប់ សេរីភាពអាចកើតមានតែក្នុងចំណោមនៃការធ្វើអ្វីមួយដែលជាឆន្ទៈរបស់យើង។ លោកបានគូសបញ្ជាក់ថា សេរីភាព គឺជាសិទ្ធិដែលធ្វើអ្វីគ្រប់បែបយ៉ាងដែលច្បាប់អនុញ្ញាត។ លោកបានលើកឡើងទៀតថា វាមិនអាចមានសេរីភាពទៅកើតទេ បើសិនជាអំណាចតុលាការ មិនអាចផ្តាច់ចេញពីអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ[៣០]។

ដើម្បីមានស្ថេរភាពក្នុងសាធារណៈក៏ដូចជានៅក្នុងរាជានិយម ចាំបាច់ត្រូវមានការបែងចែកអំណាចរដ្ឋព្រោះថា ការបែងចែកអំណាចរដ្ឋ អាចធ្វើឲ្យសមាជិកនៃសង្គមទទួលបាននូវសេរីភាព សុវត្ថិភាព យុត្តិធម៌ពិសេស គឺស្ថេរភាពសង្គមតែម្តង។ ការចែកអំណាចជាបីដូចខាងក្រោមៈ

១. អំណាចនីតិបញ្ញត្តិៈ ជាអំណាចធ្វើច្បាប់ កែច្បាប់ និងលុបច្បាប់។ អំណាចនីតិបញ្ញត្តិត្រូវប្រគល់ឲ្យទៅសភាពីរជាន់ជាអ្នកកាន់កាប់ គឺសភាអភិជន ឬសភាជាន់ខ្ពស់ និងសភាជាន់ទាប ឬសភាប្រជារាស្ត្រ។ ក្រៅពីបង្កើត ឬលុបច្បាប់។ អំណាចនេះនៅមានតួនាទីជាអ្នកតាមដានត្រួតពិនិត្យ នូវការប្រតិបត្តិរបស់ព្រះរាជា និងមាននាទីជាអ្នកកាត់ក្តីវិនិច្ឆ័យទៅលើសកម្មភាពប្រតិបត្តិក្នុងសង្គមទាំងមូល។

២. អំណាចនីតិប្រតិបត្តិៈ ជាអំណាចប្រតិបត្តិតាមឆន្ទៈរបស់អំណាចនីតិបញ្ញត្តិ សម្រាប់រៀបចំដឹកនាំសង្គមទាំងផ្ទៃក្នុងប្រទេសនិងលើឆាកអន្តរជាតិ និងជាអំណាចដែលមានសិទ្ធិប្រកាសសង្គ្រាម និងសន្តិភាព។ អំណាចនេះមានបង្កប់នូវចរិតជាអំណាចនៃច្បាប់ធម្មជាតិផងដែរ។ អំណាចនេះត្រូវបានប្រគល់ឲ្យទៅព្រះមហាក្សត្រជាអ្នកកាន់កាប់។ អំណាចនេះក្រៅពីការប្រតិបត្តិ គឺនៅមានសិទ្ធិជំទាស់ចំពោះអំណាចនីតិបញ្ញត្តិផងដែរតាមនីតិវិធី នៃការប្រើសិទ្ធិរបស់ព្រះមហាក្សត្រ។

---

[២៩] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ១៥៦

[៣០] អ៊ុំ ប៉ុម ប្រវត្តិគំនិតនយោបាយបច្ចឹមប្រទេស ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ១១៤-១១៥

៣. អំណាចតុលាការៈ ជាអំណាចវិនិច្ឆ័យដែលត្រូវបានគេប្រើប្រាស់នៅក្នុងក្របខ័ណ្ឌនៃច្បាប់រដ្ឋប្បវេណី ។ល។ អំណាចនេះ ត្រូវប្រគល់ឲ្យទៅសភាតាមរាជធានី/ខេត្តនីមួយៗ ដែលកាន់កាប់អំណាចតុលាការ។

លោកបានបន្ថែមទៀតថា គោលការណ៍ដែលបែងចែកអំណាចនេះធ្វើឡើងក្នុងគោលបំណងទប់ស្កាត់មិនអោយអំណាចបិតក្នុងដៃបុគ្គលណាមួយឡើយ។ កាលណាអំណាចបិតក្នុងដៃមនុស្សម្នាក់នោះអាចនឹងនាំទៅរកក្តីវិនាសដល់ប្រទេសជាតិបាន។ ព្រោះលោកយល់ថា សារជាតិរបស់មនុស្សបើកាលណាបានអំណាចនៅក្នុងដៃរបស់ខ្លួន ហើយរមែងចង់រក្សាអំណាចនោះបិតក្នុងដៃរបស់ខ្លួនជារៀងរហូត។ ហើយមនុស្សនឹងតស៊ូដើម្បីរក្សាអំណាចលុះដល់ដំណាក់ឈាមចុងក្រោយ។ ដូច្នេះត្រូវធ្វើយ៉ាងណាឲ្យអំណាចទប់អំណាច ពីព្រោះមនុស្សទាំងអស់ដែលមានអំណាចតែងមានការប្រើប្រាស់អំណាចផ្ទុយ និងហួសព្រំដែន។

លោកអាដាមស្មីត(ADAM SMITH) (១៧២៤-១៧៩០) ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Glasgow បង្រៀនមុខវិជ្ជាផ្នែកទស្សនវិជ្ជាទេវវិទ្យា សីលធម៌ នីតិសាស្ត្រ និងខាងសេដ្ឋកិច្ចនយោបាយ[៣១]។ ចំពោះគំនិតខាងនយោបាយ លោក ADAM SMITH បានលើកឡើងថា សេរីភាពខាងផ្នែកនយោបាយត្រូវតែមានទំនាក់ទំនងគ្នាទៅនឹងសេរីភាពខាងសេដ្ឋកិច្ច។ មនុស្សអាចប្រតិយាជលើគ្នាទៅវិញទៅមកដោយជោគជ័យ បើសិនជាគេរស់នៅក្នុងសង្គមមួយដែលមានសេដ្ឋកិច្ចសេរី។ តាមរយៈទស្សនៈរបស់លោក រដ្ឋាភិបាលនីមួយៗត្រូវមានមុខងារសំខាន់ៗ បី យ៉ាងៈ

១.ការពារជាតិ

២.ការគ្រប់គ្រងដោយមិនលំអៀងទៅលើប្រព័ន្ធយុត្តិធម៌

៣.សម្រួលចំពោះកិច្ចការសាធារណៈ និងស្ថាប័នដែលមានផលប្រយោជន៍ដល់សង្គម(ជាពិសេសបង្កើតវិស័យពាណិជ្ជកម្ម)។ ក្រៅពីនេះរដ្ឋាភិបាល មានកិច្ចការសំខាន់ពីរ ទៀតគឺៈ

ក.កិច្ចការសាធារណៈ ដូចជា ធ្វើផ្លូវ ធ្វើស្ពាន ធ្វើប្រឡាយទឹក ដែលបុគ្គលគ្មានលទ្ធភាពអាចធ្វើបាន។

ខ.ជួយឧបត្ថម្ភដល់ការអប់រំ ធ្វើសាលារៀន ហើយធ្វើយ៉ាងណាការពារការអប់រំឲ្យផុតពីជ្រុងអវិជ្ជមាននៃទំនើបនីយកម្ម។ លោកពោលពាក្យយ៉ាងដូច្នេះថា ការអប់រំត្រូវតែការពារឲ្យបាននូវជ្រុងអវិជ្ជមាននៃឥទ្ធិពលរបស់ទំនើបនីយកម្ម។ ចរិតអភិវឌ្ឍនៅតាមបណ្តាប្រទេសដែលមានកម្រិតសេដ្ឋកិច្ចជឿនលឿន ដូចជាៈ សហរដ្ឋអាមេរិក ជប៉ុន បារាំង អង់គ្លេស អូស្ត្រាលី កាណាដា ឥណ្ឌា ចិន កូរ៉េខាងត្បូង... ជាដើម គឺគេប្រមូល ចក្ខុវិស័យ ប្រាជ្ញាញាណ គតិបណ្ឌិត(របកគំហើញថ្មីៗ)ពីបណ្តាប្រជាពលរដ្ឋរបស់គេ ដើម្បីដណ្តើមឯកទេសកម្ម និងជើងឯកខាងសេដ្ឋកិច្ច និងបច្ចេកវិទ្យាក្នុងយុគសម័យដ៏ទំនើបនាពេលបច្ចុប្បន្ននេះ។

លោក កាន្ត (IMMANUEN KANT) (១៧២៤-១៨០៤) ជាទស្សនវិទូដ៏ល្បីល្បាញជនជាតិ

---

[៣១] អ៊ុំ ប៉ុម ប្រវត្តិគំនិតនយោបាយបច្ចឹមប្រទេស ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ១២៩,១៣០

អាឡឺម៉ង់[៣២]។ សេរីភាពពលរដ្ឋរបស់លោក KANT គឺជាសិទ្ធិរបស់បុគ្គលដែលឱនលំទោន ចំពោះតែច្បាប់មួយគត់ដែលពួកគេត្រូវអនុលោមតាម។ សេរីភាពដែលបាននិយាយនេះ គឺជាកម្មសិទ្ធិផ្ទាល់របស់ប្រជាពលរដ្ឋនៅក្នុងនីតិរដ្ឋ។ សេរីភាពរបស់មនុស្សរស់រានទៅបាន អាស្រ័យដោយឆន្ទៈផ្ទាល់របស់ច្បាប់។ សេរីភាពខាងនយោបាយក៏ដូច្នេះដែរ សេរីភាពនេះ អាចរស់រានមានជីវិតទៅបាន អាស្រ័យដោយច្បាប់ទាំងឡាយរបស់សហគមន៍។ ដោយឡែក សមភាពពលរដ្ឋ គឺជាសិទ្ធិដែលទទួលស្គាល់ដោយខ្លួនឯង និងចំពោះអ្នកណាមួយដែលយើងត្រូវតែធ្វើចំពោះគេ ហើយគេក៏ធ្វើចំពោះយើងវិញដែរ។ លោកលើកឡើងទៅទៀតថា សេរីភាពរបស់ពលរដ្ឋ គឺជាលក្ខខណ្ឌមួយ ដែលគ្មាននរណាម្នាក់អាចចាប់បង្ខំឲ្យគោរពផ្សេងទៀត ក្រៅពីការគោរពទៅលើសេចក្ដីប្រកាសរបស់ច្បាប់នោះឡើយ។ លោកក៏បានបន្តទៀតថា គប្បីជៀសវាងនូវករណី ដែលបុគ្គលត្រូវតែគោរពចំពោះឆន្ទៈដោយឡែកណាមួយរបស់អ្នកដទៃក្នុងករណីដែលបុគ្គលគិតថា ជាកាលៈទេសៈមួយដែលខ្លួនត្រូវប្រើប្រាស់សេរីភាពរបស់ខ្លួន។ លោកបានផ្សារភ្ជាប់សេរីភាពទៅនឹងច្បាប់។

ចំពោះលោក KANT ស្ដីពីការបែងចែកអំណាច គឺមានទស្សនៈដូចលោក JOHN LOCKE និងលោក MONTESQUIEU ដែរ។ លោក KANT បានអះអាងថា ដោយសារច្បាប់ការពារដល់សេរីភាព នោះក្បាលម៉ាស៊ីនដឹកនាំ គឺត្រូវតែចេញពីក្នុងជួរមហាជនតែប៉ុណ្ណោះ។ មេដឹកនាំត្រូវគិតថា ប្រជាជន គឺជាជនរួមជាតិតែមួយ។ គោលការណ៍នេះបានចែងក្នុងច្បាប់នានាក្នុងការបែងចែកអំណាចទាំង បី គឺៈ អំណាចតំណាងរាស្ត្រនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

លោកអេដម៉ាន់ បើក(EDMUND BURKE)(១៧២៩-១៧៩៧) ជាអ្នកនិពន្ធ និងទស្សនវិទូនយោបាយដ៏ល្បីល្បាញរបស់ប្រទេសអង់គ្លេស[៣៣]។

គោលបំណងសំខាន់របស់រដ្ឋ គឺការពារសណ្ដាប់ធ្នាប់ និងការពារច្បាប់។ ជាតុសំខាន់ពីក្នុងទ្រឹស្ដីនយោបាយរបស់លោក គឺស្ថេរភាពនយោបាយ និងស្ថេរភាពសង្គម។ លោកចូលចិត្តទម្រង់រដ្ឋដែលមានការប្រើប្រាស់អំណាចតាមរយៈតំណាងខុសប្លែកគ្នាពីទស្សនៈរបស់លោក ROUSSEAU ដែលចូលចិត្តការប្រើប្រាស់អំណាចដោយផ្ទាល់។ លោក បានអះអាងថា សភាអង់គ្លេស គឺជាទម្រង់អំណាចត្រឹមត្រូវ ហើយសកម្មភាពទាំងឡាយរបស់សភាមិនតម្រូវឲ្យមានការត្រួតពិនិត្យពីប្រជាពលរដ្ឋឡើយ។ ភាគតិចត្រូវដឹកនាំភាគច្រើនក្រោមឥទ្ធិពលនៃឆន្ទៈរួម។ អ្នកដែលជ្រើសរើសឡើងដោយប្រជាពលរដ្ឋ គឺពុំមែនធ្វើខ្លួនឲ្យទៅជាតំណាងក្នុងរូបភាពជាបេសកជន ដែលប្រជាពលរដ្ឋបញ្ជូនមកដើម្បីអនុវត្តសេចក្ដីណែនាំរបស់ប្រជាពលរដ្ឋ នោះឡើយ។

លោកហាមមិនឲ្យមានការធ្វើកំណែទម្រង់ក្នុងរូបភាពជាការទម្លាក់ចុះ ឬផ្ដួលរំលំរដ្ឋណាមួយនោះឡើយ កំណែទម្រង់រដ្ឋមិនមែនជាការសម្លាប់រដ្ឋនោះទេ តែជាការស្រោចស្រង់ឲ្យរដ្ឋនោះ អាចបន្តអត្ថិភាពរបស់ខ្លួន

[៣២] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្ដីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ២១៩

[៣៣] អ៊ុំ ប៉ុម ប្រវត្តិគំនិតនយោបាយបច្ចឹមប្រទេស ឆ្នាំ២០០៨ ទំព័រ ១៤១

តទៅទៀត។ អ្នកធ្វើកំណែទម្រង់រដ្ឋត្រូវចេះរៀបចំអាកប្បកិរិយារបស់ខ្លួន ដើម្បីបោះជំហានចូលទៅជិតចំណុចខ្វះខាតរបស់រដ្ឋឲ្យដូចជា ការចូលទៅមើលព្យាបាលរបួស ឬជំងឺបៅរបស់ឪពុកដោយទឹកចិត្តជ្រះថ្លា និងដោយប្រុងប្រយ័ត្នជាប់ជានិច្ច។

មានន័យថា រាល់ការដោះស្រាយចំពោះវិបត្តិធំៗរបស់សង្គមក្នុងប្រទេសមួយ ពុំមែនជារបៀបចាត់ការបែបបដិវត្ត បែបកញ្ឆក់ គំហុក ផ្ដាច់ផ្ដិល ឬផ្ដួលរំលំ ឬរំលាយចោលទាំងស្រុងនូវរចនាសម្ព័ន្ធនយោបាយ រដ្ឋបាលដឹកនាំទាំងខុសទាំងត្រូវដោយហិង្សានោះទេ។ រាល់ការកែប្រែរបៀបចាត់ចែងទម្រង់នៃការដឹកនាំរបស់រដ្ឋណាមួយទាមទារឲ្យមាននមធ្យោបាយសមស្របតាមពេលវេលា ថ្លឹងថ្លែង បើទោះបីមានចក្ខុវិស័យច្បាស់លាស់យ៉ាងណាក៏ដោយ ព្រោះថា ការប្រើហិង្សានយោបាយដើម្បីកែទម្រង់នយោបាយអាចបង្កឲ្យបែកបាក់នយោបាយផ្ទៃក្នុងរបស់ជាតិ និងការចងគំនុំនយោបាយដែលនាំឲ្យមានវិបត្តិធ្ងន់ធ្ងរជាងមុន។

ទ្រឹស្ដីរបស់លោក BURKE បើប្រៀបធៀបទៅនឹងប្រវត្តិកែទម្រង់រចនាសម្ព័ន្ធដឹកនាំនយោបាយក្នុងសង្គមខ្មែរ គឺមានលក្ខណៈផ្ទុយទាំងស្រុង។ នៅក្នុងសង្គមខ្មែរ បើចាប់រាប់ពីទសវត្សឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ មានរដ្ឋប្រហារដល់ទៅបីដង គឺនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្ដមសីហនុ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប៉ុត ពត ហៅ សាឡុត ស ធ្វើរដ្ឋប្រហារដោយយោធាទម្លាក់លោកប្រធានាធិបតី លន់ នល់ និងចុងក្រោយនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានធ្វើរដ្ឋប្រហារផ្ដួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ។ ចរិតនៃការធ្វើរដ្ឋប្រហារ និងការធ្វើបដិវត្តន៍របស់អ្នកដឹកនាំខ្មែរពុំមែនជាការកែទម្រង់រដ្ឋបាលដឹកនាំបែបសីលធម៌ ស្រោចស្រង់ សង្គ្រោះ ឬមានចរិតស្នេហរដ្ឋនោះទេ។ ការផ្លាស់ប្ដូរមេដឹកនាំរបស់ខ្មែរ គឺកើតឡើងក្នុងមហិច្ឆតាដណ្ដើមអំណាចគ្នា ក្នុងគំនុំគុំគួន រំលាយមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធដឹកនាំ បញ្ហានេះបណ្ដាលឲ្យក្លាយជាភ្លើងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ ចំណាយពេលអស់ជិតសាមសិបឆ្នាំទើបបញ្ចប់បាន។

លោកជើ រ៉េមី បេនថាំ (JEREMY BENTHAM)(១៧៤៨-១៨៣២) ជាអ្នកកែទម្រង់ផ្នែករដ្ឋាភិបាលដ៏គួរឲ្យកត់សម្គាល់ម្នាក់ជាតិអង់គ្លេសក្នុងចំណោមអ្នកកែទម្រង់ទាំងឡាយនៃប្រទេសអង់គ្លេស ដោយត្រូវបានគេប្រសិទ្ធិនាមថា ជាបិតារបស់ចក្រកពអង់គ្លេសក្នុងការបង្កើតទ្រឹស្ដី និងស្ថាប័នរបស់ប្រទេស ដើម្បីកែប្រែជីវិតនយោបាយរបស់ប្រទេសអង់គ្លេសនៅពាក់កណ្ដាលសតវត្សទី១៩។ គំនិតនយោបាយរបស់លោកមានឥទ្ធិពលដ៏ធំធេងទៅលើការកែប្រែម៉ាស៊ីនរដ្ឋបាល និងទៅលើច្បាប់ទាំងឡាយរបស់ប្រទេសអង់គ្លេស (ច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណី)។

ចំពោះប្រជាធិបតេយ្យ លោក BENTHAM បានលើកឡើងថា ធម្មជាតិបានទុកដាក់មនុស្សឲ្យស្ថិតក្រោមរបស់ដ៏មានអំណាចធំៗពីរ គឺការឈឺចាប់ និងសេចក្ដីសប្បាយ។ របស់ទាំងពីរនេះ បានដឹកនាំយើងគ្រប់គ្រងយើងក្នុងរាល់កិច្ចការដែលយើងធ្វើ គ្រប់អ្វីទាំងអស់ដែលយើងនិយាយ និងគ្រប់ៗទាំងអស់ដែលយើងគិត។ លោកបានចារឹកទុកនូវឃ្លាដ៏មានតម្លៃមួយយ៉ាងដូច្នេះថា ចូរបង្កើតនូវសុភមង្គលដែលអ្នកអាចបង្កើត

បាន ចូរជៀសវាងនូវសេចក្តីទុក្ខព្រួយទាំងអស់ដែលអ្នកអាចជៀសវាងបាន។ជារៀងរាល់ថ្ងៃគេតែងតែអនុញ្ញាត ឬ អញ្ជើញអ្នកទៅបំពេញបន្ថែមនូវអ្វីៗដែលជាសេចក្តីទុក្ខព្រួយរបស់អ្នកដទៃ។

តាមគំនិតរបស់លោក ដើម្បីជំរុញឲ្យមានប្រសិទ្ធិភាពប្រជាធិបតេយ្យ រដ្ឋាភិបាលគប្បីជំរុញឲ្យមនុស្ស មានសុភមង្គល ដែលជាសុភមង្គលសំខាន់ទាំងអស់គ្នា។ លោកបានទាមទារឲ្យមានសិទ្ធិបោះឆ្នោតក្នុង សភា ដែលចាត់ទុកជាកំណែទម្រង់មួយទៅលើសិទ្ធិបោះឆ្នោត។ ការទាមទារនេះបានសម្រេចជាផ្លែកផ្កាក្រោយ ពេលលោកទទួលមរណៈភាពក្នុងឆ្នាំ១៨៣៣។

លោក ជេម មេឌីសាន់ (JAMES MADISON)(១៧៥១-១៨៣៦) ជារដ្ឋបុរសសហរដ្ឋអាមេរិក និងជាទស្សនវិទូនយោបាយ និងជាប្រធានាធិបតីទី៤(១៨០៤-១៨១៧)[៣៤]។ លោក MADISON ប្រកាន់ខ្ជាប់ នូវទស្សនៈថា ប្រជាជន ជាប្រភពតែមួយគត់នៃអំណាចនយោបាយ ហើយចំណែកការបោះឆ្នោតវិញជា លក្ខណៈពិសេសរបស់ការដឹកនាំបែបសាធារណៈរដ្ឋនិយម។ ប៉ុន្តែលោក MADISON បានគិតថា ជៀសមិនរួច ឡើយនូវការសង្កត់សង្កិនទៅលើផលប្រយោជន៍របស់ភាគីភាគតិច។

ដើម្បីកុំឲ្យមានការរំលោភពីសំណាក់ភាគីភាគច្រើនបើតាមយោបល់របស់លោក MADISON អាចធ្វើទៅ បានមានតែការដឹកនាំប្រទេសតាមរយៈសាធារណៈរដ្ឋ ដែលមានលក្ខណៈខុសពីរាជាធិបតេយ្យនៅត្រង់ការយល់ ឃើញថាៈ

១.ការជ្រើសរើសអ្នកតំណាងពេញសិទ្ធិ
នៅក្នុងការដឹកនាំរដ្ឋនៅក្នុងចំណោមប្រជាជនភាគតិចក្នុងតំបន់ណាមួយ។

២.ចំនួនពលរដ្ឋកាន់តែច្រើននៅក្នុងសាធារណៈរដ្ឋ ដែលមានទឹកដីធំនោះនឹងមានរបបនយោបាយ សង្គមមនុស្ស ពេលនោះការជ្រើសរើសមេដឹកនាំនឹងត្រូវប្រព្រឹត្តទៅកាន់តែពិនិត្យពិច្ច័យថែមទៀត ពីតំណាងរបស់ ប្រជាជន ឬពីសំណាក់ប្រជាពលរដ្ឋផ្ទាល់តែម្តង។ ដោយតម្រូវឲ្យប្រជាពលរដ្ឋទទួលបាននូវអ្វីដែលជាបំណង ប្រាថ្នារបស់ពលរដ្ឋផ្តល់ឲ្យនូវសិទ្ធិនយោបាយ សិទ្ធិផ្សេងៗទៀត ហើយជាពិសេស គឺសិទ្ធិទទួលបាននូវប្រជាធិ- បតេយ្យគ្រប់ៗគ្នា និងទាំងអស់គ្នាទទួលបាននូវវឌ្ឍនភាព ហើយពុំសូវមានវិសមភាពក្នុងសង្គមឡើយ។ ខ្លឹមសារ សំខាន់នៅទីនេះ គឺតួនាទីដ៏ចម្បងរបស់ប្រជាពលរដ្ឋក្នុងការបង្កើតអំណាចរដ្ឋ ក្នុងការកំណត់វាសនារបស់ខ្លួន ដោយខ្លួនឯង ដោយមិនពឹងផ្អែកទៅលើកម្លាំងខាងក្រៅអ្វីឡើយ គឺថាសមត្ថភាពពិតៗរបស់ពលរដ្ឋតែម្តង។ បុគ្គលពលរដ្ឋម្នាក់ៗ ជាព្រលឹងរបស់រដ្ឋ គឺជាវត្ថុដែលរដ្ឋាភិបាលអាមេរិកឲ្យតម្លៃឥតគណនា។

លោក ថូម៉ាស ជេហ្វឺរសាន់(THOMAS JEFFERON)(១៧៤៣-១៨២០) ជាប្រធានាធិបតីទី៣ របស់សហរដ្ឋអាមេរិក(១៨០៤-១៨០៩) និងជាអ្នកនិពន្ធសេចក្តីប្រកាសឯករាជ្យឆ្នាំ១៧៧៦ ដែលទស្សន

[៣៤] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ២៧០

នយោបាយរបស់លោក JEFFERSON ស្ថិតនៅក្នុងមូលអត្ថន័យនៃសេចក្តីប្រកាសឯករាជ្យ[៣៥]។ ដោយឈរលើគោលការណ៍នៃច្បាប់ធម្មជាតិ លោក JEFFERSON បានធ្វើការអះអាងថា មនុស្សគ្រប់រូបកើតមកមានសិទ្ធិស្មើៗគ្នានៅចំពោះមុខច្បាប់ ចំណែកឯទំនាក់ទំនងស្រទាប់វណ្ណៈមិនមែនស្ថិតនៅក្នុងច្បាប់ទេ និងប្រឆាំងនឹងលក្ខណៈធម្មជាតិទាំងនេះ គឺកើតចេញពីច្បាប់ប្រតិកិរិយា។ មនុស្សកើតឡើងស្មើភាពគ្នា និងមានសិទ្ធិដូចៗគ្នាទាំងអស់ មានសិទ្ធិក្នុងការធ្វើអាជីវកម្ម សេរីភាព និងការប្រឹងប្រែងតស៊ូដើម្បីសុភមង្គល មនុស្សមិនត្រូវគេបដិសេធដើម្បីទទួលយកអ្វីៗទាំងអស់នេះ ទោះបីឋិតក្នុងស្ថានភាពយ៉ាងណាក៏ដោយ។ នៅក្នុងសេចក្តីប្រកាសឯករាជ្យលោក JEFFERSON បានបង្ហាញថា រដ្ឋាភិបាលបានបង្កើតឡើងដើម្បីឧបត្ថម្ភដល់មនុស្សនូវសិទ្ធិ រីឯអំណាចបានបង្កើតឡើងដោយយុត្តិធម៌ នៅក្នុងខណៈណាអំណាចនោះត្រូវបានទទួលស្គាល់ពីសំណាក់ប្រជាពលរដ្ឋ នៅពេលដែលអំណាចចាប់ផ្តើមរំលោភលើសិទ្ធិរបស់ពលរដ្ឋ ប្រជាជនមានសិទ្ធិផ្លាស់ប្តូរ ឬលុបបំបាត់អំណាច ហើយបង្កើតនូវការដឹកនាំថ្មី ដែលឈរលើគោលការណ៍ដូចមានរួចមកហើយ និងបង្កើតស្ថាប័ននៃទ្រង់ទ្រាយនោះដែលគេយល់ថា មានលទ្ធភាពបំពេញជូនដល់ប្រជាពលរដ្ឋ នូវសន្តិសុខ និងសុភមង្គល។ លោក JEFFERSON បានសិក្សាស៊ីជម្រៅទ្រឹស្តីអំពីរដ្ឋ និងលទ្ធិប្រជាធិបតេយ្យនិយម ដោយឆ្លងកាត់នូវទ្រឹស្តីនីតិរដ្ឋ។ លោក JEFFERSON បានបង្កើតដូចតទៅៈ នីតិរដ្ឋអាចកើតមានឡើងបានដោយមិនអាស្រ័យនឹងកិត្យានុភាពរបស់អគ្គមគ្គុទេសក៍នោះទេ ក៏ប៉ុន្តែឲ្យតម្លៃខ្ពស់ទៅលើច្បាប់ ច្បាប់ក៏ត្រូវតែគិតដល់សិទ្ធិ និងសេរីភាពរបស់បុគ្គលផងដែរ ដើម្បីការពារដល់សិទ្ធិនិងសេរីភាព ត្រូវគេបង្កើតឡើងជាចាំបាច់នូវស្ថាប័នការពារសិទ្ធិ និងសេរីភាពក្នុងសង្គម ទីបំផុតអាចដំណើរការប្រកបដោយជោគជ័យ លុះណាតែច្បាប់ត្រូវអនុម័តឡើងអាស្រ័យនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងការបែងចែកអំណាចយ៉ាងច្បាស់លាស់រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ រាល់ទ្រង់ទ្រាយអំណាច លោក JEFFERSON បានទាមទារឲ្យមានការយល់ព្រមពីសំណាក់ប្រជាពលរដ្ឋ ដោយគោលការណ៍នៃការបង្កើតអំណាចត្រូវអាស្រ័យទៅនឹងសិទ្ធិ និងកាតព្វកិច្ចពលរដ្ឋ។ បើសិនជាដើរលើផ្លូវមួយផ្សេងទៀតនឹងនាំទៅកាន់អំណាចផ្តាច់ការមិនខាន។ ការចង្អុលបង្ហាញទាំងនេះត្រូវបានបញ្ចូលទៅក្នុងសេចក្តីប្រកាសឯករាជ្យដែរ គឺគោលការណ៍អំពីអធិបតេយ្យរបស់ប្រជាពលរដ្ឋអំពីសិទ្ធិរបស់ប្រជាពលរដ្ឋ ហើយទាក់ទងទៅនឹងការកាត់បន្ថយអំណាចរដ្ឋ និងលទ្ធភាពបង្កើត និងពង្រឹងនីតិរដ្ឋ និងរបបប្រជាធិបតេយ្យ។

លោក JEFFERSON បានធ្វើការនៅលើច្បាប់រដ្ឋធម្មនុញ្ញទីពីរសហរដ្ឋអាមេរិកនៅឆ្នាំ១៧៨៧ បានបំពេញបន្ថែមជាច្រើនចំណុច ដូចជា ច្បាប់ស្តីពីសិទ្ធិមនុស្សដែលជាចំណុចមួយដ៏សំខាន់នៃសិទ្ធិ និងសេរីភាពនៃរបបដែលស្ថិតលើគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យនិយម។

ស្តីអំពីនីតិរដ្ឋ គំនិតនីតិរដ្ឋបានចាប់កំណើតឡើងក្នុងបុរេសម័យមកម្ល៉េះ។ នៅក្នុងកំឡុងពេលរាប់រយឆ្នាំ

---

[៣៥] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ១៨៩

ខាងមុខ អ្នកប្រាជ្ញជាច្រើនផ្នែកវិទ្យាសាស្ត្រសង្គម បានបកស្រាយគំនិតរបស់ខ្លួនហើយគិតថា នីតិរដ្ឋត្រូវតែបន្ត ដែលគ្មានអំពើអាក្រក់ យង់ឃ្នង គ្មានប្រើអំពើហិង្សា និងពុំមានការធ្វើអ្វីតាមទំនើងចិត្តឡើយ ពោលគឺធ្វើអ្វីៗទាំងអស់ត្រូវស្របតាមផ្លូវច្បាប់ ត្រូវគោរពសិទ្ធិ និងសេរីភាព។ នីតិរដ្ឋ គឺរដ្ឋប្រជាធិបតេយ្យ ដែលក្នុងនោះរាល់ដំណោះស្រាយត្រូវយកច្បាប់ធ្វើជាអធិបតេយ្យ ច្បាប់គ្រប់គ្រងលើអ្វីៗទាំងអស់ សមភាពចំពោះមុខច្បាប់ តុលាការឯករាជ្យ ពីមជ្ឈដ្ឋាននយោបាយ មានការទទួលខុសត្រូវ និងធានាដល់សិទ្ធិ និងសេរីភាពរបស់ពលរដ្ឋ។ អំណាចរបស់ស្ថាប័នទាំងបីមានព្រំដែន និងមានការបែងចែកអំណាចត្រឹមត្រូវ។

លោក តូ គឺវីល(TOCQUEVILLE ALEXIS CHARLES HENRI CLEVEL) (១៨០៥-១៨៥៩) ជាអ្នកទ្រឹស្តីនយោបាយសង្គមវិទូ និងជាប្រវត្តិវិទូជាតិបារាំង[៣៦]។

យោងតាមទស្សនៈលោក TOCQUEVELLE ការប្តូរពីរបបអភិជនាធិបតេយ្យ មកជារបបប្រជា-ធិបតេយ្យនិយមវិញ នោះមិនមែនគ្រាន់តែជាការផ្លាស់ប្តូរមធ្យោបាយដឹកនាំទេ ប៉ុន្តែការផ្លាស់ប្តូររចនាសម្ព័ន្ធនយោបាយគ្រប់គ្រងសង្គមទាំងស្រុង និងផ្លាស់ប្តូរផ្នត់គំនិតមនុស្សថែមទៀត។ លោក TOCQUEVILLE បានដាក់សំណួរថា តើរចនាសម្ព័ន្ធដឹកនាំថ្មីនឹងនាំមកដល់សង្គមមនុស្ស នូវសេរីភាព នូវលទ្ធភាពកាន់តែទូលំ-ទូលាយ ផ្តល់ជាថាមពល និងកម្លាំងចិត្តដល់បុគ្គលដែរ ឬទេ បើសិនជាក្នុងពេលបច្ចុប្បន្ន ពាក្យប្រជាធិតេយ្យសេរីបានន័យថា ជាសេរីភាពសម្រាប់ទាំងអស់គ្នានោះ? ជាការពិតណាស់ថា វាស្ថិតនៅលើគោលការណ៍សមភាព ក៏ប៉ុន្តែចេញពីគោលការណ៍សមភាពក្នុងពេលខ្លះមិនអាចកើតមានឡើងនូវសេរីភាពនយោបាយ និងសេរីភាពជំនឿឡើយ។ លោក TOCQUEVILLE បានធ្វើការអះអាងថា រាល់សង្គមណាក៏ដោយ តែងតែមាននូវលក្ខណៈពិសេសនៃវប្បធម៌នយោបាយរបស់ខ្លួន ហើយដែលអាចកំណត់នូវគំរូណាមួយនៃដំណើរការវិវត្តន៍លទ្ធិប្រជាធិបតេយ្យ។ នៅក្នុងសង្គមមួយមានសមភាពតែស្មើរតែគ្មានសេរីភាព ហើយបើមានសេរីភាព គឺគ្មានទេសមភាព ប្រសិនបើទាមទារឲ្យមានសមភាពធ្វើឲ្យសង្គមធ្លាក់ក្នុងការដឹកនាំផ្តាច់ការ ដែលធ្វើឲ្យខូចខាតដល់របបប្រជាធិបតេយ្យសេរីនិយម។

ទស្សនៈប្រជាធិបតេយ្យជាបឋម គឺសិទ្ធិស្មើគ្នា ហើយមានប្រទេសជាច្រើនដែលសាកល្បងដឹកនាំតាមផ្លូវនេះ។ លោក TOCQUEVELLE បានអះអាងថា គំនិតស្តីពីប្រជាធិបតេយ្យត្រូវបានគេរកឃើញនៅក្នុងគ្រប់បណ្តាប្រទេសទាំងអស់។ នោះគឺជាគំនិតអំពីសមភាពសង្គមសេរី នយោបាយ សិទ្ធិបោះឆ្នោត សិទ្ធិកំណត់ជោគវាសនាប្រទេសខ្លួន សិទ្ធិដោះស្រាយបញ្ហាការដឹកនាំដោយភាគច្រើន ពិសេសគឺការលើកតម្កើងថា ប្រជាជនទាំងអស់ជាម្ចាស់វាសនាប្រទេសជាតិរបស់ខ្លួន។ សម្រាប់សង្គមស៊ីវិល លោក TOCQUEVILLE បានបង្ហាញថា ស្ថាប័នអំណាចមូលដ្ឋាននៅក្នុងរចនាសម្ព័ន្ធបណ្តោះអាសន្នរបស់គេ បានធ្វើឲ្យក្លាយជាសាលាអប់រំនយោបាយ ដែលក្នុងនោះប្រជាពលរដ្ឋនឹងទទួលបាននូវទម្លាប់នៃការដឹកនាំ និងស្វ័យភាពនៅក្នុងទស្សននយោបាយ

[៣៦] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ២១២

គឺនៅក្នុងដំណាក់កាលប្រជាធិបតេយ្យ លោក TOCQUEVILLE បានបង្ហាញថា វិធីសាស្ត្រសមាគម ដែលឈរលើមូលដ្ឋានក្នុងតួនាទីវិមជ្ឈការនៃការដឹកនាំ ដែលជាកម្លាំងតែមួយគត់អាចទប់ស្កាត់កុំឲ្យមានអំណាចផ្តាច់ការ។

លោក TOCQUEVILLE បានគិតថា មធ្យោបាយដើម្បីជៀសវាងរបបផ្តាច់ការ គឺសិទ្ធិរបស់សមាគមនយោបាយ និងសិទ្ធិរបស់ពលរដ្ឋ។ មានតែការបើកឲ្យមាននូវសេរីភាពនយោបាយ សេរីភាពសមាគមនយោបាយប៉ុណ្ណោះ ដែលជាកត្តាដឹកនាំមនុស្សឲ្យផុតពីនយោបាយផ្តាច់ការ ការគាបសង្កត់នៅលើគ្រប់វិស័យនយោបាយឲ្យពួកគេចាកចេញពីភាពមន្ទិលសង្ស័យឆ្ពោះទៅរកភាពទុកចិត្តគ្នា ធ្វើសកម្មភាពជាមួយគ្នា។ ការរីកចម្រើនសហគមន៍នយោបាយ លោក TOCQUEVILLE បានបង្ហាញថា អាស្រ័យនឹងស្ថានភាពរបស់សារព័ត៌មាន កាសែត។ ពីព្រោះសារព័ត៌មានត្រូវបានបង្កើតជាសមាគម ហើយកាសែតនិយាយការពារសមាគម។ សេរីភាពក្នុងការបោះពុម្ព ផ្តល់អត្ថិភាពក្នុងការបង្កើតសមាគមថ្មី បើគ្មានសមាគម កាសែត ក៏ជួបការលំបាកផងដែរ។

លោក TOCQUEVILLE បានជឿជាក់ថា ទោះបីជាយ៉ាងណាលទ្ធិប្រជាធិបតេយ្យមានភាពដ៏ប្រសើររបស់ខ្លួន គឺការមានប្រៀបទៅលើរបបនយោបាយដឹកនាំផ្សេងៗទៀត ដែលលក្ខណៈប្រៀបនោះគឺៈ

១.លទ្ធិប្រជាធិបតេយ្យ មានលទ្ធភាពអាចឲ្យប្រជាពលរដ្ឋភាគច្រើនមានស្ថានភាពជីវិតរស់នៅល្អ។

២.នៅក្នុងរបបប្រជាធិបតេយ្យនិយម។ មានសេរីភាពនយោបាយដែលចូលរួមដោយមហាជនក្នុងសកម្មភាពនយោបាយ។

នៅក្នុងនយោបាយប្រជាធិបតេយ្យ មានទេពកោសល្យធ្វើឲ្យមានអព្យាក្រិត្យភាពនៅក្នុងសង្គម។ នៅក្នុងទិសដៅលុបបំបាត់របបផ្តាច់ការនិយម។ ប្រជាជនត្រូវតែចូលរួមធ្វើនយោបាយដោយស្ម័គ្រចិត្ត និងការរួបរួមគ្នានៅក្នុងសង្គមបង្កើតស្ថាប័នសេរីនិយមមួយ ដែលមានស្វ័យភាពក្នុងការគ្រប់គ្រងខ្លួន ហើយទន្ទឹមនឹងនេះដែរបង្កើតសមាគមប្រជាពលរដ្ឋ និងសមាគមនយោបាយស្ម័គ្រចិត្ត។ ដោយសារការជួយឧបត្ថម្ភពីសមាគមទាំងនេះអាចចូលរួមក្នុងការដឹកនាំសង្គម ដឹកនាំវប្បធម៌នយោបាយឲ្យស្របទៅតាមអារម្មណ៍ជាពលរដ្ឋពេញលេញ។

ដើម្បីថែរក្សាការពារដល់សេរីភាព លោក TOCQUEVILLE បានយកចិត្តទុកដាក់ផងដែរ ចំពោះឯករាជ្យភាពស្ថាប័នតុលាការ។ ស្ថាប័នតុលាការអប់រំប្រជាជននូវសីលធម៌នយោបាយ និងស្វ័យភាពក្នុងការគោរពច្បាប់។ ស្ថាប័នតុលាការ ជាសាលាឥតបង់ថ្លៃបើកចំហក្នុងនោះមនុស្សអាចរៀនសូត្រក្នុងការប្រើប្រាស់ច្បាប់ឲ្យបានត្រឹមត្រូវ សេរីភាពទទួលបាននូវបទពិសោធន៍នៅក្នុងការចូលរួមនយោបាយ។ ខណៈនោះលោក TOCQUEVILLE បានបង្ហាញថា សមាគមនយោបាយមានសេរីភាពក្នុងការបញ្ចេញយោបល់ និងសេរីភាពសារព័ត៌មាន។ ទន្ទឹមនឹងនេះដែរ តុលាការឯករាជ្យ នឹងក្លាយទៅជារនាំងការពារឲ្យមានលក្ខណៈប្រជាធិតេយ្យពិតៗ មិនឲ្យប្រែក្លាយធាតុពិតដ៏ល្អរបស់ខ្លួន ហើយធ្វើដំណើរទៅកាន់របបនយោបាយផ្តាច់ការ

នោះឡើយ។

លោក TOCQUEVILLE បានបញ្ជាក់ថា ការកំណត់ព្រំដែនអំណាចដោយរដ្ឋធម្មនុញ្ញ ជាលក្ខខណ្ឌដល់អធិបតេយ្យរបស់ប្រជាជនត្រូវបានធានាទាំងក្នុងរបបប្រជាធិបតេយ្យ និងទាំងក្នុងរបបរាជាធិបតេយ្យនិយមអាស្រ័យរដ្ឋធម្មនុញ្ញ ពីព្រោះអំណាចប្រជាធិបតេយ្យនៃមតិភាគច្រើន ត្រូវបញ្ចប់នៅទីណាមានការចាប់ផ្តើមធ្វើសកម្មភាពទាមទារសិទ្ធិរបស់បុគ្គល និងទាមទារឲ្យមានសិទ្ធិប្រជាធិបតេយ្យ ដែលបម្រើឲ្យមតិភាគតិច។ លោក TOCQUEVILLE ក៏បានបង្ហាញថា នៅមានគ្រោះថ្នាក់មួយទៀតនៅក្នុងលទ្ធិប្រជាធិបតេយ្យ គឺអំណាចផ្តាច់ការ ប្រជាធិបតេយ្យចេញមកពីអំណាចមជ្ឈការរបស់ថ្នាក់ដឹកនាំ។ លោក TOCQUEVILLE មានទស្សនៈ ប្រឆាំងនឹងការលូកដៃរបស់រដ្ឋទៅក្នុងបញ្ហាជីវិតរបស់ប្រជាជនថ្នាក់ក្រោម ពីព្រោះអំណាចនេះប្រមូលផ្តុំក្នុងដៃមនុស្សម្នាក់ មិនមែនសំខាន់ភាពរុងរឿងរីកចម្រើនរឹងមាំរបស់ប្រជាជននោះទេ ប្រសិនបើជាអំណាចមជ្ឈការនេះ មិនជួបប្រទះនឹងការប្រឆាំងតបវិញពីសំណាក់ប្រជាជននោះទេ អំណាចនេះនឹងនាំសង្គមទៅតាមបែបទម្រង់អំណាចផ្តាច់ការមួយទៀតដែលអាក្រក់ជាងមុន។ ទស្សនៈរបស់លោកTOCQUEVILLE ចង់ប្រាប់ និងបង្រៀនអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋមួយ ឬប្រទេសមួយឲ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការចាប់ក្រសោបច្បាមយកអំណាចដឹកនាំរបស់ប្រទេសជាតិទាំងមូល អោយធ្លាក់ក្នុងកណ្តាប់ដៃបុគ្គលតែម្នាក់ ឬក្រុមអ្នកនយោបាយណាមួយផ្តាច់មុខ ដែលអាចនាំទៅរកការដឹកនាំមួយតាមទំនើងចិត្ត អាជ្ញានិយម ចក្រពត្តិនិយម បក្សពួកនិយម ពុករលួយ ដំណោះស្រាយបែបហិង្សានិយម... ដែលលទ្ធផលចុងក្រោយសុខសន្តិភាព ស្ថេរភាព យុត្តិធម៌សង្គម ការរីកចម្រើន សិទ្ធិសេរីភាព ជោគវាសនារបស់ប្រជាពលរដ្ឋ គឺស្ថិតនៅលើឆន្ទៈ ឬអារម្មណ៍របស់អ្នកកាន់អំណាចផ្តាច់ការ ឬគណបក្ស ដែលបានប្រមូលផ្តុំអំណាចនោះ។ មានន័យថា ជីវិតរបស់ប្រជាពលរដ្ឋស្ថិតនៅក្នុងសភាពមិនច្បាស់លាស់។ ការព្រួយបារម្ភណ៍របស់ទស្សនវិទូលោក TOCQUEVILLE បើឆ្លុះបញ្ចាំងទៅនឹងទិដ្ឋភាពក្នុងសង្គមខ្មែរវិញឃើញថា ប្រទេសកម្ពុជាមានប្រពៃណីទំនៀមទម្លាប់ដឹកនាំរដ្ឋបែបរាជានិយមផ្តាច់ការ។ ដូច្នេះហើយទើបវប្បធម៌ទាំងនេះបានដុះជាប់ក្នុងបេះដូងរបស់ប្រជា-ពលរដ្ឋខ្មែរទូទៅ ហើយអំណាចនីតិប្រតិបត្តិនៅតែមានឥទ្ធិពល និងគ្រប់សង្កត់យ៉ាងខ្លាំងទៅលើអារម្មណ៍ក៏ដូចជាសង្គមប្រជាពលរដ្ឋទាំងមូល ជាពិសេសអង្គការមហាជន ចលនាសហគមន៍ គណបក្សនយោបាយ សង្គមស៊ីវិល។ល។ នៅតែមានលក្ខណៈទន់ខ្សោយ និងស្ថិតនៅក្រោមសម្ពាធពីសំណាក់រដ្ឋអំណាចកំពូល ដោយបានធ្វើឲ្យស្ថាប័នទាំងនេះមានជំហរមិនឯករាជ្យដដែល ទោះបីជាអំណាចរដ្ឋធម្មនុញ្ញបានហាមឃាត់យ៉ាងណាក្តី។ ព្រឹត្តិការណ៍ទាំងនេះដូចគ្នាទៅនឹងការលើកឡើងរបស់លោក ដេវិឌឆាណល័រ(David Chandler)បានសរសេរទុកជាប្រវត្តិសាស្ត្រថា "គូប្រកួតចម្បងរបស់សម្តេច ព្រះសីហនុ នៅក្នុងឆ្នាំ១៩៥៥ គឺគណបក្សប្រជាធិបតេយ្យ។ មុនការបោះឆ្នោតនាឆ្នាំ១៩៥៨ គណបក្សនេះ ត្រូវបានគេច្រានចោលចេញពីឆាកនយោបាយ[៣៧]។ តែសម្តេច

[៣៧] ដេវិឌ ឆាណ្ឌល័រ ប្រវត្តិសាស្ត្រខ្មែរ ភ្នំពេញ ឆ្នាំ២០០៩ ទំព័រ ២២៧

ព្រះសីហនុ នៅតែតាមព្យាបាទក្រុមដែលបាក់ផ្ទុងនេះជាដរាប ហើយរឿងនេះគួរឲ្យឆ្ងល់ ពីព្រោះគណបក្សនេះស្ទើរតែគ្មានអត្ថិភាពទៀតឡើយ ហើយសមាជិកសឹងតែទាំងអស់បានចូលរួមក្នុងសង្គមរាស្ត្រនិយមវិញ។ ក៏ប៉ុន្តែនៅក្នុងខែកញ្ញា ឆ្នាំ១៩៥៧ ដោយអះអាងថា ក្រុមប្រជាធិបតេយ្យបានបង្កគ្រោះថ្នាក់ដល់គោលនយោបាយរបស់សម្តេចសីហនុ និងបានកោះហៅមេដឹកនាំគណបក្សនេះចំនួនប្រាំនាក់ឲ្យមកគាល់ និងពិភាក្សានៅព្រះរាជវាំង។ គេបានប្រមូលផ្តុំហ្វូងមនុស្សយ៉ាងច្រើនកុះករនៅក្បែរព្រះរាជវាំង ហើយគេបានផ្សាយដំណឹងការពិភាក្សានេះតាមឧគ្ឃោសនសព្ទ។ អ្នកប្រជាធិបតេយ្យទាំងនោះមានការភ័យខ្លាចចំពោះហ្វូងមនុស្សដ៏ធំនោះ ហើយក៏ពុំហ៊ានបញ្ចេញមតិរបស់ខ្លួនបានច្បាស់លាស់ឡើយ។ ពួកគេត្រូវបានសម្តេច គំរាមអស់រយៈពេលបីម៉ោងមុនគេមានការអនុញ្ញាតឲ្យចាកចេញពីព្រះរាជវាំង។ ពេលចេញក្រៅកំពែងវាំង មានទាហ៊ាន និងនគរបាលបានវាយតប់អ្នកទាំងនោះ ហើយមានម្នាក់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ។ ពីរ បីថ្ងៃក្រោយមក មនុស្សប្រមាណពី៣០ ទៅ៤០នាក់ ដែលសង្ស័យថា ជាពួកគណបក្សប្រជាធិបតេយ្យ ត្រូវបានគេវាយតប់នៅទីក្រុងភ្នំពេញ។ ហើយយោធាមួយចំនួន ដែលជាប់ពាក់ព័ន្ធនឹងការវាយតប់អ្នកប្រជាធិបតេយ្យនៅវាំងនោះ ត្រូវបានសម្តេចព្រះសីហនុ បំពាក់គ្រឿងឥស្សរិយយសដោយសម្ងាត់ មុនពេលព្រះអង្គយាងចេញទៅសម្រាកវិស្សមកាលនៅបរទេស។ មិនយូរប៉ុន្មានក្រោយមក គណបក្សប្រជាធិបតេយ្យក៏រលាយខ្លួន ហើយបាត់មុខពីឆាកនយោបាយជារៀងរហូតមក។ ករណីនេះហាក់ដូចជាបានបង្ហាញថា របបប្រជាធិបតេយ្យនៅកម្ពុជា គឺការប្រឆាំងកាន់តែខ្លាំង នាំឲ្យអំណាចផ្តាច់ការកាន់តែលូតលាស់ ហើយប្រព័ន្ធប្រជាធិបតេយ្យបានបំឡែងជាប្រព័ន្ធសមស្តនិយម ដែលចុងក្រោយប្រព័ន្ធនេះក្លាយទៅជាប្រព័ន្ធផ្តាច់ការជាស្វ័យប្រវត្តិ ដែលមានស្ថាប័នព្រះមហាក្សត្រជាអ្នកសម្របសម្រួល។

លោក ម៉ាក់ វេបបើ (MAX WERBBER) (១៨៦៤-១៩២០) ជាសេដ្ឋកិច្ចវិទូសង្គមវិទូ និងនយោបាយវិទូជនជាតិអាឡឺម៉ង់។ តាមទស្សនៈរបស់លោក WERBBER កិច្ចការដឹកនាំសង្គមគួរតែជាកិច្ចការដែលមានការចូលរួមយ៉ាងសកម្មពីសំណាក់មហាជន ដោយតម្រូវឲ្យប្រជាជនចេះប្រើសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសអ្នកដឹកនាំ។ លោក WERBBER បានបង្ហាញនូវភាពអន់ថយរបស់លទ្ធិប្រជាធិបតេយ្យ ការទាក់ទាញមហាជនវចូលរួមនៅក្នុងសកម្មភាពនយោបាយសង្គម ដែលនាំឲ្យកើតឡើងនូវអង្គការនយោបាយច្រើន ដែលជាលទ្ធផលនាំមកនូវការបំផ្លិចបំផ្លាញរចនាសម្ព័ន្ធនយោបាយប្រជាធិបតេយ្យនិយមខ្លួនឯងតែម្តង។ ដើម្បីជៀសវាងកុំឲ្យមានអ្នកកាន់អំណាចផ្តាច់ការនៅក្នុងលទ្ធិប្រជាធិបតេយ្យ លោក WERBBER បានកំណត់ទ្រឹស្តីប្រជាធិប-តេយ្យសេរីពហុបក្ស ដែលក្នុងនោះមេដឹកនាំដែលប្រកបដោយប្រជាធិតេយ្យនឹងត្រូវបានទទួលការជ្រើសរើសដោយប្រជាជន ឬធ្វើប្រជាមតិ (ការបោះឆ្នោតជ្រើសរើសជាទូទៅ) ហើយមិនតែប៉ុណ្ណោះក៏ត្រូវការកម្លាំងស្របច្បាប់របស់រដ្ឋសភាប្រជាធិបតេយ្យដែរ។ លទ្ធិប្រជាធិបតេយ្យតាមទស្សនៈរបស់លោក WERBBER ត្រូវបានកំណត់ដោយសញ្ញាណរចនាសម្ព័ន្ធមួយចំនួន គឺជារចនាសម្ព័ន្ធធ្វើសកម្មភាពនៅក្នុងទំនាក់ទងរវាងបុគ្គលជាច្រើននាក់ ហើយពួកគេនីមួយៗនៅក្នុងចំណោមនោះមានតួនាទីជាពិសេសរបស់គេ។

ដើម្បីជៀសវាងការិយាធិបតេយ្យនិយមផ្តាច់ការ លោក WERBBER បានឲ្យតំណាងនៃការធ្វើឲ្យមាន

ប្រជាធិបតេយ្យដោយអាស្រ័យនឹងប្រជាប្រិយភាពរបស់មេដឹកនាំ ត្រូវតែជ្រើសរើសដោយអនុលោមទៅតាមការធ្វើប្រជាមតិ ឬក៏ការធ្វើការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋទៅតាមផ្លូវច្បាប់ប្រជាធិបតេយ្យ។ អ្នកដឹកនាំប្រភេទនេះ គឺជាមេដឹកនាំដែលមានភាពប៉ិនប្រសព្វពីកំណើតមក បើតាមទស្សនៈរបស់លោក WERBBER អាចដោះស្រាយបញ្ហាយ៉ាងច្រើន ដែលមានទំនាក់ទំនងទៅនឹងភាពស្មុគស្មាញក្នុងដំណើរជីវិតសង្គម និងរដ្ឋ។ តាមទស្សនៈរបស់លោក WERBBER គឺថាជាការល្អតែមួយគត់ និងមានសនិទានភាពចំពោះរចនាសម្ព័ន្ធគ្រប់បែបស្ថាន ការិយាល័យ ឬអង្គការសហគមន៍ផ្សេងៗ។ លោកបានចាត់ទុកថា ការកកើតមានឡើងនូវរបបគ្រប់គ្រងបែបស្ថាប័ន អង្គការ ការិយាល័យនិយម គឺជាការឆ្លើយតបទៅនឹងការលូតលាស់ ការកើតឡើងនៃការទាមទាររបស់សង្គម។ លោកឲ្យតម្លៃថា បញ្ហានេះជាជំហាននៃការរីកចម្រើនផ្នែកហេដ្ឋារចនាសម្ព័ន្ធទីផ្សារ សិទ្ធិសេរីភាព ដែលតម្រូវឲ្យក្បាលម៉ាស៊ីនដឹកនាំរដ្ឋ ត្រូវពង្រឹងស្ថានភាពគ្រប់គ្រងរបស់ខ្លួនឲ្យបានរឹងមាំ និងជំរុញឲ្យរដ្ឋាភិបាល កែទម្រង់ប្រព័ន្ធនយោបាយមានភាពសនិទានជាចាំបាច់។

ក្នុងបរិបទនយោបាយដឹកនាំ(Political Elite) នយោបាយត្រូវបានគេទទួលស្គាល់ដូចជាមុខរបរ អាជីពដែល WERBBER បានវែកញែកយ៉ាងលំអិតអំពីអំណាចជាពីរប្រភេទៈ

១.អំណាចបម្រើៈ គឺមានន័យថា រស់នៅនឹងអំណាច យកអំណាចជាមធ្យោបាយ ជាអាវុធសម្រាប់បម្រើប្រជាពលរដ្ឋ និងប្រទេសជាតិទាំងមូល។

២.អំណាចអាជីវកម្មៈ មានន័យថា យកអំណាចអាជីពតាមរយៈវ៉ែននយោបាយ។ បាតុភូតនេះ កើតមានឡើងនៅពាសពេញពិភពលោក ជាពិសេសនៅប្រទេសកម្ពុជាយើងតែម្តង ដែលតែងជួបវិបត្តិនយោបាយដណ្តើមអំណាចគ្នាដោយកម្លាំងយោធា ធ្វើឲ្យបែកបាក់សង្គម បាត់បង់ទឹកដី និងលំបាកដោះស្រាយទៀតផង។ តាមការសិក្សាពីចិត្តសាស្ត្រសង្គមខ្មែរតាមប្រវត្តិសាស្ត្របានរកឃើញថា ផ្នត់គំនិតរបស់ប្រជាពលរដ្ឋខ្មែរភាគច្រើនការសិក្សារៀនសូត្ររបស់គេគ្រប់គ្នា គឺមានគោលបំណងតែមួយគត់ គឺបាញ់ឆ្ពោះឲ្យក្លាយជាមេដឹកនាំនយោបាយដ៏មានអំណាច ព្រោះគេយល់ថាអំណាចជាមធ្យោបាយជួយឲ្យកម្រិតជីវភាពរស់នៅសម្បូណ៌សប្បាយអំណាចជាមាសប្រាក់។ ជាពិសេសគេយល់ថា កាលបើមានអំណាច គឺមានអ្វីៗទាំងអស់ និងធ្វើឲ្យគេគោរពខ្លាចរអាគ្រប់គ្នាក្នុងបរិបទសង្គមអសនិទាន។ អ្នកសិក្សាភាគច្រើនពុំមែនសិក្សាតាមទេពកោសល្យពីធម្មជាតិរបស់ខ្លួននោះទេ ដូច្នេះហើយ បានជាពួកមានសញ្ញាបត្រខ្ពស់ៗ ពុំយកចំណេះវិជ្ជាដែលខិតខំសិក្សាបានទៅបម្រើការងារវិជ្ជាជីវៈ ឲ្យស្របតាមចំណេះដឹងរបស់ខ្លួននោះទេ នេះគឺជាផ្នត់គំនិតមនុស្សខ្មែរក្នុងបរិបទអំណាច។

លោក មហាត្មៈគន្ធី (MOHATMA GANDHI)(១៨៦៩-១៩៤៨) ជាទស្សនវិទូផង និងជាអ្នកនយោបាយជាតិឥណ្ឌាផង។ លោក MOHATMA GANDHI គឺជាអ្នកដឹកនាំមហាជនដែលគ្មានការឧបត្ថម្ភគាំទ្រអ្វីអំពីអំណាចខាងក្រៅឡើយ។ លោក គឺជាអ្នកនយោបាយដែលទទួលជោគជ័យទាំងរថក្រោះ ហើយគ្មានមហិទ្ធិឫទ្ធិ ឬអាវុធយុទ្ធភណ្ឌផ្សេងៗឡើយ តែដោយសារកម្លាំងចិត្តដ៏រឹងមាំមុតស្រួចជាអ្នកតស៊ូដ៏អស្ចារ្យ ដែលធ្វើឲ្យកងកម្លាំង

យោធាដ៏មហិមា ទៅជាឥតន័យខ្លឹមសារ។ ជាមហាបុរសប្រកបដោយបញ្ញាឧត្តុង្គឧត្តម ដើម្បីបម្រើមនុស្សជាតិ ជាអ្នកដឹកនាំក្បួន សន្តិភាពអហិង្សា មិនងាករេ ជាអ្នកឧទ្ទិសខ្លួន ដើម្បីលើកកម្ពស់ជីវភាពមនុស្សឲ្យបានល្អប្រសើរ។ ជាមហាបុរស ដែលហ៊ានប្រឈមមុខនឹងមហាអំណាចដ៏ធំបំផុតនៃទ្វីបអឺរ៉ុប ដោយរក្សាកិត្តិយសក្នុងភាពជាមនុស្សសាមញ្ញអស្ចារ្យជាអមតៈ[៣៨]។ ទីបំផុតមធ្យោបាយអហិង្សារបស់លោក MOHATMA GANDHI បានរំដោះមនុស្ស ជាតិឥណ្ឌាឲ្យមានសេរីភាពពេញលេញទូទាំងអាហ្វ្រិកខាងត្បូង និងនៅក្នុងប្រទេសឥណ្ឌាទាំងមូល។ មានន័យថា ជ័យជម្នះនានាពិតជាពុំមែនកើតឡើងដោយសារការសុំអង្វរ ឬបានមកពីការបន់ស្រន់នោះទេ។ ជ័យជម្នះពិតជាកើតឡើងដោយមនុស្សម្នាក់ៗរួបរួមគ្នាជាផ្លុងមួយ ក្រាញនៀល តស៊ូ ស្វិតស្វាញអត់ធ្មត់ ការទាមទារ កាយវិការអហិង្សា គោរពស្រឡាញ់រាប់អាន ការទាមទារតវ៉ាដោយគ្មានការសងសឹក គ្មានគំនុំចំពោះគូភាគី។ ធ្វើយ៉ាងណាប្រឹងប្រែងបកស្រាយបំភ្លឺ បង្ហាញហេតុផលជាក់ច្បាស់នូវអ្វីៗ(សិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ...) ដែលជីវិតរស់នៅរបស់មនុស្សត្រូវការជាចាំបាច់មិនអាចខ្វះបាន ដោយធ្វើយ៉ាងណាឲ្យគូភាគីបានយល់ពីគោលបំណង។ មធ្យោបាយនេះ អាចឲ្យជនរងគ្រោះទទួលបានជ័យជម្នះលើរបបដឹកនាំផ្តាច់ការ ឬការជិះជាន់ទាំងឡាយដោយជៀសវាងបាននូវអំពើហិង្សា ហើយសង្គមជាតិទាំងមូលក៏ទទួលបានសេចក្តីសុខសាន្តផងដែរ។

លោក ស៊ុន យ៉ាត សេន (SUN YATSEN)(១៨៦៦-១៩២៥) ជាអ្នកនយោបាយ ដោយបានបង្កើតគំនិតនយោបាយដ៏ខ្លាំងក្លាមួយនៅចុងសតវត្សទី១៩ ដើមសតវត្សទី២០។

ចំពោះគោលការណ៍លទ្ធិប្រជាធិបតេយ្យត្រូវបានគេកំណត់ថា ជាស្ថានភាពនៃការចូលរួមដោយប្រជាជននៅក្នុងរដ្ឋបាលដឹកនាំ។ ប៉ុន្តែលោក SUN YATSEN បានពិនិត្យអំពីអត្ថិភាពនេះមានទំហំធំធេងជាងនេះទៅទៀតដូចជា ស្ថានភាពបង្កើតឲ្យមានសេរីភាព និងសមភាព បើសិនជាគ្មានប្រជាធិបតេយ្យសេរីភាព និងសមភាពវាគ្រាន់តែសម្រែកឥតបានការ។ នៅក្នុងតំណាក់កាលដំបូង លោក SUN YATSEN បានបង្ហាញអំពីលទ្ធភាពក្នុងការកសាងលទ្ធិប្រជាធិបតេយ្យតាមរូបមន្ត លទ្ធិប្រជាធិបតេយ្យដោយយកទស្សនៈនិងស្ថាប័ននៃប្រទេសលោកខាងលិច។ ប៉ុន្តែក្រោយនេះបន្តិច លោក SUN YATSEN ក៏បានយល់ព្រមថា ប្រទេសចិនត្រូវការដើរតាមផ្លូវរបស់ខ្លួន ដោយលោកបានមើលឃើញផ្លូវដោះស្រាយមានតែមួយគត់ គឺកសាងរចនាសម្ព័ន្ធប្រជាធិប-តេយ្យចិនមួយដោយមិនយកម៉ូដែលពីអ្នកណាទាល់តែសោះ។ រចនាសម្ព័ន្ធប្រជាធិបតេយ្យបែបចិន គឺប្រជាធិបតេយ្យ បានកើតឡើងដោយរដ្ឋធម្មនុញ្ញនៃស្ថាប័នអំណាចទាំង៥ គឺនីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ ស្ថាប័នត្រួតពិនិត្យ និងស្ថាប័នប្រឡង។ ទន្ទឹមនេះ លោក SUN YATSEN បានរៀបចំគម្រោងឲ្យប្រជាជនចូលរួមក្នុងការកំណត់អំណាចដោយផ្ទាល់ ដែលមានចែងនៅក្នុងសិទ្ធិទាំងបួនរបស់ប្រជាជនគឺៈ

១-សិទ្ធិក្នុងការជ្រើសរើស

[៣៨] សុខ សុគ្គាល មហាគ្នះគន្ធី ទស្សនវិជ្ជាអហិង្សា ឆ្នាំ១៩៩៦ ភ្នំពេញ ទំព័រ ៨៣-៨៤

២-សិទ្ធិក្នុងការកោះហៅ

៣-សិទ្ធិនៅក្នុងគំនិតផ្ដួចផ្ដើម

៤-សិទ្ធិក្នុងការធ្វើប្រជាធិបតេយ្យ[៣៩]។

លោក ហ្សង់ ប៉ូលសាត (JEAN POUL SARTRES) កើតឆ្នាំ១៩០៥។ លោកជាទស្សនវិទូជាតិបារាំង ដែលស្រឡាញ់ សេរីភាព សន្តិភាព ហើយស្អប់ខ្ពើមសង្គ្រាម និងការជិះជាន់កេងប្រវ័ញ្ចពីមនុស្សដូចគ្នា។ លោកបានទាមទារក្នុងការស្វែងរកសេរីភាពឲ្យមនុស្សគ្រប់រូប លោកបានពោលថា បើសង្គ្រាមមិនបញ្ចប់ទេ នោះទុក្ខវេទនារបស់មនុស្សនៅតែមាន ពោលគឺលោកមានបំណងចង់ឲ្យដោះស្រាយបញ្ហាមនុស្សឲ្យបានដាច់[៤០]។ លោកបានមើលឃើញការរស់នៅរបស់មនុស្សដែលគ្មានសេរីភាព គ្មានការយកចិត្តទុកដាក់ពីអ្នកកាន់អំណាច។ លោកក៏បានឲ្យតម្លៃទៅលើការរស់នៅរបស់មនុស្ស ដែលមានសេរីភាពពេញលេញផងដែរ។ លោកចង់ឲ្យមនុស្សរស់នៅដោយមានតម្លៃ។ លោកបានយកមនុស្សធ្វើកម្មវត្ថុសិក្សា ដើម្បីស្វែងរករបៀបនៃការរស់នៅដែលអាចធ្វើឲ្យមនុស្សមានសុភមង្គល។ តាមន័យទូទៅ សេរីភាពសម្គាល់ភាពធ្វើអ្វីៗបានតាមចិត្ត ដោយគ្មានការបង្ខិតបង្ខំដោយគ្មានលក្ខខណ្ឌទោះបីក្នុងផ្លូវគំនិតជំនឿក្តី និងសកម្មភាពយ៉ាងណាក្តី គឺធ្វើបានតាមចិត្ត។

លោក POULSARTRE យល់ថា មនុស្សមានសេរីភាពត្រូវមានសេចក្តីក្លាហានក្នុងការទទួលខុសត្រូវ។ មនុស្សត្រូវតែមានសេរីភាព និងការជ្រើសរើសផ្លូវមួយសម្រាប់ខ្លួនអ្នកគ្មានអ្នកណាបង្ខំអ្នកណាឡើយ។ លោកចង់ឲ្យមនុស្សគ្រប់រូបមានសេរីភាពស្មើគ្នាដោយមិនគិតពីវណ្ណៈ ឬមុខងារ អ្នកតូច អ្នកធំ អ្នកមានបុណ្យស័ក្តិ អ្នកក្រ អ្នកមានឡើយ។ ហើយសេរីភាពនេះនឹងមានលក្ខណៈស្របទៅនឹងច្បាប់របស់សង្គម។ កាលណាមនុស្សពោរពេញទៅដោយសេរីភាពហួសហេតុពេក មនុស្សមិនគិតពីការខាតបង់សេរីភាពអ្នកដទៃ តែដោយសារច្បាប់សង្គមជារបាំង ដើម្បីកំណត់សេរីភាពរបស់មនុស្ស នាំឲ្យយល់ពីសេរីភាពអ្នកដទៃដូចអ្វីដែលខ្លួនមានដែរ។

លោក ជេម ម៉ុនរ៉ូ(JAME MONROE)(១៧៥៨-១៨៣៤) ជាប្រធានាធិបតីទី៥សហរដ្ឋអាមេរិក។ លោកបានថ្លែងក្នុងសុន្ទរកថាចូលកាន់តំណែងថា... ពេលសញ្ជឹងគិតទៅដល់រាល់ប្រការដែលយើងត្រូវអនុវត្តពលរដ្ឋរាល់រូបគួរតែអបអរសាទរពេលបានឃើញ រដ្ឋអំណាចរបស់ខ្លួនឈានឆ្ពោះជិតដល់ភាពសុក្រិតកម្រិតណានោះហើយ ប្រកាសនេះយើងពុំចាំបាច់អនុវត្ត សូម្បីការកែច្នៃជាមូលដ្ឋានណាមួយ។ គោលបំណងធំរបស់យើងគឺបន្តការពាររដ្ឋអំណាចនេះស្របតាមគោលការណ៍មូលដ្ឋាន និងពឹងផ្អែកលើលក្ខណៈពិសេសរបស់វាផង។ ដើម្បីធ្វើឲ្យប្រការនេះអាចសម្រេចបាន យើងត្រូវតែរក្សាការពារនូវចរិតថ្លៃថ្នូរនៃប្រជាជាតិយើង ធានាយ៉ាងណាឲ្យពលរដ្ឋគ្រប់រូបបានរៀនសូត្រ។ ហើយដើម្បីប្រឆាំងនឹងគ្រោះថ្នាក់នៃបរទេសឈ្លានពានការអនុវត្តន៍នូវការងារទាំងប៉ុន្មាន ដូចដែលបានពោលមកខាងលើ គឺជាការចាំបាច់សំដៅការពារនូវខឿនឯករាជ្យការពារបណ្ដា

---

[៣៩] ឈុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ២៨៣-២៦៤

[៤០] ខ្លួត ធីតា មូលដ្ឋានគ្រឹះនៃសីលវិជ្ជាសកលលោក ភ្នំពេញ ឆ្នាំ២០០៦ ទំព័រ ២៨៣-២៨៤

ប្រយោជន៍ និងសិទ្ធិសេរីភាពរបស់យើងផងដែរ...។

ផ្អែកលើគោលការណ៍តំណាងប្រជាជន ប្រជាជនបានប្រគល់សិទ្ធិអំណាចរបស់ខ្លួនជូនស្ថាប័នទាំងឡាយ ដែលពួកគាត់បង្កើតឡើងជូនដល់បុគ្គលទាំងឡាយណា ដែលពួកគាត់បានបោះឆ្នោតជូនដើម្បីអនុវត្តតាមគោលដៅរដ្ឋអំណាចសេរីមានការយល់ដឹង និងប្រសិទ្ធិភាព។ ក្នុងរយៈកាលនេះ សិទ្ធិធ្វើម្ចាស់នៃប្រជារាស្ត្រពុំត្រូវបានកាត់បន្ថយឡើយ។ ប្រព័ន្ធរដ្ឋអំណាចទាំងមូល គឺបង្កើតឡើងអាស្រ័យដោយការបោះឆ្នោត។ សិទ្ធិអំណាចដ៏ខ្ពង់ខ្ពស់នៅតែចំណុះលើប្រជាជនដដែល។ មន្ត្រីរដ្ឋការទាំងឡាយនៅគ្រប់ស្ថាប័នអាចក្តាប់អំណាចបាន ឬអត់ គឺអាស្រ័យដោយប្រជារាស្ត្រជាអ្នកសម្រេច ហើយពួកគេត្រូវតែទទួលខុសត្រូវផ្នែកសីលធម៌នៃបុគ្គលខ្លួនផ្ទាល់នៅចំពោះប្រជារាស្ត្រ[៤១]។

លោក WILLIAM HENRY HARRISON(១៧៧៣-១៨៤១) ជាប្រធានាធិបតីទី៩ នៃសហរដ្ឋអាមេរិក ទស្សនៈរបស់លោកបានផ្តោតជាសំខាន់ទៅលើការគ្រប់គ្រងប្រទេស ដែលមានទម្រង់ដឹកនាំបែបប្រមូលផ្តុំអំណាចលើស្ថាប័នណាមួយនៃស្ថាប័នទាំងបី ក៏ដូចជាលើបុគ្គលណាម្នាក់នៃអ្នកដឹកនាំប្រទេស។ ដូចលោកបានលើកឡើងក្នុងសេចក្តីថ្លែងសុន្ទរកថា ចូលកាន់តំណែងថាៈ សម្រាប់ខ្លួនខ្ញុំផ្ទាល់ គ្រោះថ្នាក់ធំបំផុតចំពោះជាតិយើង មិនមែនជាកិច្ចការដែលរដ្ឋាភិបាលណាមួយអត់បានទទួលស្គាល់ពីប្រជាជនស្តីពី ការដណ្តើមអំណាចនោះទេ គឺជាផ្នែកមួយក្នុងចំណោមផ្នែកឯទៀតនៅក្នុងរដ្ឋាភិបាលមួយ ដែលប្រមូលផ្តុំរាល់សិទ្ធិអំណាចក្នុងដៃ[៤២]។ អំណាចនេះទោះមានកំណត់ក្តីនៅតែគ្រប់គ្រាន់សម្រាប់រក្សានូវរបបផ្តាច់ការ ប្រសិនបើអំណាចនោះប្រមូលផ្តុំតែនៅក្នុងផ្នែកណាមួយប៉ុណ្ណោះ។ លោកបានបន្តថា សេរីភាពនៃសារព័ត៌មាន ជាកំពែងរឹងមាំបំផុតសម្រាប់ការពារប្រជារាស្ត្រ និងការពារសេរីភាពនៃជំនឿ ដែលជាច្បាប់មួយក្នុងចំណោមច្បាប់ដ៏មានតម្លៃបំផុត ដែលយើងបានទទួលផលពីវាអាស្រ័យដោយបទពិសោធន៍ផ្ទាល់ខ្លួន។

ហ្សក បូស(GEORGE BUSH)(១៩២៤) ជាប្រធានាធិបតីទី៤១ នៃសហរដ្ឋអាមេរិក។ លោកបានថ្លែងក្នុងសុន្ទរកថា ចូលកាន់តំណែងថាៈ ប្រជាជនលើពិភពលោកខិតខំ ដើម្បីនាំមកនូវសេរីភាពខាងគំនិត សេរីភាពខាងសកម្មភាពលើមូលដ្ឋាននៃសីលធម៌ និងចំណេះដឹង។ យើងដឹងថា ជាភាពត្រឹមត្រូវនេះ ជាសិទ្ធិសេរីភាពនៃការវិនិច្ឆ័យ។ យើងនឹងត្រូវធ្វើដូចម្តេច ដើម្បីជានាឲ្យជីវភាពរស់នៅប្រកបដោយភាពស្មើគ្នា និងភាពរីកចម្រើនជាងនេះសម្រាប់ផ្តល់ជូនមនុស្សលោក ដោយឆ្លងកាត់តាមរយៈទីផ្សារសេរី សេរីភាពនៃការបញ្ចេញមតិ សេរីភាពនៃការបោះឆ្នោត។ រដ្ឋនឹងពុំដែលរារាំងនូវការងារអនុវត្តសិទ្ធិសេរីភាពទាំងនេះបានឡើយ។

លោក កាល់ វិនឃ្យូលីដ(CARL VENNQULID) លោកគិតថា អភិបាលរដ្ឋមួយដ៏ធំនៅក្នុងសហរដ្ឋអាមេរិក នៅពេលដែលក្រុមប៉ូលីសបានសម្រេចចិត្តធ្វើកូដកម្មមួយ។ កាលណាក្រុមប៉ូលីសធ្វើកូដកម្ម

---

[៤១] សទ្ធារី: សម្រង់សុន្ទរកថាចូលកាន់តំណែង ប្រធានាធិបតីអាមេរិក ភ្នំពេញ ឆ្នាំ២០០២ ទំព័រ ១៦

[៤២] ដ.ឯ.ម ទំព័រ ១៨

នោះច្បាស់ជា មានកូដកម្មប្រឆាំងនិងសន្តិសុខនៃប្រជាពលរដ្ឋទោះនៅពេលណា ឬនៅទីណាឡើយ។ រួចលោកក៏មានប្រសាសន៍ថា លោកនឹងហៅកងរក្សាសន្តិសុខជាតិ ដើម្បីធានាសន្តិសុខជូនសាធារណៈជន។ ប្រតិកម្មមួយក្រុមពីខាងប៉ូលីសបានគំរាមកំហែងដល់លោកដោយពោលពាក្យថា "បើលោកហ៊ានតែហៅកងរក្សាសន្តិសុខជាតិឲ្យមកបំបែកបាតុកម្មរបស់យើងនោះ យើងនឹងបំផ្លាញអនាគតរបស់លោក លោកនឹងគ្មាននាទីអ្វីលើឆាកនយោបាយទៀតទេ"។

លោក VENNQULID សម្លឹងចំទៅមុខពួកគេរួចពោលតបថា "ការនោះវាមិនជាបញ្ហាអ្វីទេអស់លោក"។ ចំពោះលោក VENNQULID សន្តិសុខរបស់ប្រជាជនសំខាន់ជាងមុខតំណែងរបស់លោក។ នៅពេលយប់នោះលោក VENNQULID បានសរសេរសំបុត្រទៅកាន់ឪពុកគាត់ថា "ខ្ញុំដឹងថាមុខតំណែងលើឆាកនយោបាយរបស់ខ្ញុំនឹងត្រូវចប់ ប៉ុន្តែខ្ញុំត្រូវតែធ្វើអ្វីដែលជាការត្រឹមត្រូវ"។ ក្រុមប៉ូលីសបានបន្តធ្វើកូដកម្ម។ លោក VENNQULID បានហៅកងរក្សាសន្តិសុខជាតិ ដើម្បីរក្សារបៀបរៀបរយ។ ព័ត៌មានពីភាពអង់អាចក្លាហានរបស់លោកត្រូវបានគេចុះផ្សាយពីសេចក្តីអង់អាចក្លាយហានរបស់លោក។ ពីរបីឆ្នាំក្រោយមក លោកក៏បានក្លាយទៅជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក[៤៣]។

នៅក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញសហប្រជាជាតិ បានបង្ហាញពីឧត្តមគតិ និងគោលបំណងរួមរបស់ប្រជាជនទាំងអស់ ដែលរដ្ឋាភិបាលរបស់ខ្លួនបានរួបរួមគ្នាបង្កើតអង្គការសហប្រជាជាតិ មានសេចក្តីថា "យើងប្រជាជន នៃអង្គការសហប្រជាជាតិ បានតាំងចិត្តសង្គ្រោះមនុស្សជំនាន់ក្រោយឲ្យចាកផុតពីការហែកហួរនៃសង្គ្រាម ដែលបាននាំមកនូវទុក្ខសោកហួសពីសេចក្តីថ្លែងចំពោះមនុស្សជាតិ ដែលកើតមានពីរដងរួចមកហើយក្នុងជីវិតរបស់យើង។ ដូច្នេះ ដើម្បីបញ្ជាក់ឡើងវិញ ពីសច្ចធម៌នៅក្នុងសិទ្ធិមនុស្ស ដែលជាមូលដ្ឋានគ្រឹះក្នុងសេចក្តីថ្លៃថ្នូរ និងតម្លៃនៃមនុស្សជាតិ សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី រវាងអ្នកធំនិងអ្នកតូច ដោយបង្កលក្ខណៈឲ្យមានយុត្តិធម៌ និងការគោរពចំពោះកាតព្វកិច្ចដែលកើតចេញពីសន្ធិសញ្ញាផ្សេងៗ ព្រមទាំងប្រភពនៃនីតិអន្តរជាតិដទៃទៀតដែលអាចត្រូវបានរក្សា និងដើម្បីជំរុញឲ្យមានវឌ្ឍនភាពសង្គម។ ជាពិសេស កម្រិតជីវភាពសេរីភាពរបស់មនុស្សនៃរដ្ឋនីមួយៗ ធ្វើយ៉ាងណាឲ្យកាន់តែប្រសើរឡើងក្នុងរង្វង់សេរីភាពកាន់តែទូលាយ[៤៤]។

យោងតាមទ្រឹស្តីរបស់ព្រះសម្មុទ្ធ និងទស្សនវិទូកំពូលៗក្នុងលោក ដូចបានលើកឡើងមកខាងលើគឺជាមេរៀនបង្រៀនទាំងប្រជាពលរដ្ឋម្ចាស់ប្រទេស ទាំងមេដឹកនាំ ស្តីអំពីរបៀបដឹកនាំ ប្រព័ន្ធដឹកនាំយន្តការដែលត្រូវប្រតិបត្តិឲ្យខាងតែបាន ដើម្បីផលប្រយោជន៍ទាំងអស់របស់អង្គការសហប្រជាជាតិ ដែលត្រូវនាំគ្នាផ្លាស់ប្តូរពីទម្រង់គ្រប់គ្រងដឹកនាំរបបកាចសាហាវផ្តាច់ការសក្តិភូមិ មកប្រកាន់យករបបដឹកនាំមួយដែលផ្តល់តម្លៃទៅលើប្រជាពលរដ្ឋ ជាអធិបតី ប្រជាពលរដ្ឋជាម្ចាស់អំណាច ជាម្ចាស់ប្រទេស និងជាអ្នកសម្រេចជោគវាសនា

[៤៣] លោកស្រី បណ្ឌិត បៀទ្រិសនាល្ល: ស្ថាបនាកម្ពុជាឲ្យប្រសើរ ភ្នំពេញ ឆ្នាំ២០០៣ ទំព័រ ១៨

[៤៤] សុខ ទូច តួនាទីអង្គការសហប្រជាជាតិ ភ្នំពេញ ឆ្នាំ២០០៣ ទំព័រ ៣

ប្រទេសជាតិរបស់ខ្លួនដោយផ្ទាល់។ ប្រជាពលរដ្ឋ គឺជាប្រភពអំណាចតែមួយគត់។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ មិនមែនជារបស់គណបក្សណាមួយ ក្រុមណាមួយ ឬជារបស់អាទិទេពណាមួយ ឬក៏ជារបស់ព្រះណានោះក៏ទេដែរ។ ជារបបមួយធានាបានសុខសន្តិភាព ស្ថេរភាពនយោបាយ គោរពសិទ្ធិសេរីភាព គោរពសិទ្ធិមនុស្ស យុត្តិធម៌ នីតិរដ្ឋ និងការរីកចម្រើនជាងរបបសក្តិភូមិផ្តាច់ការ នោះគឺរបបប្រជាធិបតេយ្យ។ របបដឹកនាំរដ្ឋប្រភេទនេះ តម្រូវឲ្យមានគោលការណ៍បែងចែកអំណាច រវាងស្ថាប័នកំពូលៗរបស់ជាតិឲ្យដាច់ចេញ និងឯករាជ្យពីគ្នា ដើម្បីឲ្យមានគោលការណ៍តុល្យភាពអំណាច គឺអំណានីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ មិនឲ្យមានការរំលោភឈ្លានពានគ្នាឡើយ។ រដ្ឋាភិបាលដែលកើតចេញពីរបបប្រជាធិបតេយ្យ គឺជារដ្ឋាភិបាលកើតចេញពីប្រជាពលរដ្ឋ ជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ និងធ្វើអ្វីៗដើម្បីប្រជាពលរដ្ឋ។ ដែលគោលដៅរបស់អ្នកប្រាជ្ញ ក៏ដូចជាទស្សនវិទូ គឺចង់ឲ្យប្រជាពលរដ្ឋទូទាំងសកលលោករួចផុតពីការជិះជាន់ គំរាមកំហែង រស់នៅជាទាសករ ធ្វើទុក្ខបុកម្នេញ ដូចដែលបានកើតមាននាពេលកន្លងមកបានមករួមរស់នៅក្នុងរបបសេរី សុខសន្តិភាព ដែលប្រជាពលរដ្ឋខ្លួនឯងជាម្ចាស់ប្រទេសជាតិ ប្រជាពលរដ្ឋខ្លួនឯង ជាម្ចាស់សិទ្ធិសេរីភាព ប្រជាពលរដ្ឋខ្លួនឯងជាអធិបតី អំណាចទាំងអស់ស្ថិតក្នុងកណ្តាប់ដៃប្រជាពលរដ្ឋជាអចិន្ត្រៃយ៍ ប្រជាពលរដ្ឋជាសមាជិកក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយ និងការចាត់ចែងកិច្ចការដឹកនាំរដ្ឋ។ របកគំហើញរបស់ទស្សនវិទូទាំងឡាយ ដែលបានចង្អុលបង្ហាញទៅរករបបប្រជាធិបតេយ្យទើបប្រទេសជាច្រើន និងកាន់តែច្រើនឡើងលើសកលលោកបានផ្លាស់ពីរបបផ្តាច់ការ បែរមកទទួលយករបបដឹកនាំប្រទេសតាមបែបប្រជាធិបតេយ្យវិញ ដែលធ្វើឲ្យប្រទេសជាតិទទួលបានការអភិវឌ្ឍន៍ជឿនលឿនទាំងសេដ្ឋកិច្ច ទាំងបច្ចេកវិទ្យា និងទាំងសិទ្ធិមនុស្ស។

ទន្ទឹងនេះដែរ ព្រះរាជាណាចក្រកម្ពុជាទទួលយករបបប្រជាធិបតេយ្យផ្លូវការណ៍លើកទី១ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៧[៤៥]។ រហូតមកដល់ការដឹកនាំដ៏ល្អរបស់ ព្រះបាទ នរោត្តមសីហនុ និងអំពីព្រះរាជសកម្មភាព ដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជារបស់ព្រះអង្គ ដែលប្រកបដោយសីលធម៌ ផ្តល់នូវសុខសន្តិភាព សិទ្ធិសេរីភាពជូនប្រជាពលរដ្ឋក្នុងការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន គឺសភាតំណាងរាស្ត្រ ព្រមទាំងផ្តល់សុភមង្គលជូនប្រជារាស្ត្រខ្មែរទាំងមូល ក៏ប៉ុន្តែបន្ទាប់ពីការរីកចម្រើន និងមានសន្តិភាពប្រកបដោយសីលធម៌។ ជារួមប្រទេសខ្មែរយើងក៏បានជួបនូវវិបត្តិនយោបាយមួយចំនួនគួបផ្សំនឹងការចុះអន់ថយក្នុងការគោរពច្បាប់ និងការដឹកនាំប្រទេសមិនបានល្អ បណ្តាប្រទេសជាតិរំកិលចូលដល់សង្គ្រាមនៅក្នុងឆ្នាំ១៩៧០។ ចាប់ពីឆ្នាំ១៩៧០ នោះមក ការគោរពច្បាប់ និងការអនុវត្តន៍សិទ្ធិតាមលទ្ធិប្រជាធិបតេយ្យចាប់ចុះខ្សោយបន្តិចម្តងៗរហូតដល់យុគសម័យកុម្មុយនីស្ត ចាប់រលាយសាបសូន្យតែម្តងនៅឆ្នាំ១៩៩០។ ប្រទេសខ្មែរបានជួបនូវសោកនាដកម្មដោយការជិះជាន់កាប់សម្លាប់ និងសង្គ្រាមរ៉ាំរ៉ៃ រហូតដល់ឆ្នាំ១៩៩១ គឺដល់ពេលដែលខ្មែរយើងមានការ

[៤៥] ព្រឹត្តបត្រវិទ្យាស្ថានខ្មែរ សម្រាប់លទ្ធិប្រជាធិបតេយ្យ "ប្រជាធិបតេយ្យ និងច្បាប់" ឆ្នាំ ៣ លេខ៣ ខែមីនា ឆ្នាំ២០០១ ទំព័រ ២

ស្រុះស្រួលគ្នា ហើយក៏ជាចំណុចចាប់ផ្ដើមឡើងវិញក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ។ កិច្ចព្រមព្រៀងថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺជាកិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយជម្លោះនៅកម្ពុជានិងជាថ្ងៃដែលប្រជាពលរដ្ឋខ្មែរទទួលបាននូវសិទ្ធិសេរីភាពនិងការគោរពសិទ្ធិមនុស្សក្នុងការទាមទារឲ្យបាន នូវជីវភាពរស់នៅបានសមរម្យដែលប្រជាពលរដ្ឋបានបាត់បង់អស់ជាច្រើនទសវត្សកន្លងមកនោះ។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺមានការគាំទ្រ និងការគ្រប់គ្រងប្រទេសខ្មែរដោយអង្គការសហប្រជាជាតិ ហៅកាត់ថា អ៊ុនតាក់(United Nations Transitional Authority in Cambodia-UNTAC) តាមរយៈការរៀបចំបោះឆ្នោត ការអនុម័តរដ្ឋធម្មនុញ្ញថ្មី ហើយតែងតាំងរដ្ឋាភិបាល ដោយឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញ គឺរបបប្រជាធិបតេយ្យសេរីពហុបក្ស។ ដូច្នេះគំនិតប្រជាធិបតេយ្យនិងសិទ្ធិសេរីភាព ការគោរពសិទ្ធិមនុស្សនៅកម្ពុជា កាន់តែរីកដុះដាល និងរស់រានមានជីវិតឡើងវិញក្នុងទឹកដីខ្មែរចាប់ពីឆ្នាំ១៩៩៣មករហូតដល់បច្ចុប្បន្នដែលប្រជាពលរដ្ឋ ជាសមាសធាតុនៃការការទាមទារនិងអនុវត្តដោយខ្លួនឯកមិនអាចខ្វះបាន។

## ២.៣.ទស្សនវិទ្យានៃសិទ្ធិពលរដ្ឋ

ធម្មជាតិរបស់មនុស្សទូទៅលើលោកនេះ តែងមានខុសមានត្រូវជាការធម្មតា។ ពេញមួយជីវិតរស់នៅរបស់មនុស្សមិនមែនប្រព្រឹត្តទៅបានល្អគ្រប់បែបយ៉ាងដោយឥតខ្ចោះនោះក៏ទេដែរ។ ធម្មជាតិពិតរបស់មនុស្ស គឺត្រូវតែមានកំហុសឆ្គង។ កំហុស គឺនិយាយពីមនុស្សហ្នឹងឯង។ គ្មានមនុស្សណាម្នាក់អះអាងថាខ្លួនឯងល្អជាងគេផុតលេខ ឬមានតម្លៃលើសគេឯងនោះទេ។

ការគិតខុសៗគ្នារបស់មនុស្សម្នាក់ៗនេះបានធ្វើឲ្យស្ថានភាពរស់នៅមានកម្រិតផ្សេងៗគ្នា ដែលធ្វើឲ្យប្រព័ន្ធជីវសាស្ត្រ និងសង្គមកាន់តែរឹងមាំ និងរីកចម្រើន។ ការខុសគ្នាខាងការត្រិះរិះ ការគិត គំនិតបញ្ហាផ្សេងគ្នាធ្វើឲ្យគេអាចដោះស្រាយបានផ្សេងគ្នា។ មនុស្សតាមធម្មជាតិចូលចិត្តរស់នៅជួបជុំគ្នាជាក្រុម ជាសហ-គមន៍ ។ល។ គ្មាននរណាអាចរស់នៅដោយឯកឯង ទោល ខ្វះទំនាក់ទំនង គ្មានការរៀនសូត្រ និងគ្មានពិសោធន៍ផ្សេងឡើយ។

នៅក្នុងសង្គម កាលណាតម្រូវការជាមូលដ្ឋានរបស់មនុស្សម្នាក់ៗ មិនត្រូវបានគោរព មិនឲ្យតម្លៃទេ នោះអាចនាំឲ្យកើតមានអំពើអយុត្តិធម៌ វិសមភាព ការសងសឹក គំនុំ ការប្រឆាំងតបវិញដោយហិង្សាបណ្ដាលឲ្យមានអស្ថេរភាព និងមហន្តរាយ។

ជាការឧបមាថា នៅពេលដែលភាពលំបាកនៃប្រជាជនមិនត្រូវបានគេយកចិត្តទុកដាក់ ឬការទទួលការប្រមាថមើលងាយ ឬតម្រូវការរបស់ពលរដ្ឋត្រូវបានបដិសេធ គេអាចក្លាយទៅជាមនុស្សឃោរឃៅ។ ដូចជាករណីចោរលួច។ គាត់បានលួចត្រឹមចំណីអាហារ ដើម្បីចំអែតក្រពះនៅពេលក្រោយគាត់នឹងអាចប្រើប្រាស់អាវុធដើម្បីប្លន់[៤៦]។

[៤៦] វិទ្យាស្ថានខ្មែរ ដើម្បីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៣ ទំព័រ ១៨

## ២.៣.១ លក្ខណៈទូទៅស្តីអំពីសិទ្ធិសេរីភាពពលរដ្ឋ

កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់ៗរូបពិតជាមិនអាចដកហូត ឬរំលាយចោលបានឡើយ ដោយហេតុថា កិត្តិយស និងសេចក្តីថ្លៃថ្នូរ គឺជាតម្លៃជាមូលដ្ឋានរបស់មនុស្ស ជាមរតកដ៏មានសក្តានុពលមានជាប់តាំងពីកំណើតដូចៗគ្នា។ គ្រប់រូបវន្តបុគ្គល និងនីតិបុគ្គល ទោះជាជនជាតិណាក៏ដូចជនជាតិណាដែរ នៅលើពិភពលោកនេះ ទោះក្រឬមាន ទាបឬខ្ពស់ សឬខ្មៅ សុទ្ធតែស្រឡាញ់កិត្តិយស សេចក្តីថ្លៃថ្នូរ ស្រឡាញ់សិទ្ធិសេរីភាព ស្រឡាញ់សេចក្តីសុខ និងជីវិតរបស់ខ្លួនទាំងអស់គ្នា។ គ្មានអ្នកណាម្នាក់ ទោះបីជាកើតមកនៅក្នុងព្រៃភ្នំ ចុងកាត់មាត់ញកណាក៏ដោយ ក៏មិនចង់ឲ្យគេប្រមាថមាក់ងាយខ្លួន វាយដំច្រំធាក់លើរាងកាខ្លួន ឬកាប់សម្លាប់ខ្លួន ឬក៏មិនចង់ធ្វើខ្ញុំកញ្ជះដាច់ថ្លៃឲ្យអ្នកណាម្នាក់ដែរ។ គ្មានអ្នកណាម្នាក់ដែលថា មិនចង់មានសេរីភាពដើរហើរ និយាយស្តី មានជំនឿ មានសិទ្ធិស្រឡាញ់អ្នកដែលខ្លួនស្រឡាញ់នោះទេ។ សេរីភាពរបស់បុគ្គលគ្រប់រូបត្រូវទទួលបាននូវសិទ្ធិរួចផុតពីការធ្វើទុក្ខបុកម្នេញគំរាមកំហែង បំភិតបំភ័យ ទារុណកម្មគ្រប់រូបភាព ។ល។

សិទ្ធិសេរីភាពរបស់ពលរដ្ឋ គឺសេរីភាពក្នុងការគិត ធ្វើ និយាយស្តី សិទ្ធិដើម្បីបោះពុម្ពផ្សព្វផ្សាយគំនិតសេរីក្នុងការពិភាក្សាជាមួយអ្នកដទៃ និងសេរីភាពសមាគមជាមួយអ្នកផ្សេងរបស់មនុស្សម្នាក់ៗ នៅក្នុងការទាមទារបញ្ចេញគំនិតប្រកបដោយសន្តិភាព ដោយគ្មានអ្នកណាមកបង្អាក់ ឬរារាំងដំណើរបានឡើយ។ សិទ្ធិសេរីភាពបុគ្គលក្នុងសង្គមប្រជាធិបតេយ្យ រួមមានគ្រប់សិទ្ធិទាំងអស់ត្រូវបានធានាដោយច្បាប់ និងការពារដោយស្ថាប័នរដ្ឋាភិបាល។

មានទស្សនៈភាន់ច្រឡំខ្លះៗបានយល់ឃើញថាការរីកចម្រើនជឿនលឿនខាងសេដ្ឋកិច្ច និងទីផ្សារ គឺជាតម្លៃទីមួយដ៏មានសារៈសំខាន់ ដែលធ្វើឲ្យមនុស្សគ្រប់រូបប្រាថ្នាចង់បាន ប៉ុន្តែតាមការពិតធម្មជាតិរបស់មនុស្សជាតិត្រូវការជាចាំបាច់ពីដំបូងនោះគឺ កិត្តិយស សេចក្តីថ្លៃថ្នូរ សិទ្ធិសេរីភាពទាំងឡាយនោះទៅវិញទេ។ តាមទស្សនៈស្តីពីសិទ្ធិសេរីភាពរបស់ពលរដ្ឋយល់ឃើញថា ការធ្វើឲ្យអន្តរាយដល់ផលប្រយោជន៍ ខឿនសេដ្ឋកិច្ច និងសង្គម ពុំមែនបណ្តាលមកតែពីគ្រោះមហន្តរាយធម្មជាតិ ឬកម្មពារវេរា ឬការឡើងចុះនៃសេរីភាពរបស់មនុស្ស ឬក៏បណ្តាលមកពីគ្មានគំនិតផ្តួចផ្តើមនោះក៏ពុំមែនដែរ ប្រការសំខាន់ត្រង់ថាការមិនគោរពសិទ្ធិសេរីភាពរបស់មនុស្ស និងរំលោភបំពារបំពានទៅលើមនុស្សទៅវិញទេ។

លោកអាប្រាហាមលីនខូន( ABRAHAM LINCOLN ) ប្រធានាធិបតីទី៦ របស់សហរដ្ឋអាមេរិក( ១៨៦១-១៨៦៥) មានប្រសាសន៍ថា "រដ្ឋាភិបាលប្រជាធិបតេយ្យ ជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ កើតចេញពីប្រជា-ពលរដ្ឋ និងធ្វើអ្វីៗដើម្បីប្រជាពលរដ្ឋ" [៤៧]។

-រដ្ឋាភិបាលរបស់ប្រជាពលរដ្ឋមានន័យថា ជារដ្ឋាភិបាលមិនមែនជាកម្មសិទ្ធិរបស់បុគ្គលណា ឬរបស់មេដឹកនាំណា ឬរបស់គណបក្សនយោបាយ ឬក្រុមណានោះទេ។

---

[៤៧] ព្រឹត្តិបត្រៈ ស្រាវជ្រាវឆ្នាំទី៧ លេខ០៦៥ ខែកុម្ភៈ ភ្នំពេញ ឆ្នាំ២០០០ ទំព័រ ៥

-រដ្ឋាភិបាលកើតចេញពីប្រជាពលរដ្ឋមានន័យថា ជារដ្ឋាភិបាលកើតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌តាមឆន្ទៈពិតរបស់ប្រជាពលរដ្ឋ។

-រដ្ឋាភិបាលធ្វើអ្វីៗដើម្បីប្រជាពលរដ្ឋមានន័យថា ជារដ្ឋាភិបាលបំពេញភារកិច្ច ដើម្បីផលប្រយោជន៍សាធារណៈជន ដែលជាម្ចាស់អំណាច ដោយមិនប្រកាន់បក្សពួក រើសអើងក្រុមណាឡើយ។

ប្រជាធិបតេយ្យ ជាវិទ្យាសាស្ត្រនយោបាយដែលសិក្សាអំពីរបបស្វ័យគ្រប់គ្រងសង្គមដោយខ្លួនឯង របស់ប្រជាជនសិក្សាថា ប្រជាពលរដ្ឋកាន់កាប់អំណាចដែលពោរពេញដោយអធិបតេយ្យភាព និងកំណត់ថា អធិបតេយ្យភាព ស្ថិតនៅក្នុងដៃរបស់ប្រជាពលរដ្ឋទាំងអស់[៤៨]។

ដូច្នេះ សិទ្ធិសេរីភាពពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យ គឺសំដៅទៅលើសង្គមមួយដែលប្រជាពលរដ្ឋមានសិទ្ធិ មានសេរីភាពពេញលេញក្នុងការប្រើប្រាស់សិទ្ធិ ដោយសេរីក្រោមក្រិត្យក្រមច្បាប់ ដោយពុំខ្លាចពុំញញើតក្នុងការចូលរួមក្នុងកិច្ចការសង្គមរបស់ខ្លួន ដើម្បីធ្វើការសម្រេចចិត្តក្នុងការកំណត់ជោគវាសនាប្រទេសជាតិរបស់ខ្លួនគ្រប់ៗរូប និងជាពិសេសប្រជាពលរដ្ឋប្រើអធិបតេយ្យរបស់ខ្លួន ដើម្បីទាមទារឲ្យរដ្ឋាភិបាលការពារសិទ្ធិសេរីភាព ការពារសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្សជាតិ ដែលសិទ្ធិសេរីភាពទាំងអស់នេះ មានជាប់តាំងពីកំណើត ដែលតម្រូវឲ្យអាជ្ញាធររដ្ឋាភិបាលការពារឲ្យបានដូចមានចែងក្នុងច្បាប់ជាតិ កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិ។ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ អាចប្រើអធិបតេយ្យរបស់ខ្លួនតាមរយៈអ្នកតំណាងរាស្ត្រដែលជាអ្នកត្រួតពិនិត្យ និងជានាំឲ្យរដ្ឋាភិបាលគោរព និងប្រតិបត្តិតាមគម្រោងផែនការត្រឹមត្រូវរបស់ខ្លួន។

សិទ្ធិសេរីភាពពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យសេរីពហុបក្ស គឺជាផ្នែកមួយនៃសិទ្ធិមនុស្ស ដែលអត្ថន័យទូទៅរបស់សិទ្ធិមនុស្ស ត្រូវបានទស្សនៈទំនើបរបស់លោកខាងលិចបានព្យាយាមកំណត់និយមន័យ សិទ្ធិមនុស្សតាមចរន្តបីផ្សេងគ្នាគឺ ១-តាមទ្រឹស្តីបែបធម្មជាតិនិយម (Iusnaturalist Approach) ២-តាមទ្រឹស្តីនៃការយល់ដឹងបែបវិជ្ជមាននិយម(Positivist Understanding)និង ៣-ទ្រឹស្តីដែលឈរលើមូលដ្ឋានប្រវត្តិសាស្ត្រ(Historic accounty)។

តាមទ្រឹស្តីអ្នកធម្មជាតិនិយម(Iusnaturalist Approach) ដូចដែលបានអនុម័តដោយធម្មនុញ្ញអង្គការសហប្រជាជាតិ បានកំណត់និយមន័យសិទ្ធិមនុស្សថា "អ្វីដែលមាននៅជាប់ ឬនៅជាស្ថិតស្ថេរ (Inherent or immanet) ដោយឯកឯងជាមនុស្ស។ មានន័យថា សិទ្ធិមនុស្សមានតាំងពីមុន ដែលមានការទទួលស្គាល់ដោយច្បាប់ទៅទៀត។ ជំហររបស់អ្នកធម្មជាតិនិយមបានគាំទ្រដល់ការប្តឹងតវ៉ា ខាងសីលធម៌ដែលសមស្របអាចបង្កើតបានជាសិទ្ធិ ទោះបីជាមិនមានការទទួលស្គាល់ពីរដ្ឋក៏ដោយ។ ម្យ៉ាងទៀត ទ្រឹស្តីនៃការយល់ដឹងបែបវិជ្ជមាននិយមប្រកាន់ជំហរថា មានតែការប្តឹងតវ៉ាខាងសីលធម៌ទេ ដែលសមស្របទាំងឡាយណាដែលច្បាប់ទទួលស្គាល់ប៉ុណ្ណោះ(ជាច្បាប់ធម្មជាតិ ច្បាប់អន្តរជាតិ ឬច្បាប់រដ្ឋប្បវេណី) ដែលជាមូលដ្ឋាននៃសិទ្ធិមនុស្ស។

---

[៤៨] ដៃយ៉ាន-រ៉ាវិច: ខែវិច្ឆិកា ឆ្នាំ១៩៨៩ ក្រសួងឃោសនាការអាមេរិក បោះពុម្ពខែតុលា ឆ្នាំ២០០១ ទំព័រ ៣

តាមរយៈទស្សនៈនេះត្រូវមានការសម្របសម្រួល ដែលត្រូវតែធ្វើឡើងដោយស្ថាប័នស្របច្បាប់ទាំងឡាយ (ដូចជា រដ្ឋសហគមន៍អន្តរជាតិ) ដើម្បីផ្លាស់ប្តូរការទាមទារ តាមផ្លូវសីលធម៌នោះឲ្យទៅជាសិទ្ធិ ហើយដោយការសម្របសម្រួលនេះហើយ ដែលអាចធ្វើឲ្យសិទ្ធិទាំងនេះត្រូវបានគេគោរព។ រីឯទ្រឹស្តីដែលឈរលើមូលដ្ឋានប្រវត្តិសាស្ត្រវិញអះអាងថា "សិទ្ធិមនុស្ស គឺទស្សនៈធម្មានិយម(ជាអ្វីដែលគួរតែកើតមាន) នៃសេចក្តីត្រូវការទាំងឡាយដែលត្រូវបានគេចាត់ទុកថាជាសក្តានុពលសម្រាប់ការអភិវឌ្ឍន៍មនុស្ស ទាំងបុគ្គល ជាក្រុម និងជាក្រុមប្រជាពលរដ្ឋ។ តាមទ្រឹស្តីសិទ្ធិនេះ សិទ្ធិមនុស្ស គឺជាការទទួលស្គាល់ដោយច្បាប់នូវអ្វីដែលជាតម្រូវការដើម្បីបំពេញតាមសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ពាក្យថា សេចក្តីត្រូវការជាក់ស្តែង ឬសេចក្តីត្រូវការសង្គម ឬសេចក្តីត្រូវការសំដៅលើគម្លាតរវាងស្ថានភាពបច្ចុប្បន្នរបស់បុគ្គល និងក្រុមទាំងឡាយដែលរារាំងដល់ការអភិវឌ្ឍន៍មនុស្សរបស់ពួកគេ ចំពោះលទ្ធភាពសម្រាប់ការអភិវឌ្ឍន៍ជាលក្ខណៈបុគ្គលម្នាក់ៗ ឬជាក្រុមនៅក្នុងទេសកាលប្រវត្តិសាស្ត្រនីមួយៗ។ គម្លាតនេះត្រូវបានចាត់ទុកថា ជាសក្តានុពល និងសម្រាប់យកទៅធ្វើការពិចារណាលើលក្ខខណ្ឌ ដែលអំណោយផលសម្រាប់ការអភិវឌ្ឍន៍។ ក្នុងន័យនេះ ពាក្យថា សេចក្តីត្រូវការ គឺរួមបញ្ចូលទាំងអ្វីដែលជាសក្តានុពលផងដែរ។ សិទ្ធិមនុស្សត្រូវបានគេឲ្យនិយម-ន័យថា ជាការធានាដោយច្បាប់ ដែលអាចផ្លាស់ប្តូរពីសក្តានុពលនៃការអភិវឌ្ឍន៍មនុស្សឲ្យក្លាយទៅជាការអភិវឌ្ឍន៍ជាក់ស្តែង។ យើងរកឃើញទស្សនវិជ្ជានេះនៅក្នុង"គោលដៅអភិវឌ្ឍន៍សហសវត្សរ៍" ដែលអនុម័តដោយអង្គការសហប្រជាជាតិឆ្នាំ២០០០។ គោលដៅនេះបង្ហាញពីសក្តានុពលនៃការអភិវឌ្ឍន៍មនុស្សនៅក្នុងពេលបច្ចុប្បន្ននៃប្រវត្តិសាស្ត្រ ដែលជាសក្តានុពលសម្រាប់ការពិចារណា អំពីធនធានដែលមានរបស់សកលលោក ហើយក៏ជាសក្តានុពលសម្រាប់ការពិចារណាផងដែរ ចំពោះសមត្ថភាពរបស់សកលលោកក្នុងការឆ្លើយតបចំពោះតម្រូវការបន្ទាន់ៗរបស់មនុស្សនៅក្នុងសង្គម។

ការសិក្សាស្រាវជ្រាវនេះបានសន្និដ្ឋានថា រាល់គំនិត និងទស្សនៈទាំងអស់ដែលបានរៀបរាប់មកខាងលើនេះ អាចរួមចំណែក ដើម្បីឲ្យនិយមន័យពេញលេញ និងទូលំទូលាយមួយស្តីពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងសិទ្ធិមនុស្ស។ ដូច្នេះ រាល់គំនិតនីមួយៗយើងអាចចាត់ទុកថា ជាការបំពេញបន្ថែមគ្នាទៅវិញទៅមក។ គំនិតនីមួយៗបានសង្កត់ធ្ងន់អំពីចំណុចសំខាន់នៃគោលការណ៍គ្រឹះនៃសិទ្ធិមនុស្សផង និងសិទ្ធិសេរីភាពក្នុងបរិបទប្រជាធិបតេយ្យពិតប្រាកដផង។ ទស្សនៈដែលឈរលើមូលដ្ឋានប្រវត្តិសាស្ត្របានគូសបញ្ជាក់អំពីសេចក្តីត្រូវការរបស់សង្គមថា ជាសក្តានុពលសម្រាប់ការអភិវឌ្ឍន៍មនុស្សដែលជាប្រភពនៃខ្លឹមសារ និងទម្រង់នៃសិទ្ធិ។ ចំពោះទស្សនៈបែបធម្មជាតិនិយមវិញ សំដៅលើយុត្តិកម្មតាមផ្លូវសីលធម៌នៃសិទ្ធិ រីឯទស្សនៈបែបវិជ្ជមាននិយមវិញ គឺនិយាយអំពីការទទួលស្គាល់សិទ្ធិមនុស្សដោយច្បាប់ ហើយដែលអាចផ្លាស់ប្តូរការទាមទារតាមផ្លូវសីលធម៌ និងតម្រូវការសង្គមមួយចំនួនឲ្យទៅជាសិទ្ធិស្របច្បាប់ដែលអាចយកទៅអនុវត្តបាន។

និយមន័យទូលំទូលាយនៃសិទ្ធិមនុស្ស ត្រូវបានពិចារណាទៅលើទិដ្ឋភាព ឬធាតុផ្សំបីដែលមានដូចជាៈ ក-មានការទទួលស្គាល់ដោយច្បាប់(Positivisty Approach), ខ-យុត្តិកម្មតាមផ្លូវសីលធម៌(Iusnaturalist

Approach), គ-តម្រូវការសង្គម(Historic Approach)។ សម្រាប់ការសិក្សានេះសិទ្ធិមនុស្ស គឺសំដៅលើរាល់សិទ្ធិទាំងឡាយណាដែលទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ មានន័យថា ជាសិទ្ធិទាំងឡាយណាដែលអាចអនុវត្តបាន។ ការណ៍នេះរួមបញ្ចូលទាំងការទាមទារតាមផ្លូវសីលធម៌ ដែលសង្គមទទួលស្គាល់ និងការស្វែងបំពេញនូវសេចក្ដីត្រូវការរបស់សង្គម ដោយពិចារណាទៅលើសក្ដានុពលនៃការអភិវឌ្ឍន៍មនុស្សនៅគ្រប់បរិបទនៃសង្គម នៃទេសកាលប្រវត្តិសាស្ត្រនីមួយៗ[៤៩]។

សេរីភាពរបស់ពលរដ្ឋ មានសិទ្ធិដែលមិនអាចកាត់ថ្លៃបានក្នុងការរស់រានមានជីវិត និងសេរីភាព ហើយពួកគេទាមទារនូវសិទ្ធិមានកម្មសិទ្ធិលើទ្រព្យសម្បត្តិ ដែលពួកគេបានចូលរួមចំណែកពលកម្ម ដូចជាការធ្វើស្រែចំការជាដើម។ នេះគឺជាតួនាទីរបស់រដ្ឋាភិបាលក្នុងការការពារអាយុជីវិត សេរីភាព និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ[៥០]។ មនុស្សគ្រប់រូបមានសិទ្ធិ និងមានសេរីភាពក្នុងការកាន់មតិ និងក្នុងការប្រកាន់ និងបញ្ចេញមតិដោយគ្មានការជ្រៀតជ្រែក និងបារម្ភភិតភ័យដោយសារមតិរបស់ខ្លួន និងសេរីភាពក្នុងការស្វែងរកការទទួលនិងការផ្សព្វផ្សាយទូទៅដោយឥតគិតព្រំដែនអ្វីឡើយនូវព័ត៌មាន ព្រមទាំងគំនិតអ្វីផ្សេងៗតាមមធ្យោបាយបែបណាក៏ដោយមិនខ្លាចពីការតបតពីរដ្ឋាភិបាលឡើយ[៥១]។ បុគ្គលគ្រប់រូបមានសិទ្ធិធ្វើអ្វីទាំងអស់តាមតែគេចូលចិត្ត តែចាំបាច់មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។

### ២.៣.២. សិទ្ធិសេរីភាពប្រជាពលរដ្ឋ

ជាទូទៅ តាមលក្ខណៈធម្មជាតិមនុស្សម្នាក់ៗកើតមកភ្ជាប់មកជាមួយនូវសិទ្ធិសេរីភាពពេញលេញដូចៗគ្នាទាំងអស់។ មនុស្សគ្រប់រូប ជាធម្មតាមានចលនាទៅតាមសេរីភាពនៃការគិត ចំណង់ចំណូលចិត្ត ប៉ងប្រាថ្នាតាមបែបធម្មជាតិចេះរើបម្រាស់ ចេះទាមទារតស៊ូដោយមិនត្រូវការកម្លាំងត្រួតត្រាសង្កត់ជិះជាន់កេងប្រវ័ញ្ច ដាក់កំហិត ឬសកម្មភាពផ្សេងៗដែលមនុស្សយល់ឃើញថា ជាការរំលោភសិទ្ធិសេរីភាពរបស់មនុស្ស។ មនុស្សគ្រប់ៗរូបទោះស្រី ប្រុស, ពណ៌សម្បុរ, ភាសា, សាសនា, ឋានៈ, វណ្ណៈ, ដើមកំណើតៈ ពូជសាសន៍ ខ្ពស់ ទាប ។ល។ គឺមានលក្ខណៈសកលដូចគ្នា ស្ដីពីសិទ្ធិសេរីភាព និងភាពថ្លៃថ្នូរ។ ឧទាហរណ៍ថា មានក្រុមមនុស្សមួយក្រុមធ្វើទុក្ខបុកម្នេញលើក្រុមមនុស្ស ដែលមានជាតិសាសន៍ខុសគ្នា រួចហើយបន្តធ្វើទុកបុកម្នេញលើជាតិសាសន៍ដទៃទៀត ដែលខុសពីក្រុមខ្លួនឯង ឃើញថា ចម្លើយដែលទទួលបានគឺសេចក្ដីឈឺចាប់ខ្លោចផ្សាដូចៗគ្នា។

សូមសាកល្បងពិចារណាទៅលើការដាក់ការគាបសង្កត់ រឹតត្បិតលើសិទ្ធិសេរីភាពនៃលក្ខណៈសកលរបស់មនុស្សពីអង្គការចាត់តាំងនយោបាយ ឬអាជ្ញាធរចំពោះសកម្មភាព ឬចលនារបស់មនុស្សហួសពីកម្រិតព្រំដែន

---

[៤៩] ក្រសួងយុត្តិធម៌ និងUNDP មាគ៌ាឆ្ពោះទៅរកយុត្តិធម៌ ឆ្នាំ២០០៥ ភ្នំពេញ ទំព័រ ១១-១២-១៣

[៥០] សិទ្ធិមនុស្សៈ សម្រង់ឯកសារនៃឧបករណ៍អង្គការសហប្រជាជាតិ ទំព័រ ១២

[៥១] ដេវីត បូស David Boaz: កំណើតសេរីភាពនិយម ឆ្នាំ២០០៧ ទំព័រ ៦៣

មិនអាចទទួលបានក្រុមទទួលរងគ្រោះគេនឹងតបតវិញ ដើម្បីបង្ហាញពីការមិនទទួលយកការរឹតត្បិត ការរំលោភចំពោះសិទ្ធិសេរីភាព ដែលមនុស្សទូទៅមានឡើយ។ មនុស្សគ្រប់រូបជាទូទៅ មិនត្រូវប្រព្រឹត្តរំលោភលើសកលភាពនៃសិទ្ធិសេរីភាពផងគ្នាឡើយ គប្បីគិតថា អ្នកដទៃក្រៅអំពីយើងក៏ជាមនុស្សដូចយើងដែរ។

### ២.៣.៣. ភារកិច្ចរដ្ឋចំពោះសិទ្ធិសេរីភាពប្រជាពលរដ្ឋ

ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពពីកំណើតដូចគ្នា ស្មើគ្នា ហើយមានអត្តសញ្ញាណរៀងៗខ្លួន។ ក្នុងគោលបំណងរបស់ប្រជាពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ ពួកគេបង្កើតរដ្ឋាភិបាលឡើង ក្នុងគោលបំណងឲ្យរដ្ឋាភិបាលការពារសិទ្ធិសេរីភាពដែលពួកគេកំពុងតែមានស្រាប់។ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ដែលត្រូវបានចែងក្នុងកតិកាសញ្ញាអន្តរជាតិ ដែលត្រូវបានប្រកាសជាសកលកាលពីឆ្នាំ១៩៦៦ ដោយអង្គការសហប្រជាជាតិ ដែលតម្រូវឲ្យរដ្ឋភាគីទាំងឡាយ មានកាតព្វកិច្ចធានាចំពោះការគោរពសិទ្ធិសេរីភាពដល់ដំណើរការជីវិតរស់នៅប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ដោយមិនគិតថាមានធនធាន ឬមិនមានធនធានគ្រប់គ្រាន់នោះទេ។ ជនគ្រប់រូបទាំងអស់ដាច់ខាតត្រូវតែបានធានាយ៉ាងច្បាស់លាស់ពីរដ្ឋនៃកតិកាសញ្ញា។ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋរាប់ទាំងសិទ្ធិសេរីភាពខាងសេដ្ឋកិច្ច សិទ្ធិសេរីភាពខាងសង្គម និងវប្បធម៌ និងសិទ្ធិនយោបាយ។

នៅក្នុងរបបសង្គមអនុវត្តនយោបាយប្រជាធិបតេយ្យ រដ្ឋាភិបាល គឺមិនគ្រាន់តែជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិប៉ុណ្ណោះទេ តែរដ្ឋាភិបាល គឺជាអង្គការកំពូលនៃអំណាចនីតិប្រតិបត្តិរបស់ប្រទេសដែលត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះមុខជាតិនូវអ្វីដែលមានការធានាដោយច្បាប់ ដែលប៉ះពាល់ ដល់ប្រយោជន៍ជាតិ ប៉ះពាល់ដល់ប្រជាពលរដ្ឋ និងនូវអ្វីដែលរដ្ឋាភិបាលបានសន្យា និងធានាថាអនុវត្តតាមច្បាប់ជាតិ និងអន្តរជាតិ។

## ២.៤. ដើមកំណើតសិទ្ធិពលរដ្ឋ និងការបែងចែកសិទ្ធិពលរដ្ឋក្នុងសង្គមខ្មែរ

### ២.៤.១ ដើមកំណើតសិទ្ធិពលរដ្ឋ

ប្រភពសិទ្ធិសេរីភាពប្រជាពលរដ្ឋទាំងឡាយភាគច្រើន ត្រូវបានគេកត់សម្គាល់ឃើញមាននៅតាមសាសនានានាដូចជាៈ សាសនាព្រះពុទ្ធ សាសនាព្រាហ្មណ៍ សាសនាឥស្លាម សាសនាគ្រិស្ត និងសាសនាតាវ ជាដើម ដែលឆ្លុះបញ្ចាំងពីការតស៊ូរើបម្រាស់ក្នុងបុព្វហេតុពីរយ៉ាង គឺដើម្បីសិទ្ធិសេរីភាព និងសមភាពរបស់មនុស្សគ្រប់ជនជាតិក្នុងពិភពលោក។ កាលបរិច្ឆេទខាងក្រោមនេះ លើកឡើងពីចលនាតស៊ូមតិ ដើម្បីសិទ្ធិសេរីភាពប្រជាពលរដ្ឋ។

Bill of Rights គឺជាសេចក្តីប្រកាសជាសាធារណៈនៅទូទាំងប្រទេសអង់គ្លេសនៅឆ្នាំ១៦៨៩ ស្តីពីសិទ្ធិជាមូលដ្ឋានលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ដោយប្រកាសបដិសេធចោលទាំងស្រុងនូវការអះអាងពីបុរាណ ដែលថាច្បាប់មានប្រភពចេញពីអាទិទេព ឬពីព្រះមហាក្សត្រ។ សេចក្តីប្រកាសនេះបញ្ញត្តិថា ព្រះមហាក្សត្រ ក៏ជាប្រជាជនមួយនៃវិធានច្បាប់ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ។ បន្ថែមលើសពីនេះទៅទៀត

ច្បាប់បានចែងថា ព្រះមហាក្សត្រ ត្រូវតែអនុវត្តតាមអំណាចសភា ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយសេរី ត្រឹមត្រូវ យុត្តិធម៌ នៃប្រជាជនប្រទេសអង់គ្លេស។

Bill of Rights ជាសេចក្តីប្រកាសដំបូងបំផុត ដែលបានហាមឃាត់ដាច់ខាតចំពោះការដាក់ទណ្ឌកម្មព្រៃផ្សៃ និងការកាត់ទោសដោយអយុត្តិធម៌ ហើយច្បាប់នេះក៏បានជានានូវការប្រព្រឹត្តទៅនៃគណៈវិនិច្ឆ័យរបស់តុលាការ មិនលំអៀង និងចៅក្រមឯករាជ្យផងដែរ។

នៅក្នុងសេចក្តីប្រកាសឯករាជ្យ នាឆ្នាំ១៧៧៦ របស់សហរដ្ឋអាមេរិក ដែលនិយាយពីរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរបស់ប្រជាពលរដ្ឋ ដើម្បីធានា និងការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋ។ វិសាលភាពនៃសេចក្តីប្រកាសនេះបង្ហាញពីសិទ្ធិសេរីភាពដូចខាងក្រោមៈ

តាមធម្មជាតិ មនុស្សគ្រប់រូប គឺមានសិទ្ធិសេរីភាព និងឯករាជ្យដោយស្មើភាពគ្នា និងមានសិទ្ធិផ្ទាល់ខ្លួនមួយចំនួនដូចជា សិទ្ធិមានភាពសប្បាយរីករាយក្នុងជីវិត និងមានសេរីភាពក្នុងការកាន់កាប់កម្មសិទ្ធិលើទ្រព្យសម្បត្តិ និងស្វែងរកសុភមង្គល និងសុវត្ថិភាព។

សេចក្តីប្រកាសស្តីអំពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋរបស់ប្រទេសបារាំងកាលពីឆ្នាំ១៧៨៩ មានលំនាំភាគច្រើនចេញពីសេចក្តីប្រកាសឯករាជ្យនៃសហរដ្ឋមេរិកឆ្នាំ១៧៧៦។ សេចក្តីប្រកាសនេះបានសង្កត់ធ្ងន់ទៅលើសិទ្ធិធម្មជាតិ និងសិទ្ធិដែលមិនអាចផ្ទេរបាន រួមមានដូចជាៈ សេរីភាព សិទ្ធិមានកម្មសិទ្ធិ សន្តិសុខ និងសិទ្ធិដើម្បីតស៊ូប្រឆាំងនឹងការគាបសង្កត់។ ខ្លឹមសារនៃមាត្រា១នៃសេចក្តីប្រកាស បានទទួលស្គាល់នូវសមភាព ជាពិសេសសមភាពចំពោះមុខច្បាប់ និងយុត្តិធម៌។ ទន្ទឹមនឹងនេះ សេចក្តិប្រកាសក៏បានអះអាងអំពីគោលការណ៍ នៃការបែងចែកអំណាចផងដែរ។ ស្តេចល្វីសទី១៦ បានផ្តល់សច្ចាប័នលើសេចក្តីប្រកាសនេះដោយនៅក្រោមការគាបសង្កត់ពីសភា និងពីប្រជាជនដែលបានដង្ហែក្បួនឆ្ពោះទៅកាន់ក្រុង Veersaillers[៥២]។

## ២.៤.២. ការបែងចែកសិទ្ធិពលរដ្ឋក្នុងសង្គមខ្មែរ

### ២.៤.២.១ .សិទ្ធិសង្គម

#### ២.៤.២.១.១. សិទ្ធិសេរីភាពក្នុងពិធីបុណ្យទាន

តាមមាត្រា៤៣ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជាបានចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ឬសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ មានន័យថារដ្ឋាភិបាលបានបើកចំហចំពោះសិទ្ធិសេរីភាពក្នុងការគោរពសាសនាតាមចំណង់ចំណូលចិត្តរបស់ប្រជាជនកម្ពុជា ដោយមិនបានដាក់កំហិត ឬប្រកាន់រើសអើងចំពោះការគោរពសាសនារបស់ប្រជាជនកម្ពុជាឡើយ។

---

[៥២] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៣

នៅក្នុងសង្គមខ្មែរ មានប្រារព្ធពិធីបុណ្យទានជាច្រើនប្រភេទជាយូរយាណាស់មកហើយ ដែលបុណ្យសាសនាមានដូចជា: បុណ្យពុទ្ធាភិសេក បុណ្យបច្ច័យបួន បុណ្យចម្រើនព្រះជន្ម បុណ្យមាឃបូជា បុណ្យពិសាខបូជា និងបុណ្យប្រពៃណីជាតិមានដូចជា បុណ្យចូលឆ្នាំថ្មី បុណ្យភ្ជុំបិណ្ឌ...។ ប្រជាពលរដ្ឋខ្មែរមានសេរីភាពជ្រើសរើសពិធីបុណ្យទាន ដោយសេរីទៅតាមលទ្ធភាពជាក់ស្តែង និងតាមសទ្ធាជ្រះថ្លានៃបុគ្គលម្នាក់ៗ។ ក្នុងពិធីបុណ្យទាំងឡាយ ពុំឃើញមានបទដ្ឋានបញ្ញត្តិ ឬកម្រិតថា មានតែបុគ្គលអ្នកមានទ្រព្យសម្បត្តិ អ្នកមានត្រកូលខ្ពង់ខ្ពស់ ឬអភិជន គហបតី នាម៉ឺន មហាសេដ្ឋី ឬព្រះមហាក្សត្រ ទើបអាចធ្វើបុណ្យទាននោះបានទេ។ ពោលគឺ ប្រជាពលរដ្ឋគ្រប់ៗរូប មានសេរីភាពក្នុងការធ្វើបុណ្យទៅតាមសេចក្តីប្រាថ្នារបស់ខ្លួន អាស្រ័យទៅលើការយល់ឃើញ និងធនធានរបស់ខ្លួនផង អមដោយសេចក្តីជ្រះថ្លា ដោយពុំមានការបង្ខិតបង្ខំពីសង្គម ឬពីអាជ្ញាធរឡើយ។

**២.៤.២.១.២ សិទ្ធិសេរីភាពក្នុងជំនឿសាសនា**

ជាទូទៅប្រជាជនខ្មែរមានសិទ្ធិសេរីភាព ខាងការសម្តែងមតិអំពីសាសនាដោយគ្មានការគំរាមកំហែង ឬការគាបសង្កត់លើការប្រកាន់យកអំពីសាសនាអ្វីឡើយ។ ពោលគឺ ទាំងប្រជាពលរដ្ឋរហូតដល់ព្រះមហាក្សត្រមានសេរីភាពពេញលេញចំពោះជំនឿរបស់ខ្លួនដូចជាការជឿលើអារក្ស អ្នកតា អាទិទេព សាសនាព្រះពុទ្ធសាសនាចាម សាសនាគ្រិស្ត ។ល។ ការគោរពសាសនាឃើញថា ប្រជាជនខ្មែរគោរពដោយមានការលាយឡំគ្នាដោយគ្មានចំពោះជំនឿលើសាសនាណាមួយដាច់ខាតទេ[៥៣]។ ដូចជា ក្នុងករណីជាក់ស្តែងក្នុងពិធីរៀបមង្គលការគេឃើញមានប្រារព្ធតាមព្រះពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង គឺត្រង់ពិធីសូត្រមន្ត ពិធីបង្វិលពពិលចងដៃ។ល។ ពិធីទាំងនេះ គឺសំដៅបង្ហាញពីការចង់បានសិរីសួស្តីសុភមង្គលចម្រុងចម្រើន សេចក្តីសុខក្សេមក្សាន្តក្នុងក្រុមគ្រួសារភរិយាថ្មី។ ករណីខ្លះមានពិធីសូត្រមន្តលើកជោគជាតារាសី កាត់គ្រោះ ថ្ងៃ ខែ ឆ្នាំ ដើម្បីបញ្ចៀសគ្រោះកាចចង្រៃទាំងឡាយឲ្យចាកចេញឆ្ងាយ។ ប្រាសាទអង្គរវត្តជានិមិត្តរូបបង្ហាញពីការគោរពជំនឿលើព្រះពុទ្ធសាសនា។ ឯប្រាសាទបាយ័ន ក៏បង្ហាញពីជំនឿលើព្រះព្រហ្មផង និងពុទ្ធនិយមផង ត្រង់ព្រះព្រហ្មមុខបួនតំណាងព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា។ ប្រវត្តិសាស្ត្រខ្មែរបង្ហាញពីសេរីភាពលើជំនឿសាសនាទូលំទូលាយ ដោយគ្មានការប្រទាំងប្រទើស ឬ ជម្លោះសាសនា បណ្តាលឲ្យមានការសង្កត់សង្កិនរឹតត្បិតពីរដ្ឋាភិបាលឡើយ។ ម្យ៉ាងពលរដ្ឋក្នុងសាសនានីមួយៗ មានការសាមគ្គីគ្នាអធ្យាស្រ័យបង្កើតជាបរិយា-កាសល្អក្នុងសង្គមរហូតដល់បានចូលរួមកសាងសង្គមបានរីកចម្រើននៅសម័យអង្គររុងរឿង។

ដោយសារសេរីភាពជំនឿសាសនា ប្រជាពលរដ្ឋខ្មែរភាគច្រើនមានជំនឿលើព្រះពុទ្ធសាសនា។ ដែលព្រះពុទ្ធសាសនាមានលំនាំដោយឈរលើគោលការណ៍ប្រជាធិបតេយ្យបែបសេរី ហើយម្យ៉ាងព្រះពុទ្ធសាសនាមានបង្រួមជាគោលការណ៍សន្តិភាពមានការសាមគ្គីរឹងមាំ បណ្តុះទំនាក់ទំនងល្អក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងស្របច្បាប់ធម្មជាតិ និងច្បាប់ជាតិផងដែរ។

---

[៥៣] សមាគមអាដហុកៈ សិទ្ធិមនុស្សតាមរយៈអក្សរសិល្ប៍ខ្មែរ ភ្នំពេញ ឆ្នាំ២០០២ ទំព័រ ១៣

### ២.៤.២.២ សិទ្ធិនយោបាយ

#### ២.៤.២.២.១ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ

ទោះបីប្រជាពលរដ្ឋខ្មែរយើងធ្លាប់ជួបប្រទះតែការឈឺចាប់ ការប្រែប្រួលឥតស្រាកស្រាន្តពីមួយជំនាន់ទៅមួយជំនាន់ ដោយសង្គ្រាមបំផ្លិចបំផ្លាញ និងបម្លាស់ប្តូរប្រព័ន្ធនយោបាយសង្គមឥតឈប់ឈរក៏ដោយក៏នៅតែឃើញថា ប្រជាពលរដ្ឋខ្មែរគ្រប់ជំនាន់តាំងពីយូរលង់ណាស់មកហើយ ឃើញមានសេរីភាពនៃការបញ្ចេញមតិយោបល់រិះគន់ទៅលើអ្នកគ្រប់គ្រងចំពោះការគាបសង្កត់កេងប្រវ័ញ្ច ជិះជាន់មកលើប្រជាពលរដ្ឋ ដើម្បីទាមទារនូវការគោរព ការពារផលប្រយោជន៍ចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ។ យើងឃើញថា លំអាននៃការតស៊ូមតិរបស់ប្រជាពលរដ្ឋខ្មែររហូតមកទល់ពេលបច្ចុប្បន្ននេះ កំពុងតែទទួលបាននូវ សេរីភាពទូលំទូលាយផងដែរ។

ការសម្តែងមតិតាមរយៈអក្សរសិល្ប៍ខ្មែរ គេឃើញមាននៅក្នុងរឿងខ្លះដូចជាៈរឿងធនញ្ជ័យ ជាដើម។ នៅក្នុងរឿងនេះគេឃើញថា តួអង្គធនញ្ជ័យបានលេចធ្លោក្នុងការតស៊ូមតិដោយអហិង្សាតតាំងជាមួយសេដ្ឋីស្តេចខ្មែរផង និង ក្លាហានហ៊ានតស៊ូមតិជាមួយអ្នកប្រាជ្ញចិន និងស្តេចក្រុងចិត្តផង ដើម្បីការពារព្រះនគរ។ ទីបំផុតធនញ្ជ័យ ទទួលបានជោគជ័យលើអំពើជិះជាន់របស់ពួកសក្តិភូមិ និងបរទេសឈ្លានពានជាដរាប។

នៅក្នុងរឿងទុំទាវក៏ឃើញថា តួអង្គទុំ និងទាវ ហ៊ានបញ្ចេញមតិជាមួយព្រះមហាក្សត្រ ដើម្បីទាមទារស្នេហាបរិសុទ្ធ យុត្តិធម៌របស់គូស្នេហានេះ រហូតទទួលបានយុត្តិធម៌តាមសេចក្តីប្រាថ្នាចង់បាន។ តាមរយៈរឿងនេះឃើញថា ប្រជាពលរដ្ឋ មានសិទ្ធិសេរីភាពក្នុងការតវ៉ា ក៏ដូចជាសិទ្ធិក្នុងការសម្តែងមតិ ដើម្បីទាមទាររកយុត្តិធម៌ សេរីភាពក្នុងការជ្រើសរើសគូស្រករទៅតាមមនោសញ្ចេតនានៃមនុស្សម្នាក់ៗផងដែរ។

រឿងភូមិតិរច្ឆាន រឿងនេះគឺជារឿងពិតដែលកើតឡើងក្នុងសង្គមខ្មែរ នាជំនាន់ស្រុកខ្មែរទាំងមូល ស្ថិតនៅក្រោមអាណានិគមបារាំងសក្តិភូមិផ្តាច់ការយ៉ាងមុតមាំចន្លោះពីឆ្នាំ១៨៦៣ ដល់ ឆ្នាំ១៩៥៣។ នៅចុងឆ្នាំ១៩២៣ រ៉េស៊ីដង់បារាំងសែសប្រចាំខេត្តព្រៃវែង ដែលជាមនុស្សម្នាក់ប្រកបដោយភាពស្វាហាប់ និងមហិច្ឆតាខ្លាំង ឈ្មោះហ្វេលិច ល្វីស៍ បារដេស(Félix Louis Bardez) បានរាយការណ៍ពីរបៀបប្រមូលពន្ធដារនៅតាមស្រុកឃុំ នៅក្នុងខេត្តព្រៃវែងឲ្យមានប្រសិទ្ធិភាព និងទទួលបានជោគជ័យប្រសើរជាងឆ្នាំ៩២៣។ ជោគជ័យរបស់លោក បារដេស នៅខេត្តព្រៃវែងនេះ បានធ្វើឲ្យចៅហ្វាយនាយទាំងឡាយរបស់គាត់មានការចាប់អារម្មណ៍។ ហេតុនេះហើយបានជានៅចុងឆ្នាំ១៩២៤ គេបានតែងតាំងលោក បារដេស ឲ្យទៅធ្វើជារ៉េស៊ីដង់ប្រចាំខេត្ត[៥៤]។ តាមរយៈរឿងនេះឃើញថា ដោយសារតម្លៃពន្ធដារចេះតែឡើងថ្លៃ និងខ្វះអាហារទទួលទានផងនោះញ៉ាំងឲ្យប្រជាពលរដ្ឋខ្មែរពុំអាចស៊ូទ្រាំនឹងអំពើជិះជាន់កេងប្រវ័ញ្ចមើលងាយ អំពើអយុត្តិធម៌ ប្លន់សិទ្ធិសេរីភាពប្រជាជនទាំងឡាយ និងការប្រព្រឹត្តអំពើទារុណកម្មដ៏សែនឃោរឃៅហួសហេតុរបស់ពួកអាណានិគម

[៥៤] ដេវិឌចាណ្ឌល័រ ប្រវត្តិសាស្ត្រខ្មែរ ភ្នំពេញ ២០០៩ ទំព័រ ១៨៤

បារាំង មកលើជនស្លូតត្រង់កម្ពុជា យើងតទៅទៀតបានឡើយ។ ការចងកំហឹងឈឺចាប់ទាំងប៉ុន្មាននៃជនរងគ្រោះទាំងឡាយបានពូតផ្គុំជាកម្លាំង ជិតជាមដោយទឹកចិត្តស្នេហាជាតិដ៏មោះមុត បង្កើតបានជាក្បួនមហាបាតុកម្មដ៏រំភើបដឹកនាំដោយឈ្មោះ ដួន និងឈ្មោះ នៅ បានក្រោកឡើងតស៊ូរំដោះជាតិ ដោយបានសម្លាប់រ៉េតស៊ីដង់បារាំងម្នាក់ប្រចាំនៅខេត្តកំពង់ឆ្នាំង ឈ្មោះបារដេស នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩២៥។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ គឺបានបង្ហាញអំពីចលនាមហាបាតុកម្មហិង្សារបស់មហាជនកសិករខ្មែរនៅភូមិក្រាំងលាវ ខេត្តកំពង់ឆ្នាំង ប្រតិកម្មប្រឆាំងទប់ទល់នឹងនឹមដែក ដើម្បីរំដោះជាតិពីអាណានិគមបារាំងសេស។ ដោយប្រទេសជាតិស្ថិតនៅក្រោមអាណានិគមរបស់ខ្លួន បារាំងបានស្នើឲ្យព្រះមហាក្សត្រខ្មែរព្រះនាម ព្រះនរោត្តម ប្តូរឈ្មោះពីភូមិក្រាំងលាវ ទៅជាភូមិតិរច្ឆានតាមរយៈព្រះរាជប្រកាសចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩២៥។ ក្រៅពីនេះ គេឃើញប្រជាពលរដ្ឋខ្មែរនៅតំបន់ផ្សេងៗទៀតនៅទូទាំងប្រទេសចេញតស៊ូមតិដោយអហិង្សាទាមទារយុត្តិធម៌ សេចក្តីថ្លៃថ្នូរជាមនុស្ស គោរពសិទ្ធិរស់នៅប្រពៃណី ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋជាម្ចាស់ប្រទេស។

តាមរយៈរឿងព្រេងនិទានក្តី ក៏ដូចជានៅក្នុងអក្សរសិល្ប៍ខ្មែរទាំងឡាយក្តីអាចសង្កេតឃើញថា ទោះបីសង្គមជាតិខ្មែរស្ថិតនៅក្នុងរបបសក្តិភូមិដែលមានស្តេចជាអ្នកគ្រប់គ្រងដឹកនាំ ដោយអំពើជិះជាន់ កេងប្រវ័ញ្ច អយុត្តិធម៌សង្គម អំពើបោកប្រាស់យ៉ាងណាក្តី ប្រជាពលរដ្ឋខ្មែរនៅតែចេញមុខតស៊ូទិតៀន រិះគន់ចំពោះអំពើអាក្រក់របស់អ្នកដឹកនាំគ្រប់ជាន់ថ្នាក់ មិនខ្លាចពីការគំរាមកំហែង ឬប្រឆាំងតបដោយការចាប់ចងដាក់គុកពីអ្នកកាន់អំណាចឡើយ។

ចំពោះច្បាប់ក្រមង៉ុយវិញ ក៏មានការបញ្ចេញមតិរិះគន់តាមបែបសិល្បៈពេញនិយមដោយលោកបានលើកឡើងថាៈ (នគរច្រើនប្លែក សប្បាយតែភ្នែក ក្នុងចិត្តវេងកម្ម កូនប្រុសបណ្តាច់ កុំភ្លេចបណ្តាំ កប្បាសសូត្រថ្នាំត្រីម៉ាំងលែងថោក) មានន័យថា រូបភាពក្បត់ខ្លឹមសារ ប្រទេសជាតិល្អតែសំបកក្រៅ មានសុភមង្គល និងសេចក្តីចម្រុងចម្រើន កើតមានតែជំពូកអ្នកមានមួយក្តាប់តូច។ ចំណែកឯប្រជាជនក្រីក្រ ដូចជា កម្មករ កសិករត្រូវបានទទួលរងគ្រោះ ដោយសារមនុស្សជំពូកអភិជនវិនិយោគិនបរទេស ឃុបឃិតជាមួយមន្ត្រីមានបុណ្យស័ក្តិចូលមកកេងប្រវ័ញ្ចជិះជាន់ និងប្រមូលទ្រព្យសម្បត្តិខ្មែរស្ទើរអស់។

**២.៤.២.២.២. សិទ្ធិសេរីភាពក្នុងរបបគ្រប់គ្រងសង្គម**

នៅក្នុងសម័យសង្គមរាស្ត្រនិយមៈ គេនៅតែឃើញមានការរិះគន់ទៅលើរបៀបដឹកនាំប្រទេសចំពោះអំពើកេងប្រវ័ញ្ចនានាដល់សង្គមជាតិដោយប្រើពាក្យ បង្កប់អត្ថន័យតាមរយៈបទចំរៀងសូរិយាល្ងាចថ្ងៃៈ តូចស៊ីតាមតូច ធំស៊ីតាមធំ រកស៊ីតាមភ្នំ ផឹកទឹកតាមដងអូរ...។ ធ្វើស្រែលើខ្នងរាស្ត្រ។

នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យៈ របបនេះជារបបប្រល័យពូជសាសន៍ឃោរឃៅព្រៃផ្សៃបំផុត ក៏ប៉ុន្តែនៅតែឃើញប្រជាពលរដ្ឋខ្មែរហ៊ាននិយាយដៀមដាម បញ្ឆិតបញ្ឆៀង រិះគន់ពីម្នាក់ទៅម្នាក់ដោយស្ងាត់ៗ (ពោត ឆ្នាំនេះល្អណាស់ប្រាកដជាឲ្យផលល្អ។ ប៉ុន្តែ តើអ្នកណាខ្លះមានសំណាងបាននៅទទួលទានពោតនេះ)។ ដាំ! ដាំ! កុំឲ្យសល់ដី! ដាំ! ដាំ! កុំនៅទំនេរ! ដាំ! ដាំ! ទាំងយប់ទាំងថ្ងៃ! ទាំងចាស់ទាំងក្មេង! តែនៅតែស៊ីបបរ

លាយគល់ចេកលាយត្រកួន។

នៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ក៏ឃើញមានមតិរិះគន់ដោយនិពន្ធជាពាក្យចុងដួនផ្សេងៗជាច្រើនដែរ។ ពាក្យប្រជាប្រិយទាំងនេះបានលើកឡើងថា កូនអ្នកក្រធ្វើទាហាន កូនអ្នកមានធ្វើនគរបាល កូនកម្មាភិបាលទៅរៀននៅបរទេស...។

នៅក្នុងសម័យព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នៈ រូបភាពនៃការតវ៉ាបញ្ចេញមតិយោបល់ នៅតែបន្តកើតមាន ហើយកាន់តែមានទ្រង់ទ្រាយខ្លាំងក្លាទូលំទូលាយចំពោះការរិះគន់ទៅលើទម្រង់ដឹកនាំរដ្ឋរបស់រដ្ឋាភិបាល ក៏ដូចជាស្ថាប័ននានារបស់រដ្ឋ ហើយមានពេលខ្លះប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិសេរីភាពនៃការសម្តែងមតិហួសពីព្រំដែនច្បាប់ និងធ្វើឲ្យបាត់បង់សេចក្តីថ្លៃថ្នូរថែមទៀតផង។

សរុបសេចក្តីមកឃើញថា ទិដ្ឋភាពនៃការសម្តែងមតិតាមរយៈពាក្យប្រៀបធៀប ជាពាក្យចំៗ ជាពាក្យកំណាព្យ ដើម្បីរិះគន់ទៅលើថ្នាក់ដឹកនាំរដ្ឋចំពោះទង្វើរបស់ខ្លួន ដែលធ្វើឲ្យខូចខាតផលប្រយោជន៍ របស់ប្រជាជននិងប្រទេសជាតិ ដូចជាអំពើអយុត្តិធម៌ អំពើពុករលួយ បក្សពួកនិយម អំពើឃុបឃិត កេងប្រវ័ញ្ចជិះជាន់ ។ល។ ចរន្តនៃការសម្តែងមតិទាមទារទៅតាមចរិតធម្មជាតិរបស់មនុស្ស នៅតែបន្តមានជាដរាបចាប់តាំងពីសម័យបុព្វកាលរហូតមកដល់បច្ចុប្បន្ននេះ ជាពិសេសប្រជាពលរដ្ឋខ្មែរ ក៏កំពុងតែបន្តប្រើប្រាស់សិទ្ធិសេរីភាពទាំងនេះយ៉ាងសកម្ម។ បច្ចុប្បន្ននេះ ចលនានៃការសម្តែងយោបល់ទៅតាមការយល់ឃើញរបស់មនុស្សម្នាក់ គឺកាន់តែពេញនិយម ព្រោះថាបច្ចុប្បន្ននេះព្រះរាជាណាចក្រកម្ពុជា ជាប្រទេសប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស ដែលជារបបមួយផ្តល់តម្លៃមនុស្ស។ និយាយអំពីអធិបតេយ្យរបស់ប្រជាពលរដ្ឋ គឺសិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋជារបបនយោបាយដឹកនាំប្រទេស ដោយផ្តល់សិទ្ធិពេញលេញឲ្យប្រជាពលរដ្ឋធ្វើជាម្ចាស់ប្រទេស និងជាម្ចាស់អធិបតេយ្យទាំងអស់ និងបើកសិទ្ធិចំហឲ្យប្រជាពលរដ្ឋ ចូលរួមកំណត់ ជោគវាសនាប្រទេសជាតិទទួលខុសត្រូវដោយខ្លួនឯង។ ការសម្តែងមតិនៃប្រជាពលរដ្ឋខ្មែរ ប្រព្រឹត្តតាមរយៈមធ្យោបាយមួយចំនួនដូចជាៈ

សារព័ត៌មានៈ បើសម្លឹងមើលលើទំព័រការសែតនានាក្នុងស្រុក ឃើញថាមានសារព័ត៌មានខ្លះនិយាយបង្ហាញអំពីឆន្ទៈនយោបាយមោះមុត ក្នុងការអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលដោយលើកឡើងអំពីសមិទ្ធិផលនានាដូចជា សាលារៀន មន្ទីរពេទ្យ អគាររដ្ឋ ប្រព័ន្ធធារាសាស្ត្រ ផ្លូវថ្នល់ ស្ពាន ជាដើម។ នៅលើទំព័រសារព័ត៌មានខ្លះទៀតបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការថែរក្សាសុខសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខសង្គម កេរវកម្ម និងការទាក់ទាញវិនិយោគិនក្នុង និងក្រៅប្រទេសឲ្យមកវិនិយោគនៅកម្ពុជា។ល។ រីឯសារព័ត៌មានខ្លះទៀត បានសរសេររិះគន់ថ្កោលទោសចំៗទៅលើទម្រង់ដឹកនាំប្រទេស ដែលបានធ្វើឲ្យខាតបង់ផលប្រយោជន៍របស់ប្រជាជននិងផលប្រយោជន៍ជាតិ ដែលធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនទទួលរងនូវការឈឺចាប់ ដូចជា ការរិះគន់ លើអំពើអយុត្តិធម៌សង្គម ការបង្ក្រាបលើក្រុមបាតុករអហិង្សា ការប្រព្រឹត្តពុករលួយ ការកាប់បំផ្លាញព្រៃឈើ លក់ទ្រព្យសម្បត្តិជាតិ ក៏ដូចជារិះគន់ ចំពោះការបណ្តោយឲ្យមានជនអន្តោប្រវេសន៍ខុសច្បាប់

ចូលមករស់នៅក្នុងប្រទេសជាដើម។

បច្ចុប្បន្នអ្នកនិពន្ធមានសេរីភាពទូលំទូលាយ ក្នុងការសម្តែងមតិនៅលើទំព័រសារព័ត៌មានក្នុងការចុះផ្សាយអត្ថបទនានាហើយពេលខ្លះ ក៏ការប្រើប្រាស់សិទ្ធិសេរីភាពរបស់ខ្លួនក្នុងការសម្តែងយោបល់លើសពីការពិតបណ្តាលឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយលរបស់អ្នកដទៃក៏មាន។

ការប្រើសិទ្ធិសេរីភាព ក្នុងការសម្តែងមតិ យោបល់របស់មនុស្សម្នាក់ៗក្នុងក្របខ័ណ្ឌប្រជាធិបតេយ្យគឺពិតជាត្រឹមត្រូវពុំអាចខ្វះបានឡើយ ក៏ប៉ុន្តែការសម្តែងមតិដែលមានតម្លៃគឺប្រភេទនៃការសម្តែងមតិ ឬយោបល់ទៅតាមលក្ខណៈវិទ្យាសាស្ត្រ គោរពក្រមសីលធម៌ មានគុណធម៌ក្នុងការនិយាយស្តី និយាយតែការពិត ដោយមានឥរិយាបថ កៃលំអ ស្លាបនាទន់ភ្លន់ ត្រជាក់ ពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយលើទម្រង់ច្បាប់ជាតិដោយទឹកចិត្តជ្រះថ្លា និងពិនិត្យផលប៉ះពាល់ទៅលើសង្គមជាតិ។ ការសម្តែងមតិដែលកាន់តែមានតម្លៃ និងមានអំណាចគឺការសម្តែងមតិមិនធ្វើឲ្យប៉ះពាល់សន្តិសុខជាតិ ស្ថេរភាពនយោបាយ។ល។ ទោះការមិនបកស្រាយតាមទំព័រការសែត នោះជាការពិតក៏ដោយ គប្បីយល់ថាការពិតទាំងឡាយដែលនិយាយទៅធ្វើឲ្យប៉ះពាល់ដល់ស្ថេរភាពសង្គម ដូចជាបង្កចលាចលផ្សេងៗ គួរកុំសម្តែងយោបល់ ព្រោះវាគ្មានផលប្រយោជន៍ឡើយ។ ត្រង់ចំណុចនេះបង្ហាញពីការយល់ដឹងសព្វគ្រប់ ពីការណាគួរ ការណាពុំគួរ គឺអាស្រ័យទៅលើកម្រិតយល់ដឹងពីកម្រិតស្នេហាជាតិ មនសិការជាតិ ស្មារតីជាតិនិយម សតិសម្បជញ្ញៈ កម្រិតសីលធម៌របស់អ្នកនិពន្ធតែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្ននេះបានធ្វើវិសោធនកម្ម ដោយដកទោសបទព្រហ្មទណ្ឌចេញពីបទបរិហាកេរ្តិ៍ មកនៅត្រឹមតែសងជម្ងឺចិត្តតែប៉ុណ្ណោះ នេះសបញ្ជាក់ឲ្យឃើញថា រដ្ឋាភិបាលមានឆន្ទៈនយោបាយខ្ពស់ក្នុងការបង្កើតឬបើកឲ្យកាន់តែទូលាយ បន្ថែមទៀតចំពោះការសម្តែងមតិយោបល់របស់ប្រជាពលរដ្ឋ ក្នុងការថ្លែងអំពីគំនិតរបស់ខ្លួន ឬរបបគំហើញរបស់ខ្លួនដោយមិនខ្លាចចាប់ដាក់ពន្ធនាគារដូចមុនៗឡើយ។

### ២.៤.២.២.៣ សិទ្ធិសេរីភាពក្នុងការប្រជុំ និងបង្កើតសមាគម

ជាការពិត តាមប្រវត្តិសាស្ត្រដើមរបស់មនុស្សជាតិ មានការរួមរស់នៅជាក្រុមកុលសម្ព័ន្ធ សហគមន៍ តូចធំទៅតាមការយល់ព្រម ការពេញចិត្ត ការស្ម័គ្រស្មោះនៃមនុស្សម្នាក់ៗ ទើបតែក្រោយៗមកក៏បង្កើតបានទៅជារដ្ឋប្រទេស។ ក្នុងការសាមគ្គីរស់នៅតាមក្រុម តាមពួក តាមកុលសម្ព័ន្ធនីមួយៗតែងមានមេក្រុម មេកន្ទ្រាញ ជាអ្នកដឹកនាំដើម្បីការពាររក្សាសមាជិកក្រុមរបស់គេ ពីការគំរាមកំហែង យាយី ធ្វើទុក្ខបុកម្នេញ ពីសំណាក់អ្នកដទៃក្រៅក្រុម។ តាមទំនៀមទម្លាប់ នៃសង្គមខ្មែរតាំងពីបុរាណមក ក៏នៅតែបន្តបង្កើតសមាគម ឬសហគមន៍ ដែលជាប្រពៃណីល្អដើម្បីជួយជ្រោមជ្រែងគ្នាទៅវិញទៅមកក្នុងការងារប្រចាំថ្ងៃរបស់ខ្លួន។ ដូចជាកសិករនៅជនបទធ្វើស្រែចំការនៅពេលដកសំណាប ស្ទូងស្រូវ ជម្រះស្មៅចំការ គេតែងតែប្រាប់គ្នីគ្នា ប្រកូកប្រកាស ឲ្យមានការចូលរួមសាមគ្គីពីអ្នកដទៃ (ដាក់ដៃ) ឲ្យមកជួយដកស្ទូងឲ្យឆាប់រួច ហើយគេតែងទៅជួយគេវិញ(សងដៃ) ឲ្យគ្រប់ចំនួនវិញ។ លើសពីនេះប្រជាពលរដ្ឋតាមជនបទនៅមានបង្កើតសមាគមចានឆ្នាំងតាមភូមិ តាមសហគមន៍ទៀតផង។ ប្រយោជន៍គឺនៅពេលមានពិធីបុណ្យទានផ្សេងៗ គេយកសម្ភារៈទាំងនោះមកប្រើប្រាស់បានគ្រប់ពិធីបុណ្យនៃសមាជិក

សមាគម។ ឯការសាងសង់ផ្ទះសំបែងក៏ដូច្នេះដែរ ប្រជាពលរដ្ឋនៅតាមជនបទ ក៏នៅតែរក្សាសមាគមជួយសាងសង់ សហការគ្នាទៅវិញទៅមក។ ឯក្នុងការប្រារព្ធពិធីបុណ្យផ្សេងៗ ដូចជា បុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ បុណ្យកឋិនទាន ឬបុណ្យផ្សេងៗទៀតក្តី គេឃើញប្រជាពលរដ្ឋខ្មែរចូលរួមសាមគ្គី ប្រជុំពិភាក្សាគ្នាបង្កើតគណៈកម្មការ ដើម្បីបែងចែកការងារដោយមានការទទួលខុសត្រូវតាមក្រុមនីមួយៗ រហូតដល់បញ្ចប់កម្មវិធីបុណ្យដោយក្តីសប្បាយរីករាយបំផុត។ រូបភាពនៃការចូលរួមបង្កើតជាសមាគម សហគមន៍ គឺប្រព្រឹត្តទៅដោយសេរីពីប្រជាពលរដ្ឋដោយបន្តពីសម័យបុព្វកាលរហូតមកដល់បង្កើតបានជារដ្ឋហើយក្តីក៏នៅតែមានសមាគមដែរ ដូចជា សមាគមចានឆ្នាំង សមាគមតាមវត្តអារាម សាលារៀនជាដើម។ សូមបញ្ជាក់ថា ចរិតនៃការចូលរួមជួបជុំពិភាក្សាក្តី ឬបង្កើតសមាគមក្តី គឺដើម្បីសាមគ្គីធ្វើកិច្ចការជួយគ្នាទៅវិញទៅមកសំដៅធ្វើយ៉ាងណាឲ្យកិច្ចការមានការជឿនលឿន ឆាប់រហ័ស ចម្រុងចម្រើនឲ្យទាន់ពេលវេលា ឬរដូវការបានផលច្រើន។

ឆ្លងចូលមកដល់បច្ចុប្បន្នភាពវិញ បើទោះបីកម្ពុជាពុំទាន់មានច្បាប់បញ្ញត្តិ ស្តីពីការគ្រប់គ្រងសមាគមក្តី ក៏ប៉ុន្តែឃើញមានសមាគម សហគមន៍ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល ជាច្រើនត្រូវបានអនុញ្ញាតឲ្យបង្កើតឡើងដោយរដ្ឋាភិបាល។ ដោយសារសហគមន៍ សមាគម ក៏ដូចជាអង្គការក្រៅរដ្ឋាភិ-បាលជាដៃគូរដ៏មានប្រសិទ្ធិភាព ឬអាចនិយាយបានថា ជាកញ្ចក់សម្រាប់ឆ្លុះសកម្មភាពរបស់រដ្ឋាភិបាលក្នុងការបំពេញតួនាទីតាមរដ្ឋធម្មនុញ្ញ ទើបរដ្ឋាភិបាលបើកចំហ លើកទឹកចិត្តឲ្យសមាគមនានាក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលស្របច្បាប់នានា ធ្វើសកម្មភាពរបស់ខ្លួន ដើម្បីបម្រើប្រជាពលរដ្ឋទៅតាមកម្មវិធីរបស់ខ្លួនយ៉ាងទូលំទូលាយ ពោលគឺ ដើម្បីធ្វើយ៉ាងណាជួយអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ដើម្បីឈានទៅរកការកាត់បន្ថយភាពក្រីក្រលើកស្ទួយការអនុវត្តន៍ ច្បាប់ និងប្រជាធិបតេយ្យ។

ដូច្នេះ អាចសន្និដ្ឋានបានថា តាមលក្ខណៈធម្មជាតិជាមនុស្សខ្មែរចាប់តាំងពីដើមរាងដរាបមក គឺជាប្រជាពលរដ្ឋមានវិន័យថ្លៃថ្នូរ ប្រកាន់ពាក្យសច្ចៈ ប្រកាន់ពាក្យយុត្តិធម៌ សីលធម៌ផូរផង់ខ្ពង់ខ្ពស់ មិនចេះកេងប្រវ័ញ្ច មិនចេះលួច មិនចេះរំលោភបំពានលើទ្រព្យសម្បត្តិអ្នកណាឡើយ ពោលគឺនិយាយក្នុងផ្នត់គំនិតត្រង់ទៅត្រង់មក ទឹកចិត្តប្រកបដោយសប្បុរស ខ្មាស់បាប ខ្លាចបាប ខ្មាស់អំពើអាក្រក់ទាំងឡាយ គោរពអភិសមាចារ។ ធម្មសញ្ញា នៃព្រលឹងរបស់ជនជាតិខ្មែរ ដែលជាអ្នកប្រកាន់សន្តិភាព សាមគ្គីគ្នា ស្មោះត្រង់ សីលធម៌ល្អ មេត្តាធម៌ គុណធម៌កម្រិតខ្ពស់ កតញ្ញូតាធម៌ ជាអ្នកជា ជាអ្នកជួយសង្គ្រោះ ជាមនុស្សមានដួងចិត្តទូលំទូលាយ មិនចេះរើសអើង។ ប៉ុន្តែដោយសារប្រជាជាតិមានវិបត្តិផ្ទៃក្នុងផង និងមានបរទេសចូលមកញុះញង់លាបពណ៌ផង ធ្វើឲ្យផ្នត់គំនិតដើមដ៏ថ្លៃថ្លា កម្រមានចំពោះជាតិសាសន៍ដទៃនោះ ក៏បានបាត់បង់ស្ទើរអស់ទៅហើយ។ ប្រការដ៏ចាំបាច់ និងសំខាន់បំផុតនោះ គួរតែប្រជាពលរដ្ឋខ្មែរទូទៅ ជាពិសេសរដ្ឋាភិបាលគួរដាក់ដាំបណ្តុះទស្សនៈនេះឲ្យមានជីវិតឡើងវិញ ព្រោះសំណុំនៃផ្នត់គំនិតទាំងនេះជាកម្លាំងចលករដ៏មានសក្តានុពល ដើម្បីកសាងសង្គមឲ្យជឿនលឿនក្នុងបរិយាកាសសីលធម៌ថ្លៃថ្នូរ។ ម្យ៉ាងទៀតដើម្បីបញ្ចៀសការដណ្តើមដីធ្លី ដែលកំពុងតែកើតមានយ៉ាងក្តៅគគុកផង ដែលអាចបង្កទៅជាសង្គ្រាមដីធ្លី នោះគួរតែរដ្ឋាភិបាលចេញប័ណ្ណកាន់កាប់កម្មសិទ្ធិស្របច្បាប់ឲ្យ

ឆាប់តាមដែលអាចធ្វើទៅបាន ជូនប្រជាពលរដ្ឋដែលមានកិរិយាកាន់កាប់ស្របតាមច្បាប់ភូមិបាល។

**២.៤.២.២.៤ សិទ្ធិសេរីភាពទទួលបានយុត្តិធម៌**

ជាការពិតរឿងយុត្តិធម៌ទៅតាមដំណើរពិត គឺជាសេចក្តីត្រូវការចាំបាច់បំផុតរបស់មនុស្សជាតិ។ ជាពិសេសប្រជាពលរដ្ឋខ្មែរកាលពីដើមឡើយ ប្រទេសកម្ពុជាមានព្រះរាជា ជាអ្នកដឹកនាំ និងគ្រប់គ្រងរដ្ឋទាំងមូល អំណាចទាំងអស់នៅលើព្រះរាជា រាប់ទាំងអំណាចខាងរកយុត្តិធម៌ផងដែរ។ បើទោះបីក្នុងរបបសង្គមដឹកនាំបែបនេះប្រជាពលរដ្ឋខ្មែរទទួលបានយុត្តិធម៌ពុំសូវពេញចិត្តក៏ដោយ ក៏ចលនាតស៊ូដើម្បីទាមទារយុត្តិធម៌ និងព្រឹត្តិការណ៍ស្វែងរកយុត្តិធម៌នៅតែកើតមានតាមរយៈអក្សរសិល្ប៍ខ្លះ រឿងព្រេងខ្លះដែរដូចជាៈ

រឿងក្រពើរមិលគុណៈ រឿងដណ្តើមកូនគ្នារវាងមនុស្សស្រីធម្មតា និងយក្ខិនី និងរឿងដទៃទៀត។ ទិដ្ឋភាពទូទៅនៃការលាតត្រដាង ពីការទាមទាររកយុត្តិធម៌តាមរយៈរឿងព្រេងខ្មែរទាំងនេះ សង្កេតឃើញមានដូចជា តួអង្គសុភាទន្សាយ ព្រះឥន្ទ្រ ព្រះមហោសធបណ្ឌិត និងព្រះមហាក្សត្រជាដើម ដែលជាអ្នកជានានូវការវិនិច្ឆ័យចំពោះរឿងក្តីដោយយុត្តិធម៌។ ប៉ុន្តែការសង្ឃឹមទុកក្នុងការទទួលបានយុត្តិធម៌ទាំងស្រុង១០០%នោះមិនបានដូចសេចក្តីប្រាថ្នាទេ។ ស្មារតីទាមទារយុត្តិធម៌របស់អ្នករងគ្រោះ មិនមែនឈប់ត្រឹមមន្ត្រីថ្នាក់ក្រោមឡើយ គឺថាអ្នក រងគ្រោះបន្តរកភាពបរិសុទ្ធរបស់ខ្លួនទៅដល់ព្រះឥន្ទ្រ ឬដល់ព្រះរាជាដែលប្រកាន់ខ្ជាប់នូវទសពិតរាជធម៌ ដូចជា ករណីជាក់ស្តែងក្នុងប្រវត្តិសាស្ត្រខ្មែរតែម្តង គឺរឿងតាត្រសក់ផ្អែម។ ដោយភាគីម្ចាស់ក្របីប្តឹងទៅចៅក្រមឲ្យពញាជ័យ និងពញាសួស សងក្របី ដែលអ្នកទាំងពីរបានគប់ដេញបណ្តាលឲ្យធ្លាយពោះស្លាប់។ ប៉ុន្តែពញាជ័យ និងពញាសួសមិនសុខចិត្តយល់ព្រមទទួលយកការកាត់សេចក្តីពីចៅក្រមទេត្បិតថា កាលខ្លួនគប់ក្របីនឹងដុំថ្មចង្រ្កាននោះ មិនបានប៉ងប្រាថ្នាឲ្យក្របីនោះស្លាប់ទេ គឺគ្រាន់តែឲ្យក្របីនោះខ្លាចហើយរត់ចេញទៅតែប៉ុណ្ណោះ។ ចៅក្រម កាត់មិនដាច់ស្រេច ក៏នាំសេចក្តីនេះទៅប្តឹងដល់សេនាបតី។ សេនាបតី ក៏កាត់មិនដាច់ស្រេចទៀត ទើបនាំមនុស្សនោះឡើងទៅក្រាបបង្គំទូលព្រះបរមបពិត ដើម្បីសូមឲ្យទ្រង់ព្រះរាជវិនិច្ឆ័យ។ ព្រះរាជាឲ្យយកដុំថ្មនោះចោលទៅលើក្របីឯទៀតជាការសាកល្បងមើល។ កាលពញាជ័យចោលទៅចំក្របីណា ក្របីនោះក៏ធ្លាយពោះនឹងដុំថ្មនោះស្លាប់ទាំងអស់មែន។ ព្រះរាជាទ្រង់ពិសោធន៍ឃើញយ៉ាងនេះ ក៏ទ្រង់កាត់សេចក្តីថា ក្របីនោះស្លាប់ដោយសារពញាជ័យឥតមានចិត្ត ក្លែងសម្លាប់ទេ ពីព្រោះពញាជ័យមិនបានដឹងថាថ្មនេះជាដែកកាយសិទ្ធិទេ ស្មានថាជាដុំថ្មធម្មតាបានជាចោលត្រូវស្លាប់ដូច្នេះ។ ហេតុនេះទ្រង់ប្រោសប្រទានព្រះរាជវិនិច្ឆ័យថា ក្របីនោះស្លាប់នេះទុកថា ជាកម្មរបស់វាចុះ យើងនឹងយកទោសពញាជ័យមិនបានទេ[៥៥]។

ស្មារតីស្រឡាញ់យុត្តិធម៌ឃើញផងដែរ នៅក្នុងរឿងអាខ្វាក់អាខ្វិន ព្រះរាជាក្នុងរឿងនេះមិនត្រឹមតែយកកូនរាស្ត្រ កូនមន្ត្រីទៅឲ្យយក្សស៊ីប៉ុណ្ណោះទេ ព្រះអង្គក៏បានយកបុត្រីតែមួយគត់របស់ព្រះអង្គទៅដាក់ឲ្យយក្សស៊ីតាមវេនដែរ។ ឧត្តមគតិរបស់អ្នកនិពន្ធ លោកចង់បានយុត្តិធម៌នៅក្នុងសង្គមពិតប្រាកដលើកន្លែងប្រកបដោយ

---

[៥៥] អេង សុតៈ ឯកសារមហាបុរសខ្មែរ ភ្នំពេញ ឆ្នាំ២០០០ ភាគ១-២ ទំព័រ ៥

គ្រោះថ្នាក់មិនត្រូវមានតែមុខកូនអ្នកក្រទេ ដែលត្រូវឲ្យយក្សស៊ី កូនស្តេច កូនមន្ត្រីក៏ត្រូវមានមុខដែរ។ រួមសេចក្តីមក យុត្តិធម៌ ជាសេចក្តីប្រាថ្នាចង់បានខ្ពស់បំផុតរបស់ប្រជារាស្ត្រខ្មែរគ្រប់រូប កាលណាសង្គមមានយុត្តិធម៌ នោះគេនឹងមានសេចក្តីសុខតាមផ្លូវកាយ និងចិត្តជាមិនខាន[៥៦]។

ដូច្នេះ អាចសន្និដ្ឋានបានថា ពលរដ្ឋខ្មែរកាលនោះ មានសេរីភាពច្រើនក្នុងការស្វែងរកយុត្តិធម៌ពីសំណាក់ចៅក្រមហូតដល់ព្រះរាជា។ ឯចៅក្រម ឬព្រះរាជា ក៏មិនមានគំនិតរើសអើង រារាំង យុបឃិត ស៊ីសំណូក គំរាមកំហែង បង្ខិតបង្ខំតាមការបញ្ជារបស់អ្នកមានអំណាច ឬអ្នកមានប្រាក់ឡើយ។ លើសពីនេះចៅក្រមសេនាបតី ក៏ដូចជាព្រះរាជាបានបើកផ្លូវឲ្យភាគីជម្លោះបន្តរកយុត្តិធម៌ តាមសេចក្តីពិតដោយពុំខ្លាចរអាអ្វីឡើយ។ រីឯស្ថាប័នរកយុត្តិធម៌ទាំងអស់មានការស៊ើបអង្កេត ពិសោធន៍ ជាក់ស្តែងចំពោះសំណុំរឿងបានល្អិតល្អន់ណាស់មុននឹងជំនុំជម្រះ ។ ធ្វើដូច្នេះក្នុងគោលបំណង ដើម្បីផ្តល់យុត្តិធម៌ទាំងសងខាង។ ក៏ប៉ុន្តែបច្ចុប្បន្ន ព្រះរាជាខ្មែរព្រះអង្គទ្រង់គ្រងរាជសម្បត្តិមិនកាន់អំណាចទេ ព្រះអង្គគ្រាន់តែជាព្រះប្រមុខឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី ព្រមទាំងជាអ្នកធានាសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ។ ឯអំណាចក្នុងការគ្រប់គ្រងដឹកនាំប្រទេសត្រូវបានបែងចែកអំណាចដាច់ចេញពីគ្នា គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ហើយអំណាចតុលាការនេះក៏ត្រូវបានបែងចែកទៅតាមតំបន់ ដូចជាសាលាដំបូងរាជធានី ខេត្ត តុលាការសាលាឧទ្ធរណ៍ តុលាការកំពូល និងតុលាការយោធា។ សិទ្ធិសេរីភាពក្នុងការរកយុត្តិធម៌ ថ្លែងអំពីលទ្ធភាពរបស់បុគ្គលម្នាក់ៗក្នុងការស្វែងរក និងទទួលបាននូវការឆ្លើយតបមួយប្រកបដោយប្រសិទ្ធិភាព និងយុត្តិធម៌ ដើម្បីដោះស្រាយវិវាទ ការពារសិទ្ធិ និងត្រួតពិនិត្យការរំលោភ អំណាចតាមរយៈយន្តការមួយប្រកបដោយតម្លាភាព គណនេយ្យភាព និងតម្លៃសមរម្យ។ យន្តការនេះត្រូវមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការសង្គម។ បច្ចុប្បន្នសិទ្ធិទទួលបានយុត្តិធម៌ ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងឧបករណ៍អន្តរជាតិនានាស្តីអំពីសិទ្ធិមនុស្ស។ គោលគំនិតដែលជាសិទ្ធិ ទទួលបានយុត្តិធម៌ គឺជាកត្តាមួយដ៏មានសារៈសំខាន់។ មានន័យថា ប្រជាពលរដ្ឋមានសិទ្ធិប្តឹងទាមទាររកយុត្តិធម៌។ ប្រជាពលរដ្ឋមិនគួរមានកាតព្វកិច្ចទៅសុំបម្រើយុត្តិធម៌ ដោយសារមានការបង់ប្រាក់ក្រោមតុឡើយ។ បន្ថែមលើនេះទៀត ដោយសិទ្ធិទាំងនេះត្រូវបានការពារជាអន្តរជាតិ ព្រោះថារដ្ឋមានកាតព្វកិច្ចជាអន្តរជាតិក្នុងការការពារ និងធានានូវសិទ្ធិទាំងនេះ។ ដូច្នេះ នៅពេលប្រជាពលរដ្ឋមិនអាចរកយុត្តិធម៌នៅក្នុងប្រទេសបាន ពួកគេអាចប្រើប្រាស់យន្តការអន្តរជាតិ ដើម្បីទាមទារនូវការធានា និងផ្តល់សិទ្ធិទាំងនេះ[៥៧]។

**២.៤.២.២.៥ សិទ្ធិសេរីភាពខាងប្រជាធិបតេយ្យ**

កាលណានិយាយដល់ប្រជាធិបតេយ្យ គឺសំដៅវត្តមានកាតព្វកិច្ចចាំបាច់របស់ប្រជាពលរដ្ឋចូលរួម

---

[៥៦] សមាគមអាដហុក សិទ្ធិមនុស្សតាមរយៈអក្សរសិល្ប៍ខ្មែរ ភ្នំពេញ ឆ្នាំ២០០២ ទំព័រ ៣០

[៥៧] ក្រសួងយុត្តិធម៌ និងUNDP: មាគ៌ាឆ្ពោះទៅរកយុត្តិធម៌ ភ្នំពេញ ឆ្នាំ២០០៥ ទំព័រ ២៥

កសាងសង្គមជាតិ ការពារជាតិ កំណត់ជោគវាសនាប្រទេសជាតិ ដោយមិនអាចខ្វះបានជាដាច់ខាត។ ឯក្នុងសង្គម ជាក់ស្តែងវិញក៏ឃើញមានប្រជាពលរដ្ឋប្រើប្រាស់លក្ខណៈប្រជាធិបតេយ្យ ទោះបីមិនទូទៅក៏មានតាមកាលវេលាដែរ ដោយគ្រាន់តែមិននិយាយដល់ ការបែងចែកអំណាចមានច្បាប់ត្រឹមត្រូវច្បាស់លាស់ឡើយ។ រូបភាព នៃការប្រកាន់យកសិទ្ធិប្រជាធិបតេយ្យ អាចសង្កេតឃើញមានលើកឡើង ក្នុងអក្សរសិល្ប៍ខ្មែរតាមរយៈរឿងធនញ្ជ័យ ទស្សនវិជ្ជាព្រះពុទ្ធសាសនា និងពាក្យកំណាព្យជាដើម ដូចជា អ្នកមានរក្សាខ្សត់ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅពឹងសំប៉ាន...។ កំណាព្យនេះក៏បានបង្ហាញពីលក្ខណៈប្រជាធិបតេយ្យដែរ គឺនៅត្រង់ថា អ្នកប្រាជ្ញ ទាំងអ្នកមិនប្រាជ្ញ ទាំងអ្នកមាន ទាំងអ្នកក្រ ត្រូវចេះរួបរួមសាមគ្គីគ្នា ពឹងពាក់អាស្រ័យនឹងគ្នា ការពារគ្នា សហការគ្នា ឲ្យតម្លៃគ្នា គោរពគ្នា ទៅវិញទៅមក។ មានន័យថា បើខ្វះអ្នកមានក៏មិនបានខ្វះអ្នកក្រក៏មិនបាន ខ្វះអ្នកប្រាជ្ញក៏មិនបានបោះបង់អ្នកមានបញ្ញាតិចក៏មិនបាន ពោលគឺទាំងអស់គ្នារួបរួមគ្នា គ្មានអ្នកណាម្នាក់នៅក្រៅសង្គមបានឡើយ។ នៅក្នុងច្បាប់រាជនេតិព្រះរាជាសម្ភារៈបានបញ្ជាក់ថា ខ្លែងហើរត្បិតខ្យល់ នាយច្រើនត្បិតពល រក្សាឲ្យសុខទ្រព្យគង់ត្បិតស្ត្រីចេះសំចៃទុក ផ្ទះធំស្រណុកត្បិតកិរិយា។ មានន័យថា ការចូលរួមកសាងសង្គម គ្រួសារក្តី សង្គមជាតិក្តី គឺទាមទារជាដាច់ខាតឲ្យមានការចូលរួមពីប្រជាពលរដ្ឋទាំងប្រុសស្រី ទើបអាចកសាងសង្គមជាតិឲ្យជឿនលឿននិងរឹងមាំ។

លក្ខណៈប្រជាធិបតេយ្យរបស់ប្រជាពលរដ្ឋខ្មែរតាមរយៈប្រតិបត្តិទស្សនវិទ្យាព្រះពុទ្ធសាសនាៈ នៅក្នុងព្រះពុទ្ធដិការទាំង៨៤០០០ព្រះធម្មក្ខន្ធ ពុំឃើញមានឃ្លា ឬព្រះពុទ្ធបញ្ញត្តិដោយមានការបង្ខិតបង្ខំអូសទាញឲ្យដើរតាមដោយខ្វះការពិចារណាឡើយ។ ព្រះធម៌ទាំងអស់ជាមេរៀន ប្រាប់ពីការពិតទៅតាមផ្លូវច្បាប់ធម្មជាតិ ពន្យល់ប្រាប់ពីទង្វើអាក្រក់ បង្ហាញផ្លូវខុស ផ្លូវត្រូវ ផ្លូវបុណ្យ ផ្លូវបាប ផ្លូវមានប្រយោជន៍ ផ្លូវខាតប្រយោជន៍ ទាំងបច្ចុប្បន្នទាំងអនាគត ហើយត្រូវចេះធ្វើពិសោធន៍ខ្លួនឯង ។ល។ បើពិសោធន៍ឃើញថា បានប្រយោជន៍សឹមធ្វើតាម តែបើឃើញថា ខាតប្រយោជន៍សូមបោះបង់ចោល។

ឥឡូវងាកមកពិនិត្យមើលការនិយមប្រជាធិបតេយ្យតាមរយៈអក្សរសិល្ប៍ខ្មែរវិញៈ នៅក្នុងរឿងនេះគេឃើញមានតួអង្គធនញ្ជ័យជាប្រជារាស្ត្រក្រីក្រម្នាក់ប៉ុណ្ណោះ អាចការពារប្រទេសជាតិខ្មែរ អាចគ្រប់គ្រងនគរជំនួសស្តេចយ៉ាងអង់អាចក្លាហាន ជាក់ស្តែងកិច្ចការនយោបាយសព្វសារពើ សឹងតែធ្លាក់មកក្នុងកណ្តាប់ដៃតួអង្គធនញ្ជ័យទាំងអស់។ ទឹកដីនគរទាំងមូលអាចរលាយ ឬគង់វង្សពឹងផ្អែកទាំងស្រុងលើធនញ្ជ័យ។ នេះបញ្ជាក់ថា មនុស្សសាមញ្ញក៏អាចកាន់កាប់នគរបានដែរ ឲ្យតែមានប្រាជ្ញាខ្ពង់ខ្ពស់[៥៨]។ មិនមែនជាស្តេចដែលអួតខ្លួនថាជាអ្នកតំណាងអាទិទេពនោះទេ។ មានន័យថា ក្នុងប្រទេសជាតិមួយត្រូវមានការចូលរួមពីប្រជាពលរដ្ឋសាមញ្ញគ្រប់មជ្ឈដ្ឋានគ្រប់ស្រទាប់ ពីអ្នកលូងហូតដល់អ្នកប្រាជ្ញ ពីអ្នកក្រហូតដល់មហាសេដ្ឋី ដើម្បីភាពខ្លាំងនៃប្រទេសមួយព្រោះប្រទេស គឺជាដែនដីរួមរបស់ប្រជារាស្ត្រទាំងអស់គ្នា មិនមែនរបស់អ្នកណាម្នាក់ដាច់មុខឡើយ។ វាសនាអនាគត

---

[៥៨] វ៉ាន់ឌី កាអុនៈ ចលនាអក្សរសិល្ប៍ខ្មែរ ទំព័រ ៦១

ប្រទេសជាតិ និងប្រជាជាតិ មិនមែនពឹងផ្អែកស្លាប់រស់ទៅលើអ្នកដឹកនាំម្នាក់នោះទេ ពោលគឺចាំបាច់មានការចូលរួមធ្វើពលិកម្មរបស់មហាជនទូទៅ ដូចមានសម្មតិកម្មក្នុងរឿងធនញ្ជ័យ ដែលតួអង្គធនញ្ជ័យជាជនសាមញ្ញម្នាក់ ក៏អាចចូលរួមតតាំងជាមួយអ្នកប្រាជ្ញបរទេស និងរហូតដល់ស្តេចបរទេស ដើម្បីការពារនគរទីបំផុតទទួលបានមហាជោគជ័យជូនជាតិមាតុភូមិដែរ ឲ្យតែបុគ្គលនោះមានប្រាជ្ញាភ្លឺថ្លា។

សរុបសេចក្តីមក សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរ ក្នុងចលនាប្រជាធិបតេយ្យក៏ឃើញមានអនុវត្តក្នុងអក្សរសិល្ប៍ខ្មែរខ្លះផងដែរ និងជាពិសេសក៏មានអនុវត្តជាក់ស្តែងក្នុងរបបគ្រប់គ្រងប្រទេសជាតិអស់ជាច្រើនឆ្នាំមកហើយគឺចាប់តាំងពីឆ្នាំ១៩៤៧មកម្ល៉េះ។ ប្រជាធិបតេយ្យ ជាទ្រឹស្តីដែលបានបង្ហាញពីយុត្តិធម៌បំផុត ជាលទ្ធិមួយដែលប្រជាពលរដ្ឋភាគច្រើនលើសកលលោកនិយមចូលចិត្ត ហើយធ្វើការតស៊ូពុះពារទាមទារអស់ជាច្រើនសម័យកាលមកហើយ ដោយហេតុថា ទ្រឹស្តីនេះបានបញ្ជាក់ពីសច្ចៈ យុត្តិធម៌ច្បាស់លាស់ថា ប្រទេសជាតិទាំងមូលពុំមែនជាកម្មសិទ្ធិផ្តាច់មុខរបស់អ្នកណាម្នាក់ ឬក្រុមណា ឬបក្សពួកណាមួយឡើយ ឯការអភិវឌ្ឍន៍ប្រទេសជាតិ ក៏ពុំមែនពឹងផ្អែកទាំងស្រុងទៅលើការសម្រេចចិត្តអ្នកដឹកនាំម្នាក់ឡើយ។ របបប្រជាធិបតេយ្យនេះមានលំនាំស្របតាមធម្មជាតិ គ្មានអ្នកជិះជាន់ គ្មានអ្នកត្រូវគេជិះជាន់ គ្មានខ្ញុំកញ្ជះដាច់ថ្លៃអ្នកណាឡើយ ពោលគឺរបបនយោបាយមួយដែលផ្តល់តម្លៃមនុស្សទៅតាមក្រិត្យក្រមធម្មជាតិ គឺមនុស្សមានសិទ្ធិសេរីភាពដូចគ្នា សមភាពដូចគ្នាទាំងអស់។

ពាក្យប្រជាធិបតេយ្យ ជាកន្សោមពាក្យដែលអាចប្រែមកថា ជាអំណាចប្រជាពលរដ្ឋដ៏កំពូល ជាអធិបតីមិនអាចផ្ទេរឲ្យទៅអ្នកណាម្នាក់បានឡើយ។ មានន័យថា របបមួយមានប្រជាពលរដ្ឋជាអ្នកគ្រប់គ្រងដឹកនាំដោយអំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋ ជាម្ចាស់ប្រទេស ប្រជាពលរដ្ឋ ជាអ្នកចូលរួមធ្វើសេចក្តីសម្រេចចិត្តកំណត់វាសនាប្រទេសជាតិ ជាអ្នកចូលរួមអភិវឌ្ឍជាតិ។

ប្រជាធិបតេយ្យ ជាភាវរស់នៃប្រទេសមួយដែលមានប្រជាជនធ្វើជាអធិបតី ជាប្រទេសមួយ ឬរដ្ឋមួយដែលមានប្រជាពលរដ្ឋធ្វើជាធំក្នុងការជ្រើសរើសក្បាលម៉ាស៊ីនដឹកនាំរបស់ខ្លួន ឲ្យមកសម្រេចរាល់កិច្ចការសព្វសារពើ ដែលបម្រើផលប្រយោជន៍សាធារណៈទាំងខាងសម្ភារៈ ស្មារតី និងអាយុជីវិត។ ជាទម្រង់គ្រប់គ្រងរដ្ឋមួយរបស់ប្រជាពលរដ្ឋ ជាសេរីភាពនយោបាយ និងស៊ីវិលរបស់ប្រជាពលរដ្ឋក្នុងសង្គមមួយ... ជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ... ជាស្ថាប័ននីយកម្មនៃសេរីភាពជាគំនិត និងគោលការណ៍ស្តីអំពីសេរីភាពទាំងអស់ ជាប្រព័ន្ធគ្រប់គ្រងមួយ ដែលក្នុងនោះប្រជាពលរដ្ឋទាំងអស់របស់ប្រទេសមួយអាចបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនជារដ្ឋាភិបាលរបស់ខ្លួន ជារដ្ឋាភិបាលដែលប្រជាពលរដ្ឋទាំងអស់បានអនុវត្តសិទ្ធិអំណាច ជាការពិគ្រោះបែបពហុភាពនិយម ការបោះឆ្នោត តម្លាភាព ការផ្សព្វផ្សាយព័ត៌មាន ការគោរពច្បាប់ និងការកំហិតអំណាចរដ្ឋ[៥៩]។

សង្គមប្រជាធិបតេយ្យ គឺសង្គមរបស់ប្រជាជន ដែលស្ថិតនៅក្រោមអធិបតេយ្យរបស់ប្រជាជន គឺជា

[៥៩] Auge, Cuillon, Hollier-larousse, Moreean et e[e],PetitCarouse, Dictionneaire ,imprimeries larousse en France Paris 6[eme],1967,p.310

សង្គមដែលមានរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ ច្បាប់ ក្រិត្យក្រម និងនីតិក្រមកំណត់បញ្ជាក់យ៉ាងច្បាស់លាស់អំពីមុខងារ ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋាភិបាល ដែលគ្រាន់តែជាអង្គធាតុមួយក្នុងចំណោមអង្គធាតុដទៃទៀត ដូចជា អង្គការគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល សមាគម ផលប្រយោជន៍ផ្សេងៗទៀតជាច្រើនមាន(សមាគម សាសនា សមាគមកសិករ សមាគមគ្រូបង្រៀន សមាគមយុវជន សហជីពសេរីកម្មករ...) សង្គមប្រជាធិបតេយ្យ ជាសង្គមមួយដែលសម្តែងអំពីការរីកចម្រើនដោយបង្ហាញអំពីទិសដៅ និងឆន្ទៈប្រជាធិបតេយ្យ ដូចជា ការប្រជុំ ការបោះឆ្នោត ជ្រើសរើស តាមគោលការណ៍មតិភាគច្រើន បណ្តាញផ្សព្វផ្សាយ ការវិនិច្ឆ័យ ការស្ទាបស្ទង់មតិ...។ សំណុំអង្គធាតុក្នុងសង្គមដូច្នេះគេហៅថា ពហុភាពនិយម។

## សារៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យ

១-អធិបតេយ្យភាពរបស់ប្រជាជន។
២-រដ្ឋាភិបាលឈរលើការព្រមព្រៀងពីសំណាក់ជនដែលខ្លួនអភិបាលគ្រប់គ្រង។
៣-ការគ្រប់គ្រងដោយមតិភាគច្រើន។
៤-គោរពសិទ្ធិជនភាគតិច។
៥-ធានាសិទ្ធិមនុស្សជាមូលដ្ឋាន។
៦-ការបោះឆ្នោតដោយ សេរី ត្រឹមត្រូវ និងទៀងទាត់។
៧-ស្មើភាពគ្នាចំពោះមុខច្បាប់។
៨-ដំណើរការរៀបចំកាត់ក្តីដ៏សមស្របតាមច្បាប់។
៩-ការកម្រិតរដ្ឋធម្មនុញ្ញលើអំណាចរដ្ឋបាល។
១០-ពហុភាពសង្គម សេដ្ឋកិច្ច និងនយោបាយ។
១១-តម្លៃនៃការចេះអត់ឱនគ្នា ការណ៍និយមសហប្រតិបត្តិការ និងសម្រុះសម្រួលគ្នា។
១២-ប្រជាពលរដ្ឋទូទៅទទួលបានផលប្រយោជន៍ ហើយប្រទេសជាតិក៏មានការរីកចម្រើន។
១៣-ប្រជាពលរដ្ឋអាចជ្រើសរើស និងផ្លាស់ប្តូរអ្នកដឹកនាំតាមឆន្ទៈរបស់ខ្លួនដោយសន្តិវិធី។
១៤-មានសន្តិភាព សន្តិសុខ ស្ថេរភាពពិតប្រាកដ។
១៥-ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពទូលំទូលាយ។
១៦-ជំរុញឲ្យមានអភិបាលកិច្ចល្អ មានតម្លាភាព និងអាចទប់ស្កាត់អំពើពុករលួយ[៦០]។

## គោលការណ៍សំខាន់ៗនៃលទ្ធិប្រជាធិបតេយ្យ

**១-គោរពសិទ្ធិមនុស្ស:** សិទ្ធិជាប្រភពអំណាច ហើយអំណាចជារបស់ប្រជាពលរដ្ឋ ដែលជាភាពរឹងមាំនៃសិទ្ធិប្រជាធិបតេយ្យ។ ប្រទេសប្រជាធិបតេយ្យ ត្រូវមានច្បាប់ ដើម្បីធានាការពារសិទ្ធិប្រជាពលរដ្ឋ ហើយរដ្ឋាភិបាល

[៦០] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គោលការណ៍ប្រជាធិបតេយ្យ ពលរដ្ឋវិទ្យា និងសិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៣ ទំព័រ ៨

ត្រូវទទួលខុសត្រូវ គោរពសិទ្ធិប្រជាពលរដ្ឋ ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

**២-ការចូលរួមពីប្រជាពលរដ្ឋ:** ប្រជាពលរដ្ឋនៅក្នុងប្រទេសប្រជាធិបតេយ្យមិនត្រឹមតែបំពេញកាតព្វកិច្ចរបស់ខ្លួន ជាប្រជាពលរដ្ឋប៉ុណ្ណោះទេ សំខាន់ទៅទៀតប្រជាពលរដ្ឋត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សហគមន៍ ឬរបស់ជាតិ រួមទាំងការតាក់តែងច្បាប់ តាមការបញ្ចេញមតិយោបល់ តាមរយៈតំណាងរាស្ត្រ ឬតាមរយៈសមាគម សហជីពជាដើម។ ប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យអាចប្រមូលផ្តុំគ្នាជាសមាគម សហជីព ជាអង្គការនានាក្នុងសង្គមស៊ីវិល ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋក្នុងសហគមន៍របស់ខ្លួន។ នៅក្នុងប្រទេសណាដែលប្រជាពលរដ្ឋធ្វើមិនដឹង មិនលឺ បណ្តោយឲ្យអ្នកដឹកនាំធ្វើអ្វីតាមអំពើចិត្ត ប្រទេសជាតិនោះមិនអាចរីកចម្រើនបានទេ បណ្តាលឲ្យជីវភាពប្រជាពលរដ្ឋស្ថិតនៅក្នុងភាពក្រីក្រទៀតផង។ ការចូលរួមសហការពីប្រជាពលរដ្ឋ គឺជាការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋខ្លួនឯងគិតគូរ និងប្រាប់ទៅរដ្ឋាភិបាលថា ត្រូវធ្វើអ្វីខ្លះដើម្បីបានផលប្រយោជន៍ទៅប្រជាពលរដ្ឋ និងធ្វើអ្វីខ្លះដែលប៉ះពាល់ផលប្រយោជន៍ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋអាចចូលរួមពេញលេញ ក្នុងការរួមប្រជុំបង្កើតសមាគម ដើម្បីផលប្រយោជន៍សហគមន៍ខ្លួន។

**៣-ប្រព័ន្ធនយោបាយពហុបក្ស:** គណបក្សនយោបាយ គឺជាក្រុមរបស់ប្រជាពលរដ្ឋក្នុងប្រទេសមួយដែលមានគំនិតនយោបាយដូចគ្នា ឬប្រហាក់ប្រហែលគ្នាក្នុងការគិតគូររៀបចំ និងគ្រប់គ្រងប្រទេសទៅតាមកម្មវិធី ឬបន្ទាត់នយោបាយដែលក្រុមពលរដ្ឋក្នុងគណបក្សនោះសម្រេចថានឹងយកមកអនុវត្តនៅពេលដែលគណបក្សខ្លួនឈ្នះឆ្នោតដឹកនាំរដ្ឋាភិបាល។ ដូច្នេះ ដើម្បីបើកឱកាសឲ្យក្រុមពលរដ្ឋដែលមានគោលនយោ-បាយផ្សេងគ្នាមានសេរីភាពក្នុងការលើកយកគំនិត ឬគោលនយោបាយរបស់ខ្លួនមកដាក់ជូនប្រជាពលរដ្ឋទូទៅដើម្បីសម្រេចគាំទ្រឬមិនគាំទ្រនោះ ក្នុងប្រទេសប្រជាធិបតេយ្យគេត្រូវអនុញ្ញាតឲ្យមានគណបក្សលើសពីមួយ ឬច្រើន គឺដើម្បីឲ្យប្រជាពលរដ្ឋមានជម្រើសមិនផ្តាច់មុខ ដែលជាកត្តាសំខាន់បំផុតឲ្យមេដឹកនាំនយោបាយ ឬគណបក្សនយោបាយទាំងឡាយខិតខំសម្រិតសម្រាំងខ្លួនឲ្យបានល្អប្រសើរទាំងគុណធម៌ សីលធម៌ ចក្ខុវិស័យ និងដើម្បីប្រឡងប្រជែងគ្នាបង្ហាញស្នាដៃក្នុងការបម្រើប្រជាពលរដ្ឋ និងបម្រើប្រទេសជាតិ។ ផ្ទុយទៅវិញ បើគ្រាន់តែបើកឲ្យមានគណបក្សច្រើន ហើយដាក់ស្តែងអំណាចស្ថិតនៅលើតែបក្សតែមួយដដែលក៏មិនពិតថា ជាប្រទេសប្រជាធិបតេយ្យដែរ។ គណបក្សនីមួយៗក៏ត្រូវមានប្រជាធិបតេយ្យផ្ទៃក្នុងបក្សខ្លួនជាចាំបាច់ផងដែរ ពោលគឺគណបក្សជារបស់សមាជិកគណបក្សទាំងអស់គ្នា មិនមែនជារបស់ប្រធានគណបក្សតែម្នាក់ឯងឡើយ។

បើឆ្លុះបញ្ចាំងពីសង្គមខ្មែរវិញ ឃើញថា ប្រជាពលរដ្ឋខ្មែរបានឆ្លងកាត់របបប្រជាធិបតេយ្យចាប់តាំងពីឆ្នាំ១៩៤៧មកទល់ឆ្នាំ១៩៧៥ និងចាប់ផ្តើមជាថ្មីនៅឆ្នាំ ១៩៩៣ រហូតមកដល់បច្ចុប្បន្ននេះ។ ក្នុងរយៈកាលជាង១៧ឆ្នាំ(១៩៩៣-២០១០) ប្រជាពលរដ្ឋខ្មែរបានអនុវត្តសិទ្ធិសេរីភាពតាមរយៈការចូលរួមការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្ររបស់ខ្លួន ដោយផ្ទាល់បានចំនួនបួនលើករួចមកហើយ ដោយមិនរាប់ពីការចូលរួមបោះឆ្នោតដោយផ្ទាល់ជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួនពីរលើកផងទេ។ ដែលការបោះឆ្នោតលើកទី៤ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោតបានចូលរួមបោះឆ្នោតជ្រើសរើសតំណាង

រាស្ត្រដោយផ្ទាល់។ ជាលទ្ធផលមានគណបក្សចំនួន ៥ ដែលត្រូវបានប្រជាពលរដ្ឋផ្តល់សេចក្តីទុកចិត្តសម្រាប់បម្រើប្រជាពលរដ្ឋ ក្នុងចំណោមគណបក្សចំនួន១១។ ដែលក្នុងនោះគណបក្សប្រជាជនកម្ពុជា ទទួលបានចំនួន៩០អាសនៈ គណបក្សសមរង្ស៊ី ទទួលបានការគាំទ្រចំនួន២៦អាសនៈ គណបក្សសិទ្ធិមនុស្ស ទទួលបានការគាំទ្រចំនួន៣អាសនៈ គណបក្សនរោត្តមរាណឫទ្ធិទទួលបានការគាំទ្រចំនួន២អាសនៈ និងគណបក្សហ៊្វុន-ស៊ិនប៉ិច ទទួលបានការគាំទ្រចំនួន ២អាសនៈ។

សេចក្តីសន្និដ្ឋាន ទស្សនៈទូទៅរបស់អរិយបុគ្គល ក៏ដូចជាអ្នកប្រាជ្ញនានាទាំងឡាយ ដែលបានពន្យល់ប្រាប់ដោយលើកតម្កើងតម្លៃសិទ្ធិសេរីភាព សិទ្ធិស្មើគ្នា គោរពច្បាប់ តុល្យភាព សមភាព សីលធម៌ យុត្តិធម៌ អធិបតេយ្យ អំណាច សេរីភាពទូទៅរបស់មនុស្សជាតិ ដោយភ្ជាប់ទៅនឹងការបែងចែកអំណាចរដ្ឋ ការកាត់បន្ថយអំណាចរដ្ឋក្នុងគោលការណ៍ប្រជាធិបតេយ្យ គឺក្នុងគោលបំណងបើកសិទ្ធិសេរីភាពឲ្យប្រជាពលរដ្ឋគ្រប់ស្រទាប់ចូលរួមគ្រប់គ្រងសង្គមជាតិ ដែលអាចធានានូវស្ថេរភាព និងសន្តិភាពនីយកម្ម ស្របតាមសិទ្ធិសេរីភាពតាមច្បាប់ធម្មជាតិ។ ហើយទស្សនៈទាំងឡាយនេះ ត្រូវបានប្រទេសភាគច្រើនលើសលប់លើសកលលោកយកមកអនុវត្ត ដោយអ្នកដឹកនាំនៃប្រទេសទាំងនោះ ធ្វើការកែលំអខ្លះៗ ធ្វើយ៉ាងណាឲ្យសមស្របតាមទីតាំងភូមិសាស្ត្រ ស្រប តាមប្រពៃណីទំនៀមទម្លាប់ វប្បធម៌ និងអរិយធម៌ ព្រលឹងជាតិ និងតាមស្ថានភាពជាក់ស្តែងរបស់គេ ក្នុងគោលបំណងធ្វើយ៉ាងណាឲ្យបរិយាកាសនយោបាយស្ងប់ស្ងាត់ និងអភិវឌ្ឍប្រទេសរបស់គេ។

បើនិយាយពីប្រទេសកម្ពុជាវិញ អាចកំណត់អត្តសញ្ញាណកម្មថា សិទ្ធិសេរីភាពប្រជាពលរដ្ឋខ្មែរមានចាប់តាំងពីយូរយារណាស់មកហើយ បើទោះបីមិនទូលំទូលាយ ក៏ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាពខ្លះៗដែរ។ ក្នុងសង្គមជាក់ស្តែងក៏ដូចជា នៅក្នុងអក្សរសិល្ប៍ ដែលជាកញ្ចក់ឆ្លុះបញ្ចាំងពីតថភាពរបស់សង្គមជាក់ស្តែង ក៏បានបង្ហាញផងដែរអំពីការទាមទារសិទ្ធិសេរីភាពក្នុងភាពជាមនុស្សជាតិ ជាពិសេសនៅក្នុងប្រវត្តិសាស្ត្រខ្មែរក៏ឃើញមានការចូលរួមពីប្រជាពលរដ្ឋក្នុងការតស៊ូ ដើម្បីប្រទេសជាតិ ព្រលឹងជាតិ រើបម្រាស់ចេញពីការគាបសង្កត់កេងប្រវ័ញ្ច ពីសំណាក់អ្នកដឹកនាំផ្តាច់ការចក្រពត្តិក្នុងស្រុក ក៏ដូចជាពីរបបអាណានិគមជាដើម។ ដូច្នេះ សម្រាប់ទស្សនៈលើកឡើងពីការជំរុញឲ្យប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិសេរីភាពរបស់ខ្លួនទៅតាមបរិបទប្រជាធិបតេយ្យ គឺពិតជាមិនលំបាកអ្វីឡើយ។

# ជំពូកទី៣

# ស្ថានភាពទូទៅនៃសិទ្ធិពលរដ្ឋ

# ក្នុងព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី៣

# ស្ថានភាពទូទៅនៃសិទ្ធិពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា

## ៣.១. សិទ្ធិសេរីភាពខាងសង្គម

### ៣.១.១ សិទ្ធិដើម្បីរស់រានមានជីវិត

នៅក្នុងនិយមន័យរបស់ប្រជាធិបតេយ្យសម័យទំនើបទាំងអស់ ការគ្រប់គ្រងដោយមតិភាគច្រើនមិនមែនមានន័យថា ជាប្រជាធិបតេយ្យទេ។ ជាការពិតណាស់ដែលថា ក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋអាចធ្វើសេចក្តីសម្រេចចិត្តនយោបាយដោយសេរី ដោយឈរលើមតិភាគច្រើន តែមិនមានន័យថា ជារឿងមួយត្រឹមត្រូវនិងយុត្តិធម៌បានឡើយ ប្រសិនបើគេបណ្តោយឲ្យមនុស្សភាគច្រើនគាបសង្កត់មនុស្សភាគតិចនោះ។

ទាក់ទងទៅនឹងការរស់រានមានជីវិតរបស់បុគ្គល គឺមិនមានជនណាម្នាក់ត្រូវទទួលរងការធ្វើទារុណកម្ម ឬផ្តន្ទាទោសដោយឃោរឃៅអមនុស្សធម៌ ឬទទួលរងនូវការបន្ទាបបន្ថោកណាមួយឲ្យបាត់បង់សេចក្តីថ្លៃថ្នូរជាមនុស្ស ឡើយ គ្មានជនណាម្នាក់ត្រូវគេបង្ខាំងទុក បង្ខំឲ្យធ្វើការដោយគ្មានពេលឈប់សម្រាកឡើយ។

នៅក្នុងសង្គមប្រជាធិបតេយ្យសម័យទំនើប សិទ្ធិរបស់ជនភាគតិចត្រូវបានការពារ ពីព្រោះច្បាប់និងស្ថាប័នប្រជាធិបតេយមាននាទីការពារសិទ្ធិរបស់ពលរដ្ឋគ្រប់រូប។

សិទ្ធិរបស់មនុស្សភាគតិចមិនអាចបំបាត់ចោលតាមរយៈការបោះឆ្នោតមតិភាគច្រើនបានឡើយ។ នៅក្នុងសង្គមប្រជាធិបតេយ្យរដ្ឋធម្មនុញ្ញកំណត់ព្រំដែនអំណាចរដ្ឋាភិបាល និងការពារសិទ្ធិជាមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ ទម្រង់នៃរដ្ឋាភិបាលបែបនេះឲ្យឈ្មោះថា ប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ។ នៅក្នុងសង្គមប្រជាធិបតេយ្យ សម័យទំនើប ក៏គេនៅរក្សាគោលការណ៍ស្តីពីសិទ្ធិធម្មជាតិនេះដែរ គ្រាន់តែគេធ្វើការបញ្ជាក់បំពេញបន្ថែមនូវសិទ្ធិ មិនអាចកាត់ផ្តាច់បានមួយចំនួនរួមមាន សេរីភាពខាងជំនឿសាសនា សេរីភាពក្នុងការប្រជុំ សេរីភាពទទួលបានការការពារស្មើគ្នានៅចំពោះមុខច្បាប់ មានសិទ្ធិទទួលបានការកាត់ក្តីដោយត្រឹមត្រូវយុត្តិធម៌ សិទ្ធិរស់រានមានជីវិត...។ល។ រដ្ឋាភិបាលប្រជាធិបតេយ្យត្រូវតែជានាចំពោះចំណុចសំខាន់ៗនៃសិទ្ធិសេរីភាពរបស់មនុស្សគ្រប់ៗគ្នាទាំងអស់នេះ គេមិនអាចអនុម័តច្បាប់លុបសិទ្ធិទាំងនេះចោលបានទេ សិទ្ធិសេរីភាពទាំងនេះមិនអាចត្រូវមតិភាគច្រើនលុបចោល ឬបំបាច់ចោលតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។ ពីព្រោះសិទ្ធិសេរីភាពទាំងនេះកើតឡើងដោយឯករាជ្យដាច់ចេញពីរដ្ឋាភិបាល។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិមានអ្វីៗ ដែលចាំបាច់សម្រាប់ការរស់រានមានជីវិតប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស។ សិទ្ធិសេរីភាពទាំងនេះមានតាំងពីកំណើតមក គ្មានបុគ្គលណាបង្កើតសិទ្ធិឲ្យប្រជាពលរដ្ឋទេ ហើយគ្មានបុគ្គលណាអាចដកហូតសិទ្ធិសេរីភាពស្រេចតែចិត្តបានឡើយ ព្រោះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់ និងធានានូវការគោរពសិទ្ធិនានារបស់មនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា សន្ធិសញ្ញា

ទាំងឡាយ ដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងកុមារជាដើម។

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិភាពផ្ទាល់ខ្លួន។ ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ[៦១]។

បុគ្គលគ្រប់រូបមានសិទ្ធិរស់រានមានជីវិតជាប់តាំងតែពីកំណើតមកម្លេះ ច្បាប់ត្រូវការពារសិទ្ធិនេះជាចាំបាច់។ គ្មានបុគ្គលណាម្នាក់ត្រូវគេប្រហារជីវិតតាមអំពើចិត្តបានឡើយ។

ការកាត់ទោសប្រហារជីវិត មិនត្រូវយកទៅអនុវត្តចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តដោយមនុស្សដែលមានអាយុក្រោម១៨ឆ្នាំឡើយ ហើយក៏មិនត្រូវយកទៅអនុវត្តចំពោះស្ត្រីដែលមានផ្ទៃពោះដែរ។

គ្មានបុគ្គលណាម្នាក់ត្រូវបានទទួលរងនូវប្រព្រឹត្តិកម្ម ឬផ្តន្ទាទោសដោយឃោរឃៅ អមនុស្សធម៌ ឬយ៉ាងថោកទាបឡើយ។ ជាពិសេសគ្មានបុគ្គលណាម្នាក់ត្រូវយកទៅពិសោធន៍ពីជីវសាស្ត្រឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាម៉ីខ្លួនឡើយ[៦២]។ គ្មានបុគ្គលណាម្នាក់ត្រូវគេចាប់ចង ឃុំឃាំងជាទាសភាពឡើយ។ ទាសភាព និងការជួញដូរទាសករគ្រប់បែបយ៉ាងទាំងអស់ត្រូវហាមឃាត់ដាច់ខាត។

មនុស្សគ្រប់រូបត្រូវតែបានទទួលការការពារជីវិត និងមិនត្រូវឲ្យគេសម្លាប់ឡើយ។ ដើម្បីបំពេញលក្ខខណ្ឌនេះ រដ្ឋត្រូវធានាចរាចរឲ្យមានសណ្តាប់ធ្នាប់ មានសន្តិសុខ បញ្ចៀសសង្គ្រាម រំដោះមីនឱសថមានអាហារមិនហួសពេលកំណត់ និងគ្មានជាតិពុល មានស្ពាន ថ្នល់ ទំនប់ ប្រឡាយទឹក...។

សិទ្ធិដើម្បីគុណភាព ចំណី មានជីវិតរស់នៅដោយសេរី និងសិទ្ធិប្រកបដោយសេចក្តីសុខសាន្ត គឺជាសិទ្ធិរបស់យើងទាំងអស់គ្នា[៦៣]។ រដ្ឋាភិបាល ឬរដ្ឋក្នុងរបបប្រជាធិបតេយ្យ ត្រូវមានភារកិច្ចការពារជីវិតមនុស្សទាំងអស់នៅក្នុងប្រទេស។ ត្រូវបង្ការ កុំឲ្យមានការលួចសម្លាប់ ឬការប្រហារជីវិតខុសច្បាប់។ រដ្ឋត្រូវបង្ការផងដែរ កុំឲ្យមានការសម្លាប់រង្គាលដូចជាអំពើប្រល័យពូជសាសន៍ជាដើម។ ការប្រហារមនុស្សតាមទំនើងចិត្តនៅប្រទេសកម្ពុជា នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការសម្លាប់រង្គាល។ ភាពហិនហោចបែបនេះរដ្ឋាភិបាលនោះត្រូវតែទទួលខុសត្រូវ។ រីឯការបាត់បង់ជីវិតមនុស្សរាប់រយពាន់នាក់ដោយសារទឹកជំនន់ ឬរញ្ជួយដី ដែលជាមហន្តរាយធម្មជាតិ មិនមែនជាការទទួលខុសត្រូវពេញទីរបស់រដ្ឋាភិបាលទេ។ ក្នុងករណីនេះ សហគមន៍អន្តរជាតិត្រូវនាំគ្នាជួយសង្គ្រោះ។ ធម្មតាមនុស្សគ្រប់រូប តែងតែចង់បានសេចក្តីសុខ ចង់រស់នៅប្រកបដោយសុភមង្គល សេចក្តីថ្លៃថ្នូរជារៀងរហូត។ មនុស្សម្នាក់ៗគឺស្រឡាញ់ជីវិតរបស់ខ្លួនណាស់ ដោយមិនចង់ទទួលនូវការធ្វើទុក្ខទោស បង្កសេចក្តីអន្តរាយចំពោះខ្លួនប្រាណរបស់បុគ្គលម្នាក់ៗទោះតាមផ្លូវកាយក្តី ផ្លូវចិត្តក្តី និងតាមផ្លូវចិត្តវេគក្តី(រំជួលចិត្ត)។

ឯកសារដ៏ពិស្តារមួយដែលបញ្ជាក់យ៉ាងច្បាស់លាស់ អំពីការទទួលខុសត្រូវរបស់រដ្ឋាភិបាល ក្នុងបញ្ហា

[៦១] មាត្រា៣២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
[៦២] មាត្រា៣២ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦
[៦៣] អង្គការវីជីលែនៈ អង្គការរក្សាការពារសិទ្ធិមនុស្សនៃកម្ពុជា ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ៥

សម្លាប់រង្គាលនោះ គឺអនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ អង្គការសហ-ប្រជាជាតិ កំពុងតែព្យាយាមធ្វើយ៉ាងណា ដើម្បីកុំឲ្យមានការសម្លាប់មនុស្សតទៅទៀត ដោយខិតខំណែនាំប្រទេសនានាឲ្យលុបបំបាត់ចោលច្បាប់ទាំងឡាយ ដែលកាត់ទោសប្រហារជីវិតមនុស្ស។ ទោះបីក្នុងលក្ខណៈស្របតាមច្បាប់រដ្ឋ ឬមិនស្របក៏ដោយ គឺជាការរំលោភលើបញ្ញត្តិថា មនុស្សមានសិទ្ធិដើម្បីមានជីវិតរស់នៅ។

អង្គការអាដហុកបានកំណត់ ការសម្លាប់ក្រៅច្បាប់ថា ជាអំពើហិង្សាទៅលើសិទ្ធិរស់រានមានជីវិត ដែលត្រូវបានធានាដោយមាត្រា៣២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់ព្រះរាជាណាចក្រកម្ពុជាបានចែងថា "ពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។ ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ" [៦៤]។ ការសម្លាប់ក្រៅច្បាប់នៅតែកើតមាននៅប្រទេសកម្ពុជា ដោយមិនអនុវត្តច្បាប់។

ការសម្លាប់ក្រៅច្បាប់ទាំងឡាយមានជាប់ពាក់ព័ន្ធនឹងមនោគមន៍វិជ្ជានយោបាយផងដែរ។ យោងតាមការកត់សម្គាល់របស់អាដហុក ឃើញថា ការសម្លាប់ក្រៅច្បាប់ គឺប្រព្រឹត្តដោយមហាជន និងប្រព្រឹត្តដោយសមត្ថកិច្ចរដ្ឋាភិបាលនៅតែកើតមាន។

**អំពើឃាតកម្មដោយសមត្ថកិច្ចរដ្ឋ:** អំពើឃាតកម្មដោយសមត្ថកិច្ចរដ្ឋ លើប្រជាពលរដ្ឋទន់ខ្សោយមួយចំនួនដែលយើងសង្កេតឃើញគឺថា បើទោះបីពុំមានលក្ខណៈជាប្រព័ន្ធដោយផ្លូវការមែនពិត ក៏ប៉ុន្តែសកម្មភាពនៃអំពើឃាតកម្ម និងសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធដែលពុំបានយកចិត្តទុកដាក់ផ្តន្ទាទោសជនប្រព្រឹត្តឡើយ នៅពេលខ្លះថែមទាំងជួយការពារបិទបាំងនូវទង្វើរបស់ជនប្រព្រឹត្តនោះទៀតផង។ នេះគឺជាការលើកទឹកចិត្តដោយប្រយោលឲ្យជនប្រព្រឹត្តធ្វើសកម្មភាពទាំងនេះជាបន្តទៅទៀត។ តាមរបាយការណ៍របស់អាដហុក នៅក្នុងឆ្នាំ២០០៨ កន្លងទៅនេះបានចង្អុលបង្ហាញពីអំពើឃាតកម្មដោយសមត្ថកិច្ចរដ្ឋចំនួន៤០ករណី ដែលមានការពាក់ព័ន្ធទៅនឹងកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីស៊ីវិលរបស់រដ្ឋាភិបាលមួយចំនួន។ ហើយក្នុង ៤០ករណីនេះមាន៤០%(១៦ករណី) ត្រូវបានបង្កឡើងដោយសមត្ថកិច្ចប៉ូលីស។ ទន្ទឹមនឹងមានការព្រួយបារម្ភអំពីករណីឃាតកម្ម ដែលបង្កឡើយដោយសមត្ថកិច្ច ប៉ូលីស និងរាជអាវុធហត្ថ យើងឃើញមានការកើនឡើងនូវករណីឃាតកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយយោធាមានចំនួនដល់ទៅ ៣៧,៥%(១៥ករណី) ដែលចំនួននេះមានការកើនឡើង២០,៥%លើសពីឆ្នាំ២០០៧។ ករណីដែលកើតឡើងនៅពេលដែលភាគីជនរងគ្រោះ និងជនប្រព្រឹត្តមានទំនាស់គ្នា តែអ្វីដែលជាការព្រួយបារម្ភនោះគឺ នៅពេលដែលមានទំនាស់ពាក្យសម្តីបន្តិចបន្តួចជនប្រព្រឹត្តបានប្រើឥទ្ធិពលរបស់ខ្លួន ដោយគ្មានការខ្លាចរអែងច្បាប់បន្តិចឡើយ។ សមាគមអាដហុកសង្កេតឃើញថា មានករណីខ្លះនៅក្រោយពេលកើតហេតុ ជនប្រព្រឹត្តរកមធ្យោបាយធ្វើយ៉ាងណាគេចឲ្យផុតពីកន្លែងកើតហេតុ ហើយនឹងរកការអន្តរាគមន៍ពីថ្នាក់ដឹកនាំរបស់គេ ដើម្បីធ្វើការដោះស្រាយ។ ករណីរបៀបនេះភាគច្រើនថ្នាក់ដឹកនាំរបស់ជនប្រព្រឹត្ត បានធ្វើការសម្រុះសម្រួលជាមួយគ្រួសារជនរងគ្រោះឲ្យទទួលយកសំណង

[៦៤] ADHOC: Human Rights Report ភ្នំពេញ ឆ្នាំ២០០១ ទំព័រ ១៤

ជាប្រាក់បន្តិចបន្តួចជាថ្នូរនឹងការដកពាក្យបណ្ដឹង ព្រោះថាថ្នាក់ដឹកនាំរបស់ភាគីជនប្រព្រឹត្តភាគច្រើនជាអ្នកដែលមានអំណាច និងមានឥទ្ធិពលច្រើនជាងអាជ្ញាធរ ដែលមានសមត្ថកិច្ចដោះស្រាយករណីដែលកើតឡើង។

ក្រៅពីអំពើឃាតកម្មកើតឡើងដោយកម្លាំងប្រដាប់អាវុធ ឃើញថាមានមន្ត្រីរាជការស៊ីវិលមួយចំនួនក៏ជាជនប្រព្រឹត្តផងដែរ។ ជាក់ស្ដែងនៅក្នុងឆ្នាំ២០០៨ មានអំពើឃាតកម្មចំនួន២២,៥%(៩ករណី) ត្រូវបានប្រព្រឹត្តឡើងដោយមន្ត្រីស៊ីវិលមួយចំនួនរបស់រដ្ឋាភិបាល ដែលក្នុងនោះមានមន្ត្រីក្រុមប្រឹក្សាឃុំ/សង្កាត់ មេភូមិ និងមេក្រុមជាដើម។ ករណីប្រភេទនេះកើតឡើងដោយសារតែភាគីទាំងពីរមានទំនាស់គ្នាជាលក្ខណៈបុគ្គល ក៏ប៉ុន្តែទោះជាយ៉ាងណាក្ដីជនប្រព្រឹត្តទាំងនេះ ជាអ្នកដែលមានតួនាទីនិងកិច្ចការរដ្ឋ គឺជាការបង្ហាញឲ្យឃើញថា អ្នកមានតួនាទីជាសមត្ថកិច្ចរបស់រដ្ឋអាចនឹងប្រព្រឹត្តអំពើហិង្សាបានងាយព្រមទាំងអាចគេចផុតពីការផ្ដន្ទាទោសជាងប្រជាជនធម្មតា កត្តានេះអាចឲ្យយើងឃើញថា វាស្ទើរតែក្លាយទៅជាប្រព័ន្ធទៅហើយ ក្នុងករណីអំពើឃាតកម្ម ដោយសមត្ថកិច្ចរដ្ឋនៅក្នុងឆ្នាំកន្លងមកនេះ។

យោងតាមទិន្នន័យខាងលើនេះបង្ហាញឲ្យឃើញថា ការរំលោភបំពានទៅលើសិទ្ធិរស់រានមានជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជានៅតែជាបញ្ហាមួយដែលគួរឲ្យព្រួយបារម្ភនៅឡើយ ដោយហេតុថាករណីទាំងនេះត្រូវបានកើតឡើង ដោយកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលមួយចំនួនបានប្រើប្រាស់អំណាចរដ្ឋដែលខ្លួនមានដោយពុំខ្លាចរអែងឡើយ ដូចជាជនប្រព្រឹត្តបានប្រើអំពើហិង្សាទៅលើជនរងគ្រោះនៅពេលដែលគេជួបនឹងព្រឹត្តិការណ៍ទំនាស់គ្នាជាបុគ្គល ឬនៅពេលដែលពួកគេធ្វើកិច្ចការសាធារណៈជាដើម។ រាល់អំពើដែលបានកើតឡើង គឺនៅពេលដែលជនរងគ្រោះពុំបានប្រើអំពើហិង្សាតបតទៅនឹងជនប្រព្រឹត្ត ហើយក៏ពុំមានលទ្ធភាពបន្តិចសោះ សម្រាប់ធ្វើការតបតឬការពារខ្លួនដោយខ្លួនឯង។ ម្យ៉ាងវិញទៀតការបណ្តែតបណ្តោយមិនព្រមចាត់វិធានការតាមផ្លូវច្បាប់ទៅលើជនដែលបានប្រព្រឹត្ត ជាហេតុផលចម្បងមួយធ្វើឲ្យអំពើឃាតកម្មបៀបនេះនៅតែបន្តកើតមានឡើងផងដែរ។

ឥរិយាបថបែបនេះបញ្ជាក់ឲ្យឃើញថា ទម្រង់គ្រប់គ្រងរដ្ឋដែលរដ្ឋាភិបាលមានអំណាចខ្លាំងជាងស្ថាប័នដទៃទៀត គឺបណ្តាលឲ្យមន្ត្រីរាជការស៊ីវិលមានអំណាចមួយចំនួន ក៏ដូចជាសមត្ថកិច្ចមួយចំនួនមានអំណាចលើសលប់ក្នុងមុខតំណែង ឬអាងបក្សពួក អាងខ្សែស្រឡាយតែងមិនគោរពច្បាប់រដ្ឋ មិនយកតួនាទីរបស់ខ្លួនបម្រើប្រជាពលរដ្ឋតាមខ្លឹមសារប្រជាធិបតេយ្យទេ ដោយហេតុថា ច្បាប់ពុំអាចចាប់ជនប្រព្រឹត្តទៅកាត់ទោសបានឡើយ។ ស្ថានភាពបច្ចុប្បន្ននេះ បានប្រព្រឹត្តផ្ទុយពីកិច្ចការដឹកនាំរដ្ឋតាមរបបប្រជាធិបតេយ្យ ពីព្រោះក្នុងបរិបទប្រជាធិបតេយ្យ ប្រជាពលរដ្ឋជាម្ចាស់អំណាច ឯមន្ត្រីរាជការគ្រប់ស្ថាប័នមាននាទីជាអ្នកបម្រើប្រជាពលរដ្ឋតាមបទដ្ឋានគតិយុត្ត។

**អំពើឃាតកម្មដោយហ្វូងមហាជនៈ** របបគ្រប់គ្រងប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជា បានលុបចោលទោសប្រហារជីវិត និងបានទទួលស្គាល់កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកំណត់ថា បុគ្គលគ្រប់រូបមានសិទ្ធិពេញលេញ ដើម្បីមានជីវិតរស់នៅ។ ច្បាប់ត្រូវការពារសិទ្ធិនេះជាចាំបាច់ដោយ

គ្មានអ្នកណាអាចដកសិទ្ធិនេះពីបុគ្គលម្នាក់ទៀតតាមអំពើចិត្តបានឡើយ។ ប៉ុន្តែទោះបីជាមានច្បាប់យ៉ាងណាក៏ដោយក្នុងទិដ្ឋភាពជាក់ស្តែងនៃអំពើឃាតកម្មជាច្រើនករណីកន្លងមកក្នុងនោះ ក៏មានករណីឃាតកម្មកើតឡើងដោយហ្វូងមហាជនផងដែរ។ ការកាត់ទោសប្រហារជីវិតដោយហ្វូងប្រជាពលរដ្ឋ គឺដោយសារតែមានការមិនសប្បាយចិត្តនឹងប្រព័ន្ធតុលាការ ក៏ដូចជាការបាត់បង់ជំនឿលើសមត្ថកិច្ចក្នុងការបង្ក្រាប និងទប់ស្កាត់នូវអំពើចោរកម្មដែលបានកើតឡើងនាពេលកន្លងមកនោះ។ ជាក់ស្តែងមានជនសង្ស័យក្នុងអំពើចោរកម្មចំនួន ៤នាក់ត្រូវបានប្រជាពលរដ្ឋវាយសម្លាប់ និងមាន២ករណីផ្សេងទៀតជនរងគ្រោះ ត្រូវបានសមត្ថកិច្ចអន្តរាគមន៍ទាន់ពេលវេលា[៦៥]។ ជាទូទៅយើងសង្កេតឃើញថា ឃាតកម្មបានកើតមានឡើងដោយហ្វូងមហាជនទាំងនេះមានចំនួនថយចុះជាច្រើន បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦(១៧ករណីស្លាប់ និង៤ករណីត្រូវបានអន្តរាគមន៍ទាន់ពេលវេលា)។ តែទោះជាមានការថយចុះចំនួនករណីក៏ដោយ យើងសង្កេតឃើញថា សមត្ថកិច្ចនៅពុំទាន់បានអនុវត្តច្បាប់ឲ្យបានហ្មត់ចត់ក្នុងការទប់ស្កាត់អំពើទាំងនោះទេ ដូចជា នៅពេលមានហេតុកើតឡើង អាជ្ញាធរពុំបានចាត់វិធានការទៅតាមផ្លូវច្បាប់ណាមួយ ដល់អ្នកដែលបានបង្កឲ្យមានអំពើឃាតកម្មទាំងនេះទេ។ ផ្ទុយទៅវិញ អាជ្ញាធរមួយចំនួនបានធ្វើប្រជាភិថុតនៅក្នុងករណីឃាតកម្មដោយហ្វូងមហាជនទាំងនោះទៅវិញ ដោយគេគិតថា ធ្វើឲ្យប្រជាពលរដ្ឋមិនសប្បាយចិត្ត ប្រសិនបើគេទប់ស្កាត់ ឬក៏ដាក់ពិន័យទៅលើជនណា ដែលបានប្រព្រឹត្តអំពើឃាតកម្មដោយមហាជននេះ ហើយថែមទាំងធ្វើការចោទប្រកាន់ដល់អង្គការសង្គមស៊ីវិលថា ជាអ្នកការពារចោរទៅវិញ នៅពេលដែលក្រុមអង្គការសង្គមស៊ីវិលជំរុញឲ្យអាជ្ញាធរអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ។ តាមទ្រង់ទ្រាយនេះបញ្ជាក់ឲ្យឃើញថា ប្រជាពលរដ្ឋខ្មែរទាមទារជាចាំបាច់ ដោយធ្វើការផ្សព្វផ្សាយឲ្យគេបានយល់ពីច្បាប់ និងភារកិច្ចរដ្ឋាភិបាល ដើម្បីកាត់បន្ថយរហូតដល់អស់នូវការចូលរួមសម្លាប់ពីប្រជាពលរដ្ឋ កាលណាចំនួនចេះតែកើនឡើងនោះអាចប្រឈមនឹងចលាចលពុំខាន។

ដើម្បីចូលរួមចំណែកលុបបំបាត់ស្ថានភាពបែបនេះ តំណាងអង្គការសហប្រជាជាតិបានជំរុញឲ្យរដ្ឋាភិបាល កម្ពុជាធានាថា ករណីសម្លាប់ដោយហ្វូងមហាជននីមួយៗត្រូវតែធ្វើការអង្កេតដោយហ្មត់ចត់ ហើយករណីនីមួយៗនៃការមិនចាត់វិធានការរបស់នគរបាល ត្រូវតែពិនិត្យពិច័យឲ្យបានច្បាស់លាស់ចំពោះ ការចោទប្រកាន់ពីបទវិន័យនិងព្រហ្មទណ្ឌចំពោះបុគ្គលណា ដែលមានភស្តុតាងថា មានការធ្វេសប្រហែស ឬការប្រព្រឹត្តមិនត្រឹមត្រូវកើតឡើង[៦៦]។

**អំពើឃាតកម្មលើសកម្មជនគណបក្សនយោបាយៈ** នៅព្រះរាជាណាចក្រកម្ពុជា រូបភាពនៃការរើសអើងខាងនយោបាយ ដែលឈានដល់ការសម្លាប់គ្នាដោយសារមនោគមន៍វិជ្ជានយោបាយគណបក្សផ្សេងគ្នា។ ការសម្លាប់ផ្នែកនយោបាយច្រើនកើតមានឡើងនៅក្នុងពេលមានព្រឹត្តិការណ៍បោះឆ្នោតម្តងៗ អំពើឃាតកម្មលើ

---

[៦៥] សមាគមអាដហុកៈ ស្ថានភាពសិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៧ ផ្សាយខែមករា ឆ្នាំ២០០៨ ទំព័រ ១៦

[៦៦] អង្គការសហប្រជាជាតិៈ គណៈកម្មការសិទ្ធិមនុស្ស សម័យប្រជុំលើកទី៥៧ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ខែកក្កដា ឆ្នាំ២០០២ ទំព័រ ១៥-១៦

សកម្មជនគណបក្សតែងកើតឡើងពុំដែលខានឡើយ។ តាមរបាយការណ៍អាដហុកបានបង្ហាញថា នៅក្នុងឆ្នាំ ២០០៨ ដែលជាឆ្នាំមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ នេះក៏ឃើញមានអំពើហិង្សាបានកើតឡើងលើសកម្មជនគណបក្សនយោបាយ បណ្តាលឲ្យមានការបាត់បង់ជីវិតមនុស្សចំនួន៦នាក់ផងដែរ។ អំពើឃាតកម្មប្រភេទនេះច្រើនកើតឡើងទាក់ទងទៅនឹងស្ថានការណ៍ព្រឹត្តិការណ៍បោះឆ្នោត ដូចជានៅក្នុងឆ្នាំ ២០០៨។ អំពើឃាតកម្មបែបនេះកើតឡើងនៅក្នុងអំឡុងខែមករា ហើយបញ្ចប់ទៅវិញនៅក្នុងខែកក្កដា ក្រោយថ្ងៃបោះឆ្នោត។ ឯអំពើនេះបានកើតឡើងជាពិសេសទៅលើសកម្មជនគណបក្សប្រឆាំង[៦៧]។ យោងតាមរបាយការណ៍ស៊ើបអង្កេតរបស់សមាគមអាដហុកឆ្នាំ២០០៨ ករណីឃាតកម្មលើសកម្មជនគណបក្សនយោបាយមានការថយចុះពី ៩ករណី មកត្រឹម ៦ករណី។ តាមទិន្នន័យនៃផលប៉ះពាល់ខាងស្មារតីវិញនោះ ករណីឃាតកម្មដែលចេះតែកើតឡើងជាបន្តបន្ទាប់នោះ បានធ្វើឲ្យមានការភ័យខ្លាចរបស់អ្នកគាំទ្រ និងសកម្មជនរបស់គណបក្សនយោបាយដែលតែងតែទទួលរងនូវអំពើឃាតកម្មកាន់តែមានភាពខ្លាំងឡើងជាលំដាប់។ ជាក់ស្តែងនៅក្នុងឆ្នាំ២០០៨ បើទោះបីជាអំពើឃាតកម្មលើសកម្មជនគណបក្សនយោបាយមានចំនួនតិចជាងឆ្នាំ១៩៩៨ និង២០០៣ ក៏ពិតមែន តែភាពភ័យខ្លាចរបស់អ្នកគាំទ្រ និងសកម្មជនរបស់គណបក្សមិនកាន់អំណាចមានភាពធ្ងន់ធ្ងរជាងមុន ដូចជានៅក្នុងឆ្នាំ២០០៨ បើទោះបីមានស្ថានភាពមិនប្រក្រតីធ្ងន់ធ្ងរ និងជាចំហពិតមែន ក៏ប៉ុន្តែមានប្រជាពលរដ្ឋអ្នកគាំទ្រតិចតួចណាស់ដែលហ៊ានប្តឹងតវ៉ា ហើយសុំមិនបញ្ចេញឈ្មោះទៀតផង។

**អំពើឃាតកម្មលើសកម្មជនសិទ្ធិមនុស្ស:** បុគ្គលគ្រប់រូបដែលបានធ្វើសកម្មភាពក្នុងការលើកស្ទួយ និងការពារដល់សិទ្ធិជាមូលដ្ឋានរបស់មនុស្សក្នុងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ បើទោះបីសកម្មភាពទាំងនោះកើតឡើងដោយម្នាក់ៗជាក្រុមក៏ដោយ ក៏បុគ្គលទាំងនេះត្រូវបានចាត់ទុកជាអ្នកការពារសិទ្ធិមនុស្ស[៦៨]។ បុគ្គលទាំងនោះមានសិទ្ធិគ្រប់គ្រាន់នៅក្នុងការចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាល សមាគម ឬក្រុមផ្សេងៗ។ ជាពិសេសទៅទៀតនោះអ្នកការពារសិទ្ធិមនុស្សមានសិទ្ធិសេរីភាពក្នុងការយល់ដឹងស្វែងរកទទួលយក និងការរក្សាទុកនូវព័ត៌មានស្តីអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ហើយនិងមានសិទ្ធិក្នុងការបោះពុម្ព ឬផ្សព្វផ្សាយដោយសេរីទៅកាន់អ្នកដទៃ[៦៩]។ យោងតាមអត្ថន័យនៃសេចក្តីប្រកាសនេះ មានប្រជាពលរដ្ឋតំណាងសហជីពកម្មករ តំណាងសហគមន៍ និងសកម្មជនសិទ្ធិមនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលបានធ្វើសកម្មភាពយ៉ាងសកម្មក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា។ ឆ្លងតាមការធ្វើសកម្មភាពខាងលើនេះ បានបញ្ជាក់ឲ្យអ្នកការពារសិទ្ធិមនុស្សមួយចំនួនត្រូវជួបប្រទះនឹងបញ្ហាអសន្តិសុខផ្ទាល់ខ្លួន រហូតដល់បាត់បង់ជីវិតទៀតផង។ ជាក់ស្តែងនៅក្នុងឆ្នាំ២០០៧កន្លងទៅនេះ មានអ្នកការពារសិទ្ធិមនុស្សចំនួន២នាក់ ត្រូវបានធ្វើឃាតដោយជនមិន

[៦៧] សមាគមអាដហុក: ស្ថានភាពសិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៨ ផ្សាយខែមករា ឆ្នាំ២០០៩ ទំព័រ ១១

[៦៨] មាត្រា១ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីអ្នកការពារសិទ្ធិមនុស្ស

[៦៩] មាត្រា៦ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីអ្នកការពារសិទ្ធិមនុស្ស

ស្គាល់មុខដែលករណីឃាតកម្មមកលើអ្នកការពារសិទ្ធិមនុស្សបែបនេះ ពុំដែលកើតឡើងទេក្នុងឆ្នាំ២០០៦។ ប្រការនេះបង្ហាញឲ្យឃើញថា គ្រោះថ្នាក់និងភាពប្រថុយប្រថានរបស់អ្នកការពារសិទ្ធិមនុស្ស ក្នុងការធ្វើសកម្មភាពការពារ និងលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា មានសភាពកាន់តែធ្ងន់ធ្ងរជាងមុន។ អ្នកការពារដល់ផលប្រយោជន៍ ឬសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលទាក់ទិនទៅនឹងសិទ្ធិមានដីធ្លី ហើយពួកគេក៏ធ្លាប់បានការពារព្រៃឈើ និងឡូត៍នេសាទ ដើម្បីទុកជាប្រយោជន៍សាធារណៈ បើទោះជាសកម្មភាពទាំងនេះបានជួយដល់ការងាររដ្ឋាភិបាលក្តី ក៏មន្ត្រីរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានភាគច្រើនបានចោទប្រកាន់ដល់អ្នកការពារសិទ្ធិមនុស្សទាំងនោះថា ជាមនុស្សញុះញង់ទៅវិញ[៧០]។

ការសម្លាប់ផ្តាច់ផ្តិលជីវិតគ្រប់រូបភាព បើទោះបីក្នុងទំនាស់នយោបាយក្តីគេឃើញថា រដ្ឋាភិបាលពុំសូវបានចាត់វិធានការ ចាប់ខ្លួនជនប្រព្រឹត្តមកផ្តន្ទាទោសតាមច្បាប់ឡើយ ដែលឆន្ទៈនយោបាយនេះបានស្តែងទៅជាព្រឹត្តិការណ៍បរិយាកាសនិទណ្ឌភាព។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានចែងថា ប្រវត្តិសាស្ត្រសោកនាដកម្មនៃប្រទេសកម្ពុជា ទាមទារឲ្យមានការចាត់វិធានការពិសេស ដើម្បីធានាការពារសិទ្ធិមនុស្ស និងការមិនវិលត្រឡប់មកវិញ នៃគោលនយោបាយ និងការអនុវត្តន៍ពីអតីតកាល។ របាយការណ៍មួយរបស់លោកតំណាងពិសេសមានចំណងជើងថា លំនាំនៃបញ្ហានិទណ្ឌភាពដែលកំពុងកើតមានឡើងជាបន្តនៅក្នុងប្រទេសកម្ពុជា ក្នុងខែតុលា ឆ្នាំ២០០៥ បានបង្ហាញថា ចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ភាគច្រើនលើសលប់នៃឃាតកម្មច្រើនកើតឡើងចំពោះអ្នកនយោបាយ អ្នកកាសែត សហជីព កម្មករ និងប្រជាពលរដ្ឋកម្ពុជាដទៃទៀត ដែលសកម្មនៅក្នុងជីវភាពនយោបាយ ដោយនៅតែមិនទាន់ត្រូវបានរកមុខឃាតករឃើញនៅឡើយ ដែលក្នុងនោះរួមមានករណីសម្លាប់ លោក ជា វិជ្ជា ប្រធានសហជីពកម្មករនៅកណ្តាលរាជធានីភ្នំពេញក្នុងខែមករា ឆ្នាំ២០០៤ ក៏ពុំទាន់រកឃាតករឃើញនៅឡើយ[៧១]។ ករណីនិទណ្ឌភាពទាំងនេះមានន័យថា ប្រជាពលរដ្ឋកម្ពុជាមិនត្រូវបានការពារដោយច្បាប់ទេ។ និទណ្ឌភាព កើតមាននៅពេលដែលបុគ្គលទាំងឡាយដែលបំពានច្បាប់ និងប្រព្រឹត្តរំលោភសិទ្ធិមនុស្សត្រូវបានរួចផុតពីការផ្តន្ទាទោសណាមួយ ហើយមិនត្រូវបាននាំខ្លួនឲ្យទទួលខុសត្រូវតាមនីតិវិធីណាមួយ ទោះជាតាមនីតិវិធីព្រហ្មទណ្ឌ រដ្ឋប្បវេណី រដ្ឋបាល ឬខាងវិន័យ ឬដាក់ឲ្យទទួលទោសទណ្ឌណាមួយ ហើយគ្មានការជួសជុលសំណងដល់ជនរងគ្រោះនោះទេ។ និទណ្ឌភាព គឺជាការផ្ទុយនឹងការទទួលខុសត្រូវ និងប្រតិនិក្ខេបទនៃនីតិរដ្ឋ។

ករណីនេះ លោកតំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅប្រទេសកម្ពុជា ក៏បានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងទៅលើបញ្ហានិទណ្ឌភាពនៅប្រទេសកម្ពុជា។ បុគ្គលប្រើប្រាស់អំណាចរដ្ឋជាពិសេសមន្ត្រីប្រតិបត្តិច្បាប់និងសមាជិកកងកម្លាំងប្រដាប់អាវុធ ត្រូវបានចាប់ខ្លួនឲ្យទទួលខុសត្រូវតិចតួច

---

[៧០] សមាគមអាដហុកៈ ស្ថានភាពសិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៧ ផ្សាយខែមករា ឆ្នាំ២០០៨ ទំព័រ ១៥

[៧១] http://Cambodia.ohchr.org/download.aspx?ep_id=242

ណាស់ចំពោះឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្ត[៧២]។ លោកបានរាយការណ៍ជូនសម័យប្រជុំលើកទី៦១នៃគណៈ-កម្មការសិទ្ធិមនុស្សថា បញ្ហានិទណ្ឌភាពគឺជាបុព្វហេតុនិងលទ្ធផលដ៏ចម្បងដែលបង្កឲ្យមានបញ្ហាសិទ្ធិមនុស្សជាច្រើននៅកម្ពុជា។

សិទ្ធិមានជីវិតរស់នៅដែលបានចែងក្នុងកឋាខណ្ឌទី១ មាត្រា៦នៃកតិកាសញ្ញានេះត្រូវបានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាកំណត់ថា "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិតមានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន"។

ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ ប្រការនេះបញ្ជាក់ឲ្យឃើញថា ព្រះរាជាណាចក្រកម្ពុជាចាត់ ទុកសិទ្ធិមានជីវិតរស់នៅ គឺជាសិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូប។ "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត..." សំដៅលើជនគ្រប់រូប មិនមែនចំពោះតែប្រជាពលរដ្ឋខ្មែរម្ចាស់ប្រទេសនោះទេ ជនណារស់នៅលើទឹកដីនៃ ព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិរស់រានមានជីវិតដូចគ្នាទាំងអស់។ ទោះបីមាន ច្បាប់ការពារនិងធានាសិទ្ធិមាន ជីវិតរស់នៅគ្រប់គ្រាន់ក៏ដោយ ក៏ការសម្លាប់ក្រៅច្បាប់នៅតែមានកើតឡើងដដែលដូចជា ការគំរាមកំហែង ការតាមសម្លាប់ វាយប្រហារ ជាពិសេសបញ្ហាឃាតកម្មលើសកម្មជននយោបាយ និងសកម្មជនការពារ សិទ្ធិមនុស្សជាដើម មិនទាន់ស្រាកស្រាន្តនៅឡើយនៅព្រះរាជាណាចក្រកម្ពុជាដូចជាៈ

កាលពីខែកុម្ភៈ ឆ្នាំ២០០៣ មានការបាញ់សម្លាប់ឥស្សរជននយោបាយ លោក ឱន វ៉ាដ្ឋសាឱី នៅរាជធានីភ្នំពេញ និងបាញ់សម្លាប់ព្រះសង្ឃព្រះនាម សម ប៊ុនជឿន នៅក្នុងវត្តល័ង្ការ ស្ថិតក្នុងរាជធានីភ្នំពេញ។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៣ លោក ជួរ ដេតថារិទ្ធិ ជាអ្នកយកព័ត៌មានឲ្យវិទ្យុតាព្រហ្មត្រូវបានបាញ់សម្លាប់។

នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣ កញ្ញាទូច ស៊ុននិច ត្រូវបានបាញ់ប្រហារនៅតាមដងផ្លូវស្ទើរស្លាប់ស្ទើររស់។

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៣ លោក ឈឹម ដារា ក្រឡាបញ្ជីតុលាការសាលាឧទ្ធរណ៍ត្រូវបានបាញ់សម្លាប់។

នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ លោក សុក សេដ្ឋាមុន្នី ចៅក្រមតុលាការក្រុងភ្នំពេញត្រូវបានបាញ់សម្លាប់។

នៅដើមខែមេសា ឆ្នាំ២០០៣ លោក ង៉ែត សារ៉ាត់ ព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញត្រូវបានគេបាញ់ប្រហារ និងដើមខែឧសភានៅការិយាល័យរបស់លោក ហង្ស រ៉ូរ៉ាកេន ជាព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ត្រូវបានបាញ់ប្រហារ។

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៤ លោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករ ត្រូវបានបាញ់សម្លាប់។

នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៤ លោក រស់ សុណ្ណរិទ្ធ អាយុ៣៥ឆ្នាំ ជាសមាជិកគណៈកម្មការអចិន្ត្រៃយ៍

---

[៧២] អង្គការសហប្រជាជាតិៈ គណៈកម្មការសិទ្ធិមនុស្ស សម័យប្រជុំលើកទី៥៩ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០២ ទំព័រ ១

នៃសហព័ន្ធសហជីពសេរីកម្មករ ហើយជាប្រធានសហជីពនៃរោងចក្រ Tranugal Komara Garment ត្រូវបាន គេបាញ់សម្លាប់ពេលធ្វើដំណើរពីរោងចក្រទៅផ្លូវកែងត្រង់កម្ពុជាក្រោម និងសហព័ន្ធរុស្សីនៅរាជធានីភ្នំពេញ។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៧ លោក ហ៊ី វុទ្ធី ប្រធានសហជីពសេរីកម្មករនៅរោងចក្រសាន់តិចគូវបានបាញ់សម្លាប់។

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ លោក ឃឹម សម្បូរណ៍ ជាអ្នកសរសេរព័ត៌មានឲ្យកាសែតមនសិការខ្មែរ និងកូនប្រុសខាត់ សារិន្ទកាតា អាយុ២១ឆ្នាំ ត្រូវបានបាញ់សម្លាប់។ ក្រៅពីនេះនៅមានករណីសម្លាប់ ដោយប្រការដទៃទៀតជាច្រើន ដូចជាការសម្លាប់ដោយសារទំនាស់ដីធ្លីជាដើម។ ប៉ុន្តែទោះជាយ៉ាងណាក្តី រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការស៊ើបអង្កេតយ៉ាងយកចិត្តទុកដាក់ខ្ពស់បំផុត ចំពោះបញ្ហាឃាតកម្មទាំងអស់ ដែលបានកើតមានឡើងកន្លងមក តែក្រោយមកការស៊ើបអង្កេតឃើញថា លទ្ធផលទទួលបាន គឺជាមានកម្រិតតិចតួចណាស់ ដោយជនប្រព្រឹត្តមានតួនាទីជាកងកម្លាំងប្រដាប់អាវុធមានឋានៈខ្ពស់ ដោយមិនញញើតចំពោះការប្រើអំពើព្រៃផ្សៃយង់ឃ្នងឡើយ ដើម្បីរារាំងការស៊ើបអង្កេត ឯបច្ចេកទេសក្នុងការរុករកព័ត៌មាននៅមានកម្រិតទាបពេកក្នុងការងារផងដែរ។

## ៣.១.២ សិទ្ធិមានសេរីភាពស្មើគ្នាចំពោះមុខច្បាប់

មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការនិងអង្គជំនុំជម្រះក្តី។ មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពស្នើសុំឲ្យតុលាការកាត់សេចក្តីឲ្យបានសមរម្យ ជាសាធារណៈ ដោយមិនលំអៀង និងមានឯករាជ្យភាព។

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជំនុំជម្រះក្តី។ មនុស្សគ្រប់រូបមានសេរីភាពស្នើសុំឲ្យតុលាការមានសមត្ថកិច្ច ដែលបង្កើតតាមលក្ខណៈច្បាប់ កាត់សេចក្តីរបស់ខ្លួនដោយត្រឹមត្រូវយុត្តិធម៌ ឯករាជ្យពេញលេញ មិនលំអៀងទៅខាងណា និងជាសាធារណៈ ដើម្បីរកឲ្យឃើញចំពោះការចោទពីបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណី។ ក្រុមអ្នកយកព័ត៌មាន និងសាធារណៈជន អាចត្រូវហាមឃាត់មិនឲ្យចូលរួមស្តាប់ការកាត់សេចក្តី ប្រសិនបើគេយល់ឃើញថា អាចមានទំនាស់ដល់សីលធម៌ ទំនៀមទម្លាប់ល្អរបៀបរៀបរយសាធារណៈជន ឬសន្តិសុខជាតិ នៅក្នុងសង្គមប្រជាធិបតេយ្យ ឬក៏ថាប្រសិនបើគូភាគីពុំមានឆន្ទៈចង់ឲ្យដឹងឮដល់សាធារណៈជន ឬក្នុងស្ថានការណ៍ដែលតុលាការយល់ឃើញថា ការកាត់ទោសនៅចំពោះមុខសាធារណៈជននាំឲ្យប៉ះពាល់ដល់គោលជំហរសីលធម៌[៧៣]។ ដោយឡែកក្រោយពីជំនុំជម្រះរួចសព្វគ្រប់ ហើយលទ្ធផលរបស់តុលាការត្រូវផ្សាយជាសាធារណៈ វៀរលែងតែករណីសាលក្រមទាក់ទងនឹងអនីតិជន ឬវិនិច្ឆ័យទោសពីជម្លោះ អាពាហ៍ពិពាហ៍ មិនអាចផ្សាយជាសាធារណៈឡើយ។

ជនជាប់ទោសពីបទឧក្រិដ្ឋត្រូវចាត់ទុកថាជាជនគ្មានកំហុស ដរាបណាគ្មានភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថា ជននោះជាប់ជាពិរុទ្ធជន។

---

[៧៣] មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលកិច្ចការពារច្បាប់ស្មើៗគ្នា ដោយឥតប្រកាន់ ពូជសាសន៍ ឬពណ៌សម្បុរឡើយ។ ក្នុងករណីនេះ ច្បាប់ត្រូវហាមមិនឲ្យមានការរើសអើង ហើយ ច្បាប់ត្រូវធានាជូនបុគ្គលគ្រប់រូបនូវបញ្ញត្តិការពារយ៉ាងស័ក្តិសិទ្ធិ កុំឲ្យមានការប្រកាន់ទៅលើពូជសាសន៍ ពណ៌- សម្បុរ ភេទ សាសនា ភាសា ជំហរនយោបាយ មតិនានា កំណើតជាតិ ឬសង្គម ឋានៈ វណ្ណៈ ឬអ្វីៗ ផ្សេងទៀតឡើយ[៧៤]។

មនុស្សគ្រប់ៗគ្នាត្រូវគោរពច្បាប់ដូចគ្នា មិនថា អ្នកនោះជានាម៉ឺន មន្ត្រី ឬប្រជារាស្ត្រឡើយ។ ច្បាប់មិនត្រូវគ្រប់គ្រងមនុស្សខុសពីគ្នាទេ ទោះបីអ្នកនោះ សឬខ្មៅ ក្រឬមាន ជារាស្ត្រ ឬជានាម៉ឺនក៏ដោយ[៧៥]។ ច្បាប់ គឺជាឆន្ទៈរួមគ្នារបស់មនុស្សនៅក្នុងសង្គម ឬនៅក្នុងប្រទេស។ មនុស្សនាំគ្នាបង្កើតច្បាប់ ដើម្បីការពារផលប្រយោជន៍មនុស្សរួមគ្នា។ កាលណាសង្គមមនុស្សមានការប្រែប្រួលរបៀបរស់នៅ គេនាំគ្នាកែសម្រួលច្បាប់ឲ្យស្របទៅតាមការប្រែប្រួលនោះដែរ។ ហើយដើម្បីរក្សាឲ្យមានលំនឹងនៅក្នុងសង្គម ច្បាប់ត្រូវការពារផលប្រយោជន៍មនុស្សឲ្យបានគ្រប់ៗគ្នានិងឲ្យបានស្មើគ្នាផងដែរ។ ហើយដើម្បីរក្សាឲ្យមានលំនឹងនៅក្នុងសង្គម ច្បាប់ត្រូវការពារផល-ប្រយោជន៍មនុស្សឲ្យបានគ្រប់ៗគ្នា និងឲ្យបានស្មើៗគ្នាផងដែរ។ អ្នកណាក៏ដោយឲ្យតែធ្វើខុសត្រូវទទួលទោសតាមច្បាប់ មិនថានាម៉ឺន ឬរាស្ត្រឡើយ។

ក្នុងពេលដែលសម្រេចសេចក្តីវិនិច្ឆ័យយកទោសពីបទឧក្រិដ្ឋ ជនជាប់ចោទគ្រប់ៗរូបមានសិទ្ធិសេរីភាពស្មើៗគ្នាក្នុងការទទួលបានកិច្ចសន្យាធានាការពារមួយចំនួនដូចតទៅ:

១-ត្រូវទទួលបានការប្រាប់ឲ្យដឹងខ្លួនភ្លាមៗ ដោយសេចក្តីលំអិតស្តីពីហេតុផងនៃការផ្តន្ទាទោសមកលើខ្លួនតាមភាសា ដែលជននោះអាចស្តាប់បានគ្រប់គ្រាន់។

២-សាមីជនត្រូវមានពេលវេលានិងឧបករណ៍សម្ភារៈគ្រប់គ្រាន់ ដើម្បីការពារនិងមានសិទ្ធិពេញលេញក្នុងការរកមេធាវីដែលជននោះពេញចិត្តដោយសេរី។

៣-ការជំនុំជម្រះកាត់សេចក្តីត្រូវតែធ្វើភ្លាមៗ ដោយឥតពន្យាពេលយូរឡើយ។

៤-ការជំនុំជម្រះកាត់ទោសត្រូវធ្វើនៅចំពោះមុខសាមីខ្លួន ហើយសាមីជនមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬអាចរកជំនួយពីស្មារតីដោយខ្លួនឯង ប្រសិនបើសាមីជនមានលទ្ធភាពគ្រប់គ្រាន់។ ក្នុងករណីដែលពុំមានលទ្ធភាពចាំបាច់តុលាការត្រូវតែងតាំងមេធាវីឲ្យតំណាងជនជាប់ចោទ ដោយឥតគិតកម្រៃ។

៥-បើកសិទ្ធិសេរីភាពឲ្យមានការសាកសួរដេញដោលលើសាក្សីចុងចម្លើយនិងសាក្សីដើមចម្លើយ ដោយស្មើភាពគ្នាក្នុងលក្ខខណ្ឌច្បាប់។

៦-សាមីជនអាចតម្រូវឲ្យមានអ្នកបកប្រែភាសា ដែលខ្លួនចេះមិនគ្រប់គ្រាន់ក្នុងសវនាការដោយមិនចាំបាច់បង់ប្រាក់ឡើយ។

[៧៤] មាត្រា២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[៧៥] អង្គការវីជីឡេន អង្គការរក្សាការពារសិទ្ធិមនុស្សនៃកម្ពុជា ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ៩

៧-មិនអនុញ្ញាតបង្ខិតបង្ខំឲ្យទទួលសារភាពនូវកំហុសដែលមិនត្រឹមត្រូវ។ នីតិវិធីកាត់សេចក្តី ចំពោះសាមីជនដែលមិនទាន់មាននីតិភាព ត្រូវយោងទៅលើអាយុ និងត្រូវយកវិធីអប់រំ កសាងខ្លួនជាការប្រសើរជាង។

ករណីមានជនណាម្នាក់ដែលគេបានសម្រេចផ្តន្ទាទោសឲ្យជាប់ទោសឧក្រិដ្ឋរួចរាល់ហើយ តែក្រោយមកស្រាប់តែត្រូវគេលើកលែងទោសវិញ ដោយហេតុថាមានភស្តុតាងថ្មីដែលបញ្ជាក់ឲ្យឃើញថា ការផ្តន្ទាទោសនោះពុំមានយុត្តិធម៌ទេ ជនរងគ្រោះនោះមានសិទ្ធិប្តឹងទាមទារជម្ងឺចិត្តតាមលក្ខណៈច្បាប់។

គ្មានជនណាម្នាក់ត្រូវគេដាក់ទោសជាថ្មីឡើយ ចំពោះបទល្មើសដែលសាមីជនបានទទួលទណ្ឌកម្មរួចហើយ ឬសាមីជនបានទទួលការលើកលែងទោសរួចហើយនោះ[៧៦]។

មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាដូចគ្នាចំពោះមុខច្បាប់ ហើយក៏មានសិទ្ធិសេរីភាពទទួលបានកិច្ចការពារអំពីច្បាប់ស្មើគ្នាដោយឥតប្រកាន់ពូជសាសន៍ ឬពណ៌សម្បុរឡើយ។ ក្នុងករណីនេះ ច្បាប់ហាមដាច់ខាតមិនឲ្យមានការរើសអើង ដោយធ្វើយ៉ាងណាច្បាប់ត្រូវតែធានាជូនបុគ្គលគ្រប់រូបនូវការការពារយ៉ាងស័ក្តិសិទ្ធិកុំឲ្យមានការប្រកាន់រើសអើងពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត[៧៧]។

**ក-សមភាពចំពោះមុខតុលាការ**

សមភាពចំពោះមុខតុលាការ ជាមូលដ្ឋានគ្រឹះយុត្តិធម៌ក្នុងរបបសង្គមប្រកាន់នយោបាយប្រជាធិបតេយ្យ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានធានានូវសិទ្ធិសេរីភាពសមភាពនៅចំពោះមុខតុលាការ នៃប្រជាពលរដ្ឋគ្រប់រូបដូចគ្នាគឺៈ

-ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

-ប្រជាពលរដ្ឋមានភាពស្មើគ្នាចំពោះមុខច្បាប់។

-ប្រជាពលរដ្ឋមានសិទ្ធិប្តឹងបរិហារកេរ្តិ៍ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលខូចខាត។

-ប្រជាពលរដ្ឋត្រូវបានច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូរ។

តាមគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ព្រមទាំងការពារចំពោះប្រជាពលរដ្ឋគ្រប់រូបឃើញថា សមល្មម ដើម្បីធានានីតិរដ្ឋយ៉ាងរឹងមាំដែលជាសេចក្តីសង្ឃឹមរបស់ជនគ្រប់ៗរូប។ ក៏ប៉ុន្តែតាមទិដ្ឋភាពជាក់ស្តែង គោលការណ៍ទាំងនោះមិនទាន់បានយកមកអនុវត្តឲ្យបានត្រឹមត្រូវតាមបទដ្ឋានគតិយុត្តទាំងស្រុងទេ ដោយសារនៅមានឥទ្ធិពលជាច្រើនដែលមិនអាចធានាសមភាពនៅចំពោះមុខតុលាការ។

**១-ការផ្តន្ទាទោសជនប្រព្រឹត្ត**

---

[៧៦] មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិប្រជាពលរដ្ឋ

[៧៧] មាត្រា២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិប្រជាពលរដ្ឋ

តាមច្បាប់ព្រហ្មទណ្ឌអន្តរកាលបានចែងថា គ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តី ត្រូវតែបានទទួលការកាត់ក្តីយ៉ាងយូរបំផុតប្រាំមួយខែ ក្រោយពីថ្ងៃចាប់ខ្លួន ប៉ុន្តែមានពិរុទ្ធជនខ្លះជាប់ឃុំលើសពីប្រាំមួយខែ ដោយមិនបានទទួលការកាត់ក្តីសេចក្តីពីតុលាការ ឯជនល្មើសខ្លះទៀតមិនត្រូវបានចាប់ខ្លួនយកមកឲ្យតុលាការផ្តន្ទាទោសនៅឡើយទេ ដែលភាគច្រើននៃជនប្រព្រឹត្តទាំងនោះ ជាប់ជាសាច់ញាតិជិតដិតជាមួយជំពូកអ្នកមានអំណាច។

ករណីលោក អ៊ាង ផានិត អាយុ ២៣ឆ្នាំ ត្រូវបានប្រធានប៉ុស្តិ៍ការពារព្រំដែន នៅឃុំជា ស្រុកមេមត់ ខេត្តកំពង់ចាម បាញ់បណ្តាលឲ្យស្លាប់នៅនឹងកន្លែងកាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៣ នៅពេលដែលជនរងគ្រោះចេញទៅដងទឹក។ ករណីនេះជនល្មើសនៅតែធ្វើសកម្មភាពជាធម្មតា ហើយពុំទាន់មានសមត្ថកិច្ចណាមួយបានចាត់វិធានការទៅតាមច្បាប់នោះទេ មកដល់ពេលនេះ[៧៨]។

ករណីលោក ថោង ស៊ីម៉ា អាយុ២៣ឆ្នាំ ត្រូវបានស្នងការនគរបាលខេត្តកំពង់ឆ្នាំង វាយបណ្តាលឲ្យរងរបួស នៅពេលដែលជនរងគ្រោះបានចេញទៅតាមរកឆ្កែរបស់ខ្លួនកាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣។ ករណីនេះ គ្មានស្ថាប័នណាធ្វើការស៊ើបអង្កេត និងចាត់វិធានការទេ[៧៩]។

ករណីលោក ឈប ផល្លា ត្រូវបានលោក ចាប លី ជាប៉េអឹម ខេត្តបាត់ដំបង ដែលកំពុងចាក់អាប៉ោង ចាប់វាយអុកគូថ និងចាប់ឃុំខ្លួនអស់មួយយប់ នៅខណៈពេលដែលជនរងគ្រោះបានហៅបងរបស់ខ្លួនចេញពីកន្លែងចាក់អាប៉ោង។ ពេលនេះបានយល់ព្រមត្រឹមតែសងប្រាក់ចំនួនពីរលានរៀលប៉ុណ្ណោះ ទៅជនរងគ្រោះ ហើយជនប្រព្រឹត្តពុំត្រូវបានច្បាប់យកមកកាត់ទោសតាមច្បាប់ឡើយ[៨០]។

**២-ឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ**

ប្រព័ន្ធតុលាការ ត្រូវតែសម្រេចសេចក្តី ដោយមិនលំអៀង ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់[៨១]។ ហើយការសម្រេចចិត្តនេះទៀតសោត មានទំនាក់ទំនងនឹងឯករាជ្យភាពរបស់តុលាការ និងសមភាពចំពោះតុលាការ។ ប្រព័ន្ធតុលាការចាំបាច់ណាស់ក្នុងការធានាឲ្យមានយុត្តិធម៌សម្រាប់មនុស្សទាំងអស់ក្នុងសង្គម ដែលឈានទៅដល់ការធានាបាននូវស្ថេរភាពនយោបាយ ឯកភាពជាតិ សន្តិភាព សន្តិសុខសង្គម ការរួបរួមគ្នាជាកម្លាំងជាតិដ៏រឹងមាំ ការបង្កើតឲ្យមានជំនឿទុកចិត្តរវាងប្រជាពលរដ្ឋទូទៅ និងអ្នកដឹកនាំ ព្រមទាំងការអភិវឌ្ឍន៍ប្រទេសជាតិដោយល្បឿនលឿនក្នុងចរន្តនិរន្តរភាព។

ឯករាជ្យភាពនៃប្រព័ន្ធតុលាការ មានសារៈសំខាន់ណាស់ចំពោះការប្រព្រឹត្តទៅនៃរដ្ឋប្រជាធិបតេយ្យមួយដែលប្រតិបត្តិក្រោមនីតិរដ្ឋ ប៉ុន្តែពុំមានទេក្នុងប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា។ ដូចបានកត់ចំណាំ

---

[៧៨] សមាគមអាដហុក: ស្ថានភាពសិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៨ ឆ្នាំ២០០៣ ទំព័រ ២០

[៧៩] ដ.ឯ.ម ទំព័រ ២០

[៨០] វិទ្យុអាស៊ីសេរី នាម៉ោង៦ព្រឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩

[៨១] មាត្រា១០៩/២ និងមាត្រា១១០/២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ដោយតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ទោះបីជាគោល-ការណ៍នៃឯករាជ្យភាពតុលាការមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាក៏ដោយ តែក្នុងការប្រតិបត្តិជាក់ស្តែងប្រព័ន្ធតុលាការមិនទាន់អាចប្រើសិទ្ធិប្រកបដោយប្រសិទ្ធិភាព ប្រឆាំងនឹងអំណាចនីតិប្រតិបត្តិបានទេ។ ចៅក្រមបានបន្តស្ថិតក្រោមការជ្រៀតជ្រែកផ្នែកនយោបាយ ហើយមិនអាចមានឆន្ទៈ ដើម្បីប្រើតួនាទីរបស់ខ្លួនដោយឯករាជ្យឡើយ។ ហើយតែងត្រូវបានសាធារណៈជនទទួលស្គាល់ថា ពុំទាន់ស្វ័យភាពក្នុងជំហរឯករាជ្យ អសមត្ថភាពការកាត់ក្តីដោយលំអៀង ការមិនគោរពច្បាប់ ការបាត់បង់កេរ្តិ៍ឈ្មោះ និងអំពើពុករលួយបានក្លាយជាវប្បធម៌ទៅហើយ ដែលស្ទើរតែមិនអាចកែប្រែបានទៀតផង[៨២]។ ភាគីច្រើននៃចៅក្រមត្រូវបានចាត់តាំងពីសម័យកុំម្មុយនីស្ត ដែលបានកាន់កាប់ដោយគណបក្សប្រជាជនកម្ពុជា ហើយបុគ្គលខ្លះនៅរក្សាតំណែងរបស់ពួកគេនៅក្នុងគណបក្សកាន់អំណាច ព្រមទាំងទទួលការឧបត្ថម្ភពីមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល ឬអ្នកមានទ្រព្យសម្បត្តិ និងអាជ្ញាធរមានអំណាច។ ចៅក្រមភាគច្រើនកាត់ក្តី ដោយស្ថិតនៅក្នុងក្តីបារម្ភពីបញ្ហាសន្តិសុខផ្ទាល់ខ្លួនមានការគាបសង្កត់ គំរាមកំហែង បំភិតបំភ័យ ខ្លាចបាត់បង់ការងារ និងមានការជ្រោមជ្រែងគាំពារពីអ្នកមានអំណាចក្នុងជួររដ្ឋាភិបាល។ ដូចជានៅក្នុងឆ្នាំ២០០៣ ចៅក្រមត្រូវបានគំរាមកំហែងដោយឧក្រិដ្ឋជនមិនស្គាល់មុខ ធ្វើឲ្យមន្ត្រីតុលាការជាច្រើនមានការភ័យខ្លាចអំពីសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ និងគ្មានជំនឿទុកចិត្តទៅលើការការពាររបស់ប៉ូលីស ឬអាជ្ញាធរឡើយ។

សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការឯករាជ្យ និងមិនលំអៀងធានាថា ចៅក្រមត្រូវតែរួចផុតពីការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅ និងពីភាពលំអៀងជាបុគ្គល។ នេះគឺជាសិទ្ធិមូលដ្ឋាន ដែលអនុគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានថ្លែងថា វាជាសិទ្ធិដាច់ខាតដែលមិនអាចឲ្យមានការលើក លែង[៨៣]។ ចៅក្រមតែងទទួលរងនូវការគាបសង្កត់ពីអ្នកនយោបាយមានអំណាច កើតឡើងដោយអាថ៌កំបាំង។ តុលាការនឹងមានភាពឯករាជ្យប្រសិនបើចៅក្រម និងមន្ត្រីតុលាការត្រូវបានតែងតាំង ផ្ទេរ ឬបញ្ឈប់ដោយ ត្រឹមត្រូវ និងមានមូលហេតុជាក់លាក់។ ក៏ប៉ុន្តែតាមការសង្កេតជាទូទៅជាក់ស្តែង ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីត្រូវរងសម្ពាធឲ្យចូលជាសមាជិកគណបក្សកាន់អំណាច ហើយការតែងតាំងតួនាទីក្នុងស្ថាប័នតុលាការ គឺធ្វើឡើងតាមរយៈសមាជិកភាពរបស់គណបក្សកាន់អំណាច[៨៤]។ ទន្ទឹមនឹងការចូលរួមជាសមាជិកគណបក្សកាន់អំណាចនោះ ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការជាច្រើនត្រូវទទួលភារកិច្ច ឃោសនាសម្រាប់គណបក្សនយោបាយថែមទៀតនៅពេលមានការបោះឆ្នោតមកដល់ម្តងៗ។ ដោយសារសម្ពាធនយោបាយ ដូច្នេះបានធ្វើឲ្យចៅក្រម

---

[៨២] របាយការណ៍របស់លោក យ៉ាសហ៍ ហ្គាយ ស្តីអំពីប្រព័ន្ធតុលាការនៅកម្ពុជា ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ A/HRc/4/36 នៅវគ្គ៣២ និង៤០

[៨៣] Gonzalez delRiov.Peru( 263/1987 ) សេចក្តីប្រកាសសម្រេចរបស់អនុគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ Vol.II, ( A/48/40 ) 1993 ទំព័រ ២០. របាយការណ៍ឃ្លាំមើលតុលាការរបស់អង្គការ CSD ២០០៧ ទំព័រ ១៦

[៨៤] សុក សំអឿន សាស្ត្រាច្បាប់ និងជានាយកអង្គការ CDP ភ្នំពេញ បទបង្ហាញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ទំព័រ ៤

បាត់បង់នូវឯករាជ្យភាពរបស់ខ្លួន ដែលជាហេតុធ្វើឲ្យស្ថាប័នមួយនេះត្រូវគេមើលឃើញជាទូទៅ ថាបំពេញការងារដោយខ្វះឯករាជ្យពីនយោបាយ។ ក្រៅពីលំអៀងដោយឥទ្ធិពលនយោបាយ តុលាការកម្ពុជាត្រូវទទួលរងការរិះគន់ថា មានអំពើពុករលួយថែមទៀតផង។ ជនជាប់សង្ស័យពីបទល្មើសព្រហ្មទណ្ឌមួយចំនួនត្រូវបានចៅក្រមសម្រេចឃុំខ្លួនជាបណ្តោះអាសន្នដោយពុំមានភស្តុតាងច្បាស់លាស់ ក្នុងការដាក់បន្ទុក ហើយចៅក្រមបានផ្តល់សិទ្ធិឲ្យគ្រួសារជនជាប់ចោទដាក់ពាក្យធានាឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ក៏ប៉ុន្តែរាល់ការធានាឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ត្រូវបានគ្រួសារជនជាប់ចោទរាយការណ៍ថា ត្រូវចំណាយលុយឲ្យតុលាការពីចន្លោះ៥០០ដុល្លារទៅ១០០០ដុល្លារ ទើបអាចទទួលបានការអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន។ ទន្ទឹមនឹងការសូកប៉ាន់តុលាការឲ្យនៅក្រៅឃុំបណ្តោះអាសន្ន មាននៅករណីផ្សេងទៀត គឺមានមេធាវីមួយចំនួនត្រូវចំណាយប្រាក់ពី៣០ដុល្លារទៅ៥០ដុល្លារ ដើម្បីឲ្យតុលាការលើកយករឿងក្តីរបស់គេដាក់ចូលទៅក្នុងកម្មវិធីជម្រះឲ្យបានលឿន[៨៥]។

សរុបសេចក្តីមក ក្នុងសង្គមប្រជាធិបតេយ្យមន្ត្រីតុលាការ ជាពិសេសចៅក្រម ព្រះរាជអាជ្ញា ចាំបាច់ត្រូវតែនៅជាអព្យាក្រឹតមិនត្រូវអនុញ្ញាត ឬបង្ខំឲ្យធ្វើជាសមាជិកគណបក្សនយោបាយឡើយ ដើម្បីធានាស្ថេរភាពនយោបាយ សន្តិសុខ យុត្តិធម៌សង្គម ជំនឿពីប្រជាពលរដ្ឋម្ចាស់ឆ្នោត ម្ចាស់អំណាច ព្រោះថាកាលណាចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជីជាមនុស្សរបស់គណបក្សនយោបាយ ធ្វើឲ្យការសម្រេចរឿងក្តីមិនឯករាជ្យ ហើយក៏មិនអាចរកយុត្តិធម៌ ឬភាពត្រឹមត្រូវពិតប្រាកដនៅក្នុងរឿងក្តីនោះបានទេ ម្យ៉ាងវិញទៀតកាលណាចៅក្រមហ៊ានប្រើឆន្ទានុសិទ្ធិ និងអំណាចរបស់ខ្លួនដូចរដ្ឋធម្មនុញ្ញបានចែង ដើម្បីចម្រាញ់រាវរកយុត្តិធម៌ក្នុងរឿងក្តីទាំងឡាយអាចនឹងទទួលរងនូវបញ្ហា ដូចជារងការគំរាមកំហែងដល់អាយុជីវិត អសន្តិសុខ សុវត្ថិភាពផ្ទាល់ និងកើតមានចរន្តប្រព្រឹត្តអំពើពុករលួយដូចសព្វថ្ងៃនេះ។

### ៣-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នជាតិមួយត្រូវបានបង្កើតឡើង និងទទួលអំណាចសាធារណៈមួយ គឺតួនាទី និងភារកិច្ច ដើម្បីតាមដាន ត្រួតពិនិត្យសកម្មភាពកំហុសឆ្គងរបស់ចៅក្រមព្រះរាជអាជ្ញា និងប្រព័ន្ធតុលាការ ដើម្បីធានានូវភាពឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌ និងការប្រកបវិជ្ជាជីវៈរបស់ចៅក្រម និងព្រះរាជអាជ្ញាប្រកបដោយសីលធម៌ខ្ពស់ ដែលមហាជនទូទៅគោរពហើយមានសង្ឃឹមថានឹងទទួលបានយុត្តិធម៌ក្នុងការវិនិច្ឆ័យរឿងក្តី។ ផ្ទុយទៅវិញចំណាត់ការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើវិស័យកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មិនត្រូវបានគេមើលឃើញថា មានការវិវត្តន៍គួរជាទីពេញចិត្តនោះទេ និងត្រូវបានគេរិះគន់ថា ស្ថិតក្រោមឥទ្ធិពលនយោបាយពីស្ថាប័ននីតិប្រតិបត្តិ ព្រមទាំងសមាជិកខ្លះនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាមន្ត្រីជាន់ខ្ពស់របស់គណបក្សនយោបាយកាន់អំណាច។ ការមើលឃើញបែបនេះ

[៨៥] សមាគមអាដហុក: ស្ថានភាពសិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៨ លេខ៨ ឆ្នាំទី៨ ផ្សាយខែមករា ឆ្នាំ២០០៩

សូម្បីតែមជ្ឈមណ្ឌលធនធានច្បាប់នៅអាស៊ីក៏បានលើកឡើងក្នុងរបាយការណ៍កាលពីឆ្នាំ២០០៧ ដោយបានផ្ញើទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបង្ហាញថា ប្រព័ន្ធតុលាការជាឧបករណ៍របស់រដ្ឋាភិបាល ឬអ្នកមានទ្រព្យ និងអ្នកមានអំណាច សម្រាប់បង្ក្រាបទៅលើអ្នករិះគន់រដ្ឋាភិបាល ឬជនរងគ្រោះក្នុងរឿងដីធ្លី ដោយចៅក្រមធ្វើការប្រឌិត និងចោទប្រកាន់ក្នុងគោលបំណងចាប់អ្នកទាំងអស់នោះដាក់ពន្ធនាគារ[៨៦]។ គណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) មានការងាយស្រួលក្នុងការប្រើឥទ្ធិពលរបស់ខ្លួនទៅលើប្រព័ន្ធតុលាការដោយសារចៅក្រម និងព្រះរាជអាជ្ញាស្ទើរតែទាំងអស់ជាសមាជិកគណបក្សកាន់អំណាច ព្រោះជាតម្រូវការ និងវិន័យរបស់បក្ស។ មានការចង្អុលបង្ហាញដ៏ច្បាស់លាស់ ពីការជាប់ពាក់ព័ន្ធផ្នែកនយោបាយរបស់ប្រព័ន្ធតុលាការគឺនៅពេលមានយុទ្ធនាការឃោសនាមុនការបោះឆ្នោត និងមានការផ្តល់វិភាគទានក្នុងយុទ្ធនាការឃោសនាដែលធ្វើឡើងដោយចៅក្រម។ ការជ្រៀតចូលរបស់ការងារនយោបាយ នៃគណបក្សកាន់អំណាចទៅក្នុងប្រព័ន្ធតុលាការកម្ពុជា ក៏ត្រូវបានតំណាងពិសេសអង្គការសហប្រជាជាតិ និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពី ឯករាជ្យភាពចៅក្រម និងមេធាវី បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈនៅខែសីហា ឆ្នាំ២០០៧ ដែលទាក់ទងទៅនឹងអ្វីដែលគេយល់ថា ជាឧបរណ៍គួរឲ្យចាប់អារម្មណ៍នៃឥទ្ធិពលនយោបាយទៅលើប្រព័ន្ធតុលាការ។ សេចក្តីថ្លែងការណ៍នោះ ទាក់ទងនឹងការផ្លាស់ប្តូរប្រធានសាលាឧទ្ធរណ៍កម្ពុជា និងការតែងតាំងសមាជិកថ្មីបួនរូប នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយព្រះរាជក្រឹត្យចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៧ ដែលសរសេរថា ការផ្លាស់ប្តូរ និងការតែងតាំងត្រូវបានធ្វើឡើងតាមសំណើរអង្គការនីតិប្រតិបត្តិនៃរដ្ឋាភិបាល ដោយបំពានលើការបែងចែកអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ដែលបានបញ្ជាក់ច្បាស់ក្នុងរដ្ឋធម្មនុញ្ញ។ ម្យ៉ាងទៀតស្ថាប័ននេះបានកើតឡើងជារូបរាងមែនពិត ក៏ប៉ុន្តែស្ថាប័ននេះពុំមានច្បាប់សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តន៍ដាក់ទោសវិន័យដល់ចៅក្រម ឬព្រះរាជអាជ្ញាណាដែលបានប្រព្រឹត្តខុសឆ្គងទេ ហេតុផលខាងលើនេះ ធ្វើឲ្យចៅក្រម ព្រះរាជអាជ្ញា បាត់បង់ឯករាជ្យភាពរបស់ខ្លួនក្នុងការសម្រេចសេចក្តីដោយសារមានអំពើពុករលួយ និងឥទ្ធិពលអំណាចនយោបាយ[៨៧]។ ហេតុផងទាំងនេះបង្ហាញឲ្យ ឃើញថា អំណាចរដ្ឋាភិបាលមានច្រើនលើសលប់ បណ្តាលឲ្យស្ថាប័ននីតិប្រតិបត្តិអាចប្រើអំណាចគាបសង្កត់លើស្ថាប័នដទៃទៀតរបស់ជាតិ រួមទាំងប្រព័ន្ធយុត្តិធម៌បានដោយគ្មានញញើតឡើយ ហើយក៏ពុំអាចធ្វើឲ្យដំណើរការគ្រប់គ្រងនិងដឹកនាំសង្គមរបស់រដ្ឋាភិបាល ប្រព្រឹត្តទៅដោយធានាបាននូវការគោរពអធិបតេយ្យរបស់ប្រជាពលរដ្ឋនីតិរដ្ឋព្រមទាំងទទួលនូវការអបអរសាទរពីប្រជាពលរដ្ឋម្ចាស់អំណាចដែរ។ ឯការចាប់មនុស្សដាក់គុកពីករណីជម្លោះដីធ្លីនៅតែកើតមាន បើទោះបីជាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ធ្លាប់មានប្រសាសន៍កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ថា សម្តេចនឹងមិនឲ្យមានការចាប់ខ្លួន

[៨៦] សេចក្តីថ្លែងការណ៍របស់មជ្ឈមណ្ឌលធនធានច្បាប់អាស៊ី ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ A/HRC/5/NGO/H, ទំព័រ ៤

[៨៧] សេចក្តីថ្លែងការណ៍រួម ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ដើម្បីសិទ្ធិមនុស្ស ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ www.ohchr.org

ប្រជាពលរដ្ឋក្នុងរឿងជម្លោះដីធ្លីទៀតក៏ដោយ ប៉ុន្តែនៅក្នុងឆ្នាំ២០០៨ មានប្រជាពលរដ្ឋរហូតទៅដល់១៥០នាក់ត្រូវបានចាប់ខ្លួនក្នុងករណីជម្លោះដីធ្លីតែចំនួន៣០៦ករណីប៉ុណ្ណោះ។ ក្រៅពីនេះ នៅមានអ្នកដែលកំពុងរត់គេចខ្លួនជាងមួយរយនាក់ទៀត ដែលមានដីការចាប់ខ្លួន និងមានប្រជាពលរដ្ឋចំនួន៥៩នាក់ទៀត ដែលកំពុងស្ថិតនៅជាប់ឃុំឃាំងនៅឡើយ[៨៨]។ និន្នាការនេះឃើញថា ប្រព័ន្ធតុលាការកម្ពុជា គឺកំពុងតែត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនឯកជន និងអ្នកមានអំណាច ដើម្បីចាប់ឃុំខ្លួនប្រជាពលរដ្ឋទន់ខ្សោយគ្មានញញើតច្បាប់អ្វីឡើយ។

នៅក្នុងរបបនយោបាយប្រកាន់យករបបប្រជាធិបតេយ្យ និងជាចរន្តដឹកនាំមួយដែលឈរលើនីតិរដ្ឋ គឺជារបបនយោបាយមួយដែលធានា ចំពោះសិទ្ធិសេរីភាពទាំងឡាយរបស់ប្រជាពលរដ្ឋម្ចាស់អំណាច ដូចជា សិទ្ធិការពារខ្លួន សិទ្ធិត្រូវដឹងពីមូលហេតុនៃការចោទប្រកាន់ក្នុងរយៈពេលខ្លី សិទ្ធិទទួលពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួនចំពោះមុខច្បាប់ សិទ្ធិត្រូវបានកាត់ទោសដោយឆាប់រហ័ស សិទ្ធិមានសាក្សីបំភ្លឺ សិទ្ធិមានការបកប្រែភាសា សិទ្ធិមិនត្រូវទទួលរងការបង្ខិតបង្ខំ សិទ្ធិសើរើពិនិត្យឲ្យធ្វើការវិនិច្ឆ័យទោសជាថ្មី សិទ្ធិទាមទារសំណងជម្ងឺចិត្ត...។ សិទ្ធិទាំងនេះ អាស្រ័យទៅលើប្រព័ន្ធតុលាការមួយមានអំណាចដាច់ដោយឡែកពីស្ថាប័នដឹកនាំដទៃទៀតរបស់ប្រទេស។ ប៉ុន្តែប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជានៅតែមានលក្ខណៈពុករលួយអសមត្ថភាព និងនៅមានភាពលំអៀង ប្រកាន់បក្សពួកនិន្នាការនយោបាយនៅឡើយ។ ចំណែកឯការផ្លាស់ប្តូរស្ថាប័នទាំងនេះ នាឆ្នាំ២០០៥ បានធ្វើឲ្យតុលាការស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័ននីតិប្រតិបត្តិកាន់តែខ្លាំងឡើងថែមទៀត។ ប្រព័ន្ធតុលាការនៅតែត្រូវបានគេប្រើប្រាស់ជាឧបករណ៍របស់រាជរដ្ឋាភិបាល នៅក្នុងរឿងនយោបាយនិងជាល្ខោននៃអំពើពុករលួយ[៨៩]។ ករណីដែលលេចធ្លោបំផុត គឺករណីមិនផ្តល់យុត្តិធម៌នៅក្នុងឆ្នាំ២០០៥ គឺលោក ជាម ច័ន្ទនី ដែលត្រូវបានរដ្ឋសភាបោះឆ្នោតដកអភ័យឯកសិទ្ធិសមាជិកសភា នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៥ នៅថ្ងៃដដែលនេះ លោក ជាម ច័ន្ទនី ត្រូវបានចាប់ខ្លួនសួរចម្លើយជាអយ្យការយោធា និងឃុំខ្លួននៅក្នុងពន្ធនាគារយោធា បើទោះបីជាការពិតលោកជាជនស៊ីវិលក៏ដោយ ក៏លោកត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងបង្កើតកងទ័ពខុសច្បាប់ ដោយសារលោកមានតួនាទីជាប្រធានគណៈកម្មាធិការនៃរដ្ឋាភិបាលស្រមោល របស់គណបក្សសម រង្ស៊ី ទទួលបន្ទុកការពារជាតិ។ តំណែងគណៈរដ្ឋមន្ត្រីរដ្ឋាភិបាលស្រមោលបែបនេះគឺជាការស្របច្បាប់ និងធម្មតានៅក្នុងគណបក្សធំទាស់ក្នុងសភានៅទូទាំងពិភពលោក។ ហើយលោកត្រូវបានបដិសេធដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន និងត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្ម ទាក់ទិនទៅនឹងការចោទប្រកាន់ពីបទបង្កើតកម្លាំងប្រដាប់អាវុធខុសច្បាប់ និងបទឆបោក។

ច្បាប់នៅកម្ពុជាចែងយ៉ាងច្បាស់ថា តុលាការយោធា គឺសម្រាប់បុគ្គលិកយោធាដែលប្រព្រឹត្តបទល្មើសទាក់ទងនឹងតួនាទីរបស់ពួកគេនៅក្នុងជួរកងកម្លាំងប្រដាប់អាវុធ។

---

[៨៨] ព្រឹត្តិបត្រអ្នកជា លេខ២៩៥ ឆ្នាំទី១៥ ខែមករា ឆ្នាំ២០០៩ ទំព័រ ១-២

[៨៩] របាយការណ៍លីកាដូ ខែកក្កដា ឆ្នាំ២០០៦ ទំព័រ ២៤

ក្រុមការងាររបស់អង្គការសហប្រជាជាតិស្តីពីការឃុំឃាំងដោយឥតច្បាប់ បានធ្វើការត្រួតពិនិត្យករណីនេះ ដោយធ្វើសេចក្តីសន្និដ្ឋានថា គឺធ្វើឡើងដោយទំនើងចិត្តហើយបានរំលោភទាំងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ និងបានស្នើរដ្ឋាភិបាលចាត់វិធានការដើម្បីកែតម្រូវស្ថានការណ៍នេះ[៩០]។ នៅក្នុងខែឧសភា ឆ្នាំ២០០៥ លេខា-ធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានអាណត្តិ ដើម្បីការពារឯករាជ្យ និងបូរណភាពរបស់ប្រព័ន្ធតុលាការត្រូវបានផ្ទេរឲ្យស្ថិតនៅក្រោមអំណាចរបស់ក្រសួងយុត្តិធម៌ ខណៈដែលក្រុមប្រឹក្សានៃអង្គចៅក្រមមិនដែលត្រូវបានចាត់ទុកថាឯករាជ្យផងនោះ។ ឧត្តមក្រុមប្រឹក្សានេះមានសមាជិកភាគច្រើនបំផុត ជាប់ពាក់ព័ន្ធនឹងគណបក្សនយោបាយ ដែលស្នើរតែជានិច្ចកាលធ្វើការតែងតាំងចៅក្រមណាដែលមានភក្តីភាពចំពោះគណ-បក្សរបស់ខ្លួន[៩១]។ ការផ្ទេរលេខាធិការដ្ឋាន ត្រូវបានគេមើលឃើញថា ជាការពង្រឹងអំណាចដោយស្ថាប័ននីតិ-ប្រតិបត្តិ។

ដោយឡែកគោលនយោបាយកណ្តាប់ដៃដែករបស់ប្រមុខរដ្ឋាភិបាល ក៏បានធ្វើឲ្យចៅក្រម និងក្រឡាបញ្ជីមួយចំនួនច្របូកច្របល់ ក្នុងការធ្វើយ៉ាងណាឲ្យការងាររបស់គេនៅគង់វង្ស និងការតឹងតាងមួយទៀតនៃការជ្រៀតជ្រែករបស់អង្គនីតិប្រតិបត្តិនៅក្នុងប្រព័ន្ធតុលាការ។ ការប្រើកណ្តាប់ដៃដែកកាលពីឆ្នាំ២០០៥របស់ប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានប្រកាសយុទ្ធនាការមួយ ដើម្បីដោះស្រាយបញ្ហាចៅក្រមទទួលសំណូកដោះលែងឧក្រិដ្ឋជនជាប់ចោទ។ ប្រសិទ្ធិភាពនៃការប្រើកណ្តាប់ដៃដែក ឃើញថាចៅក្រមបីរូប ព្រះអាជអាជ្ញាពីររូប និងក្រឡាបញ្ជីបីរូប ត្រូវបានចោទប្រកាន់អំពើពុករលួយ។

ជាកត្តាសត្យានុម័ត ការខ្វះសមត្ថភាព ខ្វះសុវត្ថិភាព ខ្វះឯករាជ្យភាព ការប្រព្រឹត្តអំពើពុករលួយ និងការរំលោភដោយអំណាចរដ្ឋាភិបាល ជាឧបសគ្គអាចបណ្តាលគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរចំពោះ យន្តការរកយុត្តិធម៌ក្នុងស្ថាប័នតុលាការ។ ជនជាប់ចោទដែលបានលើកលែងការចោទប្រកាន់ភាគច្រើនត្រូវបានផ្តល់សំណូកទៅចៅក្រមឬក៏សម្រេចសេចក្តីដោយលំអៀងទៅបុគ្គលណាមានអំណាចធំ បក្សពួក ដែលជាអំពើប្រាស់ចាកពីច្បាប់ជាតិ និងអន្តរជាតិដែលបានចែងថាៈ

ក-មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ ឬក្នុងសាលាជំនុំជម្រះក្តី (មាត្រា១៤នៃ ICCPR)។

ខ-តុលាការត្រូវមានសមត្ថភាពគ្រប់គ្រាន់ ប្រកបទៅដោយឯករាជ្យពេញលេញហើយមិនត្រូវមានការលំអៀងទៅខាងណាឡើយ(មាត្រា១៤ នៃICCPR)។

គ-នៅក្នុងជំពូកទី៩ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ក៏មានចែងពីស្ថាប័នតុលាការដែរ គឺថាៈ

[៩០] យោបល់របស់លោក WGAD លេខ២៩/២០០៥(កម្ពុជា) ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥

[៩១] បញ្ជីឈ្មោះចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការជាន់ខ្ពស់ដទៃទៀត ដែលចេញដោយក្រសួងយុត្តិធម៌ នៅឆ្នាំ២០០៣

១-អំណាចតុលាការ ជាអំណាចឯករាជ្យ(មាត្រា១០៩ នៃរដ្ឋធម្មនុញ្ញ១៩៩៣)។

២-តុលាការជានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ (មាត្រា១០៩ នៃរដ្ឋធម្មនុញ្ញ ១៩៩៣)។

៣-គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការបានឡើយ (មាត្រា១១១ នៃរដ្ឋធម្មនុញ្ញ ១៩៩៣)។

យោងតាមមាត្រា១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏បានបញ្ញត្តិពីប្រព័ន្ធតុលាការផងដែរថាៈ

១-ចៅក្រមទាំងឡាយ កាត់ក្តីតាមភាពលំអៀងដោយផ្អែកលើហេតុការណ៍ដែលមាននៅចំពោះមុខ។

២-កាត់ក្តីត្រូវគោរពតាមច្បាប់ដោយមិនព្រមទទួលនូវការគាបសង្កត់ ការគំរាមកំហែង ការបំភិតបំភ័យ ដោយចំពោះមុខ ឬមិនចំពោះមុខ។

៣-មានតែជនសង្ស័យករណីឧក្រិដ្ឋប៉ុណ្ណោះ ទើបអាចឈានទៅរកការឃុំខ្លួនបណ្តោះអាសន្នពន្យាហូតដល់៦ខែ(មាត្រា១៤)។ តែការអនុវត្តន៍ពិតជាក់ស្តែងវិញ គឺផ្ទុយស្រឡះ ព្រោះជនឃុំខ្លួនខ្លះ ទោះបីជាខ្លួនជាប់ចោទបទមជ្ឈឹមក៏ដោយ ក៏ត្រូវបានគេបង្អែរបង្អង់ពន្យាពេលរហូតដល់លើសពី៦ខែ ដែលជាការខុសនឹងនីតិវិធីច្បាប់ទាំងស្រុងច្បាស់ក្រឡែតក៏ដោយ ក៏ពុំទាន់បាននាំខ្លួនយកទៅកាត់ក្តីដោយតុលាការដែរ។ ហើយជនជាប់សង្ស័យទាំងនោះភាគច្រើនស្លៀកពាក់ខោអាវដូចអ្នកទោសនិងស្នាក់នៅជាមួយអ្នកទោសដែរ ដែលធ្វើឲ្យបាត់បង់សិទ្ធិនៃសេចក្តីថ្លៃថ្នូរក្នុងនាមជាពលរដ្ឋ។ ចាប់តាំងពីឆ្នាំ២០០៥ ចៅក្រមត្រូវបានផ្លាស់ប្តូរកន្លែងធ្វើការទូទាំងប្រព័ន្ធតុលាការដោយមួយភាគបួននៃប្រព័ន្ធតុលាការ ត្រូវផ្លាស់ប្តូរជារៀងរាល់ឆ្នាំ។ ទោះបីជាកំណែទម្រង់ក្នុងគោលដៅបំបែកបណ្តាញពុករលួយ និងបង្កើនភាពមិនលំអៀងក្នុងប្រព័ន្ធតុលាការយ៉ាងណាក្តី ប៉ុន្តែការផ្លាស់ប្តូរកន្លែងធ្វើការទៅកាន់ខេត្តឆ្ងាយៗហាក់ដូចជាកំពុងតែប្រើប្រាស់ជាទណ្ឌកម្ម ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ចៅក្រមដែលបានផ្លាស់ប្តូរកន្លែងធ្វើការទៅកាន់ខេត្តឆ្ងាយជាញឹកញាប់បដិសេធមិនទៅ ដែលជាហេតុធ្វើឲ្យខ្វះចៅក្រមបន្ថែមទៀតនៅតាមបណ្តាខេត្តទាំងនោះនិងមានការអូសបន្លាយការឃុំខ្លួនជនសង្ស័យមុនការកាត់ទោស។ លើសពីនេះទៀត រហូតមកដល់សព្វថ្ងៃនេះ រដ្ឋាភិបាលខកខានមិនបានផ្តល់ប្រាក់ឧត្តម្ភគ្រប់គ្រាន់សម្រាប់ចៅក្រមដែលត្រូវផ្លាស់ប្តូរទៅតុលាការខេត្តផ្សេង។ ការផ្លាស់ប្តូរកន្លែងធ្វើការរបស់ចៅក្រម គឺជាយុទ្ធសាស្ត្រ ដែលមានសារៈប្រយោជន៍ជាសក្តានុពល ប៉ុន្តែត្រូវតែទ្រទ្រង់ដោយការដាក់ទណ្ឌកម្មដ៏មានប្រសិទ្ធិភាពទៅលើអំពើពុករលួយក្នុងប្រព័ន្ធតុលាការ។

ជាទូទៅកង្វះនៃការញែកអំណាចឲ្យដាច់ចេញ រវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងទៅលើឯករាជ្យរបស់តុលាការកម្ពុជា។

### ៣.១.៣ សិទ្ធិសេរីភាពរួចផុតពីការរើសអើង

ប្រជាពលរដ្ឋខ្មែរមានសេរីភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់

ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គមធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពដទៃទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់[៩២]។

ព្រះរាជាណាចក្រកម្ពុជា ទើបនឹងចាប់យករបបដឹកនាំប្រទេសតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស ជាលើកទីពីរនៅឆ្នាំ១៩៩៣ ហើយបើគិតមកដល់ពេលនេះទើបតែមានអាយុកាល១៥ឆ្នាំប៉ុណ្ណោះ។ គេអាចនិយាយបានថា ការរៀនសូត្រពីលទ្ធិប្រជាធិបតេយ្យរបស់កម្ពុជា គឺនៅក្មេងខ្ចី និងផុយស្រួលនៅឡើយ ហើយងាយនឹងត្រឡប់ទៅរកលទ្ធិអត្តាធិបតេយ្យ ឬអំណាចផ្តាច់ការវិញបាន។

ទោះបីយ៉ាងនេះក៏ដោយ កាលពីទសវត្សរ៍ឆ្នាំ៥០ ប្រទេសកម្ពុជាក៏ធ្លាប់យកលទ្ធិប្រជាធិបតេយ្យមកដឹកនាំប្រទេសបានមួយរយៈដែរ។ ប៉ុន្តែពេលនោះ អំពើហិង្សា ការគំរាមកំហែង និងការប្រើកលល្បិចទុច្ចរិតផ្សេងៗ ក្នុងការបោះឆ្នោតហាក់ដូចជាពុំសូវប្រាកដឲ្យឃើញជាក់ស្តែង និងញឹកញយដូចសម័យឥឡូវនេះឡើយ។ ការចូលរួមក្នុងគណបក្សនយោបាយមួយ គឺជាសិទ្ធិស្របច្បាប់ និងជាឆន្ទៈនៃប្រជាពលរដ្ឋខ្មែរគ្រប់រូប ហើយដល់ពេលបោះឆ្នោតម្តងៗ នរណាក៏ចង់បោះឆ្នោតឲ្យបេក្ខជន ឬគណបក្សណាក៏បោះទៅស្រេចតែលើឆន្ទៈរបស់ខ្លួនគ្មាននរណាមកគំរាមកំហែង ឬបង្ខិតបង្ខំនរណាឲ្យចូលរួមក្នុងគណបក្សណា ឬឲ្យបោះឆ្នោតឲ្យនរណា ឬគណបក្សណាឡើយ។ ពិតហើយយើងជាប្រជាជនកម្ពុជាមាននិន្នាការរ៉ូមាំងទិស្មនៅទសវត្សរ៍ឆ្នាំ១៩៥០-១៩៦០ ហើយទទួលស្គាល់ថា គឺជាការខុសគ្នានៃសករាជ(សម័យ) គឺមានបញ្ហាផ្សេងៗគ្នា។ ប៉ុន្តែចាប់តាំងពីការបោះឆ្នោតនៅឆ្នាំ១៩៩៣ នោះមកការប្រកាន់បក្សពួក ឬការចូលរួមក្នុងគណបក្សនយោបាយ ហាក់ដូចជាមានទិដ្ឋភាពខុសប្លែកពីសម័យមុនយ៉ាងច្រើន។ បើសង្កេតជារួមទៅគេអាចមើលឃើញទិដ្ឋភាពប្លែកៗបួនចំណុច[៩៣]គឺៈ

ក/ មន្ត្រីរដ្ឋបាលសាធារណៈ និងកងកម្លាំងប្រដាប់អាវុធ(ប៉ូលីស និងយោធា) គ្មានអព្យាក្រឹត។

ខ/ អ្នកចូលរួមមិនគ្រាន់តែសង្ឃឹមថានឹងបានទទួល ឬបានឡើងបុណ្យស័ក្តិជានេះ ជានោះប៉ុណ្ណោះទេ ជឿលើគណបក្សរបស់ផ្កាប់មុខហើយគេថែមទាំងស្មោះស្ម័គ្ររហូតដល់ហ៊ានយកអាយុជីវិតទៅតស៊ូប្តូរដើម្បីបក្សទៀតផង។

គ/ តំណាងរាស្ត្រធ្វើច្បាប់ និងអនុម័តច្បាប់តាមឆន្ទៈមេបក្ស មិនមែនតាមឆន្ទៈរាស្ត្រទេ។

ឃ/ បក្សអាចបង្កើតមុខតំណែងថ្មីៗ ដែលមិនចាំបាច់គ្រាន់តែដើម្បីចែកអាសនៈគ្នាអង្គុយឲ្យសក្តិសមនឹងឋានៈក្នុងគណបក្សប៉ុណ្ណោះ។

អព្យាក្រិតភាពរបស់មន្ត្រីរាជការ គឺសំដៅដល់មន្ត្រីរដ្ឋបាលសាធារណៈតាំងពីភូមិរហូតដល់ខេត្ត និង

---

[៩២] មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[៩៣] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ព្រឹត្តិបត្រស្រាវជ្រាវ ឆ្នាំទី១៣ លេខ១៣៣ ខែកញ្ញា-តុលា ឆ្នាំ២០០៦ ទំព័រ ៩

មន្ត្រីកម្លាំងប្រដាប់អាវុធតាំងពីកងអនុសេនាតូចរហូតដល់កងពលធំ គឺជារចនាសម្ព័ន្ធចាត់តាំងរបស់គណបក្សកាន់អំណាចជាប់ពីសម័យមុនការបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំដោយអ៊ិនតាក់នោះមកម្ល៉េះ។ ក្នុងចំណោមអ្នកទាំងនោះ ភាគច្រើនតែងបំពេញមុខនាទីដ៏សំខាន់ពីរ គឺមុខនាទីជាប្រធានរដ្ឋបាលសាធារណៈ ឬជាប្រធានកងផង និងមុខនាទីជាប្រធានសាខាបក្សផង។

ដូច្នេះហើយ ទើបគេមិនអាចរកឃើញអព្យាក្រិតភាព នៅក្នុងចំណោមមន្ត្រីសាធារណៈ និងកម្លាំងទាំងនោះឡើយ។ នៅពេលបោះឆ្នោតម្តងៗតាំងពីសម័យ អ៊ុនតាក់ ក៏ដូចជាសម័យក្រោយៗមកទៀតកាលបើមានបាតុភាពមិនប្រក្រតីណាមួយកើតឡើងដូចជា ការគំរាមកំហែង ការបំផ្លិចបំផ្លាញ ឬឃាតកម្មទៅលើសកម្មជន គណបក្សណាមួយជាដើម គេក៏មិនដែលរកឃើញជនដៃដល់ណាម្នាក់ដែរ។

ការស្វាមីភក្តិចំពោះគណបក្សៈ នៃអ្នកចូលរួមជាសមាជិកក្នុងគណបក្សណាមួយគេតែងតែរំពឹងថានឹងទទួលបានឋានៈ ឬមុខតំណែងអ្វីមួយ ឬក៏បានឡើងបុណ្យសក្តិខ្ពស់ជាងមុន ឬយ៉ាងហោចណាស់ក៏ទទួលបានការគាំពារពីគណបក្សប្រសិនបើគណបក្សនោះឈ្នះឆ្នោតបានឡើនកាន់អំណាចដូចជា របបចៅហ្វាយនាយ និងដូចនៅក្នុងសម័យសក្តិភូមិដូច្នេះដែរ។ ដូច្នេះហើយ បានជាគេខិតខំសម្តែងស្វាមីភក្តិចំពោះគណបក្សគេដោយធ្វើសកម្មភាពផ្សេងៗមានការបញ្ចុះបញ្ចូលពាក្យល្អ ឬដោយការបំភិតបំភ័យអ្នកបោះឆ្នោត។ ប៉ុន្តែរាល់សកម្មភាពទាំងអស់នេះគេត្រូវតែធ្វើដោយអាថ៌កំបាំងឬដោយលុបបំបាត់ដានស្នាមឲ្យជិត។ បើចៃដន្យគេរកឃើញនោះខ្លួននឹងត្រូវទទួលខុសត្រូវដោយខ្លួនឯង ដូចជាមេភូមិម្នាក់នៅខេត្តបាត់ដំបង ដែលបើកកាណូតទៅបុកគេដោយបំណងឲ្យស្លាប់ តែគេមិនស្លាប់ និងម្នាក់ទៀតនៅខេត្តកំពង់ចាម ដែលដេញបាញ់កូនស្រីគេត្រូវរបួសក្នុងចំការស្វាយចន្ទី ជាក់ស្តែងពេកក៏ត្រូវទទួលទោសជាប់ពិន័យដោយខ្លួនឯង ហើយស្រែកឲ្យថ្នាក់លើជួយគេបដិសេធថា គេមិនបានប្រើឲ្យធ្វើដូច្នេះទេ។

ការធ្វើច្បាប់ និងការអនុម័តច្បាប់តាមគោលការណ៍ប្រជាធិបតេយ្យ សមាជិកគណបក្សម្នាក់ៗជាពិសេសតំណាងរាស្ត្រ ក៏មានសិទ្ធិសេរីភាពជំទាស់ចំពោះគោលនយោបាយរបស់គណបក្ស ឬគំនិតមេបក្សរបស់ខ្លួនបានដែរ ឲ្យតែគោលនយោបាយ ឬគំនិតមេបក្សនោះធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ប្រជាជន។ តាមរបាយការណ៍របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមបានបង្ហាញថា អ្នកចូលជាសមាជិកគណបក្សនោះមិនត្រឹមតែត្រូវគោរពលក្ខន្តិកៈ និងគោលនយោបាយនៃគណបក្សនោះប៉ុណ្ណោះទេ ថែមទាំងត្រូវគោរពតាមឆន្ទៈរបស់មេគណបក្សផងដែរ បើទោះបីឆន្ទៈនោះគ្រាន់តែដើម្បីការពារអំណាច និងផលប្រយោជន៍របស់បុគ្គល ឬមេបក្សដែលផ្ទុយនឹងផលប្រយោជន៍អ្នកបោះឆ្នោត ឬផ្ទុយនឹងឧត្តមគតិមនសិការរបស់ខ្លួនក៏ដោយ។ ចំពោះករណីដែលចាំបាច់គេថែមទាំងឲ្យតំណាងរាស្ត្រ បោះឆ្នោតដោយលើកដៃទៀតផង ស្រណុកគេសម្គាល់មើលថា តើនរណាលើកដៃ និងមិនលើកដៃ។ អ្នកមិនលើកដៃអាចបាត់បង់សមាជិកភាពពីគណបក្សដែលមានន័យថា បាត់បង់មុខតំណែង ដូច្នេះតំណាងរាស្ត្រម្នាក់ៗ ប្រសិនបើខ្លួនចង់រក្សាមុខតំណែងត្រូវហ៊ានលះបង់ឧត្តមគតិមនសិការរបស់ខ្លួន ហើយសុខចិត្តធ្វើជាចំណាប់ខ្មាំងរបស់គណបក្ស។ កាលបើដូច្នេះ អ្នកតំណាងនោះក៏ក្លាយជាតំណាង

គណបក្សដោយស្វ័យប្រវត្តិមិនមែនជាតំណាងរបស់រាស្ត្រឡើយ ព្រោះថា វាផ្ទុយគ្នាស្រឡះទៅនឹងគោលការណ៍ប្រជាធិបតេយ្យ ដែលតំណាងរាស្ត្រ និងប្រជាពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ មិនមែនជាចំណាប់ខ្មាំងរបស់អ្នកនយោបាយផ្តាច់ការនោះទេ។ ជាការដាក់ស្តែងករណីបោះឆ្នោតអនុម័តច្បាប់ធម្មនុញ្ញបន្ថែម ដើម្បីបង្កើតរដ្ឋាភិបាលកញ្ចប់ និងបោះឆ្នោតគាំទ្ររដ្ឋាភិបាលអាណត្តិទី៣[៥៤]។

**ការបង្កើតស្ថាប័ន និងមុខតំណែងថ្មីៗ**

ដូចជាការបង្កើតច្បាប់និងការអនុវត្តន៍ច្បាប់ដែរ ការបង្កើតស្ថាប័ននិងមុខតំណែងថ្មី ក៏អាស្រ័យទៅលើការចាំបាច់ខាងនយោបាយនិងតម្រូវការរបស់គណបក្សដែរ ដូចជាស្ថាប័នព្រឹទ្ធសភាជាដើម គឺគេបង្កើតឡើងគ្រាន់តែដើម្បីឲ្យមានអាសនៈបន្ថែមសម្រាប់ឲ្យមន្ត្រីជាន់ខ្ពស់ក្នុងគណបក្សអង្គុយឲ្យសក្តិសមនឹងឋានៈ និងកិត្តិយសនោះប៉ុណ្ណោះ។ ឯការបង្កើតស្ថាប័នមួយនេះរដ្ឋត្រូវចំណាយថវិកាជាតិអស់រាប់លានដុល្លារ។ បើនិយាយពីអត្ថប្រយោជន៍វិញគ្មានអ្វីសំខាន់ឡើយ ព្រោះថាក្នុងការធ្វើច្បាប់អ្វីមួយ បើរដ្ឋសភាអនុម័តហើយដោយត្រូវបញ្ជូនមកឲ្យព្រឹទ្ធសភាត្រួតពិនិត្យម្តងទៀតនោះ ទោះបីព្រឹទ្ធសភាយល់ទាស់ត្រង់ប្រការណាមួយហើយបញ្ជូនត្រឡប់ទៅរដ្ឋសភាវិញក៏រដ្ឋសភានៅតែអនុម័តយកតាមច្បាប់ដើមដែលគេអនុម័តហើយនោះដដែល[៥៥]។

យើងក្រឡេកមើលក្នុងការបង្កើតរដ្ឋាភិបាលសម្ព័ន្ធភាពម្តងៗ គេត្រូវបង្កើតមុខតំណែងមួយចំនួនសម្រាប់ឲ្យសមាជិកគណបក្សគេកាន់កាប់តាំងពីក្រសួងរហូតដល់ស្រុក ម្លោះហើយក្រសួងនីមួយៗក្រៅពីរដ្ឋមន្ត្រីចេញ អាចមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការរហូតដល់៥ ទៅ ៦រូប។ នាយកដ្ឋាននីមួយៗក៏អាចមានអនុប្រធានពី៥ ទៅ ៦រូប ដែរ។ ចំណែងរដ្ឋបាលខេត្ត និងស្រុក ក៏មានសភាពដូចគ្នានេះដែរ។ ទាំងអស់នេះសុទ្ធតែបន្ថែមទៅលើរចនាសម្ព័ន្ធដែលមានស្រាប់។ រចនាសម្ព័ន្ធរដ្ឋបាល ដែលមានមាឌធំហួសពីសេចក្តីត្រូវការស្រាប់ទៅហើយក៏កាន់តែរីកធំៗឡើងថែមទៀត។ មន្ត្រីកូតាបន្ថែមមួយចំនួនមិនសូវមានការងារធ្វើទេ ដោយមន្ត្រីចាស់ដែលមានស្រាប់គេរើសអើង ប្រកាន់បក្សពួកគេមិនចែកការងារឲ្យធ្វើ។ អ្នកថ្មីច្រើនតែទៅអង្គុយកេះក្រចក បង្គ្រប់ម៉ោង និងចាំបើកប្រាក់ខែប៉ុណ្ណោះ។ ទាំងនេះហើយសុទ្ធតែត្រូវការចំណាយថវិកាជាតិ ដើម្បីបើកប្រាក់ខែឲ្យអ្នកទាំងអស់នោះ។ លើសពីនេះនៅក្នុងសង្គមកម្ពុជា ការបញ្ជាក់ឲ្យឃើញពីឧបសគ្គនៃការរើសអើងបញ្ហានយោបាយក៏លេចធ្លោបំផុត។ ចំពោះអ្នកនៅក្រោមបង្គាប់ដែលចេញមកពីគណបក្សនយោបាយខ្លាំងមិនស្តាប់បង្គាប់ថៅហ្វាយនាយ ដែលមកពីគណបក្សខ្សោយជាងខ្លួនទេ។ ស្ថានភាពបែបនេះបំផ្លាញអំណាចឋានានុក្រមដូចរឿងខ្ទង់ដែរ។ ឧទាហរណ៍ ក្នុងខេត្តមួយមានអភិបាលខេត្តចេញមកពីគណបក្សខ្សោយ និងអភិបាលរងខេត្តមកពីគណបក្សខ្លាំង។ បើអភិបាលខេត្ត មិនប៉ិនប្រសប់ខ្វះការពិសោធន៍ និងចាត់ការតែតាមផ្លូវច្បាប់សុទ្ធសាធពេក ឬខំសម្តែងឫកពារជាថៅហ្វាយធំពេក ក្នុងការងារជាក់ស្តែងអភិបាលរងខេត្តនោះអាចខ្វាស់ការងារមិនឲ្យធ្វើអ្វីកើត

[៥៤] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ព្រឹត្តិបត្រស្រាវជ្រាវ ឆ្នាំទី១៣ លេខ១៣៣ ខែកញ្ញា-តុលា ឆ្នាំ២០០៦ ទំព័រ ១០

[៥៥] ដ.ឯ.ម ទំព័រ ១១

ដោយសារគេអាងគ្នាគណបក្សរបស់គេនៅពាសពេញក្នុងសាលាខេត្ត[៥៦]។

## ៣.២.សិទ្ធិសេរីភាពខាងនយោបាយ

### ៣.២.១ សេរីភាពនៃការបញ្ចេញមតិ

សេរីភាពបញ្ចេញមតិ ឬនៅប្រទេសបារាំងក៏ដូចជានៅសហរដ្ឋអាមេរិកក្ដី និងបណ្ដាប្រទេសដឹកនាំបែបប្រជាធិបតេយ្យដទៃទៀតក្ដី ត្រូវគេយល់ថា ជាសេរីភាពក្នុងការទាក់ទង គឺជាសេរីភាពក្នុងការគិត សេរីភាពក្នុងការជឿ សេរីភាពក្នុងការប្រកាន់យកការពិតរបស់ខ្លួន ឬសេរីភាពក្នុងការរំលែកការយល់ដឹង ឬទស្សនៈរបស់ខ្លួន។ សិទ្ធិសេរីភាពនៅក្នុងប្រព័ន្ធប្រជាធិបតេយ្យ គឺជាអំណាចដែលអាចធ្វើអ្វីគ្រប់បែបយ៉ាង ដោយមិនរំខានដល់អ្នកដទៃ។ ទាំងនេះ គឺជាគោលការណ៍ជាសារវន្តរបស់សង្គមសេរី ដូចដែលត្រូវបានចែងក្នុងមាត្រា៤ នៃសេចក្ដីថ្លែងការណ៍ឆ្នាំ១៧៨៩ ស្ដីអំពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ដែលខ្លឹមសារមានលក្ខណៈបំផុសគំនិតឲ្យមនុស្សមានសិទ្ធិបង្កើតអាកប្បកិរិយាផ្ទាល់ខ្លួន និងធ្វើសកម្មភាពគ្រប់វិស័យតាមបំណងរបស់ខ្លួន ដោយមិនបន្ទាបតម្រូវការខាងសីលធម៌ដែលនិយមន័យ សេរីភាពបានកំណត់ក្នុងមាត្រា៤ នៃសេចក្ដីថ្លៃការណ៍ជាសកល។ សព្វថ្ងៃគ្រប់សន្ធិសញ្ញាអន្តរជាតិទាំងអស់ ដែលនិយាយពីការការពារសិទ្ធិមនុស្ស និងស្ទើរគ្រប់រដ្ឋទាំងអស់បានចែងអំពី "សិទ្ធិបញ្ចេញមតិដោយសេរី" បន្ថែមទៅលើ "សិទ្ធិមិនឲ្យមានការព្រួយបារម្ភ ដោយសារមតិរបស់ខ្លួន"។ ដូចជា ករណីនៃមាត្រា១៩ នៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីអំពីសិទ្ធិមនុស្ស មាត្រា១៩ នៃកតិកាសញ្ញាអង្គការសហប្រជាជាតិឆ្នាំ១៩៦៦និងមាត្រា១០នៃអនុសញ្ញាអឺរ៉ុប ស្ដីអំពីសិទ្ធិនុស្ស។ នៅក្នុងសេចក្ដីសម្រេចរបស់តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុបនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៦ រវាង HANDYSYDE និងចក្រភពអង់គ្លេស តុលាការបានកំណត់ថា សេរីភាពក្នុងការបញ្ចេញមតិនេះជាមូលដ្ឋានដ៏សំខាន់នៃសង្គមប្រជាធិបតេយ្យ ហើយក៏ជាលក្ខខណ្ឌដ៏ចម្បងមួយ សម្រាប់ការរីកចម្រើននៃសង្គមនីមួយៗ។ ចំណែកមាត្រា១០ នៃសេចក្ដីថ្លែងការណ៍ជាសកល ស្ដីអំពីសិទ្ធិមនុស្ស និងពលរដ្ឋ ឆ្នាំ១៧៨៩ បានចែងយ៉ាងច្បាស់ថា "ការទាក់ទងដោយសេរីនៃគំនិត និងមតិ គឺជាទ្រព្យដែលមានតម្លៃបំផុតសម្រាប់មនុស្ស ដូច្នេះ ពលរដ្ឋគ្រប់រូបអាចនិយាយ អាចសរសេរ និងអាចបោះពុម្ពផ្សាយដោយសេរី" ប៉ុន្តែនៅចុងបញ្ចប់នៃមាត្រានេះ គឺបានចែងផងដែរ ចំពោះករណីលើកលែង ដូចជាការរំលោភបំពានលើសេរីភាពដែលបានកំណត់ដោយច្បាប់។

ប្រជាពលរដ្ឋគ្រប់ៗរូបនៅក្នុងសង្គមប្រជាធិបតេយ្យ មានសិទ្ធិសេរីភាពពេញលេញក្នុងការចូលរួមនៅក្នុងកិច្ចការប្រទេសជាតិរបស់ខ្លួន ដោយធ្វើជាភ្នាក់ងាររដ្ឋការបម្រើក្នុងក្រសួងនានា ដូចជា ធ្វើទាហ៊ាន ឬនគរបាល ឬឈរឈ្មោះជាតំណាងរាស្ត្រ ឬចូលរួមក្នុងពិធីបោះឆ្នោត ដើម្បីជ្រើសរើសអ្នកធ្វើការជូនជាតិតាមចិត្តរបស់ខ្លួនផ្ទាល់។ បើពុំនោះសោតទេ ធ្វើជាពលរដ្ឋធម្មតាដែលមានសិទ្ធិ ដើម្បីបោះឆ្នោតជ្រើសរើសតំណាងរាស្ត្ររបស់ខ្លួនដោយសេរី ព្រមទាំងអាចទទួលការគ្រប់គ្រងពីរដ្ឋាភិបាលស្មើៗគ្នា។ ប៉ុន្តែការអនុវត្តន៍បាន

[៥៦] សាយ បូរី៖ វិទ្យាសាស្ត្ររដ្ឋបាល ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ ១៩២

យ៉ាងណាៗ អាស្រ័យទៅលើច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេស និងប្រពៃណីនៃជាតិនីមួយៗ។ ករណីមានរបបផ្តាច់ការ សិទ្ធិសេរីភាពទាំងនេះត្រូវគេជាន់ឈ្លីចោលទាំងអស់។ សូម្បីតែនៅក្នុងកាលៈទេសៈធម្មតាក៏ដោយ ក៏នៅតែមានប្រទេសជាតិជាច្រើនពុំអាចជានាឲ្យមានការបោះឆ្នោតដោយសេរីនិងសមរម្យទេ ពោលគឺក្នុងឱកាសបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រម្តងៗ តែងតែមានការបម្ភិតបម្ភ័ ការគាបសង្កត់ ឬការសូកប៉ាន់ ការទិញសន្លឹកឆ្នោត ដែលបណ្តាលឲ្យមានការរអាក់រអួលដល់សិទ្ធិក្នុងការជ្រើសរើសដោយសេរីរបស់ពលរដ្ឋ។ លទ្ធផលដែលលេចចេញអំពីការបោះឆ្នោតបែបនេះ មិនអាចធ្វើជាតំណាងឆន្ទៈរាស្ត្របានឡើយ[៥៧]។ សិទ្ធិនយោបាយ ដូចជាសេរីភាពក្នុងការមានមតិយោបល់ និងសេរីភាពក្នុងការផ្លាស់ប្តូរយោបល់ និងព័ត៌មាន គឺជាបញ្ហាសំខាន់បំផុតសម្រាប់ពង្រឹងរដ្ឋាភិបាលប្រជាធិបតេយ្យ និងនីតិអាជ្ញា[៥៨]។ លទ្ធិប្រជាធិបតេយ្យ ទាមទារឲ្យមានស្ថេរភាពក្នុងការបញ្ចេញមតិ។ សេរីភាពនេះ មិនមែនមានន័យថា អានាធិបតេយ្យទេ។ សេរីភាពត្រូវធ្វើឡើងដោយមានព្រំដែនកំណត់ ដែលស្របទៅតាមច្បាប់នីតិរដ្ឋ។ សេរីភាព ត្រូវធ្វើឡើងដោយមានការទទួលខុសត្រូវអមដោយសីលធម៌ទៀតផង។ តម្រូវការចាំបាច់ជាមូលដ្ឋានមួយក្នុងចំណោមតម្រូវការនានារបស់មនុស្ស គឺចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត។ ដោយសារតែមនុស្សមានតម្លៃដូចគ្នា និងមនុស្សដទៃទៀត នោះមតិរបស់បុគ្គលម្នាក់ក៏មានតម្លៃដូចមតិអ្នកដទៃទៀតដែរ។ គោលគំនិតនៃសង្គមពហុនិយម គឺអាស្រ័យលើគំនិតបែបនេះវាធ្វើឲ្យសង្គមមានភាពរស់រវើក ចម្រុះពណ៌ និងកាន់តែរឹងមាំ នៅពេលសមាជិករបស់ខ្លួនទាំងអស់អាចចូលរួមចំណែកផ្តល់គំនិតនិងទស្សនៈ។ ការស្តាប់មើលមតិទាំងអស់ បង្កើតឲ្យមានឱកាសរកឃើញដំណោះស្រាយត្រឹមត្រូវសម្រាប់បញ្ហានានានៃសង្គម វាក៏បង្កើតឱកាសធ្វើការសម្រេចចិត្តនានាឲ្យបានត្រឹមត្រូវផងដែរ។ ការពឹងផ្អែក លើទស្សនៈតែមួយជាសញ្ញានៃការខ្វះគតិបណ្ឌិត ពីព្រោះបទពិសោធន៍បង្រៀនថា ភ្នែកបួនមើលឃើញច្រើន ជាងភ្នែកពីរ។ ការទប់ស្កាត់ទស្សនៈដទៃ ក៏ជាសញ្ញានៃភាពទន់ខ្សោយ និងភ័យខ្លាច ពីព្រោះវាបង្ហាញថា អ្នកគាបសង្កត់គេមិនអាចលឺ និងអត់ធនចំពោះមតិដទៃទៀត និងមិនមានម្ចាស់ការខ្លួនឯងគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងការប្រជែងមតិដោយសេរី[៥៩]។ មូលដ្ឋាននៃរដ្ឋធម្មនុញ្ញខ្មែរ គឺជាការបើកចំហដោយសេរី អនុញ្ញាតឲ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសេរីភាពជាសារវន្តខាងមតិយោបល់ ជាជម្រើសក្នុងការចូលរួមចលនានយោបាយ និងសេរីភាពដទៃទៀត ដោយគ្មានការភ័យខ្លាច ឬរារាំងតាមរូបភាពណាមួយពីអាជ្ញាធររដ្ឋាភិបាលឡើយ។

ជាទូទៅសេរីភាពនៃការបញ្ចេញមតិ គឺជាសិទ្ធិក្នុងការថ្លែងពីគំនិតដែលច្បាប់បានអនុញ្ញាតនៅក្នុងសង្គមប្រជាធិបតេយ្យ ហើយសិទ្ធិនេះ គឺជាសិទ្ធិដ៏មានតម្លៃជាងសិទ្ធិណាៗទាំងអស់។ សមត្ថភាពនិយាយថ្លែងអំពីគំនិតរបស់ខ្លួន ដើម្បីជំទាស់ទៅនឹងក្រិត្យក្រមនយោបាយ នៅក្នុងពេលដែលគេរិះគន់គោលនយោបាយរបស់រដ្ឋាភិបាល ដោយគ្មានភ័យខ្លាចចំពោះការប្រឆាំងតបវិញរបស់រដ្ឋ គឺជាភាពខុសគ្នាដ៏សំខាន់មួយរវាងជីវិតនៅក្នុង

[៥៧] អង្គការវីដីលេន អង្គការរក្សាការពារសិទ្ធិមនុស្ស នៃកម្ពុជា ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ២៣

[៥៨] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យៈ សិទ្ធិមនុស្ស ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ ៣៦

[៥៩] សេរីភាពបុគ្គល និងកម្រងសិទ្ធិមនុស្ស របស់សភាអាមេរិក ទំព័រ ៣៤

ប្រទេសប្រជាធិបតេយ្យ និងប្រទេសផ្តាច់ការ។ បុគ្គលគ្រប់រូបមានសិទ្ធិប្រកាន់យកមតិដោយគ្មានការជ្រៀតជ្រែកដោយសេរី បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាព ក្នុងការបញ្ចេញយោបល់។ សិទ្ធិនេះត្រូវរាប់ទាំងសេរីភាពក្នុងការស្វែងរកព័ត៌មាន ទទួលព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន ព្រមទាំងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែនឡើយ ទាំងតាមផ្ទាល់មាត់ក្តី តាមការសរសេរ ឬបោះពុម្ពក្តី តាមទម្រង់សិល្បៈក្តី ឬតាមរយៈចរន្តផ្សាយព័ត៌មានដទៃទៀតក្តី[១០០]។ សេរីភាពនៃការបញ្ចេញមតិ គឺជាកូនសោដ៏សំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យ វាជាសិទ្ធិរបស់ពលរដ្ឋ ដើម្បីចូលរួមក្នុងកិច្ចការប្រយោជន៍រួមលើការជជែកវែកញែកជាសាធារណៈយ៉ាងគគ្រឹកគគ្រេង ការសម្រេចចិត្តជាចំហ និងការដោះដូរដោយសេរីអំពីគំនិតយោបល់ និងព័ត៌មាន។ សេរីភាពនេះ មានសារៈសំខាន់សម្រាប់អភិវឌ្ឍចំណេះដឹង និងការយោគយល់គ្នាក្នុងចំណោមប្រជាពលរដ្ឋ។ សេរីភាពដែលទទួលបានក្នុងចំណោមប្រជាពលរដ្ឋ វាជំរុញឲ្យមានការអត់ឱនឲ្យគ្នា និងកិច្ចសហប្រតិបត្តិការផងដែរ។ សេរីភាពក្នុងការទទួលបានព័ត៌មាន ធានាឲ្យមានតម្លាភាព និងការទទួលខុសត្រូវរបស់ស្ថាប័នប្រជាធិបតេយ្យ ជាពិសេសរបស់រដ្ឋាភិបាល។ បើគ្មានសេរីភាពនៃការប្រាស្រ័យទាក់ទងនោះ រដ្ឋនឹងថ្លង់ ចំណែកប្រជាជនក៏ថ្លង់ដែរ។ ឯគំនិតប្រជាធិបតេយ្យអាច ស្ថិតស្ថេរទៅបានអាស្រ័យទៅលើសេរីភាពនៃការផ្លាស់ប្តូរមតិ។ កាលណាគ្មានការបញ្ចេញមតិផ្នែកនយោបាយដោយសេរី វានឹងគ្មានសង្គមប្រជាធិបតេយ្យទេ។ ដូច្នេះ ប្រទេសប្រកាន់យករបបប្រជាធិប-តេយ្យ មានលក្ខណៈពិសេសត្រង់ចំណុចមួយ គឺថាប្រជាធិបតេយ្យ បានផ្តល់នូវការសម្តែងមតិពីប្រជារាស្ត្រក្នុងការទិតៀនស្ថាបនាលើបញ្ហាសំខាន់ៗ ដែលកើតមាននៅក្នុងសង្គម។ ការសម្តែងមតិក្នុងសង្គមប្រជាធិបតេយ្យមានន័យថា មនុស្សមានសេរីភាពនិយាយស្តី តែងតែជជែកដេញដោលផុសផុល ការប្រមូលផ្តុំជួបជុំធ្វើការបោះឆ្នោតគាំទ្រ ឬជំទាស់ដើម្បីធានាបាននូវយុត្តិធម៌សម្រាប់ជនគ្រប់រូប។ ហេតុដូច្នេះហើយ ទើបការសម្តែងមតិក្នុងសង្គមប្រជាធិបតេយ្យត្រូវបានគេចាត់ទុកថា ជាសរសៃឈាមជីវិតនៃលទ្ធិប្រជាធិបតេយ្យ។ ដូច្នេះ លំហូចូលដោយគ្មានកម្រិតនៃមតិ និងដំណឹងដែលគេហៅថា សេរីភាពសារព័ត៌មានក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកអំពីបញ្ហារបស់គេ គឺជាការសម្រេចចិត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងត្រូវមានសេរីភាពខាងការសម្តែងមតិជាមុខសិន។ ត្រង់ចំណុចនេះអ្នកនិយម អំណាចផ្តាច់ការ និងអ្នកនិយមរិះគន់លទ្ធិប្រជាធិបតេយ្យគេយល់ច្រឡំថា ប្រជាធិបតេយ្យ ខ្វះអំណាចគាបសង្កត់ផង និងអំណាចដឹកនាំផង។ មូលដ្ឋានទស្សនៈបែបនេះពិតជាយល់ខុសស្រឡះ ព្រោះប្រជាធិបតេយ្យទាមទារឲ្យកម្រិតអំណាចរបស់រដ្ឋាភិបាលមិនមែនទាមទារឲ្យរដ្ឋាភិបាលទន់ខ្សោយនោះឡើយ។ ទិដ្ឋភាពនៃប្រជាធិបតេយ្យ ដែលធ្វើឲ្យមានភាពរស់រវើកនោះ គឺជាការជជែកដេញដោយ ខ្វែងគំនិតគ្នា និងការសម្រុះសម្រួលគំនិតគ្នាដែលអ្នករិះគន់យល់ថា ជាចំណុចខ្សោយនោះ តាមពិត

[១០០] មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

គឺជាកម្លាំងមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ[១០១]។ នៅក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្ស ដែលមានប្រជាជនរាប់លាននាក់(ឧទាហរណ៍ៈប្រជាជនកម្ពុជាចំនួន១៤លាននាក់)ការប្រាស្រ័យទាក់ទងដោយផ្ទាល់និងការដោះដូរគំនិតយោបល់នានាជាមួយគ្នាទៅវិញទៅមក មិនអាចធ្វើទៅបានឡើយ។ ដូច្នេះប្រជាជនចូលរួមផ្ទេរអំណាចរបស់គេក្នុងការសម្រេចចិត្ត(តាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌)ទៅឲ្យតំណាងរបស់ខ្លួន)។ តំណាងទាំងនេះ(ឧទាហរណ៍ៈ ក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិករដ្ឋសភា និងព្រឹទ្ធសភា)តាក់តែងច្បាប់។ រដ្ឋាភិបាលជាអ្នកអនុវត្តច្បាប់នានា ចំណែកឯតុលាការជាអ្នកត្រួតពិនិត្យ ការអនុវត្តន៍ច្បាប់។ តំណាងទាំងអស់ជាអ្នកទទួលខុសត្រូវចំពោះប្រជាជន។ ដូច្នេះហើយព័ត៌មានផ្សព្វផ្សាយដោយសេរី រវាងតួអង្គទាំងនេះមានសារសំខាន់ណាស់សម្រាប់សង្គមប្រជាធិបតេយ្យមួយដូចជាៈ[១០២]

ក-ប្រជាពលរដ្ឋត្រូវតែទទួលបានព័ត៌មានដោយសេរីអំពីសង្គមរបស់គេនិងរាល់ប្រធានបទ និងតួអង្គដែលពាក់ព័ន្ធ(ឧទាហរណ៍ៈ កម្មវិធីរបស់គណបក្សនយោបាយ, ពង្រាងច្បាប់, អំពីគោលនយោបាយរដ្ឋាភិបាល, កិច្ចការប្រជុំ ការកាត់សេចក្តី និងដំណើរគ្រប់បែបយ៉ាង)។ ពុំនោះសោតទេ ប្រជាពលរដ្ឋមិនអាចជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី មិនអាចចូលរួមក្នុងការតាក់តែងច្បាប់តាមរយៈការពិភាក្សា មិនអាចត្រួតពិនិត្យអំណាចនីតិប្រតិបត្តិរបស់រដ្ឋាភិបាលខ្លួន និងមិនមានឥទ្ធិពលលើការអនុវត្តន៍ច្បាប់ដោយតុលាការ ដែលសម្រេចសេចក្តីក្នុងនាមប្រជាពលរដ្ឋបានទេ។

ខ-ម្យ៉ាងទៀតប្រជាពលរដ្ឋត្រូវមានលទ្ធភាពបញ្ចេញមតិយោបល់របស់ខ្លួន អំពីរឿងរ៉ាវទាំងអស់នេះ ផ្តល់យោបល់ពិភាក្សាជាមួយអ្នកដទៃទៀតនិងចូលរួមផ្តល់យោបល់របស់ខ្លួន អំពីដំណោះស្រាយបញ្ហាសង្គម នៅក្នុងការសម្រេចចិត្ត។

មនុស្សជាច្រើន និងរដ្ឋាភិបាលនានា និងបុគ្គលឯកជនផ្សេងៗ មិនយល់ពិតប្រាកដអំពីតម្លៃដ៏ធំធេងនៃលំហូព័ត៌មានដោយសេរីសម្រាប់សង្គមឡើយ។ គេទុកសេរីភាពបញ្ចេញមតិជាឧបសគ្គ ឬជាការគំរាមកំហែងមួយដល់នយោបាយ និងមធ្យោបាយធ្វើជំនួញរបស់ខ្លួន។ គេមិនចង់បានការពិភាក្សាមួយដែលមានលក្ខណៈរិះគន់បើកចំហ និងមានតម្លាភាព ដែលបង្កើនការទទួលខុសត្រូវរបស់ពួកគេឡើយ។ ប៉ុន្តែពេញចិត្តឲ្យប្រជាជនធ្វើថ្លង់និងធ្វើគ ឬគេមិនយល់ពីអត្ថន័យនៃពហុនិយម និងគិតថាមានតែទស្សនៈរបស់ខ្លួនប៉ុណ្ណោះដែលសំខាន់។ ហេតុដូច្នេះហើយ គេព្យាយាមទប់ស្កាត់សេរីភាពបញ្ចេញមតិដោយមធ្យោបាយផ្សេងៗដូចជាៈ វិធានការអាក្រក់បំផុត គឺសម្លាប់ ឬចាប់ខ្លួនតាមអំពើចិត្ត ឬការគំរាមកំហែងដោយផ្ទាល់ដល់អ្នកកាសែត ឬមនុស្សដទៃទៀតដែលព្យាយាមប្រាស្រ័យទាក់ទងគ្នាដោយសេរី ឬច្បាប់នានាត្រូវបានប្រើ ដើម្បីទប់ស្កាត់សេរីភាពបញ្ចេញមតិ ឧទាហរណ៍ៈច្បាប់ស្តីពីការបរិហារកេរ្តិ៍ជាដើម។ នៅក្នុងទស្សនៈនៃរដ្ឋាភិបាលប្រជាធិបតេយ្យមួយចំនួន

---

[១០១] ព្រឹត្តិបត្រអ្នកជា ឆ្នាំទី១៦ លេខ៣១៣ ខែឧសភា ឆ្នាំ២០០៩, ទំព័រ ១-២

[១០២] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យៈ សិទ្ធិមនុស្ស ឆ្នាំ២០០៤, ទំព័រ ៣៧

ទោះបីជាចង់បាននូវការសាទរ សរសើរក៏ដោយ ក៏បែបផែនប្រជាធិបតេយ្យពិតៗត្រូវបានសម្តែងចេញឡើងនូវភាពស្មោះត្រង់ទទួលស្គាល់នូវអ្វីដែលជាកំហុស។ គេត្រូវតែហ៊ានចុះចេញពីតំណែងចំពោះអំពើពុំគប្បីអ្វីមួយរបស់គេដូចជាការងារអេសកម្មផ្ទាល់របស់គេ ឬដោយសារការដោះស្រាយពុំបានសម្រេចលទ្ធផលល្អនូវបញ្ហាចំពោះមុខ។ សិទ្ធិបញ្ចេញមតិជាសាធារណៈ សិទ្ធិនេះជាការសម្តែងមតិឲ្យមជ្ឈដ្ឋានទូទៅបានដឹង និងយល់អំពីឆន្ទៈ អំពីការទាមទារដោយសន្តិវិធីដោយលើកយកបញ្ហាទុក្ខកង្វល់ និងក្តីបារម្ភផ្តល់ជូនអាជ្ញាធររាជរដ្ឋាភិបាលនៅគ្រប់ជាន់ថ្នាក់ ដែលជាអ្នកបម្រើរាស្ត្រឲ្យជួយធ្វើការដោះស្រាយ ពីព្រោះថា អ្នកសម្តែងមតិជាដៃគូរដ៏សំខាន់នៅក្នុងការចូលរួមដោះស្រាយបញ្ហាសង្គមទាំងអស់គ្នា។ បើទោះបីសិទ្ធិសេរីភាពប្រជាពលរដ្ឋមានការបើកចំហតាមរយៈការអនុញ្ញាតឲ្យបង្កើតគណបក្សនយោបាយ និងសមាគមដោយពុំមានឧបសគ្គរារាំង ធ្ងន់ធ្ងរក៏ដោយ តាមការពិតជាក់ស្តែងនៅក្នុងស្ថានភាពបច្ចុប្បន្នសម្រាប់ប្រទេសកម្ពុជាយើង ដែលត្រូវបានគេចាត់ទុកថា ជាប្រជាធិបតេយ្យនៅក្មេងខ្ចី នៅមានបញ្ហាប្រឈមជាច្រើននៅឡើយ ចំពោះការផ្តល់សេរីភាពនៃការបញ្ចេញមតិតាមទីសាធារណៈ ឬការតស៊ូមតិតាមទីសាធារណៈ តាមគោលការណ៍ប្រជាធិបតេយ្យដែលប្រជាពលរដ្ឋដាច់ខាតត្រូវតែសម្តែងអំណាចរបស់ខ្លួនតាមមធ្យោបាយសន្តិវិធីកិត្តិយស ហាក់ដូចជានៅតូចចង្អៀត និងត្រូវបានរឹតបន្តឹងកាន់តែខ្លាំងឡើងៗ។

ចាប់តាំងពីខែមេសា ឆ្នាំ២០០៩ នេះមកមានបណ្តឹងព្រហ្មទណ្ឌដាច់ដោយឡែកពីគ្នាមិនតិចជាងប្រាំបីទេ ពីបទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិត ត្រូវបានប្តឹងទៅតុលាការនានា ដោយអាជ្ញាធរសាធារណៈជាន់ខ្ពស់មួយចំនួនរបស់រាជរដ្ឋាភិបាលប្រឆាំងនឹងការរិះគន់រដ្ឋាភិបាល។ បណ្តឹងមួយក្នុងចំណោមបណ្តឹងនោះត្រូវបានធ្វើឡើងដោយបុគ្គលដែលអះអាងថា កើតទុក្ខមិនសុខចិត្ត តែផ្ទុយទៅវិញ បណ្តឹងនោះត្រូវបានធ្វើឡើងជាលក្ខណៈទូទៅមួយក្នុងនាមរដ្ឋាភិបាល។ បច្ចុប្បន្ន ករណីទាំងនេះ កំពុងស្ថិតក្នុងការស៊ើបអង្កេតដោយលោក សុខ រឿន ព្រះរាជអាជ្ញារងអមតុលាការរាជធានីភ្នំពេញ។ ការកើនឡើងថ្មីៗនេះក្នុងការប្រើប្រាស់បណ្តឹងព្រហ្មទណ្ឌពីបទបរិហារកេរ្តិ៍និងផ្សព្វផ្សាយព័ត៌មានមិនពិត ដែលភាគច្រើនបានប្តឹងប្រឆាំងទៅនឹងអ្នកនយោបាយ អ្នកសារ-ព័ត៌មាន និងអ្នកឯទៀតដែលសម្តែងមតិរបស់ខ្លួនដោយសន្តិវិធីអំពីបញ្ហាទាំងឡាយ ដើម្បីផលប្រយោជន៍សាធារណៈ បានគំរាមកំហែងដល់ការជជែកពិភាក្សា និងផ្លាស់ប្តូរមតិយោបល់គ្នាអំពីបញ្ហាទាំងនេះបានដោយសេរីនោះ។ ទង្វើទាំងនេះធ្វើឲ្យប៉ះពាល់ដល់សេរីភាពក្នុងការសម្តែងមតិយោបល់ ដែលរដ្ឋធម្មនុញ្ញធានាការពារ ហើយជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តន៍សិទ្ធិ សេរីភាពប្រជាពលរដ្ឋ និងសិទ្ធិសេរីភាពនយោបាយ។ ការអនុវត្តន៍សិទ្ធិសេរីភាពនេះ គឺជាការវាស់ស្ទង់មួយដ៏សំខាន់អំពីកម្រិតនៃការការពារ និងការគោរពសិទ្ធិមនុស្សផង និងជាពិសេស គឺជាការឆ្លុះបញ្ចាំងអំពីការប្រើប្រាស់អធិបតីស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យ សេរីពហុបក្សផង។ គ្មានជនណាម្នាក់ត្រូវភ័យខ្លាចក្នុងការសម្តែងមតិរបស់ខ្លួនដោយសន្តិវិធីនោះទេ ឲ្យតែមិនបំពានលើសិទ្ធិរបស់អ្នកដទៃ។ ការបំពិតសិទ្ធិសេរីភាពក្នុងការសម្តែងមតិយោបល់តាមរយៈការប្រើប្រាស់ ឬការគំរាមកំហែងចាត់វិធានការតាមផ្លូវច្បាប់ ទោះជាបណ្តឹងរដ្ឋប្បវេណី ឬជាបណ្តឹងព្រហ្មទណ្ឌក្តី ជាពិសេសក្នុង

បរិបទមួយដែលតុលាការងាយនឹងរងឥទ្ធិពលពីអំណាចនីតិប្រតិបត្តិនោះ គឺជាការគំរាមកំហែងធ្ងន់ធ្ងរមួយដល់ការអភិវឌ្ឍន៍នៃលទ្ធិប្រជាធិបតេយ្យ ដែលអាចធ្វើឲ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងអស់រយៈពេល១៧ឆ្នាំកន្លងមកនេះ ក្នុងការកសាងឡើងវិញនូវបរិយាកាសមួយដែលអត់ឱននិងពហុបក្សនៅកម្ពុជា។ ទន្ទឹមនឹងនេះ សេរីភាពក្នុងការសម្តែងមតិយោបល់ មិនមែនគ្មានដែលកំណត់នោះទេសេរីភាពនេះ គួរតែបានប្រើប្រាស់ដោយសន្តិវិធីដោយគោរពចំពោះសេចក្តីថ្លៃថ្នូរអ្នកដទៃ និងមិនបង្កឲ្យមានអំពើហិង្សាឡើយ។ ច្បាប់អន្តរជាតិបញ្ជាក់ច្បាស់អំពីតុល្យភាពសមស្របរវាងសិទ្ធិសេរីភាពក្នុងការសម្តែងមតិយោបល់ និងការជជែកដោយសេរីអំពីបញ្ហាដែលជាផលប្រយោជន៍សាធារណៈ និងការការពារកិត្តិសព្ទរបស់បុគ្គល។ មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលជាផ្នែកមួយនៃច្បាប់កម្ពុជាចែងថា ការរឹតត្បិតណាមួយលើសេរីភាពក្នុងការសម្តែងមតិត្រូវកំណត់ជាច់ខាតដោយច្បាប់ និងដើម្បីគោរពសិទ្ធិ កិត្តិសព្ទរបស់អ្នកដទៃ ឬការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។ ដោយឡែកក្រោមច្បាប់អន្តរជាតិវាមិនគ្រប់គ្រាន់ទេ ដែលថាការជជែកខាងនយោបាយអំពីបញ្ហា ដែលជាផលប្រយោជន៍សាធារណៈត្រូវគេសម្តែងចេញជាពាក្យសម្តីខ្លាំងៗ ឬត្រូវគេមើលឃើញថា ជាការមិនគោរព ឬផ្ទុយទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាល សម្រាប់ការដាក់កម្រិតលើការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការសម្តែងមតិដែលស្របច្បាប់។ ការជជែកដោយចំហ និងមិនភ័យខ្លាចអំពីបញ្ហាដែលជាផលប្រយោជន៍សាធារណៈ ជាផ្នែកមួយ និងជាកញ្ចប់នៃដំណើរការលទ្ធិប្រជាធិបតេយ្យ។ ឯក្រោមរដ្ឋធម្មនុញ្ញកម្ពុជា រដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋរបស់ខ្លួន នូវគោលនយោបាយ និងការអនុវត្តន៍ទាំងឡាយរបស់ខ្លួន។ ដូច្នេះ សកម្មភាពទាំងនេះ ត្រូវតែបើកចំហឲ្យមានការពិនិត្យពិច័យការរិះគន់ និងការជជែកដេញដោលជាសាធារណៈ។ នៅជុំវិញពិភពលោកនេះមានការទទួលស្គាល់កាន់តែច្រើនឡើងៗថា ការជជែកខាងនយោបាយអំពីបញ្ហា ដែលជាផលប្រយោជន៍សាធារណៈត្រូវតែទទួលបានគោរពការពារ ហើយថាច្បាប់រដ្ឋប្បវេណីជាជាងច្បាប់ព្រហ្មទណ្ឌ គឺគ្រប់គ្រាន់សម្រាប់ការពារបុគ្គលជាជាងកិត្តិសព្ទរដ្ឋាភិបាលក្នុងករណីដ៏កម្របំផុតដែលករណីទាំងនេះត្រូវបានរំលោភបំពានដោយការជជែកដេញដោលខាងនយោបាយ។

ចំពោះសមាជិករដ្ឋសភា ច្បាប់អន្តរជាតិទទួលស្គាល់តួនាទីដ៏ពិសេសដែលជាសមាជិករដ្ឋសភាមានក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យនិងការរៀបចំឲ្យមានការសម្តែងមតិ និងការជជែកដេញដោលជាសាធារណៈ។ គោលបំណងដ៏សំខាន់នៃការផ្តល់អភ័យឯកសិទ្ធិនេះ គឺដើម្បីឲ្យសមាជិកសភាគ្រប់រូប អាចបំពេញភារកិច្ចរបស់ខ្លួជាតំណាងរាស្ត្រ និងជាអ្នកធ្វើច្បាប់ដោយគ្មានការភ័យខ្លាចមានការសងសឹក។ សភាជាកន្លែងមួយក្នុងសង្គមដែលបញ្ហាផ្សេងៗត្រូវបានពិភាក្សាដោះស្រាយ។ ការដកអភ័យឯកសិទ្ធិ ឬការគំរាមកំហែងដកអភ័យឯកសិទ្ធិសភាដោយគ្មានមូលហេតុសុពលភាពក្រៅតែពីបំភិតបំភ័យសមាជិកសភា និងបំបិទការជជែកខាងនយោបាយ ឬការជជែកផ្សេងទៀតបង្ហាញពីការមិនគោរព និងការប្រមាថចំពោះការជជែកដោយចំហ និងបែបប្រជាធិប-តេយ្យ។ គេគួរតែពិនិត្យពិចារណាចំពោះតែករណីនៃអំពើល្មើសធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ។

**ការវិវត្តន៍ខ្លះលើការសំដែងមតិកន្លងមកៈ**

រដ្ឋាភិបាលបានប្រើប្រាស់អំណាចច្បាប់ខាងបទល្មើសផ្សាយព័ត៌មានមិនពិត បរិហារកេរ្តិ៍ និងបទញុះញង់ក្នុងច្បាប់ព្រហ្មទណ្ឌ ដើម្បីរឹតបន្តឹងលើការបញ្ចេញមតិពាក់ព័ន្ធនឹងបញ្ហារសើបដូចជា បញ្ហាព្រំដែន អំពើពុករលួយ ការរំលោភយកដីធ្លី និងបញ្ហារសើបដទៃទៀត។

-ចាប់ពីខែតុលា ដល់ខែកញ្ញា ឆ្នាំ២០០៥ អ្នកគាំទ្រសិទ្ធិមនុស្សដ៏ល្បីល្បាញ ៨នាក់ ត្រូវបានចាប់ខ្លួន និងឃុំខ្លួនពីបទផ្សាយព័ត៌មានមិនពិត បរិហារកេរ្តិ៍ និងញុះញង់។ លោក ម៉ម សូណង់ដូរ ជាម្ចាស់ និងជាប្រធានវិទ្យុសំបុកឃ្មុំ ត្រូវបានចាប់ខ្លួនពីបទចាក់ផ្សាយបទសម្ភាសន៍ជាមួយនឹងសកម្មជនខ្មែរនៅបារាំង ដែលរិះគន់លើសន្ធិសញ្ញាព្រំដែនកម្ពុជា-វៀតណាម។ លោក រ៉ុង ឈុន ជាប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា ត្រូវបានចាប់ខ្លួនដោយសារការចេញសេចក្តីថ្លែងការណ៍ទាក់ទងនឹងសន្ធិសញ្ញាព្រំដែន។ លោក ម៉ែន ណាត ជាប្រធានសមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា និងលោក អៀ ចាន់ណា ជាអគ្គលេខាធិការរងនៃចលនានិស្សិត ដើម្បីប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខា លើសេចក្តីថ្លែងការណ៍នេះ បានរត់គេចខ្លួនទៅប្រទេសថៃ ហើយបច្ចុប្បន្នអ្នកទាំងពីរកំពុងរស់នៅអឺរ៉ុប។ លោក កឹម សុខា ជាអតីតប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានចាប់ខ្លួនទាក់ទងទៅនឹងផ្ទាំងប៉ាណូរបស់មជ្ឈមណ្ឌលក្នុងថ្ងៃប្រារព្ធទិវាសិទ្ធិមនុស្ស១០ធ្នូ។ លោក យ៉េង វីរៈ ជានាយកប្រតិបត្តិរបស់មជ្ឈមណ្ឌលអប់រំសម្រាប់សហគមន៍ត្រូវបានចាប់ខ្លួន៥ថ្ងៃមុនការចាប់ខ្លួនលោក ប៉ា ងួនទៀង ដែលពេលនោះជាប្រធានផ្នែកវិទ្យុរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ បន្ទាប់ពីមានសម្ពាធពីសហគមន៍ ជាតិ និងអន្តរជាតិ អ្នកដែលបានជាប់ឃុំខាងលើត្រូវបានដោះលែងនៅក្រៅឃុំ[១០៣]។

-នៅខែកញ្ញា ឆ្នាំ២០០៦ លោកទៀង ណារិទ្ធិ ជាគ្រូបង្រៀនខាងច្បាប់ និងនយោបាយនៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនៅក្នុងរាជធានីភ្នំពេញ ត្រូវបានបណ្តេញចេញពីតួនាទីដោយសារការសរសេរសៀវភៅរិះគន់ដល់រដ្ឋាភិបាល។ បន្ទាប់មកគាត់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និងត្រូវបានកាត់ទោសឲ្យជាប់គុករយៈពេលជាងពីរឆ្នាំ និងផាកពិន័យ។

-របាយការណ៍ដែលចេញផ្សាយដោយអង្គការឃ្លាំមើលសកលលោក(Global Witness) ដែលនិយាយពីការជាប់ពាក់ព័ន្ធរបស់មន្ត្រីជាន់ខ្ពស់ និងញាតិសន្តានរបស់ពួកគេក្នុងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ នៅកម្ពុជាត្រូវបានហាមឃាត់មិនឲ្យចែកផ្សាយកាលពីខែមិថុនា ឆ្នាំ២០០៧[១០៤]។

-ដោយសារលោក មឿង សុន ប្រធានអង្គការមូលនីធិទ្រទ្រង់អរិយធម៌ខ្មែរ បានធ្វើអត្ថាធិបាយរិះគន់ការដាក់ប្រព័ន្ធភ្លើងបំភ្លឺថ្មី ដែលគេតម្លើងនៅប្រាសាទអង្គរវត្ត ដោយលើកឡើងថា អំពូលនោះវាអាក្រក់មើល

[១០៣] លីកាដូៈ របាយការណ៍រួមរបស់អង្គការក្រៅរដ្ឋាភិបាលស្តីពី សេរីភាពបញ្ចេញមតិ និងការប្រជុំ សម្រាប់ការត្រួតពិនិត្យជាសកល តាមពេលកំណត់នៃការបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៧

[១០៤] ដ.ឯ.ម ទំព័រ ៨

ប៉ះពាល់ដល់តម្លៃជាសកលរបស់ប្រាសាទបុរាណ ដែលស្ថាបត្យករបុរាណខ្មែរបានស្ថាបនាឡើងដោយប្រើថ្មសុទ្ធសាធ ហើយកំដៅអាចធ្វើឲ្យប៉ះពាល់ដល់ជញ្ជាំងប្រាសាទអង្គរវត្ត[១០៥]។ យោងតាមបណ្តឹងរបស់រដ្ឋាភិបាល នៅក្នុងខែកក្កដា ឆ្នាំ២០០៩នេះ លោក មឿង សុន ត្រូវបានតុលាការក្រុងភ្នំពេញចោទប្រកាន់ពីបទញុះញង់ តាមមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌដោយកាត់ទោសឲ្យជាប់គុករយៈពេល២ឆ្នាំ និងពិន័យជាប្រាក់ប្រហែល ១.៧៥០ដុល្លារសហរដ្ឋអាមេរិក។

-នៅឆ្នាំ២០០៩ ចៅក្រមជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានគំរាមលោក មេធាវី មីសែល ផែសមែន(Michel Pestman) និងលោក អែនឌ្រូ ឡានូស៊្សី(Andrew Lanuzzi) ដែលជាអ្នកការពារក្តីឲ្យលោក នួន ជា ថានឹងទទួលការចាត់វិធានការតាមផ្លូវច្បាប់ បន្ទាប់ពីពួកគាត់បានស្នើតុលាការជាតិធ្វើការស៊ើបអង្កេតពីអំពើពុករលួយ។ មេធាវីមិនត្រូវបានលើកទឹកចិត្តក្នុងការបញ្ចេញមតិ ក្នុងការបន្ទោសបង្អាក់ចំពោះស្ថានភាពបច្ចុប្បន្នទេ ទោះបីនៅក្នុងថ្នាក់តុលាការឧក្រិដ្ឋអន្តរជាតិក្តីនកាត់នេះក៏ដោយ[១០៦]។

-នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ លោក ហង្ស ចក្រា ចាងហ្វាងកាសែតខ្មែរម្ចាស់ស្រុក ត្រូវបានចាប់ខ្លួនតាមដីការបង្គាប់ការឲ្យចាប់ខ្លួនរបស់តុលាការដំបូងរាជធានីភ្នំពេញ ជាប់ពាក់ព័ន្ធលើសំណុំរឿងព្រហ្មទណ្ឌ ដែលបានប្តឹងឡើងដោយមេធាវីរដ្ឋាភិបាល ក្រោមបទចោទប្រកាន់ថា បានផ្សព្វផ្សាយព័ត៌មាននៅថ្ងៃទី៥ ទី៧ ខែមេសា និងទី២១ ខែឧសភា ឆ្នាំ២០០៩ ធ្វើឲ្យប៉ះពាល់ដល់ស្ថិរភាពនយោបាយ ដោយសារអត្ថបទទាំងនោះបានសរសេរអំពីមេដឹកនាំរដ្ឋាភិបាល។ ចំណាត់ការបែបនេះ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ក៏បានចេញសេចក្តីថ្លែងការណ៍ថា ការប្រើប្រាស់ និងការរំលោភនៃបណ្តឹងបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសេរីភាពសារព័ត៌មាន ក្នុងការសម្តែងមតិយោបល់ ដែលរដ្ឋធម្មនុញ្ញធានាការពារ និងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ[១០៧]។ និយាយរួមនៅក្នុងឆ្នាំ២០០៩ មន្ត្រី ឬស្ថាប័នរដ្ឋាភិបាលកម្ពុជា មួយចំនួនបានប្តឹងតបតជាមួយអ្នកសម្តែងមតិប្រឆាំងជាមួយខ្លួនតាមរយៈតុលាការរាជធានី/ខេត្ត ដែលយ៉ាងហោចណាស់ក៏មានករណីប្តឹងផ្តល់ចំនួន២២ ដែលកំពុងដំណើរការក្នុងស្ថាប័នតុលាការនិងមន្ត្រីសហជីពប្រមាណ៥៨នាក់ ត្រូវបានបណ្តេញចេញពីការងារក្នុងរោងចក្រ ដោយសារតែពួកគេហ៊ានចេញមុខតវ៉ាចំពោះលក្ខខណ្ឌការងារជាមួយថៅកែរោងចក្រ។ ករណីនេះមិនឃើញមាន វិធានការផ្លូវការណ៍ណា ដើម្បីដោះស្រាយពីសមត្ថកិច្ចឡើយ។ អ្នកដែលបានបញ្ចេញទស្សនៈទិតៀន រិះគន់ដល់សកម្មភាពការងាររបស់រដ្ឋាភិបាល និងការទាមទារសិទ្ធិសេរីភាពនោះ មានមន្ត្រីសង្គមស៊ីវិល អ្នកតំណាងរាស្ត្រគណបក្សជំទាស់ និងអ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត បរិហារកេរ្តិ៍

[១០៥] ឌឹឃែមបូឌា ដេលី ថ្ងៃព្រហស្បតិ៍ ទី១៦ ខែកក្កដា ឆ្នាំ២០០៩, ជាភាសាខ្មែរ ទំព័រ ៤

[១០៦] លីកាដូៈ របាយការណ៍រួមរបស់អង្គការក្រៅរដ្ឋាភិបាលស្តីពី សេរីភាពបញ្ចេញមតិ និងការប្រជុំ សម្រាប់ការត្រួតពិនិត្យ ជាសកលតាមពេលកំណត់នៃការបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៨

[១០៧] សេចក្តីថ្លែងការណ៍របស់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩

និងបទញុះញង់ជាដើមពីរដ្ឋាភិបាល។ បើប្រៀបធៀបទៅនឹងអាណត្តិមុនៗ យើងសង្កេតឃើញហាក់បីដូចជា មាននិន្នាការរឹតត្បិត នូវសិទ្ធិសេរីភាពនេះក្រោយពេលបោះឆ្នោត និងការបង្កើតរដ្ឋាភិបាលរួមម្តងៗ។

ករណីខាងលើនេះ គឺជាឧទាហរណ៍ដែលបង្ហាញអំពើរបស់រដ្ឋាភិបាល ក្នុងការរឹតបន្តឹងលើសេរីភាពបញ្ចេញមតិ ដែលរំលោភលើសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១៩របស់ICCPR និងមាត្រា៣១ និង៤១នៃរដ្ឋធម្មនុញ្ញ។ ជាងនេះទៅទៀតច្បាប់ដែលប្រើ ឬក៏ករណីគំរាមកំហែងទាំងនេះ រួមមានបទញុះញង់ បទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតជាដើមនោះ បានរំលោភលើកាតព្វកិច្ចអន្តរជាតិ និងរដ្ឋធម្មនុញ្ញ។ មាត្រា៦២ នៅក្នុងច្បាប់អ៊ុនតាក់ និយាយពីបទព្រហ្មទណ្ឌ ក្នុងការផ្សាយព័ត៌មានមិនពិតថា "ពេលណាមានការចុះផ្សព្វផ្សាយ ឬការផ្សាយបន្តតាមមធ្យោបាយណាក៏ដោយនូវព័ត៌មានមិនពិត ព័ត៌មានប្រឌិត ព័ត៌មានក្លែងក្លាយ ឬដោយកុហកទម្លាក់កំហុស ដោយអសុទ្ធចិត្តទៅលើជនទីបីក្នុងបំណងបំផ្លិចបំផ្លាញ ធ្វើឲ្យកើតកោលាហលដល់សន្តិសុខសាធារណៈ នាយក ឬអ្នកទទួលខុសត្រូវផ្សេងទៀតនៃការផ្សាយ ឬអ្នកទទួលខុសត្រូវលើមធ្យោបាយគមនាគមន៍ឯទៀតដែលពាក់ព័ន្ធ ដែលបានសម្រេចទទួលចុះផ្សាយ ផ្សព្វផ្សាយ ឬផ្សាយបន្តនូវព័ត៌មានទាំងនោះនឹងត្រូវផ្តន្ទាទោសដាក់គុកពី៦ខែ ទៅ៣ឆ្នាំ ហើយត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ ទៅ ១០.០០០.០០០រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរនេះក៏បានដែរ"។ មាត្រា៦៣នៃច្បាប់នេះដដែលទាក់ទងនឹងបទបរិហារកេរ្តិ៍ចែងថា "ការបរិហាកេរ្តិ៍ ឬការជេរប្រមាថប្រព្រឹត្តទៅឡើងតាមមធ្យោបាយណាមួយដែលមានចែងក្នុងមាត្រា៥៩ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ៨ថ្ងៃ ទៅ១ឆ្នាំ។ ច្បាប់ទាំងនេះបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩២ ក្នុងសម័យអន្តរកាលក្រោមរដ្ឋបាលគ្រប់គ្រងសម័យអ៊ុនតាក់ នៅពេលមានសង្គ្រាមស៊ីវិលនៅកម្ពុជា។ ច្បាប់ទាំងនេះ ត្រូវបានប្រើដើម្បីការពារ និងដាក់ទណ្ឌកម្មលើការរិះគន់ដល់អ្នកកាន់អំណាច។ ច្បាប់នេះផ្ទុយនឹងស្តង់ដារសេរីភាពបញ្ចេញមតិអន្តរជាតិ ហើយបង្កើតឲ្យមានបរិយាកាសភ័យខ្លាចទៀតផង។ នៅក្នុងសេចក្តីប្រកាសរួមនៅក្នុងឆ្នាំ១៩៩៩ និងឆ្នាំ២០០០ និងបន្តទៀតនៅឆ្នាំ២០០២។ បុគ្គលថ្នាក់អន្តរជាតិ ពិសេសដើម្បីលើកស្ទួយសេរីភាពបញ្ចេញមតិ(រួមមានអ្នករាយការណ៍ពិសេសតំណាងអង្គការសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប ស្តីពីសេរីភាពនៃប្រព័ន្ធផ្សព្វផ្សាយ និងអ្នករាយការណ៍ពិសេស OAS(Organization of American State) លើសេរីភាពបញ្ចេញមតិ) បានអំពាវនាវឲ្យរដ្ឋនានាលុបចោលបទបរិហារកេរ្តិ៍ចេញពីច្បាប់ព្រហ្មទណ្ឌ។ តាមការសង្កេតលើរបាយការណ៍តាមកាលកំណត់របស់ប្រទេសម៉ិចសិចកូ ក្រុមប្រឹក្សាសិទ្ធិមនុស្ស កត់សម្គាល់ថា ក្រុមប្រឹក្សារិះគន់យ៉ាងខ្លាំងលើការចាត់ទុកការបរិហារកេរ្តិ៍រដ្ឋថាជាបទល្មើស និងអំពាវនាវឲ្យលុបចោលបទចោទនេះ។ ឆ្លើយតបនឹងសម្ពាធជាតិ និងអន្តរជាតិ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាសម្រេចលុបចោលការដាក់ទោសជាប់គុកសម្រាប់បទបរិហាកេរ្តិ៍ នៅ

ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៧[១០៨]។

ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពសិទ្ធិសេរីភាព ការបញ្ចេញមតិយោបល់ ក្នុងឆ្នាំ២០០៩ កន្លងទៅនេះ មានសភាពប្រហាក់ប្រហែលនឹងឆ្នាំ២០០៥ដែរ តែដោយឡែកក្នុងឆ្នាំ២០០៩ មានលក្ខណៈធូរស្រាលជាងត្រង់ ចំណុចពុំមានទោសជាប់ពន្ធនាគារពីបទបរិហាកេរ្តិ៍ ម្យ៉ាងទៀតអ្នកដែលត្រូវមន្ត្រី ឬស្ថាប័នរដ្ឋាភិបាលប្តឹង និង កាត់ទោសដោយតុលាការ បានទុកឲ្យគេចខ្លួនរួចចេញទៅបរទេសច្រើនជាងឆ្នាំ២០០៥[១០៩]។ ប្រការដែលស្ថាប័ន ឬមន្ត្រីរដ្ឋាភិបាលកម្ពុជាធ្វើបណ្តឹងព្រហ្មទណ្ឌរបៀបនេះអាចទុកថា ជាចេតនារឹតបន្តឹងសេរីភាពនិងដាក់ការគាប សង្កត់ទៅលើក្រុមអ្នកបញ្ចេញមតិរិះគន់រដ្ឋាភិបាល ព្រោះមន្ត្រីរដ្ឋាភិបាលជាបុគ្គលសាធារណៈដែលអំពើឬ សេចក្តី សម្រេចរបស់ខ្លួនអាចធ្វើឲ្យមានការមិនពេញចិត្ត ឬប៉ះពាល់ផលប្រយោជន៍ដល់ពលរដ្ឋមួយចំនួនណា នោះ។ ដូច្នេះ ការមានមតិទិតៀន គឺជាតម្លៃដ៏សំខាន់មួយរបស់សង្គមប្រជាធិបតេយ្យដែលខុសពីសង្គមបិទជិត។

### ៣.២.២ សេរីភាពក្នុងការចូលរួមប្រជុំមហាជន

តាមទម្លាប់បែបបទនៅក្នុងរបបប្រជាធិបតេយ្យ ជាទូទៅប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិជួបជុំគ្នាដោយសេរី ដោយសន្តិវិធីតាមរយៈ ការចូលរួមបង្កើតសហជីពនិងការចូលរួមជាសមាជិកសហជីព ដើម្បីការពារផល ប្រយោជន៍របស់ខ្លួនដោយសន្តិវិធី និងមានការការពារដោយច្បាប់ជាដាច់ខាត។

សិទ្ធិចូលរួមជួបប្រជុំមហាជនដោយសេរី ក៏ត្រូវហាមឃាត់ដោយច្បាប់ផងដែរ ចំពោះការឃោសនា ជាគុណប្រយោជន៍ដល់សង្គ្រាម[១១០]។

ការជួបប្រជុំដោយសេរី ក៏ត្រូវហាមឃាត់ដោយច្បាប់ចំពោះរាល់ការអំពាវនាវណាមួយនាំទៅដល់ការ ស្អប់ខ្ពើមជាតិ ពូជសាសន៍ឬសាសនា ដែលញុះញង់នាំឲ្យកើតមានការរើសអើងការប្រទូសរ៉ាយឬហិង្សាផ្សេងៗ។ និយាយដោយឡែក ការប្រើសិទ្ធិនេះអាចមានការរឹតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងចាំបាច់ក្នុង សង្គមប្រជាធិបតេយ្យក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការ ការពារសុខភាពសាធារណៈ សីលធម៌ ឬការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាង ការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យ ប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ជនដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ[១១១]។

---

[១០៨] លីកាដូៈ របាយការណ៍រួមរបស់អង្គការក្រៅរដ្ឋាភិបាលស្តីពីសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ សម្រាប់ការត្រួតពិនិត្យជាសកល តាមពេលកំណត់នៃការបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៩

[១០៩] លីកាដូៈ របាយការណ៍ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩ ភ្នំពេញ លេខ៩ ឆ្នាំទី៩ ផ្សាយខែមករា ឆ្នាំ២០១០ ទំព័រ ៥

[១១០] មាត្រា២០ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦

សេរីភាពនៃការប្រើសិទ្ធិដែលមានចែងនៅក្នុងកថាខណ្ឌនៃមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ-ពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦ តម្រូវការមានករណីយកិច្ច និងការទទួលខុសត្រូវជាពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះអាចមានការរឹតត្បិតខ្លះៗដែលត្រូវកំណត់ដោយច្បាប់ជាដាច់ខាតគឺៈ

ក-គោរពសិទ្ធិ និងកិត្តិយសអ្នកដទៃ។

ខ-ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។

ជាក្រិត្យក្រមនៅកម្ពុជា ដែលកំពុងប្រកាន់យករបបដឹកនាំបែបប្រជាធិបតេយ្យ ប្រជាពលរដ្ឋគ្រប់គ្នាមានសិទ្ធិសេរីភាពពេញលេញក្នុងការជួបប្រជុំគ្នាដោយសន្តិវិធីនៅតាមទីសាធារណៈ ដើម្បីសម្តែងមតិរបស់ខ្លួន។ ប៉ុន្តែនៅឆ្នាំ២០០៨ មានការអនុញ្ញាតច្បាប់ឲ្យអង្គការសង្គមប្រារព្ធអបអរសាទរទិវានានា មានទិវាសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិជនពិការ ជាដើម ។ល។ ក៏ប៉ុន្តែសិទ្ធិសេរីភាពក្នុងការជួបប្រជុំនៅតាមទីសាធារណៈ ដែលធ្វើឡើងដើម្បីទាមទារតវ៉ាពីការរំលោភបំពានលើដីធ្លី និងធនធានធម្មជាតិនានា ឬទាមទារលក្ខខណ្ឌសិទ្ធិការងារ ដើម្បីទាមទារឲ្យរដ្ឋាភិបាលចេញមុខដោះស្រាយ ក៏ដូចជាការបង្ហាញពីការខ្វះចន្លោះរបស់រដ្ឋាភិបាល សុទ្ធតែត្រូវបានរឹតបន្តឹងយ៉ាងតឹងរឹង ពីអាជ្ញាធរមានសមត្ថកិច្ច។ ឯបាតុកម្មដែលមិនធ្វើឲ្យប៉ះពាល់ដល់មុខមាត់រដ្ឋាភិបាលទើបពុំមានការបង្រ្កាប។ មានកូដកម្ម និងបាតុកម្មអហិង្សាយ៉ាងតិចចំនួន ១៥៥ករណី ត្រូវបានកើតឡើង និងមានចំនួនប្រមាណ ៧០%នៃចំនួននេះ ត្រូវបានបង្រ្កាបដោយកម្លាំងប្រដាប់អាវុធទៅលើកម្មករ-កម្មការិនី បណ្តាលឲ្យរងរបួសទៀតផង។

ចំនួននេះបើប្រៀបធៀបតួលេខនេះទៅឆ្នាំ២០០៧ ឃើញថាមានការថយចុះបន្តិច។ ការថយចុះនេះមិនកំណត់ថា រដ្ឋាភិបាលកម្ពុជាបានបើកឱកាសសម្រាប់ប្រជាពលរដ្ឋសម្តែងមតិតាមរយៈការធ្វើកូដកម្ម ឬបាតុកម្មដោយសន្តិវិធីបានដោយសេរីនោះទេ។ ចំនួននៃការធ្វើបាតុកម្ម ឬ កូដកម្មអហិង្សាហាក់មានការស្ងប់ស្ងាត់ជាងឆ្នាំមុនៗមែនក៏ដោយ ក៏ចំនួននេះពុំមានន័យថា សេរីភាពនៃការបញ្ចេញមតិត្រូវបានអនុវត្តពេញលេញនោះដែរ ព្រោះថាការធ្លាក់ចុះនៃចំនួនបាតុកម្មអហិង្សានៅឆ្នាំនេះ បណ្តាលមកពីមូលហេតុផ្សេងៗដូចជា រាល់ការជូនដំណឹងដល់អាជ្ញាធរអំពីការធ្វើបាតុកម្មអហិង្សា ត្រូវបានអាជ្ញាធរធ្វើការរារាំងតាមគ្រប់រូបភាព។ ដូចជាកម្រិតព្រំដែនធ្វើការឆ្លើយតបយឺតយ៉ាវ ធ្វើឲ្យអ្នករៀបចំបាតុកម្មគ្មានពេលគ្រប់គ្រាន់សម្រាប់រៀបចំពិធី ការកំណត់ខ្លឹមសារបដា ការកំណត់ចំនួនបដា ការឃាត់ដំណើរតាមផ្លូវ ឆែកឆេរយានយន្ត មិនអនុញ្ញាតឲ្យប្រជាពលរដ្ឋស្នាក់នៅសួនច្បារសាធារណៈ នោះក៏ជាសកម្មភាពរាំងមួយដោយប្រយោលផងដែរ។ ទន្ទឹមនឹងសកម្មភាពរាំងខាងលើ អាជ្ញាធររដ្ឋាភិបាល បានប្តឹងតំណាងធ្វើបាតុកម្ម ឬកូដកម្មទៅស្ថាប័នតុលាការដោយចោទប្រកាន់តាមបទល្មើសព្រហ្មទណ្ឌផ្សេងៗ។ ការចោទប្រកាន់ និងការទម្លាក់ការទទួលខុសត្រូវរបៀបនេះ ជាមធ្យោបាយមួយដើម្បីរាំងមិនឲ្យមានបាតុកម្មអហិង្សា ក្នុងការទាមទារនូវអ្វីដែលមហាជនចង់បាន។ ការធ្វើរបៀបនេះ គឺជា

[១១១] មាត្រា៤១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

សកម្មភាពផ្ទុយទៅនឹងគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ដែលតម្រូវឲ្យជនដែលប្រព្រឹត្តបទល្មើស ជាអ្នកទទួលទោសផ្ទាល់ទៅលើក្រុមបាតុករដែលបានមកតវ៉ា។

តាមការអង្កេតខាងលើឃើញថា សេរីភាពជួបប្រជុំតាមទីធ្លាសាធារណៈ សេរីភាពនៃការសម្ដែងមតិរបស់សង្គមស៊ីវិលមួយចំនួនក៏ដូចជាអ្នកតំណាងរាស្ត្រមកពីខាងគណបក្សប្រឆាំងនៅកម្ពុជា រយៈពេលចុងក្រោយនេះមានការរឹតបន្តឹងជាងឆ្នាំមុនៗ ហើយត្រូវបានទទួលរងនូវប្រតិកម្មតបវិញពីមន្ត្រីរដ្ឋាភិបាល ដោយថែមទាំងប្ដឹងទៅតុលាការពីបទបរិហារកេរ្តិ៍ និងញុះញង់ទៀតផង រួមមានអ្នកតំណាងរាស្ត្រមកពីគណបក្សប្រឈមធំក្នុងរដ្ឋសភា។

សិទ្ធិធ្វើបាតុកម្ម និងកូដកម្មដោយសន្តិវិធី គឺមានសារៈសំខាន់ណាស់ក្នុងប្រទេសប្រជាធិបតេយ្យ ព្រោះជាមធ្យោបាយផ្ញើសារដោយអហិង្សា ជូនអ្នកដឹកនាំឲ្យបានដឹងអំពីទុក្ខលំបាករបស់ពួកគេ ដែលជាការដាក់សម្ពាធឲ្យអ្នកដឹកនាំយកចិត្តទុកដាក់ដោះស្រាយបញ្ហានានា និងទុក្ខលំបាកទាំងឡាយ[១១២]។

ជាការពិតណាស់នៅក្នុងប្រទេសប្រកាន់របបប្រជាធិបតេយ្យ ដូចជាប្រទេសអង់គ្លេស ប្រសិទ្ធិភាពនៃលទ្ធិប្រជាធិបតេយ្យ គឺជាការទាមទារឲ្យរដ្ឋាភិបាលមានទំនាក់ទំនងជិតដិតជាប់ជាមួយប្រជាពលរដ្ឋ ដោយត្រៀមខ្លួនជាប់ជានិច្ច ដើម្បីបម្រើរាល់សេចក្ដីត្រូវការជាក់ស្ដែងស្របច្បាប់នានារបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។ កាលណាអាជ្ញាធររដ្ឋាភិបាលមិនបានដោះស្រាយជូនក្រុមប្រជាពលរដ្ឋ នោះការសម្រេចចិត្តធ្វើបាតុកម្មអហិង្សាទាមទារឲ្យមានដំណោះស្រាយកើតមានឡើង ដោយដំណើរការធ្វើបាតុកម្មរបស់ប្រជាពលរដ្ឋនៃប្រទេសទាំងនេះ គឺគេអាចធ្វើបានដោយសេរី ដោយគ្មានការជ្រៀតជ្រែកពីរដ្ឋាភិបាលឡើយ។ ការរៀបចំធ្វើបាតុកម្មអហិង្សាជាសាធារណៈ គឺផ្ដោតការតវ៉ាទៅលើសភា និងរដ្ឋាភិបាល[១១៣]។

ក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានសិទ្ធិប្រជុំគ្នា ឬរៀបចំធ្វើបាតុកម្មផ្សេងៗបានឲ្យតែប្រកបដោយសន្តិវិធី។ ប្រជាពលរដ្ឋអាចចូលរួមជាមួយក្រុមណាក៏បានឲ្យតែក្រុមនោះយល់ព្រម។ មិនត្រូវឲ្យជនណាមកបង្ខិតបង្ខំប្រជាពលរដ្ឋឲ្យចូលរួមជាមួយក្រុម ឬពួកណាដែលអ្នកមិនពេញចិត្តឡើយ។ ប៉ុន្តែបើមានប្រើហិង្សា ឬធ្វើឲ្យខូចខាតដល់របៀបរៀបរយដល់សម្បត្តិអ្នកដទៃ គឺជាការរំលោភដល់សិទ្ធិអ្នកដទៃ ឬរំលោភដល់របៀបរៀបរយសង្គម ឬរំលោភដល់សន្តិសុខសាធារណៈ។ បាតុករមានសិទ្ធិត្រឹមតែធ្វើការរួមប្រជុំ និងធ្វើបាតុកម្មអហិង្សាប៉ុណ្ណោះ ហើយត្រូវជៀសវាងជាដាច់ខាតនូវអំពើឃោរឃៅ ឬហិង្សា។ បើត្រូវការធ្វើបាតុកម្មដោយមានដង្ហែក្បួនតាមផ្លូវសាធារណៈ ត្រូវតែសុំច្បាប់អនុញ្ញាតពីក្រសួងមានសមត្ថកិច្ច ព្រោះមានប៉ះពាល់ដល់សិទ្ធិសាធារណៈ។ កាលណាមានប៉ះពាល់ដល់សន្តិសុខសាធារណៈ រដ្ឋអំណាចតែងតែយកលេស ដើម្បីធ្វើការគាបសង្កត់មកលើបាតុករ។ យ៉ាងណាមិញ ការរួមប្រជុំគ្នាដោយស្ងប់ស្ងៀម និងដោយមិនប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ឬការរួមប្រជុំ មិនមានប៉ះពាល់ដល់សិទ្ធិអ្នកដទៃ គឺជាសិទ្ធិពេញទីរបស់ប្រជាពលរដ្ឋគ្រប់ៗគ្នា។ កាលណាហាម

[១១២] ព្រឹត្តិបត្រអ្នកជា ឆ្នាំទី១៤ លេខពិសេស២៩៥សម្រាប់ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ ១

[១១៣] លទ្ធិប្រជាធិបតេយ្យ អនុវត្តនៅចក្រភពអង់គ្លេស ផ្សាយចេញពីក្រសួងការបរទេសចក្រភពអង់គ្លេស ឆ្នាំ១៩៩៤ ទំព័រ២៤

ឃាត់មិនឲ្យមានបាតុកម្មអហិង្សា គឺជាការរំលោភដ៏គួរឲ្យខ្មាសអៀន។ ឯការប្រើកងកម្លាំងប្រដាប់-អាវុធទៅបំបាក់បាតុករ ដែលជាពស្ត្រស្លូតត្រង់ ឬដែលជាសិស្សគ្មានអាវុធ គឺជាការរំលោភដ៏គួរឲ្យខ្ពើមរអើម[១១៤]។

នៅប្រទេសកម្ពុជា សិទ្ធិធ្វើកូដកម្ម និងបាតុកកម្មដោយសន្តិវិធីក៏ត្រូវបានធានាដែរ តាមរយៈមាត្រា១ និងមាត្រា២ នៃច្បាប់បាតុកម្ម ដែលបានអនុម័តកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩១ ហើយដែលនៅជាធរមាន នៅឡើយ។ ច្បាប់នេះបានអនុញ្ញាឲ្យធ្វើការប្រជុំជាក្រុម ជាពួក ជាកង និងប្រមូលផ្តុំគ្នាធ្វើបាតុកម្ម។ ប៉ុន្តែការប្រជុំ ឬការធ្វើបាតុកម្ម ឬការប្រមូលផ្តុំគ្នាដើរតាមផ្លូវសាធារណៈ ឬទីប្រជុំជនកន្លែងសាធារណៈក៏ត្រូវបានហាមឃាត់ជាដាច់ខាតដែរ ក្នុងករណីធ្វើឲ្យខូចខាតភាពសុខសាន្ត ខូចសណ្តាប់ធ្នាប់ សន្តិសុខអ្នកដទៃ ឬសន្តិសុខសាធារណៈ។ ហើយច្បាប់ស្តីពីបាតុកម្មនេះ បានកំណត់លក្ខខណ្ឌនៃការប្រមូលផ្តុំគ្នាដើរតាមផ្លូវសាធារណៈ ជាបាតុកម្មសម្តែងមតិលើបញ្ហាអ្វីមួយ និងអាចប្រព្រឹត្តទៅបាន លុះត្រាតែមិនត្រូវឲ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជាពិសេស ត្រូវជម្រាបជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ចចំនួន ៣ថ្ងៃមុន ដោយមានការបញ្ជាក់ពីគោលបំណងនៃបាតុកម្ម ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការប្រជុំ ចំនួនមនុស្ស និងឈ្មោះអ្នកចូលរួម អាសយដ្ឋាន និងហត្ថលេខា នៃអ្នករៀបចំបាតុកម្មចំនួន៣នាក់។ ដោយឡែកករណីអាជ្ញាធរមូលដ្ឋានយល់ឃើញថា បាតុកម្មនោះអាចនាំឲ្យមានចលាចល អាជ្ញាធរអាចហាមឃាត់។

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៨ វេលាម៉ោង៦:១៥នាទីព្រឹក លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យ និងលោក ជា មុន្នី ប្រធានសហជីពសេរីកម្មករកម្ពុជា និងសមាជិក៦នាក់ផ្សេងទៀតបានដឹកសម្ភារៈសម្រាប់ធ្វើបាតុកម្មដោយអហិង្សានៅមុខរដ្ឋសភាជាតិចាស់ ក្នុងគោលបំណងដង្ហែឆ្ពោះទៅកាន់ស្ថានទូតថៃ ដើម្បីទាមទារឲ្យកងទ័ពថៃ ដកចេញពីទឹកដីកម្ពុជា។ ក្នុងពេលដែលក្រុមបាតុករកំពុងរៀបចំសម្ភារៈបាតុកម្ម រួមមានបដា និងទង់ជាតិកម្ពុជា ក៏មានកម្លាំងសមត្ថកិច្ចប៉ូលីសចម្រុះប្រមាណជាង១០០នាក់ បានបង្ក្រាបក្រុមបាតុករអហិង្សាយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលឲ្យកម្មករ កម្មការិនីចំនួន៥នាក់រងរបួស។ រាល់ការបំភ្លឺរបស់អាជ្ញាធរដែនដីចំពោះការរារាំង និងបង្ក្រាបទៅលើបាតុកម្មអហិង្សាទាំងឡាយ គឺដោយសារបាតុកម្មគ្មានច្បាប់អនុញ្ញាត លើសពីនេះអាជ្ញាធរបានពន្យល់ថា អាចធ្វើឲ្យខូចខាតដល់សន្តិសុខសង្គម ប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ហើយបាតុកម្មពុំមែនជាដំណោះស្រាយទេ។

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១០ ប្រជាពលរដ្ឋនៅតំបន់បឹងកក់ចំនួន៥០០នាក់ បាននាំគ្នាជួបជុំមហាជនដោយសន្តិវិធីនៅមុខភូមិគ្រឹះសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីតវ៉ាសុំឲ្យសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រី អន្តរាគមន៍ទៅលើករណីកើតមានលើទឹកជំនន់លិចផ្ទះសម្បែងរបស់ពួកគាត់ ដែលកើតចេញពីការបូមដីចាក់លុបបឹងកក់ និងរងការគំរាមកំហែង បណ្តេញចេញពីផ្ទះកាន់តែខ្លាំងឡើងៗ ដើម្បីយកដីរបស់ពួកគេពីក្រុមហ៊ុនកាតូអ៊ីន ប៉ុន្តែត្រូវបានអាជ្ញាធរបំបែក និងបង្ក្រាប។

[១១៤] អង្គការវីជីនលេនៈ អង្គការរក្សាការពារសិទ្ធិមនុស្សនៃកម្ពុជា ឆ្នាំ២០០៨ ទំព័រ ២២

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ប្រមុខរដ្ឋាភិបាល បានគំរាមបញ្ចេញបាតុករធ្វើបាតុកម្មទល់នឹងសង្គមស៊ីវិល ដែលប្រាថ្នាធ្វើបាតុកម្មប្រឆាំងការព្យួរអភ័យឯកសិទ្ធិលោកស្រី មួរ សុខហួរ។

សមាគមអាដហុកយល់ឃើញថា ការជ្រើសរើសយកការធ្វើបាតុកម្ម ឬកូដកម្មអហិង្សា ដើម្បីសម្តែងមតិទាមទារឲ្យមានដំណោះស្រាយនោះ គឺធ្វើឡើងនៅដំណាក់កាលចុងក្រោយបន្ទាប់ពីរកឃើញថា ពុំមានយន្តការដោះស្រាយណាមួយអាចធ្វើទៅបានឡើយ ពីអាជ្ញាធរក៏ដូចជារដ្ឋាភិបាល។

សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា ត្រូវក្រុមមន្ត្រីក្រៅរដ្ឋាភិបាល និងអ្នកការទូតជាច្រើនដែលកំពុងធ្វើការនៅកម្ពុជានិយាយថា កំពុងស្ថិតនៅក្នុងការបង្ក្រាប គំរាមកំហែងតាមរយៈនៃការប្តឹងទៅតុលាការរហូតមានការចាប់ដាក់ពន្ធនាគារទៀតផង បើទោះបីជានៅឆ្នាំ២០០៦ រដ្ឋាភិបាលកម្ពុជា បានចាត់វិធានការមួយដ៏សំខាន់ក្នុងការដកចេញទោសគុណ ជាទណ្ឌកម្មមួយសម្រាប់ការបរិហាកេរ្តិ៍ជាបទព្រហ្មទណ្ឌក៏ដោយ ក៏ជាជំហានមួយក្នុងការពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់ការជជែកដេញដោលបែបប្រជាធិបតេយ្យនោះ គឺការដកបទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតចេញពីក្រមព្រហ្មទណ្ឌថ្មី ដើម្បីឲ្យតុលាការរដ្ឋប្បវេណីតែមួយប៉ុណ្ណោះ ដែលមានសមត្ថកិច្ចដោះស្រាយបញ្ហាទាំងនេះ[១១៥]។ នេះបញ្ជាក់យ៉ាងច្បាស់គ្មានការមន្ទិលសង្ស័យថា ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការសម្តែងមតិស្របច្បាប់ និងការទទួលស្គាល់ច្បាស់អំពីតម្លៃនៃការជជែកដេញដោលគ្នាដោយសេរី តាមបែបប្រជាធិបតេយ្យអំពីបញ្ហាដែលជាប្រយោជន៍សាធារណៈ ទន្ទឹមនឹងនេះដែរ ក៏ត្រូវតែការពារកិត្តិសព្ទរបស់បុគ្គលឲ្យបានត្រឹមត្រូវ ក្នុងករណីសមស្របតាមរយៈបណ្តឹងរដ្ឋប្បវេណីទាមទារសំណង។ ទោះជាយ៉ាងណាការប្តឹងនិងការដាក់ពន្ធនាគារចំពោះអ្នករិះគន់រដ្ឋាភិបាល មន្ត្រីសាធារណៈរយៈពេលចុងក្រោយនៅកម្ពុជានេះ ត្រូវបានអង្គការសិទ្ធិមនុស្សអន្តរជាតិធំៗនិយាយថា ដំណើរការប្រជាធិបតេយ្យនៅកម្ពុជាដើរថយក្រោយហើយ។ អំណាចនៅកម្ពុជា តាមការកត់សម្គាល់ក្រោយពេលចូលមកទស្សនៈកិច្ចជាផ្លូវការណ៍ រយៈពេលប្រមាណមួយសប្តាហ៍នៃសមាជិកសភាសហភាពអឺរ៉ុបកន្លងទៅនេះ របាយការណ៍របស់សមាជិក សភាអឺរ៉ុបពិពណ៌នាថា ការត្រួតត្រានៅប្រទេសកម្ពុជាប្រើច្បាប់នៃអ្នកខ្លាំង[១១៦]។

នៅក្នុងកំណត់សង្ខេបស្តីអំពីសេរីភាពក្នុងការសម្តែងមតិ ការបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតរបស់ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ដែលអង្គការសហប្រជាជាតិបានចុះផ្សាយកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ បានលើកឡើងថា វាជាការសំខាន់ណាស់សម្រាប់ការការពារលំហានៃលទ្ធិប្រជាធិបតេយ្យ ដើម្បីជជែកដេញដោលជាសាធារណៈដែលអាជ្ញាធរសាធារណៈ អ្នកនយោបាយ ក៏ដូចជាសាធារណៈជន ដែលចូលរួមក្នុងការជជែកដេញដោលទាំងនេះ ត្រូវតែមានការអត់ធ្មត់ ចំពោះទស្សនៈខ្វែងគំនិតគ្នា ហើយមិនត្រូវចាត់ទុកទស្សនៈទាំងនេះថា ជាការវាយប្រហារលើបុគ្គលឡើយ។ មិនមានអ្វីខុសទេក្នុង

---

[១១៥] សារព័ត៌មានមនសិការខ្មែរ ឆ្នាំ០៣ លេខ៤៣៩ ចេញផ្សាយថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ១-២

[១១៦] កាសែតខ្មែរម្ចាស់ស្រុក ឆ្នាំទី០៣ លេខ៤៣៩ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩

ការរិះគន់គោលនយោបាយសាធារណៈនោះ ព្រោះឥរិយាបថបែបនេះ គឺជាផ្នែកមួយនៃបរិយាកាស និង ដំណើរការនៃលទ្ធិប្រជាធិបតេយ្យមួយដែលល្អ។ ឯការដាក់ពាក្យប្ដឹងព្រហ្មទណ្ឌចំពោះបញ្ហាសាធារណៈដែលបាន លើកឡើងក្នុងករណីពាក់ព័ន្ធទាំងនេះ គឺជារឿងមួយហួសហេតុ និងមិនសមហេតុផល។ ប្រសិនបើជាបុគ្គលណា មួយមិនយល់ស្របចំពោះការពិភាក្សាជាសាធារណៈ គេគួរតែឆ្លើយតបទៅនឹងខ្លឹមសារនៃការចោទប្រកាន់នោះ ដោយ ចូលរួមជជែកវែកញែកយ៉ាងត្រឹមត្រូវអំពីបញ្ហាទាំងនោះជាមុនសិន។ ប្រសិនបើនៅតែមិនសុខចិត្តចំពោះ ពាក្យសម្ដីដែលនរណាម្នាក់បាននិយាយនោះ គេគួរតែប្ដឹងទាមទារសំណងរដ្ឋប្បវេណី ជាជាងដាក់ពាក្យបណ្ដឹង ព្រហ្មទណ្ឌ ដូចដែលច្បាប់កម្ពុជាបានចែង។ ហើយវាមិនសមស្របទេ សម្រាប់ដាក់ពាក្យបណ្ដឹងក្នុងនាម រដ្ឋាភិបាល។ ប្រសិនជាមន្ត្រីទាំងឡាយណាកើតទុក្ខមិនសុខចិត្ត តុលាការបើកចំហឲ្យមន្ត្រីទាំងនោះដាក់ពាក្យ បណ្ដឹងក្នុងនាមបុគ្គល។ ការអនុវត្តន៍ដូច្នេះ ផ្ទុះបញ្ចាំងអំពីយុត្តិសាស្ត្រអន្តរជាតិលើបញ្ហានេះ និងការបកស្រាយ មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ដោយគណៈ-កម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិ ស្ថាប័នឃ្លាំមើលការប្រតិបត្តិកតិកសញ្ញា ICCPR ដែលបានផ្ដល់អនុសាសន៍ ជំទាស់នឹងការដាក់ការបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌនៃរដ្ឋាភិបាល។ ហើយបញ្ហាដែលកើតចេញពីការចុះផ្សាយ សារព័ត៌មានអំពីបញ្ហាទាំងឡាយ ដែលទាក់ទងនឹងការជជែកដេញដោលជាសាធារណៈ គួរតែដោះស្រាយដូច មានចែងក្នុងច្បាប់ស្ដីពីរបបសារព័ត៌មាន។ ឯការដកអភ័យឯកសិទ្ធិសភាឬការគំរាមកំហែងដកអភ័យឯកសិទ្ធិក្នុង បំណងបំភិតបំភ័យធ្វើឲ្យខូចតម្លៃដ៏សំខាន់នៃអភ័យឯកសិទ្ធិ ដែលផ្ដល់លទ្ធភាពឲ្យមានការពិភាក្សាដោយសេរី អំពីបញ្ហាសាធារណៈក្នុងចំណោមតំណាងរាស្ត្រ និងអ្នកធ្វើច្បាប់។

រូបភាពនៃការរារាំងរបស់រដ្ឋាភិបាល កន្លងមកបង្ហាញកាន់តែច្បាស់ នូវស្ថានភាពនៃសេរីភាពជួបប្រជុំ មហាជនដោយសន្តិវិធីនៅកម្ពុជា គឺពុំត្រូវគេផ្ដល់ឲ្យ ដែលនេះជាចំណុចខ្វះខាតនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា បច្ចុប្បន្ន។ ដូច្នេះរដ្ឋាភិបាលត្រូវអនុញ្ញាតឲ្យប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិអធិបតេយ្យដ៏ទូលំទូលាយ តាមគោល-ការណ៍ប្រជាធិបតេយ្យ និងរដ្ឋធម្មនុញ្ញ ដើម្បីប្រែក្លាយកម្ពុជាទៅជាប្រទេសប្រជាធិបតេយ្យនីតិរដ្ឋពិតប្រាកដ និងបង្កើនល្បឿនអភិវឌ្ឍឲ្យកាន់តែឆាប់រហ័ស។

### ៣.២.៣ សិទ្ធិសេរីភាពស្ដីពីសារព័ត៌មាន

ក្នុងអារ្យធម៌ប្រជាធិបតេយ្យភាវូបនីយកម្ម សម័យកុំព្យូទ័រ អ៊ីនធ័រណិត(Internet) ប្រព័ន្ធសារព័ត៌មាន ត្រូវបានចាត់ទុកថា ជាស្ថាប័នដ៏មានអំណាចកំពូលទីបួនក្នុងទ្រឹស្ដីបែងចែកអំណាច។ វគ្គស័ព្ទ "សារព័ត៌មាន" ត្រូវបានប្រើប្រាស់ជាទ្រឹស្ដីនៃយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងចំណោមវិស័យដទៃទៀត ជាពិសេសទាក់ទងនឹង វិទ្យាសាស្ត្រនយោបាយ។ ក្នុងចរន្តនយោបាយ សារព័ត៌មានត្រូវបានចាត់ទុកជា"អំណាចទីបួន" បន្ទាប់ពីអំណាច អង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។ ជាទូទៅនៅក្នុងសង្គមវប្បធម៌ប្រតិបត្តិអំណាចរបស់ ស្ថាប័ននីមួយៗ គឺគេនិយមហៅថា ការកាន់កាប់ ការដឹកនាំ ការគ្រប់គ្រង ការត្រួតពិនិត្យ។ ទម្រង់ទាំងនេះ

សារព័ត៌មានត្រូវបានចាត់ទុកជា "អំណាចត្រួតពិនិត្យ"។ នៅក្នុងបរិបទប្រព័ន្ធនយោបាយបែបណាក៏ដោយ សារព័ត៌មាន គឺមានសារៈសំខាន់ខ្លាំងណាស់លើគ្រប់វិស័យទាំងអស់ ដែលទាក់ទងផ្ទាល់ទៅនឹងជីវិតរស់នៅរបស់មនុស្សនៅលើពិភពលោកទាំងមូលតែម្ដង។ ពោលសារព័ត៌មានបានផ្សាភ្ជាប់យ៉ាងជិតស្និតទៅនឹងដំណើរការដឹកនាំ ការគ្រប់គ្រង និងចំណេះដឹងរបស់ប្រជាពលរដ្ឋ ដែលត្រូវបានផ្គត់ផ្គង់ដោយប្រព័ន្ធ បច្ចេកទេសអេឡិចត្រូនិចដ៏ទំនើប។ លោក A. Toffler, Dapendorf, Mc.Likan បានសរសេរថា ប្រព័ន្ធព័ត៌មានកើតចេញពីយុគសម័យជឿនលឿន ផ្នែកឧស្សាហកម្មសារព័ត៌មានសេដ្ឋកិច្ច[១១៧]។ លោក D.Bell។ ជាជនជាតិអាមេរិកកាំង បានថ្លឹងថ្លែងតាមតក្កៈយ៉ាងដូច្នេះថា: ការទាក់ទងរវាងអំណាច និងសារព័ត៌មាន មានលក្ខណៈដូចជាគូរបដិបក្ខ ឬគូរប្រគួតប្រជែងនឹងគ្នាដ៏ខ្លាំងក្លា គឺមានន័យថា បើអំណាចស្ថិតនៅជួរទីមួយ នោះសារព័ត៌មាននៅជួរទីពីរ គឺមានលក្ខណៈផ្ទុយ។

លោក Mak-Luena(១៩៦៤) បានផ្ដល់និយមន័យថា: សារព័ត៌មាន គឺជាប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដឹកនាំដោយបានតភ្ជាប់ពីទីក្រុងទៅជនបទ និងពីជនបទទៅទីក្រុង។ លោក Gelbart(១៩៦៧),Brzezinski បានសរសេរថា: ដោយសារបច្ចេកវិទ្យាជឿនលឿននៅក្នុងពិភពលោក សារព័ត៌មានបានក្លាយជាអំណាចមួយដ៏មានប្រសិទ្ធិភាពដើម្បីត្រួតពិនិត្យ លើវិស័យពាណិជ្ជកម្ម និងការដឹកនាំរបស់រដ្ឋាភិបាល[១១៨]។ លោក Masuda ជាអ្នកប្រាជ្ញជនជាតិជប៉ុនបានសរសេរកាលពីឆ្នាំ១៩៨៣ថា: ប្រព័ន្ធព័ត៌មាន មានការរីកលូតលាស់ខ្លាំង ដែលអាចចាត់ទុកថា ជាអំណាចការពារសន្តិសុខមួយដ៏ចំណាន ដែលបានមកពីការវិវត្តន៍នៃសង្គមមនុស្សទាំងមូល។ លោកបានបន្ថែមទៀតថា សង្គមសារព័ត៌មាន គឺជាឧស្សាហកម្មនៃមូលដ្ឋានសង្គមថ្មី ដែលផ្អែកលើកុំព្យូទ័របច្ចេកវិជ្ជា ដោយសារមានជំនួយដ៏ទំនើបនេះហើយ ទើបធ្វើឲ្យមនុស្សរំដោះខ្លួនចេញផុតពីភាពស្មុគស្មាញ និងភាពអរូបីនៅក្នុងការសិក្សាស្រាវជ្រាវពីវិទ្យាសាស្ត្រ ដោយជួយជំរុញឲ្យមនុស្សមានបញ្ញាញាណជឿនលឿនជាងមុន។ លោកបានផ្ដល់សេចក្ដីសន្និដ្ឋានថា បដិវត្តន៍សារព័ត៌មាន គឺជាភាពសរុបនៃកម្លាំងប្រាជ្ញា ស្មារតី និងចំណេះដឹងរបស់មនុស្ស។ ដោយសារមនុស្សចេះចងក្រងជាក្បួនខ្នាត បែងចែកជាអង្គការអំណាចត្រឹមត្រូវ ទើបមនុស្សអាចគ្រប់គ្រងមនុស្ស រដ្ឋអាចគ្រប់គ្រងសង្គមបានយ៉ាងងាយស្រួល។

សង្គមប្រជាធិបតេយ្យ គឺត្រូវមានសេរីភាពសារព័ត៌មាន ប្រសិនបើគ្មានសេរីភាពសារព័ត៌មានទេ នោះមិនមែនជាសង្គមប្រជាធិបតេយ្យទេ[១១៩]។ សារព័ត៌មានត្រូវបានគេចាត់ទុកថា ជាសេរីភាពប្រវត្តិសាស្ត្រទី១នៃសេរីភាពក្នុងការបញ្ចេញមតិ និងមានតួនាទីជាអ្នកនាំពាក្យសំខាន់ និងសម្រួលការប្រាស្រ័យទាក់ទង និងការផ្ដល់វេទិកាពិភាក្សាដ៏ចំហមួយសម្រាប់ការរែកញែកក្នុងចំណោមភាគីទាំងអស់ក្នុងសង្គម។

---

[១១៧] Toffler A. The third wave,N.Y., 1980; McLukan. Culture society andthe media.N.Y.1982-page 458-460

[១១៨] Brzezinski Z.Between two ages. Americas Role in the tichnotronic Era. N.E.1970-p356

[១១៩] ប្រសាសន៍របស់ឯកឧត្តមខៀវ កាញារីទ្ធ ក្នុងសារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ ឆ្នាំទី១ លេខ១ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ ២

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់កិត្តិយសរបស់អ្នកដទៃ ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ[១២០]។ ប្រជាធិបតេយ្យ ទាមទារឲ្យមានការទទួលព័ត៌មានពីប្រភពផ្សេងៗទៀត។ ប្រជាពលរដ្ឋ គឺជាអ្នកធ្វើការសម្រេចចិត្ត ដូច្នេះហើយប្រជាពលរដ្ឋត្រូវបានទទួលព័ត៌មាន និងអំណាចគ្រប់គ្រាន់ដើម្បីមានមូលដ្ឋានក្នុងការសម្រេចចិត្ត។ ប្រព័ន្ធផ្តាច់ការទទួលផលប្រយោជន៍ពីភាពល្ងង់ខ្លៅនិងភាពក្រីក្ររបស់ប្រជាពលរដ្ឋ កាលណាមានអ្នកល្ងង់ខ្លៅច្រើនងាយស្រួលក្នុងការបោកប្រាស់ កេងប្រវ័ញ្ច បំភិតបំភ័យនិងគំរាមកំហែង[១២១]។

សេរីភាពខាងការបញ្ចេញមតិត្រូវបានទទួលស្គាល់ជាបណ្តើរៗនៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩២មកម្ល៉េះ។ សព្វថ្ងៃនេះការសម្តែងមតិបានរីកដុះដាលលើគ្រប់រូបភាព និងព្រមទាំងគ្រប់មធ្យោបាយដូចជា សារព័ត៌មានទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ និងការបោះពុម្ពផ្សាយ។ បច្ចុប្បន្ននៅព្រះរាជាណាចក្រកម្ពុជា មានកាសែតជាង ១០០ជាភាសា ខ្មែរ បារាំង អង់គ្លេស ចិន និងភាសារផ្សេងៗទៀត បាននិងកំពុងបោះពុម្ពផ្សាយជាសាធារណៈ[១២២]។ មានស្ថានីយ៍ទូរទស្សន៍ជាតិ៨ និងឯកជនចំនួន៨ និងវិទ្យុផ្សាយជាភាសាខ្មែរ និងបរទេសចំនួន២៥នៅភ្នំពេញ និងចំនួន៤០នៅតាមខេត្តបាននិងកំពុងធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយទូទាំងប្រទេស[១២៣]។ ការផ្សព្វផ្សាយទាំងនេះពុំមានការត្រួតពិនិត្យពីរដ្ឋាភិបាលជាមុនឡើយ ដោយគ្រាន់តែសុំការអនុញ្ញាតពីក្រសួងព័ត៌មានតែប៉ុណ្ណោះ ទើបអាចផ្សាយបាន។ នៅក្នុងសង្គមប្រជាធិបតេយ្យ បានប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់បី គឺសង្គមស៊ីវិលឯករាជ្យ សង្គមមានសន្តិភាព និងសេរីភាពខាងសារព័ត៌មាន។ ដូច្នេះ ចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជាមានច្បាប់ស្តីពីរបបសារព័ត៌មានដែលបានអនុម័តដោយរដ្ឋសភាមានចំណុចពិសេសល្អច្រើន ហើយចំណុចល្អៗទាំងបួននេះគឺៈ

១-ពលរដ្ឋកម្ពុជាគ្រប់រូបមានសិទ្ធិពេញលេញក្នុងការបោះពុម្ពផ្សាយ។

២-ជនបរទេសក៏មានសិទ្ធិបើកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាបាន។

៣-ការបោះពុម្ពផ្សាយទាំងឡាយគ្មានការត្រួតពិនិត្យជាមុនឡើយ លើកលែងតែពាក់ព័ន្ធការងារបច្ចេកទេស ដូចជា សុខាភិបាល កសិកម្ម ដែលត្រូវឆ្លងកាត់ការត្រួតពិនិត្យពីស្ថាប័នជំនាញច្បាស់លាស់។

ទាំងអស់នេះ គឺជាចំណុចពិសេសនៃច្បាប់ស្តីពីរបបសារព័ត៌មាននៅកម្ពុជា ហើយក៏ជាច្បាប់ដែលមាន

[១២០] មាត្រា៤១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[១២១] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ឆ្នាំទី១៤ លេខ១៣៥ ខែមករា-កុម្ភៈ ឆ្នាំ២០០៥ ទំព័រ ៥

[១២២] កាសែតកោះសន្តិភាព ឆ្នាំទី៤២ លេខ៦៦៩៧ ចេញផ្សាយថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ១និង៣

[១២៣] លីកាដូ របាយការណ៍សង្ខេប ស្តីពីកាដាក់កម្រិតលើសេរីភាពសារព័ត៌មាន ខែឧសភា ឆ្នាំ២០០៩

លក្ខណៈទូលាយជាងបណ្តាប្រទេសក្រៅក្រុមមួយចំនួននៅតំបន់អាស៊ី[១២៤]។ អត្ថបទជាច្រើនស្តីពីមាត្រាសិទ្ធិមនុស្ស នៅក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងអនុសញ្ញាអន្តរជាតិចែងយ៉ាងជាក់លាក់ថា សិទ្ធិជាមូលដ្ឋាននេះអាចត្រូវបានគេដាក់ដែនកំណត់ ហើយកម្រិតដោយច្បាប់សម្រាប់គោលបំណងជាក់លាក់ ជាពិសេស ដើម្បីការពារនូវសេរីភាពរបស់អ្នកដទៃ។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថាៈ ពលរដ្ឋខ្មែរទាំងអស់នឹងមានសេរីភាពខាងការបញ្ចេញមតិ លើសារព័ត៌មាន ការបោះពុម្ពផ្សាយ និងការប្រជុំគ្នា។ គ្មាននរណាម្នាក់នឹងត្រូវប្រើសិទ្ធិនេះ ដើម្បីរំលោភដល់សិទ្ធិអ្នកដទៃជះឥទ្ធិពលដល់ប្រពៃណីល្អៗរបស់សង្គម រំលោភដល់ច្បាប់សាធារណៈ និងបទបញ្ញា ហើយព្រមទាំងសង្គមជាតិទៀតផង។ ច្បាប់មួយចំនួនដែលដាក់កំហិតលើសិទ្ធិជាមូលដ្ឋានបែបនេះគឺមានធម្មនុញ្ញភាព និងស្របទៅតាមបទដ្ឋាន សិទ្ធិមនុស្ស លុះត្រាតែច្បាប់នោះអនុវត្តតាមគោលបំណងពិសេស ហើយមិនដាក់កម្រិតមិនចាំបាច់ណាមួយលើសិទ្ធិនេះ។ ជាទូទៅច្បាប់មួយដែលផ្តល់អំណាចដល់ពលរដ្ឋ អំណាចក្នុងការដាក់កំហិតលើសិទ្ធិមួយនោះ មិនស្របទៅតាមតម្រូវការនៃការកម្រិតជាធម្មនុញ្ញនៃសិទ្ធិនោះទេ[១២៥]។

សូមលើកពាក្យសន្តិសុខជាតិដែលបានបញ្ញត្តិក្នុងច្បាប់មកលាតត្រដាងៈ សន្តិសុខជាតិមិនមែនមានន័យថារាល់សន្តិសុខជាប្រយោជន៍របស់រដ្ឋាភិបាលទេ។ បើមិនដូច្នេះទេរដ្ឋាភិបាលអាចហាមឃាត់រាល់ការបញ្ចេញមតិទាំងអស់ដោយគ្រាន់តែនិយាយថា វាប៉ះពាល់នឹងផលប្រយោជន៍របស់រដ្ឋាភិបាលប៉ុណ្ណោះ។ អត្ថន័យដ៏ទូលំទូលាយសេរីភាពនៃការបញ្ចេញមតិនេះ រាប់បញ្ចូលមិនត្រឹមតែសេរីភាពក្នុងការចែកចាយព័ត៌មាន និងគំនិតផ្សេងៗ គ្រប់បែបប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងសេរីភាពក្នុងការស្វែងរក និងទទួលព័ត៌មានទាំងនោះដោយមិនគិតព្រំដែន និងតាមប្រព័ន្ធផ្សព្វផ្សាយដទៃទៀតណាមួយ ដែលគេពេញចិត្ត ពោលគឺ សេរីភាពនៃការបញ្ចេញមតិសំដៅមិនត្រឹមតែលើការពិត ទិន្នន័យ និងព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងគំនិតយោបល់ ទស្សនៈផងដែរ ដូចជាគំនិត និងទស្សនៈនានាដែលប្រឆាំងឬទិតៀនអំពីនយោបាយរដ្ឋាភិបាល បង្ហាញយ៉ាងច្បាស់នៅក្នុងទំហំនៃការការពារនូវសិទ្ធិជាចម្បងរបស់សេរីភាពក្នុងការបញ្ចេញមតិ។ ការកម្រិតយ៉ាងខ្លាំងស្តីពីសេរីភាពនៃការបញ្ចេញមតិនេះមិនត្រូវប្រើប្រាស់ក្នុងករណីបង្ខូចកេរ្តិ៍ឈ្មោះ ឬការបរិហារទេ តែនឹងត្រូវបានប្រើក្នុងករណីទាក់ទងនឹងការប្រកាន់ពូជសាសន៍ ឬការរើសអើងខាងពាក្យសម្តី ឬអំពាវនាវឲ្យមានអំពើហិង្សា។ ដូច្នេះ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ គួរត្រូវតែធ្វើការកំណត់និយមន័យឲ្យកាន់តែល្អិតល្អន់ថែមទៀត។ សន្តិសុខជាតិមានន័យថា ការគ្រោះថ្នាក់ដល់ជីវិត និងសន្តិសុខរបស់ប្រជាពលរដ្ឋទាំងមូល។ ឧទាហរណ៍ ជីវិតរបស់ជាតិទាំងមូលស្ថិតក្នុងភាពគ្រោះថ្នាក់ ពីព្រោះតែការវាយប្រហារយោធាពីប្រទេសផ្សេងទៀត ឬដោយមានការញុះញង់ឲ្យមានអំពើហិង្សាទម្លាក់រដ្ឋាភិបាលកាន់អំណាច។

ដើម្បីជានាការផ្សព្វផ្សាយត្រឹមត្រូវនិងមិនរំលោភច្បាប់យើងបានបង្កើតឲ្យមានច្បាប់ស្តីពីរបបសារព័ត៌មាន

[១២៤] ប្រសាសន៍ឯកឧត្តម ខៀវ កាញារីទ្ធ ក្នុងទិវាសេរីភាពសាព័ត៌មានពិភពលោកកាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៩ នៅវិទ្យាស្ថានជាតិអប់រំ

[១២៥] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យៈ សិទ្ធិមនុស្ស ឆ្នាំ២០០៤, ទំព័រ ៤១

និងក្រមសីលធម៌ព័ត៌មាន ដែលជាគោលការណ៍ដ៏ធំបំផុតនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដោយប្រជាធិបតេយ្យ ត្រូវឈរលើច្បាប់ និងមូលដ្ឋាននីតិរដ្ឋ។ បើគ្មាននីតិរដ្ឋជាមូលដ្ឋានទេ នោះអាចឈានទៅរកភាពអនាធិបតេយ្យ។ ដូច្នេះ ការពង្រឹងនីតិរដ្ឋ គឺធ្វើឲ្យមានតុល្យភាពរវាងសិទ្ធិសេរីភាព និងការទទួលខុសត្រូវរបស់អ្នកសារព័ត៌មាន។ អ្នកកាសែតត្រូវតែធ្វើឲ្យបានត្រឹមត្រូវតាមវិជ្ជាជីវៈ និងតាមច្បាប់ស្តីពីរបបសារព័ត៌មានដូចមានចែងក្នុងមាត្រា៧ថា ត្រូវគោរពសច្ចៈធម៌ និងគោរពសិទ្ធិយល់ដឹងនូវសច្ចៈធម៌របស់សាធារណៈជន បានន័យថាកុំកុហក កុំបំផ្លើស កុំបង្កើតព័ត៌មានប្រាសចាកការពិត ត្រូវផ្សាយនូវដំណឹងទាំងឡាយដោយសុចរិត និងធ្វើអត្ថាធិប្បាយ ឬរិះគន់ឲ្យត្រឹមត្រូវ និងសមស្របតាមសីលធម៌ ព្រមទាំងរាយការណ៍តាមហេតុការណ៍ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ។ អ្នកកាសែត មិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ ឬកែបន្លំឯកសារផ្សេងៗឡើយ[១២៦]។ បើផ្តេកទៅលើទម្រង់នៃរបបវិជ្ជាជីវៈសារព័ត៌មានដាច់ខាតត្រូវតែមានជំហរឯករាជ្យ អព្យាក្រិត្យមិនប្រឆាំង និងមិនគាំទ្រ ហើយត្រូវតែឈរលើពាក្យពិត ព្រោះពាក្យពិតជាខ្នងបង្អែកដ៏រឹងមាំសម្រាប់ការពារខ្លួន។ ឯនៅក្នុងសីលប្រាំរបស់ព្រះពុទ្ធបរមគ្រូ នៃមនុស្សលោក ក៏បានបញ្ញត្តិទុកហាមប្រាមពុទ្ធសាសនិកជនមិនឲ្យនិយាយភូតភ និយាយមិនពិត(មុសាវាទ) កាលណាពោលពាក្យមុសាវាទបណ្តាលឲ្យទទួលបាបកម្ម។ ចាប់ពីក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣ ដែលបង្កើតបានរបបរាជាណាចក្រកម្ពុជាទី២ ប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្សរហូមកដល់បច្ចុប្បន្ន។ រូបភាពនៃការសម្តែងមតិតាមរយៈការសរសេរព័ត៌មាន មានការរីកចម្រើនខ្លាំងជាងគេ ដោយបង្កើតបានជាសមាគមអ្នកសារព័ត៌មានខ្មែរ និងសម្ព័ន្ធសារព័ត៌មានខ្មែរឡើងសម្រាប់ធានានូវសិទ្ធិស្របច្បាប់របស់សារព័ត៌មាន។ ប៉ុន្តែ ទោះបីមានច្បាប់ស្តីពីរបបសារព័ត៌មាន និងសិទ្ធិទាំងឡាយនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងគោលការណ៍នីតិរដ្ឋ ក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សក៏ដោយ ក៏នៅតែមានសារព័ត៌មានមួយចំនួនបានប្រើសិទ្ធិនេះហួសព្រំដែនច្បាប់ ដោយមិនគ្រាន់តែទិតៀនរដ្ឋាភិបាល ដោយការសម្តែងមតិរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជេរប្រមាថដល់ថ្នាក់ដឹកនាំប្រទេស ដែលអំពើនេះធ្វើឲ្យប៉ះពាល់កិត្តិយសយ៉ាងធ្ងន់ធ្ងរចំពោះប្រមុខរាជរដ្ឋាភិបាល។ មានកាសែតខ្លះសរសេរដោយមានចេតនាមិនល្អបង្កប់នូវអំពើញុះញង់ផងដែរ ដូចជាសរសេរថា"លោកជំទាវ មួរ សុខហួរ ប្តឹងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សម្តេច ជា ស៊ីម សប្បាយចិត្ត, សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ខឹងលោក សុខ អាន ខ្លាំងណាស់ព្រោះគាត់ចេះតែចង់ធ្វើនាយករដ្ឋមន្ត្រី។ លើសពីនេះមានសរសេរថា ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសសម្រាប់ដាក់លក់ ប្រទេសចោរដឹកនាំដោយនាយករដ្ឋមន្ត្រីជាចោរលួចជាតិ...។ ការជេរប្រមាថហួសពីសេចក្តីថ្លៃថ្នូរជាមនុស្ស វានាំទៅដល់ការញុះញង់ និងអាចក្លាយទៅជាភាពអាណាធិបតេយ្យ ដោយសារការអនុវត្តន៍សិទ្ធិរបស់ខ្លួនហួសព្រំដែនច្បាប់។ ដោយឡែក បើទោះបីតាមច្បាប់ស្តីពីរបបសារព័ត៌មានចែងថា អ្នកកាសែតមិនត្រូវបានគេចាប់ដាក់គុកពីកំហុសឆ្គងក្នុងការសរសេរអត្ថបទចុះផ្សាយនោះទេ និងបើទោះបីមានការប្រកាសក្តែងៗជា

[១២៦] សម្រង់ប្រសាសន៍របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន នៅក្នុងកាសែតកោះសន្តិភាព លេខ៦៦៩៧ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩

សាធារណៈពីប្រមុខរដ្ឋាភិបាលថា ឈប់ឲ្យមានការចាប់អ្នកការសែតដាក់គុក ព្រោះការសរសេរក៏ដោយ តែឥឡូវនេះបែរជាផ្ទុយទៅវិញ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ យោងតាមរបាយការណ៍លីកាដូពីខែមករា ឆ្នាំ២០០៨ ដល់ខែមីនា ឆ្នាំ២០០៩ បានរកឃើញថា អ្នកសារព័ត៌មានមួយចំនួនដែលសរសេររិះគន់ដល់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ត្រូវបានទទួលរងការគំរាមកំហែង របួសស្នាម ការប្តឹងពីបទបរិហាកេរ្តិ៍ និង/ឬបទផ្សាយព័ត៌មានមិនពិត។ ការរាយការណ៍លើប្រធានបទសើបជារឿងប្រថុយប្រថាន[១២៧] និងបាញ់សម្លាប់ដូចជាៈ

នៅខែវិច្ឆិកា ឆ្នាំ២០០៧ ក្រសួងមហាផ្ទៃ និងក្រសួងព័ត៌មានបានដកហូតយក **ទស្សនាវដ្តី សារព័ត៌មានសេរី** ពីតូបលក់កាសែត។ អ្នកបោះពុម្ពផ្សាយត្រូវបានបញ្ជាឲ្យបិទផ្សាយរបស់ខ្លួន។ ក្រោយមកលោក ឡឹម ពិសិដ្ឋ និពន្ធនាយកបានរត់គេចខ្លួនទៅនៅបរទេសកាលពីខែឧសភា ឆ្នាំ២០០៨។

នៅខែឧសភា ឆ្នាំ២០០៨ ក្រសួងព័ត៌មានបានបិទស្ថានីយ៍វិទ្យុអង្គររដ្ឋា ខេត្តក្រចេះ និងដកហូតយកអាជ្ញាប័ណ្ណ ដោយសារវិទ្យុនេះបានលក់ម៉ោងផ្សាយទៅឲ្យគណបក្សនយោបាយ ៤ ដោយគ្មានការអនុញ្ញាត។

នៅខែមិថុនា ឆ្នាំ២០០៨ លោក ដាំសិទ្ធិ ជានិពន្ធនាយកកាសែត មនសិការខ្មែរ ត្រូវបានចាប់ខ្លួពីបទជេរប្រមាថ និងផ្សាយព័ត៌មានមិនពិតក្នុងការរាយការណ៍ពីសន្ទរកថា របស់មេដឹកនាំគណបក្សប្រឆាំងដែលថាមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលពីរនាក់មានជាប់ពាក់ព័ន្ធនឹងរបបខ្មែរក្រហម។ ករណីនេះត្រូវបិទភ្លាមនៅពេលលោក ដាំ សិទ្ធិ បានសុំទោសពីកំហុសរបស់ខ្លួន។

នៅឆ្នាំ២០០៩ យើងឃើញមានឈានទៅដល់ការ កម្រិតសេរីភាពបញ្ចេញមតិនៅលើអ៊ីធឺណែត (Internet) តាមការរាយការណ៍ឲ្យដឹងថា រដ្ឋាភិបាលបានបិទវែបសាយ(Webside)ពីរ គឺវែបសាយឃ្លាំមើលសកលលោក(Global- Witness) និង វែបសាយ (Reahu.net)[១២៨]។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ អ្នកសារព័ត៌មានភាសាខ្មែរបីនាក់ ដែលមិនសូវស្គាល់បានភៀសខ្លួនពីខេត្តពោធិ៍សាត់ ក្រោយពីតុលាការបានចេញដីកាចាប់ខ្លួន ដោយចោទប្រកាន់ពីបទបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍ បើទោះបីជាពួកគេទាំងបីនាក់បានអះអាងថា គ្រាន់តែបានចតរថយន្តរបស់ខ្លួននៅជិតស្ពានមួយដើម្បីថតរូបស៊ើបអង្កេតការដឹកជញ្ជូនគ្រឿគេចពន្ធតែប៉ុណ្ណោះក៏ដោយ។

នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ កងរាជអាវុធហត្ថខេត្តស្ទឹងត្រែង បានប្ដឹងអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី និងក្រុមសិទ្ធិមនុស្សទៅតុលាការ។ តុលាការខេត្តស្ទឹងត្រែង បានចោទប្រកាន់អ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីឈ្មោះ រដ្ឋា វីសាល និងសកម្មជនសិទ្ធិមនុស្សអាដហុក ឈ្មោះ ឆាយ រ័ត្ន ពីបទផ្សាយព័ត៌មានមិនពិត និងការស៊ើបអង្កេតមិនត្រឹមត្រូវ។

---

[១២៧] របាយការណ៍ឃ្លាំមើលសភា មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ឆ្នាំ២០០៧

[១២៨] លីកាដូៈ របាយការណ៍រួមរបស់អង្គការក្រៅរដ្ឋាភិបាលស្ដីពីសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ សម្រាប់ការត្រួតពិនិត្យជាសកលតាមពេលកំណត់នៃការបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ ១០

នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ លោក លឹម ពិសិដ្ឋ អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរីត្រូវបាន គំរាមកំហែងដល់អាយុជីវិត។ ដោយមានការទម្លាក់គ្រាប់កាំភ្លើយអាកា ៤៧ ចំនួន ៦គ្រាប់ នៅខាងក្រៅផ្ទះរបស់ លោកនៅខេត្តបាត់ដំបង។ ហើយនៅខែមករា ឆ្នាំ២០០៩ លោក លឹម ពិសិដ្ឋ និងគ្រួសាររបស់លោកបានទទួល សិទ្ធិជ្រកកោណនៅប្រទេសន័រវេស៍។

នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ស្ថានីយ៍វិទ្យុអង្គរវដ្ឋា ខេត្តក្រចេះ បានបិទដោយក្រសួងព័ត៌មាន ក្រោមការចោទប្រកាន់ពីបទរំលោភកិច្ចសន្យា។

នៅថ្ងៃទី២៧ ខែមិថុនាឆ្នាំ២០០៨ អ្នកសារព័ត៌មានមាតុភូមិឈ្មោះ រី នៅ បានត្រូវគ្រាប់ចំពាម កៅស៊ូត្រូវចំមុខបណ្តាលឲ្យរបួសធ្ងន់ខណៈពេលលោកកំពុងស៊ើបអង្កេតក្នុងករណីកាប់ឈើខុសច្បាប់ នៅស្រុក សន្ទុកខេត្តកំពង់ធំ។

នៅថ្ងៃទី១១ ខែកក្កដា(២សប្តាហ៍មុនថ្ងៃបោះឆ្នោតជាតិ)ឆ្នាំ២០០៨ លោក ឃឹម សំបូរ អ្នក សារព័ត៌មានរបស់សារព័ត៌មានមនសិការខ្មែរ ដែលជាសារព័ត៌មានភាសាខ្មែរគាំទ្រគណបក្សសម រង្ស៊ី ត្រូវបាន គេបាញ់សម្លាប់ព្រមទាំងបាញ់សម្លាប់កូនប្រុសរបស់លោកឈ្មោះ ខាត់ សារិនភាតា អាយុ២១ឆ្នាំផងដែរ។

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨ អ្នកយកព័ត៌មានកោះសន្តិភាពម្នាក់ឈ្មោះ រស់ សុភីណា ប្រចាំនៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ត្រូវបានមេបញ្ជាការកងរាជអាវុធហត្ថ ឧត្តមសេនីយ៍ផ្កាយបី ឈ្មោះ ង៉ែត វណ្ណថា ទះកំភ្លៀងដោយគ្រាន់តែលោកចុះផ្សាយពីលោកមេបញ្ជាការរូបនេះមានជាប់ពាក់ព័ន្ធនឹងការដឹក ឈើខុសច្បាប់។

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ លោក ស៊ុន យ៉ាត ជាអ្នកសារព័ត៌មានកោះសុវណ្ណភូមិ ត្រូវបាន មន្ត្រីនគរបាលឈ្មោះ ហួ យ៉ៃ បានវាយឲ្យរបួសក្បាលយ៉ាងធ្ងន់ធ្ងរ ហើយថែមទាំងបានដកយកម៉ាស៊ីនថតរូប របស់លោកទៀតផង ខណៈពេលលោកកំពុងថតរូបនគរបាលរូបនេះ កំពុងអង្គុយជិតស្ត្រីសក់ក្រហមម្នាក់ក្នុង ពិធីអាពាហ៍ពិពាហ៍មួយនៅក្នុងខេត្តព្រះសីហនុ។

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៦ លោកចាងហ្វាងកាសែតខ្មែរម្ចាស់ស្រុក ឈ្មោះ ហង្ស ចក្រា ត្រូវ បានចាប់ខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់សាលាដំបូងរាជធានីភ្នំពេញ ក្រោមបទចោទប្រកាន់ថា បានផ្សាយ ព័ត៌មានមិនពិត តាមបណ្តឹងរបស់លោកមេធាវីរដ្ឋាភិបាល[១២៥]។

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ លោកខេវិន ដូល (Kevin Doyle) ជាអ្នកនិពន្ធនាយករបស់សារព័ត៌ មាន The Cambodia Daily និងលោក នៅ សារិន ជាអ្នកយកព័ត៌មាន ត្រូវបានតុលាការរាជធានីភ្នំពេញ បាន សម្រេចឲ្យបង់ប្រាក់ក្នុងម្នាក់ៗចំនួន៤លានរៀល តាមមាត្រា១០ នៃច្បាប់ស្តីពីសារព័ត៌មានឆ្នាំ១៩៩៥ ពីបទ

[១២៥] ការសែតកោះសន្តិភាព លេខ៦៦៨៧ ចេញផ្សាយថ្ងៃទី២៧-២៨ ខែមិថុនា ឆ្នាំ២០០៩

មិនបានបោះពុម្ពផ្សាយព័ត៌មានកែតម្រូវព័ត៌មានបរិហារកេរ្តិ៍[១៣០]។ លោកស្រី ណាលី ភីលូក នាយកអង្គការសិទ្ធិមនុស្សលីកាដូ បានលើកឡើងថាសមាជិកនៃប្រព័ន្ធផ្សព្វផ្សាយ គួរត្រូវបានការពារក្នុងការបំពេញភារកិច្ចរបស់គេ ហើយមិនគួរប្រឈមនឹងការវាយប្រហារផ្លូវច្បាប់ ដោយគ្រាន់តែរាយការណ៍ព័ត៌មាននោះទេ។

ឯកឧត្តម ខៀវ កាញារីទ្ធ បានលើកឡើងតាមរយៈបទសម្ភាសន៍របស់អ្នកកាសែតភ្នំពេញប៉ុស្តិ៍ ដែលចេញផ្សាយកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩ ថា កម្ពុជាបានចែងក្នុងច្បាប់ដែរថា រាល់ការបោះពុម្ពផ្សាយផ្សេងៗ គឺមិនត្រូវមានការត្រួតពិនិត្យជាមុននោះទេ និងមួយទៀត គឺកម្ពុជាធានានូវសិទ្ធិរបស់អ្នកសារព័ត៌មានដែលថាមិនមានអ្នកសារព័ត៌មានណាម្នាក់ជាប់ពន្ធនាគារដោយសារតែការបញ្ចេញមតិរបស់ខ្លួនទេ ប៉ុន្តែវាផ្ទុយពីករណីផ្សាយព័ត៌មានមិនពិត។ កម្ពុជាត្រូវបានគេចាត់ទុកថា សិស្សល្អក្នុងតំបន់ខាងផ្នែកសេរីភាពសារព័ត៌មាន។

ចាប់តាំងពីឆ្នាំ១៩៩៣មកដល់ពេលនេះ អ្នកកាសែតចំនួន១០នាក់ហើយ ដែលត្រូវបានសម្លាប់ តែរដ្ឋាភិបាលនៅតែរកឃាតករពុំឃើញ[១៣១]។ អ្នកកាសែតភាគច្រើននិយាយថា ពួកគាត់មិនទាន់ទទួលសិទ្ធិសេរីភាពគ្រប់គ្រាន់តាមច្បាប់សារព័ត៌មាននៅឡើយទេ នៅក្នុងរបបប្រជាធិបតេយ្យនៅកម្ពុជាបច្ចុប្បន្ននេះ បានសេចក្តីថាទាំងរដ្ឋាភិបាល និងតុលាការតែងអនុវត្តច្បាប់ផ្ទុយទាំងស្រុងពីច្បាប់ស្តីពីរបបសារព័ត៌មាន ដែលរដ្ឋសភាបានអនុម័តរួចហើយកាលពីឆ្នាំ១៩៩៥ ក្នុងការផ្តល់សិទ្ធិសេរីភាពជូនអ្នកសារព័ត៌មាន។ បើយោងតាមច្បាប់ស្តីពីរបបសារព័ត៌មាននោះ គឺអ្នកកាសែតមិនត្រូវបានគេចាប់ដាក់គុកពីកំហុសឆ្គងក្នុងការសរសេរអត្ថបទចុះផ្សាយនោះទេ សូម្បីប្រមុខរដ្ឋាភិបាលក៏ធ្លាប់បានប្រកាសគាំទ្រពីបញ្ហានេះរួចហើយដែរ។ តែរហូតមកដល់ពេលនេះ អ្នកកាសែតខ្មែរ បែរជានៅតែត្រូវគេចាប់ដាក់គុណដោយយកច្បាប់ព្រហ្មទណ្ឌអន្តរកាល មកចាត់ការយ៉ាងអយុត្តិធម៌ទៅវិញដូចជា ករណីចាប់លោក ហង្ស ចក្រា(ជ័យឧត្តម) ចាងហ្វាងកាសែតខ្មែរម្ចាស់ស្រុកយកទៅដាក់គុកព្រៃស ព្រោះតែសរសេរអត្ថបទចុះផ្សាយរិះគន់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលពេលថ្មីៗនេះជាដើម[១៣២]។ ការយកច្បាប់ព្រហ្មទណ្ឌអន្តរកាលមកកាត់ទោសអ្នកកាសែត គឺជាការប្រមាថមើលងាយយ៉ាងធ្ងន់ធ្ងរ ចំពោះច្បាប់ស្តីពីរបបសារព័ត៌មានដែលរដ្ឋសភាបានអនុម័តរួចហើយ។

នៅពេលដែលអ្នកសារព័ត៌មានទូទាំងពិភពលោក ប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកកាលពីថ្ងៃអាទិត្យទី ០៥ ខែ ឧសភា ឆ្នាំ២០០៩ ក្រុមអង្គការឃ្លាំមើលអន្តរជាតិ ក៏ដូចជាអង្គការឃ្លាំមើលក្នុងស្រុកបាននិយាយថា ប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសកម្ពុជា ត្រូវបានគេដាក់កម្រិតក្នុងការបញ្ចេញមតិកាន់តែខ្លាំង[១៣៣]។ លើសពីនេះ មានការវាយតម្លៃ កាលពីខែឧសភា ឆ្នាំ២០០៩ ដោយអង្គការអ្នកយកព័ត៌មានគ្មានព្រំដែន

---

[១៣០] កាសែតភ្នំពេញប៉ុស្តិ៍ ឆ្នាំទី១ លេខ១០ ថ្ងៃទី៣២ ខែកញ្ញា ឆ្នាំ២០០៩

[១៣១] ប្រសាសន៍របស់លោក ប៉ែន សមិទ្ធិ និពន្ធនាយកសារព័ត៌មាន រស្មីកម្ពុជាៈ កម្មវិធីផ្សាយបន្តផ្ទាល់របស់វិទ្យុ VOA នៅកម្ពុជាម៉ោង៧ និង៣០នាទី ដល់ម៉ោង៨ និង៣០នាទីល្ងាច ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩

[១៣២] កាសែតខ្មែរអមតៈ ឆ្នាំទី១០ លេខ៦២៦ ចេញផ្សាយថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩

[១៣៣] កាសែតឌឺ ឃែមបូឌា ដេលី ច្បាប់ទី៤២ ចេញផ្សាយ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩

(Reporters Without Borders) ជាអង្គការឃ្លាំមើលអន្តរជាតិ បានរាប់បញ្ចូលប្រទេសកម្ពុជានៅ ក្នុងចំណោមប្រទេសដែល "ស្ទាក់ស្ទើររវាងការគាប់សង្កត់ និងសេរីភាវូបនីយកម្ម ជាទីដែលបម្រាមនៅតែមិនអាចរំលោភបំពានបាន និងច្បាប់សារព័ត៌មានងាកត្រឡប់ទៅរកសម័យមួយទៀត"។ អង្គការនេះបានបន្ទាបការចាត់ចំណាត់ថ្នាក់ប្រទេសកម្ពុជា ផ្នែកសេរីភាពសារព័ត៌មានរបស់កម្ពុជាមកទី១២៦នៅក្នុងពិភពលោក សម្រាប់ឆ្នាំ២០០៨ គឺធ្លាក់ចុះពីទី៨២ នៅឆ្នាំ២០០៧។ ការធ្លាក់ចុះនេះ កើតឡើងដោយសារមានឃាតកម្មលើអ្នកសារព័ត៌មាន។

អង្គការអន្តរជាតិមួយទៀត គឺអង្គការ Freedom House ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក បានបន្ទាប់ចំណាត់ថ្នាក់ផ្នែកសារព័ត៌មានរបស់កម្ពុជាពី "មានសេរីភាពដោយអន្លើ" មក "គ្មានសេរីភាព" ការវាយតម្លៃរបៀបនេះដោយសារកើតមានអំពើហិង្សាកើនឡើងប្រឆាំងអ្នកសារព័ត៌មាន។ យោងតាមរបាយការណ៍ខ្លីមួយរបស់អង្គការសិទ្ធិមនុស្សក្នុងស្រុកលីកាដូ ចេញផ្សាយពីខែឧសភា បានឲ្យដឹងថា កាសែតចំនួន ១៣ ក្នុងចំណោមកាសែតចំនួន ២៧ ត្រូវបានគេដឹងថា មានការលំអៀងទៅរកគណបក្សប្រជាជនកម្ពុជា ដែលកំពុងកាន់អំណាច[១៣៤]។ ព្រឹត្តិការណ៍អាប់អួរដូចបានលើកឡើងខាងលើនេះ ជាហេតុផលដែលបង្ហាញ អំពីកម្រិតយល់ដឹងមិនទាន់ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយអំពីព្រំដែនសេរីភាពនៃការបញ្ចេញមតិ ដែលការពិតក្នុងស្ថានភាពខ្លះមិនអំណោយផលឡើយក្នុងការបញ្ចេញមតិដែលជ្រុលហួសនោះ ដូចជាមានកំណត់នៅក្នុងកថាខណ្ឌទី៣ មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ឯច្បាប់ស្តីពីរបបសារព័ត៌មានដែលរដ្ឋសភាជាតិបានអនុម័ត កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥ ក៏បានទាមទារ និងអនុញ្ញាតឲ្យមានសមាគមអ្នកកាសែតធ្វើសកម្មភាពការពារសេរីភាពរបស់សារព័ត៌មានឲ្យបានគាប់ប្រសើរ។ លក្ខខណ្ឌកម្រិតព្រំដែនសិទ្ធិសេរីភាពបញ្ចេញមតិ គឺជាការចាំបាច់ ដើម្បីធានាឲ្យមានលទ្ធភាពប្រជាធិបតេយ្យ ព្រោះថាសេរីភាពត្រូវដើរទន្ទឹមនឹងកាតព្វកិច្ច និងករណីយកិច្ច។ ដូច្នេះ សេរីភាពខាងការបញ្ចេញមតិ ជាពិសេសសេរីភាពខាងសារព័ត៌មានក៏ត្រូវមានការកំណត់ដោយកាតព្វកិច្ចមួយចំនួនដែរ[១៣៥]។ ស្មារតីចំពោះការកម្រិតព្រំដែនសិទ្ធិខាងការបញ្ចេញមតិនេះ គឺក្នុងគោលបំណងធានាសន្តិសុខ សណ្តាប់ធ្នាប់ សីលធម៌សង្គម និងការពារសិទ្ធិរបស់បុគ្គលដូចមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញចែងថា ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។

ដូច្នេះអាចសន្និដ្ឋានបានថាៈ ប្រព័ន្ធសារព័ត៌មាន មានសារៈសំខាន់ណាស់ ព្រោះវាបានផ្តល់អំណាចថាមពលខ្ពស់ ប្រៀបដូចជាប្រេងរំអិល អាចជួយសម្របសម្រួល ផ្តល់ចំណេះដឹង បណ្តុះ និងពង្រឹងស្មារតីសង្គមជាដើម ហើយក៏ជាការផ្តល់នូវវិទ្ធង្សនា ញុះញង់ផងដែរ។ បើប្រៀបធៀបពីទ្រឹស្តីរបស់អ្នកប្រាជ្ញស្តីពីប្រព័ន្ធសារ

[១៣៤] កាសែតឌឹ ឃែមបូឌា ដេលី ច្បាប់ទី៦ ចេញផ្សាយថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩

[១៣៥] រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៩៨

ព័ត៌មានទៅនឹងប្រព័ន្ធសារព័ត៌មាននៅកម្ពុជាបច្ចុប្បន្ន ឃើញថាស្ថានភាពប្រព័ន្ធសារព័ត៌មាននៅកម្ពុជាពុំទាន់ត្រូវបានបើកចំហទៅតាមកម្រិតវិជ្ជាជីវៈសារព័ត៌មាន ទៅតាមសច្ចភាពនៃព្រឹត្តិការណ៍ ដែលបានកើតឡើងជាក់ស្តែងនោះទេ ប្រព័ន្ធសារព័ត៌មានភាគច្រើន បង្កើតឡើងដោយមាននិន្នាការគណបក្សនយោបាយបង្កើតឲ្យមានភាពចម្រូងចម្រាសគ្នាជាច្រើន និងមានការរើសអើង ឯអ្នកសារព័ត៌មាននៅមានភាពភ័យខ្លាចពីសុវត្ថិភាពទៀតផង។ ដោយសារស្ថាប័ននេះនៅពុំទាន់មានធម្មនុញ្ញភាព និងក្រមសីលធម៌ត្រឹមត្រូវ។ សិទ្ធិសេរីភាពពលរដ្ឋក្នុងគោល-ការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ប្រសិនបើអំណាចសារព័ត៌មានគ្មានខ្នាតជាលាយលក្ខណ៍ និងពុំមែនជាស្ថាប័នអព្យាក្រឹតទេ នោះពលរដ្ឋខ្មែរម្ចាស់ប្រទេសទាំងអស់ មិនអាចរស់នៅក្នុងសង្គមជាមួយគ្នាដោយសុខសន្តិភាព ជានានឹងគ្នាបានឡើយ។

### ៣.២.៤ សិទ្ធិសេរីភាពទទួលព័ត៌មានរបស់សាធារណៈជន

បើនិយាយពីព័ត៌មានសាធារណៈ សំដៅដល់ព័ត៌មានទាំងឡាយដែលប្រមូលចងក្រង និងកាន់កាប់ដោយស្ថាប័នសាធារណៈ ហើយស្ថិតនៅក្រោមបញ្ញត្តិច្បាប់ ឬទាក់ទងនឹងកិច្ចការផ្លូវការណ៍ទាំងឡាយរបស់ស្ថាប័នសាធារណៈ។ ព័ត៌មានសាធារណៈអាចមានទម្រង់ជាសៀវភៅ ក្រដាសស្នាម លិខិត ឯកសារ រូបថត ភាពយន្តខ្សែអាត់ មីក្រូហ្វីល សំឡេងអាត់ទុក ផែនទី និងគំនូរ ខ្សែវីដេអូ សំឡេង រូបភាព ឬទិន្នន័យ និងវីដេអូរ[១៣៦]។ តាមផ្នត់គំនិត និងទម្លាប់ជាប្រវត្តិសាស្ត្ររបស់មេដឹកនាំខ្មែរ របៀបរបបគ្រប់គ្រង និងដឹកនាំកិច្ចការរដ្ឋ គឺបិតក្នុងភាពសម្ងាត់ និងបិទជិតទាំងស្រុង។ ព័ត៌មានទាក់ទងនឹងការសម្រេចចិត្តលើកិច្ចការនានាភាគច្រើនពុំហ៊ានផ្សព្វផ្សាយឲ្យសាធារណៈជនបានដឹងលឺឡើយ។

ដំណើរការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យលើកទី២ ដោយគិតចាប់តាំងពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ននេះ ឃើញថា ការគោរពសិទ្ធិមនុស្ស និងការបំពេញកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា បានវិវត្តជាវិជ្ជមានជាបន្តបន្ទាប់ស្របតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ដែលទាំងអស់នេះជាសិទ្ធិសេរីភាព និងជាអំណាចរបស់ប្រជាពលរដ្ឋម្ចាស់ប្រទេសជាតិ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏ប្រជាពលរដ្ឋខ្មែរនៅតែមិនទាន់អាចប្រើសិទ្ធិសំខាន់ៗ ជាពិសេសប្រជាពលរដ្ឋខ្មែរពុំអាចមានអំណាចពិតប្រាកដដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងតាមគោលការណ៍ប្រជាធិបតេយ្យនៅឡើយទេ។ ភាពខ្វះចន្លោះទាំងនោះមានជាអាទិ៍ ការរំលោភសិទ្ធិមនុស្ស ការកាប់បំផ្លាញព្រៃឈើដើម្បីទន្ទ្រានយកដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ទំនាស់ដីធ្លី ការនេសាទខុសច្បាប់ ការបណ្តេញចេញដោយបង្ខំ។ អ្នករងគ្រោះភាគច្រើនជាប្រជាជនក្រីក្រគ្មានអំណាច និងរហូតដល់សហគមន៍ជនជាតិដើមភាគតិចទៀតផង។ សិទ្ធិសេរីភាពបញ្ចេញមតិតាមទីសាធារណៈរបស់ប្រជាពលរដ្ឋនៅមានកម្រិត។ ព័ត៌មានសាធារណៈសំខាន់ៗមួយចំនួន ដូចជា

[១៣៦] ខិត្តប័ណ្ណរបស់អង្គការ បើកចំហព័ត៌មានសាធារណៈ ឆ្នាំ២០០៦

កិច្ចសន្យាវិនិយោគសាធារណៈ ការដេញថ្លៃការចំណាយផ្សេងៗរបស់រដ្ឋ ការកំណត់ថ្លៃសម្រាប់សេវាសាធារណៈនានាមិនទាន់បានផ្សព្វផ្សាយឲ្យបានគ្រប់គ្រាន់ និងជាសាធារណៈដល់ប្រជាពលរដ្ឋឡើយ។ ឧទាហរណ៍ៈ ការបង់ថ្លៃសេវាធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ អត្តសញ្ញាណប័ណ្ណ សកម្មភាពនេសាទ ការចុះបញ្ជីដីធ្លី និងសេវាមិនបង់ថ្លៃជាច្រើនទៀតរបស់រដ្ឋនៅតែជាអំពើអាថ៌កំបាំងដដែល ដែលបង្កភាពមន្ទិលដល់ប្រជាពលរដ្ឋនៅតែបន្តញាំញីដោយភាពក្រីក្រ។ តាមការពិតប្រជាពលរដ្ឋខ្មែរមានសិទ្ធិដឹងលឺ អំពីកិច្ចការសាធារណៈ ឬព័ត៌មានសាធារណៈពីព្រោះពួកគាត់ជាអ្នកបង់ពន្ធ ជាម្ចាស់អំណាច និងជាម្ចាស់ប្រទេសជាតិរបស់ខ្លួន។ សិទ្ធិជាមូលដ្ឋាន ទាំងនេះធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋ ដើម្បីទទួលបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពនូវព័ត៌មានប្រកបដោយគុណភាពខ្ពស់ និងត្រឹមត្រូវ ដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរសាធារណៈ ផ្សេងទៀតដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២ៈ ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ...[១៣៧]។

ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួលព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែនដោយផ្ទាល់សរសេរ ឬបោះពុម្ពតាមទម្រង់សិល្បៈក្តី ឬក៏មធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន[១៣៨]។

សិទ្ធិទទួលព័ត៌មា ជាសិទ្ធិដ៏មានសារៈសំខាន់និងចាំបាច់បំផុតនៅក្នុងគោលការណ៍ប្រជាធិបតេយ្យ ព្រោះថា ការទទួលព័ត៌មាន វាធ្វើឲ្យយើងមានចំណេះដឹងដើម្បីធ្វើការប្រៀបធៀប ឬផ្លាស់ប្តូរព័ត៌មានទៅអ្នកឯទៀត ឬក៏ប្រឆាំងទប់ទល់នឹងការរំលោភបំពានផ្សេងៗ ជាពិសេសទប់ទល់នឹងការគ្រប់គ្រងមិនត្រឹមត្រូវ ឬការសម្រេចចិត្តមិនត្រឹមត្រូវជាដើម។ ម្យ៉ាងវិញទៀត ក៏អាចជាប្រយោជន៍ដល់រាជរដ្ឋាភិបាលខ្លួនឯងផ្ទាល់ផងដែរ ដើម្បីកែលំអ។ ព្រោះថា ការធ្វើសេចក្តីសម្រេចចិត្តដោយបើកចំហ និងតម្លាភាពអាចជួយពង្រីក និងពង្រឹងនូវទំនុកចិត្តពីប្រជា-ពលរដ្ឋចំពោះរាជរដ្ឋាភិបាលផងដែរ[១៣៩]។ សេរីភាពនៃការបញ្ចេញមតិ រួមបញ្ចូលផងដែរនូវការទទួលបានព័ត៌មានដោយសេរី ពីព្រោះព័ត៌មានអំពីគំនិតនិងការពិត គឺជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតគំនិតនិងទស្សនៈ។ ឧទាហរណ៍ៈ ដើម្បីធានាបានសិទ្ធិជាមូលដ្ឋានគ្រឹះនៃសេរីភាពសារព័ត៌មាន ការកាត់សេចក្តីនានារបស់តុលាការ ឬសម័យប្រជុំនានា របស់រដ្ឋសភាក្នុងប្រទេសកម្ពុជាទាំងអស់ ត្រូវបើកទូលាយចំពោះសារជាណៈជន។ សិទ្ធិទទួលបានព័ត៌មានដោយសេរីនឹងត្រូវប៉ះពាល់នៅពេលអ្នកសារព័ត៌មាននានា មិនត្រូវអនុញ្ញាតឲ្យចូល និងរាយការណ៍អំពីអង្គប្រជុំ

---

[១៣៧] មាត្រា៤១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

[១៣៨] មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[១៣៩] រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៩៨

នានា។ រាល់បុគ្គលទាំងអស់មានសិទ្ធិស្នើសុំដឹងពីព័ត៌មានស្ថាប័នរដ្ឋ លើកលែងតែស្ថាប័ននោះស្ថិតនៅក្នុងចំណុច នៃករណីលើកលែងដែលគេកំណត់ទុក។ ការបដិសេធមិនព្រមផ្សព្វផ្សាយព័ត៌មានអាចធ្វើទៅបាន ប្រសិនបើអាជ្ញាធរសាធារណៈនោះអាចបង្ហាញថា ព័ត៌មាននោះស្ថិតក្នុងចំណុចករណីលើកលែងដាច់ខាតបីចំណុចៈ

(ក) ព័ត៌មានត្រូវទាក់ទិននឹងមាត្រាច្បាប់យ៉ាងត្រឹមត្រូវដូចដែលមានចែងក្នុងច្បាប់។

(ខ) ការផ្សព្វផ្សាយព័ត៌មានអាចបណ្តាលឲ្យមានផលប៉ះពាល់ច្រើនដល់មាត្រាច្បាប់នោះព្រមទាំងផលប៉ះពាល់នៃមាត្រាច្បាប់ធំជាងផលប្រយោជន៍សាធារណៈ ប្រសិនបើគេផ្សព្វផ្សាយព័ត៌មាននោះ។

(គ) គ្មានស្ថាប័នរដ្ឋណា ដែលគួរត្រូវបានគេដកចេញទាំងស្រុងពីគន្លងច្បាប់ទេ ទោះជាកិច្ចការរបស់គេភាគច្រើនស្ថិតក្នុងករណីលើកលែងទាំងនោះក៏ដោយ។ (ស្ថាប័នទាំងនេះគឺ សាខានីតិបញ្ញត្តិ សាខានីតិប្រតិបត្តិ សាខាតុលាការ និងភារកិច្ចរបស់រដ្ឋាភិបាលដូចជាភារកិច្ចការពារសន្តិសុខ) [១៤០]។

សិទ្ធិសេរីភាពក្នុងការទទួលព័ត៌មាន គឺជាសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបាននូវព័ត៌មានពីស្ថាប័នសាធារណៈទាំងឡាយ ហើយសិទ្ធិនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។ ឧទាហរណ៍ៈ

-ប្រជាពលរដ្ឋម្នាក់មានសិទ្ធិទទួលព័ត៌មានពីក្រុមប្រឹក្សាឃុំ សង្កាត់ ទាក់ទងនឹងការដេញថ្លៃ និងការចំណាយផ្សេងៗរបស់ឃុំ សង្កាត់ដែលគាត់រស់នៅ។

-អ្នកកាសែតម្នាក់ មានសិទ្ធិទទួលបានព័ត៌មានពីមន្ត្រីសាធារណៈនៃក្រសួងណាមួយ ដែលទាក់ទងនឹងការដេញថ្លៃ និងការចំណាយផ្សេងៗរបស់ក្រសួងនោះ។

ដើម្បីលើកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អចំពោះសេវាសាធារណៈ និងមានការទទួលខុសត្រូវ ជាប្រការដ៏សំខាន់ គឺចាំបាច់ណាស់ចំពោះអ្នកសារព័ត៌មាន និងសាធារណៈជន ត្រូវតែមានសិទ្ធិក្នុងការទទួលព័ត៌មានពីមជ្ឈដ្ឋានសាធារណៈ[១៤១]។ បើទោះបីនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨ ខែមីនា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានសន្យាថា នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ ស្តីពីសិទ្ធិទទួលព័ត៌មានឲ្យហើយក្នុងខែធ្នូ ឆ្នាំ២០០៦ ក៏ដោយ ក៏នៅព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ពុំទាន់មានច្បាប់ស្តីពីសេរីភាពទទួលព័ត៌មាននៅឡើយដែរ។ ផ្តើមចេញពីចំណុចខ្វះខាតច្បាប់ ស្តីពីសិទ្ធិសេរីភាពទទួលព័ត៌មានរបស់សាធារណៈជន ដែលជាហេតុធ្វើឲ្យអ្នកកាសែត និងប្រជាពលរដ្ឋជាម្ចាស់អំណាច មានការលំបាកក្នុងការរុករកព័ត៌មានពីស្ថាប័នសាធារណៈ។ រាល់ព័ត៌មានដែលស្ថិតនៅក្នុងរង្វង់នៃការគ្រប់គ្រង ដោយមន្ត្រីរដ្ឋាភិបាល អាជ្ញាធរសាធារណៈ គឺនៅតែជាវប្បធម៌រក្សាការសម្ងាត់ដដែល។ រាល់ការសុំព័ត៌មានពីមន្ត្រីរដ្ឋាភិបាល គឺវាស្ថិតនៅលើការទាក់ទងជាលក្ខណៈបុគ្គលរបស់អ្នកត្រូវការព័ត៌មាន និងមន្ត្រីសាធារណៈ ហើយពេលខ្លះក៏ត្រូវ

---

[១៤០] ព្រឹត្តិបត្រអ្នកជាៈ ឆ្នាំទី១១ លេខ២៥១-២៥២ សម្រាប់ខែមេសា ឆ្នាំ២០០៤ ទំព័រ ២៨០

[១៤១] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម របាយការណ៍ស្ទាបស្ទង់មតិអំពីសេរីភាពក្នុងការទទួលព័ត៌មាន ឆ្នាំ២០០៤ ទំព័រ ១-២

ចំណាយប្រាក់កាស ដើម្បីទទួលបានព័ត៌មានដែលខ្លួនត្រូវការទៀតផង[១៤២]។ ក្នុងពេលទៅសុំព័ត៌មាន ឬឯកសារមួយចំនួនត្រូវគេអះអាងថា ទុកជាការសម្ងាត់មិនអាចឲ្យបាន ព្រោះវាអាចនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់ជនណាមួយ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិជាដើម ដែលជា លេសក្នុងការបិទបាំងព័ត៌មាន។ ចរិតបែបនេះបង្ហាញឲ្យឃើញថា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅកម្ពុជានៅមានកម្រិតទាប[១៤៣]។ ទន្ទឹមនឹងនេះក៏មានការហាមឃាត់ដល់អ្នកសារព័ត៌មាន មិនឲ្យចូលក្នុងបរិវេណតុលាការរាជធានីភ្នំពេញ និងមានការគំរាមកំហែងដោយពាក្យសម្តីចំពោះអ្នកសារព័ត៌មាន ក្នុងការទទួលព័ត៌មាន។ ដូចជានៅក្នុងពេលថ្មីៗនេះ រដ្ឋសភាជាតិនីតិកាលទី៤ បានប្រជុំបោះឆ្នោតលើកអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រពីររូប មកពីគណបក្សជំទាស់ក្នុងរដ្ឋសភា តាមសំណើររបស់តុលាការរាជធានីភ្នំពេញ។ សន្តិសុខត្រូវបានរឹតបន្តឹងសម្រាប់សម័យប្រជុំកាលពីថ្ងៃច័ន្ទ ទី២២ ខែមិថុនា ឆ្នាំ២០០៩ នេះដោយមានក្រុមប៉ូលីសប្រឆាំងកុបកម្មឈរជើងនៅជុំវិញរដ្ឋសភា និងកងរាជអាវុធហត្ថបានឈររារាំងយ៉ាងច្រើនជាន់ ជាចន្លោះៗពីបរិវេណសភា។ ដោយឡែកសម័យប្រជុំដែលធ្វើឡើងជាសម្ងាត់ក្រុមអ្នកយកព័ត៌មាន ក្រុមអ្នកការទូតបរទេស និងក្រុមអ្នកតំណាងមកពីអង្គការក្រៅរដ្ឋាភិបាលត្រូវបានរាំងមិនឲ្យមើលឃើញការពិភាក្សានោះទេ។ នេះជាសេចក្តីសម្រេចមួយដែលត្រូវបានក្រុមអ្នកតំណាងមកពីស្ថានទូតអាមេរិក បារាំង អង់គ្លេស និងស្ថានទូតអាឡឺម៉ង់ថ្កោលទោស[១៤៤]។

សិទ្ធិសេរីភាពទទួលព័ត៌មាន ដែលជាផ្នែកមួយដ៏សំខាន់នៃសេរីភាពបញ្ចេញមតិ ត្រូវបានរឹតត្បិតយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ ដំណើរការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាលធ្វើឡើងក្នុងភាពសម្ងាត់ ហើយចំពោះការប៉ះពាល់ផលប្រយោជន៍របស់បុគ្គលឯកជន តែងនាំទៅរកការគំរាមកំហែងដល់អ្នកសារព័ត៌មានផ្នែកស៊ើបអង្កេត។ ដូចជាៈ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៧ មន្ត្រីយោធាម្នាក់បានដកហូតព័ត៌មានពីលោក សូ វិសាល នៅវត្តនិរោធន៍ ក្នុងរាជធានីភ្នំពេញ ដែលជាអ្នកយកព័ត៌មានឲ្យវិទ្យុសំឡេងប្រជាធិបតេយ្យ។ លោក សូ វិសាល កំពុងធ្វើការស៊ើបអង្កេតលើព័ត៌មានដែលលោកទទួលបានថា មានអ្នករងរបួស និងអ្នកស្លាប់ដោយសារវាយកម្ទេចចោលព្រះពុទ្ធបដិមាករនៅទីនោះ។ មន្ត្រីយោធាបានគំរាមកំហែងលោក សូ វិសាល និងដកហូតយកប្រដាប់ថតសំឡេង និងម៉ាស៊ីនថតពីលោក។ បន្ទាប់ពីលុបរូបថត និងសំឡេងអស់ទើបមន្ត្រីយោធានេះប្រគល់សម្ភារៈឲ្យលោកវិញ[១៤៥]។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨ អ្នកយកព័ត៌មានពីររូបមកពីកាសែតខ្មែរម្ចាស់ស្រុក និងកាសែតស្រឡាញ់ខ្មែរ ត្រូវបានហាមឃាត់មិនឲ្យយកព័ត៌មាន ស្តីអំពីជម្លោះដីធ្លីមួយកន្លែងរវាងប្រជាពលរដ្ឋបី

---

[១៤២] សិក្ខាសាលាស្តីពីការអនុវត្តន៍ល្អ និងបទដ្ឋានអន្តរជាតិ នៃសេរីភាពក្នុងការទទួលព័ត៌មានថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥

[១៤៣] សមាគមអាដហុក ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៥ ទំព័រ ១៥

[១៤៤] កាសែត ឌឹ ឃែមបូឌា ដេលី ខួបលើកទី៣៥ ច្បាប់ទី៨៥ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩

[១៤៥] លីកាដូៈ របាយការណ៍រួមរបស់អង្គការក្រៅរដ្ឋាភិបាលស្តីពីសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ សម្រាប់ការត្រួតពិនិត្យជាសកលតាមពេលកំណត់នៃការបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ១១-១២

គ្រួសារនិងក្រុមហ៊ុនផានអីម៉ិច នៅភូមិអណ្ដូង សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ក្រុមហ៊ុនបានជួលជនប្រដាប់អាវុធមកយាមដី ហើយជនប្រដាប់អាវុធទាំងនេះបានយកកាំភ្លើងមកគំរាមកំហែងអ្នកកាសែតពីររូបនេះមិនឲ្យថតរូប។

នៅក្នុងប្រទេសដឹកនាំរដ្ឋតាមបែបប្រជាធិបតេយ្យពិតប្រាកដ សេរីភាពក្នុងការទទួលព័ត៌មានរបស់សាធារណៈជនមានសារៈសំខាន់ និងចាំបាច់បំផុត ដើម្បីធ្វើការអភិវឌ្ឍន៍លើគ្រប់វិស័យ ពីព្រោះវាជាប់ទាក់ទងផ្ទាល់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត ខាងវិស័យឯកជន និងបានជាប្រយោជន៍ដល់រដ្ឋាភិបាល ដែលជាអ្នកបម្រើរាស្ត្រផងដែរ។ សេរីភាពទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ និងការបើកចំហជាសាធារណៈនូវរាល់ព័ត៌មានទាំងឡាយ ដែលជាឧបករណ៍ដ៏សំខាន់មួយធានាធ្វើឲ្យរាល់ប្រតិបត្តិកិច្ចការរបស់ស្ថាប័នសាធារណៈ មានតម្លាភាព គណនេយ្យភាព បើកចំហអភិបាលកិច្ចល្អ និងបង្កឲ្យមាននីតិរដ្ឋពិតប្រាកដ។ ដូច្នេះរាល់ការដេញថ្លៃរាល់ការចំណាយផ្សេងៗរបស់ស្ថាប័នរដ្ឋទាំងឡាយ គួរត្រូវអនុញ្ញាតឲ្យប្រជាពលរដ្ឋដឹងជាសាធារណៈបានឆាប់រហ័ស ដោយឥតរើសអើងអ្វីឡើយ។

តាមទិដ្ឋភាពជាក់ស្ដែងនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នមានលក្ខណៈពីរយ៉ាង:

១-កម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរភាគច្រើន ស្ដីពីសិទ្ធិសេរីភាពក្នុងការទទួលព័ត៌មាននៅទាបខ្វះការស្វែងយល់ខ្វះសេចក្ដីក្លាហាន មានសេចក្ដីបាក់ស្បាតរាងចាល ដោយភាពក្រីក្រ គិតតែផលប្រយោជន៍ផ្ទាល់ខ្លួន ជាប់ជំពាក់ដោះស្រាយវិបត្តិសេដ្ឋកិច្ចគ្រួសារប្រចាំថ្ងៃ ថែមទាំងពុំដឹងថា ប្រជាពលរដ្ឋខ្លួនឯងជាម្ចាស់អំណាចមានសិទ្ធិសំខាន់ៗអ្វីខ្លះ ជាពិសេសពុំបានដឹងថា ខ្លួនឯងមានសិទ្ធិសេរីភាពក្នុងការទទួលព័ត៌មាន និងសារៈសំខាន់នៃការប្រើប្រាស់សិទ្ធិសេរីភាពនេះយ៉ាងណាឡើយ។

២-ស្មារតីសមាជិកដឹកនាំស្ថាប័នរដ្ឋ និងអ្នកចាត់ចែងកិច្ចការរដ្ឋ ពុំទាន់មានភាពចាស់ទុំក្នុងការដឹកនាំរដ្ឋតាមបែបប្រជាធិបតេយ្យសេរី នៅមានគំនិតចង្អៀតចង្អល់ច្រើន សីលធម៌ក្នុងភាពជាអ្នកដឹកនាំនៅមានកម្រិតនៅមានការប្រកាន់រើសអើង ខ្វះការទទួលខុសត្រូវចំពោះកិច្ចការរបស់ខ្លួន អំពើពុករលួយ និងជាពិសេសទម្រង់ដឹកនាំរដ្ឋមានលក្ខណៈប្រមូលអំណាចនៅលើប្រមុខរដ្ឋាភិបាលតែប៉ុណ្ណោះ។

និយាយដោយឡែក តាមការអង្កេតមើលឃើញជាក់ស្ដែងជាទូទៅ បច្ចុប្បន្ននេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ សមល្មមគ្រប់គ្រាន់សម្រាប់ផ្សាយជូនសាធារណៈជន ដោយគ្រាន់តែខ្វះព័ត៌មានសំណៅជាលាយលក្ខណ៍អក្សរសម្រាប់ចែកចាយ ដើម្បីឲ្យសាធារណៈជនអាចធ្វើការពិចារណា ពិភាក្សា ថ្លឹងថ្លែង ប្រៀបធៀបឲ្យបានល្អិតល្អន់ មុនធ្វើការសម្រេចចិត្តរបស់ខ្លួនក្នុងកិច្ចការអ្វីមួយប៉ុណ្ណោះ។ ប្រការសំខាន់ បើមានច្បាប់បើកសិទ្ធិឲ្យប្រជាពលរដ្ឋ និងសង្គមស៊ីវិល មានសេរីភាពក្នុងការទទួលព័ត៌មាននោះទើបប្រសើរ។ ប៉ុន្តែច្បាប់ទទួលព័ត៌មានក៏នឹងកម្រិតដែនកំណត់ដែរព្រោះថាព័ត៌មានទាំងអស់របស់ប្រទេសជាតិមិនសុទ្ធតែត្រូវផ្សព្វផ្សាយ ឬអនុញ្ញាតឲ្យសាធារណៈជនរុករកនោះឡើយ ដូចជាករណីព័ត៌មានទាក់ទងនឹងយុទ្ធសាស្ត្រយោធា ការពារប្រទេសជាតិ សន្តិសុខជាតិ កិច្ចការ

សម្ងាត់ដែលអាយុជីវិតរបស់ប្រទេសជាតិព័ត៌មានស្តីពីបុគ្គលឯកជន។ល។ បច្ចុប្បន្ននេះនៅកម្ពុជា ការសម្ងាត់វិជ្ជាជីវៈហាក់ដូចជា មានលក្ខណៈផ្ទុយទៅនឹងគោលការណ៍តម្លាភាពនៃរដ្ឋបាលប្រជាធិបតេយ្យ និងសិទ្ធិរបស់ប្រជាពលរដ្ឋដែលមានចែងក្នុងមាត្រា៣៥ នៃច្បាប់រដ្ឋធម្មនុញ្ញថាៈ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។ ប៉ុន្តែទោះជាយ៉ាងណាក្តីនៅមានការងារមួយចំនួនដែលត្រូវរក្សាការសម្ងាត់ជាពិសេស គឺព័ត៌មានដែលអាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងកិត្យានុភាពរបស់សង្គមនិងប្រទេសជាតិ ហើយព័ត៌មានខ្លះទៀតដែលមិនទាន់ដល់ពេលវេលានឹងធ្វើការផ្សព្វផ្សាយមិនត្រូវធ្វើការផ្សព្វផ្សាយដែរ។ ការសម្ងាត់វិជ្ជាជីវៈ មិនចេះតែត្រូវអនុវត្តចំពោះសាធារណៈជនប៉ុណ្ណោះទេ ប៉ុន្តែត្រូវអនុវត្តចំពោះសហសេវិកអ្នករួមការងារជាមួយគ្នាក្នុងរដ្ឋបាល ដែលមិនមានភារកិច្ចត្រូវដឹងនូវការងារនេះទៀតផងដែរ។

ព្រះរាជាណាចក្រកម្ពុជាចាំបាច់ត្រូវមានច្បាប់ស្តីពីសិទ្ធិសេរីភាពទទួលព័ត៌មាន ព្រោះច្បាប់នេះជានាសិទ្ធិប្រជាពលរដ្ឋខ្មែរ ដើម្បីទទួលព័ត៌មានពីស្ថាប័នសាធារណៈ។ សិទ្ធិសេរីភាពទទួលព័ត៌មានមានប្រយោជន៍ដូចជាៈ

**សម្រាប់ប្រជាពលរដ្ឋ**

-អាចដឹងថា តើសេវាសាធារណៈណាខ្លះដែលមិនបង់ថ្លៃ ហើយបើបង់ថ្លៃ តើពួកគេត្រូវចំណាយប្រាក់ប៉ុន្មាន។

-អាចតាមដានសំណើសុំនានា ដែលបានស្នើសុំទៅអាជ្ញាធរដូចជាៈ ការធ្វើអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត និងលិខិតស្នាមផ្សេងៗថា តើដំណើរការដល់ណាហើយ?។

-អាចដឹងពីការចំណាយរបស់ស្ថាប័នសាធារណៈ សម្រាប់គម្រោងការអ្វីមួយ។ល។

**សម្រាប់សមាជិកសភា មន្ត្រីរដ្ឋាភិបាល និងតុលាការ**

-អាចឲ្យសមាជិកសភា ទទួលបានព័ត៌មានជាក់លាក់ស្តីពីកិច្ចការសាធារណៈពីស្ថាប័នសាធារណៈ ដូចជា គម្រោងអភិវឌ្ឍ កិច្ចសន្យាសាធារណៈ ជាមួយក្រុមហ៊ុនឯកជនការចំណាយរបស់ស្ថាប័នសាធារណៈជាដើម។

-អាចឲ្យមន្ត្រីរដ្ឋាភិបាល ទទួលព័ត៌មានពីស្ថាប័នសាធារណៈផ្សេងៗបានរហ័សទាន់ចិត្ត ជាអាទិ៍ដូចជា សវនករជាតិ អាចទទួលព័ត៌មានស្តីពីការចំណាយរបស់ក្រសួងនានាជាដើម។

-អាចឲ្យមន្ត្រីតុលាការទទួលបានព័ត៌មានស្តីពីស្ថាប័នសាធារណៈ ពេលត្រូវការដើម្បីការងារស៊ើបអង្កេត។ល។

**សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ**

- អាចស្នើសុំទៅស្ថាប័នសាធារណៈ ហើយអាចទទួលបានព័ត៌មានផ្លូវការណ៍សម្រាប់ការងារផ្សព្វផ្សាយរបស់ខ្លួន។

-មន្ត្រីសាធារណៈ ដែលមានលេសលាក់ព័ត៌មានសាធារណៈដែលធ្វើឲ្យការផ្សព្វផ្សាយកាន់តែមានលក្ខណៈវិជ្ជាជីវៈ។ល។

**សម្រាប់វិស័យឯកជន**

-អាចទទួលបានព័ត៌មានផ្លូវការណ៍ស្តីពីការដេញថ្លៃគម្រោងសាធារណៈ ក៏ដូចជាគម្រោងអភិវឌ្ឍនានារបស់រដ្ឋ។

-អាចទទួលបានព័ត៌មានផ្លូវការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច វិនិយោគ ពន្ធដារ។

-ច្បាប់ទម្លាប់ និងព័ត៌មាន ដទៃទៀតដែលមានប្រយោជន៍សម្រាប់កិច្ចការអាជីវកម្ម ។ល។

**សម្រាប់សង្គមស៊ីវិល**

-អាចទទួលបានព័ត៌មានផ្លូវការណ៍ទាក់ទងនិងកិច្ចការសាធារណៈ ពីស្ថាប័នសាធារណៈផ្សេងៗ ដើម្បីចូលរួមផ្តល់យោបល់ ធ្វើកិច្ចសហប្រតិបត្តិការក្នុងនាមដៃគូអភិវឌ្ឍ ។ល។

ដូច្នេះ នៅក្នុងសង្គមប្រជាធិបតេយ្យ គឺចាំបាច់ណាស់ក្នុងការធ្វើច្បាប់អនុញ្ញាតឲ្យប្រពលរដ្ឋមានសិទ្ធិទទួលព័ត៌មានពីស្ថាប័នសាធារណៈដើម្បីធ្វើការប្រៀបធៀបផ្ទួរផ្ទង... ដែលឈានទៅរកធ្វើឲ្យប្រសើរឡើងនូវស្ថានភាពជីវិតរស់នៅប្រចាំថ្ងៃ និងជោគវាសនាប្រទេសជាតិរបស់ខ្លួន។

### ៣.២.៥ សិទ្ធិបោះឆ្នោតជាសកលដោយ សេរី យុត្តិធម៌ និងទៀងទាត់

ប្រទេសដែលជឿនលឿនទាំងឡាយគឺដោយសារមានរដ្ឋាភិបាលល្អ និងមានរដ្ឋធម្មនុញ្ញល្អ។ ហើយរដ្ឋធម្មនុញ្ញល្អ គឺដោយសារអ្នកតំណាងរាស្ត្រដែលជាអ្នកតែងច្បាប់ ជាអ្នកដែលប្រជារាស្ត្រជ្រើសរើសដោយសេរី និងត្រឹមត្រូវ។ រដ្ឋាភិបាលល្អ គឺជារដ្ឋាភិបាលដែលគោរពតាមច្បាប់យ៉ាងខ្ជាប់ខ្ជួន បម្រើប្រជាជនជានិច្ច និងប្រកបដោយសេចក្តីស្មោះត្រង់ផងដែរ។ តាមរយៈតំណាងរាស្ត្រ ប្រជាពលរដ្ឋមានសិទ្ធិផ្លាស់ប្តូរសមាជិករដ្ឋាភិបាល ឬរដ្ឋាភិបាលណា ដែលប្រជាពលរដ្ឋម្ចាស់អំណាចមិនពេញចិត្ត[១៤៦]។

រដ្ឋាភិបាលប្រជាធិបតេយ្យ ដែលឈរលើការព្រមព្រៀង ពេញចិត្ត ឯកភាព ពីជនដែលខ្លួនគ្រប់គ្រងអាចនិយាយនិងធ្វើសកម្មភាពពោរពេញដោយសេចក្តីទុកចិត្តខ្លួនឯង ព្រមទាំងមានអំណាចដែលបានមកពីការបោះឆ្នោតសម្តែងការទុកចិត្ត។ អំណាចរដ្ឋាភិបាលប្រជាធិបតេយ្យ គឺជាអំណាចដែលផុសចេញពីសេចក្តីសម្រេចចិត្តដ៏ត្រឹមត្រូវ និងសុទ្ធចិត្តរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត តាមរយៈការបោះឆ្នោតជាសកល ដោយសេរី យុត្តិធម៌ និងទៀងទាត់។ ការបោះឆ្នោតជាសកល គឺជាការសម្តែងឆន្ទៈ និងសិទ្ធិសេរីភាពដ៏ទូលំទូលាយរបស់ប្រជាពលរដ្ឋទូទៅ ទាំងប្រុស ទាំងស្រី អ្នកមាន អ្នកក្រ ដោយគ្មានការរើសអើងខាងជំនឿសាសនា និន្នាការនយោបាយ លើកលែងតែអនីតិជន ជនវិកលចរិត និងជនជាប់ទោស។ ក្នុងរបបប្រជាធិបតេយ្យ បង្កប់នូវអត្ថន័យ នៃការបោះឆ្នោតជាសកល ដែលសម្តែងពីសិទ្ធិផ្តាច់មុខជាអចិន្ត្រៃយ៍របស់ប្រជាពលរដ្ឋទូទៅ។ គោលការណ៍ជាមូលដ្ឋានក្នុងរបប

---

[១៤៦] អង្គការវីជីលេន អង្គការរក្សាការពារសិទ្ធិមនុស្ស នៃកម្ពុជា ទំព័រ ២៣

ប្រជាធិបតេយ្យ ការបោះឆ្នោតដោយផ្ទាល់នៃប្រជាពលរដ្ឋ គឺជាគោលការណ៍ចម្បង និងចាំបាច់ណាស់ ព្រោះប្រជាពលរដ្ឋជាម្ចាស់ប្រទេស ម្ចាស់អំណាច និងជាម្ចាស់ជោគវាសនានៃប្រទេសជាតិទាំងស្រុង និងក្នុងន័យនេះគឺសំដៅទៅដល់ធ្វើឲ្យសង្គមនៅតែមានទិដ្ឋភាពរស់រវើកជានិច្ច។ ការប្រើសិទ្ធិ ដើម្បីបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួននៃប្រជាពលរដ្ឋក្នុងពេលបោះឆ្នោត គឺជាការប្រើអំណាចស្របច្បាប់របស់ខ្លួនតាមរដ្ឋធម្មនុញ្ញ។ ការបោះឆ្នោតវាជួយឲ្យអ្នកនយោបាយដឹកនាំគ្រប់គ្រងមានការប្រកួតប្រជែងគ្នា ខាងគតិបណ្ឌិត ខាងបញ្ញាញាណចាក់ធ្លុះ ចក្ខុវិស័យច្បាស់លាស់វែងឆ្ងាយក្នុងការរកឃើញនូវគំនិតថ្មីៗជឿនលឿន សីលធម៌ខ្ពង់ខ្ពស់ ដើម្បីបម្រើប្រជា-ពលរដ្ឋជាម្ចាស់ប្រទេស ម្ចាស់ឆ្នោតម្ចាស់អំណាចឲ្យមានស្ថេរភាពនយោបាយ សន្តិសុខ មានជីវភាពរីកចម្រើនទៅតាមរបត់ពិភពលោកដ៏ជឿនលឿន។ ត្រង់ចំណុចនេះ លោកស្រី ដៃយ៉ាន់រ៉ាវិច អ្នកប្រាជ្ញនិពន្ធ ជាឧបការីរដ្ឋមន្ត្រីនៃក្រសួងអប់រំសហរដ្ឋអាមេរិក បានមានប្រសាសន៍ថា ការបោះឆ្នោតជាសកល គឺជាស្ថាប័នស្នូលនៃរដ្ឋាភិបាលប្រជាធិបតេយ្យបែបសភានិយម។ យន្តការដ៏សំខាន់ ដែលជាការប្រែក្លាយការព្រមព្រៀងដោយស្មោះស្ម័គ្ររបស់ប្រជាពលរដ្ឋទៅជាអំណាច នោះគឺជាការធ្វើការបោះឆ្នោតប្រព្រឹត្តទៅដោយសេរីនិងត្រឹមត្រូវ។ ដោយលោកស្រីបានបន្ថែមទៀតថា ការបោះឆ្នោតប្រជាធិតេយ្យ គឺមិនគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះទេ... វាជាការប្រកួតប្រជែងដោយមានការរៀបចំដ៏ត្រឹមត្រូវទៀងទាត់ជាច់ណាត់តាមថេរៈវេលាកំណត់និងតាមមតិភាគច្រើន។ មានន័យថា ការបោះឆ្នោតគឺជាការប្រកួតប្រជែងគ្នារវាងគណបក្ស និងបេក្ខជនទាំងអស់ដែលត្រូវតែមាន សេរីភាពក្នុងការនិយាយស្តីការប្រជុំ និងការធ្វើដំណើរ ដើម្បីសម្តែងការរិះគន់ចំហទៅលើរដ្ឋាភិបាល និងស្នើជូននូវនយោបាយនិងបេក្ខជនថ្មីៗ សម្រាប់ឲ្យប្រជាពលរដ្ឋ ធ្វើការជ្រើសរើសដោយល្អិតល្អន់ និងទៀងទាត់បំផុត។ លទ្ធិប្រជាធិបតេយ្យ ជារបបគ្រប់គ្រងរបស់ប្រជាពលរដ្ឋ។ មេដឹកនាំរដ្ឋមុនឡើងមកដឹកនាំរដ្ឋាភិបាល ប្រជា-ពលរដ្ឋដាច់ខាតត្រូវឆ្លងកាត់ការបោះឆ្នោតជ្រើសរើស ដោយត្រឹមត្រូវ យុត្តិធម៌ពីប្រជាពលរដ្ឋ ដែលជាម្ចាស់អំណាច ឬតំណាងរាស្ត្រ។ មេដឹកនាំនោះត្រូវបង្ខំខ្លួនធ្វើអ្វីៗឲ្យអស់ពីសមត្ថភាព ហើយក៏ត្រូវបង្ខំខ្លួនឲ្យយល់ថាប្រជាពលរដ្ឋអាចដកហូតមុខតំណែងខ្លួនគ្រប់ពេល។ នេះគឺជារបបស្វ័យគ្រប់គ្រងដោយប្រជាពលរដ្ឋ ដែលមានការចូលរួមពីប្រជាពលរដ្ឋតាមរយៈពហុនិយម និងការបោះឆ្នោតជាសកល។ រូបភាពនៃការបោះឆ្នោតប្រជាធិប-តេយ្យ គឺជាការចូលរួមរបស់ប្រជាពលរដ្ឋទូទៅ ពីព្រោះវាជាការសម្តែងសិទ្ធិបោះឆ្នោត និងសិទ្ធិកាន់កាប់តំណែងរដ្ឋ។ វាជួយឲ្យប្រជាពលរដ្ឋមានឱកាសជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន និងមានឱកាសបញ្ចេញសម្លេង ទៅលើបញ្ហាអ្វីមួយ និងជួយឲ្យមន្ត្រីរដ្ឋការទាំងអស់ យកចិត្តទុកដាក់ចំពោះសំណូមពររបស់ប្រជាពលរដ្ឋផងដែរ។ ការបោះឆ្នោតដែលបានសម្រេចជាស្ថាពរ ដោយជ្រើសយកអ្នកដឹកនាំរដ្ឋាភិបាលស្របតាមរដ្ឋធម្មនុញ្ញ ព្រមទាំងមានតំណាងរាស្ត្រ ដែលសាធារណៈជនបានជ្រើសរើស គឺជាអ្នកត្រួតពិនិត្យឬទប់អំណាច។ ការបោះឆ្នោតមិនគ្រាន់តែធ្វើឡើងសម្រាប់តែជ្រើសតាំងតំណាងរាស្ត្រប៉ុណ្ណោះទេ តែគេនៅប្រើសម្រាប់សម្រេចបញ្ហា ឬគំនិតផ្តួចផ្តើមនយោបាយដោយផ្ទាល់តាមរយៈការធ្វើប្រជាមតិ ឬការបោះឆ្នោតអនុម័ត។

ការបោះឆ្នោត គឺជាយន្តការបង្កើតឲ្យមាននូវការជ្រើសរើសតំណាងល្អជាងគេនៅក្នុងសង្គម ដើម្បីកាន់អំណាចរដ្ឋ និងជាការកំណត់នូវវាសនាសម្ព័ន្ធសង្គម។ តាមសេចក្ដីថ្លែងការណ៍ស្ដីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ដែលបានអនុម័តជាឯកច្ឆ័ន្ទដោយក្រុមប្រឹក្សាអន្តរសភានៅសម័យប្រជុំលើកទី១៥៤ នៅទីក្រុងប៉ារីស ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៤ បានចែងថា អំណាចគ្រប់គ្រងត្រូវតែកើតដោយឆន្ទៈរបស់ប្រជាពលរដ្ឋ ដែលសម្ដែងឡើងតាមរយៈការបោះឆ្នោតតាមពេលកំណត់ទៀងទាត់ និងពិតប្រាកដឥតក្លែងបន្លំ។

**ការបោះឆ្នោត និងសិទ្ធិចូលរួមបោះឆ្នោត**

(១) ពលរដ្ឋពេញវ័យគ្រប់រូបមានសិទ្ធិបោះឆ្នោតក្នុងពេលមានការបោះឆ្នោត ដោយផ្អែកលើមូលដ្ឋាននៃការមិនរើសអើង។

(២) ពលរដ្ឋពេញវ័យគ្រប់រូប មានសិទ្ធិចូលរួមក្នុងនីតិវិធីដ៏មានប្រសិទ្ធិភាពឥតលំអៀង និងឥតរើសអើងសម្រាប់ចុះឈ្មោះអ្នកបោះឆ្នោត។

(៣) ពុំមានពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ ត្រូវបានគេបដិសេធមិនឲ្យបោះឆ្នោត ឬ ត្រូវគេដកសិទ្ធិចេញពីបញ្ជីជាអ្នកបោះឆ្នោតទេ លើកលែងតែតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយច្បាប់សមស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋចំពោះច្បាប់អន្តរជាតិ។

(៤) បុគ្គលគ្រប់រូប ដែលត្រូវបានបដិសេធមិនឲ្យមានសិទ្ធិបោះឆ្នោត ឬត្រូវបានគេបដិសេធមិនចុះឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតមានសិទ្ធិប្ដឹងទៅរដ្ឋអំណាចដែលមានសមត្ថកិច្ចពិនិត្យឡើងវិញនូវសេចក្ដីសម្រេចបែបនេះ ដើម្បីសុំឲ្យកែកំហុសឲ្យបានឆាប់រហ័ស និងឲ្យមានប្រសិទ្ធិភាព។

(៥) អ្នកបោះឆ្នោតគ្រប់រូបមានសិទ្ធិស្មើគ្នាចូលទៅក្នុងស្ថានីយ៍បោះឆ្នោត ដើម្បីប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួន។

(៦) អ្នកបោះឆ្នោតគ្រប់រូបត្រូវមានលទ្ធភាពស្មើគ្នា ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួនហើយមានសន្លឹកឆ្នោតមួយសំឡេងស្មើគ្នានឹងសំឡេងឆ្នោតរបស់អ្នកឯទៀតដែរ។

(៧) សិទ្ធិបោះឆ្នោតជាសម្ងាត់ គឺជាសិទ្ធិដាច់ខាត ហើយមិនត្រូវមានកម្រិតព្រំដែនឡើយទោះបីនៅក្នុងករណីណាក៏ដោយ។

ការបោះឆ្នោតក្នុងចន្លោះពេលទៀងទាត់ពិតប្រាកដ ធ្វើឡើងដោយឈរលើមូលដ្ឋាននៃការបោះឆ្នោតដោយស្មើភាពមានន័យផងដែរថា គឺជាភាពស្មើភាពគ្នានៃអំណាចបោះឆ្នោត។ ជាគោលការណ៍ គឺថាគ្មានសន្លឹកឆ្នោតណាមួយមានទម្ងន់ ដែលធ្វើឲ្យមានវិសមាមាត្រលើសន្លឹកឆ្នោតមួយទៀតនោះទេ ក៏ប៉ុន្តែមិនមែនចាំបាច់តម្រូវឲ្យមានអ្នកតំណាងតាមសមាមាត្រដែរ។

ក្នុងរដ្ឋមួយដែលប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស និងធម្មាធិបតេយ្យ គឺមានសារៈសំខាន់ ដើម្បីធានាចំពោះការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។ ក្នុងចំណោមអង្គធាតុនានានៃយុត្តិធម៌ ដែលមាន

សារៈសំខាន់ចំពោះការបញ្ចេញដោយពេញទំហឹង នូវសេចក្ដីថ្លៃថ្នូរដែលមានជាប់នឹងមនុស្ស និងសិទ្ធិស្មើគ្នា មិនអាចដកហូតបានរបស់ម្ចាស់ឆ្នោត គឺការបោះឆ្នោតដោយសេរី ធ្វើឡើងក្នុងចន្លោះពេលពីមួយទៅមួយយ៉ាងសមស្របដោយសន្លឹកឆ្នោតសម្ងាត់។ រដ្ឋាភិបាលដែលមានអ្នកតំណាងក្នុងរដ្ឋាភិបាល នោះអំណាចនីតិបញ្ញត្តិត្រូវទទួលខុសត្រូវចំពោះអំណាចនីតិបញ្ញត្តិ ដែលជ្រើសរើសតាំងឡើង ឬចំពោះអ្នកបោះឆ្នោត និងការបែងចែកអំណាចដោយច្បាស់លាស់ រវាងរដ្ឋនិងគណបក្សនយោបាយ។ ដើម្បីធានាឆន្ទៈរបស់ពលរដ្ឋធ្វើជាមូលដ្ឋាននៃអំណាចរបស់រដ្ឋាភិបាលនោះ រដ្ឋត្រូវចូលរួមៈ

-បើកការបោះឆ្នោតក្នុងចន្លោះពេលដ៏សមស្រប ពីមួយទៅមួយ តាមការកំណត់ដោយច្បាប់។

-អនុញ្ញាតឲ្យអាសនៈទាំងអស់ យ៉ាងហោចណាស់នៅក្នុងសភាមួយនៃអង្គនីតិបញ្ញត្តិបានប្រកួតប្រជែងដណ្ដើមយកដោយសេរី ដោយការបោះឆ្នោតរបស់ប្រជាពលរដ្ឋ។

-ធានារ៉ាប់រងការបោះឆ្នោតជាសកល និងស្មើភាពចំពោះពលរដ្ឋម្ចាស់ឆ្នោត។

-ធានាឲ្យបាននូវការបោះឆ្នោតដោយសម្ងាត់ ឬដោយនីតិវិធីបោះឆ្នោតដោយសេរីណាមួយដែលមានលក្ខណៈស្មើ ហើយការរាប់សន្លឹកឆ្នោតត្រូវបានរាប់ និងរាយការណ៍ដោយសុចរិត ដោយប្រកាសលទ្ធផលផ្លូវការណ៍ឲ្យសាធារណៈជនបានដឹង។

-គោរពសិទ្ធិពលរដ្ឋ ដើម្បីស្វែងរកតំណែងនយោបាយ ឬសាធារណៈជាបុគ្គលខ្លួនឯង ឬជាតំណាងនៃគណបក្ស ឬអង្គការនយោបាយដោយគ្មានការរើសអើង។

-គោរពសិទ្ធិគ្រប់រូប និងក្រុមនានា ដើម្បីបង្កើតគណបក្សនយោបាយ ឬអង្គការនយោបាយផ្ទាល់ខ្លួនគេ ដោយសេរីភាពពេញលេញ ហើយផ្ដល់ឲ្យគណបក្សនយោបាយ ឬអង្គការនយោបាយនោះនូវការធានាផ្លូវច្បាប់ជាចាំបាច់ ដើម្បីអាចឲ្យគេប្រកួតប្រជែងគ្នាទៅវិញទៅមក ឈរលើមូលដ្ឋាននៃការទទួលស្គាល់ស្មើគ្នានៅចំពោះមុខច្បាប់ និងដោយអាជ្ញាធរ។

-ធានាថា ច្បាប់ និងនយោបាយសាធារណៈ រៀបចំឲ្យមានការឃោសនានយោបាយបានធ្វើទៅក្នុងបរិយាកាសត្រឹមត្រូវ និងដោយសេរី ដោយគ្មានវិធានការអ្វីតាមផ្លូវរដ្ឋបាល ហិង្សា ឬគ្មានបំភិតបំភ័យអ្វីមករារាំងគណបក្ស និងបេក្ខជនមិនឲ្យបង្ហាញទស្សនៈ និងគុណសម្បត្តិរបស់គេដោយសេរី ឬរារាំងអ្នកបោះឆ្នោតមិនឲ្យដឹងនិងពិភាក្សាទស្សនៈនិងគុណសម្បត្តិ ឬមិនឲ្យគេបោះឆ្នោតដោយសេរីដោយខ្លាចមានការសងសឹកនោះឡើយ។

-ធានាថាគ្មានឧបសគ្គខាងផ្លូវច្បាប់ ឬផ្លូវរដ្ឋបាលនៅរារាំងមិនឲ្យគេប្រើប្រាស់ប្រព័ន្ធឃោសនាដោយគ្មានប្រកាន់រើសអើងចំពោះក្រុមនយោបាយ និងបុគ្គលនានាដែលចង់ចូលរួមក្នុងដំណើរការបោះឆ្នោត។

អំណាចនយោបាយដឹកនាំប្រទេស តាមក្របខ័ណ្ឌប្រជាធិបតេយ្យសេរីពហុបក្សត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតប្រកបដោយលក្ខណៈសេរី និងយុត្តិធម៌។ នេះគឺជាទំនាក់ទំនងផ្សាភ្ជាប់គ្នារវាងសេរីភាពនៃការបោះឆ្នោតជ្រើសរើសតំណាងទៅនិងអធិបតេយ្យប្រជាពលរដ្ឋ និងអំណាចប្រជាធិបតេយ្យ។ ការបោះឆ្នោតបែបប្រជាធិបតេយ្យ គឺជាការប្រកួតប្រជែងគ្នា ដោយចំហរវាងគណបក្សនានា ផ្ដោតជាសំខាន់លើទស្សនៈក្នុង

ការអភិវឌ្ឍន៍ប្រទេស ដើម្បីឈោងចាប់អំណាច។ ការសន្ទតអំពីលក្ខណៈសេរី និងយុត្តិធម៌ នៃការបោះឆ្នោត មិនមែនគ្រាន់តែជាការវាយតម្លៃមួយផ្តោតលើដំណើរការប្រព្រឹត្តទៅនៃការងាររៀបចំការបោះឆ្នោត របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតប៉ុណ្ណោះទេ លើសពីនេះ និងជាការចាំបាច់ផងដែរនោះ គឺការចូលរួមរបស់គណបក្សនយោបាយ និងប្រការដែលប្រជាពលរដ្ឋខ្លួនឯងត្រូវយល់ដឹងថា តើពលរដ្ឋម្នាក់ៗក្នុងនាមជាម្ចាស់ឆ្នោត និងជាម្ចាស់អំណាច ត្រូវមានឆន្ទៈមុះមុតយ៉ាងដូចម្តេច ដើម្បីបំពេញតាមគន្លងបែបបទនៃច្បាប់ដែលជាមូលដ្ឋាន នៃការប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួន សម្រាប់ដំណើរការសម្រេចចិត្តខាងនយោបាយ ក្នុងការស្វែងរកតំណាងនិង ការផ្ទេរអំណាចរបស់ខ្លួនទៅឲ្យអ្នកតំណាងសម្រាប់នីតិកាលនីមួយៗ។ ឆន្ទៈមុះមុតនេះអាចកើតមានឡើងបាន លុះត្រាតែពលរដ្ឋគ្រប់រូបឲ្យតម្លៃថា ការបោះឆ្នោតមិនមែនជាការអាណិតស្រឡាញ់ឬស្អប់ ចំពោះគណបក្សណាមួយ បេក្ខជនណាមួយ ឬបោះឆ្នោតជូនដោយសារជំពាក់គុណនោះទេ។ ផ្ទុយទៅវិញការបោះឆ្នោត គឺជាឱកាសនយោបាយដ៏សំខាន់សម្រាប់ពលរដ្ឋម្នាក់ៗ គិតគូរអំពីជីវភាពរស់នៅរបស់ខ្លួននិងអ្នកដទៃ ដែលរួមរស់ក្នុងសហគមន៍ជាមួយ។ ពលរដ្ឋមានឱកាសជ្រើសរើសវិញ្ញូជននយោបាយណា ឬក្រុមនយោបាយណា ឲ្យធ្វើជាតំណាងផលប្រយោជន៍របស់ខ្លួនសម្រាប់អាណត្តិ៥ឆ្នាំ។ ប្រជាពលរដ្ឋម្នាក់ៗ ប្រើប្រាស់ឱកាសវិសេសវិសាលនេះប្រកបដោយប្រសិទ្ធិភាព លុះត្រាតែពលរដ្ឋម្នាក់ៗជ្រើសរើសអ្នកណា ឬក្រុមនយោបាយណាដែលគោរពស្រឡាញ់ម្ចាស់ឆ្នោត មានសីលធម៌ផូរផង់ មានឆន្ទៈខ្ពស់ មានមនសិការជាតិជ្រាលជ្រៅ...។ ជាពិសេសប្រជា-ពលរដ្ឋខ្មែរម្ចាស់ឆ្នោតត្រូវពិនិត្យមើល និងជ្រើសរើសក្រុមអ្នកនយោបាយណាដែលមានចក្ខុវិស័យច្បាស់លាស់ និងយន្តការប្រាកដប្រជា ភក្តីភាពមកដឹកនាំ និងអភិវឌ្ឍប្រទេសជាតិជំនួសខ្លួន។ ព្រោះថាអត្ថន័យបោះឆ្នោត គឺបើកឱកាសអ្នកនយោបាយខិតខំសម្រិតសម្រាំងកម្មវិធីនយោបាយដ៏ជឿនលឿន នាំមធ្យោបាយដោះស្រាយបញ្ហាធំ ប្រាជ្ញាញាណ ភាពឈ្លាសវៃរបស់ខ្លួនទាំងប៉ុន្មានមកដាក់ឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោតជេញថ្លៃ។ ប្រសិនបើក្រុមអ្នកនយោបាយណាមានលក្ខខណ្ឌគ្រប់គ្រាន់ នោះប្រជាពលរដ្ឋផ្តល់សេចក្តីទុកចិត្តសម្រេច ជ្រើសរើសគណបក្សនោះមកដឹកនាំ ហើយករណីដឹកនាំមិនបានល្អដូចការសន្យា ឬខុសពីរបបប្រជាធិបតេយ្យ ឬមានលេចចេញសញ្ញាមិនល្អ ដូចជា ប្រព្រឹត្តពុករលួយ បក្សពួកនិយម ប្រើអំណាចផ្តាច់ការ...ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនបណ្តេញចេញពីអំណាចភ្លាម។ គួរយល់ថា ក្នុងក្របខ័ណ្ឌនៃប្រព័ន្ធគ្រប់គ្រងប្រជាធិបតេយ្យបែបតំណាង ពលរដ្ឋម្នាក់បោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ពុំមែនបោះឆ្នោតឲ្យគេធ្វើម៉ែឪ ឬចៅហ្វាយនាយរបស់ខ្លួនទេ។ មានន័យថា អំណាចរដ្ឋដាច់ខាតត្រូវតែកើតឡើងពីប្រជាពលរដ្ឋតាមរយៈបោះឆ្នោតដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតាមកាលកំណត់ជាក់លាក់ពីប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេស។

ការបោះឆ្នោតមួយមានលក្ខណៈសេរី និងយុត្តិធម៌បាន លុះ្កណាតែការបោះឆ្នោតនោះអនុវត្តតាម គោលការណ៍ ៥ចំណុច ដូចខាងក្រោមៈ

**(ក) គោលការណ៍បោះឆ្នោតជាសកល**

អត្ថន័យគន្លឹះនៃគោលការណ៍នេះ គឺប្រជាពលរដ្ឋចាប់ពីអាយុ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត។ សិទ្ធិ

នេះពុំត្រូវបានអនុញ្ញាតធ្វើឲ្យរាំងស្ទះដោយប្រការណាមួយ ឬពីសំណាក់បុគ្គលណាមួយ អង្គការណាមួយ ឬក៏និន្នាការណាមួយជាដាច់ខាត។ ការប្រើវិធីណាមួយដើម្បីបង្កឧបសគ្គដល់ការប្រើប្រាស់សិទ្ធិបោះឆ្នោត គឺជាការលួចសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋ និងជាការរំលោភលើគោលការណ៍បោះឆ្នោតជាសកល។ ម្យ៉ាងទៀត គោលការណ៍បោះឆ្នោតជាសកល គឺជាការធានានូវអធិបតេយ្យភាពរបស់ប្រជាពលរដ្ឋខ្មែរ ក្នុងការសម្រេចជោគវាសនាប្រទេសជាតិដោយខ្លួនឯង។ ដូច្នេះសិទ្ធិបោះឆ្នោត គឺមានតែចំពោះពលរដ្ឋខ្មែរតែប៉ុណ្ណោះ ដែលសំដៅតែទៅលើជនណាមួយដែលមានសញ្ជាតិជាខ្មែរ ដោយផ្អែកលើច្បាប់សញ្ជាតិជាធរមាន។ អនុលោមតាមច្បាប់ស្តីពីសញ្ជាតិគឺជនណាម្នាក់ដែលពុំមែនជាពលរដ្ឋខ្មែរតាំងពីកំណើតអាចក្លាយខ្លួនជាពលរដ្ឋខ្មែរបាន ដោយសំអាងតែលើព្រះរាជក្រឹត្យផ្តល់សញ្ជាតិតែមួយប៉ុណ្ណោះ។ ជនអន្តោប្រវេសន៍ប្រភេទណាក៏ដោយ ទោះបីជាទទួលបាននូវសិទ្ធិរស់នៅស្របច្បាប់នៅកម្ពុជាក៏ដោយក្តី ពុំមែនមានន័យថា ជននោះជាពលរដ្ឋខ្មែរដោយស្វ័យប្រវត្តិបានដែរ។ អញ្ចឹងបើសិនជាមានជនអន្តោប្រវេសន៍ណាម្នាក់ទទួលបានសិទ្ធិបោះឆ្នោត ដោយប្រការណាមួយដែលមិនផ្អែកលើបទបញ្ញត្តិនៃច្បាប់ស្តីសញ្ជាតិ គឺជាការរំលោភលើអធិបតេយ្យភាពរបស់ប្រជាពលរដ្ឋខ្មែរ និងរំលោភលើសិទ្ធិស្វ័យសម្រេចរបស់ប្រជាពលរដ្ឋខ្មែរ។ សន្លឹកឆ្នោត គឺជាការឆ្លុះបញ្ចាំងនូវឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរតែប៉ុណ្ណោះ។

### (ខ) គោលការណ៍បោះឆ្នោតដោយសេរី

គោលការណ៍បោះឆ្នោតដោយសេរី គឺសំដៅលើសេរីភាពនៃការសម្រេចចិត្តខាងនយោបាយរបស់ប្រជាពលរដ្ឋម្នាក់ៗលើសន្លឹកឆ្នោត។ សេរីភាពនៃការសម្រេចចិត្តនេះ គឺពលរដ្ឋម្នាក់ៗមានសិទ្ធិសម្រេចដោយសេរី តាមឆន្ទៈរបស់ខ្លួនផ្ទាល់ ដោយពុំត្រូវទទួលរងនូវសម្ពាធ, ការបង្ខិតបង្ខំ, ការគំរាមកំហែង ឬវិធីរាំងស្ទះណាមួយដល់ដំណើរការសម្រេចចិត្តរបស់ពលរដ្ឋម្ចាស់ឆ្នោតបានឡើយ។ សេរីភាពនៃការសម្រេចចិត្តនេះ គិតតាំងពីដំណាក់កាលត្រៀមទៅបោះឆ្នោត(ដូចជាៈ ការចុះបញ្ជីឈ្មោះ ការពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះ ការតាមដានអំពីគណបក្ស និងបេក្ខជនឈរឈ្មោះ) រហូតដល់ការសម្រេចចិត្តជ្រើសរើសគណបក្សនិងបេក្ខជន។ ការឃោសនារកសំឡេងគាំទ្រ ដែលប្រព្រឹត្តទៅដោយសុក្រិតពុំអាចចាត់ទុកថា ជាការរំលោភដល់សេរីភាពនៃការសម្រេចចិត្តរបស់ម្ចាស់ឆ្នោតទេ បើការឃោសនានោះធ្វើឡើង ដើម្បីផ្សព្វផ្សាយពន្យល់បកស្រាយអំពីគោល-នយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិ ក៏ដូចជាលាត-ត្រដាងអំពីលក្ខណៈសម្បត្តិ និងគុណសម្បត្តិរបស់អ្នកដឹកនាំបក្ស និងបេក្ខជនឈរឈ្មោះ។ ម្យ៉ាងវិញទៀត ទោះបីជាមានសម្ពាធយ៉ាងណាក៏ដោយ ពលរដ្ឋខ្មែរគ្រប់រូបឲ្យតម្លៃសន្លឹកឆ្នោតរបស់ខ្លួន ស្មើនឹងសេចក្តីត្រូវការ សម្រាប់ជីវភាពរស់នៅរបស់ខ្លួនក្នុងកំឡុងពេល៥ឆ្នាំ រហូតដល់ការបោះឆ្នោតបន្ទាប់ នោះពលរដ្ឋម្នាក់ៗយល់ច្បាស់ថា សន្លឹកឆ្នោតមួយសន្លឹករបស់ខ្លួនពិតជាមានតម្លៃមិនអាចកាត់ថ្លៃបានឡើយ ហើយប្រជាពលរដ្ឋ ខ្មែរម្នាក់ៗពិតជាមានភាពក្លាហានមុះមុតប្រើប្រាស់សិទ្ធិស្វ័យសម្រេចរបស់ខ្លួនដោយសេរី។

សេរីភាពក្នុងការបោះឆ្នោត គឺជាគោលការណ៍មិនសម្រាប់តែបោះឆ្នោតប៉ុណ្ណោះទេ តែបានដល់នីតិវិធី

បោះឆ្នោតទាំងមូលផងដែរ ជាពិសេសការចាត់តាំងបេក្ខជន និងការរៀបចំដទៃទៀត រួមមានទាំងការឃោសនាបោះឆ្នោត និងការយកសន្លឹកឆ្នោតទៅបោះឆ្នោតទៀតផង[១៤៧]។ សេរីភាពក្នុងការបោះឆ្នោតមិនមែនមានន័យថា សេរីភាពមិនចូលបោះឆ្នោតនោះទេ។

**(គ) គោលការណ៍បោះឆ្នោតដោយផ្ទាល់**

ការបោះឆ្នោតដោយផ្ទាល់ មានន័យថា អ្នកបោះឆ្នោតគ្រប់រូបធ្វើការសម្រេចចិត្តដោយខ្លួនឯងផ្ទាល់ ដោយមិនមានមេអណ្ដើក ឬអ្នកណាឯទៀតចូលរួមជាមួយឡើយ។

**ការបោះឆ្នោតដោយផ្ទាល់ប្រព្រឹត្តទៅជាពីរតំណាក់កាលជាប់ៗគ្នាគឺៈ**

១-គិតតាំងពីការចាប់ផ្ដើមនៃដំណើរការសម្រេចចិត្ត រហូតដល់នាទីចុងក្រោយ នៃការសម្រេចចិត្ត។ មានន័យថា មកទល់នឹងខណៈពេលគូសសន្លឹកឆ្នោត ប្រជាពលរដ្ឋខ្មែរម្នាក់ៗធ្វើការសម្រេច ចិត្តផ្អែកលើឆន្ទៈ និងបណ្ដូលចិត្តរបស់ខ្លួនឯងផ្ទាល់ ដោយពុំមានឆ្លងកាត់អ្នកដទៃ ឬពុំធ្វើតាមចំណង់ចំណូលចិត្តអ្នកដទៃផ្ទុយនឹងឆន្ទៈរបស់ខ្លួនឡើយ។ បានសេចក្ដីថា ឆន្ទៈរបស់ម្ចាស់ឆ្នោតម្នាក់ៗ និងឆន្ទៈនៅលើ សន្លឹកឆ្នោតដែលខ្លួនបានគូស គឺជាឆន្ទៈតែមួយគត់របស់ម្ចាស់ឆ្នោតម្នាក់ៗ។ ក្នុងតំណាក់កាលនេះប្រជាពលរដ្ឋម្នាក់ៗបង្កើតឆន្ទៈរបស់ខ្លួនផ្អែកលើសតិសម្បជញ្ញៈទទួលខុសត្រូវដោយប្រើប្រាស់សេរីភាពក្នុងការពិចារណា ថ្លឹងថ្លែង និងវិនិច្ឆ័យ ហើយអ្វីដែលជាលទ្ធផលចុងក្រោយនៃសេរីភាពនេះ គឺស្ថិតនៅលើការសម្រេចចិត្តដោយខ្លួនឯងដែលជាម្ចាស់នៃសន្លឹកឆ្នោត ហើយក៏ជាម្ចាស់អំណាចនៃការសម្រេចឆន្ទៈនយោបាយ[១៤៨]។ ការសម្រេចចិត្តខាងនយោបាយនេះ គឺផ្សារភ្ជាប់ទៅនឹងសេចក្ដីត្រូវការសម្រាប់ជីវភាពផ្ទាល់ខ្លួនរបស់ម្ចាស់ឆ្នោត។

២-គោលការណ៍បោះឆ្នោតដោយផ្ទាល់ គឺចាប់គិតពីការបោះឆ្នោតរួចរាល់ រហូតដល់ការរាប់សន្លឹកឆ្នោត និងក្រោយការប្រកាសលទ្ធផលបោះឆ្នោត។ ក្នុងដំណាក់កាលនេះ ក៏ពុំអនុញ្ញាតឲ្យមានឥទ្ធិពលណាមួយបំភ្លៃ ឬមកកែច្នៃថែមថយឆន្ទៈដើមរបស់ម្ចាស់ឆ្នោតបានឡើយ។ វិធី ឬដោយមធ្យោបាយណាមួយ ឬក៏ចេតនាណាមួយដែលធ្វើឲ្យការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបាត់បង់នូវឆន្ទៈដើមរបស់ប្រជាពលរដ្ឋដែលបានសម្ដែងក្នុងសន្លឹកឆ្នោតរបស់ខ្លួន គឺជាការរំលោភលើគោលការណ៍បោះឆ្នោតដោយផ្ទាល់។ ការរំលោភនេះ គឺជាការលួចបន្លំសន្លឹកឆ្នោតដោយផ្ទាល់ ឬការបំភ្លៃឆន្ទៈរបស់ម្ចាស់ឆ្នោត។

**(ឃ) គោលការណ៍បោះឆ្នោតដោយស្មើភាព**

ការបោះឆ្នោតនឹងប្រកបដោយស្មើភាព លុះត្រាតែសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតមាន តម្លៃស្មើៗគ្នារវាងសន្លឹកឆ្នោតនីមួយៗរបស់ពលរដ្ឋម្ចាស់ឆ្នោត ដោយមិនប្រកាន់និន្នាការនយោបាយខុសគ្នា ស្ថានភាពខុសៗគ្នានៃជីវភាពរស់នៅក្នុងសង្គម។ល។ មានន័យថា សន្លឹកឆ្នោតនីមួយៗត្រូវបានរាប់ និងគណនាជាសំឡេង

---

[១៤៧] វិទ្យាស្ថានខ្មែរសម្រាប់លទ្ធិប្រជាធិបតេយ្យៈ ប្រព័ន្ធបោះឆ្នោត និងការគ្រប់គ្រង ភ្នំពេញ ឆ្នាំ១៩៩៨ ទំព័រ ២៩

[១៤៨] ឈឹម ផលវុណ្ណ ស្វែងរកបែបគ្រប់គ្រងបែបប្រជាធិបតេយ្យសេរីពហុបក្ស ភ្នំពេញ ឆ្នាំ២០០៧ទំព័រ ២៧-២៨

ដូចគ្នា ស្មើគ្នា។ ការបោះឆ្នោតដោយស្មើភាពគ្នា សំដៅទៅលើភាពស្មើគ្នាក្នុងស្រទាប់ប្រជាពលរដ្ឋក្នុងការគាំទ្រ គណបក្សការចូលរួមការបោះឆ្នោត, ការទទួលព័ត៌មានគណបក្សនានា ដោយគ្មានការរើសអើងនិងប្រកាន់និន្នាការនយោបាយ។ មានន័យថា គឺសំដៅលើឱកាសស្មើគ្នានៃការសម្រេចចិត្ត ខាងនយោបាយរបស់ពលរដ្ឋ ម្នាក់ៗក្នុងការជ្រើសរើសតំណាងរបស់ខ្លួន។ គោលការណ៍ស្មើភាពនេះធានាដល់គោលការណ៍ ទូទៅនៃការបោះឆ្នោត និងសេរីភាពរបស់បុគ្គលក្នុងការទទួលព័ត៌មាន និងធ្វើការប្រៀបធៀបមុននឹងធ្វើការសម្រេចចិត្ត ដែលជាកត្តាក្នុងប្រព័ន្ធពហុបក្ស។

គោលការណ៍បោះឆ្នោតដោយស្មើភាពគ្នា ក៏សំដៅដល់ភាពស្មើគ្នារវាងគណបក្សនានា និងរវាងបេក្ខជនឈរឈ្មោះក្នុងការប្រកួតប្រជែងរកសំឡេងគាំទ្រផងដែរ បានសេចក្ដីថា គោលការណ៍នេះតម្រូវឲ្យមានឱកាស វាសនាស្មើគ្នាសម្រាប់គ្រប់គណបក្ស ក៏ដូចជាសម្រាប់បេក្ខជនឈរឈ្មោះទាំងអស់ ដោយរាប់បញ្ចូលទាំងភាព ស្មើគ្នានៃការទទួលបាននូវសិទ្ធិ និងរបៀបរបបនៃការឃោសនាបោះឆ្នោត ទាំងភាពស្មើគ្នានៃវិធានគណនាសន្លឹកឆ្នោតសម្រាប់បែងចែកអាសនៈដល់គណបក្សនីមួយៗ។

**(ង) គោលការណ៍បោះឆ្នោតដោយសម្ងាត់**

ពាក្យថា ការបោះឆ្នោតសម្ងាត់មានន័យថា អ្នកបោះឆ្នោតអាចគូសសន្លឹកឆ្នោតរបស់ខ្លួនដោយពុំឲ្យអ្នកណាដឹងអំពីការសម្រេចចិត្តឡើយ។ មិនឲ្យនរណាដឹងក្រៅតែពីម្ចាស់ខ្លួនដែលបានដឹងថាបានបោះឆ្នោតឲ្យអ្នកណាម្នាក់នោះឡើយ។ ការធ្វើរបៀបនេះ គឺការពារកុំឲ្យមានគំនុំគុំគួនទៅលើអ្នកបោះឆ្នោត ដែលបានបោះឆ្នោតជ្រើសរើសនរណាម្នាក់ដែលគេពេញចិត្ត។ ការចង់ដឹងអំពីការសម្ងាត់ ឬការបង្ហើបការសម្ងាត់តាមរូបភាពណាក៏ដោយត្រូវហាមឃាត់[១៤៩]។ គោលការណ៍នេះជាគន្លឹះនៃការធានាដល់ប្រជាពលរដ្ឋខ្មែរក្នុងប្រើសេរីភាពសម្រាប់ការសម្រេចចិត្តតាមឆន្ទៈ ដោយគ្មានព្រួយបារម្ភចំពោះបរិយាសអាប់អួរ, សង្កត់សង្កិត, ភ័យខ្លាចជុំវិញខ្លួនឡើយ។ ទន្ទឹមនេះដែរ ប្រជាពលរដ្ឋខ្មែរក៏ត្រូវយល់និងជឿជាក់ថា គ្មានបច្ចេកវិទ្យាណាដែលអាចដឹងបានអំពីការសម្រេចចិត្តរបស់ខ្លួនក្នុងការគូសលើសន្លឹកឆ្នោតក្នុងបន្ទប់បោះឆ្នោតនោះបានទេ ក្រៅពីសាមីខ្លួនឯងតែប៉ុណ្ណោះ។ ការប្រើល្បិចលួងលោម ឬសំឡុតគំរាមកំហែង បំភិតបំភ័យ ដើម្បីឲ្យម្ចាស់ឆ្នោតឆ្លើយប្រាប់អំពីការសម្រេចចិត្តបោះឆ្នោតឲ្យគណបក្សណា ឬបេក្ខជនណានោះ គឺជាអំពើល្មើសនឹងច្បាប់បោះឆ្នោត ដែលត្រូវផ្ដន្ទាទោស[១៥០]។

នៅក្នុងសង្គមប្រជាធិបតេយ្យកំពុងអភិវឌ្ឍក្នុងវិស័យនយោបាយនឹងមានចំណុចខ្សោយយ៉ាងច្រើនចំពោះប្រជាពលរដ្ឋម្ចាស់ឆ្នោត ដោយសារតែអ្នកទាំងនោះ ភាគច្រើនខ្វះការពិសោធន៍ក្នុងផ្លូវនយោបាយ ឬការសិក្សាទាប ឬមិនចេះអក្សរ ដែលជាហេតុធ្វើឲ្យការបោះឆ្នោតទៅជារឿងស្មុគស្មាញ ដែលចាំបាច់ត្រូវទទួលការ

---

[១៤៩] មាត្រា៩៥ នៃច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងគណបក្សនយោបាយ ឆ្នាំ១៩៩៧

[១៥០] ឈឹម ផលវុណ ស្វែងរករបបគ្រប់គ្រងបែបប្រជាធិបតេយ្យសេរីពហុបក្ស ភ្នំពេញ ឆ្នាំ២០០៧ទំព័រ ៣០-៣១

អប់រំថែមទៀត ដើម្បីជៀសវាងកុំឲ្យមានការប្រើឥទ្ធិពលផ្សេងៗ។ បេក្ខជនឈរឈ្មោះគំរាមកំហែងឲ្យអ្នកបោះឆ្នោតខ្លាច ឬទិញសន្លឹកឆ្នោត ឬមានការឆបោកក្លែងបន្លំក្នុងការបោះឆ្នោត។ល។ ក្រៅពីនេះនៅក្នុងចំណោមបេក្ខជនដូចគ្នា ក៏ត្រូវផ្ដល់សិទ្ធិខាងផ្លូវនយោបាយដល់ពួកគេ ដែលជាគណបក្សនយោបាយប្រកួតប្រជែងផងដែរ។ បេក្ខជនត្រូវមានឥស្សរភាព សេរីភាពនៅក្នុងការថ្លែងសុន្ទរកថា ឬការប្រាស្រ័យទាក់ទង ការបោះឆ្នោតផ្សព្វផ្សាយ ការឃោសនា ឬការស្រាវជ្រាវរកព័ត៌មានជាដើម។ល។ ហេតុនេះហើយការទទួលខុសត្រូវរបស់អ្នកចាត់ចែង រៀបចំធ្វើការបោះឆ្នោត ទាំងអាជ្ញាធរមានសមត្ថកិច្ច និងសង្គមស៊ីវិលនៃអង្គការមិនមែនរដ្ឋាភិបាលត្រូវតែមានសមត្ថកិច្ចខ្ពស់ មានការពិសោធន៍ក្នុងផ្លូវនយោបាយ មានចំណេះដឹងផ្នែកមនោគមន៍វិជ្ជានៃរបបប្រជាធិបតេយ្យ និងមានចំណេះដឹងខាងផ្លូវច្បាប់ផងដែរ។ អ្នកចាត់ចែងបោះឆ្នោតត្រូវមានភារកិច្ចផ្សព្វផ្សាយបំប៉នខាងចំណេះវិជ្ជា ការយល់ដឹងពីរឿងការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យដល់ប្រជាពលរដ្ឋរួមទាំងភារកិច្ចក្នុងការទាក់ទាញ និងដាស់តឿនឲ្យប្រជាពលរដ្ឋមានការយកចិត្តទុកដាក់ និងភ្ញាក់រលឹកក្នុងការចូលរួមប្រើប្រាស់សិទ្ធិក្នុងផ្លូវនយោបាយ និងការចេញទៅប្រើប្រាស់សិទ្ធិក្នុងការបោះឆ្នោតឲ្យបានច្រើនជាទីបំផុត។

សរុបសេចក្ដីមក ការបោះឆ្នោតអាចប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌តាមគោលការណ៍ទាំងប្រាំនៃការបោះឆ្នោតបែបប្រជាធិបតេយ្យដូចបានលើកមកបង្ហាញខាងលើនេះ គឺអាស្រ័យទៅនឹងតួអង្គសំខាន់បីៈ (១) គឺតួអង្គម្ចាស់ឆ្នោត (២)គណបក្សនានា និង(៣) គឺស្ថាប័នមានសមត្ថកិច្ចរៀបចំការបោះឆ្នោត។ ការផ្ដេកផ្ដួលទាំងស្រុងតែលើគណៈកម្មធិការជាតិរៀនចំការបោះឆ្នោត(គ.ជ.ប.) ក្នុងគោលបំណងចង់ឲ្យការបោះឆ្នោតនៅកម្ពុជាប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌តាមគោលការណ៍នៃការបោះឆ្នោតនេះ គឺពុំគ្រាន់និងពុំមានប្រសិទ្ធិភាពល្អប៉ុន្មានទេ បើទោះបីជា គ.ជ.ប រៀបចំដំណើរការបោះឆ្នោតបានរលូនល្អយ៉ាងណាក៏ដោយក៏មិនអាចប្រាកដថា ការបោះឆ្នោតប្រព្រឹត្តទៅបានដោយសេរី និងយុត្តិធម៌ បំពេញលក្ខខណ្ឌតាមគោលការណ៍៥យ៉ាងបានមួយរយភាគរយទេ ដរាបណាប្រជាពលរដ្ឋខ្មែរមិនទាន់យល់ដឹង និងទទួលស្គាល់ថាកាប្រើសិទ្ធិអំណាចសម្រេចខាងនយោបាយមានសារៈសំខាន់ចំពោះវាសនាខ្លួន និងប្រទេសជាតិខ្លួននៅឡើយនោះ។ ដើម្បីលើកស្ទួយឲ្យប្រជាពលរដ្ឋមានការយល់ដឹងអំពីសិទ្ធិបោះឆ្នោត និងការចូលរួមបោះឆ្នោត គណបក្សនយោបាយ គឺជាតួអង្គដ៏សំខាន់មួយក្នុងកិច្ចការនេះ ទន្ទឹមគ្នានឹងការផ្សព្វផ្សាយអំពីគោលការណ៍នយោបាយកម្មវិធីនយោបាយនិងសកម្មភាពនយោបាយរបស់ខ្លួន។ ការរួមចំណែករបស់គណបក្សនយោបាយ គឺជាវិភាគទានដ៏ចាំបាច់ ដើម្បីធ្វើឲ្យការបោះឆ្នោតអាចប្រព្រឹត្តទៅបានដោយសេរី និងយុត្តិធម៌អនុលោមតាមគោលការណ៍ទាំងប្រាំនៃការបោះឆ្នោតបែបប្រជាធិបតេយ្យសេរីពហុបក្ស។

ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១មក យើងឃើញថាប្រជាពលរដ្ឋខ្មែរទូទៅត្រូវបានបើកទូលាយឲ្យមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យតាមមាត្រា៣៤ នៃរដ្ឋធម្មនុញ្ញ។

ដើម្បីបោះឆ្នោតបាន តាមមាត្រា៥០ចែងថា ប្រជាពលរដ្ឋទាំងឡាយត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

និងមានប័ណ្ណបោះឆ្នោត។ លក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោតគឺៈ

១-មានសញ្ជាតិខ្មែរពីកំណើត។

២-មានអាយុ១៨ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត។

៣-មានអាសយដ្ឋានច្បាស់លាស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

៤-ត្រូវទៅចុះឈ្មោះដោយខ្លួនឯងផ្ទាល់។

៥-មិនត្រូវស្ថិតនៅក្នុងស្ថានភាពជាប់ពន្ធនាគារ។

៦-ពុំមែនជាជនវិកលចរិត ឬជនស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។

តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងគណបក្សនយោបាយឆ្នាំ១៩៩៧ មាត្រា៣៣ចែងថា ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

១-មានសញ្ជាតិខ្មែរតាំងពីកំណើត។

២-មានអាយុម្ភៃប្រាំ(២៥)ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត។

៣-មានសិទ្ធិបោះឆ្នោត។

៤-ស្នាក់នៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិចមួយឆ្នាំគិតទៅដល់ថ្ងៃបោះឆ្នោត។

៥-មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត។

ច្បាប់បោះឆ្នោតឆ្នាំ១៩៩៨ មានចែងអំពីការការពារអ្នកបោះឆ្នោត និងអ្នកឈរឈ្មោះបោះឆ្នោត។ ច្បាប់នេះមានសារៈសំខាន់ណាស់ទាក់ទងទៅនឹងការការពារអធិបតេយ្យប្រជាពលរដ្ឋ។ ការរារាំងសិទ្ធិមិនឲ្យបោះឆ្នោត និង ឈរឈ្មោះជាបេក្ខជនមានចែងក្នុងមាត្រា១២២ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមានចែងពីទណ្ឌកម្មដល់អ្នករំលោភសិទ្ធិនេះ។ ត្រូវស្តីបន្ទោស ឬបណ្តេញចេញពីការងារដោយគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះភ្នាក់ងារចុះឈ្មោះបោះឆ្នោតណាដែលប្រព្រឹត្តបទល្មើសណាមួយដូចជាៈ ១-បានចុះឈ្មោះ ប៉ុន្តែមិនព្រមប្រគល់ប័ណ្ណបោះឆ្នោតជូនប្រជាពលរដ្ឋ។ ២-ចេញប័ណ្ណបោះឆ្នោតដោយចេតនាដល់អ្នកដែលពុំទាន់គ្រប់អាយុបោះឆ្នោត ឬដល់អ្នកដែលពុំទាន់បំពេញលក្ខខណ្ឌគ្រប់គ្រាន់អាចចុះឈ្មោះបោះឆ្នោតបាន។ ៣-បានចុះឈ្មោះ និងបានប្រគល់ប័ណ្ណដោយចេតនាទៅអ្នកដែលត្រូវបានដកសិទ្ធិបោះឆ្នោត។ ៤-រារាំងប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ មិនឲ្យចុះឈ្មោះបោះឆ្នោត។ ៥-រារាំងប្រជាពលរដ្ឋមិនឲ្យទទួលប័ណ្ណបោះឆ្នោតក្រោយពេលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ។ ដោយឡែកការប្រើអំពើហិង្សា ឬបំភិតបំភ័យ ក៏ដូចជា គំរាមកំហែងលើអ្នកបោះឆ្នោត អំពើទាំងនេះត្រូវមានទោសទណ្ឌដែលមានចែងក្នុងមាត្រា១២៤ គឺត្រូវដកហូតប័ណ្ណបោះឆ្នោត លុបបេក្ខភាពសាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ឬ/

និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀលទៅម្ភៃប្រាំលានរៀល ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា និងគណបក្សនយោបាយណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោមៈ

ក-ប្រើកម្លាំងអំពើហិង្សា ឬបំភិតបំភ័យមិនឲ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ឬទៅទទួលប័ណ្ណបោះឆ្នោត។

ខ-ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឲ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។

គ-ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំឲ្យធ្វើសម្បថឲ្យគេបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត។

ឃ-ប្រើកម្លាំង ឬអំពើហិង្សា ដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឲ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន។

ង-ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យប្រើពាក្យសម្តីប្រមាថមើលងាយធ្វើឲ្យមានការភ័យខ្លាចការភាន់ច្រឡំធ្វើឲ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។ ឯការបន្លំឯកសារសន្លឹកឆ្នោត ឬប្រើកល្បិចបន្លំលទ្ធផលនៃការបោះឆ្នោតៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពិន័យដប់លានរៀល ដល់ម្ភៃប្រាំលានរៀល ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងដកហូតប័ណ្ណបោះឆ្នោតសម្រាប់រយៈពេល៥ឆ្នាំ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតចំពោះសមាជិកគណៈកម្មាធិការជាតិ សមាជិកគណៈ-កម្មាធិការខេត្ត/ក្រុង ឃុំ/សង្កាត់ រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតចំពោះអំពើណាមួយដែលទាក់ទងអំពើខាងលើ(មាត្រា១២៥ច្បាប់ស្តីពីការបោះឆ្នោតឆ្នាំ១៩៩៨)។

ការលួងលោម ការបោកបញ្ឆោតឲ្យអ្នកបោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយណាមួយត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀល ដល់ដប់លានរៀល ឬ/និងត្រូវដកហូតប័ណ្ណបោះឆ្នោត ចំពោះជនដែលប្រព្រឹត្តអំពើខាងលើ តាមរយៈការចង្អុលបង្ហាញ ឬតាមមធ្យោបាយមួយផ្សេងទៀតក្នុងការបោះឆ្នោត។ ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬបុគ្គលិក ឬជាសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់នោះគណៈកម្មការរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឲ្យចូលបម្រើការងារជាមួយគណៈ-កម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ។ ប្រសិនបើជនល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មខាងលើ។ ការរារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឲ្យឃោសនាបោះឆ្នោតតាមការកំណត់ការការពារសិទ្ធិនេះមានចែងក្នុងមាត្រា១២២។

### ខ-ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០២

សិទ្ធិអ្នកបោះឆ្នោតត្រូវបានការពារក្នុងមាត្រា២៣០ ដែលមានចែងដូចខាងក្រោមៈ

ត្រូវស្តីបន្ទោស ឬបណ្តេញចេញពីការងារដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងៗទៀត ចំពោះមន្ត្រីចុះឈ្មោះបោះឆ្នោតណាដែលប្រព្រឹត្តបទល្មើសណាមួយដូចតទៅនេះ:

ក-បានចុះឈ្មោះ ប៉ុន្តែមិនព្រមប្រគល់ប័ណ្ណបោះឆ្នោតឬវិញ្ញាបនបត្រជំនួសប័ណ្ណបោះឆ្នោតឲ្យប្រជាពលរដ្ឋ។

ខ-បានចេញប័ណ្ណបោះឆ្នោត ឬវិញ្ញាបនបត្រជំនួសប័ណ្ណបោះឆ្នោត ដោយចេតនាទៅដល់អ្នកដែលត្រូវបានដល់សិទ្ធិបោះឆ្នោត។

ឃ-រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឲ្យចុះឈ្មោះបោះឆ្នោត។

ង-រារាំងប្រជាពលរដ្ឋមិនឲ្យទទួលប័ណ្ណបោះឆ្នោត ឬវិញ្ញាបនបត្រជំនួសប័ណ្ណបោះឆ្នោត ក្រោយពេលបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតរួចហើយ។

## ៣.៣ ការប្រឈមចំពោះសិទ្ធិសេរីភាពក្នុងការបោះឆ្នោតនៅកម្ពុជា

### ៣.៣.១ ការប្រឈមក្នុងឆ្នាំ២០០២

បើទោះបីកម្ពុជាមានច្បាប់ស្តីពីការបោះឆ្នោតគ្រប់គ្រាន់ក៏ដោយ តែកម្ពុជានៅតែមានប្រវត្តិមិនល្អនៅឡើយ ចំពោះការរំលោភលើអធិបតេយ្យភាពរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេសសិទ្ធិបោះឆ្នោត ដែលធ្វើឲ្យទម្រង់ប្រជាធិបតេយ្យនៅកម្ពុជាពុំទាន់រីកធំធាត់ ស្របតាមការប្រកាសជាឱឡារិករបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល ចំពោះជាតិនិងអង្គការសហប្រជាជាតិ ថាប្រជាធិបតេយ្យនៅកម្ពុជាកំពុងចាក់ឬសយ៉ាងជ្រៅទៅក្នុងស្រទាប់មហាជន។

ឯការឲ្យនិទណ្ឌភាពចំពោះអ្នកដែលរំលោភលើអធិបតេយ្យប្រជាពលរដ្ឋក៏នៅតែកើតមានដដែល។ ការកើតមានជម្ងឺបក្សពួកនិយម នៅពេលដែលអំណាចទាំងអស់ត្រូវបានផ្តុំនៅលើតំណែងប្រមុខរដ្ឋាភិបាលនិងខ្វះឆន្ទៈនយោបាយក្នុងការអនុវត្តន៍ច្បាប់ ដើម្បីធ្វើឲ្យមានប្រសិទ្ធិភាពប្រឆាំងនឹងបុគ្គល ជាពិសេសសមាជិកកម្លាំងប្រដាប់អាវុធខ្លះដែលត្រូវតែទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួនដូចជា ការគំរាមកំហែងម្ចាស់ឆ្នោត។ រដ្ឋធម្មនុញ្ញកម្ពុជា ចែងអំពីតុលាការឯករាជ្យ តែតាមពិតការអនុវត្តន៍ជាក់ស្តែង រដ្ឋាភិបាលមិនបានគោរពតាមការចែកទាំងនេះឲ្យបានត្រឹមត្រូវឡើយ គឺតុលាការលុះនៅក្រោមឥទ្ធិពលអំណាចនីតិប្រតិបត្តិ ដែលជាហេតុធ្វើឲ្យគ្មានប្រសិទ្ធិភាពក្នុងការអនុវត្តន៍ច្បាប់។ ម្យ៉ាងទៀតមន្ត្រីតុលាការខ្វះធនធានចំណេះដឹង និងប្រព្រឹត្តអំពើពុករលួយ។ ប្រជាជនមិនមានសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌។ ឯបទល្មើសទាក់ទងរឿងនយោ-បាយវិញ ក៏កម្រនឹងត្រូវបានចោទប្រកាន់ផងដែរ។

អំពើហិង្សាលើសិទ្ធិម្ចាស់ឆ្នោតរួមមានៈ ការគំរាមកំហែង ការបំភ័យ ការឃុំខ្លួនដោយប្រើអំណាច និងការសម្លាប់សកម្មជន និងបេក្ខជនក្រុមប្រឹក្សាឃុំសង្កាត់ ដែលប្រឆាំងនឹងគណបក្សកំពុងកាន់អំណាច

ព្រមទាំងប្រើអំពើហិង្សាលើទ្រព្យសម្បត្តិរបស់មន្ត្រី និងស្លាកគណបក្ស។ ការគំរាមកំហែង និងការបង្ខិតបង្ខំអ្នកបោះឆ្នោត ជាពិសេសការរឹបអូសប័ណ្ណបោះឆ្នោត និងបង្ខំឲ្យចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា។ ការបដិសេធមមិនឲ្យប្រើប្រព័ន្ធឃោសនារបស់រដ្ឋសម្រាប់គណបក្ស ដែលជំទាស់នឹងគណបក្សកាន់អំណាច និងការខកខានដោយចេតនារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មន្ត្រីសន្តិសុខការពារការបោះឆ្នោត និងយន្តការ រដ្ឋាភិបាលក្នុងការទទួលខុសត្រូវ និងដាក់ទោសលើការរំលោភច្បាប់បោះឆ្នោតដូចជា ការរើសអើងការទទួលសំណូក គំរាមកំហែង និងអំពើហិង្សា[១៥១]។

តាមទិដ្ឋភាពទូទៅក្នុងសង្គមប្រជាធិបតេយ្យនៅកម្ពុជា ជារួមប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសេរីភាពពេញលេញ ដើម្បីសម្តែងមតិ សម្តែងឆន្ទៈនយោបាយ ជាពិសេសអំណាចក្នុងការប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួន។ និយាយដោយឡែកចាប់ពីថ្ងៃទី០១ មករា ២០០១ ដល់ ០៣ កុម្ភៈ ២០០២ សមាគមអាដហុកបានរកឃើញថា សមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិច និងសម រង្ស៊ី ១៥រូប ភាគច្រើនជាបេក្ខជនក្រុមប្រឹក្សាឃុំ/សង្កាត់ ទៅថ្ងៃអនាគត ដែលគេអះអាងថា ត្រូវបានសម្លាប់។ ការធ្វើឃាតដោយសារនិន្នាការនយោបាយ បានកើតឡើងនៅពេលការបោះឆ្នោត ឃុំ/សង្កាត់ ជិតមកដល់ ឯរឿងប្តឹងផ្តល់កើតមានឡើងច្រើនជាងពាក់កណ្តាលនៅចន្លោះពីវិច្ឆិកា ឆ្នាំ២០០១ ដល់ខែមករា ឆ្នាំ២០០២។ ករណីជាក់ស្តែងក្រុមអ្នកសង្កេតការណ៍រឿងក្តីពីរដែលកើតឡើងក្នុងខែកុម្ភៈ ឆ្នាំ២០០២ មានការព្រួយបារម្ភថា ក្នុងរឿងក្តីទាំងពីរនេះជនជាប់ចោទសំខាន់ត្រូវគេស្វែងរកថាមានទោស ទោះជាមានភស្តុតាងគ្រប់គ្រាន់ក៏ដោយ ការជាប់ទោសរបស់ពួកគេផ្តល់ឲ្យមានយុត្តិកម្មមិនសមហេតុផលឡើយ ដោយគ្រាន់តែអះអាងថា ការសម្លាប់នោះមិនជាប់ពាក់ព័ន្ធនឹងរឿងនយោបាយប៉ុណ្ណោះ។ ជាការបន្ថែមពីលើការសម្លាប់នេះសមាគមអាដហុករកឃើញថា ចាប់ពីថ្ងៃទី០១ មករា ២០០១ ដល់ ០៣ កុម្ភៈ ២០០២ មានច្រើនជាង២០០ នៃរឿងក្តីជាប់ទាក់ទងនឹងការគំរាមកំហែង បំភិតបំភ័យ រុកគួន ប្រឆាំងនឹងសកម្ម-ជននិងបេក្ខជនដែលមាននិន្នាការផ្ទុយ ហើយប្រឆាំងនឹងគណបក្សCPP រួមមានការគំរាមកំហែងគ្រោះថ្នាក់ដល់ជីវិតមាន២៤ករណី ការចាប់ខ្លួននិងឃុំខ្លួនដោយប្រើអំណាចផ្តាច់ការ ទៅលើអ្នកគាំទ្រគណបក្សប្រឆាំងមាន២៣ករណី និងមាន៥០ករណីទៀត ជាប់ទាក់ទិននឹងការរំលោភលើទ្រព្យសម្បត្តិ គណបក្សប្រឆាំងមាន៤០ករណី ដែលស្លាកគណបក្សត្រូវបានបំផ្លាញ ឬយកចេញដោយភ័យខ្លាច និង១០ករណីទៀត បាត់ពុំអាចរកឃើញ។ ក្នុងអំឡុងពេលមុនការបោះឆ្នោត ឃើញមានការគំរាមកំហែង មកលើអ្នកមានសិទ្ធិបោះឆ្នោត ដូចជាការរឹបអូសប័ណ្ណបោះឆ្នោត និងការបង្ខិតបង្ខំឲ្យគាំទ្រ និងបោះឆ្នោតឲ្យគណបក្សកាន់អំណាច។ ក្នុងករណីនេះត្រូវបានរកឃើញយ៉ាងហោចណាស់មានដប់ខេត្ត។ នៅដើមខែសីហា ឆ្នាំ២០០១ អង្គការតាមដាន និងត្រួតពិនិត្យការបោះឆ្នោត បានចេញរបាយការណ៍ស្តីពីចំនួនខេត្តដែលបានទិញសន្លឹកឆ្នោតដល់ថ្ងៃបោះឆ្នោត។ ក្នុងចំណោម គណបក្សទាំងបី គឺគណបក្សប្រជាជនកម្ពុជា ត្រូវបានរាយការណ៍ថា ជាប់ពាក់ព័ន្ធនឹងការទិញ

---

[១៥១] សមាគមអាដហុកៈ ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០២ ទំព័រ ១១

សន្លឹកឆ្នោត លើសពីនេះទៅទៀត នៅយប់ថ្ងៃ ស(យប់មុនថ្ងៃបោះឆ្នោតមកដល់គឺថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០២) ត្រូវបានរកឃើញថា នៅស្ទើរគ្រប់ខេត្តទាំងអស់មានការចែកអំណាចពីគណបក្ស និងការបង្ខំអ្នកបោះឆ្នោតដោយមន្ត្រីគណបក្សប្រជាជនកម្ពុជាមូលដ្ឋាន[១៥២]។

រីឯលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធឃោសនារបស់គណបក្សប្រឆាំង ជាពិសេសប្រព័ន្ធឃោសនាផ្សព្វផ្សាយត្រូវបានរឹតបន្តឹងជាងការបោះឆ្នោតជាតិឆ្នាំ១៩៩៨។ ក្រសួងព័ត៌មានបានច្រានចោលជាដដែលៗចំពោះការដាក់ពាក្យសុំបើកស្ថានីយ៍វិទ្យុគណបក្សសមរង្ស៊ី។ ស្ថានីយ៍វិទ្យុជាតិ ទាំងដប់បីមានតែប៉ុស្តិ៍ FM102 តែមួយប៉ុណ្ណោះពុំជាប់ទាក់ទងនឹងនយោបាយឡើយ ហើយផ្សាយដោយមជ្ឈមណ្ឌលស្ត្រីខ្មែរដើរតួនាទីជាអង្គការមិនមែនរដ្ឋាភិបាល និងវិទ្យុសំបុកឃ្មុំដែលបានផ្សាយដោយគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ជាគណបក្សមិនគាំទ្រគណបក្សប្រជាជនកម្ពុជាផងដែរ ប៉ុន្តែមិនបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ទេ។

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅម្ពុជា (Commmittee for Free and Fair Elections) ហៅកាត់ថា COMFREL បានបង្ហាញឲ្យឃើញថា សកម្មភាពរបស់រដ្ឋាភិបាល និងគណបក្សកាន់អំណាចបានគ្របដណ្តប់លើការផ្សព្វផ្សាយព័ត៌មាននានាស្តីពីគុណសម្បត្តិ និងកម្មវិធីនយោបាយរបស់ខ្លួនទាំងមុន និងក្រោយការបោះឆ្នោត ស្របពេលដែលម៉ោងផ្សព្វផ្សាយកម្មវិធីនយោបាយ ដែលផ្តល់ឲ្យគណបក្សប្រឆាំងមានចំនួនតិចតួច។ ចំណែកឯប្រជាពលរដ្ឋម្ចាស់ឆ្នោត ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានព័ត៌មានជាគន្លឹះ ដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវនៅថ្ងៃបោះឆ្នោតនោះទេ[១៥៣]។

ការរក្សាស្ថេរភាពនយោបាយក៏ដូចជាសន្តិសុខចំពោះប្រជាពលរដ្ឋ និងជាពិសេសសកម្មជនគ្រប់ និន្នាការនយោបាយ អាជ្ញាធររដ្ឋាភិបាលចាំបាច់ត្រូវតែការពារឲ្យបានហ្មត់ចត់ ដូចដែលខ្លួនបានប្តេជ្ញាចិត្តជាឱឡារិកចំពោះជាតិ និងអន្តរជាតិកន្លងមក។ ស្ថានភាពជាក់ស្តែង បញ្ហាសន្តិសុខសម្រាប់សកម្មជននយោបាយ និងបេក្ខជននយោបាយមួយចំនួនទទួលរងគ្រោះថ្នាក់ជាហូរហែរហូតមកហើយ នៅតែបន្តមានការភ័យខ្លាចពីបញ្ហាអសន្តិសុខក្នុងជីវិតរស់នៅ។ បើតាមរបាយការណ៍ដែលចេញផ្សាយដោយអង្គការក្រៅរដ្ឋាភិបាលបាន ត្រួតពិនិត្យពីបញ្ហាអសន្តិសុខ ចំពោះសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលជាប់ឆ្នោតថ្មីៗអតីតបេក្ខជនក៏ដូចជាសកម្មជនគណបក្សប្រឆាំងឯទៀត នៅពេលក្រុមប្រឹក្សាឃុំសង្កាត់ថ្មីបានបង្កើតឡើង។ របាយការណ៍នេះបានបញ្ជាក់ថា តាំងពីដំណើរការបោះឆ្នោតចាប់ផ្តើម អ្នកគាំទ្រគណបក្សសមរង្ស៊ីម្នាក់ត្រូវបានបាញ់សម្លាប់ក្នុងរាជធានីភ្នំពេញ និងម្នាក់ទៀតត្រូវបានគេបាញ់ឲ្យរបួសធ្ងន់ធ្ងរក្នុងខេត្តកំពង់ចាម។ មានភស្តុតាងបានបង្ហាញថា គ្រោះថ្នាក់ទាំងពីរនេះ គឺជារឿងនយោបាយ ដែលតាមពិតរដ្ឋាភិបាលកម្ពុជាគួរណាស់តែរក្សាសន្តិសុខឲ្យបានម៉ឺងម៉ាត់

[១៥២] សមាគមអាដហុកៈ ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០២ ទំព័រ ១២

[១៥៣] ខុមហ្វ្រែល ព្រឹត្តិបត្រអ្នកឃ្លាំមើល លេខ៣០ ចេញថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ ទំព័រ ៦

ដើម្បីធានាថា អ្នកនយោបាយត្រូវបានការពារពីអំពើហិង្សា និងការយាយី និងប្រជាពលរដ្ឋមានសេរីភាពបោះឆ្នោត ដោយមនសិការផ្ទាល់ខ្លួន គ្មានការគំរាមកំហែង បំភិតបំភ័យនៅក្នុងរយៈពេលយុទ្ធនាការបោះឆ្នោតជាតិ[១៥៤]។

### ៣.៣.២ ការប្រឈមក្រោយការបោះឆ្នោតសកលក្នុងឆ្នាំ២០០៣

**ករណីបាត់បង់ជីវិតសកម្មជនគណបក្សនយោបាយៈ** កម្ពុជានៅតែមិនអាចលុបបំបាត់អំពើឃាតកម្មទាំងនយោបាយ និងក្រៅច្បាប់ បើទោះបីជាមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានធានាសិទ្ធិរស់រានមានជីវិតរបស់មនុស្សទូទៅ ព្រមទាំងហាមដាច់ខាតមិនឲ្យមានច្បាប់ប្រហារជីវិតក៏ដោយ។ តែការប្រហារជីវិតក្រៅច្បាប់នៅតែកើតមាន ជាពិសេសឃាតកម្មជាប់ទាក់ទងនឹងសកម្មជនគណបក្សនយោបាយ។ ហើយករណីបែបនេះសមត្ថកិច្ចពុំសូវចាប់ខ្លួនជនដៃដល់នោះ មកផ្តន្ទាទោសនៅឡើយ។ ជាក់ស្តែងយោងតាមរបាយការណ៍ស៊ើបអង្កេតរបស់សមាគមADHOC បានបង្ហាញឲ្យឃើញថា យ៉ាងហោចណាស់ក៏មានករណីឃាតកម្មលើសកម្មជនគណបក្សនយោបាយ២៩ករណី បានកើតឡើងក្នុងអំឡុងពេលពីដើមខែមករា ឆ្នាំ២០០៣ មកដល់ថ្ងៃបោះឆ្នោត ២៧ កក្កដា ឆ្នាំ២០០៣។ តាមតួលេខនេះបង្ហាញថា ករណីនេះមានចំនួនច្រើនជាងកាលពីឆ្នាំ២០០២ មានប្រមាណជាង៥២.៣%(២០០២=១៩ករណី)[១៥៥]។ តាមរបាយការណ៍អង្កេតរបស់ COMFREL គិតត្រឹមខែសីហា ឆ្នាំ២០០៣ ដែលក្នុងអំឡុងពេលបោះឆ្នោតនេះមានចំនួន ២៨ករណី និងមានចំនួន៣១នាក់ត្រូវបានបាត់បង់ជីវិត។ របាយការណ៍នេះក៏បានបង្ហាញដែរថា ក្នុងអំពើឃាតកម្មទាំង២៨ករណី គណបក្សហ្វ៊ុនស៊ិនប៉ិច ៧ករណី និងគណបក្សសម រង្ស៊ី ១០ករណី។ ដោយឡែកអំពើឃាតកម្មទាំង២៩ករណី សមាគម ADHOC បានបង្ហាញថា មានសកម្មជនគណបក្សនយោបាយចំនួន៣៣នាក់ ត្រូវបាត់បង់ជីវិតដោយសារជនល្មើសធ្វើការបាញ់ទៅលើជនរងគ្រោះ ១៩ករណី ដោយគប់គ្រាប់បែក ១ករណី និងមានចំនួន៩ករណីទៀតជនរងគ្រោះស្លាប់ដោយសារការកាប់សម្លាប់។ ក្នុងចំនួន២៩ករណីនោះមាន១២ករណីកើតឡើងចំពោះគណបក្សសម រង្ស៊ី ដោយមានមនុស្ស១២នាក់ស្លាប់ និង៧ករណីទៀតកើតឡើងចំពោះគណបក្សហ្វ៊ុនស៊ិនប៉ិច មានមនុស្សចំនួន១០នាក់ស្លាប់។ ទន្ទឹមនោះនៅមានចំនួន១០ករណីទៀតកើតឡើងចំពោះគណបក្សប្រជាជនកំពុងកាន់អំណាចដោយមានសកម្មជនចំនួន១១នាក់បានស្លាប់។ ជាទូទៅអំពើឃាតកម្ម ដែលបានកើតឡើងចំពោះសកម្មជនអ្នកគាំទ្រគណបក្សនយោបាយទាំងអស់នោះ ភាគច្រើនទទួលរងនូវការគំរាមកំហែងដល់អាយុជីវិតមុនពេលកើតហេតុ។ ចំពោះការចាត់វិធានការតាមផ្លូវច្បាប់ទៅលើជនល្មើសវិញក្នុងចំណោម២៩ករណីដែលកើតឡើង ឃើញថាសមត្ថកិច្ចបានចាត់វិធានការតាមនីតិវិធី១១ករណីស្មើនឹង៣៧,៩៣% នៃចំនួនករណីទាំងអស់ ហើយនៅក្នុង១១ករណីនោះ មានចំនួន៧ករណីជនល្មើសត្រូវបានចាប់ខ្លួនបញ្ជូនទៅតុលាការ និងធ្វើការជំនុំជម្រះទោស និងមានចំនួន៤ករណី តុលាការស្គាល់អន្តសញ្ញាណច្បាស់លាស់ និងបានចេញដីកាស្វែងរក

---

[១៥៤] ខុមហ្វ្រែល ព្រឹត្តិបត្រអ្នកឃ្លាំមើល លេខ៣០ ចេញថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ ទំព័រ ៧

[១៥៥] សមាគមអាដហុកៈ ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៣ ទំព័រ ១២

ចាប់ខ្លួន។ ឯក្រៅពីនោះមិនទាន់ឃើញមានសញ្ញាណណាមួយបង្ហាញថា ជនល្មើសត្រូវបានសមត្ថកិច្ចរកឃើញអត្តសញ្ញាណនៅឡើយ។ ឧទាហរណ៍ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣ វេលាម៉ោង ៧និង២០នាទីព្រឹក លោក ថន បិនធឿង អាយុ២៨ឆ្នាំ ជាសកម្មជនគណបក្សសមរង្ស៊ី ត្រូវបានឃាតករបាញ់សម្លាប់នៅខាងមុខផ្ទះរបស់លោកតែម្តង[១៥៦]។

**ការគំរាមកំហែងទាក់ទងនឹងនយោបាយ:** ប្រសិនបើធ្វើការប្រៀបធៀបទៅនឹងដំណើរការបោះឆ្នោតមុនៗ នៅតាមបណ្តាខេត្តក្រុងភាគច្រើន សង្កេតឃើញថា បរិយាកាសក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ឆ្នាំ២០០៣ មានសភាពល្អប្រសើរជាងឆ្នាំ១៩៩៨។ បើទោះបីជាមានការថយចុះនូវករណីគំរាមកំហែងគួរឲ្យកត់សម្គាល់ក្តី ក៏ការគំរាមកំហែងទាំងនោះនៅតែបន្តមានចលនារស់រវើក និងមានភាពប៉ិនប្រសប់នៅតាមតំបន់ដាច់ស្រយាលនានា។ ជាក់ស្តែងក្នុងកំឡុងឆ្នាំ២០០៣ ករណីគំរាមកំហែងមកលើសកម្មជន និងអ្នកគាំទ្រគណបក្សមានចំនួន២០៩ករណី បានកើតឡើង ហើយក្នុងនោះមានជនរងគ្រោះចំនួន ៧១៩នាក់ (ស្ត្រី២០៨នាក់ ៥០៨នាក់ជាបុរស)។ ជនរងគ្រោះ ប្រមាណជា ៦៥.២២%ជាអ្នកគាំទ្រ និងមានចំនួន ៣៤.៧៨% ជនរងគ្រោះជាសកម្មជនរបស់គណបក្សនយោបាយ។ ជាមួយគ្នានេះដែរ ក្រុមអង្គការក្រៅរដ្ឋាភិបាលឯករាជ្យមួយចំនួនបានធ្វើការស៊ើបអង្កេតទៅលើករណីនេះបានធ្វើការវាយតម្លៃថា មានករណីគំរាមកំហែងជាច្រើនបានកើតឡើងក្នុងកំឡុងពេលបោះឆ្នោតជាតិ ក្នុងឆ្នាំ២០០៣ តួលេខរបស់COMFREL និង NICFEC មានចំនួន ២១៣ករណី។ តួលេខនេះបង្ហាញថា មានចំនួនប្រមាណជា៥ដងច្រើនជាងបើប្រៀបធៀបទៅនឹងចំនួនករណីដែលកើតឡើងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ កាលពីឆ្នាំ២០០២(៤៨ករណី)។ ការប្រើអំពើហិង្សា គំរាមកំហែងមកលើសកម្មជនគណបក្សនយោបាយនេះ ឃើញថាមានការកើនឡើងយ៉ាងគំហុកនៅក្នុងរយៈពេលខ្លីនៅមុនការចាប់ផ្តើមឃោសនា រហូតដល់ថ្ងៃបោះឆ្នោត(មានចំនួន១៤០ករណីស្មើនឹង៦៦.៩៨%នៃចំនួនសរុប)។ ការគំរាមកំហែងទាំងនោះមានចំនួន១៦៣ករណីកើតឡើងចំពោះគណបក្សសមរង្ស៊ី កើតឡើងចំពោះគណបក្សហ្វ៊ុនស៊ិនប៉ិច មានចំនួន៦២ករណី ៣ករណីកើតឡើងចំពោះគណបក្ស ប្រជនកម្ពុជា និងមានចំនួន៨ទៀតកើតមានចំពោះគណបក្សផ្សេងៗទៀត។ របាយការណ៍ទាំងអស់នេះបានចង្អុលបង្ហាញថា ការគំរាមកំហែងទាំងឡាយ ច្រើនតែបង្កឡើងដោយប្រធានភូមិចំនួន៣១.៣% ដោយអាជ្ញាធរឃុំ/សង្កាត់មានចំនួន ១៨.៩% ដោយប្រធានក្រុម១៤.៤% ដោយកងកម្លាំងប្រដាប់អាវុធ១១% ប៉ូលីសនិងកង រាជអាវុធហត្ថ៤% ឃោជា៧% និងក្រៅពីនេះក៏ឃើញមានជនប្រព្រឹត្តជាប្រធានអង្គភាពរបស់ជនរងគ្រោះ៦% និងកើតឡើងដោយជនមិនស្គាល់ចំនួន១៣.៩%។ សមាគម ADHOC បានកត់សម្គាល់ឃើញថា ករណីគំរាម កំហែងដែលបានកើតឡើងនោះ ជាសកម្មភាពរបស់ជនប្រព្រឹត្តដែលបានធ្វើការគំរាមកំហែងទៅសន្តិសុខ របស់ ជនរងគ្រោះប្រមាណជា៤៤.៨% គំរាមទម្លាក់ស្លាក២២.៤% គំរាមបណ្តេញចេញពីភូមិ៧.៥% បណ្តេញចេញ ពីការងារ២.៥%

[១៥៦] សមាគមអាដហុក: ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៣ ទំព័រ ១៣

និង២.៥%ទៀតគំរាមតាមរយៈសំបុត្រអនាមិក។ ចំពោះករណីគំរាមកំហែងដោយហេតុផល នយោបាយបានកើតឡើង ២០៩ករណី។ ហើយ ៣០ករណីស្មើនឹង ១៤.៣៥% ប៉ុណ្ណោះត្រូវ បានដោះស្រាយ ទៅតាមនីតិវិធីដោយមានការឃុំខ្លួនជនល្មើស៦ករណី ព្រមាន៦ករណី និង១៨ករណីធ្វើការសម្រុះសម្រួល ដោយគណៈ-កម្មការរៀបចំការបោះឆ្នោតឃុំ/សង្កាត់។ ប៉ុន្តែកាលពីនៅក្នុងកំឡុងពេលបោះឆ្នោតជាតិឆ្នាំ២០០៣ គណៈកម្មការរៀបចំការបោះឆ្នោតខេត្ត/ក្រុង បានទទួលពាក្យបណ្តឹងរហូតដល់១៨៥៥ករណី ហើយក្នុងបណ្តឹងទាំងនោះមានតែ១១ករណីទេដែលគណៈកម្មការនេះបានធ្វើការដោះស្រាយដោយដាក់ទណ្ឌកម្ម៩ករណីនិងចេញលិខិតព្រមាន២ករណី(ព័ត៌មានផ្តល់ដោយនាយកដ្ឋានសេវាកម្មច្បាប់**គ.ជ.ប.** ចំនួនរាប់ទាំងបណ្តឹងពីភាពមិនប្រក្រតីផង)។ ផ្អែកតាមទិន្នន័យនេះបង្ហាញថាមានការប្រឈមមុខដោះស្រាយបណ្តឹងទាំងឡាយដែលជាប់ទាក់ទងទៅនឹងអំពើឃាតកម្មការគំរាមកំហែង។ ទោះជាមានមន្ត្រីអនុវត្តច្បាប់មួយចំនួនបានចាត់វិធានការខ្លះ ដើម្បីផ្តន្ទាទោសជនល្មើសក៏ពិតមែន ក៏ប៉ុន្តែចំនួនខាងលើនេះនៅមិនទាន់បានឆ្លើយតបទៅនឹងចំនួនករណីដែលបានកើតឡើងនោះឡើយ ហើយនេះជាចំណុចមួយដែលបង្ហាញថា គណៈកម្មការជាតិរៀបចំការបោះឆ្នោតមិនបានអនុវត្តទៅតាមតួនាទីនិងមិនអាចប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីធ្វើការដាក់ពិន័យ ឬដាក់ទណ្ឌកម្មទៅលើជនល្មើសឲ្យបានសមស្របឡើយ។ ព្រោះថា ការចាត់វិធានការតាមច្បាប់បានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍នយោបាយរបស់បក្សឬក្រុមមន្ត្រី ដែលមានភារកិច្ចក្នុងការដោះស្រាយបញ្ហា និងសមត្ថកិច្ចមានការញញើតក្នុងការចេញសេចក្តីសម្រេច។ ជាពិសេសសេចក្តីសម្រេចចំពោះករណីដែលពាក់ព័ន្ធទៅនឹងមន្ត្រីរាជការដែលមានឋានៈខ្ពស់និងមានអំណាចធំ។ នេះបង្ហាញឲ្យឃើញថា ស្ថាប័នដោះស្រាយទំនាស់ខ្វះឯករាជ្យភាពពីគណបក្សនយោបាយ ជាពិសេស អំណាចរដ្ឋាភិបាលមានទំហំធំគ្របសង្កត់ទៅលើស្ថាប័នដទៃទៀត ដែលធ្វើឲ្យបាត់បង់គោលការណ៍តុល្យភាពអំណាចក្នុងរបបប្រជាធិបតេយ្យ[១៥៧]។

**ភាពមិនប្រក្រតីលើអ្នកបោះឆ្នោត និងសន្លឹកឆ្នោត:** មិនគ្រាន់តែមានការគំរាមកំហែង ការបំភិតបំភ័យ និងការសម្លាប់ចំពោះសកម្មជន ដែលមាននិន្នាការនយោបាយផ្សេងគ្នាប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅក្នុងរបាយការណ៍របស់សហគមន៍ ដើម្បីលទ្ធិប្រជាធិបតេយ្យ(**ម.ស.ម.ក.**) បានចូលរួមមកពី១៧៦ស្រុក ក្នុងវគ្គបណ្តុះបណ្តាលបានលើកឡើងអំពីការបង្ខិតបង្ខំអ្នកបោះឆ្នោត និងទិញសន្លឹកឆ្នោតក្នុងការបោះឆ្នោតជាតិក្នុងឆ្នាំ២០០៣។ ការបង្ខិតបង្ខំអ្នកបោះឆ្នោតត្រូវបានគេធ្វើឡើងតាមមធ្យោបាយជាច្រើនបែបយ៉ាង។ របាយការណ៍នេះបានបញ្ជាក់យ៉ាងច្បាស់ថា ការបង្ខិតបង្ខំបង្កឡើងដោយអាជ្ញាធរមូលដ្ឋាន ហើយបង្គាប់បញ្ជា គំរាមអ្នកបោះឆ្នោតឲ្យបោះឲ្យគណបក្សដែលអាជ្ញាធរនោះគាំទ្រ ឬមិនឲ្យបោះឆ្នោតឲ្យគណបក្សឯទៀត។ របាយការណ៍នេះបានលើកយកសម្មភាពបង្ខិតបង្ខំរបស់អាជ្ញាធរមូលដ្ឋានមានដូចជា: ការរឹបអូសយកប័ណ្ណបោះឆ្នោត ការបង្ខំឲ្យស្បថ និងផ្តិតមេដៃថាគាំទ្រគណបក្សរបស់គេ ការគំរាមថាសង្គ្រាមនឹងកើតឡើង បើប្រជាពលរដ្ឋបោះឆ្នោតឲ្យគណបក្សផ្សេង

[១៥៧] សមាគមអាដហុក: ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៣ ទំព័រ ១៣

ឬបោះឆ្នោតឲ្យគណបក្សប្រឆាំង គេបំភ័យថា មានបច្ចេកវិទ្យាម្យ៉ាងដែលអាចមើលឃើញថាអ្នកបោះឆ្នោតបោះឲ្យគណបក្សណាមួយ ហើយការគំរាមកំហែងកាន់តែមានសភាពធ្ងន់ធ្ងរនៅពេលថ្ងៃបោះឆ្នោតជិតមកដល់។ នៅថ្ងៃទី២៦ ជាថ្ងៃស ខែកក្កដា ឆ្នាំ២០០៣ មានការរំលោភបំពានផ្សេងៗជាច្រើនបានកើតឡើង។ អង្គការ **និកហ្វិក**(NICFEC)បានធ្វើការសង្កេតឃើញថា ការរំលោភបំពានដែលលេចធ្លោជាងគេបំផុត គឺជាការធ្វើយុទ្ធនាការឃោសនាដោយខុសច្បាប់។ នៅថ្ងៃ **ស** នេះមានការរំលោភលើច្បាប់បោះឆ្នោតចំនួន៤៤ករណី ដែលភាគច្រើននៃការរំលោភទាំងនោះ ធ្វើឡើងដោយគណបក្សកាន់អំណាច។ យុទ្ធនាការទិញសន្លឹកឆ្នោត ដោយប្រើវិធីសាស្ត្រពីរយ៉ាងគឺៈ ដោយមិនផ្ទាល់(ការផ្តល់អំណោយដល់សហគមន៍ទាំងមូល)និងឲ្យផ្ទាល់(គេឲ្យលុយដល់បុគ្គលិកម្នាក់ៗឲ្យទៅបោះឆ្នោត)។ ការរំលោភបែបនេះ ធ្វើឡើងស្ទើរគ្រប់ទីកន្លែងនិងរហ័សបំផុត ជាពិសេសនៅក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល សៀមរាប តាកែវ បាត់ដំបង កំពត កំពង់ចាម និងខេត្តកោះកុង[១៥៨]។

របាយការណ៍របស់ **ម.ស.ម.ក.** ក៏បានបង្ហាញថា មានការរឹបអូសប័ណ្ណបោះឆ្នោត ២០ករណី ការបង្ខំឲ្យស្បថមាន ១២ករណី។ ឧទាហរណ៍ៈ នៅថ្ងៃទី១១ និង ១៦ ខែមករា នៅឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត លោកចៅហ្វាយស្រុក មេឃុំ មេភូមិបានប្រមូលប្រជាពលរដ្ឋនៅក្នុងភូមិស្នួរលើ មកធ្វើការស្បថស្បែរ ដែលមានដាក់រូបព្រះពុទ្ធត្រាំក្នុងទឹកឲ្យប្រជាជនទាំងនោះផឹក ហើយឲ្យពួកគេនៅតែស្មោះត្រង់នឹងគណបក្សប្រជាជកម្ពុជា ហើយត្រូវតែបោះឆ្នោតឲ្យគណបក្សនេះជាដាច់ខាត។ ក្រោយពីស្បថរួចមន្ត្រីគណបក្សប្រជា-ជនទាំងនេះ បានបង្ខំឲ្យប្រជាពលរដ្ឋក្នុងភូមិនេះផឹកទឹកស្បថ ដែលមានដាក់គ្រាប់គាំភ្លើង។ តាមការសម្ភាសន៍របស់**ម.ស.ម.ក.** ជាមួយប្រជាពលរដ្ឋក្នុងភូមិនេះបានឲ្យដឹងថា ទង្វើបែបនេះធ្វើឲ្យប្រជាពលរដ្ឋមានការភ័យខ្លាច[១៥៩]។

**ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោតៈ** បរិយាកាសទូទៅនៅទូទាំងប្រទេសនាថ្ងៃបោះឆ្នោតមានសភាពស្ងប់ស្ងាត់ល្អ បើប្រៀបធៀបទៅនឹងការបោះឆ្នោតមុនៗ។ ដោយសារតែមានលក្ខណៈមិនប្រក្រតីតិចតួចប៉ុណ្ណោះបានកើតឡើង។ ប្រជាពលរដ្ឋប្រមាណ៦៥% ក្នុងចំណោមអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានចូលរួមបោះឆ្នោតដោយរីករាយ។ ជារួមដំណើរការបោះឆ្នោតបានបំពេញត្រូវតាមស្តង់ដាបោះឆ្នោតរបស់អង្គការ **ខុមហ្វ្រែល** និង **និកហ្វិច** ក៏ពិតមែន ក៏នៅតែសង្កេតឃើញមាននូវភាពមិនប្រក្រតីមួយចំនួនផងដែរ បានកើតឡើងថ្ងៃបោះឆ្នោតនៅតាមបណ្តាខេត្តមួយចំនួនដូចជា នៅរាជធានីភ្នំពេញ កំពង់ឆ្នាំង កំពង់ចាម ព្រះវិហារ សៀមរាម តាកែវ បាត់ដំបង។ បញ្ហាមិនប្រក្រតីទាំងនេះ មានដូចជា ការមិនអាចធានាបាននូវភាពសម្ងាត់នៃសន្លឹកឆ្នោតមានចំនួន៦០៧ករណី(ការិយាល័យមួយចំនួននៅផ្នែកខាងក្នុងនៃបន្ទប់សម្ងាត់ អាចមើលឃើញពីខាងក្រៅ)។ ការមិនពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត រកមើលទឹកខ្មៅមុនពេលប្រគល់សន្លឹកឆ្នោតឲ្យ ឬមិន

[១៥៨] អង្គការនិកហ្វិកៈ របាយការណ៍ឃ្លាំមើលការបោះឆ្នោត ឆ្នាំ២០០៣ ទំព័រ ៨

[១៥៩] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាៈ របាយការណ៍អង្កេតការបោះឆ្នោតជាតិឆ្នាំ២០០៣ ទំព័រ ១៣

បានយកម្រាមដៃអ្នកបោះឆ្នោតជ្រលក់នឹងទឹកថ្នាំ ដែលមិនអាចលាងជ្រះបាន ឬការមិនបានផ្ទៀងផ្ទាត់ប័ណ្ណបោះឆ្នោត និងបញ្ជីមានចំនួន៤៥៥ករណី។ ការធ្វើមិនដឹងមិនឮ នៃមន្ត្រីការិយាល័យក្នុងការផ្តល់ទម្រង់ពាក្យបណ្តឹងទៅឲ្យអ្នកដែលសុំប្តឹងមានចំនួន១៥៣ករណី។ ការមិនសរសេរលេខកូដ និងបោះត្រានៅលើហិបឆ្នោតមានចំនួន០៩ករណី។ ការបើកការិយាល័យបោះឆ្នោតមិនតាមកាលកំណត់របស់គ.ជ.ប. មន្ត្រីការិយាល័យបោះឆ្នោតមកយឺត និងការដឹកសម្ភារៈបោះឆ្នោតមកយឺតមានចំនួន៦៧ករណី។ ការរៀបចំឧបករណ៍សម្ភារៈបោះឆ្នោតដោយមិនបានធ្វើតាមការណែនាំរបស់គ.ជ.ប.មានចំនួន៦៧ករណី។ ការមិនបង្ហាញហិបឆ្នោតទទេទៅអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយមានចំនួន ៣៩ករណី។ របាយការណ៍នេះបញ្ជាក់ថា មានការបង្កកំហុសឆ្គង ក្នុងការរៀបចំសន្លឹកឆ្នោត ដែលបណ្តាលឲ្យមានការពន្យាពេលនៃដំណើរការបោះឆ្នោតតាមការិយាល័យខ្លះៗ ដូចជានៅទីតាំងរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម[១៦០]។

**បញ្ហាប្រឈមក្រោយពេលបោះឆ្នោត:** លទ្ធផលនៃការបោះឆ្នោតមិនបាននាំមកនូវភាពសុខសាន្តសម្រាប់សង្គមជាតិនោះទេ តែផ្ទុយទៅវិញវាបាននាំមកដល់ចំណុចទ័លច្រក ដើម្បីបង្កើតរដ្ឋាភិបាលសម្រាប់នីតិកាលទី៣។ ការជាប់គាំនេះបានបង្កនូវភាពខ្វល់ខ្វាយដល់ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស។ ស្ថានភាពនយោបាយមានការវិវត្តន៍អាប់អួរ រហូតមានសេចក្តីរាយការណ៍ថា មានការកើនឡើងនូវការគំរាមកំហែងទៅលើសកម្មជនគណបក្សសមរង្ស៊ី និងហ៊្វុនស៊ិនប៉ិច ដោយសារតែគណបក្សទាំងពីរនេះបានសម្រេចចិត្ត បដិសេធលទ្ធផលការបោះឆ្នោត និងបង្កើតសម្ព័ន្ធភាពប្រឆាំង។ ដោយគ្រាន់តែការគំរាមកំហែងនេះមានលក្ខណៈធូរស្រាលជាងក្រោយការបោះឆ្នោតឆ្នាំ១៩៩៨។ តាមរបាយការណ៍ **និកហ្វិក** បានឲ្យដឹងថាខ្លួនបានទទួលពាក្យបណ្តឹងស្តីពីការគំរាមកំហែងចំនួន៤ ពីខេត្តចំនួនតែ៤ប៉ុណ្ណោះ និងតាមរបាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាទទួលបាន ១១ករណីដោយគិតពីក្រោយបោះឆ្នោត។ នៅពេលដែលមេដឹកនាំសំខាន់គណបក្សទាំងបីពុំទាន់អាចរកឃើញកុងសង់សុស ដ៏សមស្របនៅឡើយ ដើម្បីទម្លុះទម្លាយការជាប់គាំងនយោបាយផង ស្រាប់តែស្ថានភាពទូទៅក្នុងប្រទេសបានប្រែក្លាយទៅជាតានតឹងភ្លាម បណ្តាលឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ពីសំណាក់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ម្ចាស់ប្រទេស។ ការព្រួយបារម្ភរបស់ប្រជាពលរដ្ឋផ្តោតសំខាន់ទៅលើបញ្ហាសន្តិសុខសង្គម ដូចជា ក្រៅពីចោរលួច ចោរប្លន់ប្រដាប់អាវុធដែលកើតមានជាហូរហែរ និងមានឃាតកម្មផ្សេងៗទៀត ដែលបានកើតមានឡើងដល់សកម្មជនគណបក្សនយោបាយ និងតារាចម្រៀងល្បីឈ្មោះជាដើម។ តាមរបាយការណ៍មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលបានតាមដាន និងពិនិត្យយ៉ាងច្បាស់លាស់នៅក្រោយការបោះឆ្នោតឃើញមានឃាតកម្មមានចំនួន១០ករណីបានកើតឡើង(របាយការណ៍ CCHR)[១៦១]។

### ៣.៣.៣ ការប្រឈមនៅក្នុងឆ្នាំ២០០៨

[១៦០] អង្គការនិកហ្វិក: របាយការណ៍ឃ្លាំមើលការបោះឆ្នោត ឆ្នាំ២០០៣ ទំព័រ ១៦

[១៦១] អង្គការនិកហ្វិក: របាយការណ៍ឃ្លាំមើលការបោះឆ្នោត ឆ្នាំ២០០៣ ទំព័រ ១៨

**ករណីបាត់បង់ជីវិតសកម្មជនគណបក្សនយោបាយៈ** នៅមុនការរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ សម្រាប់នីតិកាលទី៤នៃរដ្ឋសភា បើទោះបីជាមានសេចក្តីថ្លែងការណ៍ជាទូទៅរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប.) បានលើកឡើងពីភាពរលូនចាប់តាំងពីការចុះឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតមកមានដំណើរការល្អប្រសើរបំផុត បើប្រៀបធៀបទៅនឹងការរៀបចំការបោះឆ្នោត កាលពីលើកមុនៗក្តី ក៏នៅតែមានភាពប្រទាំងប្រទីសចាប់តាំងពីពេលចុះឈ្មោះបោះឆ្នោត រហូតដល់ពេលបិទបញ្ជីឈ្មោះបោះឆ្នោត ពេលយុទ្ធនាការឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោត។ ដែលភាពអសកម្មដោយចេតនាទាំងនេះ ត្រូវបានអង្គការសង្គមស៊ីវិលធ្វើការអំពាវនាវតាមរយៈលិខិតចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ ឲ្យបញ្ឈប់ហិង្សានយោបាយនៅតំណាក់កាលយុទ្ធនាការឃោសនាបោះឆ្នោត ដែលក្នុងខ្លឹមសារនេះគណៈ-pកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធអង្គការសមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ២១បានលើកឡើងថា គណៈកម្មាធិការសូមសម្តែងនូវការព្រួយបារម្ភជាខ្លាំងពីស្ថានភាពនយោបាយជាទូទៅ និងការអនុវត្តន៍ប្រជាធិបតេយ្យនៅព្រះរាជាណាចក្រកម្ពុជា ដោយបន្តលើកឡើងថា នៅក្នុងតំណាក់កាលឃោសនាបោះឆ្នោតដែលចាប់ផ្តើមពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ មានការកើតឡើងនូវអំពើហិង្សានយោបាយប្រឆាំងនឹងសកម្មជនគណបក្សនយោបាយមិនកាន់អំណាចទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដោយផ្តោតចំលើគណបក្សប្រឆាំង បាននិងកំពុងគំរាមកំហែងដល់សេរីភាព ក្នុងការចូលរួមឲ្យបានពេញលេញ នៅក្នុងពេលបោះឆ្នោតជាតិខាងមុខ។ សេរីភាពសារព័ត៌មាននេះ គឺជាសមាសធាតុដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ហើយសេរីភាពនេះក៏ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះ-រាជាណាចក្រកម្ពុជា។ សេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិលដដែលនេះក៏បានលើកឡើងផងដែរថា ក្នុងរយៈពេលឃោសនាបីសប្តាហ៍ប៉ុណ្ណោះ មានអំពើហិង្សានយោបាយកើតឡើងដូចជាៈ ការគំរាមកំហែង ការសម្លាប់អ្នកសារព័ត៌មាន និងសកម្មជនរបស់គណបក្សមិនកាន់អំណាច ដែលឈានទៅដល់ការធ្វើឲ្យចុះខ្សោយនៃស្ថានភាពសន្តិសុខជាទូទៅ ហើយដែលបង្កើតឲ្យមានការភ័យខ្លាចដល់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។ សេចក្តីថ្លែង-ការណ៍រួមនេះបានបន្ថែមថា ទោះបីជាចំនួនសរុបនៃករណីហិង្សានយោបាយហាក់ដូចជា មានចំនួនតិចជាងកាលពីរយៈពេលឃោសនាបោះឆ្នោតនៅពេលបោះឆ្នោតមុនៗក៏ដោយ ក៏អង្គការសង្គមស៊ីវិលបានសង្កេតឃើញមានព្រឹត្តិការណ៍បានកើតមានដូចជាៈ ឃាតកម្មលើសកម្មជនគណបក្សនយោបាយ និងឃាតកម្មផ្សេងៗមានចំនួន១៥ករណី បានកើតឡើងចំពោះសមាជិកសកម្មជនអ្នកគាំទ្រគណបក្សនយោបាយក្នុងនោះ គណ-បក្សសមរង្ស៊ីរងគ្រោះ៧ករណី គណបក្សនរោត្តមរណឫទ្ធិរងគ្រោះ៣ករណី គណបក្សប្រជាជនកម្ពុជា ៤ករណី គណបក្សសិទ្ធិមនុស្ស១ករណី ដែលឃាតកម្មទាំងនេះកើតមានតាមតំបន់ដូចជា កំពង់ចាម ៤ករណី បន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ធំ សៀមរាប ២ករណីដូចៗគ្នា និងកំពង់ឆ្នាំង កំពត កណ្តាល ភ្នំពេញ ព្រះវិហារ រតនៈគិរី ស្វាយរៀង តាកែវ ប៉ៃលិន ១ករណីដូចៗគ្នា។ ការរំខានឃាយី និងគំរាមកំហែងលើសកម្មជនគណបក្សនយោបាយមានចំនួន២៥ករណី ការទម្លាក់ និងបំផ្លាញស្លាកគណបក្សនយោបាយមានចំនួន១២

ករណី ការរារាំងឃោសនាបោះឆ្នោតមានចំនួន៨ករណី ការរំលោភនីតិវិធីឃោសនាបោះឆ្នោតមានចំនួន៩ករណី ការបង្កបរួសស្នាមគំរាមកំហែងមាន៥៦ករណី បានកើតមានចំពោះសមាជិកសម្ទជនអ្នកគាំទ្រគណបក្សនយោបាយនានានៅស្ទើគ្រប់ខេត្តក្រុង។ មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋានជាច្រើន បានចូលរួមសកម្មភាពគាំទ្រគណបក្សប្រជាជនកម្ពុជា ព្រមទាំងប្រឆាំងគណបក្សផ្សេងៗដោយរំលោភច្បាប់ បទបញ្ញា និងនីតិវិធីបោះឆ្នោត ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិគណបក្សនយោបាយ ដូចជា ទម្លាក់ស្លាកផ្ទាំងរូបភាព ខិតប័ណ្ណឃោសនា ការរារាំងរំខានសកម្មភាពឃោសនា ករណីចែកអំណោយក្នុងន័យទិញសន្លឹកឆ្នោតមានសរុប១៥១ករណី។ ឯជនប្រព្រឹត្តបទល្មើសភាគច្រើននៅតែមិនទាន់ត្រូវបានចាប់ខ្លួន ដើម្បីយកទៅផ្តន្ទាទោសតាមច្បាប់ និងមិនទាន់មានចំណាត់ការផ្លូវច្បាប់ឲ្យបានម៉ឺងម៉ាត់ ណាមួយពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីលុបបំបាត់ និងរារាំងកុំឲ្យមានការប្រព្រឹត្តសកម្មភាពបែបនេះនៅក្រោយៗទៀតនៅឡើយ។ ការបោះឆ្នោតដែលបើកចំហឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោតមានសិទ្ធិសេរីភាពពេញលេញ តាមបែបប្រជាធិបតេយ្យ គឺជាការសម្តែងអំណាច ឬអធិបតីរបស់ខ្លួនក្នុងការជ្រើសរើសតំណាងរបស់ខ្លួនដែលខ្លួនពេញចិត្ត ដូច្នេះបើមានអំពើហិង្សានយោបាយកើតឡើងនោះ វាធ្វើឲ្យការបោះឆ្នោតមិនអាចដំណើរការទៅតាមទម្រង់ប្រជាធិបតេយ្យពិតប្រាកដឡើយ[១៦២]។

តាមរបាយការណ៍សង្កេតទី៨ របស់ខុមហ្វ្រែល ចេញផ្សាយកាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ បានលើកឡើងថា ខ្លួនបានដាក់ពង្រាយអ្នកសង្កេតការណ៍ប្រមាណជាង ១.០០០នាក់ រួមទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិប្រមាណជាង ២០ស្ថាប័ន ព្រមទាំងសហការណ៍យ៉ាងជិតស្និទ្ធជាមួយអង្គការសង្កេតការអន្តរជាតិ ដូចជាបណ្តាញអាស៊ី ដើម្បីការបោះឆ្នោត(ANFEREL) និងវេទិការនៃប្រជាពលរដ្ឋស្តីពីកម្ពុជា ប្រទេសជប៉ុន(PEFOC,J) ដោយទាញសេចក្តីសន្និដ្ឋានថា ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ បានប្រព្រឹត្តទៅក្នុងលក្ខណៈល្អលើបច្ចេកទេសនៃការចាត់ចែងនីតិវិធីដំណើរការបោះឆ្នោតរាប់សន្លឹកឆ្នោតក្នុងបន្ទប់ការិយាល័យ។ ទោះជាយ៉ាងណា មានភាពមិនប្រក្រតីនិងបណ្តឹង(ផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ) ប្រហាក់ប្រហែលគ្នានឹងការបោះឆ្នោតកាលពីឆ្នាំ២០០៣ដែរ។ ដោយឡែក មានបញ្ហាធ្ងន់ធ្ងរប៉ះពាល់លើការបាត់បង់សិទ្ធិអ្នកបោះឆ្នោតច្រើនជាងការបោះឆ្នោតមុនៗ។ ភាពមិនប្រក្រតីស្តីពីការបាត់សិទ្ធិបោះឆ្នោត និយាយទៅដល់ឧបសគ្គដល់អ្នកបោះឆ្នោតនៅការិយាល័យ ដែលបណ្តាលមកពីអ្នកមានសិទ្ធិបោះឆ្នោតបាត់ឈ្មោះពីក្នុងបញ្ជីបោះឆ្នោត អ្នកបោះឆ្នោតគ្មានព័ត៌មានអំពីការិយាល័យបោះឆ្នោត(មិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ឬការប្តូរការិយាល័យបោះឆ្នោត) និងការយល់ច្រឡំរបស់អ្នកបោះឆ្នោតក្នុងការប្រើប្រាស់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដែលភាគច្រើនមាននៅទីរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ កំពង់ចាម តាកែវ កំពត កំពង់ធំ សៀមរាប កំពង់ឆ្នាំង ព្រះសីហនុ ព្រៃវែង ព្រះវិហារ បាត់ដំបង

[១៦២] គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា លិខិតចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨

កំពង់ស្ពឺ មណ្ឌលគីរី កោះកុង ក្រចេះ និងខេត្តស្វាយរៀង[១៦៣]។

របាយការណ៍របស់អ្នកសង្កេតការណ៍ខុមហ្វ្រែលបានបង្ហាញថា ចំនួននៃភាពមិនប្រក្រតីនៅក្នុងការិយាល័យបោះឆ្នោតរាប់សន្លឹកឆ្នោតមានចំនួនប្រហាក់ប្រហែលនឹងការបោះឆ្នោតឆ្នាំ២០០៣ដែរ (ដែលមាន៣,៧២៣ករណីមានអ្នកសង្កេតការណ៍ប្រមាណ១,៥០០នាក់ ក្នុងប្រមាណជាង៩០%នៃការិយាល័យសរុបគ្រប់រាជធានី/ខេត្ត) ចំណែកការបោះឆ្នោតឆ្នាំ២០០៨ នេះមាន២,០១២ករណី(ដែលមានអ្នកសង្កេតការណ៍ចំនួន ១១,០០០ សង្កេតនៅក្នុងប្រមាណជាង ៧០% នៃការិយាល័យបោះឆ្នោតសរុបក្នុងរាជធានី ខេត្ត/ក្រុង ចំនួន ១៥ និង៥% នៃការិយាល័យក្នុងរាជធានី ខេត្ត/ក្រុងចំនួន ៩ផ្សេងទៀត)។ ភាពមិនប្រក្រតីនៅខាងក្រៅបន្ទប់ការិយាល័យបោះឆ្នោតជាច្រើននៅពុំទាន់បានកែលំអ រួមទាំងវត្តមានមេក្រុម អាជ្ញាធរភូមិឃុំនៅជុំវិញការិយាល័យបោះឆ្នោត ដោយមានសកម្មភាពមិនអព្យាក្រឹត្យ ដើម្បីជះឥទ្ធិពលទៅលើអ្នកបោះឆ្នោតដែលមិនស្របតាមបទបញ្ញា និងនីតិវិធីនានាពាក់ព័ន្ធនឹងការបោះឆ្នោត។ ភាពមិនប្រក្រតីនឹងបណ្តឹងមួយចំនួនដែលអាជ្ញាធរមូលដ្ឋាន ឃុំ/សង្កាត់ មិនបានគោរព និងអនុវត្តតាមនីតិវិធី និងសេចក្តីណែនាំរបស់ គ.ជ.ប ទេ ដោយមានចេញទម្រង់១០១៨ នៅថ្ងៃបោះឆ្នោតក្នុងឃុំ/ស្រុកឡាបានសៀក ខេត្តរតនៈគីរី ឃុំព្រែកញ្ចៅ ស្រុកពញាឮ ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តព្រះសីហនុ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ និងរាជធានីភ្នំពេញ និងគណៈកម្មាធិការរៀបចំការបោះឆ្នោត ថ្នាក់ឃុំ/សង្កាត់ និងរាជធានី ខេត្ត/ក្រុង មិនសូវយកចិត្តទុកដាក់ក្នុងការទទួល និងដោះស្រាយពាក្យបណ្តឹងឡើយ ដោយបដិសេធរហូតដល់ប្រហែល៤៥% នៃពាក្យបណ្តឹងរបស់គណបក្សនយោបាយ។ របាយការណ៍នេះបានលើកឡើងថា មានប្រជាពលរដ្ឋតែ៧៤.៨%បានបោះឆ្នោត(ប្រមាណ៦លាននាក់ប៉ុណ្ណោះ) នៃអ្នកមានឈ្មោះបោះឆ្នោតទូទាំងប្រទេសប្រមាណ៨.១២លាននាក់ ដើម្បីជ្រើសតាំងតំណាងរបស់ខ្លួន។ ការសង្កេតរបស់ខុមហ្វ្រែល រកឃើញថាក្នុងចំណោមអ្នកមិនបានបោះឆ្នោតមាន១,១៤៨ករណី ដែលអ្នកបោះឆ្នោតបានទៅការិយាល័យបោះឆ្នោត ប៉ុន្តែបានជួបឧបសគ្គ ដែលមិនអាចបោះឆ្នោតបាន[១៦៤]។

### ១-ភាពមិនប្រក្រតីនៅថ្ងៃ ស អំឡុងថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត និងបូកសរុបលទ្ធផល

ចំនួនភាពមិនប្រក្រតីក្នុងកំឡុងពេលថ្ងៃ ស និងដំណើរការបោះឆ្នោត ព្រមទាំងរាប់សន្លឹកឆ្នោតរួមមានប្រមាណ ២០១២ករណីបានកើតមាននៅស្ទើរគ្រប់រាជធានី ខេត្ត/ក្រុង ដូចជា រាជធានីភ្នំពេញមានចំនួន ៦១៦ករណី បន្ទាយមានជ័យមានចំនួន ៣៥៤ករណី កំពង់ចាមមានចំនួន១៧៧ករណី កោះកុងមានចំនួន ១១៦ករណី តាកែវមានចំនួន១០៧ករណី កំពង់ឆ្នាំងមានចំនួន៩៣ករណី ព្រៃវែងមានចំនួន៧៤ករណី កំពង់ធំមានចំនួន៦៧ករណី សៀមរាបមានចំនួន៣០ករណី បាត់ដំបងមានចំនួន២៩ករណី កំពង់ស្ពឺមានចំនួន២៧ករណី ព្រះសីហនុមានចំនួន២៣ករណី ព្រះវិហារមានចំនួន២២ករណី ខេត្តកែបមានចំនួន១០ករណី កណ្តាល

[១៦៣] របាយករណ៍សង្កេតទី៨ របស់ខុមហ្វ្រែល ចេញផ្សាយថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩

[១៦៤] ដ.ឯ.ម

មានចំនួន៨ករណី មណ្ឌលគីរីមានចំនួន៨ករណី ឧត្តរមានជ័យមានចំនួន៦ករណី ប៉ៃលិនមានចំនួន៥ករណី និងខេត្តស្ទឹងត្រែងមានចំនួន៣ករណី។ ហើយករណីទាំងអស់នេះបានកើតឡើងដូចជាៈ

**១-១ ថ្ងៃ ស (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨)**

-វិទ្យុនិងទូរទស្សន៍ជាច្រើនបានខិតខំគោរពតាមបទបញ្ជា និងនីតិវិធី ក៏ដូចជាសេចក្តីណែនាំរបស់ **គ.ជ.ប.** បានល្អដោយមិនផ្សាយឃោសនានយោបាយឲ្យគណបក្សណាមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានការបិទផ្សាយវិទ្យុមហានគរ FM 93.5 MHz ទាំងយប់(វេលាម៉ោងប្រមាណ ១១យប់ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨) ពីសំណាក់ក្រសួងព័ត៌មាន ដោយមូលហេតុកម្មវិធីនេះបានចាក់ផ្សាយប្រវត្តិរបស់លោក សម រង្ស៊ី ដែលមានការទិតៀនដល់នាយករដ្ឋមន្ត្រី ហ៊ុន សែន។ វិទ្យុនេះត្រូវបានក្រសួងព័ត៌មានអនុញ្ញាតឲ្យធ្វើការផ្សាយឡើងវិញនៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៨ បន្ទាប់ពីម្ចាស់ស្ថានីយ៍វិទ្យុនេះបានស្នើទៅក្រសួងព័ត៌មាន។

-ការធ្វើសកម្មភាពឃោសនាថ្ងៃ ស ដោយខុសច្បាប់បានកើតមានក្នុងខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ កំពត កោះកុង ព្រៃវែង ពោធិ៍សាត់ រាជធានីភ្នំពេញ សៀមរាប រតនៈគីរី និងតាកែវ យ៉ាងតិច ២៤ករណី ដូចជាករណីចែកអំណោយ ដើម្បីទិញទឹកចិត្តអ្នកបោះឆ្នោតជាដើម។ ករណីនេះគណបក្សនយោបាយបានដាក់ពាក្យប្តឹងចំនួន២ ប៉ុន្តែមិនត្រូវបានដោះស្រាយទាំង២ករណី។

-បរិយាកាសដែលគ្មានសុវត្ថិភាពនៅក្នុងភូមិជុំវិញការិយាល័យបោះឆ្នោតចំនួន២០ករណី ដូចជានៅខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពត ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ និងខេត្តកែបជាដើម។ ករណីនេះគណបក្សនយោបាយបានដាក់ពាក្យប្តឹងចំនួន៦ករណីប៉ុន្តែមិនត្រូវបានដោះស្រាយចំនួន៥ករណី។

-ករណីខ្វះសម្ភារៈមួយចំនួនដែលនាំឲ្យមានការរាំងស្ទះ ឬយឺតយ៉ាវដល់ដំណើរការនៃកាបើកការិយាល័យបោះឆ្នោតមានចំនួន១៦ករណី នៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង ក្រចេះ សៀមរាប និងតាកែវ។

**១-២ ថ្ងៃបោះឆ្នោត(ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨)**

-បាត់សិទ្ធិបោះឆ្នោតមានរហូតដល់៧០៣ករណី បានកើតឡើងនៅរាជធានីខេត្ត/ក្រុង មួយចំនួនធំ ដូចជា រាជធានីភ្នំពេញ ២៤៧ករណី ខេត្តបន្ទាយមានជ័យ១៦២ករណី កំពង់ចាម៤៨ករណី តាកែវ៣៣ករណី កំពត២៦ករណី កំពង់ធំ២៤ករណី សៀមរាប២១ករណី កំពង់ឆ្នាំង១៧ករណី ព្រះសីហនុ១៧ករណី ព្រៃវែង ១៤ករណី ព្រះវិហារ១០ករណី បាត់ដំបង៨ករណី កំពង់ស្ពឺ មណ្ឌលគីរី កោះកុង ក្រចេះ ព្រមទាំងខេត្តស្វាយរៀង។ ករណីនេះអ្នកបោះឆ្នោតដែលមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ ឬអ្នកបោះឆ្នោតបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ២០០៧ តែមិនមានឈ្មោះបោះឆ្នោតឆ្នាំ២០០៨នោះទេ។ ករណីគណបក្សនយោបាយបានដាក់ពាក្យប្តឹងចំនួន៧១បណ្តឹង ប៉ុន្តែមិនត្រូវបានដោះស្រាយ ចំនួន២២ករណី។

-អ្នកបោះឆ្នោតរកឈ្មោះមិនឃើញមានចំនួនប្រមាណ៤៤៥ករណី ដែលកើតមាននៅខេត្ត/ក្រុងមួយចំនួនដូចជា រាជធានីភ្នំពេញ២១៥ករណី បន្ទាយមានជ័យ១១០ករណី កំពង់ចាម២៩ករណី សៀមរាប១៧ករណី ក្រចេះ១៦ករណី តាកែវ១៣ករណី កំពត១២ករណី កំពង់ធំ បាត់ដំបង កំពង់ឆ្នាំង កោះកុង មណ្ឌលគីរី ព្រះវិហារ ព្រៃវែង ព្រមទាំងខេត្តស្វាយរៀង។ ករណីនេះគណបក្សបានដាក់ពាក្យប្តឹងចំនួន៣៥ ប៉ុន្តែមិនត្រូវបានដោះស្រាយចំនួន១៥ករណី។

-មានសកម្មភាពដឹកជញ្ជូន ឬផ្តល់លុយកាត់ដល់អ្នកបោះឆ្នោតក្នុងទ្រង់ទ្រាយធំ ទៅបោះឆ្នោតពីសំណាក់ សកម្មជនគណបក្សនយោបាយមួយចំនួន ជាពិសេសគណបក្សកាន់អំណាច(គណបក្សប្រជាជនកម្ពុជា)។ ជាក់ស្តែងនៅឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង(ការិយាល័យលេខ០៧២២) ស្រុកឡាបានសៀក ខេត្តរតនគីរី ខេត្តស្វាយរៀង ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង និងខេត្តកំពង់ចាមជាដើម។

-ការឃោសនាតាមរយៈការចែកអំណោយ ឬឃោសនាដោយចែក/បិតផ្ទាំងរូបភាព ឬខិតប័ណ្ណដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយរបស់ខ្លួនមាន២៨ករណី កើតមានឡើងនៅខេត្តព្រះសីហនុ ខេត្តកំពង់ចាម បន្ទាយមានជ័យ កំពង់ឆ្នាំង កំពត កោះកុង ក្រចេះ កំពង់ធំ និងសៀមរាប។

-វត្តមានដោយខុសច្បាប់របស់អាជ្ញាធរមូលដ្ឋាន ជាពិសេសមេក្រុម បិតនៅជុំវិញការិយាល័យបោះឆ្នោត ដើម្បីតាមឃ្លាំមើលអ្នកបោះឆ្នោត ណែនាំអ្នកបោះឆ្នោតឲ្យគូសគណបក្សរបស់ខ្លួន ដែលជាហេតុបណ្តាលឲ្យអ្នកបោះឆ្នោតមួយចំនួនមានអារម្មណ៍ភ័យខ្លាចចំនួន១៤១ករណី។ ករណីទាំងនេះកើតឡើងនៅតាមការិយាល័យបោះឆ្នោតមួយចំនួនក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កោះកុង ក្រចេះ ភ្នំពេញ ព្រៃវែង សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង តាកែវ និងប៉ៃលិន។

-មានការអនុញ្ញាតឲ្យកងកម្លាំងប្រដាប់អាវុធក្នុងឯកសណ្ឋាន និងយកអាវុធជាតិផ្ទុះចូលទៅក្នុងការិយាល័យបោះឆ្នោតមាន១៣៣ករណី ក្នុងខេត្តកំពង់ចាម ភ្នំពេញ មណ្ឌលគិរី តាកែវ កំពង់ធំ ក្រចេះ និងសៀមរាប។

-ការរារាំងអ្នកបោះឆ្នោត ដោយផ្តល់ជាលុយកាក់ ឬសម្ភារៈផ្សេងៗ ដើម្បីកុំឲ្យទៅបោះឆ្នោតមាន៤ករណី នៅខេត្តកំពង់ចាម កំពង់ស្ពឺ និងខេត្តសៀមរាប។

-នីតិវិធីនៃការបោះឆ្នោត មិនត្រូវបានគោរពពេញលេញដោយមន្ត្រីការិយាល័យ ដែលនាំមកនូវភាពមិនប្រក្រតីចំនួន២០៧ករណី នៅក្នុងការិយាល័យបោះឆ្នោត។ ករណីភាគច្រើនកើតមានឡើងនៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម ព្រះវិហារ សៀមរាប តាកែវ កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ បាត់ដំបង ពោធិ៍សាត់ ស្វាយរៀង ឧត្តរមានជ័យ និងខេត្តកោះកុងដោយរួមមាន:

-មិនមានការបង្ហាញហិបឆ្នោតទទេ មុនពេលចាប់ផ្តើមដំណើរការបោះឆ្នោតមាន២៥ករណី។

-ការបើកការិយាល័យយឺតជាងម៉ោង ៧:០០ព្រឹក (បើកមិនតាមពេលកំណត់) មាន២៣ករណី។

-ភាពមិនប្រក្រតីនានាដែលនាំឲ្យបាត់ភាពសម្ងាត់នៃដំណើរការបោះឆ្នោតមាន ៨៩ករណី។

-ការមិនពិនិត្យមើលម្រាមដៃ ឬមិនជ្រលក់ទឹកខ្មៅលាងមិនជ្រះ ឬមិនពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះជាមួយ ឯកសារ ឬការឲ្យសន្លឹកឆ្នោតលើសពីមួយសន្លឹកមានចំនួន ៥០ករណី។

-ការផ្អាក ឬបិទការិយាល័យនៅពេលកំពុងដំណើរការបោះឆ្នោតមានចំនួន២០ករណី កើតមាននៅខេត្តកំពត បន្ទាយមានជ័យ ព្រៃវែង សៀមរាប តាកែវ និងរាជធានីភ្នំពេញ។

-មានអ្នកគ្មានសិទ្ធិបោះឆ្នោតឬអ្នកមានស្នាមទឹកខ្មៅនៅម្រាមដៃសម្គាល់ថា បានបោះឆ្នោតរួចហើយ អនុញ្ញាតឲ្យបោះឆ្នោតម្តងទៀតមានចំនួន១២ករណី កើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម ភ្នំពេញ ក្រចេះ និងខេត្តសៀមរាប។

-មានអ្នកបោះឆ្នោតព្យាយាមយកសន្លឹកឆ្នោតចេញមក្រៅ ដើម្បីឲ្យអ្នកបោះឆ្នោតផ្សេងទៀតគូស មាន១ករណីកើតមាននៅខេត្តព្រះវិហារ។

-ការបដិសេធ ឬមិនអើពើ ឬមិនព្រមប្រគល់ទម្រង់ប្តឹងតវ៉ា ឬជំទាស់(ទម្រង់លេខ១២០២) ទៅអ្នកបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ ពីសំណាក់មន្ត្រីរៀបចំការបោះឆ្នោតចំនួន១០ករណី ដែលកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំង ភ្នំពេញ និងខេត្តស្វាយរៀង។

**១-៣ ភាពមិនប្រក្រតីក្នុងដំណើរការរាប់សន្លឹកឆ្នោត និងបូកសរុបលទ្ធផល**

**ក-ភាពមិនប្រក្រតីក្នុងការថែរក្សាសុវត្ថិភាពសន្លឹកឆ្នោត**

បន្ទាប់ពីដំណើរការបោះឆ្នោតបានបញ្ចប់នៅម៉ោង ៣រសៀល ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខុមហ្វ្រែលនៅបន្តពិនិត្យលើការថែរក្សាសុវត្ថិភាពសន្លឹកឆ្នោតរបស់មន្ត្រីរៀបចំការបោះឆ្នោត ដែលក្នុងនោះ ខុមហ្វ្រែលបានរកឃើញនូវភាពមិនប្រក្រតីមួយចំនួនដូចជាៈ[១៦៥]

-ការអនុញ្ញាតឲ្យមនុស្សគ្មានភារកិច្ចដើរចេញចូលការិយាល័យបោះឆ្នោត នៅពេលក្រោយបិទការិយាល័យ មានចំនួន១៨ករណី កើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំង ភ្នំពេញ សៀមរាប និងតាកែវ។

-ករណីមិនមួលផ្សិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត និងមិនចាក់សោឃ្លុំហឹបឆ្នោតមានចំនួន ៤ករណី កើតមាននៅខេត្តបាត់ដំបង និងព្រៃវែង។

-ការរំខានរារាំងដល់ដំណើរការរាប់សន្លឹកឆ្នោតមាន ២៣ករណី កើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំង ព្រៃវែង និងតាកែវ។

**ខ-ភាពមិនប្រក្រតីក្នុងដំណើរការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៅការិយាល័យរាប់សន្លឹកឆ្នោត**

នៅពេលរាប់សន្លឹកឆ្នោតតាមសេចក្តីរាយការណ៍បានបង្ហាញថា មានមន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត មិនបានគោរពតាមបទបញ្ញា និងនីតិវិធីព្រមទាំងសេចក្តីណែនាំរបស់ គ.ជ.ប ដែលធ្វើឲ្យមានភាព

[១៦៥] ព្រឹត្តិបត្រ ខុមហ្វ្រែល អ្នកឃ្លាំមើល លេខ៣១ ឆ្នាំទី៨ ផ្សាយចេញថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ទំព័រ ៧

មិនប្រក្រតីមានចំនួនកើតមានដូចជា៖[១៦៦]

-ការពន្យាពេលរាប់សន្លឹកឆ្នោតក្នុងការិយាល័យរាប់សន្លឹកឆ្នោតមានចំនួន១៣ករណី ដែលកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ធំ ភ្នំពេញ ព្រៃវែង និងខេត្តតាកែវ។

-ការមិនអនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោយ និងអ្នកសង្កេតការណ៍ចូលរួមសង្កេតការណ៍រាប់សន្លឹកឆ្នោត មានយ៉ាងហោចណាស់ ២២ករណី នៅខេត្តបន្ទាយមានជ័យនិង ព្រៃវែង។

-ការមិនបង្ហាញឲ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយចូលរួមពិនិត្យសោឃ្លុំមុននឹងបើកគម្របហឹបឆ្នោតមានយ៉ាងហោចណាស់ ២២ករណី នៅខេត្តកំពង់ចាម។

-ភាពមិនប្រក្រតីក្នុងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោតមានចំនួន១៤ករណី ដែលកើតឡើងជាពិសេសនៅខេត្តតាកែវ ភ្នំពេញ និងខេត្តកំពង់ធំ។

-ការទទួលស្គាល់សន្លឹកឆ្នោតបានការ និងការបដិសេធលើសន្លឹកឆ្នោតមិនបានការ ដោយមិនអនុញ្ញាតឲ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយបានធ្វើការត្រួតពិនិត្យមាន៥ករណី ដែលកើតឡើងនៅខេត្តកំពង់ឆ្នាំង និងភ្នំពេញ។

-បញ្ហាខ្វះខាតសម្ភារៈសំខាន់ៗ ធ្វើឲ្យរាំងស្ទះដល់ដំណើរការរាប់សន្លឹកឆ្នោតមានចំនួន៣ករណី ដែលកើតមាននៅខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ។

**គ-ការផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបោះឆ្នោតនៅគឃ/សប និងគខ/កប**

ការសង្កេតខ្លះៗ រកឃើញក្នុងកំឡុងការបូកសរុបលទ្ធផលបោះឆ្នោត នៅគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត(គឃ/សប) មានភ្នាក់ងារសង្កេតការណ៍គណបក្សប្រជាជនកម្ពុជាគ្រប់កន្លែង និងភ្នាក់ងារសង្កេតការណ៍របស់គណបក្សសមរង្ស៊ីខ្លះ ក្រៅពីនេះ គឺមិនមានអ្នកសង្កេតការណ៍គណបក្សណាផ្សេងទៀតបានចូលរួមនោះទេ។ អ្នកសង្កេតការណ៍ខុមហ្វ្រែល រកឃើញការផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបោះឆ្នោតដែលស្ទើរគ្រប់គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត(គខ/កប) មិនបានយកចិត្តទុកដាក់ផ្ទៀងផ្ទាត់លទ្ធផលបូកសរុបសន្លឹកឆ្នោតរបស់គឃ/សប និងកំណត់ហេតុលទ្ធផលបោះឆ្នោតរបស់គណៈកម្មការការិយាល័យបោះឆ្នោត(គករ)នោះទេ។

**ឃ-ភាពមិនប្រក្រតីក្នុងការរៀបចំ និងការវេចខ្ចប់សម្ភារៈ ឯកសារបោះឆ្នោត**

-ការមិនបង្ហាញកំណត់ហេតុបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំពោះអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយមានចំនួន៨ករណី។

-ការមិនអនុញ្ញាតឲ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយសង្កេតមើលរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារៈ ឯកសារបោះឆ្នោត សម្រាប់បញ្ជូនពីការិយាល័យរាប់សន្លឹកឆ្នោតទៅ

---

[១៦៦] ព្រឹត្តិបត្រ ខុមហ្វ្រែល អ្នកឃ្លាំមើល លេខ៣១ ឆ្នាំទី៨ ផ្សាយចេញថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ទំព័រ ៨

គយ/សប មានចំនួន ៩ករណី នៅខេត្តបន្ទាយមានជ័យ ភ្នំពេញ កំពង់ធំ និងខេត្តតាកែវ។

-ការមិនផ្តល់ព័ត៌មានដល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ អំពីផ្ទះ ឬទីតាំងសុវត្ថិភាព ដែលរក្សាទុកលទ្ធផលបោះឆ្នោតមានចំនួន៩ករណី។

**២-បណ្តឹងថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត**

នៅរាល់ការបោះឆ្នោតជាសកលចាប់តាំងពីឆ្នាំ១៩៩៣មកឃើញថា ការប្តឹងផ្តល់គ្នា ការតវ៉ាស្តីពីការរំលោភនីតិវិធីបោះឆ្នោត ភាពមិនប្រក្រតីផ្សេងៗកើតមានមិនចេះចប់។ សម្រាប់ការបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រនៃនីតិកាលទី៤ រដ្ឋសភា ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ឃើញថា បញ្ហាទាំងនេះនៅតែកើតមានដដែល ហើយកាន់តែមានសភាពធ្ងន់ធ្ងរជាងមុន។ យោងតាមរបាយការណ៍របស់គ.ជ.ប. ការទទួល និងដោះស្រាយបណ្តឹងនៅ គយ/សប គខ/កប និង គ.ជ.ប. ក្នុងដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត គិតត្រឹមថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៨ មានបណ្តឹងចំនួន១៤៣ករណី នៅគយ/សប បណ្តឹង៨៤ករណី នៅ គខ/កប និងបណ្តឹងចំនួន២៤ករណីទៀតនៅ គ.ជ.ប. [១៦៧]។

**២-១ ដំណើរការបណ្តឹងនៅគយ/សប**

បើទោះបីមានករណីខ្លះថា មន្ត្រីការិយាល័យបោះឆ្នោតមិនចង់ផ្តល់ទម្រង់បណ្តឹង និងភ្នាក់ងារគណ-បក្ស មានការភ័យខ្លាច នៅពេលមានការប្តឹងផ្តល់យ៉ាងណាក៏ដោយ ក៏បណ្តឹងទាំងអស់ដែលបានដាក់ទៅគយ/សប ពីសំណាក់គណបក្សនយោបាយដែលផ្តោតលើបញ្ហាស្តីពីការចេញ និងដកហូតទម្រង់១០១៨ ពីសំណាក់អាជ្ញាធរភូមិ/ឃុំ វត្តមានមេភូមិ មេឃុំ នៅមុខការិយាល័យបោះឆ្នោត និងការបដិសេធលើលទ្ធផលបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងនោះមានបណ្តឹងចំនួន៦០ស្មើនឹង៤២% នៃចំនួនបណ្តឹងសរុបខាងលើត្រូវបានចាបដិសេធដោយយោងលើមូលហេតុ បណ្តឹងគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់។ ក្នុងចំណោមបណ្តឹងទាំងនោះគណបក្សសមរង្ស៊ី មានបណ្តឹងច្រើនជាគេរហូតដល់១១២ករណី ប៉ុន្តែត្រូវបានចាបដិសេធចំនួន ៥៤ករណី ផ្សះផ្សា សះជា មានចំនួន៣៩ករណី ប្រជុំសម្រេចបដិសេធបណ្តឹងចំនួន៨ករណីដកពាក្យបណ្តឹងដោយសាមីខ្លួនចំនួន៤ករណី និងផ្សះផ្សាមិនសះជាចំនួន៧ករណី។ មានបណ្តឹងរបស់គណបក្សប្រជាជនកម្ពុជាចំនួន១២ករណី ដែលត្រូវបានគណៈកម្មការឃុំ/សង្កាត់ រៀបចំការបោះឆ្នោតលើកយកមកដោះស្រាយចំនួន៧ករណី រួមមានការផ្សះផ្សាសះជាចំនួន១ករណី ប្រជុំសម្រេចបដិសេធចំនួន១ករណី និងផ្សះផ្សាមិនសះជាចំនួន ៣ករណី។ បណ្តឹងរបស់គណបក្សនរោត្តមរណឫទ្ធិ មានចំនួន១០ករណី ដែលមានការចាបដិសេធចំនួន២ករណី ដោះស្រាយចំនួន២ករណី រួមមានការផ្សះផ្សាសះជា១ករណីនិងផ្សះផ្សាមិនសះជាចំនួន៤ករណី។ បណ្តឹងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិចមានចំនួន២ករណី ដែលបានលើកយកមកដោះស្រាយចំនួន១ករណី និងផ្សះផ្សាសះជាចំនួន១ករណី។ គណបក្សសិទ្ធិមនុស្សមានបណ្តឹងចំនួន៣ករណី ដែលត្រូវបានចាបដិសេធចំនួន២ករណី និង

---

[១៦៧] ព្រឹត្តិបត្រ ខុមហ្វ្រែល អ្នកឃ្លាំមើល លេខ៣៤ ឆ្នាំទី៩ ផ្សាយចេញថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៨ ទំព័រ ៨

លើកយកមកដោះស្រាយចំនួន១ករណី។

យោងតាមចំណុច ៨.១៧.២ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ការប្រើប្រាស់អំណាចបដិសេធ ដោយស្របច្បាប់មិនទទួលយកពាក្យបណ្តឹងមកដោះស្រាយដោយ គឃ/សប អាចធ្វើទៅបានតែក្នុងករណីហួសរយៈពេលកំណត់នៃការទទួលពាក្យបណ្តឹងតែប៉ុណ្ណោះ(ហួស អាជ្ញាយុកាលនៃបណ្តឹងត្រឹមម៉ោង ១១:៣០នាទី នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨)។ ហេតុដូច្នេះ គឃ/សប មិនមានអំណាចណាមួយក្នុងការចារបដិសេធពាក្យបណ្តឹង ឬមិនទទួលយកពាក្យបណ្តឹងមកដោះស្រាយនៅក្នុង ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោតនោះទេ។ ផ្ទុយទៅវិញក្នុងករណីនេះការបដិសេធទៅលើពាក្យបណ្តឹង ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ដែលទាមទារឲ្យឆ្លងកាត់ការប្រជុំសម្រេច ដូច្នេះការបដិសេធ ទាំងនោះត្រូវធ្វើឡើងដោយទម្រង់១២០៣។ ការរំលោភអំណាចសមត្ថកិច្ចជាក់ស្តែងបែបនេះដោយចារបដិសេធ លើទម្រង់១២០២ មានជាង៣៦ករណី បានធ្វើឲ្យប៉ះពាល់ដល់និយ័តភាពនៃការគោរពបទដ្ឋានគតិយុត្ត ទាក់ទងនឹងការបោះឆ្នោត[១៦៨]។

**២-២ ដំណើរការបណ្តឹងនៅ គខ/កប**

នៅថ្នាក់ គខ/កប វិញមកបណ្តឹងចំនួន៨៤ករណីត្រូវបានដើមបណ្តឹងដាក់មក។ ក្នុងនោះមានបណ្តឹង ចំនួន៤៩ករណីស្មើនឹង៥៨% ត្រូវបានបដិសេធដោយយោងទៅលើមូលហេតុបណ្តឹងមិនគ្រប់លក្ខណៈសម្បត្តិ។ មានបណ្តឹងចំនួនតែ ១៦ករណី ប៉ុណ្ណោះត្រូវបានដោះស្រាយដោយយល់ស្របតាមភាគីដើមបណ្តឹង។

កម្មវត្ថុនៃពាក្យបណ្តឹង ដែលត្រូវបានលើកឡើងរួមមានវត្តមានអាជ្ញាធរមូលដ្ឋាននៅខាងក្រៅការិយាល័យ បោះឆ្នោតការដកហូតឯកសារអត្តសញ្ញាណពីប្រជាពលរដ្ឋ ការចេញទម្រង់១០១៨មិនស្របច្បាប់ ការ ចែកអំណោយ ការទិញសន្លឹកឆ្នោត ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត និង ប្រធានការិយាល័យបោះឆ្នោតជួយគូសលើសន្លឹកឆ្នោត។ ដោយឡែក គខ/កប បានទទួលពាក្យបណ្តឹងស្តីពីការ បដិសេធលទ្ធផលបោះឆ្នោត ហើយបានសម្រេចបដិសេធពាក្យបណ្តឹងនេះ ប៉ុន្តែតាមមាត្រា១១៤នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺគណបក្សនយោបាយអាចដាក់ពាក្យបណ្តឹងជំទាស់នឹងលទ្ធផលនៃ ការបោះឆ្នោតក្នុងរយៈពេល៧២ម៉ោង ក្រោយពេលគ.ជ.ប. ប្រកាសលទ្ធផលបណ្តោះអាសន្ន ហើយពាក្យបណ្តឹង នេះត្រូវដាក់នៅ គ.ជ.ប. ឬក្រុមប្រឹក្សាធម្មនុញ្ញ មិនមែនដាក់នៅ គឃ/សប ឬនិង គខ/កប ទេ[១៦៩]។

ចំពោះពាក្យបណ្តឹង ពីភាពមិនប្រក្រតីនៅថ្ងៃបោះឆ្នោតរាប់សន្លឹកឆ្នោត បណ្តឹងភាគច្រើនត្រូវបានបដិសេធ ដោយ គខ/កប ដោយមូលហេតុថា គ្មានភស្តុតាងបញ្ជាក់គ្រប់គ្រាន់។ មានពាក្យបណ្តឹងមួយចំនួនទៀតត្រូវបាន បដិសេធដោយសារបញ្ហាបច្ចេកទេស ដោយដើមបណ្តឹងមិនបានទទួលលិខិតផ្ទេរសិទ្ធិពីសាមីខ្លួន ដែលមានការ

[១៦៨] ដ.ឯ.ម ព្រឹត្តិបត្រ ខុមហ្វ្រែល អ្នកឃ្លាំមើល លេខ៣៤ ឆ្នាំទី៩ ផ្សាយចេញថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៨ ទំព័រ ៩

[១៦៩] ដ.ឯ.ម ទំព័រ ១០

ពាក់ព័ន្ធជាមួយហេតុការណ៍ជាក់ស្តែង។

គ.ជ.ប. បានទទួលបណ្តឹង២៤ករណី ដែលមាន២២ករណីមកពីគណបក្សសមរង្ស៊ី ១ករណីមកពីគណបក្សនរោត្តមរណឫទ្ធិ និង១ករណីមកពីគណបក្សសិទ្ធិមនុស្ស។

**ភាពមិនប្រក្រតីចំពោះសន្លឹកឆ្នោតនៅថ្ងៃបោះឆ្នោតៈ**

ជាទូទៅនៅពេលបោះឆ្នោតជាតិម្តងៗឃើញថា នៅលើប្រព័ន្ធផ្សព្វផ្សាយជាច្រើនទាំងរដ្ឋ និងឯកជនមានភាពលំអៀងខ្លាំងទៅរកគណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជាក្នុងខណៈដែលគណបក្សដទៃទៀតមានលទ្ធភាពតិចតួចបំផុតក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទាំងនេះ។ ដោយឡែកជាទម្លាប់នៅពេលជិតដល់ការបោះឆ្នោតម្តងៗ តែងឃើញមានការប្រឹងប្រែងទាក់ទាញសមាជិកថ្មី ផ្តាច់ខ្លួនចេញពីគណបក្សនយោបាយផ្សេងទៀតតាមរូបភាពសន្យាផ្តល់លាភសក្ការៈ ឬមុខតំណែងផ្សេងៗ ឬបង្ខំឲ្យស្បថ។ ដូចជា ករណីកើតមាននៅឃុំស្រះរាំង ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ គឺសមាជិកគណបក្សកាន់អំណាច បានផ្តល់ប្រាក់កាសដល់សកម្មជនឃុំដែលមួយចំនួនជាសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សសមរង្ស៊ី និងគណបក្សនរោត្តមរណឫទ្ធិ ដើម្បីឲ្យឈប់ឈរធ្វើសកម្មភាពក្នុងឃុំ និងសន្យាឲ្យប្រាក់ដល់ប្រជាពលរដ្ឋនៅទីនោះនៅពេលបោះឆ្នោតរួចដោយបង្ហាញទឹកខ្មៅម្រាមដៃ[១៧០]។ នៅកំឡុងពេលបោះឆ្នោតមានការចោទប្រកាន់អំពីការបង្ខិតបង្ខំបុគ្គលិកឲ្យចូលជាសមាជិក និងសន្យាបោះឆ្នោតឲ្យគណបក្សប្រជាជនកម្ពុជា ពីសំណាក់ថៅកែកាស៊ីណូចំនួនពីរនៅឃុំប៉ោយប៉ែត ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ជាថ្នូរនឹងការផ្តល់ទីកន្លែងស្នាក់នៅ និងទីកន្លែងធ្វើការ។ ការទិញសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជាតិអាណត្តិទី៤កន្លងទៅ ការទិញសន្លឹកឆ្នោត គឺជាបញ្ហាមួយដ៏ធ្ងន់ធ្ងរបំផុតក្នុងចំណោមបញ្ហាធ្ងន់ធ្ងរដែលបានរកឃើញ និងត្រូវបានធ្វើការវិភាគដោយគណៈកម្មាធិការសម្រាប់ការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ នៅក្នុងរបាយការណ៍ស្ទង់មតិស្តីពីបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលត្រូវគេរក្សាទុកបន្ថែមទៀត និងការព្រួយបារម្ភរបស់អ្នកបោះឆ្នោតអំពីប្រតិកម្មមិនល្អ ចំពោះការមិនបោះឆ្នោតឲ្យគណបក្សជាក់លាក់ណាមួយ។ ទាក់ទងនឹងការទិញសន្លឹកឆ្នោត លោក ទេព នីថា អគ្គលេខាធិការគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត បានលើកឡើងថាការទិញសន្លឹកឆ្នោត ការផ្តល់ប្រាក់ដល់នរណាម្នាក់ឲ្យបោះឆ្នោតឲ្យ គឺខុសច្បាប់ប៉ុន្តែការសន្យាផ្តល់ប្រាក់ដល់នរណាម្នាក់ ដើម្បីឲ្យពួកគាត់បោះឆ្នោតឲ្យ គឺមិនខុសច្បាប់ទេ[១៧១]។ លោក គល់ បញ្ញា នាយកប្រតិបត្តិរបស់អង្គការខុមហ្វ្រែល បានលើកឡើងថា បញ្ហាចម្បងដទៃទៀតដែលពាក់ព័ន្ធនឹងការបោះឆ្នោត បញ្ហានៃប្រជាជន២,១០០,០០០នាក់ មិនបានបោះឆ្នោត កាលពីឆ្នាំ២០០៨ ដោយមនុស្សប្រហែល៤៤០,០០០នាក់មិនអាចបោះឆ្នោតបាន បើទោះបីជាពួកគេធ្លាប់បោះឆ្នោតបានពីមុនក៏ដោយ[១៧២]។ នៅក្នុងសេចក្តីថ្លែងការណ៍រួមកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ របស់សម្ព័ន្ធអង្គការសង្គមស៊ីវិល បានវាយតម្លៃអំពីដំណើរការរៀបចំ

[១៧០] ព្រឹត្តិបត្រ ខុមហ្វ្រែល អ្នកឃ្លាំមើល លេខ៣៣ ឆ្នាំទី៩ ខែធ្នូ ឆ្នាំ២០០៨ ទំព័រ ៤
[១៧១] កាសែត ឌឹ ភ្នំពេញ ប៉ុស្តិ៍ ... 

ចាត់ចែងការបោះឆ្នោតថា នៅមានភាពមិន ប្រក្រតីជាច្រើន ជាពិសេសឧបសគ្គដែលនាំឲ្យបាត់សិទ្ធិបោះឆ្នោតច្រើនជាងការបោះឆ្នោតមុនៗ។ ការបាត់សិទ្ធិអ្នកបោះឆ្នោត នេះត្រូវបានកើតឡើងដោយសារបច្ចេកទេសនីតិវិធី និងការសង្ស័យថា ជាចេតនានយោបាយផងដែរ បណ្តាលមកពីភាពខ្វះការទទួលខុសត្រូវរបស់គ.ជ.ប. និងអាជ្ញាធរមូលដ្ឋានឃុំ/សង្កាត់ក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតការសំអាតបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ការប្តូរការិយាល័យបោះឆ្នោត និងកង្វះខាតជំនួយរកឈ្មោះពីសំណាក់មន្ត្រីការិយាល័យបោះឆ្នោត។ ការបាត់ឈ្មោះអ្នកបោះឆ្នោតនេះ វាធ្វើឲ្យប៉ះពាល់ដល់ការបោះឆ្នោត ហើយឈានទៅដល់រំលោភសិទ្ធិនយោបាយអធិបតេយ្យប្រជាពលរដ្ឋ ដែលត្រូវបានរដ្ឋធម្មនុញ្ញធានាផងដែរ។ លោក ធន សារាយ ប្រធានគណៈកម្មាធិការ នាយកខុមហ្វ្រែល និងជាប្រធានសមាគមអាដហុកបានលើកឡើងថា គេគួររៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មី និងសម្រួលនីតិវិធីឲ្យអ្នកបោះឆ្នោតមានឯកសារអាចបោះឆ្នោត និងព័ត៌មានស្តីពីការិយាល័យបោះឆ្នោតអចិន្ត្រៃយ៍ ដើម្បីធានាការគោរពសិទ្ធិបោះឆ្នោតឲ្យបានពេញលេញ។ លោកបានបន្តទៀតថា បរិយាកាស និងដំណើរការបោះឆ្នោតមិនទាន់ធានាបាននូវភាពអព្យាក្រិត្យ និងយុត្តិធម៌បាននៅឡើយទេ ដោយសារតែមានការប្រើប្រាស់ ធនធានរដ្ឋ និងការចូលរួមពីសំណាក់មន្ត្រីរាជការអាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដ៏ច្រើនលើសលប់ជាងការបោះឆ្នោតមុនៗ ដើម្បីគាំទ្រគណបក្សនយោបាយកាន់អំណាច និងខ្វះយន្តការដ៏មានប្រសិទ្ធិភាពក្នុងការដោះស្រាយទំនាស់ នៃភាពមិនប្រក្រតី និងបណ្តឹងបោះឆ្នោតនានា។

ប្រមុខរាជរដ្ឋាភិបាល ដែលបានថ្លែងនាពិធីបើកមហាសន្និបាតលើកទី៦នៃសន្និសីទអន្តរជាតិនៃគណបក្សនយោបាយនៅអាស៊ី នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ក្នុងសុន្ទរកថានោះបានលើកឡើងថា៖លទ្ធិប្រជាធិបតេយ្យបានចាក់ ឫសយ៉ាងជ្រៅចូលក្នុងកោសិកាសង្គមដែលក្នុងនោះ ប្រជាជនទូទៅមានសិទ្ធិជ្រើសរើសមេដឹកនាំរបស់ខ្លួនតាមរយៈការបោះឆ្នោតត្រូវបានធ្វើឡើងជាទៀងទាត់ នៅក្នុងបរិយាកាសចំហសេរី និងយុត្តិធម៌។ សេរីភាពក្នុងការធ្វើដំណើរ និងក្នុងការសម្តែងមតិត្រូវបានគោរពយ៉ាងពេញលេញ ដែលត្រូវបានឆ្លុះបញ្ចាំងឡើង ជាពិសេសតាមរយៈអត្ថិភាពដ៏ច្រើនកុះករ និងប្រតិបត្តិការដោយសេរីនៃបណ្តាញព័ត៌មានជាតិ និងអន្តរជាតិ ក៏ដូចជាមានអង្គការក្រៅរដ្ឋាភិបាល នៃសង្គមស៊ីវិលចំនួនរាប់ពាន់នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន[១៧៣]។ លើសពីនេះក្នុងឱកាសចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នារសៀលថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ នៅទីស្តីការក្រសួងមហាផ្ទៃ ឯកឧត្តម RON HOFFMAN ឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសកាណាដា បានគូសបញ្ជាក់ថា រដ្ឋាភិបាលកាណាដា បានវាយតម្លៃខ្ពស់ចំពោះការវិវត្តន៍រីកចម្រើនរបស់ប្រទេសកម្ពុជា និងសូមគាំទ្ររាជរដ្ឋាភិបាល ក្នុងកិច្ចដំណើរការពង្រឹងលទ្ធិប្រជា

[១៧៣] សុន្ទរកថាសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន ថ្លែងក្នុងពិធីបើកសន្និបាទលើកទី៦ នៃសន្និសីទអន្តរជាតិនៃគណបក្សនយោបាយនៅអាស៊ី ភ្នំពេញ, ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១០ ទំព័រ ២

ធិបតេយ្យនៅកម្ពុជា ដោយចាត់ទុកថា ប្រទេសកម្ពុជាជាមិត្តភក្តិមួយដែលមានកិច្ចសហប្រតិបត្តិការដ៏ល្អនៅក្នុងតំបន់អាស៊ីនេះ[១៧៤]។

សរុបសេចក្តីមក តាមរយៈព្រឹត្តិការណ៍មួយចំនួនដែលបានកើតឡើងជាក់ស្តែង ដូចបានលើកឡើងខាងលើនេះ គឺពុំទាន់ស្របទាំងស្រុងដូចគ្នាទៅនឹងការអះអាងរបស់ប្រមុខរាជរដ្ឋាភិបាល ដែលថាប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិសេរីភាពពេញបរិបូរណ៍ តាមគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជានោះទេ។ ប្រជាពលរដ្ឋពិតជាមានសិទ្ធិតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ប្រាកដមែន ប៉ុន្តែប្រជាពលរដ្ឋម្ចាស់អំណាចគ្មានអំណាចប្រើប្រាស់សិទ្ធិសេរីភាព ដែលជាតម្លៃដាច់ខាតរបស់ខ្លួនទាំងនេះបានឡើយ ជាពិសេសសិទ្ធិសេរីភាពខាងនយោបាយ។ ការទិញលក់សិទ្ធិបោះឆ្នោត និងទិញ/លក់សន្លឹកឆ្នោតរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោតធ្វើឲ្យឆន្ទៈនៅក្នុងសន្លឹកឆ្នោតមិនឆ្លុះបញ្ចាំងទៅនឹងឆន្ទៈដើមរបស់ម្ចាស់ឆ្នោតឡើយ។ ស្ថានភាពសិទ្ធិក្នុងបរិបទប្រជាធិប-តេយ្យ តាមមធ្យោបាយនីតិរដ្ឋនៅកម្ពុជា គឺកំពុងស្ថិតនៅដំណាក់កាលអន្តរកាលនៅឡើយ ហើយក៏ត្រូវបាននិងកំពុងតែកែលំអដោយឈរលើតថភាពនៃកម្រិតសេដ្ឋកិច្ច កម្រិតយល់ដឹង ទាំងផ្នែកសីលធម៌ ទាំងបច្ចេកវិទ្យា និងទាំងខាងពលរដ្ឋវិជ្ជារបស់ប្រជាពលរដ្ឋ ដោយផ្សាភ្ជាប់ទៅនឹងនិន្នាការល្បឿននៃការវិវត្តន៍ប្រជាធិបតេយ្យសកលលោកផងដែរ។

ដូច្នេះដើម្បីការកែលំអនីតិវិធីបោះឆ្នោត គឺត្រូវកែសម្រួលសមាសភាពដឹកនាំគណៈកម្មការជាតិរៀបចំការបោះឆ្នោតជាមុនសិន ពោលគឺតម្រូវឲ្យស្ថាប័នជាតិសំខាន់ ជាពិសេសគឺរដ្ឋសភាជាតិត្រូវពិភាក្សាគ្នា បង្កើតស្ថាប័ននេះឲ្យក្លាយជាស្ថាប័នជាតិដ៏មានអំណាចឯករាជ្យ អព្យាក្រិត្យ និងចាំបាច់ត្រូវដឹកនាំដោយបុគ្គលឯករាជ្យនៅក្រោមឆ្ឋដ្ឋានគណបក្សនយោបាយ ទើបជានាបាននូវការសម្រេចចិត្តនយោបាយក្នុងបរិយាកាសប្រជាធិប-តេយ្យរបស់ប្រជាពលរដ្ឋម្ចាស់អំណាច។ តាមរយៈនេះប្រជាពលរដ្ឋម្ចាស់អំណាចនឹងចម្រាញ់រកឃើញនូវ បេក្ខជនមានសមត្ថភាពខ្ពស់បំផុត មានបញ្ញាញាណភ្លឺថ្លា មានស្មារតីស្នេហាជាតិ មានគុណធម៌ថ្លៃថ្លា ជ្រើសរើសបុគ្គលប្រភេទនេះ មកដឹកនាំនិងគ្រប់គ្រងប្រទេស។ ដែលជាលទ្ធផល ធ្វើឲ្យសង្គមជាតិមានសុភមង្គល ប្រទេសមានការអភិវឌ្ឍន៍ យុត្តិធម៌សង្គម...ពិតប្រាកដ។

---

[១៧៤] http://www,interior.gov.kh

# ជំពូកទី៤
# វិភាគពីការប្រើសិទ្ធិសេរីភាពពលរដ្ឋតាមរយៈស្ថាប័នដឹកនាំ

# ជំពូកទី៤
# វិភាគពីការប្រើសិទ្ធិសេរីភាពពលរដ្ឋតាមរយៈស្ថាប័នដឹកនាំ

## ៤.១ ផលវិបាកនៃការអនុវត្តន៍សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ

### ៤.១.១ ការលំអៀងរបស់អាជ្ញាធរ

នៅក្នុងសង្គមប្រកាន់យករបបគ្រប់គ្រងដឹកនាំ តាមទម្រង់ប្រជាធិបតេយ្យសេរី កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គឺជាកងកម្លាំងសាធារណៈនៅក្នុងសង្គមរដ្ឋ ដែលជាកម្លាំងដ៏សំខាន់បំផុត ដើម្បីធានាឲ្យការប្រព្រឹត្តទៅនៃចរន្តសង្គមស្ថិតនៅក្នុងដំហររស់រវើក សមភាព អព្យាក្រិត្យ ដាច់ចេញពីសម្ពាធអំណាចនយោបាយ ក្នុងគោលបំណងធានាអោយាមានយុត្តិធម៌ និងសន្តិសុខជាតិ សុវត្ថិភាពសាធារណៈ ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋប្រកបដោយភាពកក់ក្តៅ ដោយមិនប្រកាន់បក្សពួករើសអើងឡើយ និងជាពិសេស គឺជាកម្លាំងការពារអធិបតេយ្យជាតិមាតុភូមិទាំងមូល។ រដ្ឋបាលសាធារណៈគ្រប់ជាន់ថ្នាក់ និងកម្លាំងប្រដាប់អាវុធដូចជាអាជ្ញាធរថ្នាក់លើ និងមូលដ្ឋាន នគរបាល ទាហាន កងរាជអាវុធហត្ថ ជាដើមត្រូវដឹកនាំបំពេញការងារដោយអព្យាក្រិត្យ។ ជាការពិតបុគ្គលដែលបម្រើក្នុងស្ថាប័នរដ្ឋបាល ឬកម្លាំងប្រដាប់អាវុធទាំងនោះក៏ជាប្រជាពលរដ្ឋដែរ ហើយក៏មានសិទ្ធិក្នុងការចូលជាសមាជិក ឬគាំទ្រគណបក្សនយោបាយដែលខ្លួនពេញចិត្ត ដោយអាចសម្តែងមតិតាមរយៈការបោះឆ្នោតជ្រើសរើសគណបក្សណាមួយ បុគ្គលណាមួយបាន ក៏ប៉ុន្តែបុគ្គលជាអ្នកកាន់ការងាររដ្ឋបាល ក៏ដូចជាកម្លាំងប្រដាប់អាវុធដាច់ខាត់មិនត្រូវយកតួនាទី មុខតំណែងឋានៈរបស់ខ្លួនទៅបម្រើ និងធ្វើជាសមាជិកគណបក្សណាមួយនោះទេ គឺត្រូវបម្រើប្រជាពលរដ្ឋទូទៅ ដោយមិនគិតពីនិន្នាការនយោបាយឡើយ។ ជាពិសេសទៅទៀតគេមិនត្រូវយកទ្រព្យសម្បត្តិ សម្ភារៈ ថវិការដ្ឋទៅបម្រើឲ្យគណបក្សដែលគេគាំទ្រនោះទេ។ ការយកមុខតំណែងទៅប្រើជាអំណាចដើម្បីឲ្យគេផ្តល់សម្បត្តិ គឺជាការរំលោភច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ រដ្ឋាបាល និងកម្លាំងប្រដាប់អាវុធជារបស់រដ្ឋាភិបាល រីឯរដ្ឋាភិបាល គឺជារបស់ប្រជាពលរដ្ឋ ដូច្នេះ រដ្ឋាបាល និងកម្លាំងប្រដាប់អាវុធ គឺជារបស់ប្រជាពលរដ្ឋ ហើយត្រូវធ្វើការបម្រើប្រជាពលរដ្ឋ ដោយឥតរើសមុខ អព្យាក្រិត្យពិតប្រាកដ ឥតប្រកាន់និន្នាការនយោបាយ និងមិនត្រូវបែងចែកបក្សពួកឡើយ។ បច្ចុប្បន្នទិដ្ឋភាពរួមនៅកម្ពុជា កម្លាំងសមត្ថកិច្ចរបស់រដ្ឋ មានសមាសភាពជាមន្ត្រីដែលតែងតាំងពីរបបរដ្ឋកម្ពុជា ដែលជារបបកុំមុយនីស្តដឹកនាំដោយគណបក្សប្រជាជនកម្ពុជាមកម្លេះ។ ត្រង់នេះវាបញ្ជាក់យ៉ាងច្បាស់ថា កម្លាំងសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ មិនអាចគេចផុតពីការទទួលរងនូវសម្ពាធនយោបាយដោយផ្ទាល់ និងចាក់ឫសជាមួយគណបក្សកាន់អំណាច និងបម្រើឲ្យអ្នកកាន់អំណាចឡើយ ដែលភាគច្រើននៃសមាសភាពទាំងនេះគឺ ជាសមាជិកគណបក្សកាន់អំណាច និងក្រុមហ៊ុនឯកជនដែលស្និតនឹងអ្នកកាន់អំណាច។ ករណីនេះអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានលើកឡើងថា កម្លាំងប្រដាប់អាវុធសាធារណៈរបស់រដ្ឋបាន ចូលរួម

ក្នុងគណបក្សកាន់អំណាច[១៧៥]។ មិនតែប៉ុណ្ណោះ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមបានលើកឡើងដែរថា អាជ្ញាធរមូលដ្ឋានមានការរើសអើង និងប្រកាន់បក្សពួកចំពោះប្រជាពលរដ្ឋក្នុងដំណើរការបោះឆ្នោត[១៧៦]។ ករណីជាច្រើនត្រូវបានសាធារណៈជន មើលឃើញថា នៅពេលមានបាតុកម្មអហិង្សាកើតឡើងកងកម្លាំងប្រដាប់អាវុធ សាធារណៈរបស់រដ្ឋ តែងតែការពារក្រុមហ៊ុនឯកជន និងការពារក្រុមមនុស្សរបស់គណបក្សកាន់អំណាច ហើយបែរមកបង្ក្រាបបាតុករអហិង្សាទៅវិញ ធ្វើឲ្យសមាជិកបាតុករមួយចំនួនទទួលរងគ្រោះថ្នាក់។ ចំពោះការបង្ក្រាបរបស់អាជ្ញាធរប្រដាប់អាវុធសាធារណៈទៅលើបាតុកម្មរបស់សមាគមនិស្សិត បញ្ញវន្តខ្មែរ ដែលតែងតាំង ប្រឆាំង នឹងថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលប្រទេសវៀតណាមចូលឈ្លានពានកម្ពុជា។ ការធ្វើបាតុកម្ម នេះត្រូវបានអាជ្ញាធររារាំង និងបង្ក្រាបដោយហិង្សា មកលើបាតុករជារៀងរាល់ឆ្នាំ នៅពេលមានបាតុកម្ម ប្រឆាំងប្រទេសវៀតណាមកើតឡើង ដោយគ្រាន់តែយកសំអាងថា ជាបាតុកម្មខុសច្បាប់ប៉ុណ្ណោះ។ ចំពោះការ បង្ក្រាបរបស់អាជ្ញាធរប្រដាប់អាវុធទៅលើបាតុកម្មរបស់កម្មករ-កម្មការនី នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ មាន កម្មករប្រមាណជា ២,០០០នាក់ បានធ្វើកូដកម្មអហិង្សាមួយ ដើម្បីទាមទារឲ្យថៅកែរោងចក្រ Forunne Garment & Woolen Knittong Factory Ltd គោរពនូវសេចក្តីបង្គាប់ការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងកិច្ចព្រម ព្រៀងលក្ខខណ្ឌការងារ។ ករណីនេះត្រូវបានកម្លាំងប៉ូលីសខេត្តកណ្តាលចំនួនជា១០០នាក់ ប្រដាប់ដោយ ដំបងឆក ខែល ឧស្ម័នបង្ហូរទឹកភ្នែក និងអាវុធអាកា។ ក្រុមប៉ូលីសបានបាញ់គំរាមទៅលើហ្វូងកម្មករ បណ្តាលឲ្យ តំណាងកម្មករ៣នាក់រងរបួស និងចាប់ខ្លួនកម្មករចំនួន៤នាក់ និងស្វែងរកចាប់ខ្លួនកម្មករជាច្រើន នាក់ទៀតផង។ ក្រោយពីបានចាប់ខ្លួនកម្មករទាំង៤នាក់បញ្ជូនមកតុលាការខេត្ត ហើយបង្ខំឲ្យតំណាងកម្មករទាំងនេះធ្វើកិច្ចសន្យាបញ្ឈប់ការធ្វើកូដកម្ម ទើបតុលាការខេត្តដោះលែង[១៧៧]។ មិនត្រឹមតែកងកម្លាំងប្រដាប់អាវុធទេ ដែលហ៊ុំព័ទ្ធដោយឥទ្ធិពលនយោបាយនៃគណបក្សកាន់អំណាច សូម្បីតែមន្ត្រីរាជការស៊ីវិលភាគច្រើន ក៏ត្រូវបានរងសម្ពាធអំណាចនយោបាយឲ្យចូលរួមជាមួយគណបក្សដឹកនាំនីតិប្រតិបត្តិដែរ ទើបអាចរក្សាការងាររបស់ខ្លួននឹងនរ។ មន្ត្រីរាជការចាប់ពីថ្នាក់អគ្គនាយកដ្ឋាន អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាន នាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ រហូតដល់មន្ត្រីសាមញ្ញ ត្រូវបានគណបក្សកាន់អំណាច ដាក់បញ្ចូលជាក្រុមការងារចុះជួយគណបក្សតាមខេត្ត/ក្រុងទាំងអស់។ ទង្វើបែបនេះផ្ទុយពីគោលការណ៍ច្បាប់ ដែលបានចែងនៅក្នុងមាត្រា៣៧ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដែលចែងថា មន្ត្រីរាជការត្រូវ មានអព្យាក្រិត្យភាពក្នុងសកម្មភាពការងារ និងហាមឃាត់ជាដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួននិង សម្ភារៈរបស់រដ្ឋដើម្បីបម្រើសកម្មភាពនយោបាយដូចខាងក្រោមនេះ:

១-ធ្វើការដើម្បីផលប្រយោជន៍រួមដល់បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ។

---

[១៧៥] ព្រឹត្តិបត្រខុមប្រែ្វល លេខ៣៥ ឆ្នាំទី១០ ចេញថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ទំព័រ ៤
[១៧៦] ព្រឹត្តិបត្រស្រាវជ្រាវៈ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម លេខ១៤៤ ខែកក្កដា-សីហា ឆ្នាំ២០០៨ ទំព័រ ៣៣
[១៧៧] សមាគមអាដហុក ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៧ លេខ៧ ឆ្នាំ៧ ខែមករា ឆ្នាំ២០០៨ ទំព័រ ២១-២២

២-ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ។ មន្ត្រីរាជការ គឺជាអ្នកបម្រើរដ្ឋបម្រើផលប្រយោជន៍សាធារណៈ ប្រយោជន៍រួម មិនមែនប្រយោជន៍បុគ្គល ឬក្រុមណាមួយឡើយ។ ដូច្នេះ ក្នុងការបំពេញការងារគឺជាការបម្រើអតិថិជនដែលជាប្រជាពលរដ្ឋ ជាអ្នកទទួលសេវារដ្ឋ អ្នករាជការទាំងអស់ ត្រូវប្រកាន់ឲ្យខ្ជាប់នូវភាពអព្យាក្រិត្យ មិនលំអៀង មិនអគតិ។ ភាពមិនអព្យាក្រិត្យអាចនាំមកនូវគ្រោះថ្នាក់ធ្ងន់ធ្ងរ ដល់អាយុជីវិត និងអនាគតរបស់អ្នកទទួលសេវារដ្ឋ។

### ៤.១.២ ចំណេះដឹងរបស់ម្ចាស់អំណាចនៅមានកម្រិត

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺជាថ្ងៃប្រវត្តិសាស្ត្រនៃការបញ្ចប់ជម្លោះរ៉ាំរ៉ៃនយោបាយផ្ទៃក្នុងរបស់កម្ពុជា។ ផ្តើមចេញពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីដ៏ថ្លៃថ្លានេះ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវបំណងដ៏ត្រឹមត្រូវរបស់បណ្តាឥស្សរៈជននយោបាយ និងសេចក្តីសម្រេចចិត្តដ៏មុតមាំរបស់ប្រជាជនកម្ពុជាខ្លួនឯងផ្ទាល់ ក្នុងការជ្រើសរើសយកលទ្ធិប្រជាធិបតេយ្យមកធ្វើជាគោលដៅអភិវឌ្ឍប្រទេសរបស់ខ្លួន ហើយក៏មិនមែនជារឿងដែលគួរឲ្យងឿងឆ្ងល់ដែរ ចំពោះប្រការដែលសហគមន៍អន្តរជាតិទាំងមូលបានសម្តែងនូវការអបអរយ៉ាងកក់ក្តៅ និងគាំទ្រយ៉ាងពេញទំហឹងទៅលើការជ្រើសរើស និងសេចក្តីសម្រេចចិត្តប្រកបទៅដោយគតិធម៌។ ឈរលើមូលដ្ឋាននៃបទពិសោធន៍របស់បណ្តាប្រទេសជឿនលឿននានាលើសកលលោក គេមិនពិបាកនឹងធ្វើការបកស្រាយ និងបង្ហាញឲ្យឃើញពីចំណុចវិជ្ជមាន និងឧត្តមភាពទាំងឡាយ ដែលអាចទទួលយកបានពីការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនោះទេ ក៏ប៉ុន្តែប្រការមួយដែលប្រកបទៅដោយគ្រោះថ្នាក់ជាទីបំផុតនោះ គឺប្រសិនជាគេនាំគ្នាយល់ថា ការអនុវត្តន៍ប្រជាធិបតេយ្យបាននៅគ្រប់មជ្ឈដ្ឋាន និងគ្រប់ពេលទាំងអស់ សុទ្ធតែបាននាំមកនូវលទ្ធផលវិជ្ជមានដោយគ្មានជួបការលំបាក ព្រមទាំងគ្មានឧបសគ្គសោះនោះទេ។ គំនិតដែលថាប្រជាធិបតេយ្យ អាចរីកចម្រើនលូតលាស់ ហើយផ្តល់ផ្លែផ្កាដោយអាស្រ័យតែនឹងគោលបំណងអត្តនោមតិរបស់សមាជិកទាំងឡាយនៃសង្គម ឬរបស់ឥស្សរៈជនណាម្នាក់ក្នុងការជ្រើសរើសយកលទ្ធិនេះមកធ្វើជាមាគ៌ា ដើម្បីឈានទៅកាន់វឌ្ឍនភាពនោះ គឺជាការស្រមើស្រម៉ៃមួយដ៏ជ្រាលជ្រៅ។ ផ្ទុយទៅវិញទេ ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យទាំងងងិតងងុល អាចនាំមកនូវលទ្ធផលអវិជ្ជមានប្រកបដោយគ្រោះថ្នាក់ នាំឲ្យសង្គមធ្លាក់ក្នុងអស្ថេរភាព និងធ្វើឲ្យលទ្ធិប្រជាធិបតេយ្យដែលលូតលាស់ថ្មីនេះស្លាប់បាត់បង់ជីវិតទៅវិញ។ ដូច្នេះកាលណានិយាយអំពីប្រជាធិបតេយ្យ គឺសំដៅដល់ការផ្តល់សក្តានុពលស្មើៗគ្នាចំពោះប្រជាពលរដ្ឋទូទៅឲ្យមានលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិសេរីភាព និងអំណាចប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋខ្លួនឯង យល់ដឹងពីរបៀបរបបនៃការប្រើប្រាស់សិទ្ធិសេរីភាព និងអំណាចផ្អែកលើកម្រិតយល់ដឹងដោយប្រជាពលរដ្ឋខ្លួនឯង ដែលជាសរសរស្តម្ភដ៏រឹងមាំសម្រាប់ទ្រទ្រង់លទ្ធិប្រជាធិបតេយ្យ ព្រោះប្រជាពលរដ្ឋក្នុងរបបនេះ គឺជាអ្នកនាំមុខក្នុងការកំណត់ជោគវាសនានៃប្រទេសជាតិរបស់ខ្លួន។ ប្រទេសជាតិមួយរុងរឿងចំរើនថ្កុំថ្កាន ឬអន់ថយ សង្គ្រាម ឬសន្តិភាព គឺទាក់ទងផ្ទាល់នឹងចំណេះដឹងរបស់ប្រជាពលរដ្ឋដែលអាចពិចារណាស្វែងយល់ ប្រៀបធៀបចែកញែកសាមគ្គីសម្រប

សម្រួលយោគយល់ អធ្យាស្រ័យក្លាហាន ពុះពារ ព្យាយាម និងទទួលខុសត្រូវក្នុងបញ្ហាសង្គមជាតិ ដែលជាកម្មសិទ្ធិរបស់ខ្លួន។ កាលណាប្រជាពលរដ្ឋម្ចាស់ឆ្នោត ម្ចាស់អំណាចមានចំណេះដឹងតិចតួច ពុំអាចមើលឃើញពីតម្លៃពិតប្រាកដ និងសារៈប្រយោជន៍នៃអំណាច និងពុំអាចប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួនតាមគោលការណ៍ប្រជាធិបតេយ្យឡើយ។ តថភាពជាក់ស្តែងប្រជាពលរដ្ឋខ្មែរ ដែលជាម្ចាស់អំណាច ពុំទាន់បានយល់ច្បាស់លាស់អំពីសិទ្ធិសេរីភាព និងជាពិសេសពុំទាន់ស្គាល់ច្បាស់អំពីតម្លៃអំណាចរបស់ខ្លួននៅឡើយ*។ បាតុភូតទាំងនេះកើតឡើង ដោយសារប្រជាជនកម្ពុជាទូទាំងប្រទេសឆ្លងកាត់សង្គ្រាមស៊ីវិលអស់រយៈពេលជិត៣០ឆ្នាំ និងស្របពេលដែលរដ្ឋធម្មនុញ្ញខ្មែរទទួលរបបប្រជាធិបតេយ្យក្នុងការដឹកនាំប្រទេស តម្រូវឲ្យប្រជាពលរដ្ឋខ្មែរ ជាអ្នកសម្រេចជោគវាសនាប្រទេសជាតិ។ ស្របពេលដែលប្រជាពលរដ្ឋមានចំណេះដឹងទាបផងនោះ មានអ្នកនយោបាយខ្លះបានឃោសនាថា រដ្ឋាភិបាលជាម៉ែ ជាឪ ឯប្រជាពលរដ្ឋជាកូនចៅទៅវិញ នេះជាគំនិតកេងចំណេញ ពីលើការមិនអាចយល់បានរបស់ប្រជាពលរដ្ឋខ្មែរ[១៧៨]។ ដែលតាមការពិតសម្រាប់អ្នកនយោបាយដែលមានគតិបណ្ឌិត ស្រឡាញ់ជាតិ ស្រឡាញ់ប្រជាពលរដ្ឋ ដោយសុទ្ធចិត្តចេញពីបេះដូង ត្រូវបង្ហាញប្រាប់ការពិតដល់ប្រជាពលរដ្ឋខ្មែរថា នៅក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋជាម្ចាស់អំណាច ប្រជាពលរដ្ឋជាអ្នកបង្កើតរដ្ឋាភិបាល ប្រជាពលរដ្ឋមានសិទ្ធិបណ្តេញអ្នកនយោបាយណា ដែលមិនអាចបម្រើប្រជាពលរដ្ឋដោយសេចក្តីស្មោះត្រង់ គ្មានសមត្ថភាពក្នុងការដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋទូទៅនិងប្រទេសជាតិបាន។ ប្រជាពលរដ្ឋជាម៉ែជាឪរបស់រដ្ឋាភិបាល ឯរដ្ឋាភិបាលជាកូនចៅបម្រើប្រជាពលរដ្ឋ។

សមត្ថភាពយល់ដឹងអំពីពលរដ្ឋវិជ្ជារបស់ប្រជាពលរដ្ឋខ្មែរ គឺជាកត្តាសំខាន់ចាំបាច់សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋខ្មែរ ក្នុងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម ប្រកបដោយប្រសិទ្ធភាព និងគុណភាព។ លុះត្រាណាប្រជាពលរដ្ឋខ្មែរមានការយល់ដឹងជាមូលដ្ឋានអំពីពលរដ្ឋវិជ្ជា លុះត្រានោះប្រជាពលរដ្ឋខ្មែរប្រាកដជានឹងទទួលស្គាល់ថា របបគ្រប់គ្រងរដ្ឋប្រជាធិបតេយ្យសេរី អាចដំណើរការទៅបានសម្រាប់ជាប្រយោជន៍ទាំងអស់គ្នា (រាប់បញ្ចូលទាំងការធ្វើឲ្យប្រសើរឡើងនៃជីវភាពរស់នៅ យុត្តិធម៌សង្គម និងយុត្តិធម៌ផ្លូវច្បាប់ ការគោរពសិទ្ធិមនុស្សនិងគោរពសេរីភាពរបស់បុគ្គល។ល។)គឺអាស្រ័យទៅនឹងការចូលរួមរបស់ប្រជាពលរដ្ឋម្នាក់ៗប្រកបដោយការយល់ដឹង និងការទទួលខុសត្រូវតាមរូបមន្តៈ **ដឹង-យល់-ពិចារណា-សម្រេច**។

បច្ចុប្បន្ននេះប្រជាពលរដ្ឋខ្មែរចាំបាច់ណាស់ គឺត្រូវពង្រីកការយល់ដឹងរបស់ខ្លួនលើចំណេះដឹងពលរដ្ឋវិជ្ជា ព្រោះវាញ៉ាំងឲ្យប្រជាពលរដ្ឋខ្មែរម្នាក់ៗស្គាល់អំពីតម្លៃពិតរបស់ខ្លួន ជាតួអង្គចលករដ៏សំខាន់របស់សហគមន៍ ដែលខ្លួនកំពុងរស់នៅក៏ដូចជាសង្គមជាតិទាំងមូល។ ទន្ទឹមនឹងនេះ ការយល់ដឹងអំពីពលរដ្ឋវិជ្ជានឹងធ្វើឲ្យប្រជាពលរដ្ឋខ្មែរជ្រះស្រឡះពីផ្នត់គំនិតចាស់គំរឹលដែលជាឧបសគ្គរាំងស្ទះដល់ដំណើរការការកសាងប្រជាធិបតេយ្យ។

* សូមពិនិត្យមើលព្រឹត្តិការណ៍នៅពេលបោះឆ្នោតម្តងៗ ម្ចាស់ឆ្នោតបានលក់សិទ្ធិបោះឆ្នោតរបស់ជាថ្នូរនឹងរបស់របរបន្តិចបន្តួច។

[១៧៨] ព្រឹត្តិបត្រស្រាវជ្រាវ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ឆ្នាំ២០០៤ ទំព័រ ៣

ផ្នត់គំនិតចាស់នេះ ចង់សំដៅទៅលើ **វប្បធម៌ បុគ្គលសក្ការៈ** មានន័យថា ការឲ្យតម្លៃហួសហេតុលើបុគ្គលដឹកនាំ ហួតឈានដល់បាត់បង់ភាពម្ចាស់ការ និងស្វ័យទទួលខុសត្រូវ ហើយដាក់ខ្លួនផ្តេកផ្តួលទាំងស្រុងទៅលើថ្នាក់ដឹកនាំ។ ការយល់ដឹងអំពីពលរដ្ឋវិជ្ជាធ្វើឲ្យប្រជាពលរដ្ឋយល់ច្បាស់អំពីសារៈសំខាន់នៃការចូលរួមរបស់ខ្លួន ក្នុងដំណើរការកសាងសង្គមប្រជាធិបតេយ្យ ការអភិវឌ្ឍន៍ដោយផ្អែកលើសតិសម្បជញ្ញៈជឿនលឿន និងចក្ខុវិស័យភ្លឺថ្លាច្បាស់លាស់ គឺការធ្វើឲ្យមានប្រជាធិបតេយ្យ ត្រូវធ្វើទាំងអស់គ្នា ហើយជ័យជម្នះនៃប្រជាធិបតេយ្យ គឺជាជ័យជម្នះសម្រាប់សមាជិកសង្គមទាំងអស់គ្នា ហើយប្រជាពលរដ្ឋខ្មែរនឹងមានអធិបតេយ្យភាពពិតប្រាកដក្នុងដៃដូចប្រជាពលរដ្ឋនៃបណ្តាប្រទេសប្រជាធិបតេយ្យលើសកលលោក ហើយនឹងអាចពង្រឹងភាពជាម្ចាស់អំណាចប្រកបដោយសតិសម្បជញ្ញៈស្វាហាប់ចូលរួមរៀបចំនិងការចូលរួមទទួលខុសត្រូវក្នុងដំណើរការកសាងសង្គមប្រជាធិប-តេយ្យ និងការស្ថាបនាបែបបទគ្រប់គ្រងរដ្ឋឲ្យមានលក្ខណៈនីតិរដ្ឋ ដោយបានធ្វើឲ្យប្រទេសជាតិអភិវឌ្ឍ ទាំងបញ្ញា ស្មារតី និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

ប្រជាធិបតេយ្យសេរី មិនមែនគ្រាន់តែមានន័យថា ប្រជាពលរដ្ឋជាម្ចាស់អំណាច ហើយអំណាចទាំងអស់កើតចេញពីប្រជាពលរដ្ឋតែប៉ុណ្ណឹងនោះទេ។ លើសពីនេះ និងស៊ីជម្រៅជាងនេះ អត្ថន័យស្នូលនៃប្រជាធិបតេយ្យសេរី គឺចង់សំដៅទៅលើអធិបតេយ្យពលរដ្ឋ ដែលជាអំណាចស្វ័យប្រវត្តិ ត្រូវតែកើតចេញពីការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយមានការយល់ដឹងខ្លួនឯង។ អធិបតេយ្យនេះសំដៅលើតម្លៃ សេរីភាពរបស់បុគ្គលម្នាក់ៗចំពោះភាពជាម្ចាស់រួមមានៈ ម្ចាស់នៃអំណាចគ្រប់គ្រង និងម្ចាស់នៃអំណាចលើការកំណត់ជោគវាសនាប្រទេសជាតិរបស់ខ្លួន។ ដើម្បីឲ្យឧត្តមគតិប្រជាធិបតេយ្យនេះ ក្លាយជារូបភាពអនុវត្តជាក់ស្តែងនៅក្នុងសង្គមខ្មែរ គឺអាស្រ័យដោយប្រជាពលរដ្ឋមានលទ្ធភាព និងសមត្ថភាពប្រើប្រាស់តួនាទីខ្លួនជាម្ចាស់នៃអំណាចគ្រប់គ្រង និងចាត់ចែង(សមត្ថភាពនៃការប្រើសិទ្ធិបោះឆ្នោតជ្រើសរើសអ្នកដទៃធ្វើជាតំណាងរបស់ខ្លួន ដើម្បីផ្តល់សិទ្ធិអំណាចឲ្យអ្នកតំណាងនោះបំពេញការងារឆ្លើយតបតាមឆន្ទៈរបស់ម្ចាស់ឆ្នោត និងសមត្ថភាពនៃការត្រួតពិនិត្យ ឃ្លាំមើលការងាររបស់អ្នកតំណាង ការរួបរួមដាក់សម្ពាធលើតំណាងរបស់ខ្លួន) ឈរលើសិទ្ធិស្វ័យសម្រេច ភាពម្ចាស់ការលើខ្លួនឯង និងស្មារតីទទួលខុសត្រូវខ្ពស់។

វាពិតជាមិនទាន់គ្រប់គ្រាន់នៅឡើយទេ សម្រាប់មូលដ្ឋាននៃការកសាងសង្គមប្រជាធិបតេយ្យនៅកម្ពុជា ប្រសិនបើពលរដ្ឋខ្មែរ ដែលគ្រាន់តែដឹងអំពីកាតព្វកិច្ចកបោះឆ្នោត ហើយប្រើប្រាស់លទ្ធភាពត្រឹមមួយថ្ងៃ ដើម្បីធ្វើការសម្រេចចិត្តជ្រើសរើសតំណាងរបស់ខ្លួនឲ្យកាន់អំណាច៥ឆ្នាំ ដោយពុំទាន់ចេះប្រើប្រាស់សិទ្ធិអំណាចជាម្ចាស់ឲ្យបានសមស្របតាមគោលការណ៍បទដ្ឋានគតិយុត្ត និងឲ្យអស់លទ្ធភាពនោះ។ តាមការពិតប្រជាពលរដ្ឋក្នុងរបបដឹកនាំរដ្ឋប្រជាធិបតេយ្យ គឺចាំបាច់ណាស់ត្រូវមានចំណេះដឹង កាលណាមានចំណេះដឹង មនុស្សតែងមានទឹកចិត្តក្លាហាន ពុះពារហ៊ាន និងចេះប្រើប្រាស់សិទ្ធិសេរីភាព អំណាចរបស់ខ្លួនចូលរួមតាមពិនិត្យឃ្លាំមើល និង វិនិច្ឆ័យលើប្រក្រតីភាពនៃការបំពេញការងាររបស់តំណាងរាស្ត្រ រដ្ឋាភិបាល និងតំណាងដទៃទៀត ថាតើវាឆ្លើយតបនឹងឆន្ទៈម្ចាស់ឆ្នោតដែរ ឬទេ?។

ចំណេះវិជ្ជាស្តីពីសិទ្ធិសេរីភាព និងតួនាទីរបស់ប្រជាពលរដ្ឋក្នុងក្របខ័ណ្ឌរបបសេរី គឺជាមូលដ្ឋានគន្លឹះសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូបក្នុងដំណើរការកសាងសង្គមប្រជាធិបតេយ្យនៅកម្ពុជា។ សតិសម្បជញ្ញៈនេះអាចចារឹកក្នុងឧត្តមគតិប្រជាធិបតេយ្យខ្មែរបាន នៅពេលណាប្រជាពលរដ្ឋខ្មែរម្នាក់ៗទទួលការយល់ដឹងស្តីអំពីសិទ្ធិពលរដ្ឋវិជ្ជា។ ការយល់ដឹងអំពីពលរដ្ឋវិជ្ជា គឺលើកស្ទួយសតិសម្បជញ្ញៈដ៏ចាំបាច់សម្រាប់ប្រសិទ្ធភាពនៃកិច្ចដំណើរការពង្រឹងអំណាចរបស់ពលរដ្ឋ។ កាលណាប្រជាពលរដ្ឋខ្មែរយល់ដឹងច្បាស់ពីសារៈសំខាន់ និងភាពចាំបាច់ពីសិទ្ធិសេរីភាព អំណាច និងកាតព្វកិច្ចរបស់ខ្លួនពិតហើយ នោះឧត្តមភាពជាច់ខាតរបស់ប្រជាពលរដ្ឋម្ចាស់អំណាចក្នុងការអភិវឌ្ឍន៍ជាតិ គឺងាយស្រួលក្នុងការកសាងសង្គមប្រជាធិបតេយ្យភាវូបនីយកម្មនៅកម្ពុជា។ ឧទាហរណ៍ សិទ្ធិសេរីភាពក្នុងការបោះឆ្នោតចាំបាច់ត្រូវយល់ពីឫសគល់ពិតប្រាកដនៃគោលដៅក្នុងការបោះឆ្នោត ដែលជាការស្វែងរកអ្នកតំណាង ឬក្រុមនយោបាយតំណាងប្រកបដោយគុណសម្បត្តិលើសពីមនុស្សធម្មតា ពោលគឺក្រុមអ្នកនយោបាយ ដែលមានបញ្ញាចាក់ធ្លុះ សម្រាប់ធ្វើឲ្យសង្គមជាតិរីកចម្រើន ហើយការជ្រើសរើសតំណាងទាំងនោះគឺជាការផ្ទេរសិទ្ធិអំណាចរបស់ខ្លួនដែលជាម្ចាស់ឆ្នោតឲ្យទៅអ្នកតំណាងធ្វើកិច្ចការជំនួសខ្លួន(មានន័យថា ការផ្តល់ធុរកិច្ច) ដើម្បីពលរដ្ឋម្ចាស់ឆ្នោតអាចទទួលបានមកវិញនូវបរិស្ថាននយោបាយមួយដែលមានអត្ថប្រយោជន៍ដល់ខ្លួន ជាពិសេស គឺធ្វើឲ្យបរិយាកាសសង្គមជាតិទាំងមូលស្ថិតក្នុងដំណើរប្រក្រតីក្នុងនីតិកាលបោះឆ្នោតនីមួយៗ។ ទាំងអស់នេះត្រូវការកើតចេញពីការយល់ដឹងរបស់ប្រជាពលរដ្ឋម្ចាស់អំណាចស្តីពីសិទ្ធិសេរីភាព និងអំណាចរបស់ខ្លួនដែលជាស្នូលនៃលទ្ធិប្រជាធិបតេយ្យសេរី។ កាលណាប្រជាពលរដ្ឋខ្មែរម្នាក់ៗឲ្យតម្លៃលើភាពជាម្ចាស់អំណាច ពេលនោះពលរដ្ឋខ្មែរម្នាក់ៗពិតប្រាកដជាយល់កាន់តែច្បាស់អំពីតម្លៃនៃការប្រើសិទ្ធិសេរីភាពជ្រើសរើសតំណាង និងផលប្រយោជន៍នៃការផ្ទេរសិទ្ធិអំណាចឲ្យទៅអ្នកតំណាង ដើម្បីធ្វើកិច្ចអភិវឌ្ឍជំនួសខ្លួនក្នុងរយៈពេល៥ឆ្នាំម្តង ព្រោះថាអំណាចរដ្ឋកើតចេញពីឆន្ទៈសុទ្ធចិត្តរបស់ប្រជាពលរដ្ឋគ្រប់គ្នា ហើយអំណាចនេះវាមិនចាំបាច់រងចាំដល់បញ្ចប់អាណត្តិឡើយ ប្រជាពលរដ្ឋអាចដកហូតយកអំណាចវិញ ករណីក្រុមដឹកនាំរដ្ឋាភិបាលនោះ មិនអាចធ្វើឲ្យសង្គមជាតិរីកចម្រើនបាន ឬមិនអាចដោះស្រាយវិបត្តិអាយុជីវិតប្រទេសជាតិបាន។

ដូច្នេះអាចសន្និដ្ឋានបានថា ការលើកកម្ពស់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីពលរដ្ឋវិជ្ជា គឺជាការពង្រឹងសតិសម្បជញ្ញៈជាម្ចាស់ នៃអំណាចស្របតាមស្មារតីអធិបតេយ្យប្រជាពលរដ្ឋរបស់រដ្ឋធម្មនុញ្ញ។ ស្មារតីនេះនឹងមានប្រសិទ្ធភាពក្នុងជីវភាពរស់នៅជាក់ស្តែង លុះត្រាតែពលរដ្ឋម្នាក់ៗយល់ឲ្យបានស៊ីជម្រៅជាមុនថា អំណាចរបស់ខ្លួនដែលសម្តែងតាមរយៈអំណាចសន្លឹកឆ្នោត ជាដំបូងបង្អស់ ត្រូវគិតអំពីផលប្រយោជន៍សាធារណៈនិងជោគវាសនាប្រទេសជាតិខ្លួនឯង។ តាមទ្រឹស្តីនេះកាលណាប្រជាពលរដ្ឋខ្មែរម្នាក់ៗមានចំណេះដឹងគ្រប់គ្រាន់អាចពិចារណាឃើញហេតុផលពិតជាក់ស្តែង ទទួលបានព័ត៌មានពិតប្រាកដគ្រប់គ្រាន់នោះប្រជាពលរដ្ឋម្នាក់ៗអាចប្រើសតិសម្បជញ្ញៈជាម្ចាស់អំណាចភ្ជាប់ជាមួយនឹងសេរីភាពបុគ្គល និងយកការយល់ដឹងអំពីពលរដ្ឋវិជ្ជាធ្វើជាគោលសម្រាប់វាយតម្លៃនូវអ្វីដែលខ្លួនពេញចិត្តនិងអ្វីដែលខ្លួនមិនទាន់ពេញចិត្ត ហើយជាចុងក្រោយចងក្រងឆន្ទៈទាំង

នេះ ធ្វើជាមូលដ្ឋាននាំទៅដល់ការសម្រេចចិត្តលើសន្លឹកឆ្នោតដោយស្មារតីទទួលខុសត្រូវ។

### ៤.១.៣ ភាពក្រីក្រ

ប្រទេសកម្ពុជា ជាប្រទេសក្រីក្រកំពុងអភិវឌ្ឍដែលទើបតែងើបចេញផុតពីសង្គ្រាមរ៉ាំរ៉ៃ តែក្នុងរយៈកាលជាងដប់ឆ្នាំប៉ុណ្ណោះ បើចាប់គិតពីឆ្នាំ១៩៩៨ ជាឆ្នាំដែលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានដាក់ចេញនូវនយោបាយឈ្នះ-ឈ្នះ។ ក្រោយពេលសង្គ្រាមផុតរលត់ទៅ បន្សល់ទុកនូវធនធានហេដ្ឋារចនាសម្ព័ន្ធជាតិទាំងមូលរាប់ទាំងធនធានមនុស្ស ដែលត្រូវបានបំផ្លាញ និងសម្លាប់ស្ទើរគ្មានសល់ ប្រព័ន្ធអប់រំជាតិ គ្រឹះស្ថានអប់រំធំៗ សំខាន់ៗសម្រាប់បណ្តុះបណ្តាលធនធានមនុស្សរបស់ប្រទេសត្រូវបានរំលាយចោលទាំងស្រុង។ ពុម្ពគំរូនៃផ្នត់គំនិតខ្មែរដើម ដែលជាបេះដូងជាតិក៏ត្រូវបានបំផ្លាញបំបាត់ចោលស្ទើរអស់ ប្រជាពលរដ្ឋទូទាំងប្រទេសជួបគ្រោះមិនចេះអក្សរ ជួបសេចក្តីស្រេកឃ្លាន ក្រក្សត់តោកយ៉ាក វេទនាខ្លោចផ្សា និរាសព្រាត់ប្រាស់បងប្អូន ក្រុមគ្រួសារ រកទីបំផុតគ្មាន។ ឆ្លងកាត់ការកសាងជាតិឡើងវិញនៅក្នុងពេលមានសង្គ្រាមផង។ រហូតមកដល់ពេលនេះ បើទោះបីជាមានការរីកចម្រើនខ្លះៗក្នុងចរន្តសេដ្ឋកិច្ចសេរីភាវូបនីយកម្មទាំងក្នុងតំបន់ និងពិភពលោកក្តី ក៏កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរនៅពុំទាន់ធូរស្បើយ ហើយជីវភាពប្រជាពលរដ្ឋភាគច្រើនរស់នៅក្រោមបន្ទាត់ក្រីក្រនៅឡើយ។ កត្តានេះហើយដែលចាប់បង្ខំឲ្យប្រជាពលរដ្ឋក្រីក្រទាំងនោះ ចំណាយពេលវេលាស្ទើរទាំងអស់ មមាញឹកក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ដើម្បីបង្កើនជីវភាពរស់នៅរបស់ខ្លួន។ ជាក់ស្តែងប្រជាពលរដ្ឋខ្មែរភាគច្រើនស្ទើរតែពុំមានពេលគ្រប់គ្រាន់ ដើម្បីសិក្សាស្វែងយល់ស្គាល់ភាពជាម្ចាស់នៃបុព្វសិទ្ធិសេរីភាពនិងអំណាចរបស់ខ្លួន និងពុំទាន់ស្គាល់ច្បាស់ពីភាពចាំបាច់របស់វាក្នុងរបបប្រជាធិបតេយ្យពហុបក្សនៅឡើយ បើទោះបីជាមាត្រារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានផ្តល់សិទ្ធិសេរីភាពយ៉ាងធំធេងទូលំទូលាយដល់ប្រជាពលរដ្ឋកម្ពុជា ដូចគ្នាក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជាភាគច្រើនហាក់ដូចពុំសូវយកចិត្តទុកដាក់ ពុំចាប់អារម្មណ៍ ពុំចង់បានសិទ្ធិសេរីភាព និងអំណាចដ៏មានតម្លៃបំផុត និងចាំបាច់របស់ខ្លួនទេ។ ភាពក្រីក្រជាឧបសគ្គរារាំង ចំពោះដំណើរការរីកចម្រើនឿនប្រជាធិបតេយ្យភាវូបនីយកម្មនៅកម្ពុជា។ កាលណាជីវភាពក្រីក្រនាំឲ្យបាត់បង់ថាមពល បាត់បង់កម្លាំងចិត្ត គ្មានស្មារតីរឹងប៉ឹង គ្មានទឹកចិត្តឯណាចង់បាន សិទ្ធិសេរីភាព និងអំណាចដ៏សម្បើមអស្ចារ្យរបស់ខ្លួន ដូចដែលគោលការណ៍ប្រជាធិបតេយ្យបានលើកឡើងនោះឡើយ ម្នាក់ៗព្យាយាមសម្របសម្រួលយ៉ាងណាឲ្យតែរស់និងទទួលទានគ្រប់គ្រាន់ប៉ុណ្ណោះ។ តាមការពិតសង្គមប្រជាធិបតេយ្យ ជាសង្គមមួយដែលកើតឡើងពីការធ្វើបដិវត្តន៍របស់ប្រជាពលរដ្ឋឲ្យចេញផុតពីភាពក្រីក្រ ការជិះជាន់កេងប្រវ័ញ្ច សង្កត់សង្កិន អំពើផ្តាច់ការអយុត្តិធម៌កើតចេញពីពួកអភិជនសក្តិភូមិ មិនចាំបាច់ទាល់តែមានជីវភាពធូរធារទើបចូលរួមឡើយ តួយ៉ាងដូចជាចលនាប្រជាពលរដ្ឋ ដែលស្ថិតនៅក្រោមអាណានិគម ប្រជាពលរដ្ឋនៅក្នុងរបបប្រជាធិបតេយ្យ មិនគ្រាន់តែប្រើប្រាស់សេរីភាពរបស់ខ្លួន ក្នុងការជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការ

របស់សង្គម ដូចមានចែងក្នុងមាត្រា៣៦ នៃរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ តួអង្គប្រជាពលរដ្ឋនេះមានតម្លៃជាសក្តានុពលមិនអាចខ្វះបានឡើយក្នុងការចូលប្រឡូករកដំណោះស្រាយបញ្ហានានារបស់ប្រទេសជាតិប្រកបដោយការយល់ដឹង និងត្រូវទាមទារឲ្យបាននូវតម្លៃដាច់ខាតចំពោះសិទ្ធិសេរីភាព និងអំណាចស្របច្បាប់របស់ខ្លួនតាមរយៈលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅប្រទេសរបស់ខ្លួនដោយសកម្ម និងក្លាហានមោះមុតបំផុតក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះកាតព្វកិច្ចជាពលរដ្ឋដ៏មានឥទ្ធិពលក្នុងការកំណត់ និងបែងចែកអំណាចចំពោះស្ថាប័នជាតិទាំងបីគឺ ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងតុលាការ ព្រមទាំងធ្វើការផ្លាស់ប្តូរក្រុមអ្នកនយោ-បាយដឹកនាំប្រទេសតាមច្រកសន្តិភាពនិងជាពិសេសសម្រាប់ដាក់សម្ពាធលើតំណាងគ្រប់ជាន់ថ្នាក់របស់ខ្លួន។

### ៤.១.៤ ការភ័យខ្លាច និងការបំភិតបំភ័យ

ប្រវត្តិសាស្ត្រនយោបាយ ស្តីពីបទពិសោធន៍លេចចេញជាសោកនាដកម្មបានកើតមានក្នុងប្រវត្តិសាស្ត្រសហសម័យខ្មែរ បានចង្អុលបង្ហាញប្រាប់ឲ្យយើងឃើញនូវព្រឹត្តិការណ៍នាំឲ្យជាតិខ្មែរលិចលង់អំឡុងឆ្នាំ១៩៧០។ ជាពិសេសទៅទៀតអំពើអាក្រក់គួរឲ្យរន្ធត់នៅសម័យខ្មែរក្រហម ដែលសាបព្រោះអំពើព្រៃផ្សៃ និងកម្រិត ឈឺចាប់វេទនាខ្លោចផ្សាដល់មនុស្សជាតិ គឺជាប្រវត្តិហាយនភាពក្នុងអំឡុងទសវត្សនៃសោកនាដកម្មរបស់ ប្រជាជនខ្មែរ។ ការបំភិតបំភ័យ និងអំពើភេរវកម្មដែលប្រើប្រាស់មកលើប្រជាជនខ្មែរទូទៅបានបណ្តាលឲ្យប្រជាពលរដ្ឋទទួលនូវភាពអសកម្មក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ អនុស្សាវរីយ៍នៃសេចក្តីភ័យខ្លាចដ៏លើសលប់ និងអំពើភេរវកម្មយ៉ាងសាហាវឃោរឃៅបានក្លាយជាជម្ងឺបាក់ស្បាតកើតមាន កំពុងតែញាំញីជីវិតរស់នៅរបស់ពលរដ្ឋខ្មែររស់នៅសព្វថ្ងៃ ដែលត្រូវបាននឹកឃើញឡើងវិញយ៉ាងល្អិតល្អន់ក្នុងដួងចិត្ត បើទោះបីជាការគំរាមកំហែងនៃការរំលោភទាំងនោះបានផុតរលត់ទៅហើយក្តី។

ប្រជាពលរដ្ឋខ្មែររស់នៅសព្វថ្ងៃ ធ្លាប់បានឆ្លងកាត់នូវភាពគ្មានអំណាចក្នុងទម្រង់របបផ្តាច់ការខ្លាំងបំផុត។ ចំពោះកម្រិតបុគ្គលវិញ សេចក្តីភ័យខ្លាច មិនត្រាប្រណីនោះទាក់ទងទៅនឹងអត្ថន័យនៃភាពអស់សង្ឃឹម ការខ្វះនូវឆន្ទៈក្នុងការឈានទៅអភិវឌ្ឍន៍លក្ខខណ្ឌរបស់ខ្លួនជាដើម។ ប្រវត្តិសាស្ត្រយ៉ាងវែងអំពីអំពើហិង្សា ដែលបានបញ្ជាក់អំពីភាពគ្មានទីពឹង បានទម្លាប់ប្រជាពលរដ្ឋខ្មែរឲ្យរស់នៅដោយភ័យខ្លាច ដែលជាលក្ខណៈពិសេសតែងតែកើតមានជានិច្ចនៅក្នុងជីវិតរបស់គេ។ ផលនៃការភ័យខ្លាច ដែលធ្វើឲ្យមានការខូចខាតនាំឲ្យលោក រ៉ូលឡូម៉េត (Roll May) កត់សម្គាល់ឃើញថាៈ[១៧៥] ពេលប្រជាពលរដ្ឋមានបារម្ភត្រូវគេគំរាមកំហែង និងថប់អារម្មណ៍ គេក្លាយទៅកាន់តែតឹងរឹង ហើយពេលណាដែលមានការសង្ស័យ គេទោទន់ទៅរកការអះអាងដោយមានះហើយ នៅពេលនោះគេបាត់បង់ភាពភ្ញៀវក្លាផ្ទាល់ខ្លួនរបស់គេ។ គេប្រើប្រាស់សំណល់នៃតម្លៃប្រពៃណី ដើម្បីកសាងរបងការពារ ហើយរួញខ្លួនតូចក្រោយរបងនោះ ឬដកថយភ្លាមដោយភ័យខ្លាចទៅរកអតីតកាល។ ចំពោះប្រជាជនភាគច្រើន ដែលមានឋានៈមិនសំខាន់នៅក្នុងសង្គម ការហ៊ានឃ្លាតចេញពីបទដ្ឋាន ចរិយាធម៌ដែលគេកំណត់

---

[១៧៥] ប៊ិន ស៊ានលឹមៈ ពូជអ្នកចម្បាំង ភ្នំពេញ ឆ្នាំ១៩៩១ ទំព័រ១៥៤

នោះ ធ្វើឲ្យមានការប្រថុយប្រថាន ដែលធ្វើឲ្យបុគ្គលងាយរងគ្រោះ ដោយទណ្ឌកម្មពីអ្នកដែលមានឋានៈ ជាអ្នកអនុវត្តបទដ្ឋានវចនានុក្រម។ ស្ថានភាពប្រទេសកម្ពុជានៃការកោតខ្លាចដោយឥតប្រកែក និងការការពារ ខ្លួន ត្រូវបានធ្វើឡើងដើម្បីធ្វើឲ្យស្ងប់ស្ងាត់ នូវសម្លេងប្រឆាំង ឬអំពើបាតុកម្មមិនគោរពដោយប្រជាជន។ ជាលទ្ធផលប្រទេសកម្ពុជាមិនទាន់ពង្រីកមនសិការ ដើម្បីគាំទ្រសិទ្ធិសេរីភាពអំណាចរបស់ប្រជាពលរដ្ឋជាមូលដ្ឋានឲ្យបានទូលំទូលាយ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិដែលខ្លួនបានផ្តល់សច្ចាប័ន ដែលអាចលើកទឹកចិត្តពលរដ្ឋម្ចាស់អំណាច ឲ្យធ្វើការទិតៀន ដោយស្ថាបនាអំពីបញ្ហាសង្គមទេ។ អវត្តមាននៃការខិតខំប្រឹងប្រែងរបស់ប្រជាពលរដ្ឋក្នុងការទាមទារស្របច្បាប់ផ្នែកសីលធម៌នាំទៅដល់ការរំលោភដែលមិន អាចជៀសផុតបាននូវសិទ្ធិសេរីភាព អំណាច និងសិទ្ធិមនុស្ស ដែលផ្ទុយពីប្រជាពលរដ្ឋក្នុងគោលការណ៍ប្រជាធិបតេយ្យដូចប្រទេសប្រជាធិបតេយ្យជឿនលឿនលើសកលលោកបានអនុវត្តកន្លងមក។ គ្មានស្ថាប័នសង្គមណា ដែលមានការវិវត្តន៍ខ្ពស់អាចផ្តល់ការគាំទ្រ ឬការខិតខំប្រឹងប្រែងក្នុងការលុបបំបាត់ចោល ការរំលោភទាំងអស់ នោះបាននៅឡើយទេ។ បុគ្គលនៅក្នុងសង្គមកម្ពុជាត្រូវបានទុកឲ្យការពារផលប្រយោជន៍បក្សពួក និងផ្ទាល់ខ្លួនឯង ដោយមិនប្រកាន់ចរិយាដែលអាចប្រឆាំងនឹងទស្សនៈ ដែលមានជាទូទៅ និងដែលបានចាក់គ្រឹះទៅហើយនោះ។ ការភ័យខ្លាចមានភាពប៉ះពាល់សំខាន់បំផុត ទៅលើការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈបុគ្គល។ សេចក្តីត្រូវការ ដើម្បីសុវត្ថិភាពសមរម្យរបស់បុគ្គល បានរារាំងសក្តានុភូតប្រឌិតញ្ញាណរបស់បុគ្គលក្នុងការឆ្លុះបញ្ចាំង អំពីសេចក្តីត្រូវការផ្នែកវប្បធម៌ និងការកំណត់ចម្លើយ និងការបញ្ចូលរបៀបថ្មី ដែលអាចធ្វើឲ្យសង្គមចលនាទៅមុខ។ គ្មានព្រំដែនបញ្ហាដែលត្រូវប្រឈមមុខនឹងពង្រីកនោះទេ និងដែលតាមរយៈនេះ បង្កើតនូវទុនបញ្ញាមនុស្សដែលត្រូវការជាចាំបាច់ សម្រាប់ធ្វើទំនើបវូបនីយកម្មសង្គម។ សក្តានុពលក្នុងការគិតគូរដោយឯករាជ្យនិងភាព ប៉ិនប្រសប់ក្នុងការវិភាគ ដើម្បីកំណត់បញ្ហាតាមផ្លូវដែលនាំទៅដល់ការដោះស្រាយបញ្ហាដោយប្រឌិតញ្ញាណត្រូវបាន កម្រិតស្រដៀងគ្នានេះដែរ។ ទស្សនៈពិភពលោកដែលតម្រង់ទិសជីវិតផ្នែកបញ្ញារបស់ប្រជាជនកម្ពុជា វាចង្អៀតនិងមានកម្រិតត្រឹមប្រភពអំណាចជាប្រពៃណីដែលគេបានទទួលយកហើយ។

គំរូភាពហិង្សាផ្តាច់ការបំផុតនឹងកើនឡើងភ្លាមៗបានរៀបរាប់ជាច្រើនដងនៅក្នុងរឿងនិទាន និងការបានទទួលពិសោធន៍ផ្ទាល់ ពិសេសដោយមនុស្សជំនាន់នេះនៅបានបន្សល់ទុកនូវស្នាមដែលមិនអាចលុបបាននៅក្នុងព្រលឹងរបស់មនុស្ស។ ការគំរាមកំហែងធ្វើឲ្យសាបសូន្យហាក់ដូចជា មាននៅក្នុងជោគវាសនារបស់ប្រទេសជាតិ សង្គមគ្រួសារ និងបុគ្គល។ ការឆ្លើយតបដោយរំភើបចិត្ត និងមិនភ័យខ្លាចចំពោះគ្រោះថ្នាក់ដែលមាននៅក្នុងបរិយាកាស ត្រូវបានលុបបំបាត់ចោលដោយសារសេចក្តីត្រូវការនៃការអនុវត្តន៍ភារកិច្ចរស់នៅប្រចាំថ្ងៃ។ ការភ័យខ្លាចធ្វើឲ្យខូចដល់សមត្ថភាពក្នុងការគិតដោយមិនលំអៀងអំពីអនាគត ឬក្នុងការបង្កើតផ្លូវជ្រើសរើសដ៏ពេញចិត្ត។ ជាងនេះទៅទៀតសម្រាប់ទំនាក់ទំនងដោយសន្តិភាព និងទប់ស្កាត់ការខិតខំប្រឹងប្រែង ដើម្បីបំផ្លាញចោលនូវរបាំងប្រឌិតញ្ញាណនៅក្នុងការដោះស្រាយបញ្ហា។

បើទោះបីជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងកតិកាសញ្ញាអន្តរជាតិនានាដោយបានផ្តល់

តម្លៃជាធំបំផុតដែលសង្កត់ធ្ងន់ទៅលើសិទ្ធិសេរីភាព និងអធិបតីអំណាចប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យសេរីពហុបក្ស បានលើកទឹកចិត្តយ៉ាងទូលំទូលាយឲ្យប្រជាពលរដ្ឋខ្មែរទូទៅចូលរួមកសាងនិងទទួលខុសត្រូវចំពោះប្រទេសជាតិ ជាពិសេសបើកចំហឲ្យប្រជាពលរដ្ឋចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយក៏ដោយ តាមទិដ្ឋភាពជាក់ស្តែង ចលនាប្រជាពលរដ្ឋម្ចាស់អំណាចក្នុងសង្គមប្រជាធិបតេយ្យភាវូបនីយកម្មនៅតែទទួលរងគ្រោះថ្នាក់ពីសំណាក់អ្នក ឬក្រុមអ្នកនយោបាយកាន់អំណាចដឹកនាំរដ្ឋមាននិន្នាការផ្តាច់ការ។ យោងតាមរបាយការណ៍របស់អង្គការសង្គមស៊ីវិល ផ្នែកសិទ្ធិមនុស្សជាច្រើនបានផ្សព្វផ្សាយរបាយការណ៍ស្តីអំពីការរំលោភលើ សិទ្ធិមនុស្សជាពិសេសផ្តោតសំខាន់ទៅលើការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរលើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ពីអ្នកមានអំណាចដឹកនាំអង្គការរដ្ឋ។ មិនចំពោះតែអ្នកមានទស្សនៈ ឬនិន្នាការនយោបាយផ្សេងពីគណបក្សដឹកនាំរដ្ឋាភិបាលទេ ដែលធ្លាប់ទទួលរងការវាយប្រហារ គំរាមកំហែង បំភិតបំភ័យ ឬចាប់ខ្លួន សូម្បីតែសកម្មជនសង្គមស៊ីវិល ដែលបម្រើការងារក្នុងការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ អ្នកការពារសិទ្ធិមនុស្ស ដែលបុគ្គលទាំងនេះមានសិទ្ធិគ្រប់គ្រាន់តាមមាត្រា១ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីអ្នកការពារសិទ្ធិមនុស្ស ក្នុងការចូលរួមព្រមទាំងជាមួយអង្គការក្រៅរដ្ឋាភិបាល សមាគម ឬក្រុមផ្សេងៗទៀត ទាំងប្រជាពលរដ្ឋខ្លួនឯង ក៏ត្រូវទទួលរងការគំរាមកំហែង បំភិតបំភ័យ ចាប់ខ្លួននិងសម្លាប់ដែរ ឲ្យតែហ៊ានតវ៉ា ឬក៏រិះគន់ចំណុចអសមត្ថភាពរបស់អ្នកកាន់ការងាររដ្ឋ។ ឆ្លងតាមការធ្វើសកម្មភាពតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក៏ដូចជាតាមអំណាចរដ្ឋធម្មនុញ្ញកន្លងមក បានធ្វើឲ្យអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនដែលតវ៉ានៃសមាគមសហជីពកម្មករមួយចំនួនបានជួបប្រទះនឹងបញ្ហាអសន្តិសុខផ្ទាល់ខ្លួនរហូតដល់បាត់បង់ជីវិតទៀតផង។ នៅឆ្នាំ២០០៧ មានសកម្មជនសិទ្ធិមនុស្សចំនួន២នាក់ ត្រូវបានធ្វើឃាតដោយជនមិនស្គាល់មុខ[១៨០]។ នៅឆ្នាំ២០០៨ មានករណីគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សចំនួន៦៣ករណីត្រូវបានកើតឡើង ហើយបានធ្វើឲ្យមានការប៉ះពាល់ដល់អ្នកការពារសិទ្ធិមនុស្សចំនួន១៦៤នាក់ ដែលក្នុងនោះមាន៥២ករណីស្មើនឹង១៥៦នាក់ ជាអ្នកតំណាងសហគមន៍ការពារដីធ្លី៥ករណីកើតឡើងចំពោះលើសកម្មជនសិទ្ធិមនុស្ស៦ករណីកើតឡើងលើតំណាងសហជីព[១៨១]។នៅក្នុងឆ្នាំ២០០៨ ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សបានរីករាលដាលស្ទើរតែគ្រប់ខេត្ត/ក្រុង។ ការគំរាមកំហែងលើអ្នកការពារសិទ្ធិមនុស្ស បានធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់ស្មារតីរបស់ប្រជាពលរដ្ឋទន់ខ្សោយ ដែលប្រការនេះបានធ្វើឲ្យជនប្រព្រឹត្តប្រើប្រាស់មធ្យោបាយគំរាមកំហែងលើអ្នកការពារសិទ្ធិមនុស្ស ក្នុងគោលបំណងធ្វើឲ្យប្រជាពលរដ្ឋភ័យខ្លាចមិនហ៊ានប្តឹងតវ៉ាទាមទារសិទ្ធិជាមូលដ្ឋានរបស់ពួកគេ។ ការធ្វើឃាតនេះ ដោយសារតែពួកគាត់បានធ្វើសកម្មភាពការពារដល់ប្រយោជន៍ ឬសិទ្ធិរបស់ប្រជាពលរដ្ឋដូចជាសិទ្ធិគោរពច្បាប់ការងារ សិទ្ធិមានដីធ្លី ការពារ

[១៨០] សមាគមអាដហុក ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៧ ទំព័រ ១៥

[១៨១] សមាគមអាដហុក ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៨ ទំព័រ ១៦

ព្រៃឈើនិងឡូត៍នេសាទ ដើម្បីទុកជាប្រយោជន៍សាធារណៈ បើទោះបីជាសកម្មភាពទាំងនេះបានជួយដល់ការងាររដ្ឋាភិបាលក៏ដោយ ក៏មន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ភាគច្រើនបានចោទប្រកាន់ដល់អ្នកការពារសកម្មជនសិទ្ធិមនុស្សទាំងនោះជាអ្នកញុះញង់ទៅវិញ។ មិនមែនតែតំណាងសកម្មជនសិទ្ធិមនុស្សតំណាងសហជីព តំណាងសមាគមឬតំណាងសហគមន៍ ឬក្រុមដទៃទៀតទេ ដែលបានទទួលរងនូវការសម្លាប់ ចាប់ខ្លួន បំភិតបំភ័យ និងការគំរាមកំហែង សូម្បីតែសកម្មជនគណបក្សនយោបាយក៏រងនូវអំពើទាំងនេះដូចគ្នាដែរ។ នៅពេលមានព្រឹត្តិការណ៍បោះឆ្នោតម្តងៗ អំពើឃាតកម្មលើសកម្មជនគណបក្សនយោបាយតែងកើតឡើងដោយពុំមានខកខានឡើយ។ នៅក្នុងឆ្នាំ២០០៨ដែលជាឆ្នាំមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ នោះក៏នៅឃើញមានអំពើហិង្សាបានកើតឡើងលើសកម្មជនគណបក្សនយោបាយ បានបណ្តាលឲ្យមានការបាត់បង់ជីវិតមនុស្សចំនួន៦នាក់ផងដែរ។ អំពើឃាតកម្មបែបនេះបានកើតឡើង ជាពិសេសទៅលើសកម្មជនគណបក្សប្រឆាំង។ យោងតាមរបាយការណ៍ស៊ើបអង្កេតរបស់សមាគមអាដហុកឆ្នាំ២០០៨ ករណីឃាតកម្មលើសកម្មជននយោបាយមានការថយចុះពី២៩ករណីមកត្រឹម៦ករណី[១៨២]។ ផ្អែកតាមទិន្នន័យនេះឃើញថា ហាក់ដូចជាមានភាពប្រសើរឡើង ប៉ុន្តែប្រសិនបើយើងសង្កេតទៅលើទិដ្ឋភាពនៃផលប៉ះ-ពាល់ខាងផ្នែកស្មារតីវិញនោះ ករណីឃាតកម្មដែលចេះតែកើតឡើងជាបន្តបន្ទាប់ នោះបានធ្វើឲ្យការភ័យខ្លាចរបស់អ្នកដែលគាំទ្រ និងសកម្មជនរបស់គណបក្សនយោបាយ ដែលតែងតែទទួលរងនូវអំពើឃាតកម្មកាន់តែមានភាពខ្លាំងឡើងជាលំដាប់។ ជាក់ស្តែងនៅក្នុងឆ្នាំ២០០៨ បើទោះបីជាអំពើឃាតកម្មលើសកម្មជនគណបក្សនយោបាយមានចំនួនតិចជាងឆ្នាំ២០០៣ ក៏ពិតមែនភាពភ័យខ្លាចរបស់អ្នកគាំទ្រ និងសកម្មជនរបស់គណបក្សមិនកាន់អំណាចមានសភាពធ្ងន់ធ្ងរជាងមុនដូចជានៅក្នុងឆ្នាំ២០០៨មិនគ្រាន់តែមានអំពើឃាតកម្មលើសកម្មជននយោបាយប៉ុណ្ណោះទេ ដែលជាឆ្នាំបោះឆ្នោតជាតិក៏នៅមានការគំរាមកំហែងលើសកម្មជនរបស់គណបក្សនយោបាយចំនួន១៣៣ករណី[១៨៣]។ បានកើតឡើងភាគច្រើនលើសកម្មជនរបស់គណបក្សនយោបាយមិនកាន់អំណាច ដែលមានឥទ្ធិពលក្នុងការប្រកួតប្រជែង។ ជាការពិតនៅក្នុងការបោះឆ្នោតជាតិឆ្នាំ២០០៨ មានគណបក្សនយោបាយចំនួន១១បានចូលរួមប្រកួតប្រជែង ប៉ុន្តែជាក់ស្តែងឃើញមានតែគណបក្សចំនួន៥ប៉ុណ្ណោះ ដែលសកម្មជនគណបក្សត្រូវបានទទួលរងការគំរាមកំហែងដែលក្នុងនោះគណបក្សសមរង្ស៊ី ទទួលរងការគំរាមកំហែងរហូតដល់ទៅ១០៨ករណី គណបក្សសិទ្ធិមនុស្សមានចំនួន១០ករណី គណបក្ស នរោត្តមរណឫទ្ធិមាន១០ករណី គណបក្សហ៊្វុនស៊ិនប៉ិច១ករណី និងគណបក្សប្រជាជនកម្ពុជា ១ករណី។

### ៤.១.៥ អំណាចមជ្ឈការ ឬប្រមូលផ្តុំ

លក្ខណៈមួយនៃសង្គមប្រជាធិបតេយ្យ គឺវត្តមាននៃអង្គការ ឬក្រុមក្រៅរដ្ឋាភិបាលដែលឯករាជ្យដាច់ចេញ

[១៨២] សមាគមអាដហុក ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៨ ទំព័រ ១១

[១៨៣] ដ.ដ.ម ទំព័រ ១៤

ពីរដ្ឋ។ អង្គការទាំងនេះមានជាអាទិ៍ ក្រុមគ្រួសារ ស្ថាប័ន សាសនា សមាគម វប្បធម៌ ក្លឹបកីឡា វិទ្យាស្ថាន សេដ្ឋកិច្ច សហជីព សមាគមនិស្សិត គណបក្សនយោបាយ ភូមិសមាគមអ្នករស់នៅជិតខាងគ្នា ក្លឹបសួនច្បារ អង្គការសិទ្ធិមនុស្ស ក្រុមក្លេងសង្គមអក្សរសិល្ប៍ និងក្រុមឯទៀតៗ។ អង្គការទាំងនេះ មានសារៈសំខាន់ក្នុងការបម្រើគោលបំណងខ្លួនឯង និងជួយបំពេញសេចក្តីត្រូវការរបស់សង្គមផងដែរ ដែលក្រុមទាំងនេះផ្តល់ជាមូលដ្ឋាន ឬវេទិកាដែលប្រជាពលរដ្ឋអាចបញ្ចេញឥទ្ធិពលទៅលើទិសដៅនៃដំណើរវិវត្តរបស់សង្គមទាំងមូល ហើយទប់ទល់នឹងអង្គការ ឬរដ្ឋាភិបាលណាដែលគេឃើញថា បានធ្វើអ្វីប៉ះពាល់ដោយអយុត្តិធម៌ទៅលើផលប្រយោជន៍ សកម្មភាព និងគោលបំណងរបស់គេ[១៨៤]។

ប្រព័ន្ធប្រជាធិបតេយ្យ តម្រូវឲ្យមានរដ្ឋធម្មនុញ្ញមួយដែលបង្កើតឲ្យមានប្រព័ន្ធដែលគេចង់បានសម្រាប់រដ្ឋាភិបាលប្រជាធិបតេយ្យ។ រដ្ឋធម្មនុញ្ញកំណត់អំពីគោលបំណងនៃរដ្ឋាភិបាល និងដាក់កម្រិតដល់អំណាចរបស់រដ្ឋាភិបាល មធ្យោបាយ និងពេលវេលាសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមអ្នកធ្វើច្បាប់ និងមន្ត្រីរដ្ឋការ សិទ្ធិជាមូលដ្ឋាននៃប្រជាពលរដ្ឋ ហើយនឹងពាក់ព័ន្ធរវាងរដ្ឋាភិបាលជាតិ និងប្រព័ន្ធគ្រប់គ្រងថ្នាក់ក្រោមឯទៀត។ ការគ្រប់គ្រងជាតិតាមលក្ខខណ្ឌប្រជាធិបតេយ្យ គេត្រូវតែមានការបែងចែកអំណាចឲ្យបានច្បាស់និងដាច់ចេញពីគ្នារវាងនីតិបញ្ញត្តិ(ក្រុមអ្នកធ្វើច្បាប់) នីតិប្រតិបត្តិ(ក្រុមអ្នកយកច្បាប់ទៅអនុវត្ត)និងតុលាការ(ក្រុមអ្នកកាត់ក្តី)។ គេគួរតែបញ្ចូលនូវការកំណត់យ៉ាងតឹងតែងទៅលើសកម្មភាពរបស់នគរបាល ភ្នាក់ងារស៊ើបការណ៍សម្ងាត់យោធា ដើម្បីហាមឃាត់មិនឲ្យក្រុមទាំងនេះ ពាក់ព័ន្ធតាមផ្លូវច្បាប់ណាមួយទៅក្នុងវិស័យនយោបាយ។ ការចូលរួមពីប្រជាពលរដ្ឋម្ចាស់អំណាចជាការប្រសើរ ហើយជាការចាំបាច់សម្រាប់អនុម័តរដ្ឋធម្មនុញ្ញ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រង់ចំណុចណាមួយ។ គេត្រូវមានការប្រយ័ត្នបំផុតចំពោះការដាក់ចូលក្នុងរដ្ឋធម្មនុញ្ញនូវមាត្រាណាមួយដែលតម្រូវឲ្យអំណាចច្រើនផ្តុំទៅលើរដ្ឋាភិបាល ព្រោះការណ៍នេះគឺជាកត្តាដែលអាចសម្រួលឲ្យមានរបបផ្តាច់ការថ្មី។ ចំណុចនេះ គឺដូចគ្នាទៅនឹងខ្លឹមសារក្នុងសុន្ទរកថា ឡើងកាន់តំណែងរបស់លោក WILLIAM HENRYHARRISON ជាប្រធានាធិបតីសហរដ្ឋអាមេរិកថ្ងៃទី០៩/០២/១៧៧៣-០៤/០៤/១៨៤១ ដោយបានលើកឡើងជាសាធារណៈយ៉ាងដូច្នេះថា សម្រាប់ខ្លួនខ្ញុំផ្ទាល់ គ្រោះថ្នាក់ធំបំផុតចំពោះជាតិយើងមិនមែនជាកិច្ចការដែលរដ្ឋាភិបាលណាមួយ អត់បានទទួលស្គាល់ពីប្រជាជនស្តីពីការដណ្តើមអំណាចនោះទេ គឺជាផ្នែកមួយក្នុងចំណោមផ្នែកដទៃទៀតនៅក្នុងរដ្ឋាភិបាលមួយ ដែលប្រមូលផ្តុំរាល់សិទ្ធិអំណាចក្នុងដៃ។ អំណាចនោះទោះមានកំណត់ក្តី នៅតែគ្រប់គ្រាន់សម្រាប់រក្សានូវរបបផ្តាច់ការមួយ ប្រសិនបើអំណាចនោះប្រមូលផ្តុំតែនៅក្នុងផ្នែកណាមួយប៉ុណ្ណោះ...។ ប្រជាពលរដ្ឋអាចអនុវត្តសិទ្ធិសេរីភាព និងអំណាច របស់ខ្លួនបានលុះត្រាតែអំណាចទាំងបីមិនឋិតនៅក្នុងដៃបុគ្គលណាម្នាក់ ឬគ្រួសារតែមួយ ឬអង្គការតែមួយ[១៨៥]។ ឧទាហរណ៍ បុគ្គល "ក" មានទំនាស់ និង

[១៨៤] ជីន សាបៈ ពីរបបផ្តាច់ការ ទៅប្រជាធិបតេយ្យ តាមគោលការណ៍អហិង្សា ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ២៩

[១៨៥] សុខ គាងៈ វិទ្យាសាស្ត្រនយោបាយ ភ្នំពេញ ឆ្នាំ២០០២ ទំព័រ ៨៨

ត្រូវបានរំលោភបំពានដោយបុគ្គល"ខ" ដែលមានឳពុករបស់ខ្លួនកាន់កាប់អំណាចតុលាការ។ តើបុគ្គល"ក" ហ៊ានទៅប្តឹងអំពីបុគ្គល"ខ" ទេ? ដូច្នេះ បញ្ហាចម្បង គឺមិនស្ថិតនៅត្រង់បំបាត់ចោល ឬកំទេចអំណាចចោលនោះទេ តែស្ថិតនៅត្រង់ថា តើគួរប្រើអំណាចតាមរបៀបណា? ប្រើអំណាចបានត្រឹមត្រូវតាមគោលការណ៍ នោះប្រជា-ពលរដ្ឋទូទៅនឹងទទួលបានសេចក្តីសុខសប្បាយទាំងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ។ លក្ខណៈសម្គាល់នៃលទ្ធិប្រជាធិបតេយ្យស្តីអំពីគោលការណ៍តុល្យភាពអំណាច(Checks and Balances) នៅក្នុងប្រព័ន្ធរដ្ឋអំណាចគ្រប់គ្រងរដ្ឋ។ គោលការណ៍នេះ អំណាចនៅក្នុងប្រទេសត្រូវចែកជាបីផ្នែកដាច់ពីគ្នា គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ មែកធាងនីមួយៗនៃរដ្ឋអំណាចធ្វើសកម្មភាពដោយឯករាជ្យ ក៏ប៉ុន្តែស្ថិតនៅក្រោមអន្តរកម្មយ៉ាងជិតស្និទ្ធជាមួយនឹងមែកធាងឯទៀត។

បើផ្អែកតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានបើកចំហរឲ្យប្រជាពលរដ្ឋខ្មែរប្រើប្រាស់អំណាច និងសិទ្ធិសេរីភាពរបស់ខ្លួន។ ដូចជាមាត្រា៣៥ចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលយកមកពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។ មាត្រា៤១ចែងថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើប្រាស់សិទ្ធិនេះដោយរំលោភឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ មាត្រា៤២ចែងថា: ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ ប្រជាពលរដ្ឋទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិនិងសណ្តាប់ធ្នាប់សង្គម។ មាត្រា៥១ ចែងថា:ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់នៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើប្រាស់អំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ អំណាចបែងចែកដាច់ចេញពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

ផ្តើមចេញពីទិដ្ឋភាពជាក់ស្តែងឃើញថា ស្ថាប័ននីតិប្រតិបត្តិបានក្រសោបច្បាមយកអំណាចលើសលប់ ហេតុមានឥទ្ធិពលលប់លើស្ថាប័នពីរទៀតគឺ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការ ក្រោមរូបភាពប្រជាធិបតេយ្យប្រជាភិថុត ដែលប្រព័ន្ធដឹកនាំរបស់រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នបណ្តាលឲ្យមានលក្ខណៈប្រមូលផ្តុំអំណាចតាមរយៈ :

១-ការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយអំណាចរដ្ឋាភិបាល។ តាមទម្រង់រដ្ឋាភិបាលប្រជាធិបតេយ្យ តំណែងទាំងអស់នេះមិនគួរអនុញ្ញាតឲ្យអង្គការនីតិប្រតិបត្តិលូកដៃមកតែងតាំងជំនួយប្រជាពលរដ្ឋនោះទេ។ គណៈអភិបាលទាំងនេះនៅផ្ទាល់ជាមួយប្រជាពលរដ្ឋ ហើយជារដ្ឋាភិបាលមូលដ្ឋានថ្នាក់ក្រោមជាតិ និងទទួលខុសត្រូវផ្ទាល់ចំពោះប្រជាពលរដ្ឋ។

ដូច្នេះ ដើម្បីពង្រឹងអំណាចប្រជាពលរដ្ឋ ចាំបាច់ត្រូវទុកលទ្ធភាពឲ្យប្រជាពលរដ្ឋជាអ្នកចាត់ចែងតាម

រយៈការបោះឆ្នោតជាសកល និងផ្ទាល់ពីប្រជាពលរដ្ឋ ដោយត្រូវមានច្បាប់បញ្ញត្តិស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សា និងថ្នាក់ដឹកនាំគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយយកតាមទម្រង់ការបោះឆ្នោតជាសកល និងផ្ទាល់ពីប្រជាពលរដ្ឋ ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ការអនុវត្តន៍ប្រព័ន្ធវិសហមជ្ឈការបែបនេះ ទើបបង្ហាញពីឆន្ទៈនយោបាយដ៏ឆ្នើមក្នុងការលើកតម្កើងពីតម្លៃអធិបតេយ្យភាពប្រជាពលរដ្ឋ ក្នុងភាពជាម្ចាស់តាមគោលការណ៍ជាសកលនៃប្រជាធិបតេយ្យពិតប្រាកដ។ ការបើកឱកាសឲ្យប្រជាពលរដ្ឋប្រើសិទ្ធិសេរីភាព ដើម្បីជ្រើសតាំងសមាជិកក្រុមប្រឹក្សា និងថ្នាក់ដឹកនាំគណៈអភិបាលតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនមែនគ្រាន់តែបញ្ជាក់ពីបុព្វហេតុដើម្បីប្រជាធិបតេយ្យ ឬមិនមែនគ្រាន់តែអនុវត្តសិទ្ធិសេរីភាពក្នុងលទ្ធិប្រជាធិបតេយ្យនោះទេ។ ផ្លែផ្កាជាវិជ្ជមានដែលថ្នាក់ដឹកនាំគណៈអភិបាលកើតចេញពីការបោះឆ្នោតជាសកល និងផ្ទាល់ពីប្រជាពលរដ្ឋ គឺនាំគ្នាបង្កើតយន្តការបំបែកប្រព័ន្ធពួកឡេមឡឺម អែបអបពុករលួយ ការច្រណែន វប្បធម៌ក្រាញអំណាចតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស គឺជាយន្តការចូលរួមកាត់បន្ថយអំណាចរដ្ឋាភិបាល និងជាយន្តការបន្សុទ្ធកម្មជ្រើសរើសយកតែបុគ្គលរូបណា ដែលមានសមត្ថភាពជាអ្នកដឹកនាំប្រកបដោយវិជ្ជាជីវៈមានក្រមសីលធម៌ មានទស្សនវិស័យក្នុងការងារបម្រើ និងគោរពឆន្ទៈប្រជាពលរដ្ឋ ខ្លាចអំណាចប្រជាពលរដ្ឋ និងធ្វើឲ្យសង្គមជាតិមានការអភិវឌ្ឍន៍ជាលំដាប់។ ដែលផ្ទុយពីលទ្ធផលកើតចេញពីការតែងតាំងដោយរដ្ឋាភិបាល គឺបណ្តាលឲ្យកើតមានជម្ងឺបក្សពួកនិយម ពុករលួយ អំណាចត្រាញ់មិនគោរពអំណាចប្រជាពលរដ្ឋ ពុំសូវមានការទទួលខុសត្រូវក្នុងការងារនោះទេ។ ហើយគណៈអភិបាលទាំងនោះ ខ្លាចអំណាចរដ្ឋាភិបាលយកចិត្តរដ្ឋាភិបាល ស្តាប់បញ្ជារដ្ឋាភិបាល។ ដូច្នេះរាល់សេចក្តីសម្រេចចិត្តនានាគឺពឹងផ្អែកទាំងស្រុងទៅលើរដ្ឋាភិបាល បើទោះបីជាការសម្រេចចិត្តនោះខុស ឬត្រូវក៏ដោយ។ ប្រសិនបើតំណែងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កើតចេញពីប្រជាពលរដ្ឋ ធ្វើឲ្យអភិបាលនៃគណៈអភិបាលទាំងនេះ ខិតខំបម្រើអស់ពីសមត្ថភាព ដើម្បីធ្វើឲ្យប្រជាពលរដ្ឋមានស្មារតីទទួលខុសត្រូវរាល់ទង្វើ និងសេចក្តីសម្រេចចិត្តរបស់ខ្លួន និងប្រជាពលរដ្ឋអាចប្រើសិទ្ធិសេរីភាពដោយសន្តិវិធីដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីតវ៉ារាល់ការសម្រេចចិត្តនានារបស់គណៈអភិបាល ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍របស់ក្រុមខ្លួន ឬសហគមន៍ខ្លួនដោយអយុត្តិធម៌ ឬអាចបណ្តេញចេញពីតំណែងចំពោះមន្ត្រី ដែលអសមត្ថភាព ហើយរដ្ឋសភាគួរអនុម័តច្បាប់ស្តីពីការបោះឆ្នោតជាសកល និងផ្ទាល់ពីប្រជាពលរដ្ឋតាមយន្តការណាមួយដូចបានបង្ហាញខាងលើនេះ សំដៅពង្រឹងសិទ្ធិសេរីភាពនិងអំណាចប្រជាពលរដ្ឋនៅក្នុងសង្គមប្រជាធិប-តេយ្យសេរីពហុបក្ស។

២-នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា២៣បានចែងថា ព្រះមហាក្សត្រទ្រង់ជាអគ្គមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទ និងមាត្រា២៤ចែងថា ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សា-ការពារជាតិ។ មាត្រា៩ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ចែងថា យោធិនត្រូវមានអព្យាក្រិត្យភាពក្នុងមុខនាទី ក្នុងសកម្មភាព

ការងារ និងហាមឃាត់ការប្រើមុខងារ និងប្រើប្រាស់សម្ភារៈរបស់រដ្ឋ ដើម្បីបម្រើសកម្មភាពនយោបាយណាមួយ។

ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងកម្លាំង យោធពលខេមរភូមិន្ទ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៧ ពុំបានចែងអំពីតំណែង អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ជាបុគ្គលឯករាជ្យពីគណបក្សនយោបាយឡើយ។ បន្ថែមពីនេះ បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សាការពារជាតិដើម្បីត្រួតពិនិត្យ និងតាមដាន និងតំណែងអគ្គមេបញ្ជាការគ្រប់អគ្គបញ្ជាការដ្ឋាន កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទឡើយ។

រដ្ឋាភិបាលបានតែងតាំងគ្រប់តំណែងអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដូចជា នគរបាល កងរាជអាវុធហត្ថ កងយោធពលខេមរភូមិន្ទ ដោយបានយកចេញពីថ្នាក់ដឹកនាំមន្ត្រីជាន់ខ្ពស់របស់គណបក្សកាន់អំណាច។ គណបក្សកាន់អំណាចបានប្រមូលការគ្រប់គ្រងលើផ្នែកទាំងបីនៃរដ្ឋាភិបាល និងស្ថាប័នជាតិដទៃទៀត ដែលអំណាចភាគច្រើនបំផុតត្រូវប្រមូលផ្តុំនៅក្នុងកណ្តាប់ដៃរបស់នាយករដ្ឋមន្ត្រី។ ទោះបីជាអាជ្ញាធរស៊ីវិលជាធម្មតាត្រូវគ្រប់គ្រងដោយកងកម្លាំងសន្តិសុខក៏ដោយ ក៏ក្នុងករណីជាច្រើនកម្លាំងសន្តិសុខធ្វើសកម្មភាពក្រោមការបញ្ជារបស់ថ្នាក់ដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា[១៨៦]។ តាមការពិតតំណែង ទាំងនេះមិនមែនជាតំណែងនយោបាយឡើយ ព្រោះថា តំណែងសម្រាប់រក្សាការពារអធ្យាក្រិត្យភាពរបស់ជាតិ រក្សាស្ថេរភាពនិរន្តរភាពនៃរដ្ឋជាប្រក្រតី និងសន្តិសុខសាធារណៈរបស់សង្គមជាតិ។ ដូច្នេះ បើតំណែងទាំងនេះកើតចេញពីរដ្ឋាភិបាលនោះធ្វើឲ្យរដ្ឋាភិបាលមានអំណាចខ្លាំង ហើយចង់មិនចង់មានឥទ្ធិពលលើអំណាចដទៃទៀត។ ប្រជាជនកម្ពុជា ទទួលបទពិសោធន៍ដ៏ឈឺចាប់ចុងក្រោយ គឺព្រឹត្តិការណ៍យោធាថ្ងៃ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ចលាចលភាពនេះកើតឡើងដោយសារកងកម្លាំងប្រដាប់អាវុធជាពិសេស មេបញ្ជាការចាប់ពីឧត្តមសេនីយ៍ត្រី ដល់នាយឧត្តមសេនីយ៍ឯក ត្រូវបានយកចេញពីគណបក្សនយោបាយកាន់អំណាចទាំងពីរ(គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច) និងបានតែងតាំងដោយរដ្ឋាភិបាល។

យន្តការដើម្បីបញ្ចៀសបញ្ហានេះកុំឲ្យកើតឡើងជាដដែល រដ្ឋសភាត្រូវអនុម័តច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សាការពារជាតិ ដើម្បីឧត្តមក្រុមប្រឹក្សាការពារជាតិមានអំណាច រៀបចំតែងតាំងតំណែងអគ្គមេបញ្ជាការគ្រប់កងកម្លាំងប្រដាប់អាវុធ ដោយតម្រូវឲ្យផ្តល់សេចក្តីទុកចិត្តលើការតែងតាំងនេះពីរដ្ឋសភាជាតិ និងបញ្ញត្តិហាមឃាត់មិនឲ្យមន្ត្រីបំពេញតួនាទីជាកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាប់ពាក់ព័ន្ធនឹងគណបក្សនយោបាយព្រមទាំងបញ្ញត្តិបញ្ជាក់ពីទោសទណ្ឌកម្មផងដែរ ករណីអនុវត្តផ្ទុយនឹងច្បាប់។

ច្បាប់ទាំងពីរនេះ អាចធ្វើឲ្យគោលការណ៍តុល្យភាពអំណាចទាំងបី(Cheks and Balances) មានលំនឹងក្នុងប្រព័ន្ធដឹកនាំផង រីឯប្រជាពលរដ្ឋអាចប្រើអធិបតីរបស់ខ្លួនបានយ៉ាងរលូន ដើម្បីទទួលបានឱកាសចូលរួមអភិវឌ្ឍប្រទេសជាតិ ប្រកបដោយការទទួលខុសត្រូវ និងទទួលបានយុត្តិធម៌សង្គម ស្ថេរភាពនយោបាយ សន្តិភាព

---

[១៨៦] របាយការណ៍ស្ថានទូតអាមេរិកស្តីពីសិទ្ធិមនុស្ស ឆ្នាំ២០១០:http://www.state.gov/g/drl/rls/hrrpt/2009/eap/135988.htm

សន្តិសុខសង្គម រំលាយបណ្តាញពុករលួយ បក្សពួកនិយម ជាពិសេស គឺជារនាំងការពារនូវការប៉ុនប៉ងរបស់គណបក្សនយោបាយណាមួយ នាំប្រទេសជាតិទៅរករបបផ្តាច់ការ។ អំណាចនៅក្នុងរបបប្រជាធិបតេយ្យពិតប្រាកដ គឺរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រាន់ក្នុងការប្រើអំណាចរបស់ខ្លួនដាក់ឥទ្ធិពលទៅលើសកម្មភាពការងាររបស់រដ្ឋាភិបាលរបស់ពួកគេ។ ដូចសម្តីរបស់លោកឡុតអគុន(Lord Acton) បានធ្វើការកត់សម្គាល់ថា"អំណាចធ្វើឲ្យអំពើពុករលួយ។ មានអំណាចពេញទំហឹងក៏ធ្វើឲ្យមានអំពើពុករលួយយ៉ាងពេញបន្ទុកដែរ"[១៨៧]។ នៅក្នុងលទ្ធិប្រជាធិបតេយ្យ អំណាចបានបែងចែកឲ្យដល់ប្រជាពលរដ្ឋគ្រប់ៗរូបមិនមែនសម្រាប់តែមនុស្សម្នាក់ទេ។ ប្រសិនបើប្រជាពលរដ្ឋមើលឃើញថា តំណាងរបស់ខ្លួនបំពេញការងារបានល្អនោះ ពួកគេអាចសម្តែងមតិគាំទ្រតាមរយៈការបញ្ចេញសម្លេងចំពោះការបោះឆ្នោត។ ប៉ុន្តែប្រសិនបើពួកគេមើលឃើញថា អ្នកតំណាងរបស់ខ្លួនធ្វើការមិនបានល្អទេ ពួកគេអាចបោះឆ្នោតទម្លាក់អំណាចដោយសន្លឹកឆ្នោត ហើយជ្រើសរើសអ្នកថ្មីដែលមានគុណសម្បត្តិល្អជាងមកជំនួសវិញ។

នីតិក្រមរបស់មេដឹកនាំអំណាចក្នុងប្រទេសប្រកាន់គោលការណ៍ប្រជាធិបតេយ្យត្រូវបានកំណត់យ៉ាងជាក់លាក់ណាស់ គឺមិនឲ្យមេដឹកនាំកាន់អំណាចលើសពីរយៈពេលពីរ(២)អាណាត្តិឬ១០ឆ្នាំឡើយ។ ការកំណត់រយៈពេលបែបនេះ ព្រោះតែគេស្មានថា អាចធ្វើឲ្យមេដឹកនាំអំណាចបញ្ចេញសមត្ថភាពរបស់គេបានពេញលេញប្រកបដោយប្រសិទ្ធិភាពក្នុងការបម្រើប្រជាពលរដ្ឋ និងប្រទេសជាតិរបស់គេ។ ហើយជាពិសេស ដោយសារតែរយៈពេលនេះគឺវាបានក្លាយទៅជារនាំងមួយ ដែលរារាំងមិនឲ្យពួកមេដឹកនាំអំណាចមានឱកាសក្នុងការបង្កើតក្រុមបក្ខពួក ឬគ្រួសារនិយម ដែលបង្កឲ្យមានអំពើពុករលួយ ផ្តាច់ការ នាំឲ្យគ្រោះថ្នាក់ដល់ជាតិ។ ជាក់ស្តែងមេដឹកនាំកាន់អំណាចនៅក្នុងប្រទេសប្រជាធិបតេយ្យខ្លះ កាន់អំណាចមិនដល់ពីរអាណត្តិផង ក៏សុំលាឈប់ទាំងពាក់កណ្តាលទីប្រកបដោយសម្បជញ្ញៈទទួលខុសត្រូវ និងកម្រិតសីលធម៌ខ្ពង់ខ្ពស់នៅពេលដែលគេមិនអាចឆ្លើយតបឬដោះស្រាយរាល់បញ្ហាដែលបានសន្យានៅក្នុងអំឡុងពេលឃោសនាបោះឆ្នោតឬក៏យល់ថា គេពុំមានសមត្ថភាពគ្រប់គ្រាន់ដឹកនាំប្រទេសជាតិ និងបម្រើប្រជាពលរដ្ឋ។ ឧទាហរណ៍ លោក យូ គីអូហាតូយ៉ាម៉ា ដែលបានជាប់ឆ្នោតឡើងកាន់អំណាចនាយករដ្ឋមន្ត្រីប្រទេសជប៉ុន មិនទាន់ទាំងបានមួយឆ្នាំស្រួលបួលផង បន្ទាប់ពីគណបក្សប្រជាធិបតេយ្យរបស់លោកបានធ្វើដំណើរយ៉ាងត្រដាបត្រដួសអស់រយៈពេលជាង៥០ឆ្នាំ ដើម្បីបានអំណាចហើយក៏ស្រាប់តែលាលែងពីតំណែងកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០។ ការលាលែងនេះដោយសារតែទទួលបរាជ័យក្នុងការជំរុញឲ្យដកមូលដ្ឋានយោធាអាមេរិក ចេញពីកោះអូគីណាវ៉ា ដូចការអះអាងរបស់ខ្លួនជាមួយប្រជាពលរដ្ឋ ក្នុងពេលឃោសនាបោះឆ្នោត។

## ៤.២ វិភាគលើការប្រើសិទ្ធិពលរដ្ឋតាមរយៈស្ថាប័នដឹកនាំ

ប្រជាពលរដ្ឋអាចប្រើអំណាចរបស់ខ្លួនតាមរយៈរាជរដ្ឋាភិបាល រដ្ឋសភា និងសាលាជម្រះក្តី។ មាន

[១៨៧] ព្រឹត្តិបត្រស្រាវជ្រាវ របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ឆ្នាំទី១៤ លេខ១៣៥ ខែមករា-កុម្ភៈ ឆ្នាំ២០០៧ ទំព័រ ៦

ន័យថា សិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋដែលបានបញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញ ដោយបើកចំហឲ្យប្រជា-ពលរដ្ឋម្ចាស់ឆ្នោតគ្រប់និន្នាការប្រើប្រាស់អំណាចរបស់ខ្លួនតាមរយៈស្ថាប័នជាតិធំទាំងបី ដោយមិនញញើត មិនខ្លាច។ នៅក្នុងរបបប្រជាធិបតេយ្យ អំណាចរបស់ប្រជាពលរដ្ឋ គឺត្រូវតែប្រជាពលរដ្ឋអាចប្រើប្រាស់តាមរយៈការកំណត់របស់ច្បាប់ ដោយគ្មាននរណាមករារាំងបានឡើយ ដោយឡែកសិទ្ធិសេរីភាព គឺជាព្រលឹងរបស់ប្រជាពលរដ្ឋមានតាំងពីកំណើតដោយមិនមែនរដ្ឋាភិបាល ឬរដ្ឋសភា ឬស្ថាប័នណាមួយជាអ្នកផ្ដល់ឲ្យនោះទេ ផ្ទុយទៅវិញ ស្ថាប័នជាតិទាំងបីនេះគឺជាអ្នកមានកាតព្វកិច្ចការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋឲ្យបានម៉ឺង -ម៉ាត់ និងមានឧត្តមគតិទទួលខុសត្រូវខ្ពស់បំផុត។

នៅក្នុងរដ្ឋមួយដែលគ្រប់គ្រងសង្គមបែបប្រជាធិបតេយ្យពិតប្រាកដ គឺសំដៅដល់ប្រជាពលរដ្ឋអាចប្រើប្រាស់សិទ្ធិសេរីភាព និងអំណាចរបស់ខ្លួនដោយសន្តិវិធីទៅបាន លុះត្រាតែមានការបែងចែកអំណាចឲ្យដាច់ពីគ្នាសម្រាប់ស្ថាប័នជាតិកំពូលទាំងបីដោយរក្សាឲ្យបាននូវគោលការណ៍តុល្យភាពអំណាច ហើយការបែងចែកអំណាចគឺជាទ្រឹស្ដីនយោបាយមួយ ដែលប្រកាន់របបដឹកនាំ និងគ្រប់គ្រងរបស់ពួកមូលធនអាស្រ័យរដ្ឋធម្មនុញ្ញ។ ទ្រឹស្ដីនេះមានចំណងទាក់ទងផ្ទាល់ទៅនឹងការយល់ឃើញរបស់ទស្សនវិទូ Jonh Locke ដែលស្ដែងឡើងក្នុងរូបភាព ជាការសម្របសម្រួលអំណាចនៅក្នុងរដ្ឋតាមការព្រមព្រៀង។ ផ្អែកលើទ្រឹស្ដីនេះ អំណាចនីតិបញ្ញត្តិត្រូវតែជាអំណាចកំពូល។ ចំណែកអំណាចដទៃទៀតដែលកើតចេញពីអំណាចនេះ ត្រូវតែស្ថិតក្រោមការគ្រប់គ្រងរបស់អំណាចនីតិបញ្ញត្តិ បើទោះបីជាអំណាចនោះស្ថិតនៅក្នុងដៃមនុស្សប្រភេទណាក៏ដោយ។ គោលដៅសំខាន់របស់ទ្រឹស្ដីនេះ គឺដើម្បីធានាសន្តិសុខជូនប្រជាពលរដ្ឋ ផ្ដត់ផ្ដង់សិទ្ធិសេរីភាពនយោបាយដល់ប្រជាពលរដ្ឋឲ្យបានត្រឹមត្រូវ ជាពិសេសធ្វើឲ្យសង្គមចាកផុតពីអំណាចផ្ដាច់ការ និងចាកផុតពីការដឹកនាំទៅរកផ្លូវអាក្រក់ និងដើម្បីធានាភាពងាយស្រួលចំពោះប្រជាពលរដ្ឋក្នុងការប្រើប្រាស់សិទ្ធិរបស់គាត់តាមរយៈស្ថាប័នទាំងបី។

**តើស្ថាប័នកំពូលទាំងបីនេះបានការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋដូចចែងក្នុងរដ្ឋធម្មនុញ្ញដែរ ឬទេ?**

### ៤.២.១ ករណីស្ថាប័នរដ្ឋសភា

រដ្ឋសភាបានបង្កើតជាគណៈកម្មការផ្សេងៗ មានអំណាចនិងសិទ្ធិ[១៨៨] តាមការកំណត់នៃរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រមទាំងច្បាប់ជាធរមានដូចជា:

-គំនិតផ្ដួចផ្ដើមធ្វើច្បាប់។

-សិទ្ធិធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញតាមសេចក្ដីស្នើសុំពីតំណាងរាស្ត្រ១/៤ នៃចំនួនសមាជិកសភាទាំងមូល។

- ការអនុម័តថវិកាជាតិ ផែនការរដ្ឋ ការអនុញ្ញាតឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការអនុញ្ញាតឲ្យរដ្ឋឲ្យប្រាក់គេខ្ចី( ProvidedLoan )ការសន្យានានាខាងផ្នែកហិរញ្ញវត្ថុនិងការបង្កើត កែប្រែឬលុបពន្ធដារចេញ។

---

[១៨៨] ព្រឹត្តិបត្រ: ស្រាវជ្រាវ លេខ១០១ ខែកុម្ភៈ-មីនា ឆ្នាំ២០០៣ ទំព័រ ១៥-១៩

- ការផ្តល់សេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល។
- ការអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។
- ការអនុម័តច្បាប់ ឬលុបចោលនូវសន្ធិសញ្ញា ឬអនុសញ្ញាជាមួយអន្តរជាតិ។
- ការអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។
- ការបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើន(២/៣)នៃសមាជិករដ្ឋសភាទាំងមូល។
-សិទ្ធិជ្រើសតាំងឥស្សរជនឲ្យធ្វើជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញតាមមតិភាគច្រើនដាច់ខាតនៃសមាជិកសភាទាំងមូល។

រដ្ឋសភា និងអ្នកតំណាងរាស្ត្រគួរតែអនុវត្តឲ្យមានប្រសិទ្ធិភាពខ្ពស់ និងទទួលខុសត្រូវលើការអនុវត្តន៍អំណាចទាំងនេះឲ្យសមស្រប និងបម្រើផលប្រយោជន៍ប្រជាជនជាធំជាងផលប្រយោជន៍បុគ្គល ឬគណបក្សដែលខ្លួនគាំទ្រ ព្រមទាំងប្រកាន់ជំហរអព្យាក្រិត្យ មិនលុះក្រោមសំពាធឥទ្ធិពលរបស់គណបក្សណាឡើយ។

រដ្ឋសភាមានមុខងារនីតិបញ្ញត្តិ(តាមមាត្រា៩០) មុខងារត្រួតពិនិត្យ(តាមមាត្រា ៩៦, ៩៧, ៩៨ និង ១២៦) មុខងារជ្រើសតាំង និងផ្តល់នីត្យានុកូលភាព(មាត្រា ៩០ វាក្យខ័ណ្ឌ៨, មាត្រា១១៩ និងមាត្រា១៣៧ វាក្យខ័ណ្ឌ១) មុខងារជាវេទិការសាធារណៈ នៃការបង្កើតធន្ទះនយោបាយ(មាត្រា៥១, ៧៧, ៨០, ៨៨, ៨៩, ៩៦, ៩៧ និង៩៨) [១៨៩]។

## ក.ការធានាឲ្យមានតម្លាភាពក្នុងការតាក់តែង និងការអនុម័តច្បាប់

សភាត្រូវបង្កើតវេទិការសេរីជូនប្រជាពលរដ្ឋឲ្យបញ្ចេញមតិ យោបល់ផុសផុលលើពង្រាងច្បាប់មុននឹងអនុម័ត។ ក្នុងការអនុម័ត ត្រូវចាប់អារម្មណ៍លើមតិប្រឆាំងជំទាស់ និងថ្លឹងថ្លែងឲ្យគ្រប់ជ្រុងជ្រោយដោយគតិបណ្ឌិត។ ច្បាប់ល្អ មានពាក្យពេចន៍ងាយយល់ច្បាស់លាស់ ហើយពាក្យគន្លឹះនីមួយៗមាននិយមន័យច្បាស់លាស់ ព្រមទាំងបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅ។ ចាប់តាំងពីបង្កើតរដ្ឋាភិបាល និងរដ្ឋសភាថ្មីរួមមក ឃើញថា រដ្ឋសភាបានអនុម័តច្បាប់សំខាន់ៗរួចហើយ ដូចជា ក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ច្បាប់បាតុកម្មច្បាប់ អំពើហិង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំង នឹងការជួញដូរមនុស្ស និងច្បាប់ស្តីពីសេរីភាពសារព័ត៌មាន។

## ខ.ការធានាឲ្យមានភាពសុច្ចរិត និងស្អាតស្អំក្នុងសង្គម

រដ្ឋសភា ត្រូវរៀបចំឲ្យមានក្រមសីលធម៌ រៀបចំឲ្យមានស្ថាប័នឃ្លាំមើលឯករាជ្យ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋសភាផ្ទាល់ ដូចជា ស្ថាប័នអគ្គសវនកម្ម គណៈកម្មាធិការជាតិទប់ស្កាត់អំពើពុករលួយ និងគណៈកម្មាធិការជាតិទទួលពាក្យបណ្តឹងសារទុក្ខ ដើម្បីរាយការណ៍ជូនរដ្ឋសភា។ ពុំនោះទេរដ្ឋសភាពុំអាចមានប្រសិទ្ធិភាពក្នុងការស្រាវជ្រាវរកភាពអសកម្មនិងភាពមិនប្រក្រតីរបស់ស្ថាប័ននីតិប្រតិបត្តិបានឡើយ។

---

[១៨៩] ព្រះរាជាណាចក្រកម្ពុជាៈ រដ្ឋធម្មនុញ្ញ ជំពូក៤, ជំពូក៧, ជំពូក១០, និងជំពូក១២ ឆ្នាំ១៩៩២ ទំព័រ ២៩,៤១, ៤៣,៤៩, ៥០, ៥៥, ៦៩, ៧០,៧២,៧៣, និង៧៧-៧៨

## គ-ការគោរពតាមសំណូមពររបស់ម្ចាស់

មាត្រា៧៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា តំណាងរាស្ត្រក្នុងរដ្ឋសភាគឺជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនប៉ុណ្ណោះទេ។ តំណាងរាស្ត្រត្រូវចុះសួរសុខទុក្ខរាស្ត្រយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅ និងមតិយោបល់របស់រាស្ត្រតាមមណ្ឌល ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពប្រជាជន ពិសេសតំបន់ដាច់ស្រយាល និងតំបន់ជាយដែន។

សភាជាតិអ្នកត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និងសកម្មភាពរបស់រាជរដ្ឋាភិបាល។ រដ្ឋធម្មនុញ្ញតម្រូវឲ្យអនុម័តច្បាប់ថវិកាជាតិ ផែនការរដ្ឋ ច្បាប់សារពើពន្ធ ការឲ្យរដ្ឋឲ្យប្រាក់ខ្ចី ការសន្យា ផ្នែកហិរញ្ញវត្ថុនានា គណនីការកែប្រែឬលប់ចោលនូវពន្ធដារនិងតម្រូវឲ្យរដ្ឋសភា ការអនុម័តយល់ព្រម ឬលប់ចោល នូវសន្ធិសញ្ញា អនុសញ្ញា ឬកតិកាសញ្ញាអន្តរជាតិ អនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម អនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។ រដ្ឋសភាត្រួតពិនិត្យសកម្មភាពរបស់រាជរដ្ឋាភិបាល តែកន្លងមកមិនឃើញមានប្រតិកម្មចំពោះលិខិតបទដ្ឋានគតិយុត្ត ដែលចេញដោយរដ្ឋាភិបាល ហើយអនុវត្តមិនបានត្រឹមត្រូវទេ ពិសេសការតែងតាំងមន្ត្រីរាជការ ការអនុវត្តន៍ច្បាប់ព្រៃឈើ...។

តាមគោលការណ៍ ១/៤ នៃចំនួនសមាជិកសភាទាំងអស់ សមាជិកសភាមានសិទ្ធិៈ

- អញ្ជើញឥស្សរជន ឬរដ្ឋមន្ត្រីណាមួយឲ្យមកឆ្លើយបំភ្លឺអំពីបញ្ហាសំខាន់ៗដែលសភាចង់ដឹង។
- អញ្ជើញឥស្សរជន ឬរដ្ឋមន្ត្រីណាមួយឲ្យមកធ្វើការសាកសួរឲ្យឆ្លើយបំភ្លឺអំពីបញ្ហាសំខាន់ណាមួយ ដែលពាក់ព័ន្ធនឹងវិស័យដែលខ្លួនទទួលខុសត្រូវ។

រដ្ឋសភាមានសិទ្ធិអាចរំលាយរដ្ឋាភិបាល អាចបណ្តេញសមាជិកណាមួយ នៃរដ្ឋាភិបាលតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញត្រង់មាត្រា៩៧ ។ រដ្ឋសភាអាចអនុម័តយល់ព្រម ឬមិនយល់ព្រមដោយសំឡេងឆ្នោតភាគច្រើននៃចំនួនសមាជិកសភាទាំងមូល លើការតែងតាំងមន្ត្រីជាន់ខ្ពស់របស់រដ្ឋ ដូចជាការតែងតាំងប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ៣រូប...។ តែក៏អាចបណ្តេញមន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលស៊ីវិល ដូចជាសមាជិកសភាចំនួន ១/៤ បានធ្វើបញ្ញត្តិសុំដកហូតតំណែង និងផ្តន្ទាទោសតាមច្បាប់ចំពោះឯកឧត្តម សូម៉ារ៉ា អគ្គនាយកក្រសួងទេសចរណ៍ពីបទលួចចុះហត្ថលេខាកាលពីដើមខែមិថុនា ឆ្នាំ២០០១ ប្រគល់ប្រាសាទព្រះវិហារដែលជាសម្បត្តិមរតកវប្បធម៌ដ៏មានតម្លៃរបស់ជាតិ ខ្មែរឲ្យបរទេសរកស៊ីខុសច្បាប់ធ្វើជូនសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា។ ក្រោយមកមានព្រះរាជក្រឹត ដកតំណែងអគ្គនាយកពីឯកឧត្តម សូម៉ារ៉ា តាមសំណើរបស់ប្រមុខរដ្ឋាភិបាល។ មួយទៀតសំណើសុំ រដ្ឋសភា អនុម័តតែងតាំងអគ្គសវនករ៣រូប របស់នាយករដ្ឋមន្ត្រីត្រូវបានធ្វើឡើង ៣លើកទើបបានសម្រេចដោយសំឡេង ២/៣ និងដោយព្រះរាជក្រឹត្យ។

ដោយឡែកមាត្រា៩៦ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថា តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រដ្ឋាភិបាល។ សំណួរនេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។

ចម្លើយអាចធ្វើឡើយដោយ រដ្ឋមន្ត្រីមួយរូបឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ រដ្ឋមន្ត្រីមួយរូបឬច្រើនរូប បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាលនាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។

ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ។

ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីបានទទួលសំណួរ។

យើងឃើញថា មានការខ្វះចន្លោះ មិនឃើញបញ្ញត្តិអំពីស្ថានទម្ងន់ទណ្ឌកម្មបែបណានៅឡើយទេ ចំពោះការគេចវេះ ឬព្រងើយកន្តើយមិនព្រមឆ្លើយ ឬឆ្លើយមិនទាន់តាមការកំណត់របស់រដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី។ ដូច្នេះ ត្រូវបញ្ញត្តិច្បាប់ស្តីពីការដាក់ទណ្ឌកម្មចំពោះរដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី ដែលមិនព្រមឆ្លើយឬឆ្លើយមិនគោរពតាមការកំណត់រយៈពេលរបស់មាត្រា៩៦នេះទើបរក្សាប្រសិទ្ធិភាពរបស់រដ្ឋសភា និងមានការទទួលខុសត្រូវចំពោះរដ្ឋសភានៃសមាជិកគណៈរដ្ឋមន្ត្រី។

### ឃ.អភ័យឯកសិទ្ធិរដ្ឋសភា

អភ័យឯកសិទ្ធិសភា គឺជារបាំងការពារទប់ទល់នឹងការអង្កេតព្រហ្មទណ្ឌចំពោះអ្នកតំណាងរាស្ត្រ។ អភ័យឯកសិទ្ធិសភា ដែលមានតួនាទីទប់ស្កាត់ការចោទប្រកាន់ ការចាប់ឃាត់ ឬឃុំខ្លួនអ្នកតំណាងរាស្ត្រណាម្នាក់ដែលបានសម្តែងមតិយោបល់ក្នុងអាណត្តិ ត្រូវបានរដ្ឋធម្មនុញ្ញផ្តល់ជូនគ្រប់អ្នកតំណាងរាស្ត្រ(វាក្យខ័ណ្ឌ ១ និង២ នៃមាត្រា៨០)។ អភ័យឯកសិទ្ធិសភា ការពារដល់ដំណើរការនៃមុខងាររបស់រដ្ឋសភា និងជាបុព្វសិទ្ធិរបស់រដ្ឋសភា(វាក្យខ័ណ្ឌ៣និង៤ មាត្រា៨០នៃរដ្ឋធម្មនុញ្ញ) លើកលែងតែបទល្មើសធ្ងន់ធ្ងរជាក់ស្តែងរបស់អ្នកតំណាងរាស្ត្រ ដែលមុននឹងត្រូវទទួលការចោទប្រកាន់តាមផ្លូវតុលាការ ឬមុននឹងត្រូវចាប់ខ្លួននោះ លុះត្រាតែអ្នកតំណាងរាស្ត្រនោះត្រូវបានសភាដកអភ័យឯកសិទ្ធិលើសម្លេងភាគច្រើន២/៣ នៃចំនួនសមាជិកសភាទាំងមូលជាមុនសិន(វាក្យខ័ណ្ឌ៤ មាត្រា៨០នៃរដ្ឋធម្មនុញ្ញ) ផ្ទុយទៅវិញ រដ្ឋសភាអាចអនុម័តតាមមតិភាគច្រើន ១/៤នៃសមាជិកសភាទាំងមូល សំដៅបញ្ឈប់ការទាមទារធ្វើការចោទប្រកាន់ និងការទទួលខុសត្រូវចំពោះតុលាការព្រមទាំងការចាប់ខ្លួនទៀតផង (វាក្យខ័ណ្ឌ៥ មាត្រា៨០ នៃរដ្ឋធម្មនុញ្ញ) តំណាងរាស្ត្រម្នាក់អស់អភ័យឯកសិទ្ធិមិនមានន័យថា អស់អាណត្តិជាអ្នកតំណាងរាស្ត្រ(សមាជិកភាពរបស់រដ្ឋសភា) នោះទេ[១៥០]។

### ខ.សមាជិកតំណាងរាស្ត្រ

អាណត្តិឯករាជ្យនៃអ្នកតំណាងរាស្ត្រ ប្រឈមនឹងអំពើហួងហែងដែលប្រកាន់ថា ជាកម្មសិទ្ធិរបស់គណបក្ស។ អាណត្តិឯករាជ្យរបស់អ្នកតំណាងរាស្ត្រត្រូវបានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់យ៉ាងពេញលេញ។ មាត្រា៧៧ បានចែងថា តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងប្រជាជាតិទាំងមូល... អាណត្តិអាជ្ញា

---

[១៥០] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក៧ ឆ្នាំ១៩៩៣ ទំព័រ ៤៣

បញ្ហាទាំងឡាយត្រូវទុកជាមោឃៈ។ នេះបញ្ជាក់ថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់គោលការណ៍ប្រជាធិបតេយ្យប្រព័ន្ធសភានិយម ដែលផ្តល់អធិបតេយ្យពេញលេញដល់អ្នកតំណាងរាស្ត្រក្នុងអំណាចនីតិបញ្ញត្តិនៃអង្គការតំណាងរាស្ត្រកំពូលរបស់ជាតិ។ អ្នកតំណាងរាស្ត្រម្នាក់ៗសុទ្ធតែត្រូវបានប្រជារាស្ត្រផ្តល់នីត្យានុកូលភាពបែបប្រជាធិបតេយ្យ តាមរយៈការបោះឆ្នោតដែលបានប្រព្រឹត្តទៅនៅរៀងរាល់ប្រាំឆ្នាំម្តងនៃអាណត្តិរដ្ឋសភា ដូចមានចែងក្នុងមាត្រា៧៦(តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកលដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់)នៃរដ្ឋធម្មនុញ្ញ)។ តាមច្បាប់បោះឆ្នោតមាត្រា៣៧ចែងថា បេក្ខជនតំណាងរាស្ត្រត្រូវរៀបចំចាត់ចែងដោយគណបក្សនីមួយៗ តែប្រជារាស្ត្រជាអ្នកសម្រេចចុងក្រោយ។ តែក្នុងការអនុវត្តន៍ជាក់ស្តែងគណបក្សនីមួយៗតែងចាត់ទុកថា តំណាងរាស្ត្រ គឺជាតំណាងរបស់គណបក្ស។ អាសនៈនៅក្នុងរដ្ឋសភាជាអាសនៈរបស់គណបក្ស និងជាតំណាងរាស្ត្ររបស់គណបក្ស ដែលអាចចាត់ចែងបញ្ជា បានតាមទំនើងចិត្ត(ដូចប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីថ្លែងក្នុងឱកាសបើការដ្ឋានជារាសាស្ត្រនៅក្នុងស្រុកពញាឮថា... បើគណបក្សប្រជាជនមិនបោះឆ្នោតឲ្យ តើធ្វើម៉េចនឹងបានប្រធាន អនុប្រធានរដ្ឋសភា...)។ ការពិតពេលកំពុងកាន់តំណែងក្នុងអាណត្តិជាអ្នកតំណាងរាស្ត្រដាច់ខាតមិនអាចបាត់បង់សមាជិកភាពជាអ្នកតំណាងរាស្ត្រឡើយ បើទោះបីមានការបណ្តេញចេញ ឬតាមការលាលែងពីគណបក្សដើមក៏ដោយ។ ដូច្នេះ អាណត្តិអ្នកតំណាងរាស្ត្រ មិនអាចប៉ះពាល់បានឡើយ។ លើសពីនេះទៀត គ្មានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តណាមួយ អាចអនុញ្ញាតឲ្យធ្វើការទាមទារយកអាណត្តិពីអ្នកតំណាងរាស្ត្រនោះដែរ។ ប៉ុន្តែបើមានវិញ បទបញ្ញត្តិនោះគ្មានធម្មនុញ្ញភាពទេ។ ដូច្នេះ ទង្វើដកហូត ដោះដូរអាណត្តិពីអ្នកតំណាងរាស្ត្រ ដោយមូលហេតុណាមួយ ក៏ជាទង្វើផ្ទុយនឹងរដ្ឋធម្មនុញ្ញទាំងស្រុងដែរ លើកលែងតែករណីដែលអ្នកតំណាងរាស្ត្រនោះទទួលមរណភាព ឬស្ម័គ្រចិត្តប្រកាសប្រគល់អាសនៈ របស់ខ្លួនជូនទៅគណបក្សដើមដែលគាត់បានឈរឈ្មោះក្នុងបញ្ជីបោះឆ្នោតវិញ។ តែទោះជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាសីលធម៌ប៉ុណ្ណោះ ពុំមែនជាកាតព្វកិច្ចខាងផ្លូវច្បាប់ណាមួយទេ។ ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក៏ពុំមានចែងអំពីការបោះឆ្នោតដកហូតអាណត្តិពីអ្នកតំណាងរាស្ត្រដែរ។ អាណត្តិបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ។ អ្នកតំណាងរាស្ត្រ ដែលមិនស្ថិតនៅក្រោមបញ្ជាណាមួយឡើយ អាស្រ័យលើស្មារតីស្វ័យសម្រេចរបស់ខ្លួនសូម្បីតែប្រជារាស្ត្រ ដែលជាម្ចាស់ឆ្នោតក៏មិនមានសិទ្ធិអ្វីទៅបញ្ជាអ្នកតំណាងរាស្ត្រដែរ។ គោលការណ៍អាណត្តិ ឯករាជ្យនៃអ្នកតំណាងរាស្ត្រ ដែលចែងជាធម្មនុញ្ញបញ្ញត្តិក្នុងមាត្រា៧៧ គឺជាកត្តាចាំបាច់បំផុតសម្រាប់ការពារឲ្យអ្នកតំណាងរាស្ត្រមានអធិបតេយ្យភាព និងសេរីភាពគ្រប់គ្រាន់ពេញលេញក្នុងការសម្តែងឆន្ទៈដោយវាចា ឬជាលាយលក្ខណ៍អក្សរ និងធ្វើសកម្មភាពបំពេញការងារនៃអំណាចនីតិបញ្ញត្តិក្នុងអាណត្តិរបស់ខ្លួន ដែលជាអ្នកតំណាងឲ្យប្រជារាស្ត្រទាំងមូល។ ជាងនេះទៀត អាណត្តិឯករាជ្យបានផ្តល់សុវត្ថិភាពជូនអ្នកតំណាងរាស្ត្រឲ្យជៀសផុតពីការភ័យខ្លាច បាត់បង់អាណត្តិចំពោះមុខ ការគាបសង្កត់ ការបង្ខិតបង្ខំ គំរាមកំហែងតាមគ្រប់រូបភាព។ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ទាមទារឲ្យអនុវត្តគោលការណ៍នេះដោយគោរពចំពោះអ្នកតំណាងរាស្ត្រ និង

រដ្ឋសភា ដែលជាអង្គការតំណាងរាស្ត្រដ៏កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ពុំនោះទេវានឹងនាំដល់បច្ច័យអវិជ្ជមាន(បង្វែរឲ្យឃ្លាតឆ្ងាយពីគន្លងប្រជាធិបតេយ្យ) ដល់ដំណើរការប្រជាធិបតេយ្យនីយកម្ម ការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ និងឯកភាពជាតិ ដែលទាមទារយកគន្លងប្រជាធិបតេយ្យ និងគំនិតពហុភាព និយមធ្វើជាមូលដ្ឋានគ្រឹះ[១៩១]។

អនុលោមតាមរដ្ឋធម្មនុញ្ញប្រព័ន្ធគ្រប់គ្រងរដ្ឋរបស់កម្ពុជា គឺអនុវត្តតាមបែបប្រជាធិបតេយ្យសភានិយម។ រដ្ឋសភា គឺជាមជ្ឈមណ្ឌលនៃតំណាងឆន្ទៈនយោបាយចម្រុះរបស់សង្គមជាតិ។ ដំណើរការនៃការបង្កើតឆន្ទៈនយោបាយគ្រប់គ្រងរដ្ឋ តាមរយៈរដ្ឋសភាដែលជាអង្គការកំពូលថ្នាក់ជាតិ មានន័យថា រដ្ឋសភា មានមុខងារជាវេទិកាកំពូលរបស់ជាតិសម្រាប់ដំណើរការបង្កើតឆន្ទៈរដ្ឋ។ ការបង្កើតឆន្ទៈរដ្ឋសំដៅដល់ការជជែកដេញដោលវែកញែកអំពីនយោបាយអភិវឌ្ឍគ្រប់វិស័យ ដោយរាប់បញ្ចូលទាំងវឌ្ឍនភាពនៃដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម ដំណើរស្ថាបនានីតិរដ្ឋ ការលើកស្ទួយគោរពសិទ្ធិសេរីភាពពលរដ្ឋ និងសិទ្ធិបុគ្គល យុត្តិធម៌សង្គម វឌ្ឍនភាពនៃនយោបាយសេដ្ឋកិច្ចទីផ្សារសេរី។ល។ ដែលចុងក្រោយត្រូវបានរដ្ឋសភាអនុម័តជាច្បាប់ អនុសាសន៍ និងសេចក្តីបង្គាប់នានា ដើម្បីឲ្យដំណើរការអភិវឌ្ឍន៍ប្រទេសឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែងសំដៅកាត់បន្ថយទំនាស់នៃភាពអសកម្ម និងឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍសង្គម។ នៅក្នុងខែកញ្ញា ឆ្នាំ២០០៨ សភាថ្មីបានស្បថចូលកាន់តំណែង គណបក្សប្រជាជនកម្ពុជាបានប្រើអំណាចគ្របសង្កត់លើការយកបទបញ្ជាផ្ទៃក្នុងថ្មីមកអនុម័តសម្រាប់រដ្ឋសភាថ្មីមកប្រើ ទោះបីជាមានការមិនយល់ព្រមពីគណបក្ស-សមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សក៏ដោយ។ តាមមាត្រា៤៨ និងមាត្រា៥៥ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា តម្រូវឲ្យសមាជិករដ្ឋសភាត្រូវអង្គុយ និងរៀបចំជាក្រុម ហើយក្រុមនីមួយៗត្រូវមានសមាជិកយ៉ាងតិចដប់រូបដោយមានប្រធានមួយរូប និងអនុប្រធានមួយរូប។ តំណាងរាស្ត្រមកពីគណបក្សនយោបាយណា ដែលមានអាសនៈតិចជាងដប់ត្រូវតែចូលរួមជាមួយក្រុមណាមួយ។ តំណាងរាស្ត្រមិនអាចបញ្ចេញមតិនៅក្នុងសម័យប្រជុំពេញអង្គបានទេ លុះត្រាតែតំណាងរាស្ត្រជាសមាជិកនៃក្រុមណាមួយ មានបំណងបញ្ចេញមតិត្រូវសុំតាមរយៈប្រធានក្រុមរបស់ខ្លួន ហើយទទួលការអនុញ្ញាតពីប្រធានរដ្ឋសភាជាមុនសិនទើបអាចនិយាយបាន។ បទបញ្ជាទាំងនេះ បានរារាំងតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្សចំនួន៣រូបមិនឲ្យបញ្ចេញមតិនៅក្នុងរដ្ឋសភា ពីព្រោះពួកគេចង់រក្សាភាពឯករាជ្យរបស់ពួកគេមកពីគណបក្សដទៃ។ យើងឃើញថា មាត្រា៤៨ និងមាត្រា៥៥នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានេះ ជារចនាបទដ៏មានទេពកោសល្យកើតចេញពីផ្នត់គំនិតផ្តាច់ការ រើសអើងបក្សពួកនិយមបែបថ្មី នៅក្នុងចរន្តប្រជាធិបតេយ្យ ដើម្បីបំបិតសំឡេងមតិភាគតិចដែលជាតំណាងរាស្ត្រដោយរដ្ឋសភាខ្លួនឯង។ សំណួរសួរថា តើវាចាំបាច់ដែរឬទេ ឬជាបេសកកម្មដ៏ចម្បង ដែលតម្រូវឲ្យសមាជិករដ្ឋសភាត្រូវតែចូលរួមជាក្រុមទើបអាចសម្តែងមតិបាន? ក្នុងគោលការណ៍ប្រជាធិបតេយ្យ

[១៩១] ព្រឹត្តិបត្រៈ អ្នកជា ខែ៦-៧ ឆ្នាំ២០០១ ទំព័រ ២០-២២

តំណាងរាស្ត្រមានសិទ្ធិគ្រប់គ្រាន់ ដើម្បីការពារឯករាជ្យភាព អធិបតេយ្យរបស់ខ្លួន។ បន្ថែមលើសពីនេះច្បាប់លក្ខន្តិកៈសម្រាប់តំណាងរាស្ត្រត្រូវបានអនុម័តថ្មី ដែលស្រដៀងគ្នាទៅនឹងច្បាប់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា(UNTAC)ឆ្នាំ១៩៩២ ដែលត្រូវបានប្រើប្រាស់នៅក្នុងកំឡុងពេលនោះ ដើម្បីឃាត់ខ្លួនអ្នករិះគន់រដ្ឋាភិបាល ដោយចោទប្រកាន់ពីបទព្រហ្មទណ្ឌបរិហាកេរ្តិ៍។ ការអនុវត្តន៍វិធាន លក្ខន្តិកៈតំណាងរាស្ត្រថ្មីនេះគឺផ្ទុយនឹងរដ្ឋធម្មនុញ្ញបានចែងថា តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួនឬឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ទោះបីជាយ៉ាងណា មាត្រា៥នៃច្បាប់ថ្មីបានដកចេញនូវ ការការពារទាំងនោះ គឺប្រសិនបើតំណាងរាស្ត្រណាមួយត្រូវបានរកឃើញថា បានរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់ឯកជនទំនៀមទម្លាប់សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខសង្គមជាតិ ដោយមិនចាំបាច់បញ្ជាក់ពីធម្មនុញ្ញភាព។ ពេលតំណាងរាស្ត្រភ័យខ្លាចចាប់ខ្លួនពួកគេ ត្រូវបានកំណត់ព្រំដែនក្នុងការអនុវត្តន៍កាតព្វកិច្ចរបស់ពួកគេ ដើម្បីសម្តែងទស្សនៈ និងតស៊ូមតិសម្រាប់ផលប្រយោជន៍របស់មណ្ឌលរបស់ពួកគេ។ ទិដ្ឋភាពបែបនេះបណ្តាលឲ្យមានលេចឮមតិទិតៀនជាច្រើនពីប្រជាពលរដ្ឋម្ចាស់អំណាចដោយបានលើកឡើងនិងវាយតម្លៃលើហេតុផលផ្សេងៗគ្នាថារដ្ឋសភា ទន់ខ្សោយរដ្ឋសភា បម្រើគណបក្ស រដ្ឋសភាគ្មានអំណាច រដ្ឋសភាចំណុះរដ្ឋាភិបាល រដ្ឋសភាប្រថាប់ត្រា[១៩២]។ល។ រដ្ឋសភាត្រូវបានប្រជាពលរដ្ឋមើលឃើញជាទូទៅថា ពុំមានជំហររឹងមាំដាច់ចេញពីស្ថាប័នអង្គការរដ្ឋឡើយហើយត្រូវទទួលរងការរំលោភអំណាចពីស្ថាប័ននីតិប្រតិបត្តិ។ ហេតុផលនេះហើយទើបមានការស្រាវជ្រាវដ៏ស៊ីជម្រៅមួយរបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI) បានបង្ហាញថា ឥទ្ធិពលរបស់គណបក្សនយោបាយ និងអំណាចរដ្ឋាភិបាល បានរុញច្រានឲ្យរដ្ឋសភាកម្ពុជាទន់ខ្សោយ និងបាត់បង់ឯករាជ្យភាពរបស់ខ្លួន។ របាយការណ៍ស្រាវជ្រាវស្តីពីការអភិវឌ្ឍន៍ ប្រចាំឆ្នាំ២០០៩ និង២០១០ របស់វិទ្យាស្ថាន (CDRI) ដែលទើបផ្សព្វផ្សាយជាសាធារណៈថាសមាជិកសភា ពុំទាន់មានសមត្ថភាពអនុវត្តតួនាទីរបស់ខ្លួនបានឯករាជ្យ និងមានប្រសិទ្ធិភាពនោះទេ ដោយសារតែពួកគេត្រូវប្រឈមមុខទៅនឹងអំណាចនីតិប្រតិបត្តិផង និងអំណាចគណបក្សនយោបាយរបស់ពួកគេផង បើទោះបីជាសមាជិកសភាទាំងនោះបានដឹងច្បាស់អំពីតួនាទីរបស់ពួកគេស្តីអំពីមុខងារជាតំណាងរបស់ប្រជាជនជាអ្នកតាក់តែងច្បាប់ និងមុខងារជាអ្នកតាមដានត្រួតពិនិត្យសកម្មភាពរបស់អំណាចនីតិប្រតិបត្តិ ឬរដ្ឋាភិបាលក៏ដោយ។ លើសពីនេះតាមការស្រាវជ្រាវរបស់វិទ្យាស្ថាន (CDRI) បានលើកឡើងថា ប្រសិទ្ធិភាពបង្កើតច្បាប់របស់រដ្ឋសភាកម្ពុជាមានកម្រិតទាប ត្បិតរដ្ឋាភិបាល គឺជាអ្នកក្តោបក្តាប់ផ្តាប់មុខ លើការផ្តួចផ្តើមគំនិតតាក់តែងច្បាប់ ហើយសមាជិករដ្ឋសភាត្រូវគោរពតាមសេចក្តីព្រាងច្បាប់ដែលរៀបចំដោយរដ្ឋាភិបាលផង[១៩៣]។ ម្យ៉ាងវិញទៀត សមាជិកសភាខ្លួនឯងក៏ខ្វះសមត្ថភាពធ្វើសេចក្តីព្រាងច្បាប់ និងវិភាគច្បាប់ដែរ។ ទន្ទឹមនោះរបាយការណ៍ដដែលនេះបានរកឃើញ ទៀតថា សមាជិកសភាមានលទ្ធភាព

---

[១៩២] ឈឹម ផលវរុណៈ ស្វែងយល់ពីរបបគ្រប់គ្រងបែបប្រជាធិបតេយ្យសេរីពហុបក្ស ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ ៨១

[១៩៣] ការផ្សាយរបស់វិទ្យុសំលេងសហរដ្ឋអាមេរិក( V.O.A. ) ព្រឹកថ្ងៃទី២៨ ខែ មីនា ឆ្នាំ២០១០ ម៉ោងនៅកម្ពុជា

តិចតួចណាស់ក្នុងការទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋ ជាអ្នកបោះឆ្នោតឲ្យខ្លួនព្រោះពួកគេស្ថិតក្រោមសម្ពាធនយោបាយយ៉ាងខ្លាំង ដែលតម្រូវឲ្យសមាជិកសភាទាំងនោះ គិតពីផលប្រយោជន៍គណបក្សរបស់ពួកគេច្រើនជាងប្រជារាស្ត្រម្ចាស់ឆ្នោត ម្ចាស់អំណាច។ បន្ថែមពីលើនេះការត្រួតពិនិត្យរបស់សភាទៅសកម្មភាពរបស់អំណាចនីតិប្រតិបត្តិនៅមានភាពទន់ខ្សោយបំផុត។ លោក សុន ឆ័យ សមាជិក សភាមកពីគណបក្សជំទាស់សម រង្ស៊ី បានគាំទ្រចំពោះការរកឃើញរបស់របាយការណ៍នេះ។ លោកបានលើកឡើងថា នេះជាការរកឃើញត្រឹមត្រូវ ព្រោះយើងជាសមាជិកសភាបានរងគ្រោះការលំបាកច្រើនឆ្នាំមកហើយ យើងមើលឃើញនីតិវិធីជាច្រើនដែលពុំផ្តល់សិទ្ធិមកដល់អ្នកតំណាងរាស្ត្រ បំបិទសិទ្ធិអ្នកតំណាងរាស្ត្រមិនឲ្យសួរ។ ហើយការចុះទៅធ្វើការតាមមូលដ្ឋាន មន្ត្រីមូលដ្ឋានគេមិនគិតរវីរវល់ជាមួយអ្នកតំណាងរាស្ត្រទេ គេអាងអំណាចនីតិប្រតិបត្តិរបស់គេ[១៩៤]។ លោក ជាម យៀប តំណាងរាស្ត្រមកពីគណបក្សកាន់អំណាច(គណបក្សប្រជាជនកម្ពុជា)និងជាប្រធានគណៈកម្មាធិការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភាបានច្រានចោល លទ្ធផលស្រាវជ្រាវដែលថា សមាជិកសភាស្ថិតក្រោមអំណាចនីតិប្រតិបត្តិដែលរាំងខ្ទប់ពួកគេក្នុងការបំពេញតួនាទី ដោយឯករាជ្យ ប៉ុន្តែលោក ជាម យៀប ទទួលស្គាល់ថា សមាជិកសភាចាំបាច់ត្រូវគិតពីផលប្រយោជន៍របស់គណបក្សនយោបាយរៀងៗខ្លួន។ ការរៀបចំសមាសភាពនៃមន្ត្រីរាជការ គណបក្សជាអ្នករៀបចំ ទោះបីយ៉ាងណាត្រូវស្តាប់គណបក្សរបស់គេដែរ មិនអាចលះបង់ចោលទៅធ្វើការងារឯកោ មិនស្តាប់គណបក្សនោះទេ គឺត្រូវការពារ គណបក្ស ចុះបើរឹងទទឹងមិនយកចិត្តទុកដាក់នឹងគណបក្សទៅធ្វើអ្វីទៀត? ជាមួយគ្នានោះ ដែរលោក ជាម យៀប ក៏បានទទួលស្គាល់ផងដែរ ចំពោះការខ្វះសមត្ថភាពរបស់អ្នកតំណាងរាស្ត្រ ក្នុងការធ្វើសេចក្តីព្រាងច្បាប់ ឬវិភាគ ច្បាប់ដោយលោកមានប្រសាសន៍ថា សមាជិកសភានីមួយៗមានសមត្ថភាពខុសៗគ្នា ហើយមិនមានសមាជិកសភាទាំងអស់សុទ្ធតែអាចបង្កើតច្បាប់បាននោះទេ។ យ៉ាងណាក៏ដោយលោក ធន់ សារាយ ប្រធានសមាគមការពារសិទ្ធិមនុស្សអាដហុកដែលឃ្លាំមើលសកម្មភាពរបស់សភា បានយល់ស្របទៅតាមលទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថានCDRI ហើយលោកធ្វើអធិប្បាយទាក់ទងទៅនឹងភាពទន់ខ្សោយរបស់សភាថា ខ្លឹមសារធំៗ ខ្លះសភាមិនហ៊ានប៉ះទេ ត្រូវតែបញ្ជូនមកអំណាចនីតិប្រតិបត្តិវិញ ដើម្បីសុំយោបល់ក្នុងការកែប្រែវិញ ដែលខុសពីតួនាទីសភា ដែលមានសិទ្ធិអំណាចក្នុងការធ្វើពង្រាងដោយខ្លួនឯងបាននិងអាចធ្វើការកែប្រែនៃពង្រាងច្បាប់ ដែលអំណាចនីតិប្រតិបត្តិបញ្ជូនមក ដោយមិនចាំបាច់ធ្វើពង្រាងនេះទៅវិញ។ រដ្ឋសភាកម្ពុជា មានសមាជិកពហុបក្សជាថ្មីចាប់តាំងពីការ បោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំដោយអង្គការសហប្រជាជាតិ។

នាពេលបច្ចុប្បន្ននេះ សមាជិករដ្ឋសភាកម្ពុជាមានចំនួន១២៣នាក់ ចេញមកពីគណបក្សនយោបាយចំនួនប្រាំរួមមាន សមាជិកមកពីគណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តមរណឫទ្ធិ។ របាយការណ៍អភិវឌ្ឍប្រចាំឆ្នាំ២០០៩-២០១០ របស់វិទ្យាស្ថាន

---

[១៩៤] V.O.A. បទសម្ភាសន៍ ឯកឧត្តមសុន ឆ័យ ព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១០ ម៉ោងនៅកម្ពុជា

CDRI បានលើកឡើងថា ចាប់តាំងពីឆ្នាំ១៩៩៣មកម្លេះ សមាជិកសភាកម្ពុជាទាំងមកពីគណបក្សកាន់អំណាច និងគណបក្សប្រឆាំង មិនបានទទួលការការពារគ្រប់គ្រាន់ ដើម្បីធ្វើការដោយឯករាជ្យបានឡើយ ផ្ទុយទៅវិញ ប្រសិនបើសមាជិកសភាធ្វើសកម្មភាពណាមួយដែលគេយល់ថា នាំឲ្យខូចខាតដល់ផលប្រយោជន៍របស់គណបក្ស ឬប៉ះពាល់ដល់មន្ត្រីនៃអំណាចនីតិប្រតិបត្តិ នោះពួកគេនឹងមិនត្រូវបានគេអត់ឲ្យឡើយ។ ប្រការនេះបានធ្វើឲ្យសមាជិកសភាមានការភ័យខ្លាច ហើយត្រូវប្រតិបត្តិតាមគណបក្សរបស់ខ្លួន និងស្ថាប័ននីតិប្រតិបត្តិដ៏មានអំណាច។ ប៉ុន្តែលោកសុន ឆ័យ បាននិយាយថា គណបក្សរបស់លោកមិនធ្លាប់ដាក់ការគាបសង្កត់ណាមួយមកលើសកម្មភាពការងាររបស់សមាជិកសភាឡើយ ក៏ប៉ុន្តែលោកទទួលស្គាល់ថា ការបំពេញតួនាទីរបស់សមាជិកសភាមកពីគណបក្សប្រឆាំង ដើម្បីការពារផលប្រយោជន៍ប្រជាពលរដ្ឋស្ថិតក្នុងកម្រិតតិចតួចប៉ុណ្ណោះ ដោយសារតែសំណើភាគច្រើនរបស់គណបក្សប្រឆាំងត្រូវអង្គសភាទាត់ចោល។ ក្រៅពីនេះការលើកឡើងពីទំនាក់ទំនងរដ្ឋសភានិងរដ្ឋាភិបាល របាយការណ៍ដដែលក៏បានគូសបញ្ជាក់ផងដែរអំពីទំនាក់ទំនងរវាងរដ្ឋសភា និងសង្គមស៊ីវិល មានសារៈសំខាន់បំផុត ដើម្បីភ្ជាប់គម្លាតរវាងអំណាចនីតិប្រតិបត្តិ និងប្រជាពលរដ្ឋ។ អង្គការសង្គមស៊ីវិលគឺជាស្ថាប័នស្ថិតនៅចន្លោះរដ្ឋនិងប្រជាពលរដ្ឋ ដែលមានមុខងារពិនិត្យលំអិតពីអំណាចរបស់រដ្ឋ ដើម្បីការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ ប៉ុន្តែការស្រាវជ្រាវរបស់វិទ្យាស្ថាន(CDRI) បានរកឃើញថា រដ្ឋសភានិងស្ថាប័នសង្គមស៊ីវិលមានទំនាក់ទំនងគ្នាតិចតួចប៉ុណ្ណោះ ដោយសារតែសមាជិកសភាខ្វះគំនិតផ្តួចផ្តើមក្នុងការចូលរួមពាក់ព័ន្ធជាមួយសង្គមស៊ីវិល ត្បិតពួកគេទទួលសម្ពាធពីគណបក្សនយោបាយ ខណៈដែលសង្គមស៊ីវិលខ្លួនឯងនៅមានភាពទន់ខ្សោយនិងជួបបញ្ហាផ្ទៃក្នុង។ លទ្ធផលអង្កេតរបស់វិទ្យាស្ថាន(CDRI) បានបង្ហាថា មានអង្គការសង្គមស៊ីវិលតែ២១% ក្នុងចំណោមអង្គការសង្គមស៊ីវិលចំនួន១១៦ ដែលតំណាងឲ្យប្រជាពលរដ្ឋ ៣០% នៃចំនួនប្រជាពលរដ្ឋសរុប១៤លាននាក់ មានទំនាក់ទំនងជាមួយសមាជិកសភា។ លោក ឈិត សំអាត នាយកប្រតិបត្តិអង្គការ NGO FORUM បាននិយាយថា ជាទូទៅគ្រប់អង្គការទាំងអស់ តែងតែចង់មានទំនាក់ទំនងជាមួយសភា ប៉ុន្តែលទ្ធផលជាវិជ្ជមានដែលទទួលបានគឺតិចតួច[១៥៥]។

ជាទូទៅប្រជាពលរដ្ឋខ្មែរតែងចោទសួរថា បើរដ្ឋាភិបាល ឬអាជ្ញាធរអនុវត្តពុំត្រឹមត្រូវតាមច្បាប់ ឬមិន

គោរពតាមគោលការណ៍ប្រជាធិបតេយ្យសេរី តើរដ្ឋសភាមានសិទ្ធិអំណាចអ្វីមកលើរដ្ឋាភិបាល? អនុលោមតាមរដ្ឋធម្មនុញ្ញ រដ្ឋសភាខ្មែរឃើញថា រដ្ឋសភាមានសិទ្ធិអំណាចពេញលេញ និងគ្រប់គ្រាន់សម្រាប់បំពេញមុខងាររបស់ខ្លួន។ ប៉ុន្តែបញ្ហាស្ថិតនៅត្រង់ថា តើរដ្ឋសភាខ្លួនឯង ក៏ដូចជាអ្នកតំណាងរាស្ត្រម្នាក់ៗហ៊ានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដែរឬទេ។ ជាក់ស្តែងកន្លងមកនៅក្នុងសភាខ្មែរ យន្តការត្រួតពិនិត្យអំណាចរដ្ឋាភិបាលតាមរយៈវេទិការរដ្ឋសភា ដែលជាមជ្ឈមណ្ឌលប្រជាធិបតេយ្យ ពុំទាន់ដំណើរការទៅតាមខ្លឹមសារជាសារវ័ន្តពីប្រជាធិបតេយ្យនៅឡើយទេ។ ដូចជាសមាជិករដ្ឋសភាមានសិទ្ធិអំណាចក្នុងការតាំងសំណួរ និងកោះ

[១៥៥] ការផ្សាយរបស់វិទ្យុសំឡេងសហរដ្ឋអាមេរិក(V.O.A) ព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១០ ម៉ោងនៅកម្ពុជា

អញ្ជើញនាយករដ្ឋមន្ត្រី ឬសមាជិករាជរដ្ឋាភិបាល អនុលោមតាមមាត្រា៩៦ នៃរដ្ឋធម្មនុញ្ញក៏ពុំទាន់ឃើញរដ្ឋសភាហ៊ានអនុវត្តសិទ្ធិអំណាចដ៏សំខាន់នេះនៅឡើយដែរ។ ក្នុងក្របខ័ណ្ឌនៃរបបគ្រប់គ្រងរបបប្រជាធិបតេយ្យសភានិយម សិទ្ធិអំណាចនេះ ផ្តល់ជូនអ្នកតំណាងរាស្ត្រក្នុងការតតាំងនឹងអំណាចនីតិប្រតិបត្តិ ជាពិសេសតតាំងនឹងនាយករដ្ឋមន្ត្រី ពាក់ព័ន្ធបញ្ហាទទួលខុសត្រូវលើនយោបាយរួមរបស់រដ្ឋាភិបាល ក៏ដូចជាតតាំងនឹងរដ្ឋមន្ត្រីពាក់ព័ន្ធនឹងបញ្ហាទទួលខុសត្រូវរបស់ក្រសួងនីមួយៗ។ ការប្រើប្រាស់សិទ្ធិអំណាចនេះក្នុងរបបសភានិយម គឺជាលក្ខខណ្ឌចាំបាច់ ដើម្បីតម្រូវឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះរដ្ឋសភា។ វេទិការបែបនេះ គឺជាព្រឹត្តិការណ៍នយោបាយសំខាន់ណាស់ក្នុងរបបប្រជាធិបតេយ្យសភានិយម ដែលជាការផ្តល់ឱកាសដល់ប្រជាពលរដ្ឋម្ចាស់ឆ្នោត ម្ចាស់អំណាច ពិនិត្យមើលសេចក្តីក្លាហានរបស់អ្នកតំណាងរាស្ត្រក្នុងការបំពេញតួនាទីនិងកាតព្វកិច្ចក្នុងអាណត្តិរបស់ខ្លួន។ ជាពិសេសប្រើអំណាចរបស់ខ្លួនក្នុងការដាក់សម្ពាធទៅលើរដ្ឋាភិបាលឲ្យគិតគូរ និងយកចិត្តទុកដាក់ដល់ជីវភាពរស់នៅប្រចាំរបស់ប្រជាពលរដ្ឋ និងនយោបាយអភិវឌ្ឍប្រទេសជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គមជាតិ ក្នុងនាមជាអ្នកបម្រើប្រជាពលរដ្ឋជាម្ចាស់អំណាច។ តាមរយៈទិដ្ឋភាពនៃវេទិការចោទសួរដេញដោលរវាងអ្នកតំណាងរាស្ត្រ និងរដ្ឋាភិបាលនេះ គឺជាទម្លាប់ ឬជាវប្បធម៌មិនអាចខ្វះបានដាច់ខាតក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីឲ្យប្រជាពលរដ្ឋមើលឃើញនិងវិនិច្ឆ័យថា តើរដ្ឋសភាពិតជាមានសិទ្ធិអំណាចដូចមានចែងក្នុងរដ្ឋធម្មនុញ្ញដែរឬទេ? តាមការពិតចាប់តាំងពីឆ្នាំ១៩៩៣មកទល់នឹងបច្ចុប្បន្ននេះ រដ្ឋសភាខ្មែរពុំទាន់មានសិទ្ធិអំណាច ជាក់ស្តែងដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីគាបសង្កត់រដ្ឋាភិបាលនៅពេលដែលរដ្ឋាភិបាល ឬមន្ត្រីរដ្ឋាភិបាល ដែលបានធ្វើឲ្យមានកំហុសឆ្គងក្នុងការបំពេញការងាររបស់ខ្លួនឲ្យមកទទួលខុសត្រូវចំពោះរដ្ឋសភាឡើយ។ រដ្ឋសភាកម្ពុជាទទួលរងឥទ្ធិពលគាបសង្កត់អំណាចពីនីតិប្រតិបត្តិដោយសារស្ថាប័ននីតិប្រតិបត្តិឬាមយកអំណាចស្ទើរតែទាំងស្រុងមកគ្រប់គ្រង។ ដូច្នេះធ្វើឲ្យរដ្ឋសភាពុំមានទម្ងន់នយោបាយមកលើសមាជិករដ្ឋាភិបាលឡើយ ដែលជាអង្គហេតុធ្វើឲ្យសមាជិករដ្ឋសភាខ្មែរដែលតំណាងឲ្យអំណាចរបស់ប្រជាពលរដ្ឋ មិនហ៊ានយកវេទិការនយោបាយដដែកដេញដោលតតាំងគ្នាជាដុំកំភួន ដើម្បីបង្ហាញអំពីឥទ្ធិពល ឬសិទ្ធិអំណាចរបស់ខ្លួនជំរុញឲ្យរដ្ឋាភិបាលរិះរកមធ្យោបាយដោះស្រាយបញ្ហានានាដែលកើតមានក្នុងសង្គមខ្មែរឡើយ។ រូបភាពបែបនេះ បញ្ជាក់ឲ្យឃើញថា វប្បធម៌ប្រជាធិបតេយ្យក្នុងការតស៊ូមតិខាងនយោបាយ ពុំទាន់មានលក្ខណៈទូលំទូលាយនៅឡើយនៅកម្ពុជា ដែលផ្ទុយទៅនឹងគោលការណ៍ចម្បងរបស់របបគ្រប់គ្រងប្រជាធិបតេយ្យ។ សេរីភាពខាងការនិយាយស្តី និងសម្តែងមតិ គឺជាសសៃឈាមជីវិតនៃលទ្ធិប្រជាធិបតេយ្យ។ ដើម្បីដដែកដេញដោល និងការប្រមូលជួបជុំធ្វើបាតុកម្មដោយសន្តិវិធី តវ៉ា និងធ្វើការជំទាស់ដើម្បីគោរពបូជា ដើម្បីជានាយុត្តិធម៌សម្រាប់ជនគ្រប់រូបទាំងអស់នេះ អាស្រ័យទៅលើការហូរចេញដោយគ្មានកម្រិតនូវមតិយោបល់ គ្មានការរារាំង គ្មានការបង្ក្រាប និងប្រភពព័ត៌មានដ៏ទូលំទូលាយ។

ពលរដ្ឋនៃរបបប្រជាធិបតេយ្យរស់នៅដោយមានសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ អំណាចក្នុងនាមជាម្ចាស់ពេញលេញ ដោយមានឥទ្ធិពលជាស្វ័យប្រវត្តិទៅលើអ្នកតំណាងរបស់ខ្លួន និងរស់នៅដោយជឿជាក់ថា

តាមរយៈលទ្ធភាព ដែលអាចប្រើប្រាស់សិទ្ធិសេរីភាព អំណាចរបស់ពលរដ្ឋជាម្ចាស់ប្រទេស និងឈរលើការផ្លាស់ប្តូរគំនិត និងមតិដោយចំហ ការពិតវានឹងឈ្នះលើអំណាចផ្តាច់ការ អំពើឃោរឃៅការគំរាមកំហែង អំពើពុករលួយ និងឈ្នះទៅលើភាពក្លែងក្លាយ ភូតកុហក។ ហើយគេនឹងយល់ពីតម្លៃរបស់បុគ្គលផ្សេងៗទៀត ការសម្រុះសម្រួលគ្នានឹងត្រូវគេកំណត់កាន់តែច្បាស់ លើផ្លូវឈានទៅកាន់ការរីកចម្រើននឹងត្រូវបើកចំហ។ ការកម្រិតនៃការប្តូរគំនិតគ្នាកាន់តែខ្ពស់នោះវានឹងរឹតតែល្អប្រសើរឡើយ។ រដ្ឋាភិបាលប្រជាធិបតេយ្យមិនត្រូវយកអំណាចមកត្រួតត្រា និងបញ្ជា ឬវិនិច្ឆ័យ ខ្លឹមសារនៃការបញ្ចេញវាចាផ្ទាល់ និងការសរសេររបស់ប្រជាពលរដ្ឋម្ចាស់អំណាចឡើយ។ ម្យ៉ាងវិញទៀត ប្រជាធិបតេយ្យពឹងផ្អែកទៅលើប្រជាពលរដ្ឋ ចេះសរសេរ ចេះអាន ចេះវិភាគ មានសេចក្តីក្លាហាន គោរពការពារសន្តិភាព មានសីលធម៌ និងមានការយល់ដឹង លទ្ធភាពធំទូលាយ ទទួលដំណឹងដែលអនុញ្ញាតឲ្យគេចូលរួមក្នុងជីវភាពសាធារណៈប្រកបដោយការទទួលខុសត្រូវនៃសង្គមរបស់គេបានពេញលេញតាមលទ្ធភាព។ ប្រជាធិបតេយ្យរីកធំធាត់ និងរឹងមាំបាន គឺដោយសារថាមពលរបស់ប្រជាពលរដ្ឋចូលរួមធ្វើសេចក្តីសម្រេចចិត្ត មានស្មារតី តវ៉ា ទាមទារ ជំទាស់ ដោយអហិង្សាប្រកបដោយកិត្តិយស ទៅលើអង្គការរដ្ឋដែលបានប្រព្រឹត្តខុសឆ្គងរបស់ខ្លួនឬធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍សង្គមជាតិ ឬផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងបានមកពីការហូរចេញចូលឥតឈប់ឈរនូវការផ្លាស់ប្តូរគំនិតគ្នា ព័ត៌មានប្រាកដប្រជា មតិយោបល់ និងការចេះប៉ាន់ប្រមាណ។ ផ្លែផ្ការបស់សិទ្ធិសេរីភាពក្នុងការនិយាយស្តី គឺជាសេរីភាពរបស់ប្រជាពលរដ្ឋដើម្បីជួបជុំ និងទាមទារដោយសន្តិវិធីឲ្យរដ្ឋាភិបាលស្តាប់យល់ដឹងអំពីទុក្ខសោករបស់ប្រជាពលរដ្ឋម្ចាស់ប្រទេស ម្ចាស់អំណាច បើគ្មានសិទ្ធិប្រមូលផ្តុំ និងទាមទារឲ្យគេស្តាប់ទេ នោះសេរីភាពក្នុងការនិយាយស្តីការធ្វើបាតុកម្មអហិង្សា... ដែលជាតម្លៃដាច់ខាតរបស់ប្រជាពលរដ្ឋនឹងត្រូវបាត់បង់តម្លៃ ហើយរួញខ្លួនក្នុចង្កូមអំណាចផ្តាច់ការ។ ហេតុនេះហើយសិទ្ធិសេរីភាពក្នុងការនិយាយស្តីត្រូវចាត់ទុកថា ជាប់ទាក់ទងយ៉ាងជិតស្និតជាមួយសិទ្ធិប្រមូលផ្តុំគ្នាសម្តែងមតិជំទាស់និងទាមទារឲ្យផ្លាស់ប្តូរ។ រដ្ឋាភិបាលប្រជាធិបតេយ្យអាចសម្រួលដោយត្រឹមត្រូវតាមច្បាប់នូវពេលវេលា និងទីកន្លែងសម្រាប់ការប្រជុំនយោបាយ និងព្យុះហយាត្រា ដើម្បីសន្តិភាព ប៉ុន្តែរដ្ឋាភិបាល មិនអាចប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីគាបសង្កត់ការជំទាស់តវ៉ា ឬរារាំងមិនឲ្យក្រុមប្រឆាំងសម្តែងមតិរបស់ខ្លួនឲ្យមហាជនឮបានឡើយ។

អំណាចជាក់ស្តែងរបស់រដ្ឋសភា គឺផ្តោតសំខាន់ទៅលើពង្រាងច្បាប់ អនុម័តច្បាប់ និងតាមដានការអនុវត្តន៍ច្បាប់។

កាតព្វកិច្ចមុខងារធ្វើសេចក្តីព្រាងច្បាប់ គឺសំដៅជានាដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ យុត្តិធម៌សង្គម ការពារផលប្រយោជន៍ទូទៅរបស់ប្រជាជាតិ និងផលប្រយោជន៍របស់ប្រជារាស្ត្រម្ចាស់ឆ្នោត ម្ចាស់ប្រទេស និងជាម្ចាស់អំណាច។ ជាពិសេសបង្កើតច្បាប់ឡើង ដើម្បីធ្វើជាមូលដ្ឋានរឹងមាំ ក្នុងការគ្រប់គ្រងប្រទេសជានានូវការដឹកនាំនៃប្រទេសជាតិមួយឲ្យប្រព្រឹត្តទៅមានរបៀបរៀបរយ មាននិរន្តរភាព ស្ថេរភាពពេញលេញ សេចក្តីថ្លៃថ្នូរ។ល។ ចំណែកអំណាចក្នុងការអនុម័តរបស់រដ្ឋសភាវិញ គឺជាយន្តការដ៏សំខាន់បំផុត របស់រដ្ឋសភាក្នុង

សង្គមប្រជាធិបតេយ្យមានន័យថា មុននឹងអនុម័តនូវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នីមួយៗ អ្នកតំណាងរាស្ត្រចាំបាច់ត្រូវយកខ្លឹមសារអត្ថបទច្បាប់នោះ មកពិគ្រោះយោបល់ជាសាធារណៈ ឬសវនាការសាធារណៈ និងពិភាក្សាគ្នាឲ្យបានទូលំទូលាយ ដោយតម្រង់ទិសដៅរកការការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋនិងប្រទេសជាតិជាមូលដ្ឋាន។ តាមរយៈសវនាការសាធារណៈ តំណាងរាស្ត្រម្នាក់ៗមានឱកាសគ្រប់គ្រាន់ស្តាប់មតិយោបល់ពីក្រុមប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ មានដូចជា សមាគម សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល អ្នកជំនាញបច្ចេកទេស ក្រុមតំណាងផលប្រយោជន៍ ឬវិជ្ជាជីវៈនានា។ល។ ប៉ុន្តែជាក់ស្តែង ដំណើរការធ្វើច្បាប់របស់រដ្ឋសភាកន្លងមកពុំទាន់សម្រេចឲ្យបានត្រឹមត្រូវតាមអំណាចនីតិវិធីប្រជាធិបតេយ្យនៅឡើយ។ ការពិភាក្សាដេញដោលជាច្រើននៅក្នុងរដ្ឋសភា ពាក់ព័ន្ធទៅនឹងសេចក្តីព្រាងច្បាប់ គឺកាន់តែត្រូវបានរឹតបន្តឹង ពិសេសការសម្រេចចិត្តសំខាន់ៗលើច្បាប់ដែលកំពុងត្រូវបានពិភាក្សា។ តួយ៉ាងច្បាប់ស្តីពីអស្សាមិក ដែលចែងពីការដកហូតដីកម្មសិទ្ធិឯកជនរបស់ពលរដ្ឋត្រូវបានពិភាក្សាត្រឹមតែ៦ម៉ោងប៉ុណ្ណោះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មឲ្យសន្តិវិធី ដែលចំណុះទៅដោយអនុប្រយោគធ្ងន់ធ្ងរជាច្រើន ដែលអាចរឹតបន្តឹងដល់សិទ្ធិសេរីភាពបញ្ចេញមតិ ត្រូវបានរដ្ឋសភាពិភាក្សាអស់រយៈពេលសរុបតែ៧ម៉ោងប៉ុណ្ណោះ ដែលតាមការពិភាក្សាច្បាប់ទាំងនេះ ទាមទារឲ្យតំណាងរាស្ត្រពិភាក្សាគ្នាដោយទូលំទូលាយល្អិតល្អន់ និងអាចយកទៅធ្វើប្រជាមតិពីប្រជាពលរដ្ឋម្ចាស់ឆ្នោតម្ចាស់អំណាច និងជាម្ចាស់ប្រទេស ព្រោះច្បាប់ទាំងនេះទាក់ទងដល់ការសម្តែងមតិរបស់អ្នកតំណាងរាស្ត្រផងនិងប្រជាពលរដ្ឋផង ដែលមិនគួរដាក់កំហិតលើការពិភាក្សារបស់រដ្ឋសភាឡើយ។

ដោយឡែកចំពោះកាតព្វកិច្ចតាមដាន ការអនុវត្តន៍ច្បាប់របស់ស្ថាប័ននីតិបញ្ញត្តិរបស់រដ្ឋសភាវិញ គឺថារដ្ឋសភាកម្ពុជាមានអំណាចគ្រប់គ្រាន់ក្នុងការតាមដាន អង្កេតរាល់ការអនុវត្តន៍របស់រដ្ឋាភិបាល។ មានន័យថារដ្ឋសភាមិនមែនធ្វើច្បាប់រួចហើយទុកច្បាប់នោះចោលទេ កាតព្វកិច្ចអចិន្ត្រៃយ៍របស់ខ្លួន គឺប្រើអំណាចរបស់ខ្លួនតាមដានរាល់ការអនុវត្តន៍ច្បាប់របស់រដ្ឋាភិបាល ថាតើច្បាប់ដែលសភាបានអនុម័តរួចហើយ រដ្ឋាភិបាលគោរពឲ្យបានត្រឹមត្រូវដែរឬទេ? ការយកច្បាប់ទៅអនុវត្តរបស់រដ្ឋាភិបាលមានប្រសិទ្ធិភាពកម្រិតណា? តើច្បាប់ទាំងនោះអាចធានាសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការប្រើអំណាចរបស់ខ្លួនដែរឬទេ? បច្ចុប្បន្ននេះ គឺគេពុំឃើញរដ្ឋសភាហ៊ានប្រើអំណាចរបស់ខ្លួនក្នុងការធ្វើសេចក្តីព្រាងច្បាប់ ដោយឯករាជ្យខ្លួនឯងមកអនុម័ត ឬហ៊ានប្រើអំណាចរបស់ខ្លួនក្នុងការធ្វើវិសោធនកម្មច្បាប់ណាមួយទៅតាមគំនិតរបស់ខ្លួនឡើយ។ ប៉ុន្តែគេឃើញការធ្វើវិសោធនកម្មច្បាប់ កើតចេញពីការស្នើឡើងដោយរដ្ឋាភិបាលទៅវិញ។ រូបភាពនេះបញ្ជាក់ថា រដ្ឋសភាកម្ពុជាគ្មានអំណាចពិតប្រាកដរបស់ខ្លួនដោយឯករាជ្យនោះទេ រដ្ឋសភាកម្ពុជា ទទួលរងឥទ្ធិពលអំណាចពីរដ្ឋាភិបាលយ៉ាងពិតប្រាកដ។ រដ្ឋសភាកម្ពុជាពិតជាគ្មានសមត្ថភាពពេញលេញខាងនយោបាយក្នុងការបំពេញតួនាទីជារដ្ឋសភាតំណាងរាស្ត្រ ដើម្បីដោះស្រាយវិបត្តិក្នុងសង្គមបានឡើយ។ អំណាចរបស់រដ្ឋសភាកម្ពុជា គឺគ្រាន់តែយកលិខិតព្រាងរបស់រដ្ឋាភិបាលមកអនុម័តយល់ព្រមឲ្យក្លាយទៅជាច្បាប់ប៉ុណ្ណោះ ឬ ធ្វើវិសោធនកម្ម ដើម្បីសម្រួលទៅតាមឆន្ទៈរបស់រដ្ឋាភិបាលដែលចង់បាន។ ដំណើរការនីតិបញ្ញត្តិក្នុងកម្រិតបែបនេះ គឺជាភាពអសកម្មដ៏ចម្បង

របស់រដ្ឋសភា ក្នុងការប្រើអំណាចនីតិបញ្ញត្តិឆ្លើយតបទៅនឹងឆន្ទៈប្រជាពលរដ្ឋម្ចាស់ឆ្នោត ម្ចាស់អំណាច អនុលោមតាមបទបញ្ញត្តិមាត្រា៣៨ វាក្យខ័ណ្ឌ១និង២ នៃរដ្ឋធម្មនុញ្ញ។ ភាពអសកម្មនេះធ្វើឲ្យការអនុវត្តន៍ របប គ្រប់គ្រងបែបប្រជាធិបតេយ្យសភានិយមនៅកម្ពុជាពុំបានល្អ គឺដោយសារតែរដ្ឋសភាខ្លួនឯងផងដែរ។ ការខិតខំ ប្រឹងប្រែងឃោសនារកសម្លេងឆ្នោតគាំទ្រ ក្នុងរដូវកាលបោះឆ្នោតរដ្ឋសភាម្តងៗ ឃើញថាបេក្ខជនឈរឈ្មោះ មានសភាពស្វាហាប់ ក្លាហាន ម៉ឺងម៉ាត់ ជានាចំពោះម្ចាស់ឆ្នោត តែក្រោយពេលពីជាប់ឆ្នោតធ្វើជាតំណាង ប្រជាពលរដ្ឋ ជាពិសេសទទួលបានអំណាចនីតិបញ្ញត្តិពីប្រជាពលរដ្ឋហើយ បែរជាតំណាងរាស្ត្រពុំប្រើអំណាច នេះទៅវិញ។ អ្នកនយោបាយឲ្យតម្លៃការបោះឆ្នោតរដ្ឋសភាត្រឹមតែជាការប្រកួតប្រជែងយកអំណាចគ្រប់គ្រង រដ្ឋាភិបាលតែប៉ុណ្ណោះ។ ការពិតការបោះឆ្នោតរដ្ឋសភាក្នុងប្រព័ន្ធប្រជាធិបតេយ្យសភានិយម មានតម្លៃទូលំ-ទូលាយជាងនេះ។ គឺថា រដ្ឋសភាចាំបាច់ហ៊ានប្រើអំណាចស្របច្បាប់របស់ខ្លួននៅខាងប្រជាពលរដ្ឋម្ចាស់អំណាច ម្ចាស់ឆ្នោត ការពាររាល់ឧបសគ្គនានា ដែលកើតមានដល់ប្រជាពលរដ្ឋម្ចាស់ឆ្នោត ពីព្រោះប្រជាពលរដ្ឋជាប្រភព ម្ចាស់អំណាចតែមួយគត់សម្រាប់អ្នកតំណាងរាស្ត្រ។ ដូច្នេះដើម្បីឲ្យអំណាចរដ្ឋសភា មានសក្តានុពល រដ្ឋសភាខ្មែរ ត្រូវផ្តួចផ្តើមតាក់តែងច្បាប់ស្តីពី តំណែងចាប់ពីនាយឧត្តមសេនីយ៍ដល់ឧត្តមសេនីយ៍ត្រីនៃកងកម្លាំងប្រដាប់អាវុធ គ្រប់ប្រភេទចាំបាច់ត្រូវផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភា ក្នុងគោលបំណងសំដៅបន្ថយអំណាចរដ្ឋាភិបាលឲ្យស្រប តាមគោលការណ៍តុល្យភាពនៃអំណាចរបស់រដ្ឋ(Checks and Balances) ក្នុងសង្គមប្រជាធិបតេយ្យ និងដើម្បី ទប់ស្កាត់ការប្រើអំណាចផ្តាច់ការ បក្សពួកនិយម អយុត្តិធម៌ ការរំលោភបំពានអំណាច ការរើសអើងនយោបាយ ជាពិសេសដើម្បីពង្រឹងអំណាចប្រជាពលរដ្ឋស្របតាមខ្លឹមសារប្រជាធិបតេយ្យ។

តាមទិដ្ឋភាពជារួម រដ្ឋសភាមានលក្ខណៈប្រជាធិបតេយ្យ ដូចមានមាត្រាជាច្រើនបានបញ្ញត្តិអំពីនីតិ វិធីសម្រាប់ដោះស្រាយបញ្ហា។ នីតិកាលមានរយៈពេល ប្រាំឆ្នាំ។ ការបោះឆ្នោតជ្រើសរើសតាមកំណត់។ រដ្ឋសភា អាចបន្តករណីយកិច្ចរបស់ខ្លួនពេលចប់អាណត្តិនិងពេលវេលាបរទេសចូលឈ្លានពានកាន់កាប់ទឹកដី ការប្រកាស ភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។ រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ។ មានថវិកាស្វ័យប្រវត្តិ មានបទបញ្ជាផ្ទៃក្នុងមានគណៈកម្មាធិការអចិន្ត្រៃយ៍។ ទាំងនេះជាអំណាចដ៏មានឥទ្ធិពលរបស់សភាខ្មែរ បើ ប្រៀបធៀបទៅនឹងស្ថាប័នរដ្ឋធំៗពីរទៀត។

ការងាររដ្ឋសភាធ្វើការជាសាធារណៈ (មាត្រា៨៨) មានន័យថា រដ្ឋសភាខ្មែរមានលក្ខណៈច្បាស់លាស់ នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ សមាជិករដ្ឋសភានីមួយៗមានសុពលភាពអំណាចក្នុងទង្វើរបស់ខ្លួន។ រដ្ឋសភា ជាអ្នកបង្កើតរដ្ឋាភិបាល ជាក្រុមជំនុំជម្រះក្តី និងជាអ្នកមានសិទ្ធិវិសោធនកម្មច្បាប់ ជាមេប្រយោគ ដែលមានអំណាច ឯករាជ្យសក្តានុពល សម្រាប់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលប្រឡងចូលនិងចេញ ព្រមទាំងជាអ្នកសម្រេចផ្តល់ពិន្ទុ យ៉ាងក្រិត្យក្រមលើស្ថាប័ននីតិប្រតិបត្តិផងដែរ។ ប្រធានរដ្ឋសភាមានអំណាចខ្លាំងទៅលើនាយករដ្ឋមន្ត្រី ឬមន្ត្រី ជាន់ខ្ពស់តាមរយៈមាត្រា៩៦,៩៧។ ទន្ទឹមនឹងនេះរដ្ឋាភិបាលក៏មានសិទ្ធិអំណាចខ្លាំងទៅលើរដ្ឋសភាផងដែរ តាមរយៈការដាក់ឲ្យអនុវត្ត ការធ្វើស្នើច្បាប់ឲ្យរដ្ឋសភាអនុម័ត។ មាត្រា៩២ នៃរដ្ឋធម្មនុញ្ញ បានបដិសេធចោល

រាល់ការអនុម័តទាំងឡាយណារបស់រដ្ឋសភា ដែលមិនការពារសិទ្ធិពេញលេញចំពោះរចនាសម្ព័ន្ធ និងរបបនយោបាយរបស់រដ្ឋាភិបាល។ ទាំងនេះជាភាពវិជ្ជមានរបស់រដ្ឋសភាក្នុងរដ្ឋធម្មនុញ្ញខ្មែរ។

ចំពោះភាពអវិជ្ជមានខ្លះៗរដ្ឋធម្មនុញ្ញខ្មែរ។ ការបោះឆ្នោតដោយផ្ទាល់ ជាសកលនៅក្នុងរបបប្រជាធិបតេយ្យ គឺជាការបោះឆ្នោតប្រកបដោយការយល់ដឹង និងការទទួលខុសត្រូវ ពោលគឺ ម្ចាស់ឆ្នោតជ្រើសរើសបុគ្គលដែលមានលក្ខណៈសម្បត្តិដូចជាបុគ្គលមានប្រាជ្ញាខ្ពស់ មានទេពកោសល្យក្នុងការដឹកនាំ ភាពប៉ិនប្រសព្វ បុគ្គលមានបញ្ញាញាណចាក់ធ្លុះ មានគុណធម៌ មានសីលធម៌ថ្លៃថ្នូរកម្រិតមេដឹកនាំ។ មាត្រា៧៦ ចែងថាៈ ...អ្នកដែលមានសិទ្ធិឈរឈ្មោះបោះឆ្នោតជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច២៥ឆ្នាំ មានសញ្ជាតិខ្មែរពីកំណើត។ តាមការសិក្សាវប្បធម៌អំណាចនយោបាយ ក្នុងរយៈកាលបោះឆ្នោតជាសកលចំនួន៦លើក( ១៩៩៣,១៩៩៨,២០០២,២០០៣,២០០៧,២០០៨): ប្រជាពលរដ្ឋខ្មែរមានទំនៀមទម្លាប់ក្នុងការជ្រើសរើសមេដឹកនាំរបស់ខ្លួន មិនមែនជ្រើសរើសដោយសំដៅរកបុគ្គលមានកម្រិតយល់ដឹងខ្ពស់ ឬអ្នកមានប្រាជ្ញាដឹកនាំ អ្នកមានចក្ខុវិស័យដឹកនាំ...។ល។ ស្ទើរនោះទេ គឺប្រជាពលរដ្ឋខ្មែរបោះឆ្នោតជ្រើសរើសសំដៅរកអ្នកណាដែលពួកគេស្រឡាញ់ពេញចិត្ត អាចនិយាយលេងសើចបាន ការជំពាក់គុណបំណាច់ជាដើមទៅវិញ។ ដូច្នេះ ការកំណត់បេក្ខភាពតំណាងរាស្ត្រ ឬមេដឹកនាំតាមតំបន់ ចាំបាច់ត្រូវបន្ថែមបុគ្គលិកលក្ខណៈដូចជាចំណេះដឹងខ្ពស់(កម្រិតឧត្តមសិក្សា) ក្រមសីលធម៌ ភាពជាមេដឹកនាំ សមត្ថភាពពេញលេញ មានចក្ខុវិស័យទេពកោសល្យ គុណធម៌ ដាក់បញ្ចូលក្នុងមាត្រានេះបន្ថែមទៀត។ ជាពិសេសត្រូវបង្កើតស្ថាប័នថ្មី ឯករាជ្យ ស្វយ័តពីអំណាចស្ថាប័នកំពូលទាំងបីរបស់រដ្ឋ ដើម្បីត្រួតពិនិត្យមើលបេក្ខភាពអ្នកតំណាងរាស្ត្រ( Examination Power )។ ការធ្វើដូច្នេះ នឹងនាំឲ្យប្រជាពលរដ្ឋភ្លឺច្បាស់ លែងច្រឡំបុល មានការទទួលខុសត្រូវខ្ពស់ក្នុងការជ្រើសរើសតំណាងរាស្ត្រផង ហើយចូលរួមរំលាយបុគ្គលឡេមឡឺម អែបអប អសមត្ថភាព ចង់ធ្វើតំណាងរាស្ត្រ ដែលជាគំរូអាក្រក់ និងប្រែក្លាយទៅជាពុម្ពគំរូល្អ រឹងមាំសម្រាប់ស្ថាប័នរដ្ឋសភារបស់ប្រជាពលរដ្ឋ។ ដែលលទ្ធផលគឺនាំប្រទេសជាតិធ្វើដំណើរលើគន្លងអភិវឌ្ឍជឿនលឿនពិតប្រាកដក្នុងជំហរចេរភាព។

### ៤.២.២ ករណីស្ថាប័នប្រព័ន្ធតុលាការ និងច្បាប់

### ក.ករណីប្រព័ន្ធតុលាការ

ប្រព័ន្ធតុលាការកម្ពុជា រួមមានសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ អំណាចតុលាការ គឺជាអំណាចត្រូវបានកំណត់ឡើងសម្រាប់វិនិច្ឆ័យ ដើម្បីស្វែងរកយុត្តិធម៌នៅក្នុងទំនាក់ទំនងរវាងបុគ្គល និងបុគ្គលរវាងបុគ្គល និងរដ្ឋ ព្រមទាំងរវាងរដ្ឋ និងសង្គម។ ស្ថាប័នអំណាចតុលាការជាអាជ្ញាកណ្តាល នៅពេលដែលស្ថាប័នអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិមានទំនាស់គ្នា។ អំណាចតុលាការនេះ គឺសំដៅដល់អំណាចវិនិច្ឆ័យស្វែងរកយុត្តិធម៌ពិតប្រាកដនៅក្នុងសង្គម ដែលនៅក្នុងនោះមានស្ថាប័នជាច្រើនដូចជា ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តុលាការកំពូល សាលាឧទ្ធរណ៍ តុលាការរាជធានី/ខេត្ត តុលាការយោធា ជាដើម។

ស្ថាប័នតុលាការជាផ្នែកមួយដ៏សំខាន់ នៃការបែងចែកអំណាចក្នុងស្ថាប័នរដ្ឋ។ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១២៨ថ្មី បានចែងថា អំណាចតុលាការគ្រប់ដណ្តប់គ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចនេះត្រូវបានប្រគល់ឲ្យតុលាការកំពូល សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ ស្ថាប័នអំណាចតុលាការនេះ គឺជាស្ថាប័នជម្រះក្តីផ្តល់យុត្តិធម៌ ដែលត្រូវធ្វើក្នុងនាមប្រជាពលរដ្ឋខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន។ ក្នុងនោះមានតែចៅក្រមទេ ដែលមានសិទ្ធិដោះស្រាយក្នុងរឿងក្តី ហើយចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងហ្មឹងម៉ាត់ និងអស់ពីដួងចិត្តនៃសតិសម្បជញ្ញៈ មនសិការ វិជ្ជាជីវៈរបស់ខ្លួន។ ការជម្រះសេចក្តីផ្តល់យុត្តិធម៌នៅក្នុងអង្គតុលាការកម្ពុជា ចាំបាច់ត្រូវធ្វើឡើយត្រូវគោរពមនសិការ និងឆន្ទៈក្នុងការបម្រើប្រជាពលរដ្ឋ ដោយមិនត្រូវធ្វើសេចក្តីសម្រេចចិត្តតាមស្ថាប័នអំណាចនីតិប្រតិបត្តិនិងនីតិបញ្ញត្តិឡើយ។ ជាគោលការណ៍ស្ថាប័នតុលាការ គឺត្រូវមានឯករាជ្យភាពមុខងារការពាររដ្ឋធម្មនុញ្ញ ការពារសិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋ និងថ្លឹងអំណាចរបស់រដ្ឋាភិបាលនិងអំណាចរដ្ឋសភា។ ក្នុងន័យនេះចង់បញ្ជាក់ថា ក្នុងរបបប្រជាធិបតេយ្យ ប្រព័ន្ធតុលាការត្រូវតែឯករាជ្យ ពីអំណាចរដ្ឋាភិបាល អំណាចរដ្ឋសភា អំណាចគណបក្ស អំណាចនយោបាយ និងអំណាចសេដ្ឋកិច្ច។ល។ ម្យ៉ាងទៀត ន័យឯករាជ្យនេះចង់បញ្ជាក់ផងដែរទៅលើឯករាជ្យភាពនៃឯកត្តជន ឯករាជ្យភាពនៃការវិនិច្ឆ័យក្តី និងឯករាជ្យភាពនៃឆន្ទៈនយោបាយដោយយកមនសិការច្បាប់ជាធំក្នុងការបំពេញការងារ ស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់នៅក្នុងសង្គមឬនៅក្នុងរដ្ឋទាំងមូល។ តុលាការមានអំណាចបង្ខំស្ថាប័នទាំងឡាយនៅក្នុងសង្គម ដោយរាប់ទាំងស្ថាប័នរដ្ឋាភិបាល និងមន្ត្រីរាជការទាំងឡាយឲ្យស្ថិតនៅក្រោមច្បាប់។ លើសពីនេះរដ្ឋធម្មនុញ្ញក៏មានបែងចែកអំណាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញមួយផងដែរ ដែលមានអំណាចត្រួតពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាអ្នកតែងតាំងត្រួតពិនិត្យ និងដាក់វិន័យចៅក្រមនិងព្រះរាជអាជ្ញា។ តាមទិដ្ឋភាពជាក់ស្តែងសមាសភាពក្រុមប្រឹក្សាទាំងពីរនេះមានសភាពលំអៀងទៅរកគណបក្សប្រជាជនកម្ពុជាយ៉ាងខ្លាំង[១៩៦]។នៅក្នុងប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យ តុលាការគួរតែមានលទ្ធភាពធ្វើឲ្យយុត្តិធម៌ មានឧត្តមភាពទៅលើនយោបាយផ្តាច់ការ។ ជាបឋមវាគឺជាភារកិច្ចរបស់អង្គចៅក្រមក្នុងការការពារឯករាជ្យភាពនិងបូរណភាពរបស់ខ្លួនប្រឆាំងនឹងការជ្រៀតជ្រែកខាងនយោបាយនិងហិរញ្ញវត្ថុពីខាងក្រៅ។ តុលាការមានកាតព្វកិច្ចស្វែងរកយុត្តិធម៌ស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់ ដែលជាផ្នែកមួយនៃនិយាម និងបទដ្ឋានយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវដែលត្រូវបានទទួលស្គាល់ជាសកល ប៉ុន្តែតុលាការខ្វះនូវរចនាសម្ព័ន្ធរូបវ័ន្តនិងគតិយុត្តដែលចាំបាច់ដើម្បីផ្តល់លទ្ធភាពឲ្យស្ថាប័នទាំងនេះ អាចធ្វើការងាររបស់ខ្លួនក្នុងនាមជាអង្គតុលាការឯករាជ្យមួយ។ តាមការទទួលស្គាល់របស់រដ្ឋាភិបាលផ្ទាល់ខ្លួន វិស័យតុលាការពុំទាន់ទទួលបានការទុកចិត្តទាំងស្រុងពីសាធារណៈជននៅឡើយ

---

[១៩៦] របាយការណ៍ស្ថានទូតអាមេរិកស្តីពី សិទ្ធិមនុស្សឆ្នាំ២០១០ http://www.state.gov/g/drl/rls/hrrpt/2009/eap/135988.htm

ទេ[១៩៧]។ មាត្រា១២៨នៃរដ្ឋធម្មនុញ្ញបានចែងថា អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការរក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ មាត្រា ១២៩ចែងថា ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើឡើងក្នុងនាមប្រជាពលរដ្ឋខ្មែរតាមនីតិ និងច្បាប់ជាធរមាន។ ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែង រដ្ឋាភិបាលជាទូទៅមិនគោរពឯករាជ្យភាពរបស់តុលាការឡើយ។ តុលាការស្ថិតក្រោមឥទ្ធិពលនិងអន្តរាគមន៍របស់អង្គនីតិប្រតិបត្តិ ហើយកើតមានអំពើពុករលួយយ៉ាងរីករាលដាលក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញានិងមន្ត្រីតុលាការ។ តើការកំណត់របៀបនេះអាចអនុញ្ញាតឲ្យអំណាចតុលាការអាចធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋទូទៅបានដែរឬទេ? ក្នុងបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ឯករាជ្យភាពនៃក្រុមចៅក្រម(ចៅក្រម និងរដ្ឋអាជ្ញា)ទាមទារឲ្យចៅក្រមទាំងឡាយត្រូវកាត់សេចក្តីតាមភាពមិនលំអៀង ផ្អែកលើហេតុការណ៍ដែលមាននៅចំពោះមុខ ហើយនៅក្នុងការគោរពច្បាប់ដោយមិនព្រមទទួលការគាបសង្កត់គំរាមកំហែង ឬការបំភិតបំភ័យដោយចំពោះ ឬមិនចំពោះអំពើភាគីណាមួយក្នុងរឿងកាត់ក្តី ឬអំពីអ្នកឯទៀតណានោះទេ ហើយក្រុមចៅក្រមមិនត្រូវនៅក្រោមចំណុះអំណាចនីតិប្រតិបត្តិឬនីតិបញ្ញត្តិ ឬភាគីនយោបាយឡើយ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ដោយមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាស្ថាប័នជួយព្រះអង្គក្នុងកិច្ចការនេះ(មាត្រា១៣២នៃរដ្ឋធម្មនុញ្ញ)។

តាមលក្ខណៈក្រិត្យក្រមនៅក្នុងសង្គមប្រជាធិបតេយ្យ អំណាចតុលាការដាច់ខាតត្រូវតែឯករាជ្យយ៉ាងពិតប្រាកដ ដែលតម្រូវឲ្យស្ថាប័ននេះបំពេញមុខងាររបស់ខ្លួនជូនសង្គមជាតិនូវសន្តិសុខ ស្ថេរភាពនិងសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋក្នុងការផ្តល់យុត្តិធម៌ ព្រមទាំងកាត់សេចក្តីដោយត្រឹមត្រូវតាមច្បាប់ ដែលបានចូលជាធរមាន។ ប្រការនេះទាមទារឲ្យមានតុលាការឯករាជ្យ និងមានអំណាចពិនិត្យច្បាប់ដែលសភាអនុម័តរួច និងសេចក្តីសម្រេចនានារបស់រដ្ឋាភិបាល ព្រោះតុលាការជាអ្នកអនុវត្តយន្តការពីរធំៗ គឺការបែងចែកអំណាចនិងការត្រួតពិនិត្យគ្នាទៅវិញទៅមក រវាងអំណាចទាំងបីដើម្បីឲ្យមានតុល្យភាព។ ឯករាជ្យនៃប្រព័ន្ធតុលាការនិងប្រព័ន្ធ យុត្តិធម៌ រឹងមាំមានសារៈសំខាន់ ចំពោះការប្រព្រឹត្តទៅនៃរដ្ឋប្រជាធិបតេយ្យមួយដែលប្រតិបត្តិក្រោមនីតិរដ្ឋដោយមិនគ្រាន់តែដើរតួសំខាន់ក្នុងការកសាងសង្គមមួយដែលកាន់តែមានយុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងលើកស្ទួយដល់មុខមាត់ប្រទេសជាតិនៅលើឆាកអន្តរជាតិផងដែរ។ ឧទាហរណ៍ ដើម្បីរក្សាបាននូវសន្ទុះនិងពន្លឿននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះ ប្រទេសជាតិនឹងត្រូវការទាក់ទាញនូវវិនិយោគទុនបរទេសឲ្យកាន់តែច្រើនឡើងនៅក្នុងវិស័យសេដ្ឋកិច្ចសមរម្យនានា ក៏ប៉ុន្តែនៅពុំទាន់មានទេនៅកម្ពុជា។ ចំណែកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាបានលើកឡើង ស្តីពីសិទ្ធិមនុស្សដោយបង្ហាញថា ទោះបីជាគោលការណ៍នៃឯករាជ្យភាពតុលាការមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាក៏ដោយ តែក្នុងការអនុវត្តន៍ជាក់ស្តែង ប្រព័ន្ធ

---

[១៩៧] របាយការណ៍របស់លោកសាស្ត្រាចារ្យ សូរិយា ប្រាសាដ ស៊ូប៉េឌី អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ឆ្នាំ២០១០ ទំព័រ ១៧

តុលាការមិនទាន់អាចប្រើសិទ្ធិប្រកបដោយប្រសិទ្ធិភាពប្រឆាំងនឹងអំណាចនីតិប្រតិបត្តិបានទេ។ ចៅក្រមបន្តស្ថិតនៅក្រោមការជ្រៀតជ្រែកផ្នែកនយោបាយ ហើយមិនអាចឬមិនមានឆន្ទៈ ដើម្បីប្រើតួនាទីរបស់ខ្លួនដោយឯករាជ្យនោះឡើយ[១៩៨]។ តំណាងពិសេសអង្គការសហប្រជាជាតិ បានសម្តែងនូវសេចក្តីព្រួយអំពីការជ្រៀតជ្រែកពីនីតិប្រតិបត្តិនៅក្នុងការងារតុលាការដោយសម្គាល់ថាកត្តានេះអាចនាំឲ្យប្រព័ន្ធច្បាប់ការពារសិទ្ធិមនុស្ស... ក្លាយជាភ្នាក់ងារដ៏ចម្បងនៃការបង្ក្រាបទៅវិញ។ ក្តីព្រួយបារម្ភបែបនេះត្រូវបានរួមចំណែកផងដែរ ដោយមជ្ឈមណ្ឌលធនធានច្បាប់អាស៊ីនៅក្នុងរបាយការណ៍ឆ្នាំ២០០៧ របស់ខ្លួនដែលផ្ញើទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សបង្ហាញថាប្រព័ន្ធតុលាការអាចធ្វើឲ្យក្លាយជាឧបករណ៍របស់រដ្ឋាភិបាល ឬអ្នកមានទ្រព្យនិងអ្នកមានអំណាចសម្រាប់ បង្ក្រាបទៅលើអ្នករិះគន់រដ្ឋាភិបាល ឬជនរងគ្រោះក្នុងរឿងដីធ្លី ដោយចៅក្រមធ្វើការប្រឌិត និងចោទប្រកាន់ក្នុងគោលបំណងចាប់អ្នកទាំងនោះដាក់ពន្ធនាគារ។ នៅរបាយការណ៍នេះ គឺបានលើកឡើងពីគណបក្សកាន់អំណាច(គណបក្សប្រជាជនកម្ពុជា) មានភាពងាយស្រួលក្នុងការប្រើឥទ្ធិពលរបស់ខ្លួនទៅលើប្រព័ន្ធតុលាការផងដែរ។ ព្រោះចៅក្រមនិងព្រះរាជអាជ្ញាស្ទើរតែទាំងអស់ ជាសមាជិកសំខាន់នៃគណបក្សនយោបាយ ព្រោះវាជាតម្រូវការនឹងវិន័យរបស់បក្ស។ មានការចង្អុលបង្ហាញដ៏ច្បាស់លាស់ពីការពាក់ព័ន្ធផ្នែកនយោបាយរបស់ប្រព័ន្ធតុលាការ គឺនៅពេលមានយុទ្ធនាការឃោសនាមុនការបោះឆ្នោត និងមានការផ្តល់វិភាគទានក្នុងយុទ្ធនាការ ដែលធ្វើឡើងដោយចៅក្រម។ ជារឿយៗនិងជាពិសេស នៅក្នុងរឿងក្តីនយោបាយធំៗប្រព័ន្ធតុលាការហាក់ដូចជាបានអនុញ្ញាតឲ្យខ្លួនត្រូវបានប្រើប្រាស់ឬយកធ្វើជាឧបករណ៍ សម្រាប់គោលបំណងនយោបាយឬឯកជនសុទ្ធសាធ[១៩៩]។ ករណីនេះបានធ្វើឲ្យប្រធានឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលមានមូលដ្ឋាននៅទីក្រុងហ្សឺណែវបានប្រើប្រាស់សម្លេងប្រតិកម្មខ្លាំងៗ ចំពោះដំណើរការប្តឹងប្រឆាំងអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី តាមរយៈប្រព័ន្ធតុលាការមិនឯករាជ្យ ដែលបញ្ហានេះបានក្លាយទៅជាសញ្ញាអាសន្នមួយធ្វើឲ្យប៉ះពាល់ចំពោះសិទ្ធិសេរីភាពនៃការបញ្ចេញមតិនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺធ្វើឲ្យខូចខាតចំពោះដំណើរការនៃលទ្ធិប្រជាធិបតេយ្យផងដែរ[២០០]។ ទិដ្ឋភាពនេះហើយទើបតំណាងពិសេសអង្គការសហប្រជាជាតិ និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពចៅក្រម និងមេធាវី បាន ចេញសេចក្តីថ្លែងការណ៍ជាសាធារណៈនៅខែសីហា ឆ្នាំ២០០៧ ដែលទាក់ទងទៅនឹងអ្វីដែលគេយល់ថា ជាឧបករណ៍គួរឲ្យចាប់អារម្មណ៍នៃឥទ្ធិពលនយោបាយ ទៅលើប្រព័ន្ធតុលាការ។ សេចក្តីថ្លែងការណ៍នេះ គឺទាក់ទង នឹងការផ្លាស់ប្តូរប្រធានសាលាឧទ្ធរណ៍កម្ពុជា និងការតែងតាំងសមាជិកថ្មីបួនរូបនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅ ក្រមដោយព្រះរាជក្រឹត្យចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៧ ដែលសរសេរថា ការផ្លាស់ប្តូរនិងការតែងតាំង ត្រូវបានធ្វើឡើងតាមសំណើអង្គនីតិប្រតិបត្តិនៃរដ្ឋាភិបាល

---

[១៩៨] សមាគមអាដហុក: ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៧ ទំព័រ ៥៨

[១៩៩] របាយការណ៍របស់លោក សាស្ត្រាចារ្យ សូរិយា ប្រាសាដ ស៊ូប៉េឌី អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជាឆ្នាំ២០១០ ទំព័រ ១៨

[២០០] មនសិការខ្មែរ ឆ្នាំទី១៧ លេខ៣៨៣២ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០

ដែលបំពានលើការបែងចែកអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការដូចបានបញ្ជាក់ច្បាស់ក្នុងរដ្ឋធម្មនុញ្ញ។ នៅក្នុងខែមិថុនា ឆ្នាំ២០០៩ រដ្ឋាភិបាល បានចេញអនុក្រឹត្យដោយដាក់ឲ្យចូលនិវត្តន៍សមាជិក៤រូបក្នុងចំណោម ៩រូប របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការ ដាក់ឲ្យចូលនិវត្តន៍នេះ គឺជាការរំលោភទៅលើគោលការណ៍បែងចែកអំណាចដាច់ចេញពីគ្នា ដែលមានចែងក្នុង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បញ្ហានេះគឺជាការបង្ហាញនូវភាពអាម៉ាសដល់ឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌កម្ពុជា[២០១]។ ម្យ៉ាងវិញទៀត កង្វះតម្លាភាពនៅក្នុងការដាក់ឲ្យចូលនិវត្តន៍ បង្ហាញនូវដំណើរថយក្រោយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឲ្យប្រសើរឡើងចំពោះការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ និងការប្រឹងប្រែងអនុវត្ត តាមនីតិរដ្ឋ។ ការខកខានមិនបានអនុម័តច្បាប់សំខាន់ៗមួយចំនួនក្នុងការធានាឯករាជ្យភាពរបស់ឧត្តមក្រុម ប្រឹក្សានៃអង្គចៅក្រម(The Amendment on Law the Organization and Functioning of the Supreme Council of Magistracy) ច្បាប់ស្តីពីតួនាទីចៅក្រម (Law on the Statue of Judges) និងច្បាប់ស្តីពីការ រៀបចំតុលាការ បានបណ្តាលឲ្យគ្មានការការពារផ្នែកច្បាប់ទប់ទល់នឹងការរំលោភបំពានទាំងនេះ។ ដោយសារ តែអំណាចលើសលប់របស់រដ្ឋាភិបាល ឃើញថា ទោះបី ច្បាប់ដែលមិនស្របតាមរដ្ឋធម្មនុញ្ញក៏ដោយ ក៏នៅតែ មានសុពលភាព ហើយការគ្រប់គ្រងប្រទេសកម្ពុជាបច្ចុប្បន្ននៅតែជាប្រទេសមួយដែលគ្រប់គ្រងដោយក្រិត្យ មិនមែនដោយច្បាប់នោះឡើយ។ ការព្រួយបារម្ភទាក់ទងនឹងឯករាជ្យភាពនិងអត្ថប្រយោជន៍របស់ស្ថានប័នយុត្តិធម៌ជាន់ខ្ពស់ នៅក្នុងប្រទេសកម្ពុជាកាន់ តែមានភាពអាក្រក់ឡើងដោយសារតែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅតែមានការសង្ស័យទៅលើនីត្យានុកូលភាពរបស់ខ្លួននៅឡើយនោះមានភារៈទទួលខុសត្រូវ ក្នុងការតែងតាំងសមាជិក៣រូប ក្នុងចំណោមសមាជិកទាំងប្រាំបួនរូប នៃក្រុមប្រឹក្សាធម្មនុញ្ញ[២០២]។

តាមទ្រឹស្តីគោលការណ៍បែងចែកអំណាច បុគ្គលម្នាក់មិនត្រូវមានមុខតំណែងនៅក្នុងអំណាចទាំងបីច្រើនជាងមួយនោះទេ។ បើមានបុគ្គលណាម្នាក់មានតំណែង ឬអំណាចសម្រេចចិត្តលើសពីអំណាចមួយនោះ គឺមានន័យថា គ្មានការបែងចែកអំណាចហើយ។ តែទោះជាយ៉ាងណាក្នុងប្រព័ន្ធសភានិយម យ៉ាងហោចក៏មាននាយករដ្ឋមន្ត្រីម្នាក់ មានតួនាទីនៅក្នុងនីតិបញ្ញត្តិផង និងជាប្រមុខនីតិប្រតិបត្តិផង[២០៣]។ ដូច្នេះ ឯករាជ្យភាពរបស់តុលាការមានសារៈសំខាន់ណាស់ ដើម្បីធ្វើឲ្យមានសុវត្ថិភាពសង្គម និងស្ថេរភាពនយោបាយ។ មាត្រា១ នៃច្បាប់សម័យអន្តរកាលដែលបានផ្តល់សច្ចាប័នថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ទាក់ទងទៅនឹងតុលាការ និងនីតិវិធីនៃការជម្រះក្តីនៅក្នុងប្រទេសកម្ពុជា ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិបានបញ្ញត្តិពី "**ឯករាជ្យភាពនៃចៅក្រម**"។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏យើងសង្កេតឃើញថា តុលាការខ្វះឯករាជ្យភាព

---

[២០១] រដ្ឋធមនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១២៨ និង១៣០

[២០២] មជ្ឈមណ្ឌលធនធានច្បាប់នៅអាស៊ី "មូលនិធិ និងក្របខណ្ឌច្បាប់សម្រាប់Country's Judiciary required"សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី៣១ខែសីហា ឆ្នាំ២០០៩

[២០៣] សុខ សំអឿន លទ្ធិប្រជាធិបតេយ្យ ឆ្នាំ២០០៩

គ្មានសមត្ថភាព កាត់ក្តីដោយលំអៀង មិនគោរពច្បាប់ មិនសូវមានមនសិការជាតិ គ្មានសីលធម៌សមជាអ្នករកយុត្តិធម៌ បាត់បង់សេចក្តីទុកចិត្តពីប្រជាពលរដ្ឋ និងប្រព្រឹត្តអំពើពុករលួយបានក្លាយជាវប្បធម៌ស្ទើរតែមិនអាចកែប្រែបានទៀតផង។ ភាគច្រើននៃចៅក្រមត្រូវបានចាត់តាំងពីសម័យកុំមុយនីស្ត ដែលបានកាន់កាប់ដោយគណបក្សប្រជាជនកម្ពុជា ហើយបុគ្គលខ្លះនៅរក្សាតំណែងរបស់ពួកគេនៅក្នុងបក្ស និងទទួលការឧបត្ថម្ភពីមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល ឬមនុស្សមានទ្រព្យសម្បត្តិ និងអាជ្ញាធរមានអំណាច។ ចៅក្រមភាគច្រើនកាត់ក្តីដោយស្ថិតនៅក្នុងក្តីបារម្ភពីបញ្ហាសន្តិសុខផ្ទាល់ខ្លួន ដោយសារមានការគាបសង្កត់ គំរាមកំហែង បំភិតបំភ័យ ខ្លាចបាត់បង់ការងារ និងមានការឧបត្ថម្ភពីអ្នកមានអំណាចក្នុងជួររាជរដ្ឋាភិបាល។ ជាក់ស្តែងនៅក្នុងកំឡុងឆ្នាំ២០០៣ សុវត្ថិភាពរបស់ចៅក្រមត្រូវបានគំរាមកំហែងដោយឧក្រិដ្ឋជនមិនស្គាល់មុខ ធ្វើឲ្យមន្ត្រីតុលាការជាច្រើនមានការព្រួយបារម្ភអំពីសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ និងភាពមិនមានទំនុកចិត្តទៅលើការការពាររបស់ប៉ូលីស ឬកងអាជ្ញាធរមានប្រដាប់អាវុធ។ កាលពីខែមេសា ឆ្នាំ២០០៣ មន្ត្រីតុលាការពីរនាក់ត្រូវបានឃាតករបាញ់សម្លាប់នៅលើដងវិថីសាធារណៈក្នុងរាជធានីភ្នំពេញ។ ព្រឹត្តិការណ៍នេះមានដូចតទៅៈ

នៅដើមខែមេសា ឆ្នាំ២០០៣ ព្រះរាជអាជ្ញាតុលាការក្រុង ឈ្មោះ ង៉ែត សារ៉ាត់ ត្រូវបានគេបាញ់ប្រហារ។

ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៣ លោក ឈឹម ដារ៉ា ក្រឡាបញ្ជីតុលាការសាលាឧទ្ធរណ៍ត្រូវបានគេបាញ់សម្លាប់។ រំលងបានតែពីរសប្តាហ៍ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ លោក សុក សេដ្ឋាមុន្នី ចៅក្រមតុលាការរាជធានីភ្នំពេញ ត្រូវបានឃាតករបាញ់សម្លាប់នៅកណ្តាលរាជធានី នៅខណៈពេលដែលលោកកំពុងបរឡានទៅកន្លែងធ្វើការ។

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចបញ្ជូនចៅក្រម ហ៊ីង ធីរិទ្ធ ពីចៅក្រមតុលាការក្រុងភ្នំពេញទៅខេត្តស្ទឹងត្រែង។ ដោយអះអាងថា គាត់មានកំហុសខុសឆ្គងក្នុងការងារ ប៉ុន្តែមិនបានពីកំហុសឆ្គងពិតប្រាកដឡើយ។ ការផ្លាស់ប្តូរនេះ គឺដោយសារលោកកាន់សំណុំរឿងស៊ើបអង្កេតធំៗពីរ ។ ទីមួយគឺ រឿងក្តីឃាតកម្មបាញ់ប្រហារ ដែលបង្កដោយឈ្មោះ នឹម សុភា ជាក្មួយនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ និងទីពីរ ករណីធ្វើឃាតលោក ជា វិជ្ជា កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០០៤ ដែលបង្កឡើងដោយជនមិនស្គាល់មុខ។ ដោយឈរលើស្មារតី គតិយុត្តិធម៌ លោក នឹម សុភា ត្រូវបានចៅក្រមរូបនេះចោទប្រកាន់ និងនាំយកមកកាត់ទោស។ ឯរឿងក្តីលោក ជា វិជ្ជា យោងតាមលទ្ធផលនៃការអង្កេត លោកចៅក្រមរូបនេះបានបញ្ជាក់ថា ករណីនេះត្រូវបានលើកលែងចោទប្រកាន់ជនសង្ស័យ២នាក់ឲ្យនៅក្រៅឃុំដោយខ្វះភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុក។ ប៉ុន្តែព្រះរាជអាជ្ញាអំពាវនាវឲ្យមានការប្តឹងឧទ្ធរណ៍បន្តទៀត ដោយសាលក្រមរបស់លោកក៏ត្រូវបានច្រានចោលដោយចៅក្រមជំនុំជម្រះនៃតុលាការឧទ្ធរណ៍។ ចៅក្រមរូបនេះនៅតែបន្តទទួលស្គាល់ថា គាត់ពិតជាស្ថិតក្រោមអំណាចមន្ត្រីរាជរដ្ឋាភិបាលជាន់ខ្ពស់ ដើម្បីយករឿងក្តីនេះទៅកាត់ទោស។ ការផ្លាស់ប្តូរចៅក្រមឆ្លុះបញ្ចាំងពីទម្រង់នៃការអនុវត្តន៍គោលនយោបាយគ្មានតម្លាភាពបក្សពួក

និយម។ ទិដ្ឋភាពនៃការផ្លាស់ប្តូរចៅក្រមបែបនេះ ឆ្លុះបញ្ចាំងពីទម្រង់អនុវត្តគោលនយោបាយគ្មានតម្លាភាព ផ្តាច់ការ។ ឋានានុក្រមនៅពីលើចៅក្រមជំនុំជម្រះរឿងក្តីទាំង៣ថ្នាក់ គឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ឧត្តមក្រុមប្រឹក្សានេះ ត្រូវបានទទួលអំណាចសាធារណៈមួយ គឺតួនាទី និងភារកិច្ចតាមដានការអនុវត្តន៍ច្បាប់នៃប្រព័ន្ធយុត្តិធម៌ និងឯករាជ្យភាពរបស់តុលាការ ហើយក៏ជាស្ថាប័នមានសិទ្ធិអំណាចដាក់ទណ្ឌកម្មទៅលើចៅក្រមណាដែលប្រព្រឹត្តខុសក្នុងការងាររបស់ខ្លួន។ ការពិតស្ថាប័នជាន់ខ្ពស់នេះក៏ពុំមានឯករាជ្យភាពរបស់ខ្លួនដែរ រាល់ការធ្វើសេចក្តីសម្រេចអ្វីៗ គឺធ្វើឡើងក្នុងន័យគោរពតាមគោលនយោបាយគណបក្ស និងអ្នកមានអំណាចក្នុងជួររាជរដ្ឋាភិបាលប៉ុណ្ណោះ។ ករណីជាក់ស្តែងនៃភាពមិនមានឯករាជ្យក្នុងស្ថាប័នតុលាការ គឺក្នុងករណីរឿងក្តីសម្លាប់លោក ជា វិជ្ជា (មេដឹកនាំសហជីពសេរី-កម្មករ) នេះតែម្តង គឺនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤ តុលាការបានប្រគល់សំណុំរឿងនេះឲ្យចៅក្រម ហ៊ីង ធីរិទ្ធ ស៊ើបអង្កេត។ តាមការស៊ើបអង្កេតរួចមក គាត់បានបញ្ជាក់ថាករណីនេះត្រូវបានលើកលែងចោទប្រកាន់ជនសង្ស័យ២នាក់ឲ្យនៅក្រៅឃុំដោយខ្វះភស្តុតាង ប៉ុន្តែព្រះរាជអាជ្ញាអំពាវនាវឲ្យមានការប្តឹងឧទ្ធរណ៍បន្តទៀត។ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានដកតំណែងរបស់គាត់ពីចៅក្រមក្រុងភ្នំពេញទៅខេត្តស្ទឹងត្រែងវិញ ដោយមិនបានបញ្ជាក់ពីកំហុសឆ្គងឲ្យបានច្បាស់លាស់ឡើយ។ ករណីមួយទៀត គឺក្នុងខេត្តព្រៃវែង ចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ក្មេងប្រុសម្នាក់ពីបទរំលោភសេពសន្ថវៈ។ ក្មេងប្រុសនោះត្រូវបានដោះលែងដោយដាក់ប្រាក់ធានា១០ម៉ឺនរៀល បន្ទាប់មកចៅក្រមបានជម្រិតទារប្រាក់ពីឪពុកក្មេងប្រុសនោះថា ប្រសិនបើចង់ឲ្យកូនរួចផុតពីការចោទប្រកាន់ទាំងអស់នោះ លុះត្រាតែបង់ប្រាក់៥០ម៉ឺនរៀលឲ្យគាត់ បើពុំដូច្នោះទេគាត់(ចៅក្រម) នឹងចាប់ខ្លួនក្មេងប្រុសនោះម្តងទៀតបញ្ជូនទៅតុលាការជំនុំជម្រះក្តី។ ដោយឡែក ជនជាប់ចោទដែលបានលើកលែងការចោទប្រកាន់ភាគច្រើន ចៅក្រមទទួលសំណូក ឬក៏សម្រេចសេចក្តីលំអៀងទៅបុគ្គលណាដោយមានវត្ថុមានតម្លៃឲ្យចៅក្រមឬបុគ្គលមានអំណាចខ្ពស់ ខ្សែលោកនេះ ខ្សែលោកនោះ ដែលប្រាសចាកពីក្រមសីលធម៌ ក្នុងនាមជាងអ្នកនៅថ្លឹងថ្លែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋដោយមិនរើសមុខ មិនប្រកាន់និន្នាការនយោបាយ ជាពិសេសប្រាសចាកពីច្បាប់ជាតិ និងអន្តរជាតិៈ ដូចជាទី១-មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ ឬក្នុងសាលាជំនុំជម្រះក្តី(មាត្រា១៤នៃICCPR)។ ២-តុលាការត្រូវមានសមត្ថភាពគ្រប់គ្រាន់ប្រកបទៅដោយឯករាជ្យពេញលេញ ហើយមិនត្រូវមានភាពលំអៀងទៅខាងណាឡើយ(មាត្រា១៤នៃICCPR)។ ៣-រីឯនៅក្នុងជំពូកទី៩នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ក៏មានចែងពីស្ថាប័នតុលាការដែរៈ ដូចជា ១-អំណាចតុលាការ ជាអំណាចឯករាជ្យ(មាត្រា១០៩ នៃរដ្ឋធម្មនុញ្ញ១៩៩៣)។ ២-តុលាការជានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ(មាត្រា១០៩នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣)។ ៣-គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការបានឡើយ(មាត្រា១១១នៃរដ្ឋធម្មនុញ្ញ១៩៩៣)។ អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សលោក រ៉ូភើត ខូលវិល (Rupert-Colville) បានប្រាប់អ្នកយកព័ត៌មានបន្ទាប់ពីកិច្ចប្រជុំរាល់ពីរសប្តាហ៍ម្តងកាលពីថ្ងៃអង្គារទី១៣ ខែកក្កដា ឆ្នាំ២០១០ ថា អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែក

សិទ្ធិមនុស្សជឿជាក់ថា ករណីរបស់លោកស្រី មូរ សុខហួរ ជាករណីនយោបាយ ហើយបានបង្ហាញឲ្យឃើញថា វាជាការធ្លាក់ចុះផ្នែកសេរីភាពបញ្ចេញមតិ និងឯករាជ្យភាពរបស់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា[២០៤]។ លោកបានបន្ថែមថា ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលជាគោការណ៍មូលដ្ឋានសម្រាប់ការពារសិទ្ធិមនុស្ស ប៉ុន្តែសម្រាប់ករណីរបស់លោកស្រី មូរ សុខហួរ ត្រូវគេបានប្រើជាឧបករណ៍ ដើម្បីបំបិទសិទ្ធិសេរីភាពបញ្ចេញមតិនៅកម្ពុជា។

កាលពីខែមិថុនា ឆ្នាំ២០១០ ស្តីពីស្ថានភាពសិទ្ធិមនុស្សអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិនៅកម្ពុជា លោក សូរិយា ស៊ូបេឌី(Surya Subedi) បានរកឃើញវិបត្តិប្រព័ន្ធយុត្តិធម៌នេះដែរ ក្នុងបេសកកម្មស្វែងរកការពិតលើកទី៣ របស់លោកនៅកម្ពុជា។ លោកថា ចៅក្រមកម្ពុជាអាចមានការប្តេជ្ញាចិត្តក្នុងការផ្តល់យុត្តិធម៌ ប៉ុន្តែការប្តេជ្ញាចិត្តទាំងនោះត្រូវបានខកខាន ពីព្រោះមានការជ្រៀតជ្រែកពីសំណាក់មជ្ឈដ្ឋានខាងក្រៅ។ មានចៅក្រមកម្ពុជាខ្លះ ជាសមាជិកនៃគណបក្សប្រជាជនកម្ពុជា។ ប្រធានតុលាការកំពូល លោក ឌិត មុន្ទី ជាសមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា។ ការអនុវត្តន៍ជាក់ស្តែង ការជំនុំជម្រះដែលទាក់ទងទៅនឹងសកម្មជនមកពីគណបក្សនយោបាយផ្សេងពីគណបក្សរបស់ខ្លួន ករណីភាគច្រើន ចៅក្រមច្រើនតែលំអៀងដោយសារឥទ្ធិពលអំណាចបង្គាប់បញ្ជា។ មូលហេតុនេះអាចកើតឡើងដោយសារៈ

**ក**-អវត្តមាននៃច្បាប់ស្តីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលនឹងផ្តល់ឲ្យចៅក្រម និងព្រះរាជអាជ្ញាគ្រប់កម្រិតនូវកិច្ចការពារ សុវត្ថិភាពមុខតំណែង និងឯករាជភាពដែលមន្ត្រីទាំងនេះត្រូវការដើម្បីបំពេញការទទួលខុសត្រូវរបស់គាត់ក្នុងលក្ខណៈឯករាជ្យ និងមានប្រសិទ្ធិភាព។ បច្ចុប្បន្នអង្គចៅក្រមស្ថិតក្រោមការគ្រប់គ្រងនៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយអ្នកដែលមានអាយុច្រើនជាង៦៥ឆ្នាំ អាចដាក់បង្ខំឲ្យចូលនិវត្តន៍តាមឆន្ទានុសិទ្ធិរបស់អំណាចនីតិប្រតិបត្តិ ឬរក្សាតំណែងរហូតដល់អាយុ៦៥ឆ្នាំ សម្រាប់ភក្តីភាពខាងនយោបាយ[២០៥]។ ព្រះរាជអាជ្ញានានាមានទំនោរទទួលកាន់បណ្តឹងព្រហ្មទណ្ឌ ពីមន្ត្រីនយោបាយជាន់ខ្ពស់នានា ដោយមិនស្ទាក់ស្ទើរជាពិសេសបណ្តឹងបរិហាកេរ្តិ៍និងផ្សាយព័ត៌មានមិនពិត។ សម្រាប់រឿងក្តីបែបនេះ តែងតែបញ្ចប់ដោយផ្តន្ទាទោសទោះបីជាខ្វះភស្តុតាងដាក់បន្ទុក ហើយមានភស្តុតាងដាក់បន្ទុកបរិបូរណ៍ក៏ដោយ។ អង្គចៅក្រមនៅសាលាដំបូង ហាក់ដូចជាមានការខ្លាចអោក្នុងការចាត់វិធានការដោយឯករាជ្យ ជាងអង្គចៅក្រមនៅតុលាការជាន់ខ្ពស់។

**ករណីជាក់ស្តែងៈ**

-នៅក្នុងឆ្នាំ២០០៨ តុលាការកំពូលបានចេញដីការសម្រេចដោះលែងជនពីររូប ដែលត្រូវបានផ្តន្ទាទោស ពីបទឃាតកម្មលើប្រធានសហព័ន្ធសហជីព លោក ជា វិជ្ជា ហើយបានស្នើឲ្យសាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យលើសំណុំរឿងនោះឡើងវិញ។ ជាក់ស្តែងរឿងនេះ ប្រសិនបើពុំមានការជ្រៀតជ្រែកផ្នែកនយោបាយ

---

[២០៤] www.cchrcambodia.org

[២០៥] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជារបស់លោកសាស្ត្រាចារ្យ សូរិយា ប្រាសាដ ស៊ូបេឌី ឆ្នាំ២០១០ ទំព័រ ១៩

នោះទេ សាលាដំបូងគួរតែបានសម្រេចឲ្យជនជាប់ចោទទាំងពីររួចខ្លួនតាំងពីដំណាក់កាលពីដំបូងមកម្ល៉េះ អាស្រ័យដោយពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងពួកគេ ដោយពុំចាំបាច់បារម្ភ ថា តើរដ្ឋាភិបាលទទួលយកសេចក្តីសម្រេចនោះដែរ ឬក៏អត់នោះទេ។ ចៅក្រមស៊ើបសួរនៃរឿងក្តីដំបូងគេ បានសម្រេចលើកបណ្តឹងនោះចោលយ៉ាងក្លាហាន។ ពីរសប្តាហ៍ក្រោយមកគាត់ត្រូវបានផ្លាស់ទៅកាន់តុលាការខេត្តដាច់ស្រយ៉ាលមួយ ហើយសំណុំរឿងនេះត្រូវបានបញ្ជូនមកជំនុំជម្រះឡើងវិញ។

-ទាក់ទងនឹងរឿងក្តីប្រឆាំងមេធាវីនានា ដែលធ្វើការឲ្យមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍។ នៅក្នុងខែមិថុនា ឆ្នាំ២០០៧ មេធាវីទាំងនេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមបណ្តឹងព្រហ្មទណ្ឌពីបទ **ញុះញង់** ប្រសិនបើមេធាវីទាំងនេះបន្តតំណាងឲ្យសហគមន៍ជនជាតិដើមភាគតិចមកពីភូមិកងយុ និងកងធំក្នុងខេត្តរតនៈគីរីទាក់ទិននឹងបណ្តឹង ដែលពួកគេបានប្តឹងប្រឆាំងពាណិជ្ជការិនីដ៏មានអំណាចម្នាក់ពីបទរិតិកម្មដីរបស់ជនជាតិភាគតិច។ រឿងក្តីនេះកើតឡើងដោយសារសហគមន៍ជនជាតិដើមភាគតិច មានបំណងប្រើប្រាស់តុលាការដើម្បីទទួលបានសំណង[២០៦]។ នៅក្នុងខែមិថុនា ឆ្នាំ២០០៧ ពាណិជ្ជការិនីម្នាក់នេះ បានដាក់បណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងតំណាងរបស់អ្នកភូមិទាំង១២ ដែលជាមេធាវីមកពីមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាព្រមទាំងតំណាងពីររូបនៃអង្គការមិនមែនរដ្ឋាភិបាលនានាប្រចាំខេត្តរតនៈគីរី។ អ្នកស្រីនោះបានស្នើឲ្យព្រះរាជអាជ្ញា ខេត្តរតនៈគីរីធ្វើការស៊ើបអង្កេតលើរឿងក្តីនោះ និងធ្វើបណ្តឹងពីបទឆបោក បទបរិហាកេរ្តិ៍ បទញុះញង់បានលើកឲ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈឹមដោយពុំបានសម្រេចផល។ ករណីនេះទោះជាចៅក្រមស៊ើបសួរនៃតុលាការខេត្តរតនៈគីរី បានលើកចោលកាលពីខែមីនា ឆ្នាំ២០០៩ក៏ដោយក៏វាមានលក្ខណៈច្បាស់ក្រឡែតតាំងពីដំបូងទីមក ហើយថា ពុំគួរនឹងមានការធ្វើបណ្តឹងពីបទញុះញង់ទេពីព្រោះថាការបង្ហាញប្រាប់ឲ្យជនណាម្នាក់ទាមទារសិទ្ធិរបស់ខ្លួនតាមផ្លូវតុលាការ ពុំមែនជាបទល្មើសនោះទេទោះជានៅក្រោមច្បាប់ណាក៏ដោយ។

**ខ**-អវត្តមាននៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ ហាក់ដូចជាមានផលប៉ះពាល់ដ៏មហន្តរាយលើប្រសិទ្ធិភាពនិងឯករាជ្យភាពរបស់តុលាការនៅក្នុងការផ្តល់យុត្តិធម៌ ឲ្យទាន់ពេលវេលាសមស្រប និងឥតលំអៀង។ តាមពិតរដ្ឋមួយត្រូវការច្បាប់នេះជាចាំបាច់ ដើម្បីធ្វើឲ្យមានឯកភាព និងភាពប្រាកដប្រជានៅក្នុងប្រព័ន្ធយុត្តិធម៌។

សរុបសេចក្តីមកឃើញថា ឯករាជ្យភាពតុលាការ គឺជាធាតុមួយដ៏សំខាន់ណាស់ ក្នុងការធានាការអនុវត្តន៍សិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋក្នុងរបបលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ តុលាការ គឺពិតជានៅពុំទាន់ស្ថិតក្នុងជំហរឯករាជ្យនៅឡើយទេ ពោលគឺខ្វះមនសិការវិជ្ជាជីវៈ ខ្វះសីលធម៌... ជាពិសេសគឺត្រូវទទួលរងនូវការគាបសង្កត់ជ្រៀតជ្រែក ពីអង្គនីតិប្រតិបត្តិ អ្នកមានអំណាច និងប្រព្រឹត្តអំពើពុករលួយ ស្ទើរតែរីកសាយ

[២០៦] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជារបស់លោកសាស្ត្រាចារ្យ សូរិយា ប្រាសាដ ស៊ូប៊ែឌី ឆ្នាំ២០១០ ទំព័រ ១៩

ភាយនៅគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធតុលាការ ពីព្រោះតែពុំមានច្បាប់សម្រាប់ការពារចៅក្រម ធ្វើឲ្យចៅក្រមត្រូវបានចាត់ទុកជាមន្ត្រីរាជការស៊ីវិល ដោយពឹងទៅលើអភិបាលកិច្ច និងការការពារខាងនយោបាយជាជាងពឹងផ្អែកទៅលើច្បាប់សម្រាប់សុវត្ថិភាពរបស់ខ្លួន។ តុលាការមិនអាចផ្តល់សេចក្តីទុកចិត្តដល់ប្រជាពលរដ្ឋរងគ្រោះ ដែលជាម្ចាស់អំណាចបានទេ។ ទម្រង់ដឹកនាំបែបនេះ តុលាការពុំអាចប្រើអំណាចយុត្តាធិការរបស់ខ្លួន ដើម្បីការពារសេរីភាព យុត្តិធម៌ ជូនប្រជាពលរដ្ឋបានឡើយ ផ្ទុយទៅវិញវាបានបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ទំនុកចិត្តជាសាធារណៈចំពោះសមត្ថភាពប្រព័ន្ធយុត្តិធម៌ ដែលជាចុងក្រោយអាចបង្កឲ្យមានចលាចលនៅក្នុងសង្គមជាពុំខាន។ មធ្យោបាយដើម្បីឲ្យប្រព័ន្ធយុត្តិធម៌ ដែលធានាឯករាជ្យភាព ឥតលំអៀង គឺរដ្ឋសភាជាតិចាំបាច់ត្រូវអនុម័ត ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃតុលាការ ដោយធ្វើបញ្ញត្តិយ៉ាងតឹងតែងហាមឃាត់សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចៅក្រម ព្រះរាជអាជ្ញា មិនឲ្យជាប់ពាក់ព័ន្ធនឹងគណបក្សនយោបាយនិងដាច់ខាតរក្សាឲ្យបានជាបុគ្គលឯករាជ្យពីគណបក្សនយោបាយ។

## ខ.តួនាទី និងភារកិច្ចរបស់តុលាការ

ជាទូទៅ តួនាទី និងភារកិច្ចរបស់តុលាការ គឺសម្រាប់វិនិច្ឆ័យ និងស្វែងរកយុត្តិធម៌ទំនាស់ រវាងបុគ្គលនិងបុគ្គល រវាងបុគ្គលនិងសង្គម។ ភារកិច្ច និងតួនាទី គឺដើរតួជាអាជ្ញាកណ្តាលក្នុងសកម្មភាពវិវាទ ដើម្បីដោះស្រាយបញ្ចប់ជម្លោះ និងរក្សាស្ថេរភាព សណ្តាប់ធ្នាប់សង្គមឲ្យមានរបៀបរៀបរយល្អ។ ភារកិច្ច និងតួនាទីតុលាការចាំបាច់ណាស់ត្រូវមានភាពឯករាជ្យយ៉ាងពិតប្រាកដ ហើយបំពេញតួនាទីនេះឲ្យបានត្រឹមត្រូវ ក្នុងគំនិតថា ខ្លួនត្រូវតែផ្តត់ផ្គង់នូវសន្តិសុខសង្គម និងសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋទូទាំងប្រទេស។ បើពិនិត្យមើលខ្លឹមសារនៃបទបញ្ញត្តិរដ្ឋធម្មនុញ្ញ អំណាចតុលាការ ជាអំណាចមួយដែលមានអំណាច និងកម្លាំងតាមផ្លូវច្បាប់យ៉ាងជាក់លាក់ក្នុងមុខងាររបស់ខ្លួន ដែលអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិមិនអាចបំពានបាន។ ទោះជារឿងក្តីកម្រិតណាក៏ដោយ មានតែតុលាការមួយតែប៉ុណ្ណោះ ដែលមានសិទ្ធិជំនុំជម្រះ វាជាការទទួលស្គាល់អំណាចតុលាការយ៉ាងទូលំទូលាយ។ តាមមាត្រា១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏បានបញ្ញត្តិពីប្រព័ន្ធតុលាការផងដែរៈ ទី១-ចៅក្រមទាំងឡាយកាត់ក្តីតាមភាពឥតលំអៀង ដោយផ្អែកលើហេតុការណ៍ដែលមាននៅចំពោះមុខ។ ទី២-កាត់ក្តីត្រូវគោរពតាមច្បាប់ដោយមិនព្រមទទួលនូវការគាបសង្កត់ការគំរាមកំហែង ឬការបំភិតបំភ័យ ដោយចំពោះមុខ ឬមិនចំពោះមុខ។ ទី៣-មានតែជនសង្ស័យករណីឧក្រិដ្ឋប៉ុណ្ណោះ ទើបអាចឈានទៅរកការឃុំខ្លួនបណ្តោះអាសន្នពន្យាពេលរហូតដល់ ៦ខែ(មាត្រា១៤)។

## គ.ករណីប្រព័ន្ធច្បាប់

នៅក្នុងបរិបទប្រជាធិបតេយ្យ សិទ្ធិសេរីភាពទូទៅ និងអំណាចរបស់ប្រជាពលរដ្ឋ ត្រូវបានបើកចំហទូលំទូលាយឲ្យប្រជាពលរដ្ឋ អាចប្រើប្រាស់បានតាមរយៈច្បាប់កំណត់ ដោយមិនសំដៅប្រើអំណាចតាមចិត្តចង់គ្មានគុណធម៌ប្រជាធិបតេយ្យនោះទេពោលគឺ ពលរដ្ឋម្នាក់ៗមានកាតព្វកិច្ចគោរពច្បាប់របស់ប្រទេសឲ្យបាន

ខ្ជាប់ខ្ជួន។ ឯការតាក់តែងច្បាប់ទាំងឡាយ ក៏មិនត្រូវដាក់កម្រិតព្រំដែនគាបសង្កត់ប្រជាពលរដ្ឋ ដែលជាម្ចាស់ដោគវាសនាឲ្យបាត់បង់សិទ្ធិសេរីភាព បាត់បង់ភាពជាម្ចាស់អំណាច ម្ចាស់ប្រទេស បាត់បង់ភាពថ្លៃថ្នូរជាមនុស្សនោះទេ។ ដោយហេតុថា នៅក្នុងសង្គមប្រជាធិបតេយ្យ ច្បាប់សំខាន់ៗទាំងឡាយដែលជាប់ទាក់ទងដល់អធិបតេយ្យពលរដ្ឋត្រូវឆ្លងកាត់ការសម្រេចចិត្តពីប្រជាពលរដ្ឋ។ យោងតាមស្មារតីរដ្ឋធម្មនុញ្ញកម្ពុជាពីឆ្នាំ១៩៩៣ដល់បច្ចុប្បន្ន បើទោះបីវិសាលភាពនៃច្បាប់កំពូលនេះបានកំណត់ពីសិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋតាមរយៈមាត្រា៥១ ដែលចែងថា ប្រជាពលរដ្ឋខ្មែរជាម្ចាស់ជោគវាសនានៃប្រទេសជាតិរបស់ខ្លួន អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ អំណាចបែងចែកដាច់ចេញពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការក៏ដោយ ក៏មាត្រានេះត្រូវបានរាំងខ្ទប់សិទ្ធិសេរីភាពក្នុងការប្រើអំណាចរួចទៅហើយ ដើម្បីសម្តែងមតិតាមទីសាធារណៈ គឺមាត្រា៧៨ត្រង់វាក្យខ័ណ្ឌទី២ ចែងថា អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈទៅវិញ។ លើសពីនេះចាប់តាំងពីឆ្នាំ១៩៩៣មកទល់នឹងឆ្នាំ២០១០នេះ មានការរីកចម្រើនច្រើននៅក្នុងប្រព័ន្ធច្បាប់ដោយរដ្ឋាភិបាលកម្ពុជាបានខិតខំពុះពារយ៉ាងខ្លាំង ដើម្បីធ្វើបច្ចុប្បន្នភាពច្បាប់ផ្សេងៗមួយចំនួន និង ដើម្បីបង្កើតច្បាប់ថ្មីដែលប្រទេសកម្ពុជាត្រូវការជាចាំបាច់ក៏ដោយ ប៉ុន្តែវានៅតែជាការព្រួយបារម្ភថា តើច្បាប់ទាំងនេះនឹងត្រូវអនុវត្តឲ្យមានប្រសិទ្ធិភាពបានដោយរបៀបណា ដែលចាំបាច់ក្នុងការធ្វើឲ្យប្រសើរឡើងពិតប្រាកដ នៃប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា ព្រោះសង្កេតឃើញថា ច្បាប់មួយចំនួនដែលបានអនុម័តរួចហើយនៅក្នុងឆ្នាំមុនកន្លងមកនៅមានការខ្វះចន្លោះដែលជាហេតុធ្វើឲ្យមិនអាចអនុវត្តបាន ឬអនុវត្តមិនមានប្រសិទ្ធិភាពនៅឡើយ។ ហើយសិទ្ធិសេរីភាពពលរដ្ឋក៏កាន់តែគាបសង្កត់លើសមុនទៀត តាមរយៈច្បាប់ស្តីសិទ្ធិក្នុងការធ្វើបាតុកម្មអហិង្សា។ ច្បាប់រៀបចំបាតុកម្មឆ្នាំ១៩៩១ តម្រូវឲ្យអ្នករៀបចំការតវ៉ាអហិង្សាជូនដំណឹងដល់អាជ្ញាធរជាមុនតែការអនុវត្តន៍ ជាក់ស្តែងអាជ្ញាធរចាត់ទុកបញ្ហានេះថា ជាការអនុញ្ញាតដែលមានការបញ្ជាក់ច្បាស់លាស់ជាមុនសិន។ ដោយឡែកច្បាប់បាតុកម្មថ្មីអនុម័តដោយរដ្ឋសភាជាតិកាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ គឺជាអត្ថបទច្បាប់ថ្មី ដែលកាន់តែរឹតបន្តឹងជាងច្បាប់ជាមុន និងបង្កឲ្យមានការព្រួយបារម្ភនៅក្នុងចំណោមប្រជាពលរដ្ឋទូទៅក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលដែរ ដែលក្នុងនោះមាន៦ចំណុចដែលគួរឲ្យព្រួយបារម្ភបំផុតៈ

១-លក្ខខណ្ឌដែលបានចែងសម្រាប់ឲ្យការតវ៉ាណាមួយស្របច្បាប់ មានភាពស្មុគស្មាញ និងរឹតត្បិតយ៉ាងខ្លាំងរហូតដល់ធ្វើឲ្យការរៀបចំបាតុកម្មមានលក្ខណៈដូចជាកាតព្វកិច្ចក្នុងការដាក់ពាក្យសុំទៅវិញ។

២-លក្ខខណ្ឌសម្រាប់ពន្យល់ការរឹតត្បិតការរៀបចំបាតុកម្មនេះ គឺជាការលើកឡើងនូវអំពើធ្វើឲ្យខូចខាតដល់សិទ្ធិសេរីភាព និងកិត្តិយសរបស់អ្នកដទៃ ប្រពៃណីល្អរបស់សង្គម និងសន្តិសុខជាតិ។ នេះជាលក្ខខណ្ឌមិនច្បាស់លាស់ និងមិនបើកចំហឲ្យមានការបកស្រាយយ៉ាងទូលំទូលាយទេ។ ដោយសារឈរលើមូលដ្ឋាននេះការរៀបចំបាតុកម្មអាចនឹងត្រូវបានហាមឃាត់។

៣-តាមអត្ថបទច្បាប់ដែលបានអនុម័តដោយរដ្ឋសភាជាតិ អាជ្ញាធរមានសិទ្ធិបដិសេធមិនអនុញ្ញាតឲ្យមានការរៀបចំបាតុកម្ម ប្រសិនបើមានព័ត៌មានទុកចិត្តថា ការរៀបចំបាតុកម្មនេះ អាចបង្កគ្រោះថ្នាក់ ឬធ្វើឲ្យ

ខូចខាតធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ចំណុចនេះ មានភាពមិនច្បាស់លាស់ រួចទៅហើយត្រង់ថា ព័ត៌មានទុកចិត្តបាននោះ មានន័យយ៉ាងដូចម្តេចនៅក្នុងបរិបទមាត្រា៩ នៃច្បាប់ស្តីពីបាតុកម្ម។

៤-លិខិតជូនដំណឹងរបស់អ្នករៀបចំគម្រោងបាតុកម្ម ត្រូវមានរៀបរាប់អំពីចំណុចមួយចំនួនរួមមាន ចំនួនអ្នកចូលរួមក្នុងបាតុកម្ម។ លក្ខខណ្ឌនេះមិនសមហេតុផលទាល់តែសោះ ដោយហេតុថា គេមិនអាចទស្សន៍ទាយទុកជាមុនបានទេថានឹងមានអ្នកចូលរួមធ្វើបាតុកម្មចំនួនប៉ុន្មាននាក់នោះ។

៥-អត្ថបទមួយចែងថា អាជ្ញាធរមានសមត្ថកិច្ចអាចចាត់វិធានការណ៍បញ្ឈប់/បំបែកបាតុកម្ម ទោះបីជាបាតុកម្មអហិង្សាក៏ដោយប្រសិនបើការរៀបចំបាតុកម្មនេះមិនបានដាក់លិខិតជូនដំណឹងជាមុន។ មិនមានការបញ្ជាក់ណាមួយ អំពីបាតុកម្មដែលរៀបចំឡើងភ្លាមៗដែលអាចស្ថិតនៅក្រោមមាត្រានេះឡើយ ហើយវាអាចនឹងត្រូវអាជ្ញាធរបញ្ឈប់ភ្លាមៗ ដោយមិនមានការពន្យល់នោះទេ។

៦-មាត្រា២៦នៃច្បាប់នេះចែងថា ប្រសិនបើក្បួនបាតុកម្មអហិង្សា ប្រែក្លាយទៅជាមានអំពើហិង្សា បង្កឲ្យមានការខូចខាតដល់ទ្រព្យសម្បត្តិឯកជន ឬសាធារណៈ នោះការជួសជុលការខូចខាត/សំណងនឹងជាបន្ទុករបស់ជនល្មើសនិងអ្នកចូលដៃ ប៉ុន្តែការធ្វើឲ្យខូចខាតទ្រព្យអ្នកដទៃត្រូវបានចែងយ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌ។ មាត្រា២៦ក៏បានចែងថា អ្នកដឹកនាំបាតុកម្មអាចក្លាយជាគោលដៅនៃបណ្តឹងព្រហ្មទណ្ឌស្ថិតក្រោយច្បាប់នេះផងដែរ។

ការគោរពច្បាប់សិទ្ធិមនុស្សមានភាពស្តួចស្តើងណាស់ ដរាបណាច្បាប់ដែលប្រើប្រាស់សព្វថ្ងៃនេះមិនស្របតាមបទដ្ឋានអន្តរជាតិ និងតុលាការក៏មិនគោរពអនុវត្តតាមទៀតនោះ។ ជាលទ្ធផលការគោរពសិទ្ធិសេរីភាព អំណាចប្រជាពលរដ្ឋ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងសន្តិសុខបុគ្គលនៅមានកម្រិតនៅឡើយ ព្រោះមកពីមាននិទណ្ឌភាព អំពើអយុត្តិធម៌ និងអំពើពុករលួយក្នុងស្ថាប័នតុលាការ ជាហេតុធ្វើឲ្យមានការថយចុះនៃការបណ្តាក់ទុនវិនិយោគផ្ទាល់ពីបរទេស។ ច្បាប់បានបញ្ញត្តិឲ្យមានស្ថាប័នឯករាជ្យ គឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនមែនជាសមាជិកគណបក្សនយោបាយ ដែលមានសមត្ថភាពគ្រប់គ្រាន់ទាំងចំណេះដឹង សីលធម៌វិជ្ជាជីវៈ គុណធម៌ ដើម្បីត្រួតពិនិត្យលើស្ថាប័នគតិយុត្តទាំងឡាយឲ្យមានតុល្យភាពនៃអំណាចរបស់រដ្ឋ(Checks and Balances) ដោយជានាឲ្យបាននូវការគោរព និងអនុវត្តច្បាប់ ព្រមទាំងអង្កេតរាល់ទង្វើទាំងឡាយ ដែលផ្ទុយនឹងច្បាប់ប្រព្រឹត្តដោយស្ថាប័នតុលាការ ដោយត្រូវកោះហៅយកមកកាត់ទោសតាមច្បាប់ឲ្យមានប្រសិទ្ធិភាព។

នៅឆ្នាំ២០០៨កន្លងមកនេះ ម្ចាស់ជំនួយអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបានរិះគន់យ៉ាងខ្លាំងក្លា និងទាមទារឲ្យមានការកែប្រែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះឡើងវិញ។ ព្រោះការរក្សាទុកសមាសភាពសមាជិកដដែលនោះ ក្រុមប្រឹក្សានេះនៅតែធ្វើការងារក្នុងជំហរបម្រើនយោបាយ ដែលរុញច្រានឲ្យស្ថាប័ននេះធ្លាក់ក្នុងស្ថានភាពបាត់បង់យុត្តិធម៌ គ្មានជំនឿទុកចិត្ត និងជះឥទ្ធិពលមិនល្អដល់ស្ថេរភាពសង្គមជាតិជាមិនខាន។ បើយើងគិតចាប់ពីការបោះឆ្នោតជាតិឆ្នាំ១៩៩៣មកដល់ឆ្នាំ២០១០ អស់រយៈពេលជាង១៧ឆ្នាំមកហើយ

ការដឹកនាំរដ្ឋាភិបាលកម្ពុជានៅដដែលៗ បញ្ហាជាឧបសគ្គនៃការអភិវឌ្ឍន៍ប្រទេសកម្ពុជា ក៏នៅតែដដែលដែរ ពុំទាន់មានអ្វីជាកែលំអ ជាសំខាន់ដែលជាវត្ថុបំណងរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោតឲ្យបានច្បាស់លាស់នៅឡើយទេ។ ប្រជាពលរដ្ឋគ្រប់ទិសទីជាច្រើន បានសម្ដែងនូវទុក្ខកង្វល់ជានិច្ចដូចជា អនាធិបតេយ្យនៃអំពើពុករលួយ និទណ្ឌភាព បញ្ហារំលោភដីធ្លី ការកាប់បំផ្លាញព្រៃឈើ នេសាទ គ្រឿងញៀន សេវាសុខភាព ភាពក្រីក្រ ភាពមិនប្រក្រតីក្នុងការបោះឆ្នោត បញ្ហារើសអើងនយោបាយ ការគំរាមកំហែងគាបសង្កត់ខាងនយោបាយ ការបង្ក្រាបលើសិទ្ធិសេរីភាពក្នុងការសម្ដែងមតិជាសាធារណៈ បាតុកម្ម-កូដកម្មអហិង្សា ការបញ្ឈប់ឲ្យដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ និងបន្តការបាត់បង់អ្នកវិនិយោគទុនផ្ទាល់ពីបរទេសជាដើម។ល។ ចំណុចនេះគឺបណ្ដាលមកពីភាពអយុត្តិធម៌ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន និងមកពីភាពទន់ខ្សោយក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស គោលការណ៍សិទ្ធិមនុស្ស នីតិរដ្ឋមានកម្រិត ជាពិសេសភាពមិនឯករាជ្យ និងពិបាករកឃើញយុត្តិធម៌របស់ប្រព័ន្ធតុលាការកម្ពុជា។

ដូច្នេះ អាសន្និដ្ឋានបានថាដើម្បីដោះស្រាយបញ្ហាទាំងអស់នេះឲ្យមានប្រសិទ្ធិភាព គឺចាំបាច់ត្រូវកែប្រែប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្នជាបន្ទាន់។ ឧទាហរណ៍ ដើម្បីបំបាត់អំពើពុករលួយ ត្រូវពឹងផ្អែកទៅលើច្បាប់ប្រឆាំងអំពើពុករលួយ ដែលអំណាចនៃច្បាប់នេះអាចផ្ដន្ទាទោសទៅលើជនពុករលួយបាន អាស្រ័យលើតុលាការយុត្តិធម៌ និងឯករាជ្យ។ ចុះបើរកឃើញថា មានមន្ត្រីជាន់ខ្ពស់ណាម្នាក់ប្រព្រឹត្តអំពើពុករលួយ តើតុលាការកម្ពុជាបច្ចុប្បន្នហ៊ានផ្ដន្ទាទោសមន្ត្រីជាន់ខ្ពស់នោះដែរឬទេ? ការកែប្រែប្រព័ន្ធតុលាការឲ្យឯករាជ្យពិតប្រាកដ កត្តាសត្យានុម័តត្រូវតែជ្រើសមន្ត្រីដឹកនាំតុលាការគ្រប់កម្រិត និងគ្រប់រាជធានី/ខេត្ត ចេញពីបុគ្គលឯករាជ្យមិនមែនមនុស្សរបស់គណបក្សនយោបាយនោះទេ។ ឯអ្នកកាន់អំណាចរដ្ឋាភិបាល ឬមេដឹកនាំគណបក្សនយោបាយដឹកនាំរដ្ឋាភិបាលចាំបាច់ត្រូវមានសីលធម៌ គុណធម៌ ស្រឡាញ់យុត្តិធម៌ គោរពស្រឡាញ់ប្រជាពលរដ្ឋទូទៅ ពោលគឺមិនត្រូវយកឥទ្ធិពលរបស់ខ្លួនទៅដាក់សម្ពាធលើឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ចៅក្រម ព្រះរាជអាជ្ញា ឬសមត្ថកិច្ចតុលាការទៀតនោះទេ។ ឯមន្ត្រីជាន់ខ្ពស់របស់តុលាការ និងសមាជិកឧត្ដមក្រុមប្រឹក្សាត្រូវចាកចេញពីតំណែងជាន់ខ្ពស់ពីគណបក្សនយោបាយឲ្យបានដាច់ បើខ្លួនពិតជាមានឆន្ទៈ ឧត្ដមគតិ មនសិការ ហើយចង់បំពេញកាតព្វកិច្ចដោយឯករាជ្យ អព្យាក្រឹត្យ និងចង់យកតួនាទីនេះបម្រើប្រជាពលរដ្ឋទូទៅ និងសង្គមជាតិមែនទែននោះ។

ដូច្នេះ ដើម្បីកែប្រែប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្នមានឯករាជ្យយុត្តិធម៌ ធ្វើឲ្យប្រជាពលរដ្ឋជឿទុកចិត្តបានត្រូវតែៈ ១-ធ្វើច្បាប់អព្យាក្រឹត្យចំពោះមន្ត្រីរាជការទូទាំងប្រទេស។ ២-ធ្វើច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាដាច់ដោយឡែកពីច្បាប់ស្ដីពីមន្ត្រីរាជការស៊ីវិលនិងរៀបចំឡើងវិញនូវសមាជិកឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម សមាសភាពចៅក្រមនៃសាលាជម្រះក្ដីបច្ចុប្បន្ន និងមន្ត្រីតុលាការគ្រប់កម្រិតសាលាជំនុំជម្រះក្ដីដោយត្រូវជ្រើសរើស(បោះឆ្នោត)ចេញពីបុគ្គលអព្យាក្រិត្យនិងឯករាជ្យ ដោយបញ្ញត្តិពីកម្រិតវិជ្ជាជីវៈ និងដាច់ខាតមិនត្រូវជ្រើស ចេញពីមន្ត្រីគណបក្សនយោបាយណាមួយនោះទេ។ ៣-ធ្វើឲ្យមានក្រមសីលធម៌ចៅក្រម។ ៤-រៀបចំតាក់

តែងច្បាប់ ដើម្បីធ្វើឲ្យស្ថាប័នព្រះរាជអាជ្ញាមានឯករាជ្យភាពជាក់ស្តែង។

ឯករាជ្យភាពតុលាការមានបីកត្តាៈ មានឯករាជ្យស្ថាប័ន ឯករាជ្យបុគ្គលចៅក្រម និងឯករាជ្យនៃការគិតពេលកាត់ក្តី។ ឯករាជ្យស្ថាប័ន គឺធ្វើយ៉ាងណាឲ្យស្ថាប័ននេះដាច់ដោយឡែកពីការជ្រៀតជ្រែករបស់អំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ មានថវិកាស្វ័យយ័ត មានអំណាច។ ឯករាជ្យពីនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ គឺការតែងតាំង ការដាក់វិន័យ និងការដកសមាជិកកំពូល មិនត្រូវមានការលូកដៃដោយប្រយោល ឬដោយផ្ទាល់ពីស្ថាប័នណាមួយឡើយ។ ថវិកាស្វ័យយ័ត គឺធ្វើយ៉ាងណាឲ្យថវិកាជាតិត្រូវមានគ្រប់គ្រាន់។ មានអំណាចធ្វើយ៉ាងណា គោរពសេចក្តីសម្រេចរបស់តុលាការ អ្នកបំពាន ឬមិនអនុវត្តតាម ត្រូវមានទោស និងទណ្ឌកម្ម។ ឯករាជ្យបុគ្គលរបស់ចៅក្រម គឺឯករាជ្យបុគ្គលគំនិតរបស់ចៅក្រម។

### ៤.២.៣ ករណីស្ថាប័នរាជរដ្ឋាភិបាល

នៅក្នុងសង្គមប្រជាធិបតេយ្យ គឺលើសពីកម្រងនៃក្រិត្យក្រមធម្មនុញ្ញ និងនីតិក្រមដែលកម្រិតបញ្ជាក់ថាតើរដ្ឋាភិបាលអាចបំពេញតួនាទីយ៉ាងណាទៅទៀត។ ក្នុងបរិបទប្រជាធិបតេយ្យរដ្ឋាភិបាល គឺគ្រាន់តែជាអង្គធាតុតែមួយគត់ដែលលាយឡំជាមួយអង្គធាតុដទៃទៀត នៅក្នុងរបៀបរបបសង្គមនៃស្ថាប័នបក្សនយោបាយ អង្គការ និងសមាគមជាច្រើន និងប្លែកៗគ្នា។ ភាពផ្សេងគ្នានេះហើយដែលគេហៅថាពហុនិយម(Pluralism) ហើយពហុភាពនិយមសន្មតថាក្រុមមានអង្គការចាត់តាំង និងស្ថាប័នជាច្រើននៅក្នុងសង្គមប្រជាធិបតេយ្យមិនអាស្រ័យលើរដ្ឋាភិបាល ដើម្បីមានជីវភាពស្របច្បាប់ ឬអំណាចរបស់ខ្លួនឡើយ។ រដ្ឋាភិបាលកើតឡើងដើម្បីប្រជាជនរស់នៅ ហើយប្រជាពលរដ្ឋរស់នៅមិនមែនដើម្បីបម្រើរដ្ឋាភិបាលឡើយ។ ពោលប្រជាជន គឺជាប្រជា-ពលរដ្ឋនៃរដ្ឋឯករាជ្យ មិនមែនជាអនុរាស្ត្ររបស់រដ្ឋឡើយ។ នៅពេលរដ្ឋការពារសិទ្ធិរបស់ពលរដ្ឋរបស់ខ្លួនជាការឆ្លើយតបប្រជាពលរដ្ឋប្រគល់សេចក្តីស្មោះត្រង់ និងជំនឿទុកចិត្តរបស់ខ្លួនជូនរដ្ឋវិញ។

រដ្ឋាភិបាល គឺជាអង្គការកំពូល នៃអំណាចនីតិប្រតិបត្តិរបស់ប្រទេស។ ក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបែបប្រជាធិបតេយ្យសភានិយម រដ្ឋាភិបាល ត្រូវបានបង្កើតឡើងតាមរយៈរដ្ឋសភា ដែលហៅថា ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើសមាសភាពគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលរដ្ឋសភា ដែលប្រព្រឹត្តទៅតាមបែបបទដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក្នុងក្របខ័ណ្ឌប្រជាធិបតេយ្យ។ នៅក្នុងសង្គមប្រជាធិបតេយ្យ អង្គការនីតិប្រតិបត្តិគឺជាអង្គការមួយដែលត្រូវបម្រើឆន្ទៈរបស់ប្រជាពលរដ្ឋ ហើយអំណាចដែលអង្គការរដ្ឋមួយនេះមានគឺជាអំណាចចាត់ចែងទៅតាមផ្លូវច្បាប់ និងប្រើប្រាស់ទៅតាមនយោបាយឲ្យមានតម្លាភាព ដោយពុំត្រូវប្រើស្រេចតែនឹងចិត្ត ដូចរដ្ឋាភិបាលផ្តាច់ការនោះទេ។ មានន័យថា រាល់សកម្មភាពទាំងឡាយរបស់អង្គការនីតិប្រតិបត្តិនេះ គឺត្រូវអនុវត្តឲ្យបានច្បាស់លាស់ និងស្របតាមរដ្ឋធម្មនុញ្ញ ដោយធានារក្សាសណ្តាប់ធ្នាប់សង្គម ការពារសន្តិសុខបញ្ចៀសសង្គ្រាម លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ និងជាអ្នករក្សាការពារសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋប្រកបដោយមនសិកាជាតិទូលំទូលាយ។ លើសពីនេះ

ទៅទៀត រាជរដ្ឋាភិបាលត្រូវតែបើកចំហនូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

ជាការពិតណាស់ថា អំណាចនីតិប្រតិបត្តិ គឺជារដ្ឋាភិបាលរបស់រដ្ឋ ឬរបស់ប្រទេសមួយដែលមាននីត្យានុកូលភាពអំណាចគ្រប់គ្រាន់ ដើម្បីមានឥទ្ធិពលគ្រប់គ្រងទៅលើដែនដីទាំងមូលរបស់រដ្ឋ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាល គឺជាឧទាហរណ៍អំណាចសម្រាប់ទ្រទ្រង់សុវត្ថិភាពរដ្ឋ ជាពិសេសជាក្បាលម៉ាស៊ីនដឹកនាំសង្គម ឬជាសមាគមនៃសមាជិកសង្គម ដែលមានតួនាទីសម្រាប់អនុវត្តតាមច្បាប់ ដែលអង្គការនីតិបញ្ញត្តិបានអនុម័ត និងសេចក្តីសម្រេចនានារបស់រដ្ឋសភា។ ប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រាន់ក្នុងការប្រើប្រាស់សិទ្ធិសេរីភាព និងអំណាចរបស់ខ្លួនតាមរយៈរាជរដ្ឋាភិបាល។ រាល់សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវទទួលពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ[២០៧]។ ក្នុងច្បាប់រដ្ឋ បានបើកសិទ្ធិ និងផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋអាចប្តឹងពីមន្ត្រីដែលកាន់អំណាចសាធារណៈឲ្យសងការខូចខាតទាំងផ្លូវការយ ទាំងសម្ភារៈ និងទាំងផ្លូវចិត្តក្នុងករណីដែលមន្ត្រីណាមួយបានប្រព្រឹត្តខុសមែននោះ គឺជាលក្ខខណ្ឌមួយនៃនីតិរដ្ឋ ដែលមានចែងក្នុងមាត្រា៣៩ មាត្រានេះចែងថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ អង្គការសង្គម និងបុគ្គលិកនៃអង្គការនោះ។ ផ្តើមចេញពីនេះ រាល់ការអនុវត្តន៍របស់អំណាចនីតិប្រតិបត្តិ ត្រូវមានលក្ខណៈតម្លាភាពត្រឹមត្រូវយុត្តិធម៌ និងស្របតាមច្បាប់ដែលបានចែង ហើយច្បាប់ដែលបានចែងនោះ គឺជាច្បាប់ដែលទទួលយកបានសម្រាប់ទាំងអស់គ្នារបស់ប្រជាពលរដ្ឋ។ រដ្ឋាភិបាល គឺជាអ្នកផ្តល់ ឬបំពេញសេវាកម្មគ្រប់បែបយ៉ាងដល់គ្រប់វិស័យនៅក្នុងប្រទេស និងបម្រើផលប្រយោជន៍ទូទៅដល់ប្រជាពលរដ្ឋក្នុងគោលដៅធ្វើឲ្យប្រទេសជាតិមានការរីកចម្រើន។ ចំណុចសំខាន់ នៃតួនាទីរបស់អង្គការនីតិប្រតិបត្តិដែលត្រូវបំពេញគឺៈ

- ធានាសិទ្ធិសេរីភាពដល់ប្រជាពលរដ្ឋ។
- អនុវត្តច្បាប់ដោយត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។
- ការពារបូរណភាពទឹកដី ឯករាជ្យជាតិ និងធានាអធិបតេយ្យភាពជាតិរឹងមាំព្រមទាំងធ្វើសហប្រតិបត្តិការទាំងអន្តរជាតិផងដែរ។
- គោរព និងអនុវត្តទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិឲ្យមានសមភាព។
- បម្រើផលប្រយោជន៍ធន្ទះរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោតទូទៅ ដោយគ្មានរើសអើង ប្រកាន់និន្នាការនយោបាយ។
- ជៀងវាងប្រព្រឹត្តអំពើពុករលួយ និងប្រកាន់បក្សពួកនិយម។
- រួបរួមគ្នាដើម្បីអភិវឌ្ឍជាតិឲ្យសេដ្ឋកិច្ចរីកចម្រើន។
- ជៀសវាងប្រើអំណាចផ្តាច់ការ គាបសង្កត់មកលើប្រជាពលរដ្ឋ។

[២០៧] មាត្រា៣៥ នៃច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

- រៀបចំសណ្ដាប់ធ្នាប់សាធារណៈឲ្យបានល្អ និងមានរបៀបរៀបរយនៅក្នុងសង្គម។

- រក្សាសន្តិសុខ សន្តិភាព ជូនប្រជាពលរដ្ឋ និងប្រទេសជាតិឲ្យបានល្អ ធ្វើយ៉ាងណាបង្ហាញថា រាល់ការបំពេញការងាររបស់ខ្លួន គឺបំណងបម្រើប្រជាពលរដ្ឋ និងប្រទេសជាតិឲ្យមានភាពកក់ក្ដៅ និងវឌ្ឍនភាព។

នាយករដ្ឋមន្ត្រីនិងគណៈរដ្ឋមន្ត្រី ជាបេះដូងនៃរាជរដ្ឋាភិបាលកម្ពុជា(មាត្រា១១៨-១២៧)[២០៨]។ គណៈរដ្ឋមន្ត្រីដឹកនាំដោយនាយករដ្ឋមន្ត្រី១រូប ដែលអមដោយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការមួយចំនួនទៀតជាសមាជិក។ គណៈរដ្ឋមន្ត្រីត្រូវបានរៀបចំនិងប្រព្រឹត្តទៅតាមច្បាប់កំណត់(ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី)។

រាជរដ្ឋាភិបាលមានភារកិច្ចទទួលខុសត្រូវលើការអនុវត្តន៍ និងកំណត់នយោបាយរដ្ឋស្របទៅតាមរដ្ឋធម្មនុញ្ញ និងមានភារកិច្ចការពាររដ្ឋ ការពារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈរបស់សង្គម និងផ្ដល់សេវាកម្មសាធារណៈ។ នាយករដ្ឋមន្ត្រី ជាប្រមុខនៃអង្គនីតិប្រតិបត្តិ ប្រមុខការិយាធិបតេយ្យ ជាអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ជាប្រមុខការទូត ដែលអនុវត្តអំណាចធ្វើសន្ធិសញ្ញា ចុះកិច្ចព្រមព្រៀងលើវិស័យផ្សេងៗជាមួយបរទេស ប្រកាសទទួល ឬមិនទទួលស្គាល់រដ្ឋាភិបាលបរទេស ជាមុខនីតិពន្ធ(ធ្វើសេចក្ដីព្រាងច្បាប់)។ នាយករដ្ឋមន្ត្រី មានអំណាចតែងតាំង ឬដកហូតសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកមន្ត្រី-រាជការជាន់ខ្ពស់ស៊ីវិល និងយោធា...[២០៩] អំណាចព្រាងច្បាប់ថវិកា...អំណាចចេញអនុក្រឹត្យ លិខិតបទដ្ឋានផ្សេងៗនិងបទបញ្ជាប្រតិបត្តិ...។ នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនជូនឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬសមាជិកគណៈរដ្ឋមន្ត្រី។ គណៈរដ្ឋមន្ត្រីត្រូវប្រជុំធំ ឬប្រជុំពិនិត្យស្រាវជ្រាវរៀងរាល់សប្ដាហ៍។ អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ដែលអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីឲ្យដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន។ កំណត់ហេតុអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រីត្រូវធ្វើថ្វាយព្រះមហាក្សត្រនិងរដ្ឋសភា ទ្រង់ជ្រាបនិងជ្រាប។ មុខងាររបស់សមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនឹងសកម្មភាពវិជ្ជាជីវៈ ខាងពាណិជ្ជកម្ម ឧស្សាហកម្ម និងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ តែពុំមានវិសមភាពទៅនឹងតំណែងជាសមាជិកសភានោះទេ។ ជាក់ស្ដែងមានសមាជិកមួយចំនួននៃរាជរដ្ឋាភិបាលមានតំណែងជាសមាជិកសភាទៀតផង (សម្ដេចនាយករដ្ឋមន្ត្រី ឯកឧត្ដមនាយករដ្ឋមន្ត្រី និងឯកឧត្ដមទេសរដ្ឋមន្ត្រី)។ ប្រការនេះសបញ្ជាក់ថា អំណាចនីតិប្រតិបត្តិញែកមិនដាច់ស្រឡះពីអំណាចនីតិបញ្ញត្តិទេ។ សមាជិករដ្ឋាភិបាលម្នាក់ៗមិនអាចសំអាងលើសេចក្ដីបង្គាប់ជា លាយលក្ខណ៍អក្សរ ឬដោយវាចាពីអ្នកណាម្នាក់ ដើម្បីដោះសារឲ្យរួចផុតពីការទទួល ខុសត្រូវបានឡើយ។ សមាជិករាជរដ្ឋាភិបាលម្នាក់ៗត្រូវទទួលទណ្ឌកម្ម ពីបទឧក្រិដ្ឋកម្ម ឬមជ្ឈឹមដែលខ្លួនបានប្រព្រឹត្តនៅពេលបំពេញការងារ។ ក្នុងករណីនេះ ឬក្នុងករណីធ្វើខុសជាក់ស្ដែងធ្ងន់ធ្ងរក្នុងសមត្ថកិច្ច រដ្ឋសភាកោះប្រជុំបោះឆ្នោតជាសម្ងាត់ ដោយមតិភាគច្រើនដាច់ខាតប្ដឹងទៅតុលាការ។

---

[២០៨] ព្រឹត្តិបត្រៈ ស្រាវជ្រាវ ឆ្នាំទី៣ ខែ១០-១១-១២ ឆ្នាំ២០០១ ទំព័រ ១៣-១៦

[២០៩] ច្បាប់ស្ដីពីការរៀបចំ និងការព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី មាត្រា៤ ឆ្នាំ១៩៩៤

អំណាចនីតិបញ្ញត្តិ ប្រតិបត្តិ និងតុលាការ ពិតជាបានចែងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់កំពូលនៃរដ្ឋធម្មនុញ្ញ។ តាមតថៈភាពជាក់ស្តែងបច្ចុប្បន្ននេះ ការអនុម័តច្បាប់របស់រដ្ឋសភាជាតិ និងការសម្រេចកាត់ក្តីតុលាការ គឺស្ថិតនៅលើអំណាចរដ្ឋាភិបាលទាំងស្រុង។ មេដឹកនាំរដ្ឋាភិបាលគ្រាន់តែហាមាត់ភ្លាម រដ្ឋសភាជាតិអនុម័តព្យួរអភ័យឯកសិទ្ធិតំណាងរាស្ត្រមកពីគណបក្សប្រឆាំងភ្លាម ដែលករណីទាំងនេះ គឺផ្ទុយនឹងបទបញ្ញត្តិដែលគ្មានការចូលរួមពីអន្តរជាតិ គឺប្រជុំដោយសម្ងាត់មិនឲ្យគណបក្សសមរង្ស៊ី(គណបក្សប្រឆាំងក្នុងរដ្ឋសភា) ដឹងជាមុន។ រដ្ឋាភិបាលគ្រាន់តែប្រើយុទ្ធសាស្ត្រកណ្តាប់ដៃដែកទៅលើមន្ត្រីនៅក្នុងស្ថាប័នតុលាការ ធ្វើឲ្យចៅក្រម និងព្រះរាជអាជ្ញាឈរជើង និងទទួលទណ្ឌកម្មព្រោងព្រាត។ ដូច្នេះហើយបានជាមតិសាធារណៈជននិយាយថារដ្ឋាភិបាលឥឡូវមានសិទ្ធិអំណាចធ្វើច្បាប់ផង និងកាត់ក្តីផង។ របៀបចាត់ចែងការងារបែបនេះ បានធ្វើឲ្យបញ្ហាសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា នៅតែជាបញ្ហាគួរឲ្យព្រួយបារម្ភកាន់តែខ្លាំងឡើង ដោយសារតែមេដឹកនាំរដ្ឋាភិបាល មិនបានបើកចំហឲ្យប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិសេរីភាពក្នុងការសម្តែងមតិតាមទីសាធារណៈបានទូលំទូលាយពេញលេញឡើយ បើទោះបីរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ និងកតិកាសញ្ញាអន្តរជាតិ ដែលកម្ពុជាខ្លួនឯងជារដ្ឋភាគីបានចុះហត្ថលេខាដោយបញ្ញត្តិយ៉ាងច្បាស់ អំពីការគោរពសិទ្ធិមនុស្ស និងផ្តល់ការធានាការពារសិទ្ធិយ៉ាងទូលំទូលាយ ដល់ប្រជាពលរដ្ឋក៏ដោយ ក៏ថ្នាក់ដឹកនាំខ្មែរមិនទាន់បានអនុវត្តទៅតាមច្បាប់កំពូលរបស់ប្រទេស និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិសេរីភាពប្រជាពលរដ្ឋបានល្អឡើយ។ ផ្ទុយទៅវិញអ្នកមានអំណាចនិងបក្សពួកនៅតែបន្តធ្វើការគំរាមកំហែងរំលោភសិទ្ធិប្រជាពលរដ្ឋយ៉ាងកំរោល ដើម្បីការពារអំណាច និងផលប្រយោជន៍ផ្ទាល់ខ្លួន។ នៅក្នុងឆ្នាំ២០០៩ កន្លងទៅមានការរឹតបន្តឹងយ៉ាងខ្លាំងថែមទៀតពីសំណាក់អាជ្ញាធរទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ តាមទីសាធារណៈដូចជាការធ្វើកូដកម្ម និង បាតុកម្មដោយអហិង្សា ដែលរៀបចំដោយប្រជាពលរដ្ឋជាជនរងគ្រោះក្រីក្រពីជម្លោះដីធ្លី ដែលមកតវ៉ានៅរាជធានីភ្នំពេញ។ ការបំបែករារាំងមិនឲ្យក្រុមបាតុករប្រមូលផ្តុំគ្នានៅកម្រិតភូមិ/ឃុំ ឬបើអាចគេចផុតពីការរំខាន ដោយ អាចប្រមូលផ្តុំគ្នាមកដល់ភ្នំពេញក៏មានការរំខានអុកឡុកមិនឲ្យប្រជាពលរដ្ឋទាំងនោះ ស្នាក់នៅតាមទីសាធារណៈបាននៅពេលយប់។ ចំពោះកូដកម្ម បាតុកម្មអហិង្សាណាដែលតវ៉ាទាមទារប៉ះពាល់ផលប្រយោជន៍របស់ក្រុមហ៊ុនដែលមានខ្នងក្រាស ឬអ្នកមានអំណាចធំត្រូវរងការបង្ក្រាបយ៉ាងតឹងរឹងពីអាជ្ញាធរប្រដាប់អាវុធ។ ដោយឡែកកូដកម្ម ឬបាតុកម្មណាដែលធ្វើឡើង ដើម្បីប្រឆាំងដូចជា ទំនិញឡើងថ្លៃ បញ្ហាព្រំដែនឬការសម្រេចចិត្តនានារបស់រដ្ឋាភិបាលសឹងតែធ្វើមិនបានទាល់តែសោះ។

នៅរៀងរាល់ឆ្នាំដែលប្រទេសកម្ពុជាប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ឃើញថាក្រុមអ្នកសង្កេតការណ៍ខាងអង្គការក្រៅរដ្ឋាភិបាលបាននិយាយថា ស្ថានការណ៍សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងការសម្តែងមតិ តាមទីសាធារណៈដោយអហិង្សាក្នុងប្រទេសកម្ពុជា ត្រូវរឹតបន្តឹងស្ថិតក្រោមការគំរាមកំហែងយ៉ាងខ្លាំង ពីគណបក្សកាន់អំណាច អ្នកមានអំណាច និងអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ការណ៍ទាំងនេះកំពុងតែរំលោភលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពពលរដ្ឋ និងជាន់ឈ្លីលើរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេស។

## ៤.២.៤ ឥរិយាបទប្រជាពលរដ្ឋ អំពីសិទ្ធិសេរីភាពក្នុងនយោបាយ

### ក.ប្រពៃណីរស់នៅក្នុងការគ្រប់គ្រងរដ្ឋ

ប្រជាពលរដ្ឋកម្ពុជារាប់ពាន់ឆ្នាំមកហើយ គឺមានប្រពៃណីរស់នៅក្នុងរបបគ្រប់គ្រងដែលទទួលឥទ្ធិពលយ៉ាងខ្លាំងពីសាសនាព្រាហ្មណ៍តាមរយៈលទ្ធិទេវរាជ ដែលត្រូវបានចាប់ផ្តើមអនុវត្តនៅក្នុងប្រទេសកម្ពុជា ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២(ប្រារព្ធធ្វើនៅឆ្នាំ៨០២នៅភ្នំគូលែន)។ លទ្ធិទេវរាជ គឺជាទស្សនាទានអំពីការគ្រប់គ្រងប្រទេសមួយបែប ដែលឈរលើគោលការណ៍ទេវរូបនីយកម្មឥស្សរៈជនមួយរូប។ ដែលជាមេដឹកនាំកំពូលនៅក្នុងប្រទេស គឺព្រះរាជា។ អំណាចទាំងស្រុងនៅក្នុងប្រទេសត្រូវស្ថិតនៅក្នុងកណ្តាប់ដៃរបស់ព្រះរាជា ដែលជាអាទិទេពមួយអង្គចុះមកសោយរាជនៅលើផែនដី។ បញ្ជាទាំងឡាយដែលចេញពីព្រះរាជា ក៏ដូចជា ចេញពីព្រះអាទិទេពដែរ ហើយបើបុគ្គលណាប្រព្រឹត្តតាមនោះនឹងបានផលប្រយោជន៍ បានកុសលផលបុណ្យយ៉ាងគាប់ប្រសើរ។ តែបើបែរជារឹងទទឹងវិញនោះនឹងត្រូវទទួងរងការផ្តន្ទាទោសជាទម្ងន់ ព្រមទាំងរង់ទុក្ខវេទនានៅជាតិក្រោយថែមទៀតផង។ ស្របតាមទស្សនាទាននៃលទ្ធិទេវរាជនេះ គេបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងប្រទេសមួយតាមបែបផ្តាច់ការ ប្រមូលផ្តុំនិយម ប្រព័ន្ធគហបតី ប្រព័ន្ធចៅហ្វាយនាយ និងកូនចៅ។ គួរកត់សម្គាល់ថា លទ្ធិទេវរាជបានបំពេញមុខងារសំខាន់បំផុត ក្នុងការសម្រេចចិត្តនូវឯកភាពជាតិខ្មែរនៅសម័យអង្គរ ហើយលទ្ធិទេវរាជនេះក៏បានដើរតួនាទីជាមូលដ្ឋានផ្នែកមនោគមន៍វិជ្ជា និងផ្នែកនយោបាយក្នុងការនាំប្រទេសកម្ពុជាឲ្យឈានទៅលើការរីកចម្រើនដ៏ល្បីល្បាញមួយនៅក្នុងប្រវត្តិសាស្ត្រជាតិ និងអន្តរជាតិ។ បើទោះបីលទ្ធិទេវរាជជាផ្លូវការណ៍បានស្លាប់បាត់បង់ទៅជាមួយនឹងការដួលរលំ នៃអរិយធម៌អង្គរដ៏ល្បីល្បាញក៏ដោយ ក៏ប្រពៃណីរបស់លទ្ធិនេះស្ថិតនៅក្នុងព្រលឹងនៃការដឹកនាំ និងគ្រប់គ្រងប្រទេស និងក្នុងការទំនាក់ទំនងរវាងអ្នកដឹកនាំ និងប្រជារាស្ត្រនៅតែបន្តរស់នៅក្នុងកោសិកាសង្គម និងក្នុងសតិសម្បជញ្ញៈជាតិនៅឡើយ។ គោលការណ៍សំខាន់របស់លទ្ធិនេះនៅតែបន្តដើរតួនាទីជាមូលដ្ឋានរួមនៃការអនុវត្តន៍យន្តការគ្រប់គ្រង និងជាចំណងយ៉ាងរឹងមាំ រវាងអ្នកដឹកនាំ និងប្រជារាស្ត្រខ្មែរ រហូតមកទល់នឹងពេលនេះ។ ដូច្នេះ នៅពេលដែលប្រទេសកម្ពុជាបានបោះបង់ចោលនូវរបបសម្បូណ៌អាជ្ញានិយម(Absolutism)មកវប្បធម៌ និងប្រពៃណីប្រជាធិបតេយ្យ គឺពិបាកនឹងចូល សណ្ឋិតក្នុងដួងព្រលឹងជាតិបានភ្លាមណាស់ព្រោះថា ជំនួសអ្វីដែលធ្លាប់បានដើរតួនាទីជាសារជាតិរបស់វប្បធម៌ ជាដួងព្រលឹង និងប្រពៃណីនយោបាយនៃសង្គមកម្ពុជា អស់រយៈកាលរាប់សតវត្សមកហើយ ហើយប្រពៃណីនេះក៏បានចាក់ឫសយ៉ាងជ្រៅរួចទៅហើយ នៅក្នុងផ្នត់គំនិតយោបាយ(Politicalmetality) នៃសង្គមខ្មែរ ព្រមទាំងបានក្លាយទៅជាមូលដ្ឋានដ៏រឹងមាំមួយយ៉ាងសំខាន់ ដែលតាមរយៈនេះគេអាចពន្យល់បានអំពីចរិតឥស្សរៈជននិយម(Cult of personality) និងអាជ្ញានិយម(Authoritar-ianism) នៃវប្បធម៌នយោបាយ(Political culture) និងប្រព័ន្ធគ្រប់គ្រងនៅកម្ពុជា។

ទស្សនៈស្តីពីអត្តចរិតខ្មែរមួយទៀតដែលគួរឲ្យកត់សម្គាល់ផងដែរនោះគឺ បើផ្អែកតាមសម័យអង្គរដ៏រុងរឿងនោះនិចលភាពរបស់ខ្មែរ គឺខ្មែរពូកែច្នៃប្រឌិត ជាពូជអ្នកជា ប៉ុន្តែពូកែធ្វើសង្គ្រាម ជាអ្នកមានថ្វីដៃចំពោះការធ្វើ

សឹកសង្គ្រាមបណ្តេញខ្មាំងឈ្លានពានទឹកដី មានចក្ខុវិស័យល្អក្នុងការដឹកនាំកងទ័ព ប៉ុន្តែលក្ខណៈសម្បត្តិ បែបនេះនាពេលបច្ចុប្បន្នត្រូវបានចុះអន់ថយយ៉ាងខ្លាំង បើប្រៀបទៅយុទ្ធសាស្ត្រសង្គ្រាមតាមបណ្តាប្រទេសនៅអឺរ៉ុប នេះប្រហែលជាខ្មែរបាត់បង់មូលដ្ឋានបច្ចេកទេស និងស្ថាប័នប្រាជ្ញាជាពុម្ពគំរូរបស់ខ្លួន[២១០]។ ទោះជាយ៉ាងណាក្តី ខ្មែរត្រូវបានទទួលស្គាល់ពីទេពកោសល្យពីធម្មជាតិរបស់ខ្លួនក្នុងយុទ្ធសាស្ត្រសឹកសង្គ្រាមផងដែរ ដូចជាកងទ័ពខ្មែរក្រហម ត្រូវបានគេចាត់ទុកថា ជាកងទ័ពដែលមានស្មារតី និងគោលជំហររឹងមាំមួយក្នុងពិភពលោក។

កត្តានេះហើយដែលរុញច្រានឲ្យកើតមានវប្បធម៌ក្នុងដំណើរជីវិតរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋខ្មែរនៅតែយល់ថា អ្នកដឹកនាំប្រទេស គឺជាពូជអាទិទេព ពូជអ្នកមានបុណ្យ ពូជគហបតី ហើយដាក់ខ្លួនយល់ព្រមរស់នៅក្នុងឋានៈជាកូនចៅរបស់អ្នកកាន់អំណាច។

### ខ. លក្ខខណ្ឌខាងផ្នែកចិត្តសាស្ត្រ និងសីលធម៌សង្គម

កត្តាសំខាន់មួយទៀតដែលជះឥទ្ធិពលផ្ទាល់ទៅលើការអនុវត្តន៍សិទ្ធិសេរីភាព ដែលជាមូលដ្ឋានគ្រឹះលទ្ធិប្រជាធិបតេយ្យក្នុងសង្គម គឺចិត្តសាស្ត្រ និងសីលធម៌សង្គម។ កន្លងមក មានអ្នកនិពន្ធជាតិ និងអ្នកនិពន្ធបរទេសជាច្រើនរូបបានលើកសរសើរអំពីចរិតស្លូតបូត ទន់ភ្លន់ សុភាពរាបសារ ឧស្សាហ៍ព្យាយាមរបស់ប្រជាជនកម្ពុជា។ ទាំងនេះគឺជាមោទនភាពដ៏ខ្ពង់ខ្ពស់របស់ប្រជាជនកម្ពុជា ជាពិសេសគឺរបស់ជនជាតិខ្មែរ។ ខ្មែរមានអារ្យធម៌ដ៏ប្រចះត្រចង់ ដែលអាចរួមបញ្ចូលគ្នាឲ្យមានសណ្តាប់ធ្នាប់ មានផ្នត់គំនិតស្នេហាជាតិ ការពារប្រទេសជាតិយ៉ាងមោះមុត ព្រលឹងចក្រពត្តិ និងជាតិនិយមប្តូរផ្តាច់។ ប៉ុន្តែផ្នត់គំនិតទាំងនេះ ត្រូវបានកប់ចោលយ៉ាងស្ងៀមស្ងាត់ក្រោមការបន្សាបផ្នត់គំនិតជាតិនិយមរបស់ខ្មែរ ដោយបរទេសទុច្ចរិតជិតខាងក្នុងផលប្រយោជន៍យុទ្ធសាស្ត្ររបស់គេ។ ប៉ុន្តែអ្នកណាក៏ដឹងដែរថា ប្រជាជនកម្ពុជាប្រមាណ៩០% ប្រកាន់ជឿលើព្រះពុទ្ធសាសនាថេរវាទ ដែលត្រូវបានគេចាត់ទុកថា ជាសាសនាមានការសន្តោសប្រណី និងសីលធម៌រស់នៅស្អាតស្អំបំផុត។ ចុះហេតុអ្វីក៏ប្រជាជនកម្ពុជាច្បាំងគ្នា កាប់សម្លាប់គ្នាមិនឈប់ឈរ ហើយពិបាកបង្រួបបង្រួមគ្នាវិញម្លេះ? ហេតុអ្វីក៏ចូលចិត្តដោះស្រាយទំនាស់ ឬជម្លោះដោយប្រើអាវុធ? ចម្លើយសូមធ្វើការវិភាគដូចខាងក្រោមៈ

បច្ចុប្បន្ន ក្រៅពីអត្តចរិតដ៏ល្អទាំងឡាយ ដែលបានរៀបរាប់មកខាងលើ ចង់ឬមិនចង់ យើងត្រូវទទួលស្គាល់នូវចរិតលក្ខណៈពីរផ្សេងទៀតរបស់ប្រជាជនកម្ពុជា គឺស្មារតីសួនតួនិយម(Egoism) និងយោធានិយម(Militar-ism) ក្នុងខ្សែជីវិតរស់នៅ និងក្នុងការដោះស្រាយបញ្ហាសង្គម។

ការសង្កេតមើលក្នុងប្រវត្តិសាស្ត្រជាតិខ្មែរ បានបង្ហាញឲ្យឃើញថា អត្តចរិតសួនតួនិយមនេះធ្លាប់មានតាំងពីយូរណាស់មកហើយ។ ឧទាហរណ៍ បញ្ហាទំនាស់ក្តីក្តាំ និងកាប់សម្លាប់គ្នាដោយសាររឿងទ្រព្យសម្បត្តិ ដីធ្លី គឺមិនមែនជារឿងថ្មី ដែលគេទើបតែបានដឹងបានឮ និងឃើញមានក្នុងពេលបច្ចុប្បន្ននេះទេ។ ចរិតសួនតួនិយម

---

[២១០] Pou.B.Etudes sun le Rama kerti,Paris,1974, page 45

នេះកើតមានឡើងដោយសារឥទ្ធិពលនៃលក្ខណៈពិសេសមួយចំនួន ដែលផ្សាភ្ជាប់ទៅនឹងលក្ខខណ្ឌភូមិសាស្ត្រ និងបែបផែននៃការរស់នៅរបស់ជនជាតិខ្មែរផងដែរ។

តាមស្ថានភាពភូមិសាស្ត្ររបស់ខ្លួន ប្រទេសកម្ពុជាមានរាងបាតខ្ទះមួយដ៏ធំ ដែលមានភ្នំ និង ខ្ពង់រាបនៅព័ទ្ធជុំវិញវាលទំនាបកណ្ដាលប្រទេស។ អាស្រ័យតាមលក្ខខណ្ឌភូមិសាស្ត្រនេះ គេអាចបែងចែកប្រជាជនកម្ពុជាទាំងអស់ជាពីរប្រភេទ គឺប្រជាជនដែលរស់នៅតាមតំបន់ភ្នំព័ទ្ធជុំវិញប្រទេស(ភាគច្រើនជនជាតិភាគតិចដែលគេនិយមហៅថា ខ្មែរលើ) និងប្រជាជនដែលរស់នៅក្នុងតំបន់វាលទំនាប និងខ្ពង់រាបកណ្ដាលប្រទេស។ ការសង្កេតប្រៀបធៀបបានបង្ហាញឲ្យឃើញថា ខ្មែរលើ និងខ្មែរកណ្ដាលមានរបៀបរស់នៅផ្សេងគ្នា ហើយស្ថិតក្នុងកម្រិតរីកចម្រើនផ្សេងគ្នា។ គួរកត់សម្គាល់ដែរថា ខ្មែរលើនៅកម្ពុជាមានចំនួនតិចបំផុត គឺប្រមាណជិត១% នៃចំនួនប្រជាជនសរុប។ មកទល់បច្ចុប្បន្ន ខ្មែរលើនៅមិនទាន់ចាកចេញផុតពីរបៀបរស់នៅបែបកុលសម្ព័ន្ធនៅឡើយទេ។ ប្រកបមុខរបរកសិកម្មដោយប្រើកម្លាំងដូចជា ដុតព្រៃ បុកជីដាំ ចិញ្ចឹមសត្វក្នុងផ្ទះបន្តិចបន្តួចបរបាញ់ និងសិប្បកម្មតូចតាចសម្រាប់តែផ្គត់ផ្គង់គ្រួសារប៉ុណ្ណោះ។ បើនិយាយពីសាសនាវិញ គឺពុំទាន់មានការរីកចម្រើនទេ ភាគច្រើនបន្តជឿនៅឡើយលើជំនឿបែបសន្តនិយម(Totemism) គឺជឿលើប្រភេទសត្វណាមួយ ដោយចាត់ទុកថា សត្វនោះជាមេបា បង្កើតវង្សត្រកូលរបស់ខ្លួន និងជឿបែបជីវចលនិយម(Animism)។ ការរស់នៅរបស់ពួកគេត្រូវស្ថិតនៅក្រោមបទដ្ឋាននៃកុលសម្ព័ន្ធដ៏តឹងរឹងដែលគ្មាននរណាម្នាក់អាចប្រព្រឹត្តល្មើសបាន។ បើប្រៀបធៀបជាមួយពួកកុលសម្ព័ន្ធខ្មែរលើនៅតាមតំបន់ខ្ពង់រាប និងវាលទំនាបមានការរីកចម្រើនខ្ពស់ជាង។ លក្ខខណ្ឌធម្មជាតិអនុញ្ញាតឲ្យគេរស់នៅបានតាមគ្រួសារ ក្នុងលក្ខណៈជាឯកជន ដោយមិនទាមទារនូវនិយតកម្មសង្គម (Social regulation)តឹងរឹងពេកទេ។ តាំងពីយូរលង់មកហើយ ថ្វីត្បិតតែព្រះរាជាត្រូវបានគេទទួលស្គាល់ថា ជាម្ចាស់លើអ្វីៗទាំងអស់នៅក្នុងប្រទេស ដែលរាប់បញ្ចូលទាំងដីធ្លីស្រែចំការផង ក៏ប៉ុន្តែជាតុពិតកសិករខ្មែរ ប្រកបរបរកសិកម្មលើដីស្រែរបស់គ្រួសារខ្លួន និងដោយប្រើប្រាស់មធ្យោបាយផ្ទាល់ខ្លួន។ ប្រការនេះបង្ហាញថា ប្រជាជនកម្ពុជាបានប្រកាន់នូវស្មារតីសួនតួនិយម និងស្មារតីករណីនិយម(Pragmatism)នៅក្នុងផ្នត់គំនិត (Mentality) ជនកម្ពុជា។

ម្យ៉ាងវិញទៀតស្មារតីទាំងនេះ ត្រូវបានទទួលការជួយពង្រឹងបន្ថែមទៀត ពីសំណាក់សីលធម៌រស់នៅបែបសម្ភារៈនិយម(ចាត់ទុកលុយកាក់ មាសប្រាក់ និងសម្ភារៈផ្សេងៗជាធំ ជាទីសក្ការៈ ឬជាសរណវត្ថុ (Fetishisation of money and goods) ដែលបានកើតឡើងតាមរយៈការលោតផ្លោះយ៉ាងគំហុកពីសេដ្ឋកិច្ច និងរបៀបរស់នៅតាមបែបកុំមុយនីស្តនិយម ទៅកាន់សេដ្ឋកិច្ចទីផ្សារសេរីនិយម ដែលបានហូរចូលយ៉ាងសកម្មក្នុងប្រទេសកម្ពុជានូវបែបផែននៃការរស់នៅ និងវប្បធម៌ សង្គមអ្នកប្រើប្រាស់(Consumer's Society) តាមរយៈប្រព័ន្ធព័ត៌មានជាតិ និងទំនាក់ទំនងអន្តរជាតិ។ ប្រជាជនកម្ពុជាដែលក្នុងនោះភាគច្រើនជាកសិករមានកម្រិតយល់ដឹងទាប រស់នៅក្នុងភាពអន់ថយក្រីក្រ ខ្វះព័ត៌មាន ឃ្លាតឆ្ងាយពីពិភពខាងក្រៅ គ្មានអ្វីជាមូលដ្ឋានរឹងមាំសម្រាប់ពិចារណា និងប្រៀបធៀបថ្លឹងថ្លែងរកចំណុចល្អអាក្រក់ឡើយ។ ការវិភាគខាងលើនេះ

អាចកត់សម្គាល់ឃើញថា កត្តាជាច្រើនពាក់ព័ន្ធទៅនឹងវប្បធម៌ ប្រពៃណី ចិត្តសាស្ត្រ និងសីលធម៌ដែលប្រមូលផ្តុំ សំយោគចូលគ្នាបង្កើតបានជាវប្បធម៌នយោបាយមួយ ដែលមានចរិតសាសនានិយម(Religionism) សមស្តនិយម(Totalitarianism)និងអាជ្ញានិយម(Authoritarianism)។

ចរិតសាសនានិយម បានស្តែងឡើងតាមរយៈរូបភាពនៃការយកជំនឿសាសនាមកធ្វើជាមធ្យោបាយ ក្នុងការពន្យល់បកស្រាយនូវបណ្តាបញ្ហាទាំងឡាយដែលកើតមានឡើងនៅក្នុងសង្គម និងជឿផ្តាប់មុខទៅលើ បុគ្គលណាម្នាក់ ឬមនោគមន៍វិជ្ជាណាមួយ ដោយគ្មានប្រើប្រាស់វិចារណញ្ញាណ និងទឡ្ហីករណ៍ជាក់ស្តែង សម្រាប់ជាមូលដ្ឋានក្នុងការត្រិះរិះពិចារណាទេ និងមានទម្លាប់ម្យ៉ាងបានចាក់ឫសទៅក្នុងផ្នត់គំនិត គឺបែងចែក មនុស្សក្នុងសង្គមជាអ្នកធំ និងអ្នកតូច អ្នកមានបុណ្យនិងអ្នកគ្មានបុណ្យ ព្រមទាំងមានទស្សនៈថា ពងមាន់ កុំជល់នឹងថ្មជាដើម។ ម្យ៉ាងវិញទៀត ពលរដ្ឋនៅពុំយល់ពីខ្លួនឯងថា មានតួនាទីសំខាន់យ៉ាងណាក្នុងការរួម ចំណែកស្តាបនាប្រទេស និងមិនអើពើចំពោះកិច្ចការងារទាំងឡាយ ដើម្បីស្ថាបនាសេចក្តីសុខឲ្យខ្លួន សហគមន៍ ខ្លួននិងសង្គមខ្លួននេះទេ តែបែរជាទ្រាំរស់នៅក្រោមការគាបសង្កត់ កេងយកកម្លាំងពលកម្ម អយុត្តិធម៌ និងភាព លំបាកវេទនាមិនចេះរើបម្រាស់ទៅវិញ។ ថែមទាំងចាត់ទុកថា ភាពលំបាកតោកយ៉ាកតាមទស្សនៈកម្មផលនៃទ្រឹស្តី របស់សាសនា។ នេះគឺជាគំនិតយល់ខុសឆ្គងចំពោះខ្លួនឯង និងជាពិសេស គឺយល់ខុសចំពោះទ្រឹស្តីព្រះពុទ្ធ សាសនា។ ព្រះពុទ្ធសាសនា បានប្រៀនប្រដៅមនុស្សឲ្យមានវឌ្ឍនភាព ចេះស្វែងរកចំណេះដឹង និងសីលធម៌ គុណធម៌។ ព្រះពុទ្ធសាសនាបង្រៀនមនុស្សឲ្យមានសេចក្តីក្លាហាន ស្មារតីរឹងមាំ សាមគ្គីគ្នា រើបំរាស់ដោយ ពឹងលើកម្លាំង និងប្រាជ្ញាញាណរបស់ខ្លួនឯង ដើម្បីដោះស្រាយបញ្ហាជីវិតខ្លួនឯង និងសង្គមមនុស្ស និងបង្រៀន ថា ការរស់នៅក្រោមអំណាចជិះជាន់ពីអ្នកដទៃ គឺជាសេចក្តីទុក្ខ ដូច្នេះតោងត្រូវខំប្រឹងប្រែងតវ៉ាទាមទារ និងរំដោះ សិទ្ធិសេរីភាព ឬឥស្សរភាពទាំងក្នុងខ្លួនដែលមាន "ចិត្តទាសភាពនៃតណ្ហា..." "ទាំងខាងក្រៅខ្លួន ដែលមានខ្លួនជា ទាសករនៃអ្នកដទៃដែល" មករស់នៅក្នុងស្ថានភាព ជឿនលឿន ថ្លៃថ្នូរ សន្តិភាព និងបង្រៀនថា ចំណេះដឹង ខ្ពង់ខ្ពស់ និងបញ្ញាជារស្មីដ៏មានអំណាចនៃជីវិត និងជាពន្លឺនៃពិភពលោក។

ចរិតសមស្តនិយម(Totalitarinism) បានឲ្យឃើញតាមរយៈបំណងក្នុងការឱបក្រសោបត្រួតត្រាគ្រប សង្កត់ ក្នុងសង្គមទាំងមូលតែម្នាក់ឯង ធ្វើយ៉ាងណាបំបាក់ស្មារតីរបស់អ្នកដែលមិនចំណុះ ឬប្រឆាំងនឹងខ្លួនដោះ ស្រាយបញ្ហាទាំងឡាយក្នុងសង្គមតាមគោលការណ៍មិត្តឬសត្រូវ ដោយប្រើវិធីហិង្សា និងការបង្រ្កាបជា មូលដ្ឋាន។ ប្រការនេះបានធ្វើឲ្យកើតមានឡើងនូវទំនាស់ប៉ែងជើង ដណ្តើមអំណាចគ្នាជាប់មិនដាច់ ដែល ប្រជាជនសាមញ្ញច្រើននិយាយពីបាតុភូតបែបនេះថា "ឲ្យតែលាស់ក្តិចត្រួយ"។ ដោយយកសម្ភារៈជាទិសដៅ បានប្រមូលផ្តុំគ្នាដើម្បីជិះជាន់ បានបន្សល់ទុកនូវគំនុំ ការអាក់អន់ចិត្តក្នុងសង្គម។

ចំណែកឯចរិតអាជ្ញានិយមវិញបានឆ្លុះបញ្ចាំងឡើង នូវការគោរពស្រឡាញ់ការពារអំណាចចាត់ទុកអំណាច ជាធំ យកអាជ្ញាធ្វើជាវិធីសម្រាប់ដោះស្រាយបញ្ហាផ្សេងៗនៅក្នុងសង្គម និងជំនឿយ៉ាងងប់ងុលថា អំណាច គឺជាប្រភពអ្វីៗទាំងអស់។ មហាជនភាគច្រើនដែលរស់នៅក្នុងសង្គមមិនត្រឹមតែត្រៀមខ្លួនជាស្រេច ដើម្បីគោរព

អំណាចប៉ុណ្ណោះទេ គឺថែមទាំងពិបាករស់នៅដោយគ្មានការគាបសង្កត់ពីលើទៀតផង។ នៅក្នុងបរិយាកាសសង្គមបរិយាកាសបែបនេះ ច្បាប់មិនសូវមានន័យប៉ុន្មានដូចអំណាចឡើយ។ ច្បាប់ គឺគ្រាន់តែជាឧបករណ៍មួយសម្រាប់អនុវត្តអំណាចតែប៉ុណ្ណោះ វប្បធម៌នយោបាយបែបនេះ ជះឥទ្ធិពលយ៉ាងខ្លាំងលើការយល់ដឹងរបស់ប្រជាពលរដ្ឋ។

ដូច្នេះសរុបសេចក្តីមកឃើញថា ឥរិយាបថផ្នត់គំនិត ទំនៀមទម្លាប់ ប្រពៃណី ចំណេះដឹងរបស់ប្រជាពលរដ្ឋកម្ពុជា ភាគច្រើននៅពុំទាន់យល់បានច្បាស់លាស់ អំពីតម្លៃ អំណាច សិទ្ធិសេរីភាពរបស់ខ្លួននៅក្នុងសង្គមប្រជាធិបតេយ្យនៅឡើយទេ។ ភាគច្រើននៃប្រជាពលរដ្ឋកម្ពុជា ចូលចិត្តសម្ងំសុខនិយម ពុំសូវចូលរួមជួយគ្នាសហការគ្នា មានចរិតបាក់ស្បាត ខ្លបខ្លាច រៀងចាល ខ្វះការតស៊ូ ឆាប់ភ្លេច ខ្លាចស្លាប់... សុខចិត្តរស់នៅក្រោមការគាបសង្កត់ គឺវាផ្ទុយស្រឡះពីសកម្មភាព និងភាពម៉ឺងម៉ាត់របស់ប្រជាពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យដែលតម្រូវឲ្យប្រជាពលរដ្ឋជាម្ចាស់ប្រទេស ម្ចាស់អំណាចមានសទ្ធាសម្បយុត្ត តាំងចិត្តក្លាហានចូលរួមសហការគ្នាយ៉ាងសកម្ម ក្នុងការប្រើប្រាស់សិទ្ធិសេរីភាព ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិការពារផលប្រយោជន៍រួមគ្នាមិនត្រូវចុះញ៉មចំពោះការប្រើអំណាចហួសព្រំដែនពីស្ថាប័នណាមួយឡើយ។

## ៤.៣ យន្តការពង្រឹងសិទ្ធិសេរីភាពប្រជាពលរដ្ឋ

### ៤.៣.១ ការអប់រំ និងជម្រុញអង្គការសង្គមស៊ីវិលចូលរួមពង្រឹងសិទ្ធិសេរីភាព

ទស្សនវិទូនានាបានចាត់ទុកថា **ពុទ្ធិ** ឬចំណេះដឹងបាននាំមកឲ្យមនុស្សជាតិ អំពីអរិយធម៌ និងលើកតម្កើងពួកគេឲ្យខ្ពស់លើសពីសត្វនានា ពុទ្ធិនេះហើយដែលបានសាងប្រវត្តិសាស្ត្រមនុស្សជាតិ និងជាអ្នកនាំដំណើរជីវិតមនុស្សឲ្យឈានមកដល់ជំហានដ៏ឧត្តុង្គឧត្តម ហេតុធ្វើឲ្យមនុស្សគ្រប់គ្រងលើប្រវត្តិសាស្ត្រខ្លួនឯង និង លើធម្មជាតិបានទៀតផង។

ជាការពិតហើយថា ពុទ្ធិនេះ មនុស្សបានមកពីធម្មជាតិ ហើយដុសខាត់ដោយបទពិសោធន៍យូរ និងច្នៃប្រឌិតវាឲ្យកាន់តែមានពន្លឺភ្លឺត្រចះត្រចង់ដោយប្រើប្រាស់ការអប់រំជាមធ្យោបាយ។ ការអប់រំ គឺជាគ្រាប់ពូជសម្រាប់ដាំបណ្តុះធនធានមនុស្សនៅលើគ្រប់វិស័យ និងធ្វើឲ្យមនុស្សទទួលបានចំណេះដឹងថ្មីៗ និងជឿនលឿនជាច្រើន។

សង្គមចាំបាច់លើកទឹកចិត្តដល់ការអប់រំក្នុងការដាក់បញ្ចូលគ្នានៃតម្លៃនយោបាយ និងការអត់ឱនតម្លៃនយោបាយជាបឋម នៅក្នុងការស្វែងយល់ឲ្យច្បាស់អំពីខ្លឹមសារសហប្រតិបត្តិការ ដើម្បីទាក់ទងនៅគ្រប់វិស័យរបស់សង្គម ដើម្បីឆ្លងចូលទៅក្នុងសកលភាពនៃពហុវប្បធម៌ ក្នុងពហុភាពផ្សេងៗគ្នាក្នុងសង្គមស៊ីវិល។

អប់រំនៃធម្មនុញ្ញប្រជាធិបតេយ្យសេរី ចាំបាច់ដាក់ទិសដៅចំពោះការអប់រំកុមារ ដោយមានចក្ខុវិស័យនៃកម្មវត្ថុដូចជា ចំណេះដឹងខាងធម្មនុញ្ញនិងសិទ្ធិជាពលរដ្ឋរបស់គេ។ ឧទាហរណ៍គេយល់ថា មនសិការនៃសេរីភាពមាននៅក្នុងសង្គមរបស់គេនិងការទាមទារសេរីភាពមិនមែនការប្រឆាំងច្បាប់ទេ ហើយគេនៅតែជាសមាជិកពេញសិទ្ធិនៅពេលដែលគេពេញវ័យ ព្រមទាំងគ្មាននរណាអាចដកសិទ្ធិជាមូលដ្ឋាន ដូចជាខ្លាចដាក់ទណ្ឌកម្ម ដោយការ

ទាមទារសិទ្ធិជាមូលដ្ឋាននេះឡើយ។ ភស្តុតាងនេះបញ្ជាក់ថា រដ្ឋប្រជាធិបតេយ្យសេរីមិនត្រឹមតែមានភាពខុសគ្នាលើការអប់រំទេ ប៉ុន្តែក៏មិនអព្យាក្រឹត្យភាពក្នុងប្រសិទ្ធភាព និងឥទ្ធិពលផងដែរ។ បំណងនៃការដាក់បញ្ចូលនូវតម្លៃនយោបាយ ដើម្បីអប់រំ និងលើកទឹកចិត្ត។ ដូច្នេះការបង្រៀនចំពោះកុមារ ជាសំខាន់ គឺការអត់ឱនក្នុងសកលភាព។ ចំពោះមុខសកលភាពមានន័យថា ឆន្ទៈដើម្បីរួមរស់ដោយសន្តិភាពចំពោះដំណើរជីវិតផ្សេងៗតាមភាពចាំបាច់របស់ខ្លួន។ តើគ្មានការគិតគូរលើការដែលមិនអាចទ្រាំទ្របាននៃការគោរសង្កត់ដែរឬទេ? ដូចជាតម្លៃនយោបាយនៃការអត់ឱសម្រាប់សកលភាពមិនអាចបញ្ចូលគ្នាឲ្យទូលំទូលាយនិងនៅមាន ភាពងាយបាក់បែកនៅឡើយ មិនអាចជៀសរួចទេ ពេលដែលការអប់រំនៃនយោបាយសេរីក្នុងលក្ខណៈមិនសុក្រិត្យនៃសកលភាព[២១១]។

ដូច្នេះអាចសន្និដ្ឋានថា ការអប់រំដើរតួយ៉ាងសំខាន់ក្នុងការស្តាបនាកែប្រែផ្នត់គំនិតនិងរបៀបរស់នៅរបស់មនុស្សជាតិ និងបេះដូងឃោរឃៅព្រៃផ្សៃដូចសត្វជាតុក្លាយជាផ្នត់គំនិត និងបេះដូងស្រឡាញ់ការរីកចម្រើនសុខសន្តិភាព ស្អប់ខ្ពើមសង្គមប្រតិកិរិយានិងការបង្ហូរឈាម។ លោក Megaranco គរុវិទូដ៏ល្បីល្បាញ បានពោលទុកមកថា ការអប់រំអាចផ្លាស់ប្តូរសារជាតិមនុស្សពីល្អទៅអាក្រក់ ឬពីអាក្រក់មកល្អវិញបាន។ លោកឲ្យ តម្លៃយ៉ាងខ្លាំងទៅលើការអប់រំ ហើយចាត់ទុកថា ការអប់រំជាអ្នកកំណត់សារជាតិមនុស្សដោយ ពុំមែនជាតិកំណើតនោះទេ។ ហេតុដូច្នេះហើយទើបការអប់រំដ៏ល្អបានដើរតួនាទីមួយយ៉ាងសំខាន់បំផុតសម្រាប់គ្រប់ការអភិវឌ្ឍន៍នានា។ ប្រទេស ឬ សង្គមមួយអាចរីកចម្រើនទៅបានលុះណាតែ សង្គមនោះសម្បូរណ៍អ្នកចេះដឹង មានន័យថា បើគេចង់អភិវឌ្ឍ សង្គមមួយ គេត្រូវពង្រឹងការអប់រំ ដាំបណ្តុះធនធានមនុស្សជាមុនសិន ឬថាសង្គមួយ អាចប្រព្រឹត្តទៅបាន លុះណាតែពលរដ្ឋនៃសង្គមនោះ ជាអ្នកដែលទទួលបាន ការអប់រំយ៉ាងល្អប្រពៃ ពោលគឺ គេមិនអាចអភិវឌ្ឍសង្គមមួយសុទ្ធតែមនុស្សល្ងង់ខ្លៅនោះទេ។ ដូច្នេះហើយទើបនៅលើពិភពលោកបច្ចុប្បន្ននេះ រាល់ការអភិវឌ្ឍន៍ទាំងឡាយ សុទ្ធតែត្រូវចាប់ផ្តើមជាដំបូង គឺការអភិវឌ្ឍន៍វិស័យអប់រំ ហើយការអប់រំ ពលរដ្ឋឲ្យក្លាយទៅ ជាមនុស្សមានចំណេះដឹង គឺជាកម្លាំងដ៏មានសក្តានុពល រុញច្រានវឌ្ឍនភាពរបស់ប្រទេសបានយ៉ាងឆាប់រហ័សនិងមានប្រសិទ្ធិភាពខ្ពស់។

ដោយសារតែសង្គមខ្មែរទើបតែបញ្ចប់ពីសង្គ្រាម ទើបស្រមោលនៃអំពើហិង្សា ការបាត់ទំនុកចិត្ត និងការបែកបាក់បានក្លាយទៅជាមរតកដ៏អាក្រក់ សម្រាប់ដំណើរការកសាងសន្តិភាព និងប្រជាធិបតេយ្យ។ បច្ចុប្បន្នប្រទេសកម្ពុជាយើងដែលកំពុងតែបោះជំហានបន្តិចម្តងៗឆ្ពោះទៅរកការអប់រំសារជាថ្មីឡើងវិញ។

នៅក្នុងស្ថានភាពបែបនេះ សង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការកសាង និងដាំបណ្តុះផ្នត់គំនិតស្រឡាញ់សន្តិភាព រដ្ឋធម្មនុញ្ញ និងប្រជាធិបតេយ្យ។ លើសពីនេះទៀត សង្គមស៊ីវិលមានតួនាទីយ៉ាងសកម្មក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេវាកម្មសម្រាប់ទ្រព្យសម្បត្តិរួម។ សង្គមស៊ីវិលជានាប់រងស្វែងរកចម្លើយដោយឡែក ក្នុងឋានៈជាអ្នកមានមុខនៅចន្លោះរដ្ឋ និងផ្នែកសេដ្ឋកិច្ចពាណិជ្ជកម្ម។ សង្គមស៊ីវិល

---

[២១១] វង្ស អែមសំអានៈ ដំណើរឆ្ពោះទៅកាន់សង្គមស៊ីវិល ភ្នំពេញ ឆ្នាំ២០០២ ទំព័រ ២-៣

ជានាអះអាងអំពីការមិនចុះសម្រុងសម្រាប់ការត្រួតត្រារបស់រដ្ឋ ឬសាជីវកម្មដ៏ទូលំទូលាយ តែសង្គមស៊ីវិលមិនមែនកំណត់ព្រំដែនសម្រាប់ អ្នកបរិស្ថាន សហជីព កម្មករ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមហាជនឡើយ។ សង្គមស៊ីវិលធ្វើសកម្មភាពប្រកបដោយឥរិយាបថ រិះគន់ស្ថាបនាចំពោះរដ្ឋាភិបាល និងអង្គការអន្តរជាតិសម្រាប់កែទម្រង់គ្រប់វិស័យ ដើម្បីផលប្រយោជន៍ និងតម្រូវការមូលដ្ឋានរបស់ប្រជាជន ជាជាងគោលនយោបាយដែលផ្តល់អាទិភាពដល់មូលធនអន្តរជាតិ។ សង្គមស៊ីវិលត្រូវតែយល់ដឹងអំពីតម្លៃ និងការនិយមនានា ដើម្បីស្តែងឲ្យឃើញទំនាក់ទំនងសង្គម និងសំណើដោះស្រាយបញ្ហា។ សង្គមស៊ីវិលបណ្តុះស្មារតីប្រជាធិបតេយ្យ និងស្មារតីសន្តិភាពពីថ្នាក់លើរហូតដល់មូលដ្ឋានថ្នាក់ក្រោម ហើយគូសវាសអាណត្តិនៃប្រជាធិបតេយ្យ និងសន្តិភាពតាំងពីសហគមន៍ក្នុងស្រុក និងក្រៅស្រុក[២១២]។

សង្គមស៊ីវិលមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍វប្បធម៌សន្តិភាព និងអហិង្សាធម៌ ជាពិសេស គឺក្នុងរូបភាពជាអង្គការស្តីពីសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យក្នុងគ្រួសារ និងការលើកកម្ពស់ស្ត្រីភេទឲ្យក្លាយទៅមាតាដ៏ល្អក្នុងគ្រួសារ ក៏ដូចជាសង្គមជាតិទាំងមូលផងដែរ[២១៣]។

ព្រមជាមួយគ្នានេះ វិភាគទានរបស់អង្គការសង្គមស៊ីវិល ដើម្បីអភិវឌ្ឍសិទ្ធិសេរីភាពក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជាមានសារៈសំខាន់ និងចាំបាច់ណាស់។ អង្គការសង្គមស៊ីវិលមានតួនាទី ជួយស្ថាបនាស្ថេរភាពនយោបាយប្រជាធិបតេយ្យផ្ទៃក្នុងរបស់ជាតិយើង និងនៅក្នុងតំបន់ ក៏ដូចជាប្រទេសនានានៅលើពិភពលោកទាំងមូលផងដែរ។ សង្គមស៊ីវិលទប់ស្កាត់ និងប្រឆាំងតបចំពោះការបំផ្លិចបំផ្លាញលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ សង្គមស៊ីវិលទូទៅមានតួនាទីសំខាន់បីយ៉ាង:

(១)-ជួយជាំបណ្តុះ ពង្រឹងការអនុវត្តន៍សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋជាមូលដ្ឋានក្នុងលទ្ធិប្រជាធិបតេយ្យ ដើម្បីអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យឲ្យក្លាយទៅជាព្រលឹង ជាវប្បធម៌មួយរបស់ជាតិយើង។ ភារកិច្ចដ៏ សំខាន់នេះ គឺត្រូវបន្តជំរុញដាក់បញ្ចូលអំពីសិទ្ធិសេរីភាព អំណាចនៅក្នុងលទ្ធិប្រជាធិបតេយ្យ ទៅក្នុងកម្មវិធីសិក្សាជាតិ។

(២)-ជួយស្ថាបនាយុវជនប្រជាធិបតេយ្យឲ្យបានច្រើននៅក្នុងកម្លាំងយោធា នគរបាល សិស្សានុសិស្ស មហាជន បញ្ញវ័ន្ត និងក្នុងជួរប្រជាពលរដ្ឋទាំងមូល។

(៣)-ជួយអប់រំផ្សព្វផ្សាយអំពីលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានជនបទ។ គោលការណ៍នេះគឺដើម្បីឲ្យពលរដ្ឋក្លាយទៅជាម្ចាស់អំណាចពិតប្រាកដ។

ការចូលរួមរបស់បណ្តាគណបក្សនយោបាយ របស់អង្គការមិនមែនរដ្ឋាភិបាល និងរបស់មហាជនគ្រប់ស្រទាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅក្នុងដំណើរការប្រជាធិបតេយ្យ គឺជាកត្តាចម្បងមួយទៀតដែលជួយគាំទ្រដល់ជ័យជម្នះនៃលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេស។ ពិតណាស់ថា នៅក្នុងដំណាក់កាលដំបូងគេ

---

[២១២] កៅ គីមហួនៈ ការកើតឡើងនៃសង្គមស៊ីវិល ការលើកកំពស់សិទ្ធិមនុស្ស និងវឌ្ឍនភាពនៃលទ្ធិប្រជាធិបតេយ្យ CICP ភ្នំពេញ ២០០១ ទំព័រ ៣១

[២១៣] ដ.ឯ.ម ទំព័រ ៨០

អាចជួបនឹងបញ្ហាជាច្រើន ដោយសារការយល់ដឹងរបស់មហាជនទូទៅអំពី សិទ្ធិសេរីភាព ប្រជាធិបតេយ្យ ច្បាប់ វិន័យ និងអំពីការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋម្នាក់ៗ នៅចំពោះមុខសង្គមទាំងមូលនៅមានកម្រិតទាបនៅឡើយ។ តែទោះជាយ៉ាងណាក៏ដោយ ការចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ(Democratic Process) អាចផ្តល់លទ្ធភាពឲ្យប្រជាពលរដ្ឋទាំងអស់គ្នារៀនសូត្រនិងយល់ដឹងអំពីកិច្ចការទាំងអស់នេះបានកាន់តែច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។ នេះគឺជាចំណែកមួយនៃកិច្ចការកសាងមូលដ្ឋានវប្បធម៌ប្រជាធិបតេយ្យ ការកែប្រែឥរិយាបថរបៀបរស់នៅ និងផ្នត់គំនិតរបស់ប្រជាជន[២១៤]។ ពិតមែនតែកិច្ចការដឹកនាំប្រទេស ត្រូវបានប្រគល់ទៅរដ្ឋាភិបាលក៏ដោយ ប៉ុន្តែមិនមែនមានន័យថា ពលរដ្ឋត្រូវស្ថិតក្រោមអំណាចដាច់ខាតរបស់បុគ្គល ឬក្រុមអ្នកដឹកនាំ ឬថាអ្នកដឹកនាំជាអ្នកសម្រេចអ្វីៗគ្រប់យ៉ាងស្រេចតែអំពើចិត្ត ឬជាភារកិច្ចផ្តាច់មុខរបស់រដ្ឋាភិបាលនោះទេ គឺទាមទារឲ្យមានការចូលរួមពីសំណាក់ពលរដ្ឋផងដែរ។ គ្រប់ពេលទាំងអស់ពលរដ្ឋជាដៃគូរបស់រដ្ឋាភិបាល បើគ្មានសង្គមពលរដ្ឋ ឬសង្គមស៊ីវិលទេ រដ្ឋាភិបាលមិនអាចបំពេញការងារដឹកនាំបានទេ ពោលគឺត្រូវសហប្រតិបត្តិការជិតស្និទនិងស្មោះត្រង់ជាមួយសង្គមស៊ីវិល ដើម្បីធ្វើឲ្យកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទទួលបានជោគជ័យ។ ដោយឡែកសង្គមស៊ីវិលត្រូវកំណត់តួនាទី និងសកម្មភាពរបស់ខ្លួនឲ្យបានត្រឹមត្រូវ ជាអ្នកជួយ បំពេញចន្លោះខ្វះខាតឲ្យរដ្ឋាភិបាល ពុំមែនជាដៃគូបដិបក្ខរបស់រដ្ឋាភិបាលឡើយ ដោយត្រូវផ្លាស់ប្តូរទស្សនៈគ្នា និងបំពេញឲ្យគ្នាទៅវិញទៅមក ដើម្បីបម្រើផលប្រយោជន៍ពលរដ្ឋនិងសង្គមជាតិ។ យោងតាមមាត្រា៤២នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពពេញលេញ ដើម្បីបង្កើតសហគម សហជីព និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវបានកំណត់ក្នុងច្បាប់។ ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមបានដោយសេរីក្នុង អង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារផលប្រយោជន៍គ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និង សណ្តាប់ធ្នាប់ល្អរបស់សង្គម។ ចាប់តាំងពីការបោះឆ្នោតឆ្នាំ១៩៩៣ គេពិនិត្យឃើញមានអង្គការក្រៅរដ្ឋាភិបាលទាំងជាតិនិងអន្តរជាតិ ត្រូវបានបង្កើតឡើងព្រមទាំងបោះទីតាំងនៅក្នុងប្រទេសកម្ពុជាមានប្រមាណ ជិត៩០០អង្គការហើយ។ សមាគម ឬអង្គការក្រៅរដ្ឋាភិបាល(NGO) ជាច្រើនដែលកំពុងសហការណ៍ និងធ្វើជាដៃគូយ៉ាងជិតស្និទជាមួយរដ្ឋាភិបាលព្រមទាំងនៅតាមក្រសួងស្ថាប័ននានាជាច្រើនទៀត។ ហើយពេលបច្ចុប្បនេះមានអង្គការមិនមែនរដ្ឋាភិបាលប្រមាណជិត៤០អង្គការ ដែលបាននិងកំពុងធ្វើសកម្មភាពខាងវិស័យសិទ្ធិមនុស្ស។ ព្រមជាមួយនេះអង្គការមួយចំនួនបានប្រមូលផ្តុំជាគណៈកម្មាធិការមួយមានឈ្មោះថា គណៈកម្មាធិការប្រព្រឹត្តកម្ម ដែលមានសមាជិកចូលរួម២៣អង្គការនិងអង្គការដទៃទៀតដូចជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ វិទ្យាស្ថានពលរដ្ឋវិទ្យា។ល។ អង្គការទាំងនះធ្វើ សកម្មភាពលើវិស័យ ដូចជា សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ដោយបានដាំបណ្តុះ អប់រំ ហ្វឹកហ្វឺន ពង្រឹងស្មារតី ជំរុញលើកទឹកចិត្ត និងផ្សព្វផ្សាយអោយយល់ដឹងអំពីគោល-ការណ៍ប្រជាធិបតេយ្យ ភាពជាម្ចាស់ឆ្នោត ភាពជា ម្ចាស់អំណាច ពលរដ្ឋវិជ្ជា និងសិទ្ធិសេរីភាព ដល់ប្រជា-

[២១៤] អូន ព័ន្ធមុនីរ័ត្ន ប្រជាធិបតេយ្យនៅកម្ពុជា និងតថភាព ភ្នំពេញ ឆ្នាំ១៩៩៥ ទំព័រ ៦០

ពលរដ្ឋទូទៅ ព្រមទាំងចុះពង្រឹងផ្នែកសិទ្ធិមនុស្សដល់ ប្រជាពលរដ្ឋកម្ពុជាផងដែរ។ ក្នុងចំណោមអង្គការទាំងនោះ មានអង្គការ៣គឺ អាដហុក លីកាដូ និង វីហ្វីឡែន ដែលធ្វើសកម្មភាពលើផ្នែកសិទ្ធិមនុស្ស។ ចំណែកអង្គការផ្សេងៗទៀតគឺ ធ្វើសកម្មភាពទៅតាមផ្នែកនីមួយៗនៃ សិទ្ធិដូចជា សិទ្ធិសេដ្ឋកិច្ច សេរីភាពខាងនយោបាយ វប្បធម៌ និងលទ្ធិប្រជាធិបតេយ្យ។ល។ សមាគម អង្គការ ក្រៅរដ្ឋាភិបាល បានចូលរួមចំណែកផ្នែកស្មារតី ចំពោះប្រជាពលរដ្ឋក្នុងការតស៊ូមតិដោយអហិង្សា ដើម្បីឲ្យមាន សេចក្តីក្លាហាន តស៊ូ ព្យាយាម សាមគ្គី សហការចូលរួម សម្តែងមតិ ជជែកដេញដោលជាសាធារណៈ ការជួបជុំ មហាជន បាតុកម្ម កូដកម្មអហិង្សា ទន់ភ្លន់ អប់រំឲ្យស្រឡាញ់វប្បធម៌ សន្តិភាព ក្នុងទិសដៅធ្វើឲ្យសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យសកម្មរស់រវើក ប្រកបដោយឥទ្ធិពលស្របតាមគោលការណ៍ប្រជាធិប-តេយ្យសេរីពហុបក្សនៅកម្ពុជា ដើម្បីដាក់សម្ពាធទៅលើស្ថាប័នតំណាងនានារបស់ប្រជាពលរដ្ឋ ដូចជា រដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា តុលាការ ជាដើម។ល។ ឲ្យបម្រើប្រជារាស្ត្រក្នុងឆន្ទៈទទួលខុសត្រូវខ្ពស់ មនសិការជាតិ យកចិត្តទុកដាក់ខ្ពស់ចំពោះរាល់ទុក្ខលំបាកទាំងឡាយរបស់ប្រជាពលរដ្ឋ ដើម្បីស្តារស្ថានភាពជីវភាពប្រជាពលរដ្ឋខ្មែរ ដែលកំពុងរងនូវការលំបាក់យ៉ាងធ្ងន់ធ្ងរផង ក៏ដូចជាសិទ្ធិសេរីភាពក្នុងការសម្តែង យោបល់ ការធ្វើបាតុកម្ម កូដកម្មដោយសន្តិវិធីផងដែរ បាននិងកំពុងទទួលការគាបសង្កត់ រឹតត្បិត គំរាមកំហែង ដើម្បីធ្វើយ៉ាងណាឲ្យលទ្ធិប្រជាធិបតេយ្យកាន់តែចាក់ឫសជាប់គង់វង្ស។ ព្រមទាំងធ្វើឲ្យស្ថានភាពសិទ្ធិមនុស្ស ក្នុងសង្គមប្រជាធិបតេយ្យមានភាពល្អប្រសើរ និងរឹងមាំជាលំដាប់។

អង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល គឺជាបង្អែកយ៉ាងសំខាន់សម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកក្នុងការការពារទល់នឹងការរំលោភបំពានផ្នែកសិទ្ធិសេរីភាព សិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋ និងសិទ្ធិមនុស្សផងដែរ។ ក្នុងនោះក្រៅពីបានជួយឧបត្ថម្ភផ្នែកបណ្តុះបណ្តាល និងបម្រើការតាមអង្គការជាតិក្នុងស្រុកជាច្រើន និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ បានចូលធ្វើអន្តរាគមន៍ដោយផ្ទាល់ទៅនឹងការរំលោភសិទ្ធិមនុស្សពិសេសសិទ្ធិសេរីភាពខាងនយោបាយរបស់ប្រជាពលរដ្ឋកម្ពុជា។ នៅកម្ពុជាអង្គការអន្តរជាតិបានចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត ហើយជាពិសេសទៅទៀតបានធ្វើការអន្តរាគមន៍ផ្នែកអយុត្តិធម៌ផងដែរ។ អង្គការទាំងនោះរួមមានៈ ១-ឧត្តមស្នងការសិទ្ធិមនុស្សនៅកម្ពុជាបានចូលរួមការពារសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ។ ជាក់ស្តែង គឺបានជួយសង្គ្រោះពីការគំរាមកំហែងលើផ្នែកនយោបាយខ្មែរ ដែលរងគ្រោះដោយសារព្រឹត្តិការណ៍ហិង្សានយោបាយ នៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧។ អង្គការឧត្តមស្នងការនៃជនភៀសខ្លួន បានចូលរួមចំណែកជួយផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋខ្មែរពីបរទេសចូលមកសង្គមជាតិ ផ្អែកតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ២-អង្គការទស្សនៈពិភពលោក ជួយជំរុញខាងផ្នែកសុខភាព អង្គការ UNFPA ជួយអភិវឌ្ឍន៍ទាំងធនធានមនុស្ស និងសេដ្ឋកិច្ច។ អង្គការកម្មវិធីស្បៀងអាហារពិភពលោក បានជួយឧបត្ថម្ភនូវស្បៀងអាហារដល់ប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់ និងគ្រោះមហន្តរាយនានា អង្គការកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ជួយឧបត្ថម្ភដល់គ្រប់ភាគីជម្លោះទាំងអស់ ដោយបាននាំមកនូវការព្យាបាលពីក្រុមគ្រូពេទ្យសង្គ្រោះ ដើម្បីជួយសង្គ្រោះដល់ប្រជាជនរងគ្រោះដោយសារធម្មជាតិ និងពីការដោយសារសង្គ្រាម។

សរុបមកឃើញថា ទាំងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ គឺជាស្ថាប័នក្រៅរដ្ឋាភិបាល ដែលមានមូលនិធិ កម្មវិធីយុទ្ធសាស្ត្រ អង្គការចាត់តាំង និងរចនាសម្ព័ន្ធពិតប្រាកដ និងច្បាស់លាស់ដាច់ដោយឡែក បាននិងកំពុងបំពេញបេសកកម្មរបស់ខ្លួនយ៉ាងមមាញឹក និងទូលំទូលាយក្នុងការអប់រំដាំបណ្ដុះ ទាំងស្មារតី និងចំណេះដឹងពិតប្រាកដ ស្ដីពីតម្លៃប្រជាធិបតេយ្យ សិទ្ធិសេរីភាព អំណាចប្រជាពលរដ្ឋ វប្បធម៌អត់ធ្មត់ អហិង្សា សីលធម៌ សណ្ដាប់ធ្នាប់សាធារណៈ ច្បាប់ទម្លាប់ ក្នុងបុព្វហេតុការពារសិទ្ធិសេរីភាព ក្នុងបរិយាកាសនៃសង្គមប្រជាធិបតេយ្យ ជាពិសេសធ្វើឲ្យប្រជាមហាជនដែលជាម្ចាស់អំណាច ម្ចាស់ប្រទេស ដែលជាអ្នកកំណត់ជោគវាសនាដ៏សំខាន់របស់ជាតិ ឲ្យបានយល់ដឹងពីបែបផែននៃការប្រើប្រាស់សិទ្ធិសេរីភាព និងអំណាចរបស់ខ្លួនឲ្យចំគោលដៅស្របច្បាប់បែបសីលធម៌ និងអហិង្សានិយម និងមានសមត្ថភាពអាចវិភាគដឹងអំពីទម្រង់ដឹកនាំរបស់រដ្ឋាភិបាល រដ្ឋសភាក៏ដូចជាស្ថាប័នតំណាងដទៃទៀត ជាពិសេសជំរុញឲ្យមានសេចក្ដីក្លាហាន ចេះតស៊ូព្យាយាម ទាមទារ តវ៉ា ចំពោះរាល់សកម្មភាពរំលោភសិទ្ធិសេរីភាព និងបញ្ញាលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ព្រោះថា នៅក្នុងសង្គមប្រជាធិបតេយ្យ បានទម្លាក់ការទទួលខុសត្រូវទៅលើប្រជាពលរដ្ឋជាអ្នកសម្រេចចិត្តចំពោះជោគវាសនារបស់ប្រទេសជាតិ។ ដូច្នេះ កម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋនៃប្រទេសមួយ គឺជាប់ទាក់ទងផ្ទាល់ទៅនឹងកម្រិតអភិវឌ្ឍន៍របស់ប្រទេសនោះ។ ជាក់ស្ដែង យើងក្រឡេកមើលប្រទេសដឹកនាំរដ្ឋតាមគោលការណ៍ប្រជាធិបតេយ្យជឿនលឿនមួយចំនួនក្នុងសកលលោក ដូចជា ប្រទេស ជប៉ុន ថៃ សហរដ្ឋអាមេរិក... យើងឃើញថា ប្រជាពលរដ្ឋនៃបណ្ដាប្រទេសទាំងនេះមានកម្រិតយល់ដឹងខ្ពស់ទាំងផ្នែកបច្ចេកទេស សីលធម៌ ច្បាប់ សិទ្ធិសេរីភាពប្រជាធិបតេយ្យ ស្មារតីរឹងមាំ ក្លាហាន មនសិការ ទទួលខុសត្រូវខ្ពស់ ការអធ្យាស្រ័យអហិង្សានិយម ការសហការរួបរួមជួយការពារផលប្រយោជន៍គ្នាទៅវិញទៅមក ទាំងនេះជាដើមទុនដំបូងដ៏មានសារៈ សំខាន់និងចាំបាច់បំផុត ដើម្បីជ្រើសរើសមេដឹកនាំ ដែលមានទេពកោសល្យ មានបញ្ញាចាក់ធ្លុះ មានសីលធម៌កម្រិតខ្ពស់ យកមកដឹកនាំប្រទេស។ ករណីជ្រើសរើសមកហើយបែរជាដឹកនាំប្រទេសជាតិមិនបានល្អទេ ប្រជាពលរដ្ឋទាំងនោះរួមគ្នាប្រើសិទ្ធិសេរី និងអំណាចរបស់ខ្លួនបណ្ដេញ ឬទម្លាក់មេដឹកនាំនោះចេញ ដោយជ្រើសរើសអ្នកថ្មីមកជំនួសវិញ ក្នុងគោលបំណងធ្វើយ៉ាងណាឲ្យប្រទេសជាតិរីកចម្រើនទាំងសេដ្ឋកិច្ច និងស្ថេរភាព នយោបាយមាននិរន្តរភាព។ កាលណាប្រជាពលរដ្ឋមានធនធាន ចំណេះដឹងគ្រប់គ្រាន់ធ្វើឲ្យជនទុច្ចរិត អសីលធម៌ ផ្ដាច់ការមិនអាចជ្រកក្រោមផ្លាកប្រជាធិបតេយ្យឈានទៅដឹកនាំប្រទេសជាតិបានឡើយ។

### ៤.៣.២ តួនាទីរបស់គណបក្សនយោបាយក្នុងបរិបទប្រជាធិបតេយ្យ

ដើម្បីនាំគ្នាថែរក្សាការពាររបបដឹកនាំតាមលទ្ធិប្រជាធិបតេយ្យ ដែលចាប់បដិសន្ធិតាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្ដីអំពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលត្រូវបានប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល គោរពស្រឡាញ់ ការពារ ដាំបណ្ដុះរហូតមកដល់បច្ចុប្បន្ននេះឲ្យបានគង់វង្សជាអមតៈ គឺទាមទារឲ្យមានការចូលរួមពីគណបក្សនយោបាយទាំងអស់ដោយត្រូវបំពេញតួនាទី

របស់ខ្លួនជាតួអង្គដ៏សំខាន់ក្នុងលទ្ធិប្រជាធិបតេយ្យ។ គោលការណ៍នេះ ក៏មានន័យជាមូលដ្ឋានគ្រឹះសម្រាប់កម្ពុជា ដែលមិនអាចរំលងឬជៀសវាងបានឡើយ និងសំដៅជាំបណ្តុះផ្សព្វផ្សាយទ្រឹស្តីពិតប្រាកដស្តីអំពីសិទ្ធិសេរីភាពទូទៅរបស់ប្រជាពលរដ្ឋ និងអនុវត្តទ្រឹស្តីប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ឲ្យបានកាន់តែទូលំទូលាយនិងមានប្រសិទ្ធិភាព។ បើពុំនោះសោតទេ ពាក្យសិទ្ធិសេរីភាព អំណាចរបស់ប្រជាពលរដ្ឋ និង ប្រជាធិបតេយ្យសេរីពហុបក្ស គឺគ្រាន់តែគ្រឿងអលង្កាសម្រាប់លំអ និងតុបតែងឲ្យអ្នកធ្វើនយោបាយផ្តាច់ការចក្រពត្តិតែប៉ុណ្ណោះ រីឯសេចក្តីប៉ងប្រាថ្នារបស់ប្រជាពលរដ្ឋចំពោះ សិទ្ធិសេរីភាព អំណាច និងលទ្ធិប្រជាធិបតេយ្យពិតៗ នឹងក្លាយជាក្តីស្រមើស្រមៃ និងសោកស្តាយប៉ុណ្ណោះ ចំណែកឯចរិតលក្ខណៈសិទ្ធិសេរីភាព និងអំណាចក្នុងគោលការណ៍ប្រជាធិបតេយ្យនៃរដ្ឋធម្មនុញ្ញកម្ពុជា ក៏អាចឃ្លាតចេញឆ្ងាយពីការគោរពប្រតិបត្តិជាមិនខានឡើយ។

ឆ្លងកាត់ការរៀបចំបោះឆ្នោតចំនួន៦លើក(១៩៩៣-២០០៨) កន្លងមកអាចកត់សម្គាល់ឃើញថា កម្ពុជាមានការអភិវឌ្ឍន៍ខ្លាំងក្លា ខាងការកើតឡើងនូវគណបក្សនយោបាយ។

គណបក្សនយោបាយក្នុងបរិបទប្រជាធិបតេយ្យសេរីពហុបក្ស មិនមែនគ្រាន់តែធ្វើសកម្មភាពនយោបាយនៅពេលជិតដល់ពេលបោះឆ្នោតមកដល់នោះទេ ព្រោះសកម្មភាពបែបនេះ គឺជាសកម្មភាពសម្រាប់ឃោសនាយកតែសន្លឹកឆ្នោតតែប៉ុណ្ណោះ។ ដោយមិនចាត់ទុកគណបក្សទាំងនេះថា បានបំពេញតួនាទីស្របតាមខ្លឹមសារ និងនិយមន័យគណបក្សនយោបាយទេ។ គណបក្សនយោបាយតម្រូវឲ្យមានរចនាសម្ព័ន្ធ និងយន្តការពីលើដល់ក្រោម សំដៅឲ្យមានការចូលរួមបង្កើតឆន្ទៈនយោបាយពីសំណាក់ប្រជាពលរដ្ឋ ផ្អែកតាមគោលការណ៍ប្រជាធិបតេយ្យសេរី និងសិទ្ធិសេរីភាពខាងនយោបាយ ដែលអមដោយប្រជាធិបតេយ្យផ្ទៃក្នុងបក្សជាមូលដ្ឋាន។

**ជាមួយគ្នានេះដែរមុខងារគណបក្សនយោបាយក្នុងសង្គមប្រជាធិបតេយ្យសេរីពហុបក្សនោះគឺ**[២១៥]

ក-គឺការចូលរួមចំណែក ផ្សព្វផ្សាយអប់រំអំពីប្រជាធិបតេយ្យ សិទ្ធិសេរីភាពទូទៅដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ក្នុងកតិកាសញ្ញាអន្តរជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ការអប់រំឲ្យគោរពច្បាប់ ស្រឡាញ់សន្តិភាព សិទ្ធិមនុស្ស ការផ្សះផ្សាជាតិ សាមគ្គីជាតិ មានសីលធម៌ បណ្តុះគុណធម៌ រក្សាវប្បធម៌ សេដ្ឋកិច្ច បរិស្ថាន ។ល។ និង ។ល។ សំដៅធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋទូទៅមានមូលដ្ឋានខាងការយល់ដឹងអំពីតម្លៃ ក្នុងភាពជាម្ចាស់អំណាចពិតប្រាកដក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា និងការធ្វើសេចក្តីសម្រេចចិត្តនយោបាយចំពោះគណបក្សនយោបាយ។

ខ-តួនាទីរបស់គណបក្សនយោបាយ ដើម្បីចូលរួមបង្កើតឆន្ទៈនយោបាយរបស់ប្រជាពលរដ្ឋ

-ប្រកាស និងបង្ហាញអំពីគោលគំនិតទស្សនៈ និងនិន្នាការនយោបាយរបស់ខ្លួននៅក្នុងសង្គមជាពិសេស គំនិត និងទស្សនៈនយោបាយខុសៗគ្នាពីគណបក្សនយោបាយមួយទៅគណបក្សនយោបាយដទៃទៀត។

-ចងក្រងគោលគំនិតនយោបាយ និងកម្មវិធីនយោបាយ ព្រមទាំងរិះរកនូវដំណោះស្រាយចំពោះរាល់

---

[២១៥] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ "ប្រជាធិបតេយ្យ និងច្បាប់" ភ្នំពេញ ឆ្នាំទី១ លេខ១ ខែឧសភា ឆ្នាំ១៩៩៩ ទំព័រ ២

បញ្ហា និងវិបត្តិនយោបាយ។

-ផ្សព្វផ្សាយជាសាធារណៈអំពីមនោគតិព្រមទាំងមានឥទ្ធិពលលើមតិសាធារណៈ និងទស្សននយោបាយរបស់ប្រជាពលរដ្ឋ បានសេចក្តីថា ធ្វើឲ្យសាធារណៈជនមានការចាប់អារម្មណ៍។

-ផ្តល់ឱកាស និងជំរុញប្រជាពលរដ្ឋឲ្យចូលរួមក្នុងសកម្មភាពនយោបាយ។

-ផ្តល់លទ្ធភាពជាអត្ថិភាពជូនប្រជាពលរដ្ឋ ដែលមានសមត្ថភាពឲ្យទទួលបាននូវតួនាទីទទួលខុសត្រូវក្នុងការងាររដ្ឋក៏ដូចជាការងារសាធារណៈ។

-ជ្រើសតាំងបេក្ខជនរបស់ខ្លួនសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភាក៏ដូចជាសមាជិក ក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់។

-បង្កើតឥទ្ធិពលលើការអភិវឌ្ឍន៍ខាងនយោបាយ ទាំងក្នុងអង្គការនីតិប្រតិបត្តិ ទាំងក្នុងអង្គការនីតិបញ្ញត្តិ។

-ជាគណបក្សក្នុងរដ្ឋាភិបាលត្រូវទ្រទ្រង់នយោបាយដឹកនាំរបស់រដ្ឋាភិបាល។

-ជាគណបក្សជំទាស់ក្នុងរដ្ឋសភាត្រូវត្រួតពិនិត្យ និងបង្ហាញនូវជម្រើសនយោបាយផ្សេងពីនយោបាយរបស់រដ្ឋាភិបាល។

### ៤.៣.៣ ការរួបរួមគ្នាជាក្រុម សមាគម ឬសហគមន៍

ពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យចាំបាច់ណាស់ត្រូវតែសាមគ្គីរួបរួមចងគ្នាជាក្រុម ជាកម្លាំង ព្រោះនេះជាក្រិត្យក្រម ឬសគល់ដ៏រឹងមាំនៃវប្បធម៌ប្រជាធិបតេយ្យ ដើម្បីការពារប្រយុទ្ធប្រឆាំងដោយសន្តិវិធីទៅនឹងអ្នកកាន់អំណាចដែលទទួលបានឱកាសកាន់កិច្ចការប្រទេសជាតិពីប្រជាពលរដ្ឋ ហើយបែរមកប្រើអំណាចផ្តាច់ការរំលោភបំពាន សិទ្ធិសេរីភាពរបស់ខ្លួនវិញ។ សម្លេងរបស់បុគ្គលតែម្នាក់ឯងពុំមែនជាកម្លាំង ឬជាអំណាចពិតប្រាកដរបស់សង្គមប្រជាធិបតេយ្យឡើយ។ សង្គមប្រជាធិបតេយ្យទាមទារឲ្យប្រជាមហាជន ម្ចាស់ឆ្នោតរួមសហការគ្នាជាសម្លេងប្រមូលផ្តុំ ទើបមានឥទ្ធិពល កម្លាំងខ្លាំងក្លា ដើម្បីតតាំងជាមួយការប្រើអំណាចរំលោភសិទ្ធិសេរីភាពទូទៅរបស់ម្ចាស់អំណាច។ លុះត្រាណាយើងជាម្ចាស់ឆ្នោតចងសម្ព័ន្ធគ្នាបានជាកម្លាំង មហាជនចូលរួមគ្នាជាដុងមួយមិនអាចបំបែកបាន នោះធ្វើការតវ៉ាប្រឆាំងទាមទារសិទ្ធិសេរីភាពអមដោយសីលធម៌ និងការយល់ដឹងធ្វើឲ្យពួកអ្នករំលោភអំណាច ខ្លាចអោរ ណេបយើងដែរ ហើយត្រូវតែចេញមកដោះស្រាយ ឬបញ្ជូនតំណាងមកចរចារសួរនាំយើងថា តើចង់បានអ្វី មានអ្វីកើតឡើង ម្យ៉ាងវិញទៀតគេមិនអាចយករួចខ្លួន សម្ងំសុខ គ្មានការទទួលខុសត្រូវ និងធ្វើអ្វីងាយស្រួលដោយធ្វេសប្រហែសឡើយ នេះដោយសារតែប្រជាពលរដ្ឋមានគ្នាច្រើន មានកម្លាំងច្រើន មានភ្នែកច្រើន សំឡេងច្រើនពួតផ្តុំគ្នា។ កាលណាប្រជាពលរដ្ឋម្ចាស់ឆ្នោតអាចចងក្រងគ្នាជាក្រុម មានកម្លាំសម្រាប់ ធ្វើការតវ៉ាទៅស្ថាប័នតំណាងរបស់ខ្លួន ចំពោះបញ្ហាទាំងឡាយដែលប្រជាពលរដ្ឋបានយល់ឃើញ ថាបាត់បង់ផលប្រយោជន៍របស់សហគមន៍ខ្លួន ក៏ដូចជាប្រទេសជាតិរបស់ខ្លួន នោះការទាមទារទាំងឡាយ ធ្វើឲ្យស្ថាប័ន ទាំងនោះនឹងត្រូវធ្វើការដោះស្រាយជាបន្ទាន់ តាមការទាមទាររបស់យើង។ នៅស្រុកប្រជាធិបតេយ្យជឿន

លឿននានា កាលណាប្រជាពលរដ្ឋប្រើសិទ្ធិសេរីភាព ឬអំណាចរបស់ខ្លួនបះបោរ ធ្វើបាតុកម្មតវ៉ា ចំពោះរឿងរ៉ាវណាមួយដែលស្ថាប័នមានសមត្ថភាពមិនអាចដោះស្រាយបាន ប្រធានស្ថាប័ននោះចុះចេញពីតំណែងភ្លាមដោយមិនចាំបាច់ប្រជារាស្ត្របណ្តេញចេញនោះទេ។ ត្រង់ចំណុចនេះ បញ្ជាក់អំពីតម្លៃនៃអំណាចប្រជាពលរដ្ឋមានឥទ្ធិពលខ្លាំងក្លា មានប្រៀបលើអ្នកកាន់កិច្ចការរដ្ឋផង និងបញ្ជាក់ពីស្មារតីទទួលខុសត្រូវ មនសិការ និងសីលធម៌ថ្លៃថ្នូរកម្រិតខ្ពស់ផង និងជាពិសេសដំណើរការនេះអាចប្រព្រឹត្តទៅបានដោយសាររដ្ឋធម្មនុញ្ញបានកម្រិតព្រំដែនអំណាច មិនអនុញ្ញាតឲ្យមានស្ថាប័នរដ្ឋណាមួយ ក្នុងចំណោមស្ថាប័នរដ្ឋទាំងបីមានអំណាចដាច់ណាត់តែម្នាក់ឯងនោះទេ ពោលត្រូវឲ្យមានតុល្យភាពអំណាច(Cheks and Balances) ដើរទន្ទឹមគ្នាផង ទើបប្រជាពលរដ្ឋអាចប្រើប្រាស់សិទ្ធិសេរីភាព និងអំណាចរបស់ខ្លួនបាន កាលណាអំណាចរដ្ឋទាំងមូលធ្លាក់ទៅផ្តុំលើប្រមុខស្ថាប័នរដ្ឋមួយតែមួយកន្លែង ពេលនោះប្រជាពលរដ្ឋមិនអាចប្រើសិទ្ធិសេរីភាពនិងអំណាចរបស់ខ្លួនបានឡើយ។ ឯ ស្ថានភាពសង្គមជាតិអាចជួបវិបត្តិទាំងសេដ្ឋកិច្ច និងនយោបាយ ព្រោះទិដ្ឋភាពបែបនេះអាចកើតឡើងនូវអំពើអយុត្តិធម៌ ការប្រកាន់បក្សពួក អំពើពុករលួយ បុគ្គលនិយម ការរើសអើងនយោបាយ។ ជាពិសេស រាល់ការប្រើសិទ្ធិសេរីភាព ឬអំណាចរបស់ប្រជាពលរដ្ឋតាមរយៈការធ្វើបាតុកម្ម-កូដកម្មអហិង្សា ការប្រជុំមហាជនអាចត្រូវសមត្ថកិច្ចរដ្ឋាភិបាល រារាំង បង្ក្រាប គំរាមកំហែង គាបសង្កត់ ចាប់ដាក់គុក។ល។ ហើយស្ថានភាពប្រជាធិបតេយ្យ ត្រូវស្ថិតនៅក្នុងចំណុចរលំរលោយដោយសារទម្រង់របបផ្តាច់ការនិយមជ្រកក្រោមដំបូលប្រជាធិបតេយ្យក្លែងក្លាយ។

ការរស់នៅក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋត្រូវចេះផ្តួចផ្តើមគំនិតចងក្រងគ្នាជាក្រុមមនុស្សមានគំនិតស្មារតីការពារសិទ្ធិសេរីភាពជាក្រុម ឬជាសហគមន៍ទើបធ្វើឲ្យមនុស្សម្នាក់ៗទទួលបាននូវសិទ្ធិសេរីភាព និងអំណាច ការគោរពសិទ្ធិមនុស្ស ជីវភាពរស់នៅសមរម្យ មានសុភមង្គល ការអភិវឌ្ឍន៍ថ្កុំថ្កើង យុត្តិធម៌សង្គម សន្តិភាព តម្លាភាពពិតប្រាកដ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។ដោយគ្មានក្រុមប្រើអំណាចផ្តាច់ការណាមករំលោភ-បំពានបានទេ ប្រជាពលរដ្ឋគ្រប់គ្នាត្រូវផ្អែក និងអនុវត្តឲ្យបាននូវគតិបណ្ឌិតរបស់ចាស់ ទុំដូនតាខ្មែរ ដែលបានបន្សល់ទុកសម្រាប់ជនរួមជាតិគ្រប់ជំនាន់ថា "**ចង្កឹះមួយដើមកាច់បាក់ តែចង្កឹះមួយបាច់កាច់មិនបាក់ឡើយ**"។ កាលណា "**ទីណាមានការជិះជាន់គាបសង្កត់ទីនោះត្រូវតែស៊ូរើបម្រាស់**" ជាពិសេស គ្មានអំណាចអ្វី អាចយកឈ្នះឆន្ទៈរួមរបស់ប្រជាពលរដ្ឋបានឡើយ។

### ៤.៣.៤ បង្កើតកម្មវិធីវគ្គបណ្តុះបណ្តាលអប់រំស្តីពី ពលរដ្ឋវិទ្យា លទ្ធិប្រជាធិបតេយ្យ ច្បាប់ និងសិទ្ធិមនុស្ស

ការសិក្សាអប់រំជាកត្តាសំខាន់ និងចាំបាច់បំផុតមិនអាចខ្វះបានសម្រាប់បុគ្គលម្នាក់ៗ នេះជាមូលដ្ឋានគ្រឹះតែមួយគត់ ដើម្បីស្វែងយល់ថ្លឹងថ្លែង ប្រៀបធៀបនូវអ្វីៗដែលទាក់ទងនឹងជីវិតរស់នៅរបស់ខ្លួន របស់ប្រទេសជាតិ ចេះបែងចែកអំពើអ្វីដែលខ្លួនធ្វើត្រូវឬខុស យល់ដឹងពីអ្វីជារបស់ខ្លួន និងរបស់អ្នកដទៃ យល់ដឹងពីព្រំដែនសិទ្ធិអំណាចរបស់ខ្លួន និងជាពិសេសធនធានចំណេះដឹងរបស់ប្រជាពលរដ្ឋ គឺជាធនធានដ៏មានសក្តានុពលចាំបាច់

មុនគេបំផុត សម្រាប់អភិវឌ្ឍ ការពារប្រទេសជាតិឲ្យបានគង់វង្ស និងរីកចម្រើន។ ផ្ទុយទៅវិញកាលណាប្រទេសមួយសម្បូរណ៍ទៅដោយប្រជាពលរដ្ឋពុំសូវចេះដឹងនោះទេ ពួកគេក៏ពុំបានយល់ពីកាតព្វកិច្ចរបស់ខ្លួនឡើយ ហើយប្រទេសជាតិក៏មិនអាចរីកចម្រើនបានលឿនដែរ។ ករណីនេះរដ្ឋាភិបាលត្រូវដើរតួនាំមុខគេ ក្នុងការអប់រំពីច្បាប់ គោលការណ៍ប្រជាធិបតេយ្យ ពលរដ្ឋវិទ្យា អំណាចរបស់ប្រជាពលរដ្ឋ សិទ្ធិមនុស្ស បច្ចេកទេសដល់ប្រជាពលរដ្ឋគ្រប់រូបក្នុងសង្គម ទើបធ្វើឲ្យមនុស្សយល់ដឹងពីការប្រើប្រាស់សិទ្ធិសេរីភាព និងអំណាចរបស់ខ្លួន និងអ្នកដទៃ និងការអនុវត្តន៍សិទ្ធិសេរីភាពរបស់ខ្លួនបានត្រឹមណា ទើបមិនប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ។ ការប្រមូលជួបជុំមហាជនបែបណា ទើបមិនបណ្តាលឲ្យខូចខាតដល់សន្តិសុខសណ្តាប់ធ្នាប់ល្អសង្គមនិងសុវត្ថិភាពសាធារណៈ។ កាលណាប្រជាពលរដ្ឋអាចយល់ដឹង ពីសិទ្ធិសេរីភាពរបស់ខ្លួនឯងគ្រប់គ្រាន់ ហើយប្រជាពលរដ្ឋ គ្រប់គ្នាមានស្មារតីភ្ញាក់រលឹក ក្លាហាន ហ៊ាននាំគ្នាតស៊ូមតិ សម្តែងមតិត្រឹមត្រូវតាមច្បាប់ ដោយជ្រើសរើសយកមធ្យោបាយសន្តិវិធី ដើម្បីប្រឆាំងទៅនឹងអំពើទាំងឡាយដែលគំរាមកំហែង រំលោភបំពាន មកលើប្រជាពលរដ្ឋ។ គោលដៅនៃការអប់រំ ផ្សព្វផ្សាយផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ គឺជាកម្មវត្ថុចម្បងក្នុងសង្គមប្រជាធិបតេយ្យ ដែលតម្រូវឲ្យប្រជាពលរដ្ឋគ្រប់រូបចូលរួមទទួលខុសត្រូវក្នុងសង្គម ដោយមិនទម្លាក់ការទទួលខុសត្រូវទាំងអស់ទៅលើរដ្ឋាភិបាលនោះទេ។

ចំពោះការផ្តល់សេវាអប់រំបណ្តុះបណ្តាលចំណេះដឹងដល់ប្រជាពលរដ្ឋ រដ្ឋាភិបាលមិនត្រូវយកចិត្តទុកដាក់គិតគូរចំពោះតែប្រជាពលរដ្ឋមួយជ្រុងនោះទេពោល គឺត្រូវបើកចំហទូលំទូលាយគ្រប់និន្នាការនយោបាយ ជាពិសេសគួរបើវគ្គសិក្ខាសាលាអប់រំពីសិទ្ធិសេរីភាពពលរដ្ឋ ពលរដ្ឋវិទ្យា ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងច្បាប់ផ្សេងៗដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ដែលជាអ្នកអនុវត្តច្បាប់ ដើម្បីឲ្យមន្ត្រីអាជ្ញាធរទាំងនោះទម្លាក់ចោលឲ្យអស់នូវមនោគមន៍វិជ្ជាកុំមុយនីស្ត ការរើសអើងផ្នែកនយោបាយ ដែលបន្សល់ទុកមកតាំងពីរបបរដ្ឋកម្ពុជា ហើយបែរមកទទួលនូវគំនិតពហុនិយមស្របតាមរបបដឹកនាំបែបប្រជាធិបតេយ្យ ជាពិសេសមេដឹកនាំរដ្ឋខ្លួនឯងតែម្តងចាំបាច់ត្រូវតែទទួលយកទាំងការរិះគន់ ការកោតសរសើរ គោរពសិទ្ធិសេរីភាព និងអំណាចប្រជាពលរដ្ឋមានសេចក្តីស្មោះត្រង់ចំពោះប្រជាជន និងជាតិ បណ្តុះជំនឿទុកចិត្តរវាងអ្នកដឹកនាំ និងប្រជាមហាជនឡើងវិញ ទើបធ្វើឲ្យប្រទេសកម្ពុជាទាំងមូលពោរពេញដោយជំនឿទុកចិត្តគ្នារវាងអ្នកដឹកនាំ និងប្រជាពលរដ្ឋ ការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ អាជ្ញាធរនិងប្រជាពលរដ្ឋ។ ការអប់រំមេរៀនពលរដ្ឋវិទ្យា និងច្បាប់ផ្សេងៗដល់អាជ្ញាធរ ជាហេតុធ្វើឲ្យពួកគាត់យល់ដឹង ជ្រាបពីតួនាទី និងភារកិច្ចរបស់ពួកគាត់កាន់តែច្រើនឡើងក្នុងការបំពេញកិច្ចការបម្រើប្រជាពលរដ្ឋទូទៅ។ ក្រោយពីយល់ជ្រាបពីសិទ្ធិអំណាចរបស់ខ្លួន អាជ្ញាធរនឹងបានស្គាល់នូវបណ្តាសិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣២ និងច្បាប់ដទៃទៀត ព្រោះអាជ្ញាធរសាធារណៈជាអ្នកការពារច្បាប់ ជាអ្នកគោរពច្បាប់ និងជាអ្នកប្រតិបត្តិតាមច្បាប់ ធានាឲ្យមានសន្តិសុខ ស្ថេរភាព សណ្តាប់ធ្នាប់ សន្តិភាព ប្រកាន់ជំហរឯករាជ្យភាព អព្យាក្រឹត្យមិនស្ថិតក្រោមសម្ពាធនយោបាយរបស់អ្នកកាន់អំណាច ហើយ

ប្រើតួនាទីរបស់ខ្លួនការពារអធិបតេយ្យភាពជូនប្រជាពលរដ្ឋ ក៏ដូចជាជូនសង្គមជាតិទាំងមូលផងដែរ ទើបសមជាអាជ្ញាធរក្នុងសង្គមប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។

**គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**

គណៈកម្មាធិការនេះ ជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាល ទទួលបន្ទុកវិស័យសិទ្ធិមនុស្សជួយផ្តល់សេចក្តីព្រាងច្បាប់នានាពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិមនុស្ស។ លើសពីនេះគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាចុះអប់រំបោះពុម្ពផ្សព្វផ្សាយបណ្តុះបណ្តាលលើកស្ទួយ និងការពារសិទ្ធិសេរីភាពជូនជនគ្រប់រូបក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះនៅមានភារកិច្ចតាមដាន និងត្រួតពិនិត្យការអនុវត្តន៍លិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍លិខិតតូបករណ៍ជូនអង្គការសហប្រជាជាតិទៀតផង។

តួនាទីរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាៈ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជានេះមានភារកិច្ចជួយដល់រាជរដ្ឋាភិបាលដូចជាៈ ១-លើកស្ទួយការពារ អភិវឌ្ឍសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ត្រួតពិនិត្យការរំលោភសិទ្ធិមនុស្ស និងពាក្យបណ្តឹងតវ៉ានានា។ ២-សហការស្រាវជ្រាវអង្កេត ជាមួយសមត្ថកិច្ច ហើយរៀបចំឯកសារផ្សព្វផ្សាយជូនសាធារណៈជន ជូននាយរដ្ឋមន្រ្តី ជូនតុលាការ ជូនសមត្ថកិច្ចនោះវិញ។ ទី៣-ចុះត្រួតពិនិត្យដល់មូលដ្ឋានដើម្បីវាយតម្លៃ និងផ្តល់ការណែនាំអំពីសិទ្ធិមនុស្ស។ ៤-អប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្សជាសាធារណៈ។ ទី៥-បង្កើតតំណាងគណៈកម្មាធិការសិទ្ធិមនុស្សរបស់ខ្លួន នៅតាមគ្រប់ស្ថាប័នរដ្ឋ ឯកជន រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងរៀបចំឲ្យមានមន្រ្តីស្ម័គ្រចិត្តនៅតាមភូមិ ឃុំ សង្កាត់ ដើម្បីឃ្លាំមើលសិទ្ធិមនុស្ស។ ទី៦-ផ្តល់យោបល់ និងលើកសំណើជូនរាជរដ្ឋាភិបាល អំពីស្ថានភាពសិទ្ធិមនុស្សជាក់ស្តែង សំដៅកែលំអ និងធ្វើយ៉ាងណាឲ្យសមស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ប្រទេស និងអនុសញ្ញាទាំងឡាយរបស់អន្តរជាតិ។ ៧-សហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីទប់ស្កាត់ និងការពាររាល់ការរំលោភសិទ្ធិមនុស្ស ក្នុងគោលដៅអភិវឌ្ឍន៍វិស័យសិទ្ធិមនុស្ស និងជាពិសេសដើម្បីសិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋនៅកម្ពុជាកាន់តែល្អប្រសើរ។

ដើម្បីធានានូវភាពទុកចិត្តពីគ្រប់មជ្ឈដ្ឋានទាំងជាតិ និងអន្តរជាតិ ព្រមទាំងជួយសម្រាលបញ្ហាសិទ្ធិមនុស្សដែលកំពុងតែកើតមានគួរឲ្យព្រួយបារម្ភ ដែលចាំបាច់បង្កើតឲ្យបាននូវគណៈកម្មាធិការសិទ្ធិមនុស្សជាតិមួយ ដែលឯករាជ្យពីនិន្នាការនយោបាយ និងដាច់ចេញពីស្ថាប័នកំពូលទាំងបីរបស់ជាតិឲ្យស្របតាមគោលការណ៍នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។

# ជំពូកទី៥

# សន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី៥
# សន្និដ្ឋាន និងអនុសាសន៍

## ៥.១ សន្និដ្ឋាន

ផ្អែកតាមការស្រាវជ្រាវទៅលើប្រធានបទស្តីអំពី សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅកម្ពុជាចន្លោះឆ្នាំ២០០២-២០១០រួចមក ខ្ញុំបាទមានមូលដ្ឋានរឹងមាំក្នុងការធ្វើសេចក្តីសន្និដ្ឋាន អំពីសក្តិភាពនៃអំណាចក្នុងការអនុវត្តន៍សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជាក្នុងទិដ្ឋភាពដូចតទៅ:

ដោយសារកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសកំពុងរស់នៅក្នុងរបបដឹកនាំបែបប្រជាធិបតេយ្យសេរីពហុបក្ស ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនចាប់តាំងពីឆ្នាំ១៩៩៣ ប្រកបដោយសន្តិភាព ស្ថេរភាពនយោបាយ ឯកភាពជាតិ ក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ រាជរដ្ឋាភិបាលតែមួយ។ បញ្ហាសិទ្ធិសេរីភាព សិទ្ធិមនុស្ស តាមគោលការណ៍ប្រជាធិបតេយ្យ តាមប្រវត្តិសាស្ត្រ ប្រជា-ពលរដ្ឋខ្មែរ ពុំមានប្រវត្តិទទួលបានការអប់រំជាំបណ្តុះស្តីអំពីមេរៀនប្រជាធិបតេយ្យ សិទ្ធិមនុស្ស សិទ្ធិសេរីភាព អំណាច ច្បាប់ ពលរដ្ឋវិទ្យា ទុកជាប្រព័ន្ធ ឬជាពុម្ពគំរូ គ្របដណ្តប់ដល់មូលដ្ឋានចុងកាត់មាត់ញកឲ្យបានច្បាស់លាស់ និងទូលំទូលាយឡើយ។ ប្រជាពលរដ្ឋចូលចិត្តរស់នៅដោយផ្ញើសេចក្តីទុកចិត្តទាំងស្រុងទៅលើអ្នកដឹកនាំរដ្ឋ និងរបត់សាសនានិយម ដោយមិនទាន់ទាំងយល់អំពីមេរៀនពិតប្រាកដរបស់ព្រះសម្មុទ្ធផង ។ល។ រហូតមកដល់បច្ចុប្បន្ននេះ ចំណេះដឹងប្រជាពលរដ្ឋខ្មែរនៅមានកម្រិតទាប និងមានបរិមាណតិចនៅឡើយ បើប្រៀបធៀបទៅនឹងចំនួនប្រជាពលរដ្ឋទូទាំងប្រទេស។ ប្រជាពលរដ្ឋខ្មែរទូទៅ ជាពិសេសពលរដ្ឋម្ចាស់ឆ្នោត មិនទាន់បោះបង់ចោលនូវផ្នត់គំនិតជ្រើសរើសតំណាង ឬអ្នកដឹកនាំរបស់ខ្លួន ដោយយកអារម្មណ៍ បែបមនោ -សញ្ចេតនា ស្រឡាញ់ចូលចិត្ត និងគិតពីការជំពាក់គុណស្រ័យនៅឡើយទេ ឯអ្នកនយោបាយនៅតែប្រើការមិនយល់ដឹងរបស់ប្រជាពលរដ្ឋ ដើម្បីកេងចំណេញនយោបាយក្នុងការចម្រាញ់យករំមោសពីប្រជាពលរដ្ឋ ម្ចាស់អំណាច តាមរយៈប្រជាធិបតេយ្យចក្រពត្តិនិយម។ សិទ្ធិសេរីភាពប្រជាពលរដ្ឋក្រៀមស្វិតនៅក្នុងចង្កោម អំណាចប្រមូលផ្តុំ។

រីកទ័រប្រវត្តិសាស្ត្រ នៃរាជរដ្ឋាភិបាលកម្ពុជា ស្តីអំពីសិទ្ធិសេរីភាពក្នុងគោលការណ៍ប្រជាធិបតេយ្យមានទិសដៅពីអតីតកាលមកដល់បច្ចុប្បន្នកាល និងទៅអនាគតកាល ដែលត្រូវបានអនុវត្តឡើងក្នុងលក្ខខណ្ឌនយោបាយដ៏ស្មុគស្មាញ។ ដោយសារកម្ពុជាខ្វះខាតនូវមូលដ្ឋានបរិស្ថាន និងលក្ខខណ្ឌប្រជាធិបតេយ្យស្ទើរតែគ្រប់ផ្នែក និងជាប្រទេសមួយដែលមានសេដ្ឋកិច្ចអន់ថយ ប្រជាជនមានកម្រិតយល់ដឹងទាប មានប្រពៃណីគ្រប់គ្រងដឹកនាំបែបឥស្សរៈជននិយម(Cult of Personality) អាជ្ញានិយម(Authoritarinism) ព្រមទាំងសីលធម៌នយោបាយបែបផ្តាច់ការ និងហិង្សានិយម និងមានការខ្វះខាតយ៉ាងខ្លាំងនូវរចនាសម្ព័ន្ធ និងបរិស្ថានច្បាប់ ព្រមទាំងមូលដ្ឋាន

បច្ចេកវិទ្យាសាស្ត្រ ដែលធ្វើឲ្យការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាបង្ហាញយ៉ាងប្រត្យក្សថា ការអនុវត្តន៍សិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋ មិនទាន់មានតម្លៃរួមទៅតាមសកលភាព(Universality) នៃគោលការណ៍ប្រជាធិបតេយ្យនោះទេ។ ប្រជាពលរដ្ឋ គឺពិតជាមានសិទ្ធិ និងសេរីភាពដូចបានចែងក្នុងច្បាប់កំពូលរបស់ជាតិអញ្ចឹងមែន។ ប៉ុន្តែអំណាចសម្រាប់ប្រើសិទ្ធិ និងសេរីភាពខាងនយោបាយរបស់ប្រជាពលរដ្ឋទាំងនេះនៅមានកម្រិត និងកាន់តែរឹងបន្តឹងជាលំដាប់ដូចជាសិទ្ធិធ្វើបាតុកម្មអហិង្សាស្របច្បាប់ សម្តែងមតិតាមទីសាធារណៈ សិទ្ធិធ្វើបែបសាសនាជាដើម។ ក្នុងដំណើរការប្រជាធិបតេយ្យ ទាមទារឲ្យមានទំនាក់ទំនងជាមួយគ្នាឈរលើមូលដ្ឋានច្បាប់ និងវិធីអហិង្សា។ ជាពិសេសជំរុញឲ្យមានសេរីភាព ការរីកចម្រើនតាមរយៈគោលការណ៍ពហុនិយម(Pluralism) ការគោរពសិទ្ធិមនុស្សនិងការគោរពសិទ្ធិរបស់រាល់បណ្តាភាគីទាំងឡាយក្នុងសង្គមដូចបានអនុវត្តនៅប្រទេសប្រជាធិបតេយ្យជឿនលឿន។ អំណាចដឹកនាំក្នុងរបបដឹកនាំតាមបែបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ស្តែងរូបរាងជាប្រព័ន្ធដឹកនាំដែលអំណាចភាគច្រើនពិតជាប្រមូលផ្តុំនៅលើស្ថាប័ននីតិប្រតិបត្តិ ច្រើនជាងស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលាការ។

ទន្ទឹមនឹងអន្តរកាលដ៏លំបាកធ្ងន់ធ្ងរកន្លងមកនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ បណ្ឌិតសភាចារ្យ ហ៊ុន សែន** ប្រកបដោយភាពប៉ិនប្រសព្វ បញ្ញាញាណចាក់ធ្លុះបានដឹកនាំគណៈរដ្ឋមន្ត្រីរបស់ខ្លួនចាប់តាំងពីឆ្នាំ១៩៨៣មកដល់បច្ចុប្បន្ន រក្សាបាននូវការពង្រឹងឯករាជ្យជាតិ សន្តិសុខសង្គម ស្ថេរភាពសង្គម ស្ថេរភាពនយោបាយ ឯកភាពជាតិ ពង្រឹងនីតិរដ្ឋ អភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ-សេរីពហុបក្ស ដើម្បីបង្កើតឡើងនូវសង្គមស្អាតស្អំ គ្មានអំពើពុករលួយ(ដោយរដ្ឋាភិបាលទទួលបានជោគជ័យដោយបានដាក់សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពប្រឆាំងអំពើពុករលួយ និងច្បាប់ប្រឆាំងអំពើពុករលួយ ជូនរដ្ឋសភាអនុម័ត ហើយរដ្ឋសភាជាតិបានអនុម័តច្បាប់នេះក្នុងឆ្នាំ២០១០រួចហើយដោយរដ្ឋាភិបាលបាននិងកំពុងដំណើរការអង្គភាពប្រឆាំងអំពើពុករលួយសព្វថ្ងៃនេះ) និងនាំយកបរិយាកាសនយោបាយបង្រួបបង្រួមជាតិ ប្រមូលផ្តុំកម្លាំងប្រជាជាតិគ្រប់មជ្ឈដ្ឋាននានា មកការពារប្រទេសជាតិ អភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងបានកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលបានខិតខំរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាល ដោយបានពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធនានា និងបានបើកចំហឲ្យមានសង្គមស៊ីវិលក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចូលរួមអប់រំ ដាំបណ្តុះ លទ្ធិប្រជាធិប-តេយ្យ សិទ្ធិមនុស្ស សិទ្ធិនយោបាយ ពលរដ្ឋវិទ្យា បច្ចេកវិទ្យា... ដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ។ ជាពិសេសរាជរដ្ឋាភិបាលខ្លួនឯងបានធ្វើកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅ ក្នុងការកែលំអប្រជាធិបតេយ្យ តាមតថភាពសង្គមជាក់ស្តែង ដោយបានធ្វើវិមជ្ឈការ និងវិសហមជ្ឈការអំណាចនៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយបានបើកឱកាសឲ្យមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី១ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ ព្រមទាំង បើកឲ្យដំណើរការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ កាលពីថ្ងៃទី១៧ ខែ

ឧសភា ឆ្នាំ២០០៩ ដោយទទួលបានជោគជ័យក្នុងរយៈកាលប៉ុន្មានឆ្នាំកន្លងមកនេះ។ ដែលការបោះឆ្នោតនេះបានឆ្លើយតបទៅនឹងបទបញ្ញត្តិនានា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ តាមគោលនយោ-បាយជាតិ និងកម្មវិធីនយោបាយយុទ្ធសាស្ត្រត្រីកោណរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី២ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាសម្រាប់នីតិកាលទី៣នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា។ តាមរយៈការបោះឆ្នោតនេះ បានបង្កើតឲ្យមាននូវប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅជាអង្គភាពអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ដែលទទួលបានសិទ្ធិអំណាចពីប្រជាពលរដ្ឋ មានការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋាន និងមានគណនេយ្យភាពជាបឋមចំពោះមូលដ្ឋាន។

ការបង្កើតឡើងនូវក្រុមប្រឹក្សានៃ រដ្ឋបាលថ្នាក់ក្រោមជាតិបាននាំយកដំណើរការប្រជាធិបតេយ្យ និង ការធ្វើសេចក្តីសម្រេចចិត្តដោយមានការចូលរួមទៅឲ្យរដ្ឋបាលថ្នាក់ជាតិ ដោយប្រជាពលរដ្ឋមានសិទ្ធិចូលរួមដោយផ្ទាល់ឬតាមរយៈអ្នកតំណាង នៅក្នុងកិច្ចការរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះការដាក់ឲ្យដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ និងបានជំរុញឲ្យមានការបង្កើតស្ថាប័នប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ដោយបានធានាដល់ការរួមចំណែកអភិវឌ្ឍន៍មូលដ្ឋានតាមគោលការណ៍នៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ការលើកកម្ពស់គុណភាពសេវាសាធារណៈ ការចូលរួមធនធានធម្មជាតិនិងបរិស្ថានការបង្កើនសុខមាលភាពរបស់ប្រជាពលរដ្ឋ និង ការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន នាំទៅដល់ការកាត់បន្ថយភាពក្រីក្រ។ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជាមកទល់ពេលនេះ គឺជាការផ្លាស់ប្តូរដ៏ជ្រាលជ្រៅនៅក្នុងរដ្ឋបាល-សាធារណៈនៅកម្ពុជា និងមានទិសដៅទូលំទូលាយចំនួនបីគឺ **ទីមួយ**-ការពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ-សេរីពហុបក្ស។ **ទីពីរ**-ការលើកកម្ពស់ការចូលរួម និងភាពជាម្ចាស់របស់មូលដ្ឋាន និង**ទីបី**-ការរួមចំណែកក្នុងការអនុវត្តន៍គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការ កាត់បន្ថយភាព ក្រីក្ររបស់ប្រជាពលរដ្ឋ។ ឃើញថា ទិសដៅទាំងនេះបានឆ្លើយតបយ៉ាងពេញទំហឹងទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលកំណត់ថា "**រាជរដ្ឋាភិបាលកម្ពុជា បានបន្តជំរុញអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការដាក់ចេញនូវវិធានការថ្មីថែមទៀត ដើម្បីអនុវត្តឲ្យមានប្រសិទ្ធិភាពនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជ ធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រង ឃុំ/សង្កាត់ ជាពិសេសបានរៀបចំ និងអនុវត្តលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិ មករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់ឲ្យបាន ច្បាស់លាស់នូវតួនាទី សិទ្ធិអំណាចនិងការធានាគណនេយ្យភាពក្នុងការបំពេញការងារ**"។ លើសពីនេះ រដ្ឋាភិបាលបានពង្រឹង និងលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ដើម្បីប្រែក្លាយជាអ្នកសាព័ត៌មាន ទាំងនេះឲ្យ

កាន់តែមានសកម្មភាពរស់រវើកក្នុងការផ្តល់ព័ត៌មាន ប្រកបដោយវិជ្ជាជីវៈ សច្ចភាព ប្រសិទ្ធិភាពនិងតម្លាភាព ជូនសង្គមជាតិ។

ទោះជាមានកិច្ចប្រឹងប្រែងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល លើសិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋ សិទ្ធិមនុស្ស គុណភាពខាងសារព័ត៌មាន សិទ្ធិសេរីភាពខាងសម្តែងមតិតាមទីសាធារណៈ ដែលជាតម្លៃដាច់ខាតនៃមូលដ្ឋានគ្រឹះនៃសរសរស្តម្ភប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ឃើញថា សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិសេរីភាពខាងនយោបាយ ត្រូវបានរដ្ឋាភិបាលដ៏មានអំណាចកម្រិតដដែល ហើយក៏អាចក្លាយជាចំណុចងាយប្រែក្លាយទៅជារបបផ្តាច់ការជាមិនខាន។ រីឯរដ្ឋសភា និងតុលាការក៏ពុំមានអំណាចឯករាជ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនឡើយ។ សម្រេចសេចក្តីដោយភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួន ហើយចៅក្រម និងព្រះរាជអាជ្ញាភាគច្រើនជាមន្ត្រីជាន់ខ្ពស់របស់គណបក្សនយោបាយកាន់អំណាច។ ក្រមព្រហ្មទណ្ឌថ្មីមិនទាន់ស្របតាមកម្រិតនៃការរឹតត្បិត ដែលអាចអនុញ្ញាតឲ្យធ្វើបានលើសិទ្ធិសេរីភាពនៃការបញ្ចេញមតិដូចមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦នៅឡើយ។ បុគ្គលសាធារណៈនានាពុំទាន់ត្រៀមខ្លួនឡើយ ហើយបែរមកប្រើប្រាស់តុលាការដើម្បីបំបិទមាត់ការរិះគន់។ ឯបទបរិហាកេរ្តិ៍ និងបទផ្សាយព័ត៌មានមិនពិតនៅតែចាត់ចូលជាបទល្មើសព្រហ្មទណ្ឌទាំងស្រុង។ ពាក្យសន្តិសុខជាតិ និងពាក្យសណ្តាប់ធ្នាប់សាធារណៈ ពុំទាន់បានបកស្រាយឲ្យស្របតាមកាតព្វកិច្ចនានាក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅឡើយ។ ដោយឡែកទស្សនទាននៃការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈក៏មិនទាន់បានឯកភាព និងផ្តល់និយមន័យឲ្យបានច្បាស់លាស់ដ៏ជាក់លាក់ និងចង្អៀតបំផុតដោយច្បាប់ដែរ ដែលកន្លងមកមានការបកស្រាយតាមឆន្ទានុសិទ្ធិដែលមានចរិតនយោបាយ និងតាមទំនើងចិត្តរបស់ចៅក្រម។

អវិជ្ជមានដែលបានរកឃើញទាំងប៉ុន្មានមិនមែនសុទ្ធតែកើតឡើងដោយសារអំណាចខ្លាំងរបស់រដ្ឋាភិបាលនោះទេ ផលអវិជ្ជាមានក៏អាចកើតឡើងដោយសារអង្គការក្រៅរដ្ឋាភិបាល និងគណបក្សប្រឆាំងផងដែរ។ ដូចជាសម្ពាធអង្គការក្រៅរដ្ឋាភិបាល និងគណបក្សប្រឆាំងទៅលើរដ្ឋាភិបាល បានបង្ហាញពីភាពជាដៃគូផង និងបដិកម្មដាក់គ្នាផង។ នៅក្នុងទម្រង់ដឹកនាំតាមលំនាំអំណាចបែបទំនៀមទម្លាប់ប្រពៃណីខ្មែរ កាលណាការប្រឆាំងកាន់តែខ្លាំង នោះភាពផ្តាច់ការអំណាចក៏កាន់តែខ្លាំងដែរ នេះជាក្រិត្យក្រមធម្មជាតិ។ តាមការសង្កេតមើលជាក់ស្តែងក្នុងដំណើរការប្រជាធិបតេយ្យនៅកម្ពុជាកន្លងមក ឃើញរបាយការណ៍ប្រជាធិបតេយ្យមានសន្ទុះខ្លាំងក្លាដែរ ប៉ុន្តែចលនានេះហាក់បីដូចជាបានបង្ហាញពីសេរីភាពបែបអនាធិបតេយ្យទៅវិញ។ ដូច្នេះ សិទ្ធិសេរីភាពពិតប្រាកដក្នុងបរិបទប្រជាធិបតេយ្យត្រឹមត្រូវ គឺជាការប្រឆាំងរិះគន់ស្ថាបនា សង្គ្រោះរដ្ឋ ឬជួយព្យាបាលជម្ងឺរបស់រដ្ឋ ប្រឆាំងបែបសីលធម៌និយម។ មិនមែនជាការប្រឆាំងដើម្បីប្រឆាំង ឬប្រឆាំងមានចរិតស្អប់ខ្ពើម រើសអើងនោះទេ ការដាក់ផ្តត់គំនិតបំពាក់មនោគមន៍វិជ្ជាបែបនេះ គឺជាទង្វើនាំទៅដល់ការបង្អាក់ដំណើរការកសាងលទ្ធិប្រជាធិបតេយ្យ ហើយក៏រុញច្រានរបបដឹកនាំមួយក្លាយជារបបសមស្តនិយមនិយមទៅវិញ។

ថ្វីត្បិតតែរដ្ឋាភិបាលពិតជាមានអំណាចដ៏លើសលប់លើស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលាការ ដែលជាទម្រង់ដឹកនាំងាកចេញពីគោលការណ៍ប្រជាធិបតេយ្យខ្លះៗពិតមែនក្តី ប៉ុន្តែអាចនិយាយបានថា បើផ្អែកតាមទីតាំងភូមិសាស្ត្រនយោបាយ ចិត្តសាស្ត្រសង្គម កម្រិតយល់ដឹងពីប្រជាធិបតេយ្យ ចំពោះសិទ្ធិសេរីភាព និងអំណាចរបស់ខ្លួន កម្រិតរីកចម្រើនខាងសេដ្ឋកិច្ច កម្រិតសីលធម៌រស់នៅ និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋជាពិសេសអន្តរកាលនៃផ្នត់គំនិតនយោបាយប្រជាធិបតេយ្យរបស់អ្នកនយោបាយ គឺសមស្រប និងចាំបាច់បំផុតដែលរដ្ឋាភិបាលចាំបាច់ប្រើចក្ខុវិស័យចាក់ជ្រៅក្នុងការច្បាមយកអំណាច ដើម្បីកែច្នៃសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងចរន្តប្រជាធិបតេយ្យនៅកម្ពុជាក្នុងគោលដៅការពារសុខសន្តិភាព ការផ្សះផ្សាជាតិ ដែលមានអាយុកាលក្មេងខ្ចីនៅឡើយ ដោយអប់រំដាំបណ្តុះ កែលំអអំពីទ្រឹស្តីប្រជាធិបតេយ្យ សិទ្ធិសេរីភាព និងអំណាចរបស់ប្រជាពលរដ្ឋឲ្យចំទិសដៅស្របទៅតាមកម្រិតលូតលាស់ និងស្ថានភាពជាក់ស្តែងពិតប្រាកដក្នុងសង្គមជាតិ។ សំដៅដល់ការកែទម្រង់ប្រព័ន្ធដឹកនាំ ដែលធានាដល់និរន្តរភាពនៃការប្រព្រឹត្តទៅរបស់រដ្ឋប្រជាធិបតេយ្យ។

ការវិភាគទៅលើមាត្រានៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣-១៩៩៩ ដែលជាប់ទាក់ទងទៅនឹង សិទ្ធិសេរីភាពប្រជាពលរដ្ឋ ឥទ្ធិពលនីតិប្រតិបត្តិ តុលាការ រដ្ឋសភា ដែលបានរកឃើញនូវបុព្វហេតុចន្លោះប្រហោង ដោយផ្តល់ផលវិជ្ជមានខ្លះ ដែលជាស្មារតីក្នុងការចូលរួមកែលំអច្បាប់កំពូល។ តាមការបញ្ជាក់ក្នុងនិក្ខេបទ បានឆ្លុះបញ្ចាំងពីទំហំនៃការផ្លាស់ប្តូរក្នុងសង្គមរបស់អ្នកដឹកនាំខ្មែរជំនាន់មុនៗ មានចរិតជាបដិវត្តន៍ជ្រុលនិយម។ ដែលផ្ទុយស្រឡះពីអ្នកកំណែទម្រង់មានលក្ខណៈសន្សឹមៗ ទៅតាមសមត្ថភាពរីកចម្រើនរបស់សង្គមនិងចង្វាក់នយោបាយ។ ចរិតនេះបញ្ជាក់កាន់តែច្បាស់ថា អំណាចកណ្តាលខ្មែរមានមាឌរឹងមាំខ្លាំងណាស់ ទើបអំណាចត្រាញ់នៅតាមតំបន់នានា ឬគណបក្សប្រឆាំងពុំមានសមត្ថភាពផ្លាស់ប្តូរបាន។

ការដឹកនាំ ការប្រកួតប្រជែងអំណាចនយោបាយ តាមវប្បធម៌ប្រជាធិបតេយ្យសេរីពហុបក្សចាំបាច់ត្រូវបង្កើតយន្តការសនិទានមួយច្របាច់បញ្ចូលគ្នាជាមួយប្រពៃណី ទំនៀមទម្លាប់និងព្រះពុទ្ធសាសនា។ ព្រោះថាទ្រឹស្តីព្រះពុទ្ធសាសនាមានតួនាទីបង្រួបបង្រួមបុគ្គលឲ្យមានភាពជិតស្និតនិងរស់នៅដោយសុខដុមរមនាជាមួយគ្នា។ដូច្នេះ ដើម្បីទប់ទល់នឹងការវិវាទប្រេះស្រាំក្នុងសង្គមខ្មែរ ពុទ្ធសាសនាចាំបាច់បង្កើតប្រសិទ្ធិភាពរបស់ខ្លួនបន្ថែម ទៀតក្នុងកែទម្រង់ជ្រុលខ្លះៗ នៃរដ្ឋបាលដឹកនាំក្នុងរចនាសម្ព័ន្ធគ្រប់គ្រងសាសនាឲ្យត្រឹមត្រូវតាមទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ខ្មែរ។

ដូច្នេះ អាចសង្ឃឹមបានថាៈ ការសិក្សាពីរបាយអំណាចក្នុងរបបប្រជាធិបតេយ្យ គឺជាធាតុផ្សំដ៏ចាំបាច់ដើម្បីចូលរួមចំណែកក្នុងការបណ្តុះស្មារតី ជម្រុញលើកទឹកចិត្តប្រជាពលរដ្ឋផង និងចូលរួមកែទម្រង់ប្រព័ន្ធក្បាលម៉ាស៊ីនដឹកនាំស្ថាប័នកំពូលៗរបស់ជាតិឲ្យមានតុល្យភាពនីយកម្មក្នុងសង្គមខ្មែរផងដែរ។

## ៥.២ អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទ "**សិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យនៅ**

**កម្ពុជា"** កន្លងមក ឃើញមានចំណុចចន្លោះប្រហោងមួយចំនួន ដែលខ្ញុំបាទចាំបាច់ផ្តល់អនុសាសន៍ក្នុងទិសដៅ ដើម្បីចូលរួមចំណែកកែលំអ ឲ្យមានតម្លៃសកលភាពនៃការគោរពសិទ្ធិសេរីភាពប្រជាពលរដ្ឋ តាមលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ឲ្យរស់រវើកអមដោយសីលធម៌តាមកាលានុវត្តភាពថ្មី តែការវិវត្តជាសកលស្តីពីលទ្ធិប្រជាធិបតេយ្យដូចតទៅៈ

**១-ចំពោះប្រជាពលរដ្ឋ**

បន្តចូលរួមរក្សាឲ្យបាននូវសន្តិសុខសង្គម ស្ថេរភាពសង្គម ស្ថេរភាពនយោបាយ និងឯកភាពជាតិ ដែលកើតចេញពីការអនុវត្តន៍ប្រជាធិបតេយ្យឲ្យកាន់តែរីកចម្រើនដុះដាលថែមទៀត និងកែប្រែផ្នត់គំនិតរបស់ខ្លួនតាមបែបប្រជាធិបតេយ្យនិយម និងពហុនិយម។ ប្រជាពលរដ្ឋខ្មែរចាំបាច់បន្តប្រកាន់សេចក្តីព្យាយាមអំណត់អត់ធ្មត់ ក្លាហាន តស៊ូទាមទារនូវសិទ្ធិសេរីភាព និងអំណាចរបស់ខ្លួនដោយមធ្យោបាយសន្តិវិធី និយមសេចក្តីថ្លៃថ្នូរបន្តទៅទៀត ដើម្បីពង្រឹងពង្រីកប្រជាធិបតេយ្យឲ្យមានជីវិតអមតៈនៅកម្ពុជា។

**២-ចំពោះរដ្ឋសភា**

- រដ្ឋសភាគួរពង្រឹងអំណាចរបស់ខ្លួនដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីការពារផលប្រយោជន៍ម្ចាស់ឆ្នោតម្ចាស់អំណាច។

- រដ្ឋសភាគួរគប្បីអនុម័តច្បាប់ស្តីពីការដាក់ឲ្យថ្នាក់ដឹកនាំ និងមន្ត្រីជម្រះសេចក្តីនៅតាមតុលាការគ្រប់កម្រិតស្ថិតឲ្យនៅជាអព្យាក្រិត្យ និងឯករាជ្យពីនយោបាយ។

- រដ្ឋសភាគប្បីអនុម័តច្បាប់កំណត់អាណត្តិឈរឈ្មោះបេក្ខជនជាតំណាងរាស្ត្រ យ៉ាងយូរត្រឹម២អាណត្តិ (១០ឆ្នាំ) និងគួរបញ្ញត្តិអំពីសមត្ថភាពរបស់បេក្ខជនតំណាងរាស្ត្រយ៉ាងតិចបញ្ចប់កម្រិតបណ្តុះបណ្តាលឧត្តមសិក្សាឡើងទៅ។

**៣-ចំពោះរដ្ឋាភិបាល**

- រដ្ឋាភិបាលគួរការពារឲ្យបានការសម្រេចចិត្តនានាតាមគោលការណ៍ប្រជាធិបតេយ្យខំប្រឹងប្រែងឲ្យអស់លទ្ធភាព ដើម្បីរាំងខ្ទប់ការវិលត្រឡប់មកវិញនូវរបបផ្តាច់ការ អាជ្ញានិយម ដែលធ្លាប់មាននៅក្នុងអតីតកាល។

- គប្បីបន្តការលុបបំបាត់កុំឲ្យមានការគុំគួន ប្រកាន់បក្សពួក លាបពណ៌និន្នាការនយោបាយ និងចាំបាច់ប្រកាន់ជំហរពង្រីកវប្បធម៌ សន្តិភាព សាមគ្គីស្មោះស្ម័គ្រ និងប្រមូលកម្លាំងជាតិឲ្យរឹងមាំ ដើម្បីអភិវឌ្ឍន៍សង្គមជាតិ។

**៤-ចំពោះអង្គការសង្គមស៊ីវិល**

- គួរបន្តការអត់ធ្មត់ធ្វើជាដៃគូរដ៏ល្អសម្រាប់សហប្រតិបត្តិការជាមួយស្ថាប័នជាតិកំពូលៗ និង អាជ្ញាធរពាក់ព័ន្ធ ដើម្បីជាំបណ្តុះសិទ្ធិមនុស្ស សិទ្ធិនយោបាយ ប្រជាធិបតេយ្យ ពលរដ្ឋវិជ្ជា និងដើម្បីប្រជាជនកម្ពុជាយល់ច្បាស់ថែមទៀតអំពីកាតព្វកិច្ច និងតួនាទីប្រជាពលរដ្ឋក្នុងបរិបទប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជានិងជាពិសេសគួរពង្រីកសកម្មភាពរបស់ខ្លួននៅតាមតំបន់ដាច់ស្រយាលតាមដែលអាចធ្វើទៅបាន។

**សំណូមពរ**

សូមសំណូមពរដល់អ្នកស្រាវជ្រាវក្រោយទៀត លើកយកប្រធានបទនេះមកសិក្សាបន្ត ដើម្បីឲ្យស្នាដៃនេះកាន់តែមានសុក្រឹត្យភាព ថែមទាំងតាមដំណើរការវិវត្តន៍របស់សង្គម និងការវិវត្តន៍ប្រជាធិបតេយ្យក្នុងសង្គមខ្មែរយើង។

# គន្ថនិទ្ទេស

## ក. ឯកសារជាសារព័ត៌មាន

១- កាសែតរស្មីកម្ពុជា ។

២- កាសែតកោះសន្តិភាព។

៣- កាសែតកម្ពុជាថ្មី ។

៤- កាសែតឌឺ មេបូឌៀដេលី ។

៥- កាសែតមនសិការខ្មែរ។

៦- កាសែតខ្មែរម្ចាស់ស្រុក។

## ខ. ឯកសារជារបាយការណ៍

៧- ក្រសួងយុត្តិធម៌ៈ របាយការណ៍ បូកសរុបលទ្ធផលការងារយុត្តិធម៌ប្រចាំឆ្នាំ២០០៥ ។

៨- ក្រសួងយុត្តិធម៌ៈ របាយការណ៍ បូកសរុបលទ្ធផលការងារយុត្តិធម៌ប្រចាំឆ្នាំ២០០៦ ។

៩- ក្រសួងយុត្តិធម៌ៈ របាយការណ៍ បូកសរុបលទ្ធផលការងារយុត្តិធម៌ប្រចាំឆ្នាំ២០០៧ ។

១០- ក្រសួងយុត្តិធម៌ៈ របាយការណ៍ បូកសរុបលទ្ធផលការងារយុត្តិធម៌ប្រចាំឆ្នាំ២០០៨ ។

១១- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិសេដ្ឋកិច្ច និងសង្គម ភ្នំពេញ ២០០៥ ។

១២- ស្ថានភាពសិទ្ធិមនុស្ស របស់សមាគមអាដហុក និងអភិវឌ្ឍនៅកម្ពុជាឆ្នាំ២០០៤ ។

១៣- ស្ថានភាពសិទ្ធិមនុស្ស របស់សមាគមអាដហុក និងអភិវឌ្ឍនៅកម្ពុជាឆ្នាំ២០០៥ ។

១៤- ស្ថានភាពសិទ្ធិមនុស្ស របស់សមាគមអាដហុក និងអភិវឌ្ឍនៅកម្ពុជាឆ្នាំ២០០៦ ។

១៥- ស្ថានភាពសិទ្ធិមនុស្ស របស់សមាគមអាដហុក និងអភិវឌ្ឍនៅកម្ពុជាឆ្នាំ២០០៧ ។

១៦- ស្ថានភាពសិទ្ធិមនុស្ស របស់សមាគមអាដហុក និងអភិវឌ្ឍនៅកម្ពុជាឆ្នាំ២០០៨ ។

១៧- ស្ថានភាពសិទ្ធិមនុស្ស របស់សមាគមអាដហុក និងអភិវឌ្ឍនៅកម្ពុជាឆ្នាំ២០០៩ ។

១៨- របាយការណ៍របស់សមាគម ADHOC ចេញផ្សាយខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីករណីរំលោភសិទ្ធិដីធ្លី របស់ប្រជាពលរដ្ឋ ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។

១៩- របាយការណ៍អង្កេតទី៨ របស់ខុមហ្វ្រែល ចេញផ្សាយថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ ។

២០- ស៊ីស៊ីអេចអ(CCHR) របាយការណ៍ស្តីអំពី ការរំលោភសិទ្ធិពលរដ្ឋ និងនយោបាយក្នុងរយៈពេលបោះឆ្នោតឆ្នាំ២០០៣ ។

២១- អង្គការសហប្រជាជាតិ គណៈកម្មការសិទ្ធិមនុស្សសម័យប្រជុំលើកទី៥៩ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០២ ។

២២- អង្គការសហប្រជាជាតិមហាសន្និបាទស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៥។

២៣- រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ជាតិស្តីពីការអនុវត្តន៍អនុសញ្ញានៃការលុបបំបាត់ការរើសអើងពូជសាសន៍ ។

២៤- សិទ្ធិបញ្ចេញមតិដោយសេរី អំពើហិង្សានៅតំបន់អាស៊ីអាគ្នេយ៍ ឆ្នាំ២០០៦ ភ្នំពេញ ២០០១ ។

## គ. ឯកសារជាព្រឹត្តិបត្រ

២៥- សមាគមអាដហុក(សៀវភៅតូចគ្មានកាលបរិច្ឆេទ) ។

២៦- សមាគមអាដហុក ឆ្នាំទី៨ លេខ១៩៤ ភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០១ ។

២៧- ព្រឹត្តិបត្រក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ភ្នំពេញ ឆ្នាំទី២ លេខ០៣ ខែមេសា-មិថុនា ឆ្នាំ២០០២។

២៨- ព្រឹត្តិបត្រក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ភ្នំពេញ ឆ្នាំទី៣ លេខ០៣ ខែកក្កដា-កញ្ញា ឆ្នាំ២០០២។

២៩- ព្រឹត្តិបត្រក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ភ្នំពេញ ឆ្នាំទី៣ លេខ០៣ ខែកក្កដា-កញ្ញា ឆ្នាំ២០០៣។

៣០- ព្រឹត្តិបត្រក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ភ្នំពេញ ឆ្នាំទី៣ លេខ០៩ ខែតុលា-ធ្នូ ឆ្នាំ២០០៣។

៣១- ព្រឹត្តិបត្រក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ភ្នំពេញ ឆ្នាំទី៥ លេខ១៧ ខែតុលា-ធ្នូ ឆ្នាំ២០០៥។

៣២- ព្រឹត្តិបត្រ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់លេខ៥ ភ្នំពេញ ឆ្នាំ២០០១ ។

៣៣- សមាគមអាដហុក ឆ្នាំទី៨ លេខ១៩៤ ភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣ ។

៣៤- ក្រុមប្រឹក្សាយុវជនកម្ពុជា លទ្ធិប្រជាធិបតេយ្យក្នុងជីវភាពរស់នៅ ភ្នំពេញ ២០០៤ ។

៣៥- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ព្រឹត្តិបត្រអ្នកឃ្លាំមើលតុលាការលេខ០១ ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៤។

៣៦- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ព្រឹត្តិបត្រអ្នកឃ្លាំមើលតុលាការលេខ០៦ ភ្នំពេញ ខែមីនា ឆ្នាំ២០០៥ ។

៣៧- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ព្រឹត្តិបត្រអ្នកឃ្លាំមើលតុលាការលេខ០៣ ភ្នំពេញ ខែកញ្ញា ឆ្នាំ២០០៦។

៣៨- សមាគមអាដហុក ព្រឹត្តិបត្រ អ្នកជា ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០០៦ ។

៣៩- សមាគមអាដហុក ព្រឹត្តិបត្រ អ្នកជា ភ្នំពេញ ខែមេសា ឆ្នាំ២០០៦ ។

៤០- សមាគមអាដហុក ព្រឹត្តិបត្រ អ្នកជា ភ្នំពេញ លេខ៣០៣ ខែកក្កដា ឆ្នាំ២០០៨ ។

៤១- សមាគមអាដហុក ព្រឹត្តិបត្រ អ្នកជា ភ្នំពេញ លេខ៣០៤ ខែសីហា ឆ្នាំ២០០៨ ។

៤២- សមាគមអាដហុក ព្រឹត្តិបត្រ អ្នកជា ភ្នំពេញ លេខ៣០៥ ខែកញ្ញា ឆ្នាំ២០០៨ ។

៤៣- សមាគមអាដហុក ព្រឹត្តិបត្រ អ្នកជា ភ្នំពេញ លេខ៣០៦ ខែតុលា ឆ្នាំ២០០៨ ។

៤៤- ខុមហ្វ្រែល ព្រឹត្តិបត្រ អ្នកឃ្លាំមើល លេខ៣០ ចេញថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ ។

៤៥- ខុមហ្វ្រែល ព្រឹត្តិបត្រ អ្នកឃ្លាំមើល លេខ៣៥ ឆ្នាំទី១០ ចេញថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ។

៤៦- ខុមហ្វ្រែល ព្រឹត្តិបត្រ អ្នកឃ្លាំមើល លេខ៣៣ ឆ្នាំទី៩ ចេញថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ ។

## ឃ. ឯកសារ ច្បាប់ និងលិខិតបទដ្ឋាននានា

៤៧- កិច្ចសន្យាព្រមព្រៀង ស្តីពីដំណោះស្រាយរួមមួយនៃជម្លោះកម្ពុជា ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។

៤៨- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៤៧ ។

៤៩- រដ្ឋធម្មនុញ្ញ នៃសាធារណៈរដ្ឋខ្មែរ ឆ្នាំ១៩៧០ ។

៥០- រដ្ឋធម្មនុញ្ញ នៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ ។

៥១- រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា ឆ្នាំ១៩៨៥ ។

៥២- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

៥៣- បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាលឆ្នាំ១៩៩២ ។

៥៤- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: សេចក្តីថ្លែងការ--ណ៍ជាសកល អំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ២០០៨ ។

៥៥- កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ឆ្នាំ១៩៦៦ ។

៥៦- កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ១៩៦៦ ។

៥៧- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើមនុស្ស ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឆ្នាំ១៩៨៤ ។

៥៨- ច្បាប់ស្តីពីការបោះឆ្នោតតំណាងរាស្ត្រ ឆ្នាំ១៩៩៧ និងវិសោធនកម្មឆ្នាំ២០០២ ។

៥៩- ក្រសួងយុត្តិធម៌: កាតព្វកិច្ច មន្ត្រីរាជការស៊ីវិល ភ្នំពេញ ឆ្នាំ២០០៤ ។

៦០- ច្បាប់ស្តីពី បាតុកម្ម ភ្នំពេញ ឆ្នាំ១៩៩១ ។

## ខ. ឯកសារជាសៀវភៅ


៦១- សាយ បូរី: វិទ្យាសាស្ត្ររដ្ឋបាល ភ្នំពេញ ឆ្នាំ២០០៧ ។

៦២- សុខ ទូច: តួនាទីអង្គការសហប្រជាជាតិ ភ្នំពេញ ឆ្នាំ២០០៣ ។

៦៣- ខ្លូច ធីតា: មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជា ភ្នំពេញ ឆ្នាំ២០០៦ ។

៦៤- អ៊ឹង ជុនហួរ: ផ្លូវទៅរកសេរីភាព ភាគ១-២ ភ្នំពេញ ឆ្នាំ១៩៩៤ ។

៦៥- អ៊ឹង ជុនហួរ: សេរីភាព និងយុត្តិធម៌ ភ្នំពេញ ឆ្នាំ១៩៩៣ ។

៦៦- ក្រសួងយុត្តិធម៌: សិទ្ធិទទួលបានយុត្តិធម៌ដោយផ្តោតលើជនក្រីក្រ ស្ត្រី និងជនជាតិភាគតិច។

៦៧- កែវ សុគុន និង ថាច់ វ៉ាន់ថាត: អាទិទេពក្រុងអង្គរ(បោះពុម្ពលើកទី៨) ភ្នំពេញ ឆ្នាំ១៩៩៣ ។

៦៨- មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងអង្គការមូលនិធិអាស៊ី: ប្រជាធិបតេយ្យនៅកម្ពុជា ការអង្កេតអំពីអ្នកបោះឆ្នោតកម្ពុជា ។

៦៩- វិទ្យាស្ថានខ្មែរសម្រាប់លទ្ធិប្រជាធិបតេយ្យ: ប្រព័ន្ធបោះឆ្នោត និងការគ្រប់គ្រង ឆ្នាំ១៩៩៨ ។

៧០- សហព័ន្ធអន្តរសភា: ការបោះឆ្នោតសេរី និងយុត្តិធម៌ ឆ្នាំ១៩៩៣ ។

៧១- ខៀវ សំផន: ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់កម្ពុជាប្រជាធិបតេយ្យ ឆ្នាំ២០០៧ ។

៧២- សុខ គាង: វិទ្យាសាស្ត្រនយោបាយ ភ្នំពេញ ឆ្នាំ២០០២ ។

៧៣- វិទ្យាស្ថានខ្មែរសម្រាប់លទ្ធិប្រជាធិបតេយ្យ: ចំណេះដឹងទូទៅ ។

៧៤- វិទ្យាស្ថានខ្មែរសម្រាប់លទ្ធិប្រជាធិបតេយ្យ: សិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងវប្បធម៌សន្តិភាព ភ្នំពេញ ឆ្នាំ១៩៩៧ ។

៧៥- ឧត្តមគតិ អៀវ កើស ភ្នំពេញ ឆ្នាំ១៩៧១ ។

៧៦- ប៊ុណ ចន្ទម៉ុល: ចរិតខ្មែរ ភ្នំពេញ ឆ្នាំ១៩៧៣ ។

៧៧- ខៀវ ជុំ: បញ្ហាជីវិត ភ្នំពេញ ឆ្នាំ២០០៤ ។

៧៨- ខៀវ ជុំ: ប្រជាធិបតេយ្យចាស់ទុំ ភ្នំពេញ ឆ្នាំ១៩៧៣។

៧៩- រាជរដ្ឋាភិបាលកម្ពុជា: ផែនការសកម្មភាពអភិបាលកិច្ច ភ្នំពេញ ឆ្នាំ២០០១ ។

៨០- ឌួង រតនា: សិល្បៈនយោបាយ តែង ស៊ាវពីង ភ្នំពេញ ឆ្នាំ២០០៤ ។

៨១- ហ៊ុន សែន: បុរសខ្លាំងរបស់កម្ពុជា ឆ្នាំ១៩៩៩ ។

៨២- នួន សុធិមន្ត: សង្គ្រាមអាមេរិកនៅកម្ពុជា ភ្នំពេញ ឆ្នាំ២០០៥ ។

៨៣- ប៊ីន ស៊ាងលឹមៈ ពូជអ្នកចំបាំង ឆ្នាំ១៩៩១ ។

៨៤- ឈុន ណារ៉េតៈ ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ភ្នំពេញ ឆ្នាំ២០០៨ ។

៨៥- ឈុន ណារ៉េតៈ សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ ភ្នំពេញ ឆ្នាំ២០០៧ ។

៨៦- សុខ សុគ្គលៈ មហាទស្សនវិទូ និងទស្សនវិជ្ជាក្នុងលោក ភាគ១-២ ភ្នំពេញ ឆ្នាំ១៩៧១ ។

៨៧- សមាគមអាដហុកៈ សិទ្ធិមនុស្សតាមរយៈពុទ្ធសាសនា ភ្នំពេញ ឆ្នាំ១៩៩៩ ។

៨៨- សភាសហរដ្ឋអាមេរិកៈ សិទ្ធិរបស់ប្រជាពលរដ្ឋ(សេរីភាពបុគ្គល និងកម្រងសិទ្ធិមនុស្ស) ។

៨៩- ឈឹម ផលវុណៈ របបគ្រប់គ្រងរដ្ឋបែបប្រជាធិបតេយ្យពហុបក្ស វិទ្យាស្ថានពលរដ្ឋវិទ្យា ភ្នំពេញ ឆ្នាំ២០០៧ ។

៩០- លី គីមសុខៈ គំនិតនយោបាយ ។

៩១- ជិន សាបៈ ពីរបបផ្តាច់ការទៅប្រជាធិបតេយ្យ ភ្នំពេញ ឆ្នាំ២០០៣ ។

៩២- ការត្រួតពិនិត្យតាមដានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករតាមដានរួមគ្នារបស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ២០១០: ភ្នំពេញ ឆ្នាំ២០១០។

៩៣- អូន ព័ន្ធមុនរ័តៈ ប្រជាធិបតេយ្យនៅកម្ពុជា ទ្រឹស្តី និងតថភាព ភ្នំពេញ ឆ្នាំ១៩៩៥ វិទ្យាស្ថានសម្រាប់សហប្រតិបត្តិការ និងសន្តិភាព។

៩៤- ធយ យីហ៊ាងៈ ព្រឹត្តិបត្រ ប្រជាធិបតេយ្យ និងច្បាប់ "ឥទ្ធិពលនៃសារព័ត៌មានទៅលើចិត្តសាស្ត្រសង្គម" ភ្នំពេញ ខែកញ្ញា ឆ្នាំ១៩៩៩ ។

៩៥- យុត ឥន្ទសេរីៈ មន្ត្រីកម្មវិធីអភិបាលកិច្ច និងនយោបាយសាធារណៈ អង្គការមូលនិធិអាស៊ី "ការកើតឡើងនៃសង្គមស៊ីវិលកម្ពុជា" ឆ្នាំ២០០១ ។

៩៦- កៅ គឹមហួនៈ "ការកើតឡើងនៃសង្គមស៊ីវិលកម្ពុជា ការកលើកកម្ពស់សិទ្ធិមនុស្ស និងវឌ្ឍនភាព នៃលទ្ធិប្រជាធិបតេយ្យ" វិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការ និងសន្តិភាព ភ្នំពេញ ឆ្នាំ២០០១ ។

៩៧- ប៉ែន ជារេតៈ ឯកសារមេរៀនទី១ គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ឆ្នាំសិក្សា២០០២-២០០៣ ។

៩៨- សុក សំអឿនៈ ព្រឹត្តិបត្រ ប្រជាធិបតេយ្យ និងច្បាប់ស្តីពី សិទ្ធិមនុស្សតាមរយៈលទ្ធិប្រជាធិបតេយ្យ និងអធិបតេយ្យ ឆ្នាំ១៩៩៩ ។

៩៩- កៅ គឹមហួនៈ លទ្ធិប្រជាធិបតេយ្យ មូលដ្ឋាននៅកម្ពុជា ភ្នំពេញ ឆ្នាំ១៩៩៩ ។

១០០- កៅ គឹមហួនៈ "លទ្ធិប្រជាធិបតេយ្យមូលដ្ឋាននៅកម្ពុជា" វិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការ និងសន្តិភាព ឆ្នាំ២០០១ ។

១០១- សុទ្ធាវីៈ សម្រង់ចូលកាន់តំណែងប្រធានាធិបតីអាមេរិក ភ្នំពេញ ឆ្នាំ២០០២ ។
១០២- ទ្រឹស្តីប្រជាធិបតេយ្យនៅអាមេរិក ។
១០៣- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតៈ ក្រមសីលធម៌ សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ភ្នំពេញ ឆ្នាំ២០០៨ ។
១០៤- ណ័របើត ហ្វុន ហូម៉ាន់ៈ ការនាំឆ្ពោះទៅរកការអនុវត្តន៍ លទ្ធិប្រជាធិបតេយ្យ ភ្នំពេញ ឆ្នាំ២០០៤
១០៥- អង្គការវីជីលែនៈ អង្គការរក្សាការពារសិទ្ធិមនុស្សនៃកម្ពុជា ។
១០៦- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាៈ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិទ្យា ភ្នំពេញ ឆ្នាំ២០០០ ។
១០៧- រាជរដ្ឋាភិបាលកម្ពុជាៈ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ស្ថានភាពសិទ្ធិមនុស្សកម្ពុជា ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០១ ។
១០៨- រាជរដ្ឋាភិបាលកម្ពុជាៈ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ស្ថានភាពសិទ្ធិមនុស្សកម្ពុជា ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០២ និងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៦ ។
១០៩- រាជរដ្ឋាភិបាលកម្ពុជាៈ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ស្ថានភាពសិទ្ធិមនុស្សកម្ពុជា ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៧ ។
១១០- រាជរដ្ឋាភិបាលកម្ពុជាៈ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ស្ថានភាពសិទ្ធិមនុស្សកម្ពុជា ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ ។
១១១- រាជរដ្ឋាភិបាលកម្ពុជាៈ របាយការណ៍ស្តីពីការអនុវត្តន៍ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ភ្នំពេញ ឆ្នាំ១៩៩៨ ។
១១២- សិទ្ធិមនុស្សពិភពលោក ។
១១៣- គណៈកម្មការទី១ រដ្ឋសភា ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៧ ។
១១៤- គណៈកម្មការទី១ រដ្ឋសភា ស្ថានភាពសិទ្ធិមនុស្ស ឆ្នាំ២០០៨ ។

## ច. ឯកសារជាភាសារអង់គ្លេស

១១៥- Robert Pine and Edward Savage DEMOCRACY IN AMERICA 1993.
១១៦- British Democracy in Action.
១១៧- Thomas E. PATTERSON: The American Democracy Seventh Edition.
១១៨- Aristotle, Person to corrode society bestial intellect. Moscow -1972.

១១៩- Center for Human Rights United Nations at Geneva-1996.

១២០- Herald. Human Right-June 2005.

១២១- Office of the United Nations : Human Rights Terrorism and Counter-terrorism .

១២២- Geoffrey Robertson QC, Crime against Humanity 2002.

១២៣- Licadho , Universal Declaration on Human Rights 2001.

១២៤- NGOs statement to the 1999 Consultative Group meeting on Cambodia-Tokyo 1999.

១២៥- Raoul Wallemberge, Human Right and Economic Relations-2004.

១២៦- Horn by, A S: Oxford Advanced Learner's Dictionary of Current English by Sally Wehmeir Phonetics Editor Michael Ashby, China ,p.596.

១២៧- Auge Guillon, Hollier- larousse, Moreanetc, petit Larousse dictionaries imprimeries Larouse en France ,Paris 6, 1967,p.310.

១២៨- Uge Horn by. A S: Oxford Advances Lean's Dictionary of Current English by Sally Wehmeire , Phonetics Editor Michael Ashby , Paris, 2001,p.334.

១២៩- Jonathan Crowther "Oxford Advanced Leaner's Dictionary" Oxford University Press, CD. Dictionary

១៣០- Lewis Lipstz "American Democracy" St. Martin's Press, Inc., The United States of American, 1986, p.4-5

១៣១- Henri Benac: Hachette Dictionaries Des Synonym 1956-1982, Paris, p.234

១៣២- LacoutureJ.,MartinM.ALe Mal Cambodien.Paris1989,page 135

១៣៣- Spent of philosophy dictionary. Misk 1999 page 778

១៣៤- Pou.B.Etudes sun le Rama kerti,Paris,1974, page 45

## ឆ. គេហទំព័រផ្សេងៗ

១៣៥- www.gov.kh/khmer/2006/January/Report2005pdf.

១៣៦- www.bigpond.com.kh/users/adhokavout_adhoc.

១៣៧- www.rghttohedthcare.org/phi-b.htm.

១៣៨- www.ancienthistory.aboutcom/od/Socrates.

១៣៩- www.book.google.com/book/ieUTF-8&vidISBN902.

១៤០- http://cambodia.ohchr.org/index_kh.htm.

១៤១- http://khmer.cambodia.usembassy.gov/index.html.

១៤២- http://www.adhoc-chra.org/?language=khmer.

១៤៣- http://www.cchrcambodia.org/Khmer/index.php.

១៤៤- http://www.comfrel.org/khm/index.php.

១៤៥- http://www.rfa.org/khmer/kh_links-12122009054325.html.

១៤៦- www: tep.utm.edu/h/hobmarn; htmdattd.

១៤៧- www.interior.gov.kh.

# ឧបសម្ព័ន្ធទី ៥

**************

## បណ្តាគោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា

១-រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេស។ គេអាចធ្វើការកែប្រែរដ្ឋធម្មនុញ្ញនេះបាន លុះត្រាតែមានរបៀបរបបចាត់តាំងមួយ ទាក់ទងដល់ការយល់ព្រមពីអង្គការនីតិបញ្ញត្តិ ការធ្វើប្រជាមតិ ឬក៏ដោយវិធីទាំងពីរនេះតែម្តង ។

២-ប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មនៅកម្ពុជា ទាមទារឱ្យមានវិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្ស។ហេតុដូច្នេះ រដ្ឋធម្មនុញ្ញត្រូវរួមមានសេចក្តីថ្លែងការណ៍មួយអំពីសិទ្ធិជាមូលដ្ឋាន នៅក្នុងនោះមានសិទ្ធិក្នុងការមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿ សាសនា រួមប្រជុំគ្នានិងបង្កើតសមាគម រួមមានគណបក្សនយោបាយនិងសហជីព ដំណើរការតុលាការត្រឹមត្រូវ និងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំឱ្យមានការដកហូតកម្មសិទ្ធិដោយវិធីផ្តាច់ការ ឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជម្ងឺចិត្តដ៏ត្រឹមត្រូវ និងសេរីភាពដោយគ្មានការប្រកាន់ រើសអើងពូជសាសន៍ ជនជាតិ ជំនឿ សាសនាឬភេទឡើយ ។រដ្ឋធម្មនុញ្ញត្រូវហាមឃាត់នូវការអនុវត្តន៍ច្បាប់ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអតីតកាល។ សេចក្តីប្រកាសត្រូវសមស្របទៅនឹងប្រការទាំងឡាយនៃសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ។ បុគ្គល ដែលត្រូវរំលោភបំពាន មានសិទ្ធិប្តឹងទៅតុលាការដើម្បីកាត់សេចក្តី និងធ្វើឱ្យគេគោរពសិទ្ធិទាំងអស់នេះ។

៣- រដ្ឋធម្មនុញ្ញត្រូវប្រកាសអំពីលក្ខន្តិកៈប្រទេសកម្ពុជា ជារដ្ឋអធិបតេយ្យភាព ឯករាជ្យ និង អព្យាក្រឹតមួយនិង អំពីឯកភាពជាតិរបស់ប្រជាជនកម្ពុជា។

៤-រដ្ឋធម្មនុញ្ញត្រូវប្រកាសថា កម្ពុជានឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យសេរី ដោយឈរលើមូលដ្ឋានពហុបក្ស។ រដ្ឋធម្មនុញ្ញត្រូវកំណត់ឱ្យមានការបោះឆ្នោតដ៏ត្រឹមត្រូវ និងតាមកាលវេលា។

រដ្ឋធមនុញ្ញត្រូវអនុញ្ញាតសិទ្ធិសម្រាប់បោះឆ្នោតនិងឈរឈ្មោះឱ្យគេបោះឆ្នោតតាមរបៀបបោះឆ្នោតជាសកល និងស្មើភាព ។ រដ្ឋធមនុញ្ញត្រូវអនុញ្ញាតឱ្យមានការបោះឆ្នោតដោយសម្ងាត់ ដោយតម្រូវឱ្យមានទម្រង់បែបបទនៃការបោះឆ្នោត ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ និងសមរម្យដើម្បីរៀបចំ និងចូលរួមដំណើរការបោះឆ្នោត ។

៥- ត្រូវបង្កើតអង្គការតុលាការមួយឯករាជ្យ ដែលត្រូវមានអំណាចដាក់ឱ្យអនុវត្តនូវបណ្តាសិទ្ធិដែលមានចែងក្នុងរដ្ឋធមនុញ្ញ ។

៦- រដ្ឋធមនុញ្ញត្រូវអនុម័តដោយសម្លេងភាគច្រើន ពីរភាគបីនៃសមាជិកសភាធមនុញ្ញ ។

----------